HANDBOOK FOR PARLIAMENTARIANS No. 5 - 2003

# ការត្រួតពិនិត្យដោយសភា លើវិស័យសន្តិសុខ

## គោលការណ៍ យន្តការ និង ការអនុវត្ត




មជ្ឈមណ្ឌលហ្សឺណែវ
សម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធ
តាមបែបប្រជាធិបតេយ្យ

សហភាពអន្តរសភា

# បុព្វកថា

វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព (Cambodian Institute for Cooperation and Peace) មានសេចក្តីសោមនស្សរីករាយដែលបានចូលរួមបោះពុម្ព និងបកប្រែសៀវភៅ **ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខៈ គោលការណ៍ យន្តការ និង ការអនុវត្ត** (Parliamentary oversight of the security sector: Principles, mechanisms and practices) ជាភាសាខ្មែរ ក្រោមកិច្ចសហប្រតិបត្តិការរបស់ មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (Geneva Centre for Democratic Control of the Armed Forces) ។

វិទ្យាស្ថានយល់ឃើញថា សៀវភៅនេះមានខ្លឹមសារទូលំទូលាយ និងឆ្លុះបញ្ចាំងអំពីគោលការណ៍លំអិត និងយ៉ាងសំខាន់សម្រាប់ការត្រួតពិនិត្យវិស័យសន្តិសុខដោយសភា។ វិទ្យាស្ថានសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះ នឹងចូលរួមចំណែកលើកកម្ពស់វិស័យសន្តិសុខក្នុងប្រទេសកម្ពុជាឲ្យរឹងរិតតែមានប្រសិទ្ធភាពកើនឡើងថែមទៀត។

វិទ្យាស្ថានសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (Geneva Centre for Democratic Control of the Armed Forces) ដែលបានផ្តល់ការឧបត្ថម្ភក្នុងការងារបកប្រែ និងបោះពុម្ពសៀវភៅដ៏សំខាន់នេះ។ ជាពិសេសសូមថ្លែងអំណរគុណចំពោះ លោក លោកស្រី សហការីទាំងអស់ដែលធ្វើការនៅវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព និងលោក **ហាម សំណាង** ជាអ្នកបកប្រែអាជីព ដែលបានរួមចំណែកក្នុងការងារបកប្រែ និងបោះពុម្ពសៀវភៅ **ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខៈ គោលការណ៍ យន្តការ និង ការអនុវត្ត** នេះប្រកបដោយជោគជ័យ។

វិទ្យាស្ថានយល់ឃើញថា ការបកប្រែនេះ នៅមានការខ្វះខាតចំពោះអត្ថន័យដែលពុំបានគ្រប់ជ្រុងជ្រោយ។ អាស្រ័យហេតុនេះ វិទ្យាស្ថានសូមអភ័យទោសជាមុន ចំពោះការខ្វះចន្លោះដែលអាចកើតមានឡើងជាយថាហេតុក្នុងការបកប្រែនេះ។ ចំពោះអត្ថបទអេឡិចត្រូនិចនៃសៀវភៅនេះ លោកអ្នក មិត្តអ្នកអាន អាចទាញយកចេញបានតាមរយៈគេហទំព័រ www.cicp.org.kh។

ភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

**ពូ សុធីរៈ**

នាយកប្រតិបត្តិ វ.ខ.ស.ស

# ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ៖

## គោលការណ៍ យន្តការ និងការអនុវត្ត

"Vis consilii expers mole ruit sua"

(ការប្រើកម្លាំងដោយមិនមានការវិនិច្ឆ័យ វានឹងដួលរលំនៅក្រោមទម្ងន់របស់ខ្លួនវា)

Horace, Odes, 3, 4, 65

# បញ្ជីរាយនាមបុគ្គលដែលបានចូលរួមនៅក្នុង ការផលិតសៀវភៅ IPU-DCAF ស្តីពីការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ

## អ្នកកែសម្រួល៖

Hans Born (ប្រទេសហុល្លង់) Philipp Fluri (ប្រទេសស្វីស) និង Anders B.Johnsson (ប្រទេសស៊ុយអែត)

## អ្នកដឹកនាំនិពន្ធ

Hans Born (ប្រទេសហុល្លង់)

## អ្នករួមចំណែក

Alexey Arbatov (រុស្ស៊ី), Jean-Christophe Burkel (បារាំង), Eva Busza (អាមេរិក), Marina Caparini (កាណាដា), Umit Cizre (តួគី), David Darchiashvili (ចយចា), Jonah Isawa Elaigwu (នេហ្សេរីយ៉ា), Hans-Peter Furrer (ស្វីស), Denise Garcia (ប្រេស៊ីល), Suzana Gavrilescu (រ៉ូម៉ានី), Wilhelm Germann (អាល្លឺម៉ង់), Owen Greene (អង់គ្លេស), Miroslav Hadzic (សែប៊ី និងម៉ុងតេនេក្រូ), Karl Haltiner (ស្វីស), Heiner Hänggi (ស្វីស), David Hobbs (អង់គ្លេស), Jan Hoekema (ហុល្លង់), Rogier Huizenga (ហុល្លង់), Andrzej Karkoszka (ប៉ូឡូញ), Peter G. Kelly (អាមេរិក), Simon Lunn (អង់គ្លេស), Tom McDonald (អង់គ្លេស), Dorijan Marsic (ស្លូវ៉ានី), Gian Giacomo Migone (អ៊ីតាលី), Michael F. Noone (អាមេរិក), Aleksandr Pikayev (រុស្ស៊ី), Christine Pintat (បារាំង), Andreas Prüfert (អាល្លឺម៉ង់), Christopher Sabatini (អាមេរិក), Liliane Serban (រ៉ូម៉ានី), Ravinder Pal Singh (ឥណ្ឌា), Anders C. Sjaastad (ន័រវេ), Bauke Snoep (ហុល្លង់), Svitlana Svetova (អ៊ុយក្រែន), Jan Trapans (ឡាត់វី), Matias Tuler (អាហ្សង់ទីន), Marlene Urscheler (ស្វីស), Pentti Väänänen (ហ្វាំងឡង់), Biljana Vankovska (ម៉ាសេដូណា), Marie Vlachova (សាធារណៈរដ្ឋឆែក), Casper W. Vroom (ហុល្លង់), Tamas Wachsler (ហុងគ្រី), Donna Winslow (កាណាដា), Herbert Wulf (អាល្លឺម៉ង់)។

## គណៈកម្មការកែសម្រួល

Willem van Eekelen (ហុល្លង់), Andreas Gross (ស្វីស), Miroslav Filipovic (សែរប៊ី និង ម៉ុងតេនេក្រូ), Stepan Sulakshin (រុស្ស៊ី), Dimitro Tabachnik (អ៊ុយក្រែន), Ahmad Husni Hanadzlah (ម៉ាឡេស៊ី), Adeseye Ogunlewe (នីហ្សេរីយ៉ា) and Elissavet Papadimitriou (ក្រិក) - សមាជិកនៃគណៈកម្មាធិការ IPU ស្តីពីបញ្ហានយោបាយ សន្តិសុខអន្តរជាតិ និងការដកហូតអាវុធ និង Beth Mugo (កិនយ៉ា) និង Ricardo Vasquez (អាហ្សង់ទីន), សមាជិកនៃគណៈកម្មាធិការ IPU ស្តីពី សភា តុលាការ និងសិទ្ធិមនុស្ស។

## អ្នកកែសម្រួលភាសា

Oliver Wates (អង់គ្លេស)

**ច្បាប់ដើម៖** ភាសាអង់គ្លេស ទីក្រុងហ្សឺណែវ ឆ្នាំ ២០០៣។

# អារម្ភកថា

ដោយសារបញ្ហាសន្តិសុខ គឺជាបញ្ហាស្នូលនៃសុខុមាលភាពរបស់មនុស្ស វាមានសារៈសំខាន់ខ្លាំងណាស់ដែលថាបញ្ហាទាំងនេះ ត្រូវបញ្ចូលទៅក្នុងគោលនយោបាយសន្តិសុខរបស់ប្រទេសជាតិ។ គោលនយោបាយនោះត្រូវតែបញ្ចូលនូវខ្លឹមសារ និងគោលការណ៍សំខាន់ៗទាំងឡាយទាក់ទងនឹងសន្តិសុខដែលរដ្ឋមួយត្រូវលើកតម្កើង និងការពារ។

ដូច្នេះវាជាក់ច្បាស់ និងមានភាពចាំបាច់ខ្លាំងណាស់សម្រាប់តំណាងដែលត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសនៅក្នុងសភា ដើម្បីធ្វើការងារយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល និងវិស័យសន្តិសុខនេះ។ ក៏ប៉ុន្តែ ទោះបីជាតំណាងរាស្ត្រទាំងនោះខិតខំធ្វើការងារដើម្បីធ្វើឲ្យសម្រេចនូវគោលបំណងរួមនេះក៏ដោយ ក៏តួនាទីរបស់ពួកគេមានមិនដូចគ្នានោះទេ។ សភាមានការទទួលខុសត្រូវក្នុងការបង្កើតច្បាប់ អនុម័តថវិកា និងត្រួតពិនិត្យសកម្មភាពសន្តិសុខ។ សភាអាចអនុវត្តនូវទំនួលខុសត្រូវទាំងនេះបានយ៉ាងពេញលេញ ប្រសិនបើខ្លួនបានទទួលនូវព័ត៌មានទូលំទូលាយ ព្រមទាំងមានជំនាញបច្ចេកទេសដ៏ចាំបាច់ និងអំណាចពេញលេញ រួមទាំងមានបំណងធ្វើឲ្យរដ្ឋាភិបាលមានទំនួលខុសត្រូវផងនោះ។ ដើម្បីសម្រេចនូវគោលបំណងនេះ វាតម្រូវឲ្យមាននូវរចនាសម្ព័ន្ធសង្គមមួយដែលត្រូវបានពង្រឹងដោយការជឿទុកចិត្ត និងការសន្ទនាគ្នា។

នៅក្នុងប្រទេសឈីលី ទំនាក់ទំនងរវាងសង្គម និងកងកម្លាំងប្រដាប់អាវុធត្រូវបានកែលម្អជាហូរហែ។ បច្ចុប្បន្ននៅក្នុងប្រទេសឈីលី សហគមន៍អន្តរជាតិនឹងមើលឃើញនូវបរិយាកាសនៃការគោរពគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការ ដែលយើងសង្ឃឹមថាបរិយាកាសនេះនឹងត្រូវបានពង្រឹងឲ្យកាន់តែរឹងមាំថែមទៀតនៅក្នុងពេលអនាគត។ យើងមានទំនុកចិត្តថា សៀវភៅគោលនេះ នឹងជួយដល់តួអង្គសំខាន់ៗនៅក្នុងវិស័យសន្តិសុខ ក្នុងការចាត់ចែងកិច្ចសហប្រតិបត្តិការសម្រាប់ជាប្រយោជន៍រួម និងល្អប្រសើរដល់ប្រជាពលរដ្ឋគ្រប់ៗរូប។

Senador Sergio Páez Verdugo

ប្រធានក្រុមប្រឹក្សាសហភាពអន្តរសភា

# ការត្រួតពិនិត្យដោយសភា
# លើវិស័យសន្តិសុខ៖
## គោលការណ៍ យន្តការ និងការអនុវត្ត

"Vis consilii expers mole ruit sua"

(ការប្រើកម្លាំងដោយមិនមានការវិនិច្ឆ័យ វានឹងដួលរលំនៅក្រោមទម្ងន់របស់ខ្លួនវា)

Horace, Odes, 3, 4, 65

# បញ្ជីរាយនាមបុគ្គលដែលបានចូលរួមនៅក្នុង ការផលិតសៀវភៅ IPU-DCAF ស្តីពីការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ

## អ្នកកែសម្រួល៖

Hans Born (ប្រទេសហុល្លង់) Philipp Fluri (ប្រទេសស្វីស) និង Anders B.Johnsson (ប្រទេសស៊ុយអែត)

## អ្នកដឹកនាំនិពន្ធ

Hans Born (ប្រទេសហុល្លង់)

## អ្នករួមចំណែក

Alexey Arbatov (រុស្ស៊ី), Jean-Christophe Burkel (បារាំង), Eva Busza (អាមេរិក), Marina Caparini (កាណាដា), Umit Cizre (តួគី), David Darchiashvili (ចយចា), Jonah Isawa Elaigwu (នេហ្សេរីយ៉ា), Hans-Peter Furrer (ស្វីស), Denise Garcia (ប្រេស៊ីល), Suzana Gavrilescu (រ៉ូម៉ានី), Wilhelm Germann (អាល្លឺម៉ង់), Owen Greene (អង់គ្លេស), Miroslav Hadzic (ស៊ែប៊ី និងម៉ុងតេនេក្រូ), Karl Haltiner (ស្វីស), Heiner Hänggi (ស្វីស), David Hobbs (អង់គ្លេស), Jan Hoekema (ហុល្លង់), Rogier Huizenga (ហុល្លង់), Andrzej Karkoszka (ប៉ូឡូញ), Peter G. Kelly (អាមេរិក), Simon Lunn (អង់គ្លេស), Tom McDonald (អង់គ្លេស), Dorijan Marsic (ស្លូវ៉ានី), Gian Giacomo Migone (អ៊ីតាលី), Michael F. Noone (អាមេរិក), Aleksandr Pikayev (រុស្ស៊ី), Christine Pintat (បារាំង), Andreas Prüfert (អាល្លឺម៉ង់), Christopher Sabatini (អាមេរិក), Liliane Serban (រ៉ូម៉ានី), Ravinder Pal Singh (ឥណ្ឌា), Anders C. Sjaastad (ន័រវេ), Bauke Snoep (ហុល្លង់), Svitlana Svetova (អ៊ុយក្រែន), Jan Trapans (ឡាត់វី), Matias Tuler (អាហ្សង់ទីន), Marlene Urscheler (ស្វីស), Pentti Väänänen (ហ្វាំងឡង់), Biljana Vankovska (ម៉ាសេដូណា), Marie Vlachova (សាធារណៈរដ្ឋឆែក), Casper W. Vroom (ហុល្លង់), Tamas Wachsler (ហុងគ្រី), Donna Winslow (កាណាដា), Herbert Wulf (អាល្លឺម៉ង់)។

## គណៈកម្មការកែសម្រួល

Willem van Eekelen (ហុល្លង់), Andreas Gross (ស្វីស), Miroslav Filipovic (ស៊ែរបី និង ម៉ុងតេនេក្រូ), Stepan Sulakshin (រុស្ស៊ី), Dimitro Tabachnik (អ៊ុយក្រែន), Ahmad Husni Hanadzlah (ម៉ាឡេស៊ី), Adeseye Ogunlewe (នីហ្សេរីយ៉ា) and Elissavet Papadimitriou (ក្រិក) - សមាជិកនៃគណៈកម្មាធិការ IPU ស្តីពីបញ្ហានយោបាយ សន្តិសុខអន្តរជាតិ និងការដកហូតអាវុធ និង Beth Mugo (កិនយ៉ា) និង Ricardo Vasquez (អាហ្សង់ទីន), សមាជិកនៃគណៈកម្មាធិការ IPU ស្តីពី សភា តុលាការ និងសិទ្ធិមនុស្ស។

## អ្នកកែសម្រួលភាសា

Oliver Wates (អង់គ្លេស)

**ច្បាប់ដើម៖** ភាសាអង់គ្លេស ទីក្រុងហ្សឺណែវ ឆ្នាំ ២០០៣។

# សេចក្តីផ្តើម

ចាប់តាំងពីយូរលង់ណាស់មកហើយ បញ្ហាអធិបតេយ្យភាពជាតិ និងសន្តិសុខជាតិត្រូវបានចាត់ទុកថាជាបញ្ហាដ៏សំខាន់សម្រាប់រដ្ឋដែលសម្រេចបានស្ថិរភាព។ សព្វថ្ងៃនេះ តួនាទីរបស់អ្នកដែលបំពេញការងារជាអ្នកផ្តល់សេវាសន្តិសុខមានការផ្លាស់ប្តូរគួរអោយកត់សម្គាល់។ បែបផែនថ្មីៗនៃជម្លោះប្រដាប់អាវុធ និងការកើនឡើងនូវការចងសម្ព័ន្ធមិត្តរវាងរដ្ឋ និងរដ្ឋ បានជម្រុញឲ្យមានការឆ្លើយតប និងការគិតគូរប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់អំពីទស្សនទានគ្រឹះរបស់សន្តិសុខ។ ការវាយប្រហារនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ និងលទ្ធផលរបស់វាបានបញ្ជាក់អំពីភាពចាំបាច់នេះ។

ដូច្នេះ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដោយសភា កាន់តែមានសារៈសំខាន់ខ្លាំងឡើងដើម្បីធានាឲ្យមានការបង្កើត និងការអនុវត្តនូវការឆ្លើយតបថ្មីៗទាំងនេះដោយតម្លាភាព និងគណនេយ្យភាពពេញលេញ។ បើមិនមានការត្រួតពិនិត្យបែបនេះទេនោះ វានឹងមានគ្រោះថ្នាក់ចំពោះសេវាសន្តិសុខ និងការបកស្រាយខុសអំពីបេសកកម្មរបស់វា ដូចជារដ្ឋមួយក្នុងរដ្ឋមួយដាក់សម្ពាធដ៏ធ្ងន់ទៅលើធនធានដ៏ក្រខ្សត់ ឬឥទ្ធិពលផ្នែកនយោបាយ និងសេដ្ឋកិច្ច ដ៏លើសលុប។ វាអាចបន្ថយបង្អាក់ប្រជាធិបតេយ្យភាវូបនីយកម្ម ហើយវាក៏អាចបង្កជម្លោះអោយកើនថែមទៀតផង។ ខណៈពេលដែលសង្គមស្ថិតនៅក្នុងសម័យអន្តរកាល ត្រូវបានហែកហួរដោយសង្គ្រាម ឬជាសង្គមដែលមានវិបត្តិជួបប្រទះនូវហានិភ័យណាមួយ ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យដ៏រឹងមាំ ក៏ត្រូវពង្រឹងនូវទំនាក់ទំនងស៊ីវិល-យោធា ធ្វើការកែទម្រង់ និងគ្រប់គ្រងនូវទំនាក់ទំនងនេះដើម្បីរក្សាសន្តិភាពនៅក្នុងខណៈពេលដែលបញ្ហាសន្តិសុខមានការប្រែប្រួល។

លក្ខណៈពីធម្មជាតិ និងភាពប្រែប្រួលជានិច្ចនៃវិស័យសន្តិសុខ គឺជាការប្រឈមដ៏ពិតប្រាកដមួយចំពោះសភាក្នុងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ ភាពខុសគ្នាផ្នែកបច្ចេកទេសដ៏ច្រើនសន្ធឹកសន្ធាប់ ភាពស្មុគ្រស្មាញនៃអង្គការបុគ្គលិកសន្តិសុខ ព្រមទាំងច្បាប់វិធានទាក់ទងនឹងព័ត៌មានសម្ងាត់ និងការអនុវត្តការសម្ងាត់ទាំងអស់នេះ វាធ្វើឲ្យសមាជិកសភាមានការលំបាកដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព លើកលែងតែពួកគេអាចប្រើប្រាស់នូវការស្រាវជ្រាវដ៏ឯករាជ្យនិងជំនាញ។ ក្នុងគោលបំណងនេះហើយ ទើបសហភាពអន្តរសភា (IPU) និងមជ្ឈមណ្ឌលទីក្រុងហ្សឺណែវសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (DCAF) បានព្រមព្រៀងគ្នាតាមតម្រូវការជាក់ស្តែង រៀបចំតាក់តែងនូវសៀវភៅមគ្គុទេសក៏ដែលផ្អែកទៅលើការអនុវត្តជាក់ស្តែងភាពប្រាកដនិយម និងភាពងាយប្រើប្រាស់មួយដែលពន្យល់អំពីការអនុវត្តដ៏គ្រប់ជ្រុងជ្រោយ និងយន្តការនានាដែលអាចជួយសភាក្នុងការរួមចំណែកដល់ការត្រួតពិនិត្យវិស័យសន្តិសុខ។ សៀវភៅគោលនេះ គឺជាប្រទីបឆ្លុះបញ្ចាំងនូវគំនិតរៀបរាប់នេះ។ ក្នុងអំឡុងពេលរៀបចំជាសេចក្តីព្រាងអត្ថបទនៅក្នុងសៀវភៅគោលនេះត្រូវបានពិនិត្យពិច័យ និងសម្រិតសម្រាំងដោយគណៈកម្មការសភាទទួលបន្ទុកការងារកែសម្រួល និងត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញមួយចំនួន។

សៀវភៅនេះ ត្រូវបានសរសេរដោយផ្អែកលើសេចក្តីសន្និដ្ឋានថា គ្មានគំរូរួមណាមួយសម្រាប់យកទៅប្រើប្រាស់សម្រាប់ការត្រួតពិនិត្យដោយសភា សម្រាប់គ្រប់ប្រទេសទាំងអស់នោះទេ។ វិធាន និងការអនុវត្តដែលអាចទទួលយកមកអនុវត្ត និងមានប្រសិទ្ធភាពនៅកន្លែងមួយ វាអាចមិនសក្តិសមជាមួយកន្លែងមួយផ្សេងទៀត។ លើសពីនេះ រាល់សភាទាំងអស់មិនមានអំណាចដូចៗគ្នានោះទេ។ ដោយសារមូលហេតុដូច្នេះហើយ ទើបសំណើខ្លះនៅក្នុងសៀវភៅគោលនេះ ចៀសមិនផុតពីការលើកឡើងនូវឧត្តមគតិខ្ពស់ហួសហេតុពេក។ ទន្ទឹមនឹងនោះ លក្ខណៈស្មុគ្រស្មាញនៃបញ្ហាសន្តិសុខរារាំងការអនុវត្តដូចៗគ្នានៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃបញ្ហាសន្តិសុខ។ ដូច្នេះ គេគួរចាត់ទុកសៀវភៅគោលនេះថា ជាសៀវភៅណែនាំដែលមានលក្ខណៈទូលំទូលាយមួយ ក្នុងការជួយពង្រឹងការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ ដែលយើងសង្ឃឹមថា វានឹងលើកទឹកចិត្តអ្នកអានឲ្យធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត។ ជាចុងក្រោយ យើងសង្ឃឹមថាការបោះពុម្ពផ្សាយសៀវភៅគោលនេះនឹងរួមចំណែកធានាឲ្យគោលនយោបាយសន្តិសុខ និងការអនុវត្តឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋពិតប្រាកដ៕



Anders B. Johnsson
អគ្គលេខាធិការ សហភាពអន្តរសភា



ឯកអគ្គរាជទូត បណ្ឌិត Theodor H. Winkler
នាយកមជ្ឈមណ្ឌលហ្សឺណែវសម្រាប់
ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធ
តាមបែបប្រជាធិបតេយ្យ

# អ្វីខ្លះដែលអ្នកអាចរកឃើញក្នុងសៀវភៅនេះ

សៀវភៅគោលនេះ ចែកចេញជា ៨ផ្នែក ដែលផ្នែកនីមួយៗមានជំពូកមួយចំនួន ហើយអ្នកអាន អាចអានជា ២របៀបខុសៗគ្នា។ ការអានចប់ចុងចប់ដើមនៃសៀវភៅនេះ នឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះបំផុតអំពីបញ្ហាសន្តិសុខ និងតួនាទីរបស់សភាក្នុងការត្រួតពិនិត្យលើវិស័យសន្តិសុខ។ ទោះជាយ៉ាងណាក្តី អ្នកអានក៏អាចជ្រើសរើសអាននូវផ្នែក និងជំពូកមួយចំនួនដែលខ្លួនចាប់អារម្មណ៍បំផុត។ យើងបានរៀបចំនូវសន្ទស្សន៍ និងលំដាប់លំដោយនៃផ្នែក ឬជំពូកសម្រាប់ជួយដល់ការជ្រើសរើសរបស់អ្នកអាន។

នៅក្នុងសៀវភៅគោលនេះ មានប្រអប់មួយចំនួនដែលពន្យល់អំពីបញ្ហាដ៏ស្មុគ្រស្មាញ ដែលបានលើកឡើងនៅក្នុងអត្ថបទមេ ដោយមានភ្ជាប់នូវឧទាហរណ៍អំពីច្បាប់ ឬបទដ្ឋានគតិយុត្ត និងបង្ហាញអំពីការអនុវត្តការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ នៅក្នុងបណ្តាប្រទេសផ្សេងៗ។ នៅចុងបញ្ចប់នៃជំពូកស្ទើរតែទាំងអស់ មានផ្នែកដែលមានចំណងជើងថា *តើអ្នកអាចធ្វើអ្វីបានខ្លះក្នុងនាមជាតំណាងរាស្ត្រ* ដែលផ្នែកនេះ មានការលើកឡើងនូវអនុសាសន៍ជាក់ស្តែងជាច្រើន។ ទោះដូច្នេះក្តី ដូចដែលបានបញ្ជាក់ពីខាងដើម អនុសាសន៍ទាំងនេះត្រូវយកមកឆ្លុះបញ្ចាំងជាមួយនឹងបរិបទជាតិរបស់ប្រទេសនីមួយៗ។

ផ្នែកទាំងពីរខាងដើម ពន្យល់អំពីក្របខណ្ឌទ្រឹស្តី និងវិភាគអំពីការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ។ ផ្នែកទី១ ផ្តោតលើការវិវត្តនៃទស្សនទានសន្តិសុខ ហើយវាពន្យល់អំពីទិដ្ឋភាពទូទៅជាសកលអំពីតួនាទីរបស់សភា និងស្ថាប័នរដ្ឋដទៃទៀតនៅក្នុងបញ្ហាសន្តិសុខ។ សំណួរចម្បងៗដែលទាក់ទងនៅក្នុងផ្នែកទីI គឺ៖

- ❑ តើមានការអភិវឌ្ឍថ្មីៗអ្វីខ្លះនៅក្នុងបរិបទសន្តិសុខ?
- ❑ តើអ្វីទៅដែលហៅថាការគម្រាមកំហែងថ្មី និងការឆ្លើយតប?
- ❑ ហេតុអ្វីបានជាការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខជាការចាំបាច់?
- ❑ តើគោលការណ៍សំខាន់ៗ នៃអភិបាលកិច្ចតាមបែបប្រជាធិតេយ្យ លើវិស័យសន្តិសុខមានអ្វីខ្លះ?
- ❑ តើតួនាទីរបស់សភាទាក់ទងរដ្ឋាភិបាល និងតុលាការមានអ្វីខ្លះ?

ផ្នែកទីII រៀបរាប់អំពី ដំណាក់កាលទាំងអស់នៃវដ្តរបស់គោលនយោបាយសន្តិសុខជាតិព្រមទាំងក្របខណ្ឌគតិយុត្តអន្តរជាតិ ដែលពាក់ព័ន្ធជាមួយគោលនយោបាយសន្តិសុខជាតិទាំងនោះ។ ជំពូកទាំងពីរចុងក្រោយនៃផ្នែកទី២នេះ បង្ហាញអំពីតួនាទីរបស់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយរួមទាំងទស្សនៈវិស្ស័យយេនឌ័រអំពីបញ្ហាសន្តិសុខ។ សំណួរធំៗមានដូចជា៖

- តើសភាមានតួនាទីអ្វីខ្លះ ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងគោលនយោបាយសន្តិសុខ?
- តើច្បាប់អន្តរជាតិរឹតត្បិត ឬបង្កើនឲ្យមានកាលានុវត្តភាពសម្រាប់រៀបចំគោលនយោបាយសន្តិសុខជាតិយ៉ាងដូចម្តេចខ្លះ?
- តើសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយវិស័យសន្តិសុខ ហើយតើសភាអាចប្រើប្រាស់នូវការចូលរួមខុសៗគ្នា របស់អង្គការទាំង២នេះ បានយ៉ាងដូចម្តេចខ្លះ?
- តើគេអាចផ្សព្វផ្សាយដល់សាធារណៈជនអំពីបញ្ហាសន្តិសុខយ៉ាងដូចម្តេចខ្លះ?
- តើស្រ្តីមានតួនាទីអ្វីខ្លះនៅក្នុងវិស័យសន្តិសុខ?

ផ្នែកទីIII បកស្រាយតួអង្គអ្វីខ្លះជាវិស័យសន្តិសុខ ដែលក្នុងនោះមានយោធា នគរបាល និងក្រុមចារកម្ម អង្គការយោធារបស់រដ្ឋដទៃទៀត រួមទាំងក្រុមហ៊ុនសន្តិសុខឯកជន។

- តើតួអង្គនីមួយៗខាងលើមានមុខងារ និងកាតព្វកិច្ចជាក់លាក់អ្វីខ្លះ នៅក្នុងវិស័យសន្តិសុខ?
- តើយន្តការគណនេយ្យភាព និងនយោបាយផ្ទៃក្នុងអ្វីខ្លះ ដែលត្រូវការជាចាំបាច់?
- តើសភាអាចអនុវត្តនូវការត្រួតពិនិត្យរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពដូចម្តេចខ្លះលើសេវាសន្តិសុខទាំងនេះ?

ផ្នែកទីIV ពិនិត្យមើលនូវឧបករណ៍ទាំងឡាយដែលសភាអាចប្រើប្រាស់ ដើម្បីធ្វើការត្រួតពិនិត្យវិស័យសន្តិសុខ ហើយផ្នែកនេះឆ្លើយនឹងសំណួរ *ដែលមានជាអាទិ៍* ដូចខាងក្រោម៖

- តើមានឧបករណ៍អ្វីខ្លះ ដែលសភាអាចប្រើប្រាស់ដើម្បីធ្វើការត្រួតពិនិត្យលើវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាព?
- តើឯកទេសរបស់សភាស្តីពីបញ្ហាសន្តិសុខ អាចត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងដូចម្តេចខ្លះ?
- តើតួនាទីរបស់សភាមានអ្វីខ្លះក្នុងការសួរដេញដោល និងបើកសវនការអំពីបញ្ហាសន្តិសុខ?
- តើគណៈកម្មការការពារជាតិសភាអាចធ្វើការអោយមានប្រសិទ្ធភាពដូចម្តេចខ្លះ?
- តើមន្ត្រីរដ្ឋដោះស្រាយបណ្តឹង (ombudsman) មានតួនាទីអ្វីខ្លះ?
- តើអង្គភាពរបស់មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងនេះ ដំណើរការក្នុងកិច្ចការពារតួនាទីរបស់ខ្លួនយ៉ាងដូចម្តេចខ្លះ?
- ហេតុអ្វីសភាគួរចុះទៅពិនិត្យដល់ទីតាំងនៃសេវាសន្តិសុខ?

ផ្នែកទីV និយាយអំពីកាលៈទេសៈទាំងឡាយ ដែលបង្កឲ្យមានបញ្ហាប្រឈមដ៏ជាក់លាក់ចំពោះសន្តិសុខ ដូចជា បញ្ហាទាក់ទងនឹងការដាក់ប្រទេសក្នុងស្ថានភាពអាសន្ន ការគម្រាមកំហែងដល់សន្តិសុខផ្ទៃក្នុង បញ្ហាភេរវកម្ម និងឧក្រិដ្ឋកម្មលើអ៊ីនធឺណែតជាដើម។ ផ្នែកនេះ ក៏គូសបញ្ជាក់អំពីបញ្ហាទាក់ទងនឹងការចូលរួម នៅក្នុងបេសកកម្មគាំទ្រសន្តិភាពអន្តរជាតិនៅក្នុងតំបន់ដែលគ្មាន

សន្តិសុខទាំងស្រុង ឬសន្តិសុខនៅមានសភាពផុយស្រួយ។ ដូច្នេះផ្នែកទីV នេះ ព្យាយាមបកស្រាយនូវសំណួរមួយចំនួនខាងក្រោម៖

- ❑ តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឲ្យមានតុល្យភាពរឹងមាំ រវាងបញ្ហានៃការដាក់ប្រទេសស្ថិតនៅក្នុងស្ថានភាពអាសន្ន និងការរក្សានូវសន្តិសុខផ្ទៃក្នុង និងការគោរពសិទ្ធិមនុស្ស?
- ❑ តើគោលបំណង និងចំណុចខ្វះខាតនៃការដាក់ប្រទេសស្ថិតនៅក្នុងស្ថានភាពអាសន្នមានអ្វីខ្លះ?
- ❑ តើមានអ្វីខ្លះបានផ្លាស់ប្តូរចាប់តាំងពីថ្ងៃទី១១ ខែកញ្ញា? តើគេអាចបែងចែកដូចម្តេចខ្លះរវាងអំពើភេរវកម្ម និងការតវ៉ាដ៏ស្របច្បាប់តាមលក្ខណៈប្រជាធិបតេយ្យ?
- ❑ តើមានផលវិបាកអ្វីខ្លះចំពោះសន្តិសុខអន្តរជាតិរបស់រដ្ឋទាំងឡាយ? តើតួនាទីរបស់សភាមានអ្វីខ្លះ នៅក្នុងបញ្ហាទាំងនេះ?
- ❑ តើការចូលរួមរបស់សភាមានសារៈសំខាន់ប៉ុណ្ណា ក្នុងការធ្វើសេចក្តីសម្រេចចិត្តបញ្ជូនកងទ័ពទៅចូលរួមក្នុងប្រតិបត្តិការគាំទ្រសន្តិភាពអន្តរជាតិនៅឯបរទេស?

ផ្នែកទីVI ទីVII និងទីVIII វិភាគលើធនធានទាំង៣ទាក់ទងនឹងវិស័យសន្តិសុខ។ ផ្នែកទីVI ផ្តោតលើថវិកាការពារជាតិ និងការត្រួតពិនិត្យទាំងដោយសភា និងដោយស្ថាប័នសវនកម្មរដ្ឋជាបច្ឆាការ (posteriori)។

- ❑ តើថវិកាអាចជាគន្លឹះមួយសម្រាប់រក្សាសន្តិសុខដោយរបៀបណា?
- ❑ តើតម្លាភាពនិងគណនេយ្យភាពអាចអនុវត្តយ៉ាងដូចម្តេចខ្លះ ទាក់ទងនឹងថវិកាសម្រាប់វិស័យសន្តិសុខ?
- ❑ តើមានលក្ខខណ្ឌអ្វីខ្លះ សម្រាប់ធ្វើការត្រួតពិនិត្យឲ្យបានសមស្របទាក់ទងថវិកាសម្រាប់វិស័យសន្តិសុខ?
- ❑ តើគេអាចធ្វើសវនកម្មលើវិស័យសន្តិសុខបានដែរឬទេ? ហេតុអ្វីបានជាសវនកម្មឯករាជ្យមានសារៈសំខាន់ ហើយតើវាដំណើរការដូចម្តេចខ្លះ?

ផ្នែកទីVII ទាក់ទងនឹងបុគ្គលិកនៃវិស័យសន្តិសុខ និងគោលបំណងក្នុងការជួយដល់សភាក្នុងការធ្វើនិយ័តកម្មលើការជ្រើសរើសការសម្រិតសម្រាំង និងការបណ្តុះបណ្តាលអ្នកបម្រើការក្នុងវិស័យសន្តិសុខ ការចូលនិវត្តន៍ និងរបបប្រាក់សោធននិវត្តន៍ ការជ្រើសរើសទ័ព និងសេវាផ្សេងទៀត។

- ❑ តើគុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យ (democratic values) អាចបណ្តុះនៅក្នុងផ្នត់គំនិតរបស់បុគ្គលិកវិស័យសន្តិសុខបានយ៉ាងដូចម្តេចខ្លះ?
- ❑ តើបុគ្គលិកវិស័យសន្តិសុខអាចបង្កើតជាសហជីពយោធា (military unions) បានដែរឬទេ?

- តើក្រមសីលធម៌វិជ្ជាជីវៈរបស់វិស័យសន្តិសុខមានអ្វីខ្លះ?
- តើនៅក្នុងប្រទេសផ្សេងៗ គេធ្វើការរៀបចំជ្រើសរើសយោធា និងរៀបចំសេវាផ្សេងៗ យ៉ាងដូចម្តេចខ្លះ?
- តើក្រមសីលធម៌របស់បុគ្គលិកវិស័យសន្តិសុខមានដែរឬទេ? តើមានបទដ្ឋានអន្តជាតិដែរឬទេ?
- តើផ្នែកណាខ្លះនៃការគ្រប់គ្រងបុគ្គលិកនៅក្នុងវិស័យនេះ មានការពាក់ព័ន្ធជាមួយសមាជិកសភា?

ចុងក្រោយ ផ្នែកទីVIII ទាក់ទងធនធានសម្ភារៈនៃវិស័យសន្តិសុខ ជាពិសេស ផ្នែកលទ្ធកម្ម (តើត្រូវទិញអ្វីខ្លះពីអ្នកណា?) ការជួញដូរ និងផ្ទេរអាវុធ។

- តើឧបស័គ្គទាក់ទងនឹងផ្នែកច្បាប់មានអ្វីខ្លះ?
- តើដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដ៏គ្រប់ជ្រុងជ្រោយ អំពីការធ្វើលទ្ធកម្មមានអ្វីខ្លះ?
- តើមានកាលៈទេសៈអ្វីខ្លះដែលផ្តល់យុត្តិកម្មដល់កិច្ចការសម្ងាត់?
- តើសភាអាចធ្វើការវាយតម្លៃនូវបញ្ហាទាំងអស់នេះបានយ៉ាងដូចម្តេចខ្លះ?

# មាតិកា

- សេចក្តីផ្តើម ........................................................................................ ៥
- អ្វីខ្លះដែលអ្នកអាចរកឃើញក្នុងសៀវភៅនេះ .......................................................... ៧

ប្រអប់បញ្ជី (List of boxes) ........................................................................................ ១៤

*ផ្នែកទី I*
ការវិវត្តទស្សនទាន និងតួអង្គក្នុងវិស័យសន្តិសុខជាតិ៖ ការប្រឈមដែលសភាជួបប្រទះ

*ជំពូក ១ - ការផ្លាស់ប្តូរសន្តិសុខនៅក្នុងពិភពលោកដែលកំពុងប្រែប្រួល* ........................ ២១
*ជំពូក ២ - សារៈសំខាន់នៃការត្រួតពិនិត្យរបស់សភា* .................................................. ២៦
*ជំពូក ៣ - តួនាទី និងទំនួលខុសត្រូវរបស់សភា និងស្ថាប័នរដ្ឋដទៃទៀត* .................... ២៩

*ផ្នែកទី II*
ការត្រួតពិនិត្យលើគោលនយោបាយសន្តិសុខជាតិ

*ជំពូក ៤ - ការជម្រុញគោលនយោបាយសន្តិសុខជាតិ* ................................................ ៣៧
*ជំពូក ៥ - គោលនយោបាយសន្តិសុខជាតិ និងបទដ្ឋានគតិយុត្តអន្តរជាតិ* ...................... ៤៣
*ជំពូក ៦ - តួនាទីរបស់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ* ............................................ ៤៨
*ជំពូក ៧ - ទស្សនៈវិស័យយេនឌ័រទាក់ទងនឹងគោលនយោបាយសន្តិសុខ* ...................... ៦០

*ផ្នែកទី III*
ផ្នែកប្រតិបត្តិសំខាន់ៗនៃវិស័យសន្តិសុខជាតិ

*ជំពូក ៨ - យោធា* ........................................................................................ ៧០
*ជំពូក ៩ - អង្គការយោធារដ្ឋដទៃទៀត* .............................................................. ៧៧
*ជំពូក ១០ - ចេនាសម្ព័ន្ធនគរបាល* ................................................................... ៨០
*ជំពូក ១១ - សេវាចារកម្ម* ............................................................................. ៨៥
*ជំពូក ១២ - ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន* ............................................... ៩២

*ផ្នែកទី IV*

## សន្តិសុខជាតិនៅក្រោមការត្រួតពិនិត្យដោយសភា៖ លក្ខខណ្ឌ និងយន្តការ


*ជំពូក ១៣ - លក្ខខណ្ឌនៃការត្រួតពិនិត្យដោយសភាប្រកបដោយប្រសិទ្ធភាព* ..................... ៩៨
*ជំពូក ១៤ - យន្តការសភាដែលត្រូវអនុវត្តទៅលើ វិស័យសន្តិសុខ* ................................ ១០៥
*ជំពូក ១៥ - គណៈកម្មការការពារជាតិ ឬសន្តិសុខរបស់សភា* ........................................ ១១៣
*ជំពូក ១៦ - ការិយាល័យដោះស្រាយពាក្យបណ្ដឹង* ....................................................... ១១៨
*ជំពូក ១៧ - ការចុះពិនិត្យទីតាំងសេវាសន្តិសុខ* ........................................................... ១២៤


*ផ្នែកទី V*

## ការត្រួតពិនិត្យសេវាសន្តិសុខពេលកំពុងធ្វើសកម្មភាព៖ កាលៈទេសៈ និងប្រតិបត្តិការពិសេស


*ជំពូក ១៨ - ករណីលើកលែង* ............................................................................... ១៣០
*ជំពូក ១៩ - ការថែរក្សាសន្តិសុខផ្ទៃក្នុង* ..................................................................... ១៣៦
*ជំពូក ២០ - អំពើភេរវកម្ម* ....................................................................................... ១៤១
*ជំពូក ២១ - សន្តិសុខ និងបច្ចេកវិទ្យាព័ត៌មាន៖ ឧបករណ៍ និងការប្រឈមថ្មីៗ* ..................... ១៥៣
*ជំពូក ២២ - បេសកកម្មសន្តិភាពអន្តរជាតិ* ................................................................. ១៥៧


*ផ្នែកទី VI*

## ធនធានហិរញ្ញវត្ថុ៖ ការធ្វើឲ្យសម្រេចបាននូវការត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធភាព ទាក់ទងនឹងបញ្ហាសន្តិសុខ


*ជំពូក ២៣ - សន្តិសុខ និងអំណាចនៃកាបូបដាក់ប្រាក់ (the power of the purse)* .............. ១៧០
*ជំពូក ២៤ - ការធ្វើសវនកម្មវិស័យសន្តិសុខទាក់ទងនឹងការចំណាយថវិកាជាតិ* ................. ១៨៦


*ផ្នែកទី VII*

## ធនធានមនុស្សនៅក្នុងវិស័យសន្តិសុខ៖ ការធានាវិជ្ជាជីវៈនិយម និងការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ


*ជំពូក ២៥ - ការលើកកម្ពស់គុណតម្លៃនៃលទ្ធិប្រជាប្រជាធិបតេយ្យ (democratic values) នៅក្នុងវិស័យសន្តិសុខ* ........................................................................................ ១៩៤
*ជំពូក ២៦ - ការគ្រប់គ្រងបុគ្គលិកនៅក្នុងវិស័យសន្តិសុខ* .............................................. ២០៨

*ជំពូក ២៧ - ការកេណ្ឌយោធា និងការបដិសេធប្រកបដោយសតិសម្បជញ្ញៈ* .................. ២១២

*ផ្នែកទី VIII*

ធនធានសម្ភារៈ៖ ការធ្វើឲ្យសម្រេចនូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការផ្ទេរ និងការធ្វើលទ្ធកម្មអាវុធ

*ជំពូក ២៨ - ការធ្វើលទ្ធកម្មអាវុធ និងឧបករណ៍យោធា* .................................... ២២២

*ជំពូក ២៩ - ការជួញដូរ និងការផ្ទេរអាវុធ* .................................................... ២២៩

សហភាពអន្តរសភា (IPU) ................................................................ ២៤៣

មជ្ឈមណ្ឌលហ្សឺណែវ សម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (DCAF) ........................................................ ២៤៥

តារាងរៀបរៀងតាមប្រធានបទ (Thematic Index) ................................... ២៤៨

# ប្រអប់បញ្ជី


ប្រអប់ទី ១៖ ការគម្រាមកំហែងសន្តិសុខនាពេលបច្ចុប្បន្នជាលក្ខណៈដាច់ដោយឡែក ឬជារួម ........ ២២

ប្រអប់ទី ២៖ ប្រភេទខុសៗគ្នានៃកិច្ចព្រមព្រៀងសន្តិសុខ ........ ២៤

ប្រអប់ទី ៣៖ មុខងារនានានៃផ្នែកសំខាន់ៗរបស់រដ្ឋ ដែលអាចមានលទ្ធភាពទាក់ទងនឹងវិស័យសន្តិសុខ ........ ៣០

ប្រអប់ទី ៤៖ អភិបាលកិច្ចល្អមានសារៈសំខាន់សម្រាប់ការត្រួតពិនិត្យវិស័យសន្តិសុខតាមបែបប្រជាធិបតេយ្យ ........ ៣២

ប្រអប់ទី ៥៖ ការស្ទួរដេញដោលទៅលើគោលនយោបាយសន្តិសុខជាតិ ........ ៣៧

ប្រអប់ទី ៦៖ លទ្ធិប្រជាធិបតេយ្យ និងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងសំខាន់ៗដទៃទៀត៖ ករណីនៃប្រទេសស្វីស ........ ៤៦

ប្រអប់ទី ៧៖ សង្គមស៊ីវិលនៅក្នុងអាមេរិកឡាទីន៖ ការបង្ហាញជាក់ស្តែងនូវតួនាទីនិងសារៈសំខាន់នៃអង្គការសង្គមស៊ីវិល ........ ៥០

ប្រអប់ទី ៨៖ ប្រភេទសង្គ្រាមថ្មី៖ គ្រាលំបាកសម្រាប់សេរីភាពនៃសារព័ត៌មាន ........ ៥២

ប្រអប់ទី ៩៖ សេរីភាពនៃសារព័ត៌មានក្រោយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ........ ៥៤

ប្រអប់ទី ១០៖ គេហទំព័រសភា ........ ៥៥

ប្រអប់ទី ១១៖ សភា និងប្រព័ន្ធផ្សព្វផ្សាយ ........ ៥៧

ប្រអប់ទី ១២៖ យេនឌ័រនៅក្នុងដំណើរការសន្តិភាព ........ ៦១

ប្រអប់ទី ១៣៖ ទស្សនៈវិស្ស័យយេនឌ័រស្តីពីប្រតិបត្តិការ និងដំណើរការសន្តិភាព ........ ៦២

ប្រអប់ទី ១៤៖ ចំនួនបុគ្គលិកយោធាជាស្ត្រី៖ ឧទាហរណ៍នៃប្រទេសជាសមាជិកនៃអង្គការណាតូ ........ ៦៤

ប្រអប់ទី ១៥៖ ការចូលរួមរបស់ស្ត្រីនៅក្នុងគោលនយោបាយសន្តិសុខជាផ្នែកមួយនៃការបញ្ជ្រាបយេនឌ័រ ........ ៦៥

ប្រអប់ទី ១៦៖ ទិដ្ឋភាព និងការប្រឈមថ្មីៗនៃការបញ្ចូលស្ត្រីទៅក្នុងវិស័យសន្តិសុខ ........ ៦៦

ប្រអប់ទី ១៧៖ ប្រទេសដែលគ្មានយោធា ........ ៧០

ប្រអប់ទី ១៨៖ កំណែទម្រង់ការពារជាតិ៖ ដើម្បីគោលបំណងអ្វី? ........ ៧១

ប្រអប់ទី ១៩៖ ការប្រើប្រាស់យោធានៅក្នុងការអនុវត្តច្បាប់ស៊ីវិល (civilian law) នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ........ ៧៤

ប្រអប់ទី ២០៖ ឧទាហរណ៍នៃអង្គភាពយោធារដ្ឋផ្សេងទៀតក្នុងប្រទេសមួយចំនួន ........ ៧៨

ប្រអប់ទី ២១៖ លក្ខណៈសំខាន់ៗនៃកងកម្លាំងនគរបាលតាមបែបប្រជាធិបតេយ្យ ........ ៨០

ប្រអប់ទី ២២៖ ការបំភ័ន្ត និង កាលៈទេសៈប្រកបគ្រោះថ្នាក់ ........ ៨១

ប្រអប់ទី ២៣៖ កងកម្លាំងនគរបាលនៅក្នុងប្រទេសអេរីទ្រា៖ ដំណើរការកំពុងវិវត្តន៍ទៅមុខ ... ៨២
ប្រអប់ទី ២៤៖ សភា និងមូលនិធិពិសេសដែលត្រូវបានផ្តល់ឲ្យសេវាចារកម្ម៖ ឧទាហរណ៍
នៃប្រទេសហុងគ្រី ... ៨៦
ប្រអប់ទី ២៥៖ ការអនុវត្តមួយចំនួននៃគណៈកម្មការសភាទាក់ទងនឹងឯកសារសម្ងាត់ ... ៨៧
ប្រអប់ទី ២៦៖ ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន និងគ្រោះថ្នាក់ជាសក្តានុពលខ្លះចំពោះ
លទ្ធិប្រជាធិបតេយ្យ ... ៩៣
ប្រអប់ទី ២៧៖ លិខិតូបករណ៍ និងឧបករណ៍ដែលសភាអាចប្រើប្រាស់សម្រាប់ធ្វើការ
ត្រួតពិនិត្យវិស័យសន្តិសុខតាមបែបប្រជាធិតេយ្យ ... ៩៩
ប្រអប់ទី ២៨៖ យុទ្ធសាស្រ្តដែលមានលក្ខណៈបង្កាទុកជាមុនសម្រាប់ការត្រួតពិនិត្យ
ដោយសភាលើវិស័យសន្តិសុខ ... ១០២
ប្រអប់ទី ២៩៖ យន្តការ និងការអនុវត្តសម្រាប់ការពង្រឹងឯកទេសសភាលើបញ្ហាសន្តិសុខ៖
សំណើមួយចំនួន ... ១០៣
ប្រអប់ទី ៣០៖ ទិដ្ឋភាពរួមនៃក្បាលម៉ាស៊ីន និងនីតិវិធីសភាសម្រាប់ការតាមដានលើ
អង្គការនីតិប្រតិបត្តិ ... ១០៦
ប្រអប់ទី ៣១៖ សំណើទាក់ទងនឹងការសួរដេញដោលប្រកបដោយប្រសិទ្ធភាព ... ១០៨
ប្រអប់ទី ៣២៖ លក្ខណៈពិសេសនៃគណៈកម្មាធិការសភាចោទសួរ ... ១១០
ប្រអប់ទី ៣៣៖គណៈកម្មការធិការស៊ើបអង្កេតនៃការពង្រាយកម្លាំងទ័ពកាណាដានៅក្នុង
ប្រទេសសូម៉ាលី៖ ឧទាហរណ៍របាយការណ៍ស្តីពីផលប៉ះពាល់ជាសាធារណៈ
ទៅលើបញ្ហាសន្តិសុខ ... ១១១
ប្រអប់ទី ៣៤៖ មុខងារសំខាន់ៗនៃគណៈកម្មាធិការសភាស្តីពីការការពារជាតិ
និងបញ្ហាសន្តិសុខ ... ១១៤
ប្រអប់ទី ៣៥៖ សម័យប្រជុំរួមរបស់គណៈកម្មាធិការកិច្ចការប្រទេស និងគណៈកម្មការ
ការពារជាតិ នៃសភាន័រវេ ... ១១៦
ប្រអប់ទី ៣៦៖ មន្ត្រីរដ្ឋទទួលដោះស្រាយពាក្យបណ្តឹង ... ១១៨
ប្រអប់ទី ៣៧៖ ទិដ្ឋភាពទូទៅរបស់មន្រ្តីរដ្ឋ ទទួលដោះស្រាយពាក្យបណ្តឹងទាក់ទងនឹង
បញ្ហាការពារ ជាតិនៅក្នុងប្រទេសមួយចំនួន ... ១២០
ប្រអប់ទី ៣៨៖ ឧត្តមស្នងការសភាអាល្លឺម៉ង់សម្រាប់កងកម្លាំងប្រដាប់អាវុធ ... ១២២
ប្រអប់ទី ៣៩៖ ករណីនៃប្រទេសអាហ្សង់ទីន ... ១២៤
ប្រអប់ទី ៤០៖ ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម បានពង្រីក
លទ្ធភាពបន្ថែមអោយមានការចុះត្រួតពិនិត្យទីតាំងសេវាសន្តិសុខ ... ១២៥
ប្រអប់ទី ៤១៖ ស្ថានភាពក្នុងគ្រាមានអាសន្ន៖ គោលបំណង និងគោលការណ៍ ... ១៣២
ប្រអប់ទី ៤២៖ ការថែរក្សាទាំងសន្តិសុខ និងលទ្ធិប្រជាធិបតេយ្យ ... ១៣៨

ប្រអប់ទី ៤៣៖ ការភ័ន្តច្រលំដែលនាំអោយមានវិបាកធ្ងន់ធ្ងរ ........................................ ១៣៩
ប្រអប់ទី ៤៤៖ ការឆ្លើយតបរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិចំពោះ
ព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ............................................................ ១៤២
ប្រអប់ទី ៤៥៖ ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ........................................................ ១៤៥
ប្រអប់ទី ៤៦៖ អនុសញ្ញាស្តីពីការគាំពារបុគ្គលទាក់ទងនឹងដំណើរការស្វ័យប្រវត្តិ
នូវទិន្នន័យបុគ្គល (ETS N° 108) ............................................................ ១៥៥
ប្រអប់ទី ៤៧៖ ការបង្កើតសន្តិភាព ការរក្សាសន្តិភាព ការជម្រុញសន្តិភាព ការកសាងសន្តិភាព៖
យមន័យដ៏មានសារៈប្រយោជន៍ខ្លះរបស់អង្គការសហប្រជាជាតិ .................... ១៥៨
ប្រអប់ទី ៤៨៖ ដំណើរការតាំងពង្រាយទ័ពរក្សាសន្តិភាព អង្គការសហប្រជាជាតិ .................... ១៦២
ប្រអប់ទី ៤៩៖ វិធានទាក់ទងនឹងការចូលរួមនៅក្នុងបេសកកម្មរក្សាសន្តិភាព ........................ ១៦៣
ប្រអប់ទី ៥០៖ ការហ្វឹកហ្វឺនរបស់អង្គការសហប្រជាជាតិចំពោះអ្នកថែរក្សាសន្តិភាព ............ ១៦៥
ប្រអប់ទី ៥១៖ ថវិកា៖ ឧបករណ៍សំខាន់សម្រាប់អភិបាលកិច្ចបែបប្រជាធិបតេយ្យ ................ ១៧០
ប្រអប់ទី ៥២៖ ហេតុអ្វីសភាគួរតែចូលរួមយ៉ាងសកម្មនៅក្នុងបញ្ហាថវិកា? ........................ ១៧២
ប្រអប់ទី ៥៣៖ ការចំណាយវិស័យការពារជាតិគិតជាភាគរយ នៃផលិតផលក្នុងស្រុកសរុប
របស់ពិភពលោក និងប្រទេសមួយចំនួន..................................................... ១៧៣
ប្រអប់ទី ៥៤៖ ប្រព័ន្ធរៀបចំផែនការ កម្មវិធី និងថវិកា (PPBS) ........................................ ១៧៥
ប្រអប់ទី ៥៥៖ សមាសភាគជាមូលដ្ឋាននៃថវិកាការពារជាតិ៖ ថវិកាការពារជាតិ
ប្រទេសអេស្ប៉ាញ ឆ្នាំ២០០២ ........................................................................ ១៧៨
ប្រអប់ទី ៥៦៖ ឧបសគ្គសំខាន់សម្រាប់ការបង្កើតកញ្ចប់ថវិកាសន្តិសុខប្រកបដោយតម្លាភាព... ១៧៩
ប្រអប់ទី ៥៧៖ ចំណាត់ថ្នាក់ទាំង៣ នៅក្នុងថវិកាសន្តិសុខ ................................................ ១៨១
ប្រអប់ទី ៥៨៖ បញ្ហាចម្បងរារាំងការត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធភាពនៅក្នុង
វិស័យសន្តិសុខ .............................................................................................. ១៨២
ប្រអប់ទី ៥៩៖ ការអនុវត្តថវិកាការពារជាតិនៅក្នុងរដ្ឋខ្លះនៅក្នុងអឺរ៉ុបភាគអាគ្នេយ៍ ................ ១៨៤
ប្រអប់ទី ៦០៖ អគ្គសវនករ .................................................................................................. ១៨៧
ប្រអប់ទី ៦១៖ តួនាទីនៃការិយាល័យសវនកម្មជាតិរបស់ចក្រភពអង់គ្លេស ក្នុងការ
ត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ ................................................ ១៨៨
ប្រអប់ទី ៦២៖ សភាប្រទេសចចា (Georgia) និងការពិនិត្យថវិកា ........................................ ១៩០
ប្រអប់ទី ៦៣៖ អនុសាសន៍ក្រុមប្រឹក្សាអឺរ៉ុបស្តីពីសិទ្ធិបង្កើតសមាគមសម្រាប់សមាជិក
បុគ្គលិកអាជីព នៃកងកម្លាំងប្រដាប់អាវុធ ................................................ ១៩៦
ប្រអប់ទី ៦៤៖ ការអប់រំអំពីភាពជាអ្នកដឹកនាំនិងពលរដ្ឋវិជ្ជានៅក្នុងកងកម្លាំងប្រដាប់អាវុធ
អាល្លឺម៉ង់៖ គោលការណ៍ "Innere Führung" ............................................ ២០១
ប្រអប់ទី ៦៥៖ ក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តច្បាប់ ........................................................ ២០២

ប្រអប់ទី ៦៦៖ ក្រមសីលធម៌អង្គការ OSCE ស្តីពីទិដ្ឋភាពនយោបាយយោធាទាក់ទងនឹង
វិស័យសន្តិសុខ (១៩៩៤)៖ ទិដ្ឋភាពសំខាន់ៗ ........................................ ២០៤
ប្រអប់ទី ៦៧៖ ការគ្រប់គ្រងបុគ្គលិក៖ មន្ត្រីបង្គោលសម្រាប់សមាជិកសភា ........................ ២០៨
ប្រអប់ទី ៦៨៖ សេវាយោធានៅជុំវិញពិភពលោក ................................................... ២១៣
ប្រអប់ទី ៦៩៖ ការធ្វើទុកបុកម្ទេញលើទាហានជាប់កំណែន ........................................ ២១៥
ប្រអប់ទី ៧០៖ សេចក្តីសម្រេចរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ
៩៩៨/៧៧៖ ការបដិសេធប្រកបដោយសម្បជញ្ញៈមិនចូលបម្រើកងទ័ព ........... ២១៧
ប្រអប់ទី ៧១៖ សេវាជំនួស៖ ករណីនៃប្រទេសស្វីស ................................................... ២១៩
ប្រអប់ទី ៧២៖ ហេតុអ្វីសភាគួរយកចិត្តទុកដាក់ចំពោះការធ្វើលទ្ធកម្មអាវុធ? ..................... ២២៣
ប្រអប់ទី ៧៣៖ គោលនយោបាយដ៏ខ្សោយ ឬមិនច្បាស់លាស់នៃការធ្វើលទ្ធកម្មអាវុធ ឬ
ដំណើរការ នៃការធ្វើលទ្ធកម្មអាវុធមានលក្ខណៈសម្ងាត់ខ្ពស់អាចនាំទៅរក...... ២២៤
ប្រអប់ទី ៧៤៖ គោលនយោបាយប្រទេសហូឡង់ស្តីពីការធ្វើលទ្ធកម្មអាវុធ៖
ការត្រួតពិនិត្យដោយសភា ........................................................ ២២៥
ប្រអប់ទី ៧៥៖ ការផ្ទេរអាវុធ៖ និយមន័យ ................................................................ ២២៩
ប្រអប់ទី ៧៦៖ កិច្ចព្រមព្រៀងថ្នាក់តំបន់ស្តីពីការផ្ទេរអាវុធ ............................................ ២៣០
ប្រអប់ទី ៧៧៖ ការធ្វើអោយការដាក់ទណ្ឌកម្មអាវុធកាន់តែមានភាពវៃឆ្លាត៖
ដែលសភាអាចធ្វើបាន ........................................................................ ២៣៤
ប្រអប់ទី ៧៨៖ ការជួញដូរអាវុធដែលនៅសល់៖ ផលអវិជ្ជមាននៃការដកហូតអាវុធ .............. ២៣៥
ប្រអប់ទី ៧៩៖ តួលេខប៉ាន់ស្មានអំពីការជួញដូរអាវុធធុនតូច .......................................... ២៣៦
ប្រអប់ទី ៨០៖ កម្មវិធីអង្គការសហប្រជាជាតិប្រឆាំងនឹងការជួញដូរខុសច្បាប់អាវុធធុនតូច
និងធុនស្រាលខុសច្បាប់៖ មន្ត្រីបង្គោលសម្រាប់សមាជិកសភា ...................២៣៧
ប្រអប់ទី ៨១៖ តួនាទីរបស់សភានៅក្នុងការត្រួតពិនិត្យការនាំចេញអាវុធ៖ តម្លាភាព
និងគណនេយ្យភាពនៅក្នុងប្រទេសសហភាពអឺរ៉ុប ...................................... ២៣៨

## ផ្នែកទី I

# ការវិវត្តនៃទស្សនទានសន្តិសុខ
# និង តួអង្គសន្តិសុខ៖
# ការប្រឈមចំពោះសភា

## ជំពូក ១

# ការវិវត្តនៃបញ្ហាសន្តិសុខនៅក្នុង ពិភពលោកដែលកំពុងប្រែប្រួល

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ស្ថានភាពសន្តិសុខនៅក្នុងសកលលោកមានការផ្លាស់ប្តូរយ៉ាងខ្លាំង។ ខណៈពេលដែលការគម្រាមកំហែងចាស់បានរលុបបាត់ទៅ ការប្រឈមថ្មីៗដ៏ធ្ងន់ធ្ងរបានកើតមានឡើងជំនួសវិញ។ ហេតុការណ៍នេះតម្រូវឲ្យយើងធ្វើការគិតគូរជាថ្មី អំពីគំនិតទាំងឡាយទាក់ទងនឹងបញ្ហាសន្តិសុខ ជម្លោះ និងសន្តិភាព។

## សន្តិភាព និងសន្តិសុខនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ

មិនមែនគ្រប់ជម្លោះទាំងអស់ បង្កការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខនោះទេ។ នៅក្នុងគ្រប់សង្គមទាំងអស់ ទស្សនៈផ្ទុយគ្នា តែងកើតមានឡើងលើបញ្ហាជាច្រើន។ នៅក្នុងសង្គមប្រជាធិបតេយ្យ សេរីភាពនៃការបញ្ចេញមតិ អនុញ្ញាតឲ្យប្រជាពលរដ្ឋ ជម្រាបជូននូវទស្សនៈទាំងនេះទៅដល់តំណាងរបស់ខ្លួនដែលបានជាប់ឆ្នោត។ តំណាងប្រជាពលរដ្ឋមានភារកិច្ចធ្វើការពិភាក្សាដេញដោល និងថ្លឹងថ្លែងចំពោះបញ្ហាទាំងនេះ តាមរយៈការពិភាក្សាដេញដោលជាសាធារណៈមួយ។ នីតិវិធីនេះអាចឲ្យសង្គមប្រជាធិបតេយ្យទប់ស្កាត់បាននូវជម្លោះ និងស្វែងរកនូវការសម្រុះសម្រួលដ៏ល្អមួយ សម្រាប់សង្គមជាតិទាំងមូល។ ជាក់ស្តែងណាស់កង្វះនូវស្ថាប័នប្រជាធិបតេយ្យដែលមានដំណើរការល្អ វានាំអោយមានភាពតានតឹងកើនឡើងហួសពីការគ្រប់គ្រង ហើយវាប្រែក្លាយជាជម្លោះហិង្សា។ ក្នុងនាមជាយន្តការដោះស្រាយជម្លោះមួយ លទ្ធិប្រជាធិបតេយ្យត្រូវបានគេមើលឃើញថា វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការរក្សាសន្តិសុខ និងសន្តិភាព។

ទំនាក់ទំនងនេះកើតឡើងតាមមូលហេតុបន្តបន្ទាប់ដូចជា៖ បច្ចុប្បន្ននេះមានការទទួលស្គាល់យ៉ាងទូលំទូលាយថាបញ្ហាសន្តិសុខមិនមែនគ្រាន់តែជាបំណងប្រាថ្នាប៉ុណ្ណោះនោះទេ តែធំបំផុតត្រូវរក្សានូវសុខុមាលភាពរបស់ប្រជាពលរដ្ឋឲ្យបានខ្ពស់។ លទ្ធិប្រជាធិបតេយ្យដែលចាក់ឫសគល់នៅក្នុងសភាដ៏មានប្រសិទ្ធភាពមួយ បានធ្វើឲ្យគំនិតនេះមានអត្ថន័យជាក់ស្តែង៖

> *“អធិបតេយ្យភាពរបស់សហគមន៍មួយ តំបន់មួយ ប្រជាជាតិមួយ រដ្ឋមួយ អាចមានន័យបានលុះត្រាតែវាចេញមកពី អធិបតេយ្យភាពដ៏ពិតប្រាកដមួយ នោះគឺថាចេញមកពីអធិបតេយ្យភាពនៃមនុស្សជាតិ”។* – Vaclav Havel

បញ្ហាសន្តិសុខជាតិ ដែលផ្តោតលើការការពាររដ្ឋ "បានក្លាយមកជា" បញ្ហាសន្តិសុខមនុស្ស ដែលយកចិត្តទុកដាក់ជាដំបូងដល់ប្រជាពលរដ្ឋម្នាក់ៗ និងសហគមន៍ទាំងមូល។ ជាក់ស្តែងបញ្ហានេះនាំឲ្យរដ្ឋពង្រីកនូវការឆ្លើយតបរបស់ខ្លួន ចំពោះការគម្រាមកំហែងលើសន្តិសុខតាមរយៈ៖

- ✓ **វិធានការទប់ស្កាត់៖** ផ្តួចផ្តើមធ្វើការទប់ស្កាត់ជម្លោះ ដូចជាវិធានការដោះស្រាយជម្លោះដោយមានការគិតគូរជាចម្បងចំពោះប្រជាពលរដ្ឋ និងវិធានការកសាងសន្តិភាព។
- ✓ **ការធ្វើអន្តរាគមន៍៖** ក្នុងករណីធ្ងន់ធ្ងរ នៅពេលដែលការខិតខំប្រឹងប្រែងដទៃទៀតបរាជ័យ ត្រូវធ្វើអន្តរាគមន៍នៅក្នុងជម្លោះផ្ទៃក្នុង ដើម្បីការពារប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត។
- ✓ **វិធានការឆ្លើយតប៖** វិធានការសង្គ្រោះដែលចាំបាច់នៅក្នុងកំឡុងពេល ឬក្រោយសង្គ្រាមស៊ីវិល ដើម្បីផ្តល់នូវការជួយគាំទ្រដល់ប្រជាជនស៊ីវិលដែលរងគ្រោះពីសង្គ្រាម។ នេះរួមមានការសាងសង់ជំរុំសម្រាប់ជនភៀសខ្លួន ការផ្តល់នូវការជ្រកកោនដល់ជនភៀសខ្លួន ឬផ្តល់នូវជំនួយសង្គ្រោះផ្សេងៗ។

## ពីសន្តិសុខយោធាឆ្ពោះទៅរកសន្តិសុខគ្រប់ជ្រុងជ្រោយ

ការផ្លាស់ប្តូរដែលផ្តោតលើ "សន្តិសុខមនុស្ស" ស៊ីសង្វាក់គ្នាជាមួយការពង្រីកនូវទស្សនទានអំពីសន្តិសុខ ទៅហួសឆ្ងាយពីការពិចារណាខាងផ្នែកយោធា។ មានការឯកភាពកាន់តែច្រើនថា គេត្រូវធ្វើការគិតគូរអំពីបញ្ហាសន្តិសុខឲ្យបានគ្រប់ជ្រុងជ្រោយ ដោយគិតទៅដល់កត្តាដែលមិនពាក់ព័ន្ធជាមួយយោធាផងដែរ (សូមអានប្រអប់ទី ១)។

**ប្រអប់ទី១**

**ការគម្រាមកំហែងមកលើសន្តិសុខដទៃទៀតនាពេលបច្ចុប្បន្ន អាចមានបញ្ហាសន្តិសុខខ្លួនឯង ឬព្រមទាំងបញ្ហាប្លុកផ្សំដទៃទៀត...**

- ▷ **ការគម្រាមកំហែងខាងផ្នែកនយោបាយ** ដូចជាអស្ថិរភាពនយោបាយ រដ្ឋដែលអសមត្ថភាព បញ្ហាភេរវកម្ម និងការរំលោភសិទ្ធិមនុស្ស។
- ▷ **ការគម្រាមកំហែងផ្នែកសេដ្ឋកិច្ច** ដូចជាភាពក្រីក្រ កំណើនគម្លាតរវាងប្រទេសអ្នកមាន និងប្រទេសអ្នកក្រ បញ្ហាហិរញ្ញវត្ថុអន្តរជាតិ ផលប៉ះពាល់មកលើរដ្ឋជិតខាងដែលជាមហាអំណាចខាងសេដ្ឋកិច្ច ឬដែលជារដ្ឋមិនមានស្ថិរភាព និងបញ្ហាចោរសមុទ្រជាដើម។
- ▷ **ការគម្រាមកំហែងដោយបរិស្ថាន ឬដោយមនុស្សជាអ្នកបង្ក** ដូចជាគ្រោះមហន្តរាយនុយក្លេអ៊ែរ ការប្រែប្រួលអាកាសធាតុសកល ការបាត់បង់គុណភាពដី ឬទឹក កង្វះស្បៀង និងធនធានដទៃទៀត។

- ▷ **ការគម្រាមកំហែងពីសង្គម** ដូចជាជម្លោះរវាងជនជាតិភាគតិច/ឬភាគច្រើន កំណើនប្រជាពលរដ្ឋ ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ការជួញដូរគ្រឿងញៀនឆ្លងដែន ការជួញដូរដោយខុសច្បាប់ ការធ្វើអន្តោប្រវេសន៍ជាទ្រង់ទ្រាយធំដែលមិនអាចគ្រប់គ្រងបាន និងជម្ងឺដង្កាត់ជាដើម។

អត្ថប្រយោជន៍នៃរបៀបវារៈដ៏ទូលំទូលាយ ស្តីពីបញ្ហាសន្តិសុខគឺថា បច្ចុប្បន្នគេមានការយល់ដឹងកាន់តែស៊ីជម្រៅ អំពីការគម្រាមកំហែងចំពោះបញ្ហាសន្តិសុខ និងការឆ្លើយតប ដ៏ចាំបាច់។ ចំណែកគុណវិបត្តិវិញគឺថា សេវាសន្តិសុខដែលមានបញ្ចូលរាល់អង្គការទាំងអស់ដែលមានសិទ្ធិអំណាចស្របច្បាប់ក្នុងការប្រើប្រាស់កម្លាំង បញ្ជាកម្លាំង ឬធ្វើការគម្រាមកំហែង លើការប្រើប្រាស់កម្លាំងដើម្បីការពាររដ្ឋ និងប្រជាពលរដ្ឋ អាចមានអំណាចហួសហេតុពេកប្រសិនបើវាសកម្មនៅក្នុងផ្នែកមិនមែនយោធានៅក្នុងសង្គមមួយ។ លើសពីនេះ វិស័យសន្តិសុខ មិនអាចមានជំនាញដ៏ចាំបាច់ក្នុងការឆ្លើយតបចំពោះការប្រឈមថ្មីៗទាំងនេះ នោះទេ។

## ពីសន្តិសុខរបស់រដ្ឋនីមួយៗឆ្ពោះទៅរកសហប្រតិបត្តិការរក្សាសន្តិសុខជាមួយរដ្ឋផ្សេងៗ

គំនិតដែលថា គេមិនអាចសម្រេចបាននូវសន្តិសុខជាតិតាមរយៈ "ការជួយខ្លួនឯង" តែប៉ុណ្ណោះទេ ក៏ប៉ុន្តែ គេត្រូវការជាចាំបាច់នូវកិច្ចសហប្រតិបត្តិការសន្តិសុខរវាងរដ្ឋនានា គំនិតបែបនេះមានជាយូរយាណាស់មកហើយ ដូចជានៅក្នុងសតវត្សរ៍ទី១៩ វិធីសាស្ត្រស្តីពី "តុល្យភាពនៃអំណាច" មានលក្ខណៈលេចធ្លោ។ នៅក្នុងសតវត្សរ៍ទី២០ អង្គការសន្តិសុខដែលមានលក្ខណៈជាសហគមន៍មានការរីកដុះដាលជាច្រើនដូចជា សង្គមប្រជាជាតិ (the League of Nations) ដែលក្រោយមកក្លាយជាអង្គការសហប្រជាជាតិ ហើយក៏មានអង្គការការពារជាតិរួមដូចជាអង្គការណាតូជាដើម។

ចាប់តាំងពីចុងសង្គ្រាមត្រជាក់ ជម្លោះផ្ទៃក្នុងជាច្រើនបានកើតឡើង។ ថ្មីៗនេះ បញ្ហាភេរវកម្មបានក្លាយជាដំណឹងជួរមុខនៅក្នុងសារព័ត៌មាន។ សកលភាវូបនីយកម្មជំរុញអោយមានការលើកកម្ពស់ភាពពឹងពាក់គ្នាទៅវិញទៅមករវាងរដ្ឋ និងរដ្ឋ នៅក្នុងវិស័យសន្តិសុខផងដែរ។ បច្ចុប្បន្នការគម្រាមកំហែងដល់សន្តិសុខនៅក្នុងប្រទេសមួយ ងាយនឹងរីករាលដាលដល់តំបន់មួយ និងធ្វើឲ្យតំបន់នោះគ្មានស្ថិរភាព ឬប៉ះពាល់ដល់សន្តិភាពពិភពលោក។ ភាពជាក់ស្តែងថ្មីៗរួមទាំងការពង្រីករបៀបវារៈសន្តិសុខ បានផ្តល់សារៈសំខាន់ច្រើនឡើងដល់កិច្ចសហប្រតិបត្តិការសន្តិសុខ ជាអន្តរជាតិ។

**ប្រអប់ទី២**

## ប្រភេទខុសៗគ្នានៃកិច្ចព្រមព្រៀងសន្តិសុខ

▷ **ការការពារជាតិរួម (Collective Defence)**

ការការពារជាតិរួម ត្រូវបានកំណត់ថាជាសន្ធិសញ្ញាមួយរវាងរដ្ឋ២ ឬរដ្ឋច្រើនសន្យាជួយគ្នាទៅវិញទៅមកក្នុងករណីមានការវាយប្រហារពីខាងក្រៅ។ ឧទាហរណ៍ជាក់ស្តែងបំផុតនៃប្រភេទកិច្ចព្រមព្រៀងសន្តិសុខនេះ គឺអង្គការណាតូ និងអង្គការនៃរដ្ឋអាមេរិក (Organisation of American States)។

▷ **សន្តិសុខជាតិរួម (Collective Security)**

ជាមួយប្រព័ន្ធនេះ សហគមន៍ឯកភាពគ្នាបោះបង់ចោលការប្រើកម្លាំង និងជួយដល់សមាជិកនៅក្នុងសហគមន៍ ទោះបីជាមានរដ្ឋដ៏ទៃទៀតចង់ប្រើប្រាស់កម្លាំងក៏ដោយ។ វាជាប្រព័ន្ធមួយ ដែលផ្តល់នូវប្រតិកម្មប្រកបដោយអនុភាព ដោយសហគមន៍អន្តរជាតិចំពោះការបំផ្លិចបំផ្លាញសន្តិភាពអន្តរជាតិ។ ខុសពីការការពារជាតិរួម សន្តិសុខរួម គឺសម្រាប់ប្រឆាំងនឹងការវាយប្រហារពីខាងក្នុងសហគមន៍។ អង្គការសហប្រជាជាតិ គឺជាឧទាហរណ៍ជាក់ស្តែងមួយនៃប្រព័ន្ធសន្តិសុខសហគមន៍នេះ។ យោងតាមមាត្រា ៤១ និង ៤២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិត្រូវប្រើប្រាស់នូវការដាក់សម្ពាធទៅលើអ្នកបំផ្លាញសន្តិភាព អាចតាមរយៈវិធានការមិនមែនយោធា ឬវិធានការប្រើប្រាស់កម្លាំងយោធា។

ប្រភព៖ SIMMA, Bruno: ធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៥

▷ **សហប្រតិបត្តិការន្តិសុខ (Cooperative Security)**

សហប្រតិបត្តិការសន្តិសុខ ផ្សារភ្ជាប់សន្តិសុខរួមជាមួយវិធីសាស្ត្រគ្រប់ជ្រុងជ្រោយឆ្ពោះទៅរកសន្តិសុខ។ គេអាចកំណត់វាថាជា "វិធីសាស្ត្រដ៏ទូលំទូលាយមួយឆ្ពោះទៅរកការរក្សាសន្តិសុខ" ដែលវិសាលភាពរបស់វាមានលក្ខណៈជាពហុវិស័យដែលសង្កត់ធ្ងន់លើវិធានទប់ស្កាត់ជាក់ស្តែង ជាជាងគ្រាន់តែការបញ្ចៀសប្រកបដោយលក្ខណៈរួមចំណែកជាជាងមិនរួមចំណែកប្រកាន់យកទម្រង់ពហុភាគី ជាជាងទ្វេភាគី ជៀសវាងដំណោះស្រាយដោយយោធា ឆ្ពោះទៅរកដំណោះស្រាយដោយមិនប្រើយោធា ចាត់ទុករដ្ឋជាតួអង្គចម្បងក្នុងប្រព័ន្ធសន្តិសុខ ក៏ប៉ុន្តែទទួលស្គាល់តួអង្គក្រៅរដ្ឋអាចដើរតួនាទីដ៏សំខាន់ផងដែរ ដែលមិនទាមទារការបង្កើតអោយមានស្ថាប័នសន្តិសុខផ្លូវការ ក៏ប៉ុន្តែមិនរារាំងអោយមានស្ថាប័នសន្តិសុខផ្លូវការ និងជាពិសេសសង្កត់ធ្ងន់លើអត្ថប្រយោជន៍នៃការបង្កើតទម្លាប់អោយមានការសន្ទនាជាពហុភាគី។

ប្រភព៖ EVANS Gareth: សហប្រតិបត្តិការដើម្បីសន្តិភាពឆ្នាំ ១៩៩៣

"កិច្ចព្រមព្រៀងការពារជាតិរួម គឺជាទម្រង់នៃកិច្ចព្រមព្រៀងសហប្រតិបត្តិការដ៏ទូលំទូលាយបំផុត។ លើសពីនេះ សហប្រតិបត្តិការសន្តិសុខដែលមិនសូវស្អិតរមួតនេះ វាកើតមាននៅក្នុងបណ្តាញនៃកិច្ចព្រមព្រៀងជាទ្វេភាគី ឬជាពហុភាគី ដោយមិនចាំបាច់មានអង្គការយោធាជាផ្លូវការមួយ ឬអង្គការយោធាដ៏សំខាន់មួយនោះឡើយ។

ការសម្រេចចិត្តចូលរួមជាមួយអង្គការសហប្រតិបត្តិការសន្តិសុខមួយ និងជាពិសេសអង្គការការពារជាតិរួមប្រាកដជាមានផលប៉ះពាល់ ដ៏ខ្លាំងក្លាទៅលើស្ថានការណ៍សន្តិសុខរបស់ប្រទេសជាមិនខាន។ ជាគោលការណ៍ សហប្រតិបត្តិការបែបនេះ វាជួយពង្រឹងដល់សន្តិសុខជាតិដោយសារវាធានាឲ្យមានកម្លាំងរួមគ្នាមួយប្រឆាំងនឹងការគម្រាមកំហែងផ្សេងៗ។ ទោះដូច្នេះក្តី ការចូលជាសមាជិកនៃអង្គការនេះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួនៈ ប្រទេសនោះត្រូវជាប់កាតព្វកិច្ចសម្របសម្រួលទៅតាមវត្ថុបំណង និងលក្ខខណ្ឌទាំងឡាយរបស់សម្ព័ន្ធនេះដែលកំណត់ជ្រើសរើសក្នុងការរៀបចំគោលនយោបាយសន្តិសុខជាតិរបស់ខ្លួនអោយមានកម្រិត។ លើសពីនេះ វានឹងប៉ះពាល់ដល់ការត្រួតពិនិត្យដោយសភាដោយហេតុថា ដំណើរការនៃការសម្រេចចិត្តមួយផ្នែកត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឲ្យអន្តរជាតិទៅវិញ ។

# ជំពូកទី ២

# សារៈសំខាន់នៃការត្រួតពិនិត្យដោយសភា

មានការជឿជាក់ជាទូទៅថា គោលនយោបាយសន្តិសុខគឺជាភារកិច្ច "ពីធម្មជាតិ" មួយរបស់អង្គនីតិប្រតិបត្តិ ដោយហេតុថាពួកគេមានចំណេះដឹងដ៏ចាំបាច់ ហើយអាចចាត់វិធានការបានរហ័សទៀតផង។ សភាត្រូវបានគេចាត់ទុកថាជាស្ថាប័នដែលមិនសូវមានភាពសក្តិសមក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងសន្តិសុខ ជាពិសេសដោយសារតែនីតិវិធីត្រូវចំណាយពេលវែង និងកង្វះនូវជំនាញព័ត៌មានដ៏ពេញលេញ និងចាំបាច់នានា។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទនៃការតាក់តែងគោលនយោបាយនានា សភាមានភារកិច្ចជាអ្នកពិនិត្យឡើងវិញ និងតាមឃ្លាំមើលលើអង្គនីតិប្រតិបត្តិ។ យ៉ាងហោចណាស់មានហេតុផល៤យ៉ាង ដែលការត្រួតពិនិត្យបញ្ហាទាក់ទងនឹងសន្តិសុខបែបនេះ វាជាការចាំបាច់៖

### គោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ គឺត្រូវទប់ស្កាត់ការដឹកនាំបែបអត្តាធិបតី (Autocratic)

អតីតនាយករដ្ឋមន្ត្រីបារាំងលោក Georges Clémenceau បានគូសបញ្ជាក់ថា *"សង្គ្រាមគឺជាបញ្ហាដ៏ធ្ងន់ធ្ងរដែលមិនត្រូវប្រគល់ទៅឲ្យយោធាជាអ្នកសម្រេច"*។ សេចក្តីថ្លែងការណ៍ប្រជាប្រិយ៍នេះរំលឹកថានៅក្នុងប្រទេសប្រជាធិបតេយ្យ តំណាងរាស្ត្រមានអំណាចកំពូល ហើយគ្មានវិស័យណាផ្សេងរបស់រដ្ឋគួរត្រូវបានផាត់ចេញពីការត្រួតពិនិត្យដោយតំណាងរាស្ត្រនោះឡើយ។ រដ្ឋមួយដែលមិនមានការឃ្លាំមើលដោយសភាទៅលើវិស័យសន្តិសុខទេនោះ ជាពិសេសទៅលើផ្នែកយោធារដ្ឋនោះ ត្រូវគេចាត់ទុកថាជារដ្ឋដែលមានលទ្ធិប្រជាធិបតេយ្យមិនពេញលេញ ឬជាប្រទេសទើបកសាងលទ្ធិប្រជាធិបតេយ្យ។

យោងតាមអ្នកសិក្សាដ៏ឆ្នើមរបស់អាមេរិកលោក Robert A Dahl បាននិយាយថា *"បញ្ហាគ្រឹះដែលស្មុគស្មាញជាងគេនៃវិស័យនយោបាយ គឺការចៀសវាងនូវរបៀបដឹកនាំបែបអត្តាធិបតី"*។

ដោយវិស័យសន្តិសុខ មានការពាក់ព័ន្ធជាមួយភារកិច្ចស្នូលមួយរបស់រដ្ឋ ប្រព័ន្ធតុល្យភាពនៃអំណាចគឺជាការចាំបាច់ដើម្បីទប់ទល់ជាមួយអំណាចរបស់អង្គនីតិប្រតិបត្តិ។ ដូច្នេះការត្រួតពិនិត្យដោយសភាទៅលើវិស័យសន្តិសុខ គឺជាធាតុដ៏សំខាន់មួយ នៃការចែករំលែកអំណាចក្នុងកម្រិតរដ្ឋ ហើយប្រសិនបើធ្វើបែបនេះ វាប្រាកដជាមានប្រសិទ្ធភាព និងអាចកម្រិតព្រំដែនអំណាចរបស់អង្គនីតិប្រតិបត្តិ ឬប្រធានាធិបតី។

## គ្មានការបង់ពន្ធបើគ្មានតំណាងរបស់រាស្ត្រជាអ្នកកំណត់ (No taxation without representation)

មកដល់បច្ចុប្បន្ននេះ យន្តការដ៏មានសារៈសំខាន់បំផុតមួយរបស់សភា សម្រាប់ធ្វើការត្រួតពិនិត្យអង្គនីតិប្រតិបត្តិគឺថវិកា។ ផ្តើមឡើងពីសភាដំបូងគេបង្អស់នៅក្នុងអឺរ៉ុបខាងលិច បានចាប់កំណើតឡើង សភាបានទាមទារគោលការណ៍មួយដែលកំណត់ថា *"គ្មានការបង់ពន្ធបើគ្មានតំណាងរបស់រាស្ត្រជាអ្នកកំណត់"*។ ដោយអង្គការសន្តិសុខប្រើប្រាស់នូវចំណែកយ៉ាងច្រើននៃថវិការបស់រដ្ឋ វាសំខាន់ខ្លាំងណាស់ដែលសភាត្រូវធ្វើការឃ្លាំមើល លើការប្រើប្រាស់នូវធនធានដ៏កម្ររបស់រដ្ឋប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផល។

## ការបង្កើតនូវក្របខណ្ឌច្បាប់ស្តីពី បញ្ហាសន្តិសុខ

ជាក់ស្តែង គឺផ្នែកនីតិប្រតិបត្តិជាអ្នករៀបចំសេចក្តីព្រាងច្បាប់ ស្តីពី បញ្ហាសន្តិសុខ។ ទោះដូច្នេះក្តី សមាជិកសភាដើរតួនាទីដ៏សំខាន់មួយក្នុងការពិនិត្យឡើងវិញ នូវសេចក្តីព្រាងច្បាប់ទាំងនោះ។ ប្រសិនបើចាំបាច់ ពួកគេអាចស្នើសុំធ្វើវិសោធនកម្មដើម្បីធានាថាបញ្ញត្តិច្បាប់ដែលបានស្នើពិតជាបានឆ្លុះបញ្ចាំងនូវគំនិតថ្មីៗអំពីការរក្សាសន្តិសុខបានគ្រប់ជ្រុងជ្រោយ យ៉ាងពិតប្រាកដមែន។ លើសពីនេះ វាសំខាន់ផងដែរសម្រាប់សភាក្នុងការបញ្ជាក់ឲ្យច្បាស់ថា ច្បាប់មិនមែនជាក្រដាសដែលគ្មានវិញ្ញាណមួយនោះទេ តែវាជាក្រដាសដែលអាចយកទៅអនុវត្តបានយ៉ាងពេញលេញ។

## សភាជាស្ពានតភ្ជាប់ទៅសាធារណជន

អង្គនីតិប្រតិបត្តិ អាចមិនមានការយល់ដឹងដ៏ពេញលេញអំពីបញ្ហាសន្តិសុខដែលជាអាទិភាពសម្រាប់ប្រជាពលរដ្ឋ។ តំណាងរាស្ត្រជាអ្នកដែលមានទំនាក់ទំនងជាទៀងទាត់ ជាមួយប្រជាពលរដ្ឋ និងជាអ្នកដែលអាចយល់ដឹងអំពីទស្សនៈរបស់ប្រជាពលរដ្ឋ។ ពួកគេអាចលើកនូវកង្វល់របស់ប្រជាពលរដ្ឋនៅក្នុងសភា និងពិនិត្យមើលថាតើទុក្ខកង្វល់ទាំងនោះ ត្រូវបានបញ្ចូលទៅក្នុងច្បាប់ និងគោលនយោបាយស្តីពីសន្តិសុខដែរឬយ៉ាងណា។

# បញ្ហាប្រឈមសម្រាប់ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ

យ៉ាងហោចណាស់មានទិដ្ឋភាពចំនួន៣ នៃវិស័យសន្តិសុខដែលបង្កឲ្យមានបញ្ហាប្រឈមដ៏ពិតប្រាកដមួយសម្រាប់ការត្រួតពិនិត្យដោយសភា៖

- ✓ ច្បាប់ស្តីពីព័ត៌មានសម្ងាត់ អាចរារាំងការចង់ពង្រឹងតម្លាភាពនៅក្នុងវិស័យសន្តិសុខ។ ជាពិសេសនៅក្នុងប្រទេសទើបមានលទ្ធិប្រជាធិបតេយ្យ ឬ ប្រទេសរងគ្រោះដោយសារជម្លោះ ច្បាប់ស្តីពីព័ត៌មានសម្ងាត់អាចរិតត្បិត ឬ ធ្វើឲ្យប៉ះពាល់ដល់ការត្រួតពិនិត្យដោយសភាទៅ

លើវិស័យសន្តិសុខ។ បញ្ហានេះ វាកើតមានផងដែរដោយសារមិនមានច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន។

- ✓ វិស័យសន្តិសុខ គឺជាផ្នែកដ៏ស្មុគ្រស្មាញធំបំផុតមួយ ដែលសភាត្រូវធ្វើការឃ្លាំមើលនូវបញ្ហាទាំងនេះដូចជា បញ្ហាលទ្ធកម្ម អាវុធ ការត្រួតពិនិត្យអាវុធ និងការត្រៀមខ្លួនឬរៀបចំរបស់អង្គភាពយោធាទាំងឡាយ។ មិនមែនគ្រប់តំណាងរាស្ត្រទាំងអស់សុទ្ធតែមានចំណេះដឹងជ្រៅជ្រះ និងជំនាញដ៏មានប្រសិទ្ធភាពអំពីបញ្ហាទាំងនេះនោះទេ ថែមទាំងពួកគេមិនមានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការបង្កើននូវចំណេះដឹងទាំងនេះផងដែរ ដោយសារតែអាណត្តិជាតំណាងរាស្ត្ររបស់ពួកគេមានកំណត់ ហើយពួកគេខ្វះប្រភពជំនាញទាំងនៅក្នុងប្រទេសនិងនៅក្រៅប្រទេសផងដែរ។
- ✓ ការផ្តោតទៅលើកិច្ចសហប្រតិបត្តិការសន្តិសុខជាអន្តរជាតិ អាចប៉ះពាល់ដល់តម្លាភាព និងភាពស្របច្បាប់តាមបែបប្រជាធិបតេយ្យ នៃគោលនយោបាយសន្តិសុខរបស់ប្រទេសមួយប្រសិនបើខ្វះការគិតគូរបញ្ចូលយន្តការសភាទៅក្នុងដំណើរការនេះទេនោះ។ ដូច្នេះវាសំខាន់ខ្លាំងណាស់ ដែលសភាអាចផ្តល់យោបល់ចូលរួមចំណែក និងបន្តធ្វើការពិភាក្សា សួរដេញដោល និងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងថ្នាក់អន្តរជាតិ។

ជំពូកទី ៣

# តួនាទី និងទំនួលខុសត្រូវរបស់សភា និង ស្ថាប័នរដ្ឋដទៃទៀត

## ការទទួលខុសត្រូវរួម

ខណៈពេលដែលសភា និងរដ្ឋាភិបាលមានតួនាទីផ្សេងគ្នានៅក្នុងបញ្ហាសន្តិសុខ ពួកគេក៏មានការទទួលខុសត្រូវក្នុងការរក្សាឲ្យមានការបំពេញមុខងារដ៏ល្អ នៃវិស័យសន្តិសុខផងដែរ។ ការទទួលខុសត្រូវរួមនេះ ក៏ជាផ្នែកសំខាន់បញ្ជាក់អំពីទំនាក់ទំនងរវាងមេដឹកនាំនយោបាយ និងមេដឹកនាំយោធាផងដែរ។ ភាគីទាំង២មិនត្រូវចាត់ទុកគ្នាជាគូបដិបក្ខដែលគ្មានគោលដៅស្របគ្នា។ ផ្ទុយទៅវិញ ពួកគេត្រូវការគ្នាទៅវិញទៅមក ដើម្បីរៀបចំនូវគោលនយោបាយសន្តិសុខមួយដ៏មានប្រសិទ្ធភាពគ្រប់ជ្រុងជ្រោយ និងមានមូលដ្ឋានដល់ប្រជាពលរដ្ឋ។ ដូច្នេះ ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យត្រូវបញ្ចូលផងដែរ នូវកិច្ចសន្ទនារវាងមេដឹកនាំនយោបាយ និងមន្ត្រីយោធាជាន់ខ្ពស់ដោយផ្អែកលើការជឿជាក់គ្នា ការសន្ទនាគ្នាដោយបើកចំហ និងការយោគយល់គ្នាទៅវិញទៅមក។ ការធ្វើទំនាក់ទំនងជាមួយគ្នាជាទៀងទាត់បែបនេះ មានអត្ថប្រយោជន៍បន្ថែមទៀត ដោយវាបង្ការអ្នកនយោបាយ និងមេដឹកនាំយោធាមិនឲ្យក្លាយជាអមិត្តនឹងគ្នា ដូច្នេះវាជួយបង្កើតបានជាស្ថិរភាពយ៉ាងច្រើន។

## ការបែងចែកតួនាទី

នៅក្នុងរដ្ឋមួយមានស្ថាប័នឯករាជ្យ៣ផ្សេងគ្នា គឺអង្គនីតិប្រតិបត្តិ អង្គនីតិប្បញ្ញត្តិ និងអំណាចតុលាការដែលបំពេញតួនាទីធំៗនៅក្នុងគោលនយោបាយសន្តិសុខជាតិ។ នៅក្នុងប្រអប់ទី៣ មានការពន្យល់អំពីស្ថាប័នទាំង៣ និងបញ្ជាក់អំពីមុខងារដ៏ជាក់លាក់របស់តួអង្គសំខាន់ទាំង៣ នៅក្នុងអង្គនីតិប្រតិបត្តិដែលក្នុងនោះមានប្រមុខរដ្ឋរដ្ឋាភិបាល និងអគ្គមេបញ្ជាការ។ តារាងនោះមានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅមួយ អំពីមុខងារនៅក្នុងប្រព័ន្ធនយោបាយ ដែលមុខងារទាំងនេះអាចមានលក្ខណៈមិនដូចគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ ដូច្នេះតារាងនេះ មិនតំណាងឲ្យស្ថានភាពដែលកើតមាននៅគ្រប់ប្រទេសទាំងអស់នោះទេ។

ក្រៅពីសភា តុលាការ និងរដ្ឋាភិបាល សង្គមស៊ីវិលក៏បានរួមចំណែកជាផ្លូវការច្រើនផងដែរដល់ការបង្កើត និងការអនុវត្តនូវគោលនយោបាយសន្តិសុខ ហើយប្រព័ន្ធផ្សព្វផ្សាយក៏បានរួមវិភាគទានតាមរយៈការផ្តល់ព័ត៌មានដល់សាធារណៈជនអំពីចេតនា និងវិធានការរបស់តួអង្គរដ្ឋ

ទាំងអស់ផងដែរ (សូមអានជំពូកទី ៦)។

ជាចុងបញ្ចប់ មានតួអង្គជាស្ថាប័នចំនួន២ ដែលដើរតួនាទីដ៏សំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយសន្តិសុខជាតិ និងថវិកាដែលពាក់ព័ន្ធ ដូចជា មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹង (the Ombudsman) (សូមអានជំពូកទី១៦) និងអគ្គសវនករ (សូមអានជំពូកទី២៨)។

## គណនេយ្យភាពនយោបាយ

សេវាសន្តិសុខ ត្រូវតែមានគណនេយ្យភាពចំពោះស្ថាប័នធំនីមួយៗរបស់រដ្ឋ៖

- ✓ អង្គនីតិប្រតិបត្តិ ធ្វើការត្រួតពិនិត្យដោយផ្ទាល់នៅថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាល និងកំណត់នូវថវិកា សេចក្តីណែនាំទូទៅ និងសកម្មភាពជាអាទិភាពនានានៃសេវាសន្តិសុខ។
- ✓ អង្គនីតិប្បញ្ញត្តិ ធ្វើការត្រួតពិនិត្យតាមរយៈការអនុម័តច្បាប់ដែលកំណត់ និងធ្វើនិយ័តកម្មលើសេវាសន្តិសុខ រួមទាំងអំណាចរបស់វា និងតាមរយៈការអនុម័តនូវថវិកាដែលពាក់ព័ន្ធ។ ការត្រួតពិនិត្យបែបនោះ ក៏អាចមានដូចជាការបង្កើតនូវការិយាល័យ ឬគណៈកម្មាធិការសភាដែលអាចធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងទាំងឡាយរបស់ប្រជាពលរដ្ឋ។
- ✓ អង្គតុលាការ ធ្វើការពិនិត្យទាំងវិស័យសន្តិសុខ និងដាក់ទោសទណ្ឌដល់យោធាដែលប្រព្រឹត្តខុសតាមរយៈនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌតាមការចាំបាច់។

**ប្រអប់ទី៣**

### មុខងាររបស់ស្ថាប័នធំៗរបស់រដ្ឋទាក់ទងនឹងវិស័យសន្តិសុខ

| | សភា | តុលាការ | អង្គនីតិប្រតិបត្តិ | | |
|---|---|---|---|---|---|
| | | | ប្រមុខរដ្ឋ | គណៈរដ្ឋមន្ត្រី | អគ្គមេបញ្ជាការ |
| អង្គភាពបញ្ជាកំពូល | នៅក្នុងប្រទេសខ្លះ: សភាពិភាក្សាដេញដោលនិង/ឬតែងតាំងមេបញ្ជាការកំពូល | តុលាការធម្មនុញ្ញមានតួនាទីដូចជាអគ្គមេបញ្ជាការ វាយតម្លៃធម្មនុញ្ញភាពរបស់ប្រធានាធិបតី ឬគណៈរដ្ឋមន្ត្រី | នៅក្នុងប្រទេសខ្លះ: ប្រមុខរដ្ឋមានមុខងារគ្រាន់តែជាកិត្តិយសតែនៅក្នុងប្រទេសផ្សេងទៀត ប្រមុខរដ្ឋមានអំណាចពិតប្រាកដ ដូចជា ជាអគ្គមេបញ្ជាការកំពូលក្នុងពេលមានសង្គ្រាម។ | រដ្ឋាភិបាលគឺជាអគ្គមេបញ្ជាការកំពូលនៅក្នុងពេលមានសង្គ្រាម។ | នៅក្នុងប្រទេសខ្លះ: មានមុខតំណែងរបស់អគ្គមេបញ្ជាការកំពូលតែក្នុងពេលមានសង្គ្រាម នៅក្នុងប្រទេសខ្លះទៀត វាជាមុខតំណែងអចិន្ត្រៃយ៍។ |
| គោលនយោ | ពិភាក្សាដេញ | - | ចុះហត្ថលេខាលើ | ស្នើ និងអនុវត្តគោល | ផ្តល់យោបល់ដល់ |

| | | | | | |
|---|---|---|---|---|---|
| បាយសន្តិសុខ | ដោលខ្លឹមសារ និងអនុម័តច្បាប់ | | ច្បាប់ទាក់ទងនឹង គោលនយោបាយ សន្តិសុខ | នយោបាយសន្តិសុខ | រដ្ឋាភិបាល និងធ្វើ ផែនការជួយ និង អនុវត្តគោល នយោបាយសន្តិសុខ |
| ថវិកា | អនុម័តថវិកា | | - | ស្នើថវិកា | ផ្តល់យោបល់ជូន រដ្ឋាភិបាល |
| ច្បាប់ការពារ ជាតិ | អនុម័តច្បាប់ | ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយធម្មនុញ្ញ ភាពនៃច្បាប់ | ចុះហត្ថលេខា ប្រកាសដាក់ឲ្យ ប្រើច្បាប់ | ស្នើច្បាប់ និងលិខិត បទដ្ឋានគតិយុត្ត ផ្សេងទៀត | ផ្តល់យោបល់ជូន រដ្ឋាភិបាល និង អនុវត្តច្បាប់ |
| បុគ្គលិក | នៅក្នុងប្រទេសខ្លះ សភាមានអំណាច អនុម័តលើការ តែងតាំងធំៗ | វិនិច្ឆ័យលើភាព ស្របច្បាប់នៃការ ប្រព្រឹត្តរបស់ បុគ្គលិក | តែងតាំងមេ បញ្ជាការសំខាន់ៗ និងអនុម័តផែនការ បុគ្គលិក | តែងតាំងមេបញ្ជាការ សំខាន់ៗ | ផ្តល់យោបល់អំពី បញ្ហាបុគ្គលិកអនុវត្ត ផែនការ បុគ្គលិក និងតែងតាំង មេបញ្ជាការ ថ្នាក់ ក្រោម |
| លទ្ធកម្ម | ពិនិត្យឡើងវិញ និង/ឬអនុម័តនូវ គម្រោងធំៗទាក់ ទងនឹងលទ្ធកម្ម អាវុធ | ធ្វើការជំនុំ ជម្រះការ រំលោភ ច្បាប់អំពើ ពុករលួយ និងការ កិបកេង | - | ស្នើលទ្ធកម្មអាវុធ | បង្កើត និងអនុវត្ត ដំណើរការ លទ្ធកម្មអាវុធ |
| ការបញ្ជូនទ័ព ទៅបរទេស/ ការទទួលទ័ព បរទេស | អនុម័តជាមុន ឬ ក្រោយឬមិន អនុម័តទាល់តែ សោះ | វិនិច្ឆ័យពីភាព ស្របច្បាប់នៃការ ប្រព្រឹត្តរបស់ពួកគេ | - | ចរចាលើការចូលរួម ជាអន្តរជាតិធ្វើ សេចក្តីសម្រេចលើ វិធាននៃការចូលរួម | ប្រតិបត្តិការបញ្ជា |
| សន្ធិសញ្ញា អន្តរជាតិ/ ការចូលរួម សម្ព័ន្ធភាព | អនុម័ត | | ចុះ និងផ្តល់ សច្ចាប័ន សន្ធិសញ្ញា អន្តរជាតិ | ទទួលខុសត្រូវ ចំពោះការចរចា អន្តរជាតិ | ផ្តល់យោបល់ ជូនរដ្ឋាភិបាល |

ដូចបានលើកឡើងពីខាងដើម តួនាទីរបស់ស្ថាប័នធំៗទាំង៣របស់រដ្ឋអាចមិនដូចគ្នា នៅក្នុងប្រទេសនីមួយៗ។ ទោះជាយ៉ាងណាក្តី ប្រព័ន្ធនៃការចែករំលែកអំណាចបានកើតមាននៅគ្រប់ពេលដែលបង្កើតឲ្យមានប្រព័ន្ធតុល្យភាពនៃអំណាច ប្រឆាំងការរំលោភបំពាន ពីផ្នែកនយោបាយទៅលើវិស័យសន្តិសុខ។ សូមចងចាំថា នៅក្នុងប្រទេសភាគច្រើន រដ្ឋាភិបាលមានបំណងបំពេញតួនាទីដែលមានលក្ខណៈត្រួតត្រានៅក្នុងបញ្ហាសន្តិសុខ ដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់ ដែលសភាត្រូវមានអំណាចប្រកបដោយប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព។ នេះគឺវាសំខាន់ជាងអ្វីៗទាំងអស់ ពីព្រោះបញ្ហាប្រឈមថ្មីៗ (សូមអាន ជំពូកទី១) អាចបណ្តាលឲ្យស្ថាប័នសាធារណៈធ្វើការកំណត់ឡើងវិញ នូវតួនាទីរបស់ខ្លួន។

## គោលការណ៍ទាំងឡាយនៃការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យដោយសភា

មិនមានបទដ្ឋានឯកភាពជាអន្តរជាតិ នៅក្នុងផ្នែកទាក់ទងនឹងការត្រួតពិនិត្យតាមលក្ខណៈប្រជាធិបតេយ្យដោយសភានោះទេ ពីព្រោះបញ្ហាសន្តិសុខ និងការពារជាតិត្រូវបានគេចាត់ទុកជាបញ្ហាអធិបតេយ្យភាពជាតិ។ ក៏ប៉ុន្តែវាមានជាបទដ្ឋានតំបន់ខ្លះ ដូចជា ក្រមសីលធម៌របស់អង្គការ OSCE (សម្រាប់ព័ត៌មានលំអិត សូមអានប្រអប់ទី៦៦) ហើយក៏មាននូវគោលការណ៍មួយចំនួនដែលគ្រប់គ្រងលើទំនាក់ទំនងតាមបែបប្រជាធិបតេយ្យរវាងស៊ីវិល និងយោធា៖

- ✓ រដ្ឋគឺជាតួអង្គតែមួយគត់នៅក្នុងសង្គម ដែលមានសិទ្ធិស្របច្បាប់ផ្តាច់មុខទៅលើកងកម្លាំងប្រដាប់អាវុធ។ សេវាសន្តិសុខមានគណនេយ្យភាពចំពោះអាជ្ញាធរប្រជាធិបតេយ្យស្របច្បាប់។
- ✓ សភាមានអធិបតេយ្យភាព និងតម្រូវឲ្យអង្គនីតិប្រតិបត្តិមានគណនេយ្យភាព ចំពោះការបង្កើតការអនុវត្ត និងការពិនិត្យឡើងវិញនូវគោលនយោបាយទាក់ទងនឹងសន្តិសុខ និងការពារជាតិ។
- ✓ សភាមានតួនាទីតាមរដ្ឋធម្មនុញ្ញតែមួយគត់ក្នុងការផ្តល់សិទ្ធិអំណាច និងត្រួតពិនិត្យលើការចំណាយដែលទាក់ទងការការពារជាតិ និងសន្តិសុខ។
- ✓ សភាមានតួនាទីដ៏សំខាន់មួយទាក់ទងនឹងការប្រកាស និងការលើក ការប្រកាសភាពអាសន្ន ឬប្រកាសសង្គ្រាម (សូមអានជំពូកទី១៨)។
- ✓ គោលការណ៍នៃអភិបាលកិច្ចល្អ (សូមអានប្រអប់ទី៤) និង នីតិរដ្ឋត្រូវគ្របដណ្តប់លើគ្រប់ស្ថាប័នទាំងអស់របស់រដ្ឋាភិបាល រួមទាំងវិស័យសន្តិសុខផងដែរ។
- ✓ បុគ្គលិកវិស័យសន្តិសុខ ត្រូវមានគណនេយ្យភាពជាបុគ្គលចំពោះតុលាការ ចំពោះការរំលោភបំពានលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ (ដូចជាការប្រព្រឹត្តកំហុសផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ)។
- ✓ អង្គការវិស័យសន្តិសុខត្រូវតែស្ថិតជាអព្យាក្រឹត្យខាងផ្នែកនយោបាយ។

**ប្រអប់ទី ៤**

### អភិបាលកិច្ចល្អ គឺជាគុណសម្បត្តិដ៏សំខាន់សម្រាប់ការត្រួតពិនិត្យ តាមបែបប្រជាធិបតេយ្យ ទៅលើវិស័យសន្តិសុខ

"អភិបាលកិច្ចល្អ គឺជាការរៀបចំគោលនយោបាយដែលមានលក្ខណៈអាចព្យាករណ៍បានបើកចំហ និងទូលំទូលាយជាការិយាល័យធិបតេយ្យមួយ ដែលប្រកាន់ក្រមសីលធម៌វិជ្ជាជីវៈដែលធ្វើសកម្មភាព ដើម្បីផលប្រយោជន៍សាធារណៈប្រកាន់នីតិរដ្ឋមានតម្លាភាព ហើយជាសង្គមស៊ីវិលដ៏រឹងមាំមួយ ដែលចូលរួមនៅក្នុងកិច្ចការសាធារណៈ។ ផ្ទុយទៅវិញអភិបាលកិច្ចទន់ខ្សោយមានលក្ខណៈស្ទាក់ស្ទើរក្នុងការកំណត់គោលនយោបាយ គ្មានការទទួលខុសត្រូវ ប្រើប្រព័ន្ធច្បាប់

*IPU and DCAF – Parliamentary oversight of the security sector, 2003*

ដែលមិនអាចអនុវត្តបាន ឬគ្មានសុក្រិតភាពច្បាប់ បំពានប្រើអំណាចនីតិប្រតិបត្តិផ្តាច់ការ ខ្វះការចូលរួមពីសង្គមស៊ីវិល និងមានអំពើពុករលួយរីករាលដាល”។

*ប្រភព៖ ធនាគារពិភពលោកឆ្នាំ ១៩៩៤ អភិបាលកិច្ច៖*
*បទពិសោធន៍របស់ធនាគារពិភពលោកទីក្រុង វ៉ាស៊ីនតោន*

ផ្នែកទី II

# ការត្រួតពិនិត្យទៅលើ
# គោលនយោបាយជាតិស្តីពី
# បញ្ហាសន្តិសុខ

# ជំពូកទី ៤

# ការបង្កើតគោលនយោបាយជាតិស្តីពីបញ្ហាសន្តិសុខ

## សារជាតុសំខាន់ៗ

គោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខចែងអំពីវិធីសាស្ត្ររបស់រដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាសន្តិសុខនិងរបៀបធ្វើឲ្យសម្រេចបានជោគជ័យតាមការរំពឹងទុក។ គោលនយោបាយជាតិនេះ ពាក់ព័ន្ធជាមួយការធ្វើសេចក្តីសម្រេចចិត្តធំៗទាក់ទងនឹងវិស័យសន្តិសុខ ដែលប៉ះពាល់ដល់សន្តិសុខខាងក្នុង និងខាងក្រៅរបស់រដ្ឋ និងរបស់សង្គម។ វាជាគោលនយោបាយមួយដែលផ្អែកលើវិធីសាស្ត្រ ដើម្បីរក្សាសន្តិសុខផ្តល់ការណែនាំចំពោះទ្រឹស្តីគ្រប់គ្រងយោធា ហើយកសាងឡើងតាមគន្លង កំណត់យកក្របខណ្ឌនៃលិខិតបទដ្ឋានគតិយុត្តតំបន់ និងអន្តរជាតិដែលរដ្ឋ គឺជាភាគី។ ដូច្នេះ គោលនយោបាយជាតិនេះ មិនមែនត្រឹមតែផ្អែកលើការយល់ឃើញ ពីតម្រូវការផ្នែកសន្តិសុខ និងអាទិភាពរបស់ជាតិប៉ុណ្ណោះនោះទេ តែថែមទាំងប៉ះពាល់ដោយកត្តា និងសម្ពាធពីខាងក្រៅនិងការប្តេជ្ញាចិត្តនានា។ នៅក្នុងគ្រប់ករណីទាំងអស់គោលនយោបាយនេះ ត្រូវស្របតាមខ្លឹមសារ និងគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញជាតិ ឬធម្មនុញ្ញ (charter)។

**ប្រអប់ទី ៥**

**ការសួរដេញដោលលើគោលនយោបាយជាតិស្តីពីបញ្ហាសន្តិសុខ**

នៅក្នុងការសួរដេញដោល និងការអនុម័តលើឯកសារគោលនយោបាយជាតិស្តីពី បញ្ហាសន្តិសុខ ឬការពិភាក្សាសួរដេញដោលទាក់ទងនឹងការអនុវត្តនៅក្នុងកាលៈទេសៈ ពិសេសតំណាងរាស្ត្រគួរលើកឡើងនូវសំណួរខ្លះ ឬសំណួរទាំងអស់ដូចខាងក្រោម៖

- ✓ តើគេត្រូវការពារសង្គមរបៀបណាកុំអោយមានការគម្រាមកំហែង និងបញ្ហាប្រឈម? តើគេត្រូវការពារអត្ថប្រយោជន៍អ្វី និងដើម្បីអ្នកណា? ដូច្នេះតើសន្តិសុខប្រភេទណាខ្លះដែលជាការចាំបាច់នោះ?
- ✓ តើគោលនយោបាយជាតិស្តីពី បញ្ហាសន្តិសុខមានបានគិតគូរអំពីបញ្ហាប្រឈមថ្មីៗចំពោះវិស័យសន្តិសុខដែរឬទេដូចជាបទឧក្រិដ្ឋដែលមានអង្គការចាត់តាំងនិងអំពើភេរវកម្មជាដើម?

- ✓ តើគេត្រូវធ្វើយ៉ាងណា ដើម្បីអោយគោលនយោបាយសន្តិសុខ សមស្របតាមគន្លងគោលការណ៍ទាំងឡាយនៃច្បាប់អន្តរជាតិស្តីពី មនុស្សធម៌និងច្បាប់ការពារសិទ្ធមនុស្ស?
- ✓ តើសន្តិសុខប៉ុន្មានទើបគ្រប់គ្រាន់?
- ✓ តើគេអាចសម្រេចបានសន្តិសុខជាតិ ដោយជោគជ័យយ៉ាងដូចម្តេចខ្លះ៖ តាមរយៈការចូលរួមជាសម្ព័ន្ធមិត្ត ឬតាមរយៈការរក្សាអព្យាក្រិតភាព?
- ✓ តើកងកម្លាំងសន្តិសុខជាតិ ត្រូវអនុវត្តប្រតិបត្តិការសំខាន់ៗបំផុតអ្វីខ្លះ? តើមានតែប្រតិបត្តិការការពារជាតិតែមួយប៉ុណ្ណោះមែនទេ ឬពួកគេត្រូវចូលរួមជាមួយប្រតិបត្តិការរក្សាសន្តិភាព?
- ✓ តើត្រូវមានមធ្យោបាយអ្វីខ្លះ ហើយតើវិស័យមួយណាត្រូវចូលរួមដើម្បីធ្វើឲ្យសម្រេចការរក្សាសន្តិសុខប្រកបដោយជោគជ័យ? ហើយត្រូវប្រើរយៈពេលប៉ុន្មាន និងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌអ្វីខ្លះ?
- ✓ តើគួរតែធ្វើការពិនិត្យឡើងវិញនូវគោលនយោបាយស្តីពី បញ្ហាសន្តិសុខជាញឹកញយតាមរបៀបណា?
- ✓ តើនឹងមានផលប៉ះពាល់អ្វីខ្លះមកលើហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ហើយតើត្រូវយកពន្ធពីអ្នកបង់ពន្ធប៉ុន្មាន?
- ✓ តើគោលនយោបាយសន្តិសុខ និងការអនុវត្តរបស់វាមានផលប៉ះពាល់អ្វីខ្លះមកលើទំនាក់ទំនងបរទេស និងស្ថិរភាពតំបន់?
- ✓ តើស្ថានភាពពិត និងយុទ្ធសាស្ត្រជាតិនាពេលអនាគតមានអ្វីខ្លះ ពាក់ព័ន្ធជាមួយអាវុធប្រល័យមនុស្សលោក?

ជាគោលការណ៍ការអនុវត្តគោលនយោបាយជាតិស្តីពីបញ្ហាសន្តិសុខមានការពាក់ព័ន្ធជាមួយរួមទាំងបណ្តាញ និងនាយកដ្ឋានផ្សេងៗរបស់រដ្ឋ ឯកសារគោលនយោបាយជាច្រើនទៀត។ ដូច្នេះវាសំខាន់ខ្លាំងណាស់ថា ប្រទេសមួយត្រូវធ្វើការរៀបចំនូវយុទ្ធសាស្ត្រជាតិស្តីពីបញ្ហាសន្តិសុខ ដ៏គ្រប់ជ្រុងជ្រោយមួយ ដែលមានការពាក់ព័ន្ធជាមួយតួអង្គ ចំពោះកិច្ច និងទិដ្ឋភាពទាំងអស់នៃបញ្ហាសន្តិសុខ។ ធ្វើរបៀបនេះវាផ្តល់ដល់រដ្ឋាភិបាលនូវឱកាសសម្រាប់ធ្វើការដោះស្រាយជាមួយទិដ្ឋភាពសន្តិសុខទាំងអស់ តាមវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈសកល ។ បញ្ហាប្រឈមថ្មីៗដូចជា អំពើភេរវកម្ម និងឧក្រិដ្ឋកម្មអន្តរជាតិ តម្រូវឲ្យមានការខិតខំប្រឹងប្រែងរួមគ្នាព្រោះថា ដើម្បីប្រយុទ្ធប្រឆាំងនឹងការគម្រាមកំហែងថ្មីៗទាំងនេះ វាទាមទារនូវការចូលរួមពីស្ថាប័នផ្សេងៗ មានដូចជា យោធា ក្រសួងហិរញ្ញវត្ថុ នគរបាល ឆ្មាំព្រំដែន និងអង្គការស៊ើបការណ៍សម្ងាត់ ជាដើម។

### សារៈសំខាន់នៃការចូលរួមរបស់សភា

ក្នុងន័យនេះ និងយោងទៅលើបេសកកម្មរបស់សភា គឺជាអ្នកតំណាងឲ្យផលប្រយោជន៍ និងកង្វល់របស់ប្រជាពលរដ្ឋ វាមានហេតុផលមួយចំនួនការចូលរួមរបស់សភា នៅក្នុងការរៀបចំគោលនយោបាយជាតិស្តីពី បញ្ហាសន្តិសុខនិងសម្រាប់ការអនុម័តយល់ព្រមតាមរបៀបដែលមានតម្លាភាពដូចខាងក្រោម៖

- ✓ គោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខ វាប៉ះពាល់ដល់ជីវិត ផលប្រយោជន៍ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដូច្នេះវាមិនត្រូវផ្អែកផ្តាក់តែទៅលើការវិនិច្ឆ័យរបស់ផ្នែកនីតិប្រតិបត្តិ ឬយោធាតែម្នាក់ឯងនោះទេ។
- ✓ គោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខ មានផលវិបាកធំៗដល់អនាគតរបស់យោធាដល់អ្នកបម្រើការងារខាងសន្តិសុខទាំងបុរស និងនារី។
- ✓ គោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខ មានផលវិបាកផ្នែកហិរញ្ញវត្ថុធំៗ ព្រោះថាវាទាក់ទងជាមួយប្រាក់របស់អ្នកបង់ពន្ធ។
- ✓ ក្រៅពីការចំណាយផ្នែកហិរញ្ញវត្ថុ វិធានការសន្តិសុខអាចកំហិតសេរីភាពរបស់ប្រជាពលរដ្ឋ ដូច្នេះវាមានផលវិបាកធំធេងចំពោះលទ្ធិប្រជាធិបតេយ្យ។
- ✓ ដូច្នេះ វាសំខាន់ណាស់ដែលថា សភាត្រូវធានាចំពោះវិធានការបែបនោះ នៅគ្រប់ពេលវេលាអោយបានស្របតាមច្បាប់អន្តរជាតិស្តីពី មនុស្សធម៌ដែលនៅជាធរមានជាពិសេសអនុសញ្ញាទីក្រុងហ្សឺណែវទាំង៤ និងពិធីសារ២ រួមទាំងច្បាប់ការពារសិទ្ធិមនុស្ស ជាពិសេសគឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ កតិកាសញ្ញាអន្តរជាតិចែងថា សិទ្ធិមួយចំនួនរបស់ប្រជាពលរដ្ឋ មិនអាចត្រូវបានដកហូតទោះក្នុងកាលៈទេសៈណាក៏ដោយ។ សូមអានជំពូក១៨-២០។

## តួនាទីរបស់សភានៅក្នុងដំណាក់កាលនៃការរៀបចំគោលនយោបាយជាតិស្តីពីបញ្ហាសន្តិសុខ

ចំពោះសភា ការពិភាក្សាសួរដេញដោលលើគោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខមិនគួរធ្វើតែម្តងនោះទេ វាគួរតែជាដំណើរការមួយ ដែលមានការវិវត្តនៅក្នុង៤ដំណាក់កាលរបស់វា៖ ការរៀបចំការធ្វើសេចក្តីសម្រេចចិត្ត ការអនុវត្ត និងការវាយតម្លៃ។ ខណៈពេលដែលមិនគួរមានការលូកដៃក្នុងការទទួលខុសត្រូវរបស់អង្គនីតិប្រតិបត្តិនៅក្នុងការតាក់តែង និងអនុវត្តគោលនយោបាយសន្តិសុខ ដំណើរការនេះគួរមានតម្លាភាព និងត្រូវមានការចូលរួមតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើឲ្យមានតុល្យភាពដ៏សមស្របរវាងអ្នកដែលមានឥទ្ធិពលទាំងអស់ ទៅលើគោលនយោបាយរួមទាំងវិស័យសន្តិសុខខ្លួនឯងនិងបញ្ហាស្មុគ្រស្មាញនៃឧស្សាហកម្មយោធា (the military-industrial complex) (ដែលពាក្យនេះ សំដៅលើទំនាក់ទំនងរវាងគោលនយោបាយ និងថវិកា)។

ដូច្នេះ នៅក្នុងគ្រប់ដំណាក់កាលទាំងអស់ តំណាងរាស្ត្រគួរតែអាចប្រើប្រាស់នូវយន្តការដែលពួកគេមានដើម្បីធ្វើឲ្យផ្នែកនីតិប្រតិបត្តិដឹងពីកង្វល់សន្តិសុខ និងការរំពឹងទុករបស់សាធារណៈជនៈ តាមរយៈការចោទសួរដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ញត្តិ ការស៊ើបអង្កេត សវនការរបស់គណៈកម្មការសភា "សៀវភៅស" (White Papers) ការលើកឡើងរបស់រដ្ឋមន្ត្រី និងក្រសួងជាដើម។ (សូមអានជំពូក១៨ ដែលនិយាយអំពីយន្តការសភាពាក់ព័ន្ធនឹងវិស័យសន្តិសុខ)។

## ដំណាក់កាលរៀបចំ

នៅក្នុងគ្រប់ប្រព័ន្ធសភាទាំងអស់ តួនាទីសភាមានកំរិតនៅឡើយនៅក្នុងដំណាក់កាលនៃការរៀបចំគោលនយោបាយជាតិថ្មីស្តីពីសន្តិសុខ។ ភារកិច្ចនេះ ស្ថិតនៅក្រោមសមត្ថកិច្ចជាចំបងរបស់ក្រសួង និងទីភ្នាក់ងារមានសមត្ថកិច្ចរបស់រដ្ឋាភិបាល។ ក៏ប៉ុន្តែសភា និងសមាជិកសភាអាចមានតួនាទីសំខាន់ក្នុងការយល់ដឹង ថាតើគោលនយោបាយដែលមានស្រាប់វាស្របតាមតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែរឬទេ ហើយវាត្រូវការធ្វើការកែសម្រួលដែរឬទេ ប្រសិនបើចាំបាច់។

ជាពិសេស តួនាទីរបស់សភាមិនគួរត្រូវបានកម្រិតត្រឹមតែជាអ្នកទទួលឯកសារ និងសម្រេចថាព្រម ឬមិនព្រមនោះទេ។ វាគួរតែមានការពិគ្រោះយោបល់ជាមុន ជាមួយគណៈកម្មការចំពោះកិច្ចផ្សេងៗរបស់សភា ដើម្បីសុំយោបល់សម្រាប់រៀបចំឯកសារនិងពង្រាងច្បាប់អោយឆ្លុះបញ្ចាក់នូវចក្ខុវិស័យនានាក្នុងសភា។ ធ្វើបែបនេះ វាមិនត្រឹមធ្វើឲ្យតំណាងរាស្ត្រអាចពាំនាំនូវទុក្ខកង្វល់របស់ប្រជាពលរដ្ឋជាមុន នៅក្នុងដំណើរការរៀបចំប៉ុណ្ណោះនោះទេ តែវាថែមទាំងអាចរក្សាបាននូវបរិយាកាស និងការពិភាក្សាដេញដោលកាន់តែវិជ្ជមាននៅក្នុងសភាថែមទៀតផង នៅពេលដែលឯកសារគោលនយោបាយត្រូវបានដាក់ស្នើសុំការអនុម័តនោះ។ ផលប្រយោជន៍ដ៏ខ្ពស់បំផុតរបស់ប្រទេសគួរតែធ្វើយ៉ាងណាអោយមានទំនាក់ទំនងដ៏ល្អប្រសើរ រវាងអំណាចនៃមតិភាគច្រើន និងមតិប្រឆាំងនៅក្នុងសភា ជៀសវាងការរារាំងដល់ការពិភាក្សាដេញដោលតាមបែបប្រជាធិបតេយ្យ ទៅលើឯកសារគោលនយោបាយជាតិស្តីពីបញ្ហាសន្តិសុខឡើយ។ ក្នុងស្មារតីនេះ សភាគួរអាចស្នើសុំនូវការកែសម្រួលឯកសារដែលបានដាក់ស្នើមកខ្លួននេះ។

## ដំណាក់កាលនៃការធ្វើសេចក្តីសម្រេច

សភាអាច និងគួរដើរតួនាទីដ៏សំខាន់ក្នុងដំណាក់កាលនៃការធ្វើសេចក្តីសម្រេចចិត្តជាពិសេស នៅពេលដែលគោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខបានមកដល់សភា។ ពេលឯកសារនេះធ្លាក់ដល់ដៃសភា ឯកសារនេះវាក្លាយជា "ទ្រព្យសម្បត្តិរបស់សភា" និងជាការទទួលសុខត្រូវដោយផ្ទាល់របស់សភា។ ដូច្នេះ សភាគួរមានពេលគ្រប់គ្រាន់ ដើម្បីសិក្សាឯកសារគោលនយោបាយនេះឲ្យបានស៊ីជម្រៅដោយមិនត្រូវប្រញាប់ប្រញាល់ពេកនោះទេ។

សភាអាចសម្រេចចិត្តទទួលយក ឬបដិសេធសេចក្តីស្នើច្បាប់ ឬគោលនយោបាយថ្មី ដែលស្នើដោយរដ្ឋាភិបាល និងស្នើសុំឲ្យធ្វើការកែសម្រួល។ ក្នុងដំណាក់កាលនេះ សភាត្រូវតែដើរតួនាទីយ៉ាងសកម្ម និងប្រើប្រាស់ឥទ្ធិពលខ្លះរបស់ខ្លួនដោយស្នើសុំឲ្យមានការកែសម្រួល ប្រសិនបើខ្លួនយល់ឃើញថាឯកសារដែលបានស្នើមកនេះមានចំណុចខ្វះខាត។ សំណួរដ៏សំខាន់ដែលអាចត្រូវធ្វើការដោះស្រាយនៅក្នុងអំឡុងពេលពិភាក្សាដេញដោលដោយសភា និងក្នុងអំឡុងពេលធ្វើសេចក្តីសម្រេចចិត្ត យើងបានលើកយកមកនិយាយនៅក្នុងជំពូកខាងដើមរួចហើយ។

នៅក្នុងដំណាក់កាលនេះ សភាមានឥទ្ធិពលបំផុត ជាពិសេសនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាថវិកា។ (សម្រាប់ព័ត៌មានបន្ថែម សូមអានផ្នែកទី៥ស្តីពីធនធានហិរញ្ញវត្ថុ)។ សភាមានឥទ្ធិពលកាន់តែច្រើន នៅពេលដែលសភាអាចរៀបចំនូវគណៈកម្មការមានសមត្ថកិច្ចរបស់ខ្លួនឲ្យចូលពិភាក្សាដេញដោលទៅតាមជំពូកនៃបញ្ហានីមួយនៅក្នុងឯកសារគោលនយោបាយ និងធ្វើការបោះឆ្នោតទៅលើការផ្តល់ថវិកា ដែលទាក់ទងនឹងបញ្ហាសន្តិសុខនីមួយៗ ក៏ដូចជាបោះឆ្នោតទៅលើការផ្តល់ថវិកាដ៏ពេញលេញដល់គោលនយោបាយសន្តិសុខទាំងមូលផងដែរ។ ផែនការការពារជាតិត្រូវកំណត់ពេលទុកសម្រាប់ពិនិត្យនិងត្រូវមានទំនាក់ទំនងច្បាស់លាស់ជាមួយតម្រូវការនៃថវិកា។

សភាអាចមានតួនាទីដ៏សំខាន់នៅក្នុងការផ្តល់ ឬបង្កើននូវការគាំទ្ររបស់សាធារណៈជននិងធ្វើការធានានូវភាពស្របច្បាប់ នៃឯកសារគោលនយោបាយដែលបានអនុម័ត។ បញ្ហាតម្លាភាពនៅក្នុងការពិភាក្សាដេញដោលដោយសភាអំពីបញ្ហាសន្តិសុខ គឺជាបញ្ហាដ៏សំខាន់ ដូច្នេះវាក៏សំខាន់ខ្លាំងណាស់ផងដែរ ដែលសាធារណៈជននិងប្រព័ន្ធផ្សព្វផ្សាយអាចចូលរួមនៅក្នុងការពិភាក្សា និងសវនការដេញដោលនេះ។

## ដំណាក់កាលអនុវត្ត

ការទទួលខុសត្រូវរបស់សភា ពាក់ព័ន្ធជាមួយសន្តិសុខជាតិមិន បញ្ចប់ត្រឹមពេលដែលឯកសារគោលនយោបាយ ឬបញ្ហាថវិកា ត្រូវបានអនុម័តនោះទេ តែការទទួលខុសត្រូវចំពោះការត្រួតពិនិត្យនិងធ្វើសវនកម្មត្រូវតែពង្រឹងឲ្យបានខ្លាំងក្លា។ នៅក្នុងអំឡុងពេលអនុវត្ត សភាត្រូវត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល ដោយប្រើប្រាស់រាល់ឧបករណ៍ទាំងឡាយដែលខ្លួនមាន (សូមអានជំពូកទី១៤) និងជំនួយពីស្ថាប័នឃ្លាំមើលដទៃទៀត (ឧ.ការិយាល័យសវនកម្មជាតិ សូមអានជំពូកទី២៤)។ សភាអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ជាពិសេសតាមរយៈការសម្រេចចិត្តលើការផ្តល់ថវិកាដែលពាក់ព័ន្ធ។ សភាក៏ត្រូវពិនិត្យឡើងវិញនូវសមត្ថភាពវិជ្ជាជីវៈ និងបច្ចេកទេសរបស់ការិយាល័យសវនកម្មដែលអនុវត្តការងារសវនកម្ម និងភាពអនុលោមតាមសវនកម្មផងដែរ។

សភាអាចធ្វើអន្តរាគមន៍នៅពេលដែលមានការកែសម្រួលធំៗ ឬមានវិបត្តិដែលតម្រូវឲ្យខ្លួនធ្វើការអនុម័តយល់ព្រមទៅលើវិធានការរបស់រដ្ឋាភិបាល។ ឧទាហរណ៍៖ ការបញ្ជូនទ័ពទៅបរទេស (សូមអានជំពូកទី២២) ឬការប្រកាសដាក់ប្រទេសក្នុងស្ថានភាពអាសន្ន (សូមអានជំពូកទី១៨)។

ក្រៅពីនេះ សភាអាចធ្វើអន្តរាគមន៍ ប្រសិនបើរដ្ឋាភិបាលធ្វើកំហុសដ៏ធ្ងន់ធ្ងរ។ ក្នុងករណីនេះ ជាធម្មតាសភាលើកជាសំណួរ។ ក្នុងករណីធ្ងន់ធ្ងរខ្លាំងសភាអាចបង្គាប់ឲ្យមានការស៊ើបអង្កេតពិសេស។

### ការវាយតម្លៃ និងមេរៀនដែលបានរៀនសូត្រ

នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ រដ្ឋាភិបាលមានតួនាទីក្នុងការវាយតម្លៃ ទៅលើការអនុវត្តឯកសារគោលនយោបាយរបស់ខ្លួន និងដាក់ជូនលទ្ធផលនៃការវាយតម្លៃនេះទៅសភាទាំងការវាយតម្លៃបែបបរិមាណ និងគុណភាព។ ដោយអង្គសភាជាតួអង្គដ៏សំខាន់នៅក្នុងបញ្ហានេះ ការវាយតម្លៃបែបនេះចៀសមិនផុតត្រូវបញ្ចូលសវនកម្ម ដោយបញ្ចូលតួលេខ និងសកម្មភាពអនុវត្តព្រមទាំងការចំណាយថវិកាដែលពាក់ព័ន្ធ។ ទោះបីការវាយតម្លៃនេះ មានការយឺតយ៉ាវក៏ដោយ ក៏ការវាយតម្លៃនេះវាសំខាន់ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា ឯកសារបច្ចុប្បន្ននេះគឺជាឯកសារដ៏ល្អត្រឹមត្រូវ ឬក៏ត្រូវរៀបចំឯកសារថ្មីស្រឡាងមួយទៀត។ កន្លែងណាដែលមានសង្គមស៊ីវិលដ៏សកម្ម ពួកគេក៏ត្រូវធ្វើការវាយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេ។ ឧទាហរណ៍ ដូចជាការវាយតម្លៃអំពីបេសកកម្មសន្តិភាព ប្រព័ន្ធអាវុធធុនធំ និងតម្លៃ ក៏ដូចជាប្រព័ន្ធបុគ្គលិករបស់ក្រសួងការពារជាតិ (ជាពិសេសផែនការជ្រើសរើសកងទ័ព) ជាដើម។ សភា ក៏អាចជួលអ្នកប្រឹក្សាយោបល់ឲ្យធ្វើសវនកម្មពិសេសផងដែរ។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើបានអ្វីខ្លះ

### អំពីគោលនយោបាយសន្តិសុខ

- ▷ ត្រូវបញ្ជាក់ឲ្យច្បាស់ថា វាមានទំនាក់ទំនងពិតប្រាកដរវាងគោលនយោបាយជាតិ ស្តីពីបញ្ហាសន្តិសុខ ប្រតិបត្តិការ ផែនការ ការពារជាតិ និងតម្រូវការថវិកា។
- ▷ បើអាចធ្វើបាន ជាពិសេសក្រោយពីធ្វើការប្រៀបធៀបជាមួយគោលនយោបាយ ដែលបានប្រើប្រាស់នៅក្នុងប្រទេសផ្សេង ដែលមានស្ថានភាពអាចប្រៀបធៀបបាន ត្រូវលើកសំណួរនៅក្នុងសភា ទាក់ទងនឹងការអនុវត្តគោលនយោបាយជាក់ស្តែង និង/ឬ អំពីការធ្វើបច្ចុប្បន្នភាពទៅលើឯកសារគោលនយោបាយ ដើម្បីដើរឲ្យទាន់ការវិវត្តន៍ថ្មីៗ៖ សូមអានផ្នែកទី១ស្តីពីការវិវត្តន៍គោលនយោបាយសន្តិសុខ និងតួអង្គ។
- ▷ សភា គួរធ្វើច្បាប់ស្តីពីដំណើរការរៀបចំធ្វើសេចក្តីសម្រេចចិត្ត អនុវត្ត និងវាយតម្លៃគោលនយោបាយជាតិស្តីពីសន្តិសុខ កំណត់នូវតួនាទីរបស់សភា នៅក្នុងគ្រប់ដំណាក់កាលទាំង៤នៃវគ្គរបស់វា។

### អំពីសំណួរពាក់ព័ន្ធផ្សេងទៀត

- ▷ ត្រូវបញ្ជាក់ឲ្យបានច្បាស់ថា នៅក្នុងដំណើរការនៃការកំណត់ ឬការកំណត់ឡើងវិញនូវគោលនយោបាយជាតិ ស្តីពីសន្តិសុខ សំណួរភាគច្រើនមាននៅក្នុងប្រអប់ទី៥ "ការសួរដេញដោលអំពីគោលនយោបាយជាតិស្តីពីសន្តិសុខ"។

**ជំពូកទី ៥**

# គោលនយោបាយជាតិស្តីពីសន្តិសុខ និងលិខិតូបករណ៍អន្តរជាតិ

## គោលការណ៍អន្តរជាតិ

សន្ធិសញ្ញាអន្តរជាតិពេលខ្លះដាក់រឹតត្បិត និងពេលខ្លះបើកទូលាយនូវជម្រើសនានា សម្រាប់ធ្វើការកំណត់នូវគោលនយោបាយជាតិស្តីពីសន្តិសុខ។ នៅក្នុងប្រទេសភាគច្រើននៅក្នុងពិភពលោក ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ និងជាប់កាតព្វកិច្ចដោយធម្មនុញ្ញអង្គការសហប្រជាជាតិ មាត្រា ២.៣ និង ២.៤ ដែលចែងថា៖

> *"រាល់សមាជិកទាំងអស់ត្រូវធ្វើការដោះស្រាយជម្លោះ ដែលមានលក្ខណៈជាអន្តរជាតិ ដោយមធ្យោបាយសន្តិវិធី ដោយមិនបង្កគ្រោះថ្នាក់ដល់សន្តិភាព និងសន្តិសុខអន្តរជាតិ និងយុត្តិធម៌"។ "រាល់សមាជិកទាំងអស់នៅក្នុងទំនាក់ទំនងអន្តរជាតិរបស់ខ្លួនមិនត្រូវធ្វើការគម្រាមកំហែង ឬប្រើប្រាស់កម្លាំងប្រឆាំងនឹងបូរណភាពដែនដី ឬឯករាជ្យភាពនយោបាយរបស់រដ្ឋណាមួយ ឬត្រូវធ្វើអ្វីមួយប្រាសចាសពីគោលបំណងរបស់អង្គការសហប្រជាជាតិឡើយ"។*

លើសពីនេះ មានគោលការណ៍ទំនៀមទម្លាប់អន្តរជាតិមួយចំនួន បានចែងនូវក្របខណ្ឌយោងមួយចំនួនផងដែរ។ សេចក្តីប្រកាសលេខ ២៦២៥ (XXV) របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីគោលការណ៍នៃច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការរវាងរដ្ឋ និងរដ្ឋ (ឆ្នាំ១៩៧០) ត្រូវបានទទួលស្គាល់ថា ជាការបកស្រាយដ៏ពិតប្រាកដនូវធម្មនុញ្ញអង្គការសហប្រជាជាតិ ដូច្នេះ វាចងកាតព្វកិច្ចលើរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់។ នៅក្នុងសេចក្តីប្រកាសនេះ មានគោលការណ៍សំខាន់ៗចំនួន៨ ត្រូវបានបកស្រាយដូចខាងក្រោម៖

**គោលការណ៍ទី I:** ការចៀសវាងការគម្រាមកំហែង ឬប្រើប្រាស់កម្លាំង។

**គោលការណ៍ទី II:** ការដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី។

**គោលការណ៍ទី III:** ការមិនរំលោភព្រំដែន និងបូរណភាពដែនដីរបស់រដ្ឋណាមួយ។

**គោលការណ៍ទី IV:** សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងនិងរស់នៅក្នុងសន្តិភាពនៅលើដែនដីរបស់ខ្លួន នៅក្នុងព្រំដែនដែលត្រូវបានទទួលស្គាល់ និងធានាជាអន្តរជាតិ។

**គោលការណ៍ទី V:** សមភាពអធិបតេយ្យភាពរបស់រដ្ឋ និងការមិនជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋផ្សេង។

**គោលការណ៍ទី VI:** គោរពសិទ្ធិមនុស្ស។

**គោលការណ៍ទី VII:** សហប្រតិបត្តិការរវាងរដ្ឋ និងរដ្ឋ។

**គោលការណ៍ទី VIII:** ការបំពេញកាតព្វកិច្ច ដោយស្មោះត្រង់ដែលបានកំណត់នៅក្រោមច្បាប់អន្តរជាតិ។

## សន្ធិសញ្ញាពហុភាគីស្តីពីសន្តិសុខ និងការពារជាតិ

មានសន្ធិសញ្ញាពហុភាគីជាច្រើនប្រភេទ ទាក់ទងនឹងវិស័យសន្តិសុខ។ សន្ធិសញ្ញាសំខាន់ៗទាំងនេះ មានដូចខាងក្រោម (ការបកស្រាយខាងក្រោមមិនបានពេញលេញនោះទេ នេះគ្រាន់តែជាឧទាហរណ៍ខ្លះ នៃសន្ធិសញ្ញាទាំងនោះ ទៅតាមប្រភេទនីមួយៗរបស់វាតែប៉ុណ្ណោះ)៖

- **សន្ធិសញ្ញាដែលធ្វើនិយ័តកម្មលើសន្តិសុខពិភពលោក៖** ធម្មនុញ្ញអង្គការសហប្រជាជាតិ។
- **សន្ធិសញ្ញាអន្តរជាតិនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលធ្វើនិយ័តកម្មលើជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិ៖** អនុសញ្ញាទីក្រុងហ្សឺណែវទាំង៤ ឆ្នាំ១៩៤៩ រួមទាំងពិធីសារបន្ថែម ២ឆ្នាំ១៩៧៧។
- **សន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងប្រភេទអាវុធ និងរបបៈ** សន្ធិសញ្ញាប្រឆាំងអាវុធមីស៊ីល សន្ធិសញ្ញាជាយុទ្ធសាស្ត្រស្តីពី ការកាត់បន្ថយអាវុធ អនុសញ្ញាមីន អនុសញ្ញា Tlatelolco ជាដើម។
- **អនុសញ្ញាអន្តរជាតិ ដែលបង្កើតនូវអង្គការតំបន់ពាក់ព័ន្ធដោយផ្នែកជាមួយបញ្ហាសន្តិសុខ៖** ធម្មនុញ្ញរបស់អង្គការរដ្ឋអាមេរិក សន្ធិសញ្ញាសហភាពអឺរ៉ុប ច្បាប់ CSCE Final Act – CSCE/OSCE, ច្បាប់របស់សហភាពអាហ្វ្រិក។
- **កិច្ចព្រមព្រៀងតំបន់នៃសហប្រតិបត្តិការយោធា និងជំនួយការពារជាតិទៅវិញទៅមក៖** សន្ធិសញ្ញាណាតូ ភាពជាដៃគូសម្រាប់កិច្ចព្រមព្រៀងសន្តិភាព សន្ធិសញ្ញា WEU សន្ធិសញ្ញាអាមេរិកស្តីពីការជួយគ្នាទៅវិញទៅមក។

ហេតុផលសម្រាប់រដ្ឋទាំងឡាយ ធ្វើការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសន្តិសុខអន្តរជាតិ គឺត្រូវកំណត់នូវគោលការណ៍អនុវត្តជាអន្តរជាតិ ក្នុងគោលបំណងពង្រឹងសន្តិសុខតំបន់ និងអន្តរជាតិ និងធ្វើអោយកាន់តែប្រសើរឡើងសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីរបស់ខ្លួន។ អង្គនីតិប្រតិបត្តិតាមរយៈក្រសួងការបរទេសរបស់ខ្លួន ជាធម្មតាដឹកនាំដំណើរការចរចាលើបញ្ហាទាំងអស់នេះ។

## កិច្ចព្រមព្រៀងទ្វេភាគី ឬ សន្ធិសញ្ញាមិត្តភាព សហប្រតិបត្តិការនិងជំនួយយោធាទៅវិញទៅមក

នៅពេលដែលរៀបចំគោលនយោបាយសន្តិសុខរបស់រដ្ឋ កិច្ចព្រមព្រៀងទ្វេភាគីដើរតួនាទីសំខាន់ខ្លាំងណាស់។ ដោយមានរដ្ឋភាគី២ ចូលរួមបញ្ញត្តិនៅក្នុងសន្ធិសញ្ញាបែបនេះ អាចត្រូវបានពិភាក្សាដើម្បីធ្វើការកែសម្រួលតាមដែលអាចធ្វើបាន ដើម្បីតម្រូវតាមផលប្រយោជន៍ជាក់លាក់កាលៈទេសៈ និងតម្រូវការរបស់ប្រទេសដែលពាក់ព័ន្ធ។ សន្ធិសញ្ញាជាយុទ្ធសាស្ត្រ ស្តីពីការកាត់បន្ថយអាវុធ (START) រវាងអតីតសហភាពសូវៀត និងសហរដ្ឋអាមេរិក គឺជាឧទាហរណ៍មួយ។

មិនត្រឹមតែសន្ធិសញ្ញាទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីសំដែងនូវមិត្តភាព និងការមិនឈ្លានពានគ្នាប៉ុណ្ណោះនោះទេ (ឧ. សន្ធិសញ្ញាទ្វេភាគីស្តីពី មិត្តភាព សហប្រតិបត្តិការ និងជំនួយទៅវិញទៅមកដែលបានចុះហត្ថលេខារវាងរុស្ស៊ី និងអាមេរិកក្នុងខែសីហា ឆ្នាំ១៩៩៧) តែសន្ធិសញ្ញាទាំងនេះថែមទាំងជួយដោះស្រាយនូវករណីជាក់ស្តែង នៃសហប្រតិបត្តិការយោធាជាច្រើនផងដែរ ដូចជា ករណីនៃការអនុញ្ញាតឲ្យមានការតាំងពង្រាយទ័ព និងអាវុធនៅលើដែនដីបរទេសថែមទៀតផង។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ រុស្ស៊ីបានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី ស្តីពីសហប្រតិបត្តិការយោធាជាមួយអតីតសាធារណៈរដ្ឋនៃសហភាពសូវៀត។

សន្ធិសញ្ញាទាំងនេះ ក៏អាចបញ្ចូលនូវជំនួយផ្នែកយោធាក្នុងករណីចាំបាច់។ ក្នុងន័យនេះ ធម្មនុញ្ញ ស្តីពីភាពជាដៃគូប្រជាធិបតេយ្យឆ្នាំ១៩៩៤ ត្រូវបានគេចាត់ទុកថាជាការបន្តនូវកិច្ចព្រមព្រៀងអាមេរិក និងកាហ្សាក់ស្តង់ឆ្នាំ១៩៩២ ដែលបើកផ្លូវឲ្យមានការកសាងទំនាក់ទំនងយោធាទ្វេភាគីរវាងប្រទេស និងប្រទេស។

ជាទូទៅ សន្ធិសញ្ញាទ្វេភាគីត្រូវបានគេចាត់ទុកថាជាឧបករណ៍មួយដែលកំណត់នូវគោលនយោបាយបរទេសស្តីពីសន្តិសុខ។ វាជាឧបករណ៍មួយ សម្រាប់ពង្រឹងនូវទំនាក់ទំនងមិត្តភាពជាមួយប្រទេសដទៃ និងជាឧបករណ៍សម្រាប់ដោះស្រាយបញ្ហាជាធំៗ។ សភាជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធនឹងបញ្ហានៃការអនុម័តយល់ព្រមលើសន្ធិសញ្ញាទាំងនេះ និងមានសិទ្ធិច្រើនក្នុងការស្នើសុំឲ្យមានការកែសម្រួលនៅក្នុងខ្លឹមសារនៃអត្ថបទ ដើម្បីអង្គការនីតិប្រតិបត្តិអាចយកទៅធ្វើការចរចាក្នុងករណីនៃសន្ធិសញ្ញាសន្តិសុខពហុភាគី ដែលមានលក្ខណៈជាប្រពៃណី។

## សារៈសំខាន់នៃការចូលរួមរបស់សភា និងសាធារណជន

នៅក្នុងប្រទេសនានា ដែលការចូលរួមរបស់សាធារណជន និងសភា នៅក្នុងដំណើរការនៃការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិដែលមិនត្រូវបានអនុវត្ត ដំណើរការនេះត្រូវតែមានការលើកទឹកចិត្ត ដោយសារវាជួយពង្រឹងការគាំទ្រពីប្រជាពលរដ្ឋ។ យោងតាមគោលការណ៍ នៅក្នុងប្រទេសប្រជាធិបតេយ្យ អង្គការនីតិប្រតិបត្តិមិនអាចសម្រេចចុះហត្ថលេខាលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគីជាសម្ងាត់ដោយមិនមានការដឹងឮ និងយល់ព្រមពីសភាបានឡើយ។ កិច្ចព្រមព្រៀង

អន្តរជាតិដែលប៉ះពាល់អធិបតេយ្យភាព ដែនដី និងមុខមាត់ជាអន្តរជាតិរបស់ប្រទេស ត្រូវតែមានការពិភាក្សាដេញដោល និងអនុម័តដោយសភា។

នៅក្នុងប្រទេសខ្លះ ដូចជាប្រទេសស្វីស សន្ធិសញ្ញាធំៗគឺត្រូវបានដាក់ក្រោមការធ្វើប្រជាមតិ។ តាមវិធីនេះ ការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងការកែសម្រួលធំៗនៅក្នុងគោលនយោបាយការបរទេសរបស់ប្រទេសនឹងត្រូវបានធានា។ នៅក្នុងប្រទេសស្វីសការធ្វើប្រជាមតិ (សូមអានប្រអប់ទី៦) ចាប់ផ្តើមធ្វើមុនការផ្តល់សច្ចាប័ន។

**ប្រអប់ទី ៦**

### លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ និងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងសំខាន់ៗដទៃទៀត៖ ករណីនៃប្រទេសស្វីស

នៅក្នុងប្រទេសស្វីស សភាសហព័ន្ធ ក្រុមប្រឹក្សាសហព័ន្ធ (រដ្ឋាភិបាល) និងប្រជាពលរដ្ឋចូលរួមនៅក្នុងដំណើរការនៃការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអន្តរជាតិ។ កិច្ចព្រមព្រៀងសំខាន់ៗសម្រាប់ប្រទេស មិនត្រឹមដាក់នៅក្រោមការពិភាក្សាដេញដោលដោយសភាប៉ុណ្ណោះនោះទេ តែថែមទាំងដាក់ឲ្យពិភាក្សាដេញដោលដោយសាធារណៈជនផងដែរ។ ប្រជាពលរដ្ឋអាចបញ្ចេញនូវមតិរបស់ខ្លួន លើកិច្ចព្រមព្រៀងតាមរយៈការធ្វើប្រជាមតិ។ ក្រៅពីនេះ តាមរយៈប្រជាមតិ ប្រជាពលរដ្ឋអាចកំណត់អាណត្តិជូនក្រុមប្រឹក្សាសហព័ន្ធ ក្នុងការចាប់ផ្តើម ឬបញ្ឈប់ការចរចាកិច្ចព្រមព្រៀងនាពេលអនាគត។ ការធ្វើប្រជាមតិ ជាការចាំបាច់ព្រោះបើរដ្ឋាភិបាលចង់ចូលជាសមាជិក នៃ "អង្គការសន្តិសុខរួម ឬនៅក្នុងសហគមន៍ដែលមានប្រជាជាតិច្រើន" (Supranational Community) (មាត្រា១៤០ ខ នៃរដ្ឋធម្មនុញ្ញសហព័ន្ធ)។

### ក្នុងនាមជាអ្នកតំណាងរាស្ត្រ អ្នកអាចធ្វើអ្វីបានខ្លះ

**ការចរចាសន្ធិសញ្ញា**

▷ ធានាថា សភា/គណៈកម្មការពាក់ព័ន្ធរបស់ខ្លួន៖
  - បានចូលរួមជាសមាជិកនៃក្រុមចរចានៅក្នុងដំណើរការចរចា រួមទាំងតំណាងរាស្ត្រមកពីគណបក្សនយោបាយផ្សេងៗផងដែរ។
  - ទទួលយកយោបល់ពីសង្គមស៊ីវិល ជាពិសេសពីអង្គការស្រាវជ្រាវ និងតស៊ូមតិដែលពាក់ព័ន្ធនឹងបញ្ហានេះ។
  - អាចបញ្ចេញនូវទស្សនៈរបស់ខ្លួនជាផ្លូវការ និងទាន់ពេលវេលាដល់រដ្ឋាភិបាលដើម្បីធានាថាទុក្ខកង្វល់ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋត្រូវបានបញ្ចូល។

### ការវិភាគពីផលប៉ះពាល់

- ធានាថា សភាទទួលបាន និងអាចពិភាក្សានូវអត្ថបទវិភាគលំអិតអំពីផលប៉ះពាល់ដែលអាចកើតមាន (ទាំងរយៈពេលមធ្យម និងរយៈពេលវែង) មកលើនយោបាយសេដ្ឋកិច្ច សង្គម បរិស្ថាន ឬបញ្ហាផ្សេងទៀតដែលមាននៅក្នុងសន្ធិសញ្ញា។

### ការផ្តល់សច្ចាប័ន

- ធានាថា សភាត្រូវបានស្នើសុំតាមពេលវេលាដ៏សមស្រប ក្នុងការផ្តល់សច្ចាប័នលើសន្ធិសញ្ញា។
- ធានាឲ្យមានភាពស៊ីសង្វាក់គ្នារវាងសន្ធិសញ្ញាដែលត្រូវផ្តល់សច្ចាប័ន ជាមួយនឹងច្បាប់ជាតិ ដោយធ្វើការកែសម្រួលនូវបញ្ញត្តិច្បាប់ជាតិមួយចំនួន ឬប្រសិនបើចាំបាច់ និងអាចធ្វើទៅបាន ត្រូវទុកខបម្រុង ឬខសម្រាប់បកស្រាយទាក់ទងនឹងកិច្ចព្រមព្រៀងអន្តរជាតិ។

### ការពិនិត្យឡើងវិញនូវខបម្រុង និងខបកស្រាយ

- ធានាថា សុពលភាពនៃខបម្រុង និងខបកស្រាយដែលប្រទេសអ្នកស្នើសុំត្រូវតែធ្វើការពិនិត្យឡើងវិញជាប្រចាំនៅក្នុងគោលនយោបាយជាតិ ស្តីពីសន្តិសុខរបស់ប្រទេស។

# ជំពូកទី ៦

# តួនាទីរបស់សង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ

វិស័យសន្តិសុខកាន់តែមានលក្ខណៈរីកធំ និងស្មុគ្រស្មាញឡើងៗ។ នេះវាបង្កនូវបញ្ហាប្រឈមធំៗចំពោះសភា ពីព្រោះជាញឹកញាប់ពួកគេខ្វះនូវធនធាន និងបុគ្គលិកជំនាញដែលខានមិនបានសម្រាប់ជួយពួកគេ ធ្វើការត្រួតពិនិត្យវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាលទ្ធផលមានស្ថាប័នជាច្រើន ត្រូវបានបង្កើតឡើងដើម្បីបំពេញនូវតួនាទីរបស់ពួកគេ ទោះបីជាសភាមានតួនាទីកំពូលក្នុងការកំណត់ឲ្យរដ្ឋាភិបាលមានគណនេយ្យភាពហើយក៏ដោយ។ ទាំងសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយអាចរួមចំណែកដល់ការត្រួតពិនិត្យរបស់សភា ទៅលើវិស័យសន្តិសុខនៅក្នុងក្របខណ្ឌដែលកំណត់ដោយសភា។

## សង្គមស៊ីវិល

ពាក្យថាសង្គមស៊ីវិល គឺសំដៅលើអង្គការស្វ័យយ័តដែលម្យ៉ាង ស្ថិតនៅចន្លោះស្ថាប័នរដ្ឋ និងជីវិតឯកជននៃបុគ្គលម្នាក់ៗ និងម្យ៉ាងទៀតស្ថិតនៅចន្លោះសហគមន៍។ សង្គមស៊ីវិលមានសមាគមស្ម័គ្រចិត្ត និងចលនាពិសេសនានា ឧទាហរណ៍ដូចជា អង្គការ និងក្រុមមនុស្សដែលតំណាងឲ្យផលប្រយោជន៍សង្គម ហើយដែលធ្វើនូវសកម្មភាពផ្សេងៗ។ ផ្នែកខាងក្រោមនេះនឹងពិនិត្យមើលថា ហេតុអ្វីបានជាសង្គមស៊ីវិល គួរតែមានតួនាទីនៅក្នុងការធានានូវគណនេយ្យភាពរបស់វិស័យសន្តិសុខ តើតួនាទីនេះមានអ្វីខ្លះ ហើយថាតើសង្គមស៊ីវិលត្រូវរួមចំណែកដូចម្តេចខ្លះដល់ការត្រួតពិនិត្យរបស់សភាទៅលើវិស័យសន្តិសុខ។

### សង្គមស៊ីវិល និងលទ្ធិប្រជាធិបតេយ្យ

សង្គមស៊ីវិលមានសារៈសំខាន់ និងជាតំណាងមួយនៃដំណើរការលទ្ធិប្រជាធិបតេយ្យនីយកម្ម និងមានតួនាទីកាន់តែច្រើនឡើង ក្នុងការធ្វើឲ្យលទ្ធិប្រជាធិបតេយ្យដែលបានបង្កើតឡើងដំណើរការបានល្អ។ សង្គមស៊ីវិលចូលរួមយ៉ាងសកម្មក្នុងការក្រើនរំលឹកដល់មេដឹកនាំនយោបាយ ថាវាមានតម្រូវការ និងផលប្រយោជន៍ជាច្រើនដែលអ្នកទាំងនោះ ត្រូវយកចិត្តទុកដាក់នៅពេលដែលពួកគេធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយរដ្ឋ និងការចំណាយថវិកាសាធារណៈ។ ហេតុដូច្នេះហើយ

បានជាសង្គមស៊ីវិលដ៏សកម្មមួយគឺជាតម្រូវការមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ។ សង្គមស៊ីវិលមានសក្តានុពលក្នុងការរក្សាតុល្យភាពជាមួយអំណាចរបស់រដ្ឋប្រឆាំង នឹងរបបផ្តាច់ការនិយម និងតាមរយៈភាពសម្បូរបែបរបស់សង្គមស៊ីវិល វានឹងធានាថា រដ្ឋមិនមែនជាឧបករណ៍បម្រើផលប្រយោជន៍ឲ្យមនុស្សមួយក្រុមណាមួយនោះទេ។

## សង្គមស៊ីវិល និងវិស័យសន្តិសុខ

ក្រុមទាំងឡាយនៅក្នុងសង្គមស៊ីវិល ដូចជា ស្ថាប័នសិក្សា (academic institutions) ក្រុមអ្នកស្រាវជ្រាវ (think tanks) អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល និងអង្គការដែលយកចិត្តទុកដាក់លើបញ្ហាគោលនយោបាយមិនមែនរដ្ឋាភិបាល អាចព្យាយាមយ៉ាងសកម្មដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេច និងគោលនយោបាយពាក់ព័ន្ធនឹងវិស័យសន្តិសុខ។

រដ្ឋាភិបាលអាចលើកទឹកចិត្តការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការពិភាក្សាដេញដោលជាសាធារណៈ អំពីសន្តិសុខជាតិ កងកម្លាំងប្រដាប់អាវុធ ការងារនគរបាល និងការស៊ើបការណ៍សម្ងាត់។ ការពិភាក្សាដេញដោលបែបនេះ តាមពិតជួយពង្រឹងតម្លាភាពរបស់រដ្ឋាភិបាលបន្ថែមទៀត។

## តួនាទីជាក់លាក់ និងធាតុចូលរបស់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវពាក់ព័ន្ធជាមួយវិស័យសន្តិសុខ

អង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាទូទៅជាអង្គការឯកជនមិនរកប្រាក់ចំណេញ។ គោលបំណងរបស់អង្គការទាំងនេះ គឺតំណាងឲ្យបំណងប្រាថ្នា និងផលប្រយោជន៍របស់សង្គមទៅតាមប្រធានបទដ៏ជាក់លាក់។ ចំពោះស្ថាប័នស្រាវជ្រាវពួកគេអាចជាអង្គការ NGOs ឯករាជ្យពីរដ្ឋាភិបាល ឬផ្ទុយទៅវិញ មានទំនាក់ទំនងជាមួយរដ្ឋាភិបាល ឧ. តាមរយៈការទទួលមូលនិធិពីរដ្ឋាភិបាល។

អង្គការ NGOs និងស្ថាប័នស្រាវជ្រាវអាចពង្រឹងការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យរបស់សភា ទៅលើវិស័យសន្តិសុខតាមរយៈ៖

- ✓ ផ្សព្វផ្សាយឯកសារវិភាគ និងព័ត៌មានដោយឯករាជ្យអំពីវិស័យសន្តិសុខ កិច្ចការយោធា និងបញ្ហាការពារជាតិដល់សភា ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជន។
- ✓ ពិនិត្យ និងលើកទឹកចិត្តឲ្យមានការគោរពនីតិរដ្ឋ និងសិទ្ធិមនុស្សនៅក្នុងវិស័យសន្តិសុខ។
- ✓ លើកបញ្ហាសន្តិសុខដែលមានសារៈសំខាន់ដល់សង្គមទាំងមូលនៅក្នុងរបៀបវារៈនយោបាយ។
- ✓ រួមចំណែកកសាងសមត្ថភាពរបស់សភា តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា។
- ✓ ផ្តល់នូវទស្សនៈផ្សេងៗរបស់អ្នកជំនាញ អំពីគោលនយោបាយសន្តិសុខរបស់រដ្ឋាភិបាល

ថវិកា ការពារជាតិ បញ្ហាលទ្ធកម្ម និងធនធាន ការលើកកម្ពស់ការពិភាក្សាដេញដោលជាសាធារណៈ និងការបង្កើតនូវជម្រើសគោលនយោបាយផ្សេងៗ។

- ✓ ផ្តល់មតិឯកទេសផ្សេងៗ អំពីសេចក្តីសម្រេចលើគោលនយោបាយសន្តិសុខជាតិ និងរបៀបដែលត្រូវអនុវត្ត។
- ✓ អប់រំសាធារណៈជន និងធ្វើការសម្របសម្រួលការពិភាក្សាដេញដោល នៅក្នុងវេទិកាសាធារណៈ។

ការធ្វើអន្តរាគមន៍ដោយសង្គមស៊ីវិលនៅអាមេរិកឡាទីន បានបង្ហាញយ៉ាងច្បាស់នូវតួនាទីដ៏សំបូរបែបរបស់អង្គការ NGOs និងមជ្ឈមណ្ឌលស្រាវជ្រាវ នៅក្នុងការត្រួតពិនិត្យវិស័យសន្តិសុខ (សូមអានប្រអប់ទី៧)។

**ប្រអប់ទី ៧**

**សង្គមស៊ីវិលនៅអាមេរិកឡាទីនៈ**

**ឧទាហរណ៍ជាក់ស្តែង អំពីតួនាទី និងសារៈសំខាន់នៃអង្គការសង្គមស៊ីវិល**

ក្រុមសង្គមស៊ីវិលជាច្រើន នៅក្នុងអាមេរិកឡាទីនត្រូវបានបង្កើតឡើង នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ដោយមានគោលបំណងលើកកម្ពស់កិច្ចសន្ទនា រវាងក្រុមស៊ីវិល និងយោធាដោយហេតុថារដ្ឋាភិបាលស៊ីវិល ដែលជាប់ឆ្នោតថ្មី កំពុងព្យាយាមរៀបចំរចនាសម្ព័ន្ធកងកម្លាំងប្រដាប់អាវុធឡើងវិញ។ កិច្ចសន្ទនាទាំងនេះ បានជួយបំបាត់នូវភាពឯកោររបស់កងកម្លាំងប្រដាប់អាវុធ និងបានបើកឡើងនូវដំណើរការ ផ្លាស់ប្តូរព័ត៌មានប្រកបដោយវិជ្ជាជីវៈខ្ពស់ រវាងសង្គមស៊ីវិល និងមន្ត្រីជាប់ឆ្នោត និងមេបញ្ជាការយោធាជាន់ខ្ពស់។ ចាប់តាំងពីពេលនោះមក ក្រុមទាំងនេះកាន់តែមានតួនាទីច្រើនឡើងៗ ដោយដើរតួនាទីជាប្រភពដ៏សំខាន់នៃជំនាញស៊ីវិល និងជំនួយបច្ចេកទេសលើបញ្ហាសន្តិសុខ និងការពារជាតិ និងមានតួនាទីកាន់តែធំឡើងនៅក្នុងការត្រួតពិនិត្យគោលនយោបាយ និងថវិកាយោធា។

**ឧទាហរណ៍**

ឧទាហរណ៍មួយ គឺក្រុមអាហ្សង់ទីន SER en 2000 ត្រូវបានបង្កើតឡើងក្រោយពីការប៉ុនប៉ងធ្វើរដ្ឋប្រហារយោធាឆ្នាំ១៩៩០ SER en 2000 ជាដំបូងបានចាប់ផ្តើមបង្កើតជាវេទិកាដើម្បីជម្រុញឲ្យមានកិច្ចសន្ទនារវាងតំណាងរបស់សង្គមស៊ីវិល គណបក្សនយោបាយ និងយោធា។ កិច្ចសន្ទនាទាំងនេះ បង្កើតបានជាមូលដ្ឋានដ៏សំខាន់មួយដែល SER en 2000 បានផ្តល់នូវមតិផ្នែកស៊ីវិលដល់ការរៀបចំពង្រាងច្បាប់សំខាន់ៗ ដែលបង្កើតបានជាក្របខណ្ឌនៃគោលនយោបាយការពារជាតិជាបន្តបន្ទាប់។

ដូចគ្នានេះផងដែរ នៅក្នុងសាធារណៈរដ្ឋដូមីនីក អ្នកជំនាញស៊ីវិលផ្នែកសន្តិសុខ និងការពារជាតិដែលបង្កើតបានជាអង្គការ FLACSO បានធ្វើការជាមួយយោធា ដើម្បីបង្កើតនូវច្បាប់មួយ ដើម្បីធ្វើកំណែទម្រង់នគរបាល ហើយក្រោយមកបានផ្តល់យោបល់ដល់នីតិប្រតិបត្តិ និងសភា នៅពេលដែលពួកគេធ្វើការពិចារណាលើច្បាប់នោះ។

ក្រុមសង្គមស៊ីវិលជាច្រើននៅក្នុងអាមេរិកឡាទីន ធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការការពារជាតិ និងសន្តិសុខ នៅក្នុងសភាជាតិដើម្បី លើកកម្ពស់សមត្ថភាព ផ្នែកបច្ចេកទេសរបស់សភា ក្នុងការត្រួតពិនិត្យ និងតាមដានការបំពេញមុខងាររបស់យោធា។

ក្រុមសង្គមស៊ីវិលរបស់ប្រទេសប៉េរូគឺ Instituto de Estudios Políticos y Estratégicos (IDEPE) ធ្វើការបណ្តុះបណ្តាលតំណាងរាស្ត្រ ស្រីប្រុស និងបុគ្គលិករបស់ពួកគេនៅក្នុងគណៈកម្មការការពារជាតិសភា អំពីការធ្វើថវិកា និងគ្រប់គ្រងថវិកាយោធា។

ក្រុម FLACSO នៅក្នុងប្រទេសកាតេម៉ាឡាបានជួយសភាធ្វើការវិភាគ និងពិចារណាលើច្បាប់មួយចំនួន ដែលប៉ះពាល់យោធា រួមទាំងកំណែទម្រង់ការស៊ើបយកការសម្ងាត់ និងការចូលបម្រើយោធាផងដែរ។

## កង្វះជំនាញស៊ីវិល

ជំនាញស៊ីវិលនៅក្នុងវិស័យការពារជាតិនិងសន្តិសុខនៅមានការខ្វះខាតនៅឡើយនៅក្នុងអាមេរិកឡាទីន។ ឱនភាពនៃជំនាញស៊ីវិលនេះ បានបន្ថយបង្អាក់មិនឲ្យស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិធ្វើការឃ្លាំមើលយោធាប្រកបដោយប្រសិទ្ធភាព។ ទោះដូច្នេះក្តី នៅក្នុងរយៈពេលខ្លីអង្គការសង្គមស៊ីវិល អាចជួយបំពេញនូវកង្វះខាតនេះដោយជួយស្ថាប័នរដ្ឋ និងធ្វើការបណ្តុះបណ្តាលក្រុមគ្រូបង្គោលប្រជាពលរដ្ឋមួយក្រុម។

## បណ្តាញ

មកដល់ពេលនេះ SER en 2000 ថ្មីៗនេះបានបង្កើតនូវបណ្តាញ think tanks និងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់តំបន់មួយដែលឧទ្ទិសការងារ ចំពោះវិស័យសន្តិសុខ និងការពារជាតិ។ បណ្តាញ RESDAL (www.ser2000.org.ar) បានបង្កើតនូវប្រព័ន្ធទិន្នន័យមួយដែលមានឯកសារ និងច្បាប់ទាក់ទងនឹងវិស័យសន្តិសុខ និងការពារជាតិ ព្រមទាំងបានផ្តល់នូវកម្មវិធីនានាសម្រាប់ប្រជាពលរដ្ឋស៊ីវិលធ្វើការសិក្សាស្រាវជ្រាវ និងធ្វើទស្សនកិច្ចសិក្សានៅក្នុងអង្គការនេះ។

*ប្រភព៖ Chris Sabatini, National Endowment for Democracy, Washington DC, 2002*

*IPU and DCAF – Parliamentary oversight of the security sector, 2003*

## ប្រព័ន្ធផ្សព្វផ្សាយ

ជាទូទៅ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យជួយសាធារណៈជន និងតំណាងអ្នកនយោបាយរបស់ពួកគេនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ពួកគេរួមចំណែកដល់ការត្រួតពិនិត្យសកម្មភាពរបស់ស្ថាប័នទាំង៣របស់រដ្ឋ ហើយអាចមានឥទ្ធិពលទៅលើខ្លឹមសារ និងគុណភាពនៃបញ្ហាដែលបានលើនៅក្នុងការពិភាក្សាដេញដោលដែលជាសាធារណៈជះឥទ្ធិពលមកលើរដ្ឋាភិបាល អ្នកធ្វើអាជីវកម្ម អ្នកសិក្សារៀនសូត្រ និងសង្គមស៊ីវិល។ ដូច្នេះ ប្រព័ន្ធផ្សព្វផ្សាយពត៌មានដោយសេរីគឺជាផ្នែកដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យ។ ប្រអប់ទី៨ លើកឡើងអំពីបញ្ហាដ៏ធំ ដែលអាចជួបប្រទះដោយអ្នកសារព័ត៌មាន ដែលព្យាយាមទិះតៀនរដ្ឋាភិបាល។ ការធានាសន្តិសុខ ជូនអ្នកសារព័ត៌មានគឺជាកត្តាសំខាន់សម្រាប់សេរីភាពនៃសារព័ត៌មាន។

**ប្រអប់ទី ៨**

### ប្រភេទសង្គ្រាមថ្មី៖ គ្រាលំបាកសម្រាប់សេរីភាពនៃសារព័ត៌មាន

"ប្រហែល ១/៣ នៃប្រជាជនក្នុងពិភពលោកកំពុងរស់នៅក្នុងប្រទេស ដែលសេរីភាពនៃសារព័ត៌មានមិនត្រូវបានអនុញ្ញាតទាល់តែសោះ។ (...) យើងត្រូវបែងចែកផងដែរ រវាងអ្នកដែលត្រូវបានសម្លាប់នៅក្នុងតំបន់សង្គ្រាម គឺអ្នកដែលមិនត្រូវបានគេជ្រើសរើសដោយសារតែពួកគេធ្វើជាអ្នកសារព័ត៌មាន និងអ្នកដែលត្រូវបានគេសម្លាប់ដោយចេតនា ពីព្រោះតែពួកគេធ្វើការស៊ើបអង្កេត និងសរសេរអត្ថបទទាក់ទងនឹងបញ្ហារសើប និងបានទិះតៀនការប្រព្រឹត្តតាមអំពើចិត្ត ការកិបកេងប្រាក់ ភាពអយុត្តិធម៌ ឧក្រិដ្ឋកម្ម និងការរកស៊ីរបរទុច្ចរិត។ សង្គ្រាមប្រភេទថ្មីនេះ មិនមែនរវាងកងទ័ពធម្មតា តែរវាងក្រុមភាគតិច ក្រុមមានមនោគមវិជ្ជា ក្រុមសាសនា ឬក្រុមឧក្រិដ្ឋជនបានធ្វើសេចក្តីរាយការណ៍កាន់តែមានគ្រោះថ្នាក់។ ក៏ប៉ុន្តែការស្លាប់ ឬរបួស របស់អ្នកសារព័ត៌មាននៅក្នុងជម្លោះទាំងនេះជានិច្ច គឺមិនមែនកើតឡើងដោយចៃដន្យនោះទេ។ ពេលខ្លះយុទ្ធជនទោះបីជាមកពីទ័ពធម្មតា តែងតែតម្រង់មករកសាក្សីដែលបង្កឲ្យមានការលំបាកដល់ពួកគេ"។

*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០០២*, Reporters Without Borders

នៅក្នុងប្រទេសដែលប្រព័ន្ធផ្សព្វផ្សាយមិនឯករាជ្យ ពីស្ថាប័នរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយងាយនឹងត្រូវបានអ្នកដឹកនាំយកទៅប្រើប្រាស់ ធ្វើជាឧបករណ៍ឃោសនារបស់ពួកគេខ្លាំងណាស់។ ក្នុងករណីនេះ ប្រព័ន្ធផ្សព្វផ្សាយ ពិតជាមិនអាចលើកកម្ពស់តម្លាភាព និងការត្រួតពិនិត្យតាមបែបលទ្ធិប្រជាធិបតេយ្យលើវិស័យសន្តិសុខបាននោះទេ។

ជាមួយការមកដល់នៃបច្ចេកវិទ្យាអ៊ីនធឺណែត ការទទួលបានព័ត៌មានជាផ្លូវការដោយសាធារណៈជនកាន់តែបានច្រើន។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ មាននិន្នាការជាទូទៅឆ្ពោះទៅរកការធ្វើឲ្យមានតម្លាភាព គណនេយ្យភាពសាធារណៈ និងការទទួលព័ត៌មានកាន់តែច្រើនឡើងៗ។ និន្នាការនេះ គួរត្រូវបានលើកទឹកចិត្ត ដោយសារវារួមចំណែកដល់ការពិភាក្សាដេញដោលជាសាធារណៈ ដោយប្រជាពលរដ្ឋ និងមានគុណភាពខ្ពស់អំពីបញ្ហាគោលនយោបាយសំខាន់ៗ និងជួយបង្កើនអភិបាលកិច្ចកាន់តែប្រសើរ។

ប្រព័ន្ធអ៊ីនធឺណែត ក៏មានចំណុចមិនល្អផងដែរ ដោយសារវាអាចត្រូវបានក្រុមជ្រុលនិយមប្រើប្រាស់ដើម្បីផ្សព្វផ្សាយ ជាឧទាហរណ៍ ដូចជាការរើសអើងពូជសាសន៍ និងការស្អប់ខ្ពើមជនជាតិជ្វីប (Prejudice against Jews-Anti-Semitism)។ នៅក្នុងជម្លោះថ្មីៗនេះ ប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដូចជា ស្ថានីយ៍ វិទ្យុ បានផ្តល់នូវវេទិកាសម្រាប់ក្រុមជ្រុលនិយម និងជួយបង្កើតនូវបរិយាកាសនៃភាពស្អប់ខ្ពើមរវាងក្រុមផ្សេងៗនៅក្នុងសង្គម។

## ការប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាទាក់ទងនឹងសន្តិសុខ

យោងតាមទស្សនៈអភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ ប្រព័ន្ធផ្សព្វផ្សាយមានសិទ្ធិប្រមូល និងផ្សព្វផ្សាយព័ត៌មាន អំពីបញ្ហាទាក់ទងនឹងសន្តិសុខ ដែលប៉ះពាល់ផលប្រយោជន៍សាធារណៈ ព្រមទាំងមានតួនាទីក្នុងការផ្តល់នូវព័ត៌មានពិត សុក្រិត និងត្រឹមត្រូវ។

ដូច្នេះ ប្រព័ន្ធផ្សព្វផ្សាយអាចជួយរដ្ឋាភិបាល និងសភាដើម្បីពន្យល់អំពីសេចក្តីសម្រេច និងគោលនយោបាយរបស់ពួកគេដល់ប្រជាពលរដ្ឋ ដែលមានសិទ្ធិទទួលព័ត៌មាន និងចូលរួមផ្តល់គំនិតផ្សេងៗ នៅក្នុងដំណើរការនយោបាយ។ ឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយអាចរួមចំណែកលើកស្ទួយសិទ្ធិទទួលព័ត៌មានរបស់សាធារណៈជន តាមរយៈការផ្សព្វផ្សាយព័ត៌មាន អំពីអ្នកដែលមានមុខងារសាធារណៈនៅក្នុងវិស័យសន្តិសុខ ប្រភេទនៃគោលនយោបាយសន្តិសុខដែលបានអនុម័ត ការតាំងពង្រាយទ័ពនៅបរទេស កិច្ចការយោធា បញ្ហាទាក់ទងនឹងលទ្ធកម្ម សន្ធិសញ្ញានិងកិច្ចព្រមព្រៀងដទៃទៀត តួអង្គដែលពាក់ព័ន្ធ បញ្ហាប្រឈមនៅពេលខាងនៅក្នុងវិស័យសន្តិសុខ និងការពិភាក្សាដេញដោលដែលពាក់ព័ន្ធ។ ទោះដូច្នេះក៏ដោយ ប្រព័ន្ធផ្សព្វផ្សាយអាចទទួលរងនូវការត្រួតពិនិត្យ ឬស្វ័យត្រួតពិនិត្យ ខណៈពេលដែលគោលការណ៍រក្សាព័ត៌មានសម្ងាត់ត្រូវបានធានា។

## ច្បាប់ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ និងបញ្ហាទាក់ទងនឹងសន្តិសុខ

គ្រប់ប្រទេសទាំងអស់ សុទ្ធតែមានច្បាប់ដោះស្រាយបញ្ហា ពាក់ព័ន្ធជាមួយសេរីភាពសារព័ត៌មាន។ គោលការណ៍នេះ មានចែងនៅក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលចែងដូចតទៅថា៖

*IPU and DCAF – Parliamentary oversight of the security sector, 2003*

*"ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការគិតនិងការបញ្ចេញមតិ៖ សិទ្ធិនេះ រួមមានសិទ្ធិសេរីភាព សំដែងមតិ ដោយមិនមានការរំខាន និងសិទ្ធិស្វែងរក ទទួលបាន និងផ្សព្វផ្សាយព័ត៌មាន និងគំនិតទាំងឡាយតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ នានាដោយឥតព្រំដែន"។*

ខណៈពេលដែលគ្មានការឯកភាពគ្នាជាអន្តរជាតិ លើគោលការណ៍ណែនាំថាត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឲ្យសម្រេចបាននូវសេរីភាពនៃការបញ្ចេញមតិនិងត្រូវការពារសេរីភាពនេះ គេគួរកត់សម្គាល់ថា គោលការណ៍អន្តរជាតិដូចបានបញ្ជាក់ខាងលើ មានន័យទូលំទូលាយដោយមិនបានយោងទៅលើ ការហាមឃាត់ណាមួយទាក់ទងនឹងបញ្ហាសន្តិសុខនោះទេ។

**ប្រអប់ទី ៩**

**សេរីភាពនៃសារព័ត៌មានក្រោយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១**

ទិវាសេរីភាពសារព័ត៌មានអន្តរជាតិ ត្រូវបានប្រារព្ធធ្វើរៀងរាល់ឆ្នាំនៅថ្ងៃទី៣ ខែឧសភា។ ប្រធានបទសម្រាប់ទិវាអន្តរជាតិនេះ ឆ្នាំ២០០២ និយាយអំពីផលប៉ះពាល់ដែលអាចកើតមាន ចំពោះសេរីភាពនៃសារព័ត៌មាន នៃវិធានការដែលប្រទេសនានាអាចប្រកាន់យកដើម្បីពង្រឹង សន្តិសុខជាតិ និងអន្តរជាតិបន្ទាប់ពីមានការវាយប្រហារភេរវកម្ម ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១។

លោក Koïchiro Matsuura អគ្គនាយកនៃអង្គការយូនីស្កូ បានមានប្រសាសន៍ថា៖ "មានភាពតានតឹងយ៉ាងច្បាស់រវាងការអនុវត្តសេរីភាពជាមូលដ្ឋាន និងតម្រូវការកាន់តែច្រើនក្នុង ការរក្សាសន្តិសុខនៅចំពោះមុខអំពើភេរវកម្ម ក៏ប៉ុន្តែគោលគំនិតទាំងមូលនៃយុទ្ធនាការប្រឆាំង ភេរវកម្មត្រូវមានការគិតគូរចំពោះសន្តិសុខនៃសេរីភាពរបស់ពួកយើងផងដែរ"។

*ប្រភព៖ The World of Parliaments, លេខ ៦, ខែឧសភា ឆ្នាំ២០០២, IPU*

## សភាផ្សព្វផ្សាយបញ្ហាសន្តិសុខដល់សាធារណជន

យោងតាមគោលការណ៍នៃអភិបាលកិច្ចល្អ ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យអាច មានប្រសិទ្ធភាពលុះត្រាតែសាធារណជន មានការយល់ដឹងអំពីបញ្ហាធំៗ និងមានការបើកទូលាយ អោយមានការពិភាក្សាដេញដោលក្នុងសភា។

ប្រសិទ្ធភាពនៃការផ្សព្វផ្សាយដល់សាធារណជនអំពីបញ្ហាសន្តិសុខ គឺវាអាស្រ័យលើព័ត៌មាន ដ៏សម្បូរបែបនិងសុក្រិតដែលត្រូវបញ្ចេញទៅឲ្យប្រជាពលរដ្ឋដោយរដ្ឋាភិបាល និងសភា។ សភាត្រូវ ដើរតួនាទីដ៏សកម្មក្នុងការផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាពដល់សាធារណជន ដើម្បីពួកគេ យល់អំពីស្ថានភាព និងលទ្ធផលនៃ ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសភា។

## ការអោយសាធារណជនទទួលបាននូវឯកសារនានា

វិធីសាស្ត្រមួយសម្រាប់សភាធ្វើការផ្សព្វផ្សាយព័ត៌មាន អំពីបញ្ហាសន្តិសុខដល់សាធារណជន ប្រកបដោយប្រសិទ្ធភាព គឺសភាអាចសហការជាមួយរដ្ឋាភិបាល ឬធ្វើការងារនេះតែឯកឯងដោយ ចងក្រងព័ត៌មានទាំងនេះនៅក្នុងឯកសារ និង/ឬចុះផ្សាយនៅលើគេហទំព័ររបស់ខ្លួន។

**ប្រអប់ទី១០**

### គេហទំព័រសភា

មកដល់ខែឧសភា ឆ្នាំ២០០២ មានអង្គសភាចំនួន២៤៩អង្គ នៅក្នុងប្រទេសចំនួន ១៨០ប្រទេស (សភាចំនួន៦៩ មានពីរកម្រិត)។ IPU បានដឹងថា មានគេហទំព័រសភាចំនួន១៦៥ នៅក្នុងប្រទេសចំនួន ១២៨ប្រទេស (អង្គសភានីមួយៗនៅក្នុងសភាទាំងពីរកម្រិតមានគេហទំព័រ ដោយឡែក)។ គោលការណ៍ណែនាំអំពីខ្លឹមសារ និងរចនាសម្ព័ន្ធរបស់គេហទំព័រសភាដែលបាន អនុម័តដោយក្រុមប្រឹក្សា IPU ក្នុងខែឧសភា ឆ្នាំ២០០០ គេអាចបើកមើលបាននៅលើគេហទំព័រ IPU៖ http://www.ipu.org.។

ឧទាហរណ៍ ឯកសារទាក់ទងនឹងព័ត៌មាន ស្តីពីបញ្ហានៃវិស័យសន្តិសុខដែលអាចធ្វើការ ផ្សព្វផ្សាយដល់សាធារណ:ជនមាន៖

- ✓ ឯកសារយុទ្ធសាស្ត្រសំខាន់ៗ ដូចជាគោលនយោបាយជាតិស្តីពីសន្តិសុខ។
- ✓ ថវិកាការពារជាតិ (មិនបញ្ចូលមូលនិធិសម្ងាត់)។
- ✓ សេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាដេញដោលធំៗទាំងអស់នៅក្នុងសភា ពាក់ព័ន្ធជាមួយវិស័យសន្តិសុខ សេចក្តីសម្រេច ញត្តិ ច្បាប់ ។ល។
- ✓ កំណត់ហេតុរបស់កិច្ចប្រជុំ និងការពិភាក្សាដេញដោល (គណ:កម្មការ) សភាទាំងអស់ ទាក់ទងនឹងបញ្ហាសន្តិសុខ (លើកលែងកិច្ចប្រជុំបិទទ្វារ) ក្នុងនោះមានរបាយការណ៍អំពី វិសាលភាព និងលក្ខខណ្ឌការងារ (ToR) នៃសវនការបិទទ្វារនោះ។
- ✓ ការបោះពុម្ពផ្សាយទាក់ទងនឹងការស៊ើបអង្កេតរបស់សភា ទាក់ទងនឹងបញ្ហាសន្តិសុខ។
- ✓ របាយការណ៍សភាប្រចាំឆ្នាំ ឬរបាយការណ៍ពិនិត្យឡើងវិញ អំពីការបំពេញមុខងាររបស់ សេវាសន្តិសុខទាំងអស់។
- ✓ របាយការណ៍របស់ការិយាល័យដោះស្រាយពាក្យបណ្តឹង ឬរបាយការណ៍របស់អគ្គសវនករ ទាក់ទងនឹងវិស័យសន្តិសុខ។ ការិយាល័យដោះស្រាយបណ្តឹងអាចមិនបានអនុញ្ញាតឲ្យ សរសេររបាយការណ៍ទាក់ទងនឹងការស៊ើបអង្កេតពិសេសខ្លះ តែត្រូវបានស្នើសុំឲ្យដាក់ជូន របាយការណ៍ទៅគណ:កម្មការសភាមួយចំនួន។ រដ្ឋាភិបាលត្រូវមានរបាយការណ៍ដាក់ជូន

សភាអំពីវិធានការដែលខ្លួនប្រកាន់យក ទៅតាមរបាយការណ៍របស់មន្ត្រីរដ្ឋដោះស្រាយបណ្តឹង ឬអគ្គសវនករ។

- ✓ ព័ត៌មានអំពីកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី។
- ✓ ព័ត៌មានពីរបៀបដែលតំណាងរាស្ត្រនីមួយៗ ឬគណបក្សនយោបាយនៅក្នុងសភាធ្វើការបោះឆ្នោតលើបញ្ហាសន្តិសុខ (ដូចជា ថវិកា ការចូលរួមជាមួយសម្ព័ន្ធមិត្តអន្តរជាតិ បញ្ហាជ្រើសរើសទ័ព បញ្ហាលទ្ធកម្ម)។
- ✓ ច្បាប់ស្តីពីសេរីភាពនៃព័ត៌មាន។

## ការលើកទឹកចិត្តចំពោះ ការចូលរួមរបស់សាធារណជននៅក្នុងការងារសភា

ការបញ្ជូនព័ត៌មានតែម្ខាង (ពីសភា ឬពីរដ្ឋាភិបាលទៅសាធារណជន) មិនគ្រប់គ្រាន់ទេ។ សភាត្រូវផ្តល់ដល់សាធារណជននូវលទ្ធភាព នៃការប្រាស្រ័យទាក់ទងជាមួយពួកគេ អំពីបញ្ហាសន្តិសុខ។ ការបញ្ជូនព័ត៌មាន ឬការសន្ទនាទៅវិញទៅមក វាសំខាន់ខ្លាំងណាស់ ពីព្រោះ៖

- ✓ វាធានាឲ្យមានការចូលរួម និងការត្រួតពិនិត្យជាអចិន្ត្រៃយ៍ ពីប្រជាពលរដ្ឋ។
- ✓ វាបង្កើននូវទំនុកចិត្តរបស់សាធារណជន មកលើការ បំពេញការងារ របស់សភា។
- ✓ វាធ្វើឲ្យមានការត្រួតពិនិត្យលើការគ្រប់គ្រងមិនត្រឹមត្រូវ (ឧ.តាមរយៈមន្ត្រីរដ្ឋដោះស្រាយបណ្តឹងរបស់សភា)។
- ✓ វាបង្កើននូវការគាំទ្រពីសាធារណជន និងភាពស្របច្បាប់របស់ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាល និងស្ថិរភាពប្រជាធិបតេយ្យ។

ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក អាចត្រូវបានពង្រឹងតាមរយៈផ្នែកព័ត៌មានសភា សវនការ និងអង្គភាពតាមដានព័ត៌មាន កិច្ចពិភាក្សាតាមទូរទស្សន៍ និងតាមការផ្ញើលិខិត តាមអ៊ីម៉េលទៅសមាជិកគណៈកម្មការផ្នែកស្រាវជ្រាវរបស់សភា ។ល។

**ប្រអប់ទី ១១**

## សភា និងប្រព័ន្ធផ្សព្វផ្សាយ

"សភាអញ្ជើញតំណាងរាស្ត្រ ឲ្យធ្វើការពិចារណាជាបន្ទាន់នូវវិធានការទាំងឡាយដើម្បីៈ

I. ធានានូវការបើកចំហរបស់ការងារសភារួមទាំងកិច្ចប្រជុំគណៈកម្មការសភា និងដើម្បីធ្វើការពិចារណានូវបញ្ហានេះ មិនត្រឹមជាបញ្ហានៃគោលនយោបាយនៃការផ្សព្វផ្សាយប៉ុណ្ណោះនោះទេ តែថែមទាំងជាអាទិភាពនយោបាយដ៏សំខាន់ដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើការបំពេញមុខងាររបស់លទ្ធិប្រជាធិបតេយ្យផងដែរ។

II. ប្រើប្រាស់នូវវិធីសាស្ត្រនៃការផ្សព្វផ្សាយដែលធ្លាប់ធ្វើពីមុនៗ និងបច្ចេកវិទ្យាព័ត៌មានថ្មីជាពិសេសៈ

ក. ដោយផ្តល់នូវលក្ខខណ្ឌការងារដ៏ល្អបំផុត ដល់ប្រព័ន្ធផ្សព្វផ្សាយ និងជាពិសេសដល់អ្នកនាំពាក្យសភា។

ខ. ដោយធានានូវការផ្សព្វផ្សាយព័ត៌មានឲ្យបានលឿនអំពី ការពិភាក្សាដេញដោលតាមរយៈការចេញផ្សាយនូវកំណត់ហេតុ និងរបាយការណ៍ នៃការពិភាក្សាដេញដោលរបស់សភា។

គ. ដោយបង្កើតសេវាអនឡាញ (on-line) សម្រាប់ធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកដោយផ្ទាល់ទៅដល់អ្នកសារព័ត៌មាន និងសាធារណជន។

ឃ. ដោយផ្តល់នូវការទទួលបានដោយពេញលេញនូវឯកសារសភា ដើម្បីឲ្យមានការពិភាក្សា ជាសាធារណៈ មុនមានការបោះឆ្នោតអនុម័តច្បាប់។

III. ឆ្លៀតយកឱកាស ដើម្បីទទួលយកយោបល់ពីអ្នកជំនាញអំពីការផ្សព្វផ្សាយព័ត៌មាន។

IV. ធ្វើឲ្យអ្នកមិនមែនជាអ្នកជំនាញ អាចទទួលបាននូវអត្ថបទច្បាប់ កាន់តែច្រើន។

V. ប្រកាន់យកវិធានការដ៏ចាំបាច់ ដើម្បីធ្វើឲ្យតំណាងរាស្ត្រខ្លួនឯងបានចូលរួមកាន់តែច្រើនឡើងនៅក្នុងកិច្ចពិភាក្សាដេញដោល ដែលកំណត់នូវនីតិវិធី ដែលអាចពន្លឿនការធ្វើសេចក្តីសម្រេច។

VI. នៅក្នុងសេវាព័ត៌មាន និងការធ្វើទំនាក់ទំនងលើកទឹកចិត្តសភាឲ្យផ្សព្វផ្សាយច្បាប់ទាំងឡាយនិងពន្យល់ទិដ្ឋភាពសំខាន់ៗនៃច្បាប់ដល់អ្នកសារព័ត៌មានដែលមានការពាក់ព័ន្ធបំផុត។

VII. រៀបចំសិក្ខាសាលាសម្រាប់អ្នកសារព័ត៌មាន អំពីការងារសភាដោយមានគោលបំណងពន្យល់ដល់ពួកគេឲ្យបានយល់ច្បាស់ពីនីតិវិធីច្បាប់ និងនីតិវិធីសភា និងដើម្បីឲ្យពួកគេយល់ដឹងឲ្យបានច្បាស់ថែមទៀតនូវទំនាក់ទំនងរវាងសភា និងស្ថាប័នអន្តរជាតិ។ អ្នកសារព័ត៌មានមកពីកាសែតក្នុងស្រុក និងតំបន់ និងទស្សនាវដ្តី គួរទទួលបាននូវការយកចិត្តទុកដាក់ពិសេស។

VIII. បង្កើតនូវបណ្តាញផ្សព្វផ្សាយព័ត៌មានតាមអ៊ីនធឺណែត ដែលអាចឲ្យប្រជាពលរដ្ឋធ្វើការប្រាស្រ័យទាក់ទងទៅវិញទៅមក ជាមួយទាំងតំណាងរាស្ត្រ និងសេវាព័ត៌មានរបស់សភា។

IX. លើកទឹកចិត្តឲ្យមានការបង្កើតនូវប៉ុស្តិ៍ទូរទស្សន៍ឯករាជ្យ ដែលធ្វើការផ្សព្វផ្សាយការងាររបស់សភាដូចជានៅក្នុងប្រទេសមួយចំនួននៅក្នុងទ្វីបអឺរ៉ុប សហរដ្ឋអាមេរិក និងកាណាដា។

X. ជួយប្រព័ន្ធផ្សព្វផ្សាយទាំងនោះ ដែលខិតខំផ្សព្វផ្សាយនូវព័ត៌មានប្រកបដោយគុណភាពខ្ពស់ ដោយឈរលើមូលដ្ឋានឯករាជ្យពេញលេញ និងដែលទទួលរងនូវការជិតបិទទ្វារដោយសារកម្លាំងទីផ្សារ”។

*ប្រភព៖ សេចក្តីសម្រេចលេខ ១១៤២ (១៩៩៧) នៃមហាសន្និបាតនៃក្រុមប្រឹក្សាសភាអឺរ៉ុប*

ការចូលរួមពីសាធារណជន មានសារៈសំខាន់ណាស់សម្រាប់ស្ថិរភាព នៃប្រព័ន្ធប្រជាធិបតេយ្យរយៈពេលវែង។ កម្រិតនៃការចូលរួមមានមិនដូចគ្នានោះទេ ពីប្រទេសមួយទៅប្រទេសមួយទៀត។ សភាខ្លះអនុញ្ញាតឲ្យសាធារណជន ចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការសភា។ នេះសំខាន់ខ្លាំងណាស់សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលម្នាក់ៗ ដែលមានចំណាប់អារម្មណ៍ចង់ចេះចង់ដឹងអំពីដំណើរការធ្វើច្បាប់។ ទោះបីជាការចូលរួមបែបនោះមិនបានផ្តល់ដល់អ្នកដែលចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការសភានូវសិទ្ធិធ្វើអន្តរាគមន៍ផ្សេងៗក៏ដោយ ក៏វត្តមានរបស់ពួកគេពិតជាមានតម្លៃខ្លាំងមែនទែន។

## ក្នុងនាមជាតំណាងរាស្ត្រ អ្នកអាចធ្វើអ្វីបានខ្លះ

### ការផ្តល់យោបល់លើគោលនយោបាយ ដោយតួអង្គមិនមែនជាស្ថាប័ន

- ត្រូវធានាថា មានយន្តការស្រាប់ដើម្បីឲ្យសភាទទួលអត្ថប្រយោជន៍ ពីការផ្តល់មតិយោបល់ពីតំណាងសង្គមស៊ីវិល នៅក្នុងការងាររបស់ខ្លួន ពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខ។
- បើអាចធ្វើទៅបាន ជម្រុញឲ្យមានការអនុម័តច្បាប់ ដែលអនុញ្ញាតឲ្យស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ ចូលរួមចំណែកជាមួយការងាររបស់គណៈកម្មការសភា ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយបញ្ហាសន្តិសុខ។

### ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន

- ត្រូវធានាថា សភាមានគោលនយោបាយស្តីពីទំនាក់ទំនងដ៏សកម្មជាមួយសាធារណជន ពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់សន្តិសុខ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យនេះ។

**ទំនាក់ទំនងរវាងសន្តិសុខ និងសេរីភាពសារព័ត៌មាន**

- ត្រូវធានាថា សេរីភាពសារព័ត៌មានត្រូវបានលើកកម្ពស់នៅក្នុងច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្តែងពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខ និងត្រូវធានាថា ការដាក់កំហិតណាមួយវាមិនបានរំលោភលើគោលការណ៍សិទ្ធិមនុស្សអន្តរជាតិនោះទេ។
- ត្រូវធានាឲ្យមានច្បាប់ស្តីពីសេរីភាពនៃព័ត៌មាន។

# ជំពូកទី ៧

# ទស្សនៈវិស័យយេនឌ័រស្តីពីគោលនយោបាយសន្តិសុខ

បញ្ហាសមភាពយេនឌ័រ គឺជាកង្វល់សាធារណៈជនថ្មីមួយនាពេលចុងក្រោយនេះ។ បច្ចុប្បន្ននេះ សមភាពយេនឌ័រ ត្រូវបានគេចាត់ទុកថាជាផ្នែកមួយដ៏សំខាន់ នៅក្នុងទំនាក់ទំនងជាមួយបញ្ហាសន្តិសុខផងដែរ នេះមិនមែនដោយសារតែភាគច្រើននៃអ្នកទាំងនោះជាស្ត្រី និងកុមារ ដែលជាជនភៀសខ្លួន និងជនផ្លាស់ទីលំនៅ ត្រូវបានប៉ះពាល់ដោយជម្លោះប្រដាប់អាវុធនោះទេ តែដោយសារស្ត្រីតំណាងឲ្យជាងពាក់កណ្តាលប្រជាជនពិភពលោក។ អ្នកទាំងនោះ មានសិទ្ធិស្មើគ្នាជាមួយបុរស និងបានចូលរួមចំណែកយ៉ាងច្រើនដល់ការដោះស្រាយបញ្ហាសន្តិសុខ។ ទេពកោសល្យ និងទស្សនៈវិស័យរបស់ស្ត្រី នឹងនាំទៅរកការឆ្លើយតបចំពោះបញ្ហាប្រឈមពាក់ព័ន្ធជាមួយសន្តិសុខ ដែលមានលក្ខណៈគិតគូរកាន់តែច្រើន ចំពោះប្រជាពលរដ្ឋ និងស្របគ្នាជាមួយវិធីសាស្ត្រស្តីពីសន្តិសុខមនុស្ស ដូច្នេះវាកាន់តែមាននិរន្តរភាព។ ដូច្នេះ នៅពេលគេគិតពីសមភាពយេនឌ័រនៅក្នុងគោលនយោបាយសន្តិសុខ វាសំខាន់ខ្លាំងណាស់ដែលត្រូវគិតគូរបញ្ហានេះ តាមវិធី២យ៉ាងខុសៗគ្នា៖ ទី១ គោលនយោបាយសន្តិសុខ ត្រូវផ្តោតលើ និងធ្វើការដោះស្រាយនូវបញ្ហារសើបទាក់ទងនឹងយេនឌ័រ។ ដំណោះស្រាយដែលអាចធ្វើទៅបាន គឺត្រូវដាក់ចេញនូវរចនាសម្ព័ន្ធដើម្បីធានាឲ្យមានការគោរពសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី។ ទី២ វាសំខាន់ខ្លាំងណាស់ក្នុងការជម្រុញការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតទាំងអស់នៃការធ្វើសេចក្តីសម្រេចចិត្ត និងនៅក្នុងគ្រប់ផ្នែកដែលទាក់ទងនឹងគោលនយោបាយសន្តិសុខ។

## ស្ត្រី និងដំណោះស្រាយជម្លោះ

ការដោះស្រាយជម្លោះ ការរក្សាសន្តិភាព និងការកសាងសន្តិភាពមិនត្រឹមមានការពាក់ព័ន្ធជាមួយអ្នកដែលចូលរួមនៅក្នុងសង្គ្រាមដោយផ្ទាល់ ឬជម្លោះប្រដាប់អាវុធដោយផ្ទាល់ ដែលភាគច្រើននៃអ្នកទាំងនោះគឺជាបុរសនោះទេ តែស្ត្រីក៏មានតួនាទីដ៏សំខាន់ផងដែរ។ ក៏ប៉ុន្តែវត្តមានរបស់ស្ត្រីនៅឯតុចរចាសន្តិភាព តែងតែត្រូវបានគេបំភ្លេចចោល សូម្បីនៅក្នុងពេលមានសង្គ្រាម ឬជម្លោះប្រដាប់អាវុធក៏ដោយ ពួកគេត្រូវពុះពារតួនាទីយេនឌ័រជាប្រពៃណី និងចាប់យកការទទួលខុសត្រូវដែលជាធម្មតាជាកិច្ចការរបស់បុរស។ ទោះដូច្នេះក្តី ស្ត្រីត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងថាបានរួមចំណែកនូវជំនាញដ៏សំខាន់ មានទស្សនៈវិស័យ និងគោលគំនិតល្អៗជាច្រើន។ ជាក់ស្តែង

ការចូលរួមដោយផ្ទាល់របស់ស្ត្រី នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងដំណោះស្រាយជម្លោះ និងសកម្មភាពគាំទ្រសន្តិភាព វាតម្រូវឲ្យមានការផ្លាស់ប្តូរនូវចក្ខុវិស័យជាប្រពៃណីនៃតួនាទីរបស់បុរស និងស្ត្រីនៅក្នុងសង្គម និងនៅក្នុងស្ថានភាពមានជម្លោះ។

**ប្រអប់ទី ១២**

## យេនឌ័រនៅក្នុងដំណើរការសន្តិភាព

"រាល់ដំណើរការសន្តិភាពណាមួយ ដែលមើលរំលងតម្រូវការនិងតួនាទីរបស់ស្ត្រី គឺជាដំណើរការខុសពីធម្មតា ដូច្នេះវាមិនមានស្ថិរភាព"។ ... "ក្នុងអំឡុងអន្តរកាលក្រោយជម្លោះ ការផ្តល់សិទ្ធិអំណាច ដល់ស្ត្រីមានសារៈសំខាន់ខ្លាំងណាស់ដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ស្ត្រីក៏ដូចជាបុរសដែរ អ្នកទាំង២គឺជាជនរងគ្រោះ និងជាតួអង្គនៅក្នុងសង្គ្រាម និងជម្លោះប្រដាប់អាវុធ ក៏ប៉ុន្តែជាធម្មតាពួកគេមានវិធីសាស្ត្រ និងជំនាញខុសៗគ្នា។ នៅក្នុងអំឡុងពេលមានសង្គ្រាម ស្ត្រីចូលរួមនៅក្នុងសកម្មភាពថ្មីៗ និងដើរតួនាទីថ្មីរួមទាំងការទទួលខុសត្រូវកាន់តែច្រើនឡើង។ ទោះបីជាមានការផ្លាស់ប្តូរដូច្នេះក្តី ស្ត្រីជាញឹកញាប់ត្រូវបានគេបំភ្លេចនៅក្នុងការកសាងសន្តិភាពក្រោយពេលមានជម្លោះ ទាំងនៅក្នុងសង្គមដែលងើបពីជម្លោះ និងទាំងនៅក្នុងការបង្កើតនិងអនុវត្តនូវយុទ្ធសាស្ត្រ ស្តីពីការកសាងសន្តិភាពដោយប្រតិបត្តិការរក្សា សន្តិភាពអន្តរជាតិ"។

*ការគិតគូរបញ្ហាយេនឌ័រនៅក្នុងសន្តិសុខមនុស្ស៖*
*ពីការមិនរាប់បញ្ចូលស្ត្រី ទៅជាការធ្វើការសមាហរណកម្មស្ត្រី*
*ក្នុងដំណើរការកសាង សន្តិភាព ២០១១ វិទ្យាស្ថានកិច្ចការអន្តរជាតិ ប្រទេសន័រវេ*

ប្រអប់លេខ១៣ ជាខ្លឹមសារដកស្រង់ចេញពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៣២៥ (២០០០) ដែលគូសបញ្ជាក់អំពីអត្ថប្រយោជន៍ នៃការផ្លាស់ប្តូរទស្សនៈលើស្ត្រី ថាជាជនរងគ្រោះនៃជម្លោះ (រួមទាំងអំពើហិង្សា និងការចាប់រំលោភស្ត្រី ថាជាឧបករណ៍នៃសង្គ្រាម) ទៅរកទស្សនៈដែលស្ត្រីជាតួអង្គនៅក្នុងដំណោះស្រាយជម្លោះកសាងសន្តិភាព និងរក្សាសន្តិភាព ដោយឈរស្មើភាពគ្នាជាមួយបុរសដែរ។ ការផ្លាស់ប្តូរនូវទស្សនៈនេះ មានន័យថាជាការពិនិត្យមើលនូវសកម្មភាព និងតួនាទីរបស់ស្ត្រី និងបុរសមុនក្នុងអំឡុងពេល និងក្រោយពេលសង្គ្រាម ឬជម្លោះប្រដាប់អាវុធ។ វាមានន័យថាសមភាពយេនឌ័រ និងបញ្ហាយេនឌ័រមានកន្លែងមួយរបស់វា តាំងពីដំណាក់កាលដំបូងនៃការកំណត់គោលនយោបាយ ទាំងគោលនយោបាយជាតិ និងអន្តរជាតិ និងនៅក្នុងច្បាប់ដែលពាក់ព័ន្ធ។

**ប្រអប់ទី ១៣**

## ទស្សនៈវិស័យយេនឌ័រស្តីពីប្រតិបត្តិការ និងដំណើរការសន្តិភាព

ក្រុមប្រឹក្សាសន្តិសុខ (...)

"៧. ជម្រុញឲ្យរដ្ឋជាសមាជិកបង្កើននូវការគាំទ្រហិរញ្ញវត្ថុ បច្ចេកទេស និងភស្តុភា ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីធ្វើការបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័រ ក្នុងនោះមានមូលនិធិសម្រាប់ស្ត្រីរបស់អង្គការសហប្រជាជាតិ មូលនិធិកុមារអង្គការសហប្រជាជាតិ និងការិយាល័យឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន និងអង្គការពាក់ព័ន្ធដទៃទៀត។

៨. អំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ នៅពេលធ្វើការចរចា និងអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ត្រូវប្រកាន់យកទស្សនៈយេនឌ័រ មានដូចជា៖ (ក) តម្រូវការពិសេសរបស់ស្ត្រី និងក្មេងស្រីក្នុងអំឡុងពេលធ្វើមាតុភូមិនិវត្តន៍ និងភើទីលំនៅ និងសម្រាប់ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងការកសាងប្រទេសក្រោយជម្លោះ។ (ខ) វិធានការដែលគាំទ្រគំនិតផ្តួចផ្តើមសន្តិភាពរបស់ស្ត្រី និងការចូលរួមរបស់ជនជាតិដើមភាគតិចសម្រាប់ដោះស្រាយជម្លោះ ហើយត្រូវឲ្យស្ត្រីចូលរួមនៅក្នុងគ្រប់យន្តការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទាំងអស់។ (គ) វិធានការដែលធានានូវការការពារ និងគោរពសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រី ជាពិសេសដោយហេតុថា ពួកគេត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងមានទំនាក់ទំនងជាមួយប្រព័ន្ធបោះឆ្នោត នគរបាល និងតុលាការ (...)។

១៥. សំដែងនូវឆន្ទៈដើម្បីធានាថា បេសកកម្មរបស់ក្រុមប្រឹក្សាសន្តិសុខ ត្រូវមានការគិតគូរខ្ពស់ពីបញ្ហាយេនឌ័រ និងសិទ្ធិរបស់ស្ត្រីតាមរយៈការពិគ្រោះយោបល់ជាមួយក្រុមស្ត្រីក្នុងស្រុក និងអន្តរជាតិ (...)"។

*ខ្លឹមសារដកស្រង់ចេញពីសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ*
*លេខ១៣២៥ (២០០០) អនុម័តថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០*

ស្របជាមួយសេចក្តីសម្រេចចិត្តលេខ១៣២៥(២០០០) អគ្គលេខាធិការអង្គការសហប្រជាជាតិបានដាក់ចេញរបាយការណ៍មួយស្តីពី "ស្ត្រី សន្តិភាព និងសន្តិសុខ" (ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០២)។ របាយការណ៍នេះ ពាក់ព័ន្ធជាមួយផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធទៅលើស្ត្រី និងក្មេងស្រី ក្របខណ្ឌច្បាប់អន្តរជាតិ ការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការសន្តិភាព ប្រតិបត្តិការរក្សាសន្តិភាព ប្រតិបត្តិការមនុស្សធម៌ ការកសាង និងស្តារប្រទេសឡើងវិញ ក៏ដូចជាការរំសាយអាវុធ ការកាត់បន្ថយកងទ័ព និងការធ្វើសមាហរណកម្ម។ លក្ខខណ្ឌខ្លះរបស់សេចក្តីសម្រេចត្រូវបានបញ្ចូលទៅក្នុងអនុសាសន៍នៅចុងបញ្ចប់នៃជំពូកនេះ។

## ស្ត្រីនៅក្នុងគណៈកម្មការការពារជាតិរបស់សភា

យោងតាមការអង្កេតជាសកល អំពីស្ត្រីនៅក្នុងនយោបាយដែលរៀបចំធ្វើឡើងជាបន្តបន្ទាប់ដោយ IPU នៅក្នុងរយៈពេល២៥ឆ្នាំចុងក្រោយនេះ បង្ហាញថា ស្ត្រីនៅតែមិនសូវមានវត្តមាន ឬតំណាងនៅក្នុងគណៈកម្មការការពារជាតិរបស់សភានៅឡើយ។ ក្រៅពីនេះ ស្ត្រីក៏កម្រ មានតួនាទីជាប្រធាន ឬអនុប្រធាន ឬជាអ្នករាយការណ៍ នៅក្នុងគណៈកម្មការសភានេះដែរ។ ការអង្កេតរបស់ IPU ក្នុងឆ្នាំ១៩៩៧ (*បុរស និងស្ត្រីនៅក្នុងនយោបាយ៖ ប្រជាធិបតេយ្យកំពុងចាប់កំណើតនៅឡើយ*) បានបង្ហាញថា ក្នុងចំណោមសភាចំនួន៩៧ សភាដែលបានផ្តល់ទិន្នន័យអំពីស្ត្រីនៅក្នុងគណៈកម្មការនានា សភាមានតែ ៣%ប៉ុណ្ណោះ មានស្ត្រីម្នាក់ជាប្រធាននៃគណៈកម្មការការពារជាតិរបស់សភា។ ជាទូទៅ ស្ត្រីតំណាងត្រឹមតែ១៨.៦% នៃអ្នកដែលជាប្រធានគណៈកម្មការសភាទាំងអស់។ ស្ថានភាពនេះអាចបកស្រាយតាមកត្តាសំខាន់ៗ ២យ៉ាង។ កត្តាទី១ ដោយសារនៅក្នុងពិភពលោកនៅមានចំនួនស្ត្រីតិចមែនទែននៅក្នុងសភា (១៤.៣% ក្នុងខែឧសភា ឆ្នាំ២០០២)។ កត្តាទី២ ទស្សនៈថាសង្គ្រាម សន្តិភាព និងបញ្ហាសន្តិសុខ ជាទូទៅមិនមែនជាកិច្ចការរបស់ស្ត្រី ដោយសារវាជាកិច្ចការរបស់បុរស។ ទស្សនៈបែបនេះ បានចាក់ឫសជ្រៅទៅក្នុងសតិអារម្មណ៍របស់មនុស្សទាំងអស់នៅពាសពេញពិភពលោក។ ទស្សនៈនេះបង្កើតជាបញ្ហា ដោយសារតែសង្គ្រាមភាគច្រើនបានប៉ះពាល់ទៅលើប្រជាពលរដ្ឋទាំងមូលនៅក្នុងរដ្ឋមួយ ហើយអ្នកដែលជាជនរងគ្រោះញឹកញាប់ជាងបុរសគឺស្ត្រីនេះហើយ។

## ស្ត្រីកាន់អាវុធ

នៅក្នុងសេវាគាំទ្រផ្នែករដ្ឋបាល ភស្តុភា និងការគាំទ្រផ្សេងទៀតការចូលរួមរបស់ស្ត្រីនៅក្នុងកងកម្លាំងប្រដាប់អាវុធ គឺមានលក្ខណៈធម្មតា និងជាប្រពៃណីនៅក្នុងប្រទេសភាគច្រើន។ វត្តមានរបស់ស្ត្រីគឺជាអ្នកគាំពារពីក្រោយ។ នេះគឺសំខាន់ណាស់មិនត្រឹមក្នុងអំឡុងពេល នៃពេលមានសន្តិភាពប៉ុណ្ណោះនោះទេ តែថែមទាំង និងពេលខ្លះច្រើនជាងនេះនៅក្នុងអំឡុងពេលមានសង្គ្រាម ឬជម្លោះប្រដាប់អាវុធកើតឡើងថែមទៀតផង។ ផ្ទុយមកវិញក្នុងកម្រិតកងទ័ព និងប្រតិបត្តិការយោធាការចូលរួមបែបនេះរបស់ស្ត្រី គឺជាបាតុភូតថ្មីស្រឡាងមួយ។ នៅថ្នាក់អន្តរជាតិ មានទិន្នន័យតិចណាស់អំពីស្ត្រីនៅក្នុងយោធា។ ប្រអប់ទី១៤ ខាងក្រោមបង្ហាញនូវឧទាហរណ៍នៃការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យយោធា នៅក្នុងរដ្ឋជាសមាជិករបស់អង្គការណាតូ។

**ប្រអប់ទី១៨**

**ចំនួនបុគ្គលិកយោធាជាស្ត្រី៖ ឧទាហរណ៍នៅក្នុងប្រទេសជាសមាជិកនៃអង្គការណាតូ**

| ឈ្មោះប្រទេស | ចំនួន | % នៃកងកម្លាំងសរុប |
|---|---|---|
| បែលហ្សិក | ៣,២០២ | ៧.៦% |
| កាណាដា | ៦,៥៥៨ | ១១.៤% |
| សាធារណៈរដ្ឋឆេក | ១,៩៩១ | ៣.៧% |
| ដាណាម៉ាក | ៨៦៣ | ៥.0% |
| បារាំង | ២៧,៥១៦ | ៨.៥% |
| អាល្លឺម៉ង់ | ៥,២៦៣ | ២.៨% |
| ក្រិក | ៦,១៥៥ | ៣.៨% |
| ហុងគ្រី | ៣,០១៧ | ៩.៦% |
| អ៊ីតាលី | ៤៣៨ | 0.១% |
| លុចហ្សំបួរ | ៤៧ | 0.៦% |
| ហុល្លង់ | ៤,១៧0 | ៨.0% |
| ន័រវេ | ១,១៥២ | ៣.២% |
| ប៉ូឡូញ | ២៧៧ | 0.១% |
| ព័រទុយហ្គាល់ | ២,៨៧៥ | ៦.៦% |
| អេស្ប៉ាញ | ៦,៤៦២ | ៥.៨% |
| តួគី | ៩១៧ | 0.១% |
| ចក្រភពអង់គ្លេស | ១៦,៦២៣ | ៨.១% |
| សហរដ្ឋអាមេរិក | ១៩៨,៤៥២ | ១៤.0% |
| | | ប្រភព៖ NATO Review Summer 2001 |

ជាទូទៅ គេអាចនិយាយដោយជឿជាក់ថាការចូលរួមរបស់ស្ត្រីជាយោធាដែលបានជ្រើសរើស និង/ឬជាយោធាអាជីពអាចត្រូវបានជម្រុញដោយថ្នាក់ដឹកនាំនយោបាយ ឬអាចបណ្ដាលមកពីការអភិវឌ្ឍនៅក្នុងវិស័យសន្តិសុខខ្លួនឯង។ វាហាក់ដូចជាមានទំនាក់ទំនងជាមួយបាតុភូត២ ដែលអាចកើតឡើងដោយដាក់ដោយឡែកពីគ្នា៖

- តម្រូវការក្នុងការកៀរគរប្រជាពលរដ្ឋទាំងមូល ដើម្បីការពារ និងលើកកម្ពស់សន្តិសុខជាតិ។
- ការធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធ ខណៈពេលដែលប្រទេសមានការអភិវឌ្ឍសង្គម និងមានការយកចិត្តទុកដាក់ច្រើនដល់ការលើកស្ទួយសមភាពយេនឌ័រ។

**ប្រអប់ទី ១៥**

## ការចូលរួមរបស់ស្ត្រី នៅក្នុងគោលនយោបាយសន្តិសុខជាផ្នែកមួយនៃការបញ្ជ្រាបយេនឌ័រ

គោលនយោបាយសន្តិសុខរបស់រដ្ឋាភិបាល អាចធ្វើការវាយតម្លៃចេញ ពីទស្សនៈនៃការបញ្ជ្រាបយេនឌ័រ។ នៅក្នុងសន្និសីទពិភពលោកស្តីពីស្ត្រីលើកទី៤ របស់អង្គការសហប្រជាជាតិ ដែលបានធ្វើនៅក្នុងទីក្រុងប៉េកាំង អង្គការសហប្រជាជាតិបានបង្កើតយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ សកលមួយសម្រាប់លើកកម្ពស់សមភាពយេនឌ័រ។ អង្គការសហប្រជាជាតិ (ECOSOC) ឲ្យនិយមន័យនៃការបញ្ជ្រាបយេនឌ័រថាជា "... ដំណើរការនៃការវាយតម្លៃពីផលប៉ះពាល់មកលើស្ត្រី និងបុរសនៅក្រោមការអនុវត្តនូវវិធានការណាមួយដែលបានគ្រោងទុក ក្នុងនោះមានការធ្វើច្បាប់ គោលនយោបាយ ឬកម្មវិធីនានានៅគ្រប់វិស័យ និងគ្រប់កម្រិតទាំងអស់។ វាជាយុទ្ធសាស្ត្រមួយសម្រាប់បញ្ចូលកង្វល់ របស់ស្ត្រីក៏ដូច បុរសចូលទៅក្នុងការតាក់តែង អនុវត្ត និងពិនិត្យតាមដាន វាយតម្លៃ គោលនយោបាយ និងកម្មវិធីនៅក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីឲ្យស្ត្រី និងបុរសទទួលបាននូវអត្ថប្រយោជន៍ស្មើគ្នា ហើយវិសមភាពយេនឌ័រត្រូវបានលុបបំបាត់។ គោលដៅដ៏ធំចម្បងនេះ គឺត្រូវធ្វើឲ្យសម្រេចនូវសមភាពយេនឌ័រជាដាច់ខាត"។

*ប្រភព៖ សេចក្តីសន្និដ្ឋានដែលបានឯកភាពគ្នារបស់អង្គការ UN ECOSOC ១៩៩៧/២*

ផ្ទុយមកវិញ ការចូលរួមច្រើនឡើងៗរបស់ស្ត្រីនៅក្នុងកងកម្លាំងប្រដាប់អាវុធ អាចរួមវិភាគទានដល់ការផ្លាស់ប្តូរ ពីការការពារជាតិដែលមានលក្ខណៈជាប្រពៃណី មកជាការការពារសន្តិសុខមនុស្សវិញ៖ មានការយកចិត្តទុកដាក់ច្រើនឡើងៗទៅលើការស្រាវជ្រាវបច្ចេកវិទ្យាពត៌មាន (រួមទាំងនៅក្នុងធនាគារផងដែរ) និងការងារស៊ើបយកការសម្ងាត់ វិធីសាស្ត្រ និងប្រតិបត្តិការដែលតម្រូវឲ្យមានកងកម្លាំងជារូបវន្ត និងការហ្វឹកហ្វឺនរាងកាយ។ និន្នាការនេះ ផ្តល់នូវកាលានុវត្តន៍ភាពថ្មីដល់ស្ត្រីជាពិសេស នៅក្នុងប្រទេសដែលបុរស និងស្ត្រីមានសិទ្ធិស្មើគ្នានៅក្នុងការរៀនសូត្រ និងបណ្តុះបណ្តាល។

**ប្រអប់ទី១៦**

**ទិដ្ឋភាព និងការប្រឈមថ្មីៗនៃការបញ្ចូលស្ត្រីទៅក្នុងវិស័យសន្តិសុខ**

ការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសន្តិសុខ ហើយជាពិសេស នៅក្នុងយោធា និងនគរបាល បានចោទជាបញ្ហាថា តើការហ្វឹកហ្វឺនលើរាងកាយ និងការអនុវត្តវិន័យត្រូវអនុវត្តដូចគ្នារវាងបុរស និងស្ត្រីដែរឬយ៉ាងណា។

គេត្រូវការនូវលិខិតបទដ្ឋានគតិយុត្ត ស្តីពីភេទ ដែលមកដល់ពេលនេះលិខិតបទដ្ឋានគតិយុត្តនេះ ត្រូវបានដកចេញពីផ្នែកយោធា ពីអង្គការយោធារបស់រដ្ឋ ឬពីនគរបាលៈ គេត្រូវមានការគិតគូរយ៉ាងយកចិត្តទុកដាក់ចំពោះតម្រូវការពិសេស និងផលប្រយោជន៍នៃគូរស្រករដែលបានរៀបការ ឬមិនបានរៀបការនៅក្នុងអង្គភាពតែមួយ ឬអង្គភាពផ្សេងគ្នា ក៏ដូចជាគេត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាទាក់ទងនឹង មាតុភាព និងបិតុភាពផងដែរ។

គេត្រូវធ្វើការពិចារណាឡើងវិញ នូវបញ្ហាទាក់ទងនឹងសម្លៀកបំពាក់ និងសោភ័ណភាព រួមទាំងភាពទាក់ទាញនៃភេទ តើឯកសណ្ឋានសម្រាប់បុរស និងស្ត្រីគួរតែដូចគ្នាដែរឬទេ? តើឯកសណ្ឋាននេះ គួរតែត្រូវបានកាត់ជាឯកសណ្ឋានបុរសគ្រប់កាលៈទេសៈទាំងអស់មែនទេ?

បញ្ហាទាំងនេះតម្រូវឲ្យមានការគិតគូរជាថ្មី។ គេត្រូវរៀបចំច្បាប់ជាតិ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តស្តីពីយោធា អង្គការយោធារបស់រដ្ឋ និងនគរបាលឲ្យស្របគ្នាជាមួយតថភាពសម័យទំនើបទាំងនេះ។

## ស្ត្រីបម្រើការនៅក្នុងប្រតិបត្តិការរក្សាសន្តិភាពនិងនៅក្នុងក្រសួងការពារជាតិ

ដូចដែលបានបង្ហាញនៅក្នុងទិន្នន័យរបស់អង្គការណាតូ នៅក្នុងសៀវភៅ Summer 2001 Review ចំនួនបុគ្គលិកស្ត្រីដែលចូលរួមនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព ចាប់តាំងពីការបញ្ចប់ទៅនៃសង្គ្រាមលោកលើកទី២ នៅមានចំនួនតិចតួចនៅឡើយ។ មានប្រទេសពីរបីប៉ុណ្ណោះ ដូចជា ប្រទេសកាណាដា ហុងគ្រី បារាំង ហុល្លង់ និងព័រទុយហ្កាល បានបញ្ចូលចំនួនស្ត្រីលើសពី៥% ចូលទៅក្នុងបុគ្គលិករក្សាសន្តិភាពរបស់ពួកគេ។ យោងតាមបទពិសោធន៍របស់អង្គការសហប្រជាជាតិបង្ហាញថា វត្តមានរបស់ស្ត្រីត្រូវបានប្រជាពលរដ្ឋអបអរសាទរ ហើយស្ត្រីមានឥទ្ធិពលជាវិជ្ជមានទៅលើលទ្ធផលនៃប្រតិបត្តិការទាំងនោះ។ ឧ.មានការយកចិត្តទុកដាក់កាន់តែច្រើនទៅលើបញ្ហាយេនឌ័រ និងអំពើហិង្សាលើស្ត្រី។

ការតែងតាំងស្ត្រីជារដ្ឋមន្ត្រីឬជាអនុរដ្ឋមន្ត្រីការពារជាតិនៅតែកម្រកើតមានដដែល។ អង្កេតសកលរបស់ IPU បង្ហាញថាក្នុងខែមីនា ឆ្នាំ២០០០ ស្ត្រីតំណាងត្រឹមតែ ១.៣% នៃរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ/សន្តិសុខទាំងអស់ និង៣.៩% នៃអនុរដ្ឋមន្ត្រី និងកាន់តំណែងជាមន្ត្រីក្រសួងដទៃទៀត រួមទាំងលេខាសភាផងដែរ នៅក្នុងវិស័យការពារជាតិ (សូមអានផែនទីសកលលោកដែលត្រូវបោះពុម្ពផ្សាយរួមគ្នាដោយ IPU និង UN ដែលមានចំណងជើងថា៖ *ស្ត្រីនៅក្នុងនយោបាយ៖ ២០០០)*។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ទិន្នន័យ

- ស្នើសុំទិន្នន័យជាស្ថិតិ ទាក់ទងនឹងសមាមាត្រនៃស្ត្រីនៅក្នុងផ្នែកនីមួយៗរបស់យោធា អង្គការយោធារបស់រដ្ឋ នគរបាល និងសេវាស៊ើបការណ៍សម្ងាត់រួមទាំងពីមជ្ឈមណ្ឌលបណ្តុះបណ្តាលដែលពាក់ព័ន្ធ។ ក្រៅពីនេះ សភាអាចស្នើសុំទិន្នន័យទាក់ទងនឹងសមាមាត្រស្ត្រីដែលមានតួនាទីខ្ពស់ និងមានតួនាទីធ្វើសេចក្តីសម្រេចចិត្ត និងទិន្នន័យទាក់ទងនឹងការបញ្ចូលស្ត្រីទៅក្នុងគណៈប្រតិភូរបស់ប្រទេសទៅកាន់អង្គការសហប្រជាជាតិ អង្គការណាតូ ឬអង្គការអន្តរជាតិដទៃទៀតដែលពិភាក្សាអំពីបញ្ហាសន្តិសុខ។

### យេនឌ័រ និងដំណោះស្រាយជម្លោះ និងកសាងប្រទេសឡើងវិញ*)

- តាមដែលអាចធ្វើទៅបាន សភាត្រូវធានាថាក្រុមចរចានៅក្នុងការស្វែងរកដំណោះស្រាយនៃជម្លោះត្រូវមានតុល្យភាពយេនឌ័រ។
- សភាត្រូវធានាថា កិច្ចព្រមព្រៀងសន្តិភាពអាចជួយដោះស្រាយនូវផលវិបាកមកលើស្ត្រីនៃជម្លោះប្រដាប់អាវុធដែលមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈច្បាស់លាស់ ការរួមចំណែករបស់ស្ត្រីដល់ដំណើរការសន្តិភាព និងតម្រូវការនិងអាទិភាពរបស់ពួកគេ ក្រោយជម្លោះបានបញ្ចប់។
- សភាត្រូវធានាថា សមត្ថភាព ចំណេះដឹង បទពិសោធន៍របស់ស្ត្រីដែលមាននៅក្នុងអំឡុងពេលនៃជម្លោះ ត្រូវបានប្រើប្រាស់ជាប្រយោជន៍ សម្រាប់ការកសាងប្រទេសឡើងវិញ។

### យេនឌ័រ និងបេសកកម្មសន្តិភាព*)

- សភា អាចតស៊ូមតិឲ្យមានការចូលរួមពីស្ត្រី នៅក្នុងបេសកកម្មសន្តិភាព និងនៅក្នុងការកសាងប្រទេសឡើងវិញក្រោយជម្លោះ។
- សភា ត្រូវធានាតាមរយៈច្បាប់ថា អ្នករក្សាសន្តិភាព និងបុគ្គលិក អន្តរជាតិផ្សេងទៀតត្រូវទទួលបាននូវការហ្វឹកហ្វឺនទាំងផ្នែក វប្បធម៌ និងយេនឌ័រ។
- សភា ត្រូវធ្វើការត្រួតពិនិត្យនូវការដាក់ទណ្ឌកម្មទៅលើ អ្នករក្សាសន្តិភាព និងបុគ្គលិកអន្តរជាតិដទៃទៀតដែលរំលោភសិទ្ធិស្ត្រី។

### រដ្ឋាភិបាល

- សភាត្រូវធានាថាកម្រិតនៃការទទួលខុសត្រូវរបស់ស្ត្រី និងបុរសនៅក្នុងក្រសួងការពារជាតិ ឧ. លើស១០ឆ្នាំត្រូវមានតុល្យភាព។ សភាត្រូវពិនិត្យពិច័យថា តើឱកាសសម្រាប់ស្ត្រី និង

បុរសមានភាពស្មើគ្នាឬទេ នៅក្នុងច្បាប់ និងនៅក្នុងការអនុវត្តជាក់ស្តែងទាក់ទងនឹងការឡើងឋានៈខ្ពស់ ឬការមានការទទួលខុសត្រូវនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

**សភា**

- សភា អាចធ្វើការផ្ទៀងផ្ទាត់សមាសភាពពីមុន និង/ឬ ពេលបច្ចុប្បន្ន នៃគណៈកម្មាធិការការពារជាតិ ឬសន្តិសុខនៅក្នុងសភា និងកម្រិតនៃការទទួលខុសត្រូវរបស់ស្ត្រីតំណាងរាស្ត្រនៅក្នុងគណៈកម្មការនោះ។
- សភា អាចត្រួតពិនិត្យមើលថាតើគណៈកម្មាធិការ បានយកចិត្តទុកដាក់ចំពោះបញ្ហាយេនឌ័រដែរឬទេ និងដាក់សម្ពាធឲ្យមានការបង្កើនតុល្យភាពយេនឌ័រ និងការទទួលស្គាល់យេនឌ័រប្រសិនបើចាំបាច់។

*) អនុសាសន៍ដកស្រង់ចេញមកពីរបាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០២។

## ផ្នែកទី III

# ផ្នែកប្រតិបត្តិការសំខាន់ៗនៃ
# វិស័យសន្តិសុខ

# ជំពូកទី ៨

# យោធា

ផ្នែកយោធា បានចាក់ឫសគល់ជាយូរលង់ណាស់មកហើយ។ ត្រូវបានគេចាត់ទុកជាទូទៅថាជាខែល និងជាដាវរបស់រដ្ឋ។ ប្រអប់ទី១៧ បង្ហាញពីប្រទេសមួយចំនួនតូចនៅក្នុងពិភពលោក ដែលមកដល់ពាក់កណ្តាលឆ្នាំ២០០២ នៅមិនមានផ្នែកយោធានេះ។

**ប្រអប់ទី ១៧**

**ប្រទេសដែលគ្មានយោធា**

ប្រទេសខ្លះ មិនមានកងកម្លាំងប្រដាប់អាវុធនោះទេ។ ប្រទេសទាំងនេះ គឺជាប្រទេសតូចៗនៅក្នុងមហាសមុទ្រភាគខាងត្បូងដូចជាប្រទេសណារ៉ូ ម៉ាល់ឌីវ គីរីបាទី សាម៉ោ (Samoa) កោះសូឡូម៉ុង ទុយវ៉ាលុយ ប៉ាលូ និងវ៉ាន់នូទូ និងប្រទេសនៅក្នុងសមុទ្រការីបៀន ដូចជា ប្រទេសវីនសង់ (Vincent) និងហ្គ្រែនណាឌីន (Grenadines) St. Kitts និង Nevis, St.Lucia, Dominica, Grenada។ ប្រទេសដទៃទៀតដែលគ្មានកងកម្លាំងប្រដាប់អាវុធ មានប្រទេស Costa Rica, Iceland, Mauritius, Panama, Somalia (ដែលកំពុងស្ថិតក្នុងដំណើរការបង្កើត កងទ័ព) Andorra, San Marino, និង Haiti។ ប្រទេសភាគច្រើននៃប្រទេសទាំងនេះមានអង្គភាពដែលមានលំនាំជាយោធា (ឧ. កងសន្តិសុខជាតិ និងឆ្មាំព្រំដែនជាដើម)។

## មុខងាររបស់យោធា

ការវិវត្តន៍ផ្នែកសន្តិសុខចាប់តាំងពីចុងសង្គ្រាមត្រជាក់មក បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅលើយោធានៅជុំវិញពិភពលោក។ យោធាត្រូវបានប្រគល់នូវភារកិច្ចថ្មីៗ ខណៈពេលដែលពួកគេត្រូវបានស្នើសុំឲ្យបំពេញនូវភារកិច្ចស្មុលជាច្រើនផ្សេងទៀត។ បច្ចុប្បន្ននេះ វាជារឿងធម្មតាសម្រាប់យោធានៅក្នុងពិភពលោកក្នុងការចូលរួមបំពេញនូវមុខងារចំនួន ៥ខុសៗគ្នា៖

- ✓ ការពារឯករាជ្យបូរណភាព និងអធិបតេយ្យភាពដែនដី និងប្រជាពលរដ្ឋរបស់ខ្លួន។
- ✓ បំពេញបេសកកម្មរក្សាសន្តិភាពអន្តរជាតិ។
- ✓ ជួយសង្គ្រោះពេលមានគ្រោះមហន្តរាយកើតឡើង។

- ✓ រក្សាសន្តិសុខផ្ទៃក្នុង (ជួយដល់អាជ្ញាធរអនុវត្តច្បាប់ស៊ីវិល ដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងករណីលើកលែង ប្រសិនបើមានការធ្វើឲ្យខូចសណ្តាប់ធ្នាប់កើតឡើង)។
- ✓ ចូលរួមនៅក្នុងការកសាងជាតិ (មុខងារសង្គម)។

កម្រិតនៃការអនុវត្តនូវមុខងារទាំងនេះ មានខុសៗគ្នា ពីរដ្ឋមួយទៅរដ្ឋមួយទៀត ដោយផ្អែកលើក្របខណ្ឌច្បាប់ជាតិ និងស្ថានភាពសន្តិសុខរបស់ប្រទេសនោះ។

## ការការពារអធិបតេយ្យភាព និងសង្គម

ទោះបីមានការវិវត្តន៍ផ្នែកសន្តិសុខ និងការគម្រាមកំហែងថ្មីៗនេះក៏ដោយ ការបំពេញមុខងារជាប្រពៃណីរបស់យោធានៅតែជាភារកិច្ចដ៏សំខាន់ នោះគឺការពារមាតុភូមិ ឬប្រទេសជាសម្ព័ន្ធមិត្តប្រឆាំងនឹងការវាយប្រហារដោយយោធាបរទេស។ ភារកិច្ចនេះមិនត្រឹមបញ្ចូលនូវការការពារដែនដី និងអធិបតេយ្យភាពនយោបាយរបស់រដ្ឋប៉ុណ្ណោះនោះទេ តែថែមទាំងការពារនូវសង្គមជាតិទាំងមូលថែមទៀតផង។

ចាប់តាំងពីចុងបញ្ចប់នៃសង្គ្រាមត្រជាក់មក មេដឹកនាំនយោបាយ និងយោធាមានការយល់ដឹងច្រើនថា អធិបតេយ្យភាពជាតិមិនត្រឹមទទួលការគម្រាមកំហែងដោយយោធាបរទេសប៉ុណ្ណោះទេ តែថែមទាំងទទួលរងការគម្រាមកំហែងថ្មីមិនមែនយោធា ដូចជា អំពើភេរវកម្ម សង្គ្រាមស៊ីវិល ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណែត និងអំពើពុករលួយជាដើម (មើលប្រអប់ទី១)។ ភាគច្រើននៃកងកម្លាំងប្រដាប់អាវុធបច្ចុប្បន្នកំពុងធ្វើការកែទម្រង់ការពារជាតិរបស់ខ្លួន។ ប្រអប់ទី១៨ ពន្យល់អំពីដំណើរការកំណែទម្រង់ ៣សំខាន់ៗ។

**ប្រអប់ទី ១៨**

**កំណែទម្រង់ការពារជាតិ៖ ដើម្បីអ្វី?**

ចាប់តាំងពីឆ្នាំ១៩៩០ យោធាភាគច្រើនត្រូវបានធ្វើកំណែទម្រង់យ៉ាងទូលំទូលាយ។ កំណែទម្រង់យោធាត្រូវបានធ្វើដោយផ្អែកលើហេតុផលខុសៗគ្នានៅក្នុងប្រទេសផ្សេងគ្នា។ និយាយឲ្យងាយយល់កំណែទម្រង់មានគោលបំណង ៣យ៉ាង៖

▷ **ប្រជាធិបតេយ្យភាវូបនីយកម្ម**

នៅក្នុងប្រទេសក្រោយកុម្មុយនីស្ត ក្រោយរបបផ្តាច់ការ និងប្រទេសក្រោយជម្លោះ គោលបំណងនៃកំណែទម្រង់ការពារជាតិ គឺការធ្វើប្រជាធិបតេយ្យនីយកម្ម៖

- ការធ្វើឲ្យយោធាមានគណនេយ្យភាព ចំពោះថ្នាក់ដឹកនាំនយោបាយដែលបានជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ បើមិនដូច្នោះទេ យោធាអាចបង្កនូវការគម្រាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ។

- ការធ្វើឲ្យមានតុល្យភាពនៃធនធានដែលត្រូវការ ដោយយោធាជាមួយតម្រូវការរបស់វិស័យផ្សេងទៀតនៅក្នុងសង្គម។

▷ **ការបន្សាំទៅនឹងបរិយាកាសសន្តិសុខថ្មី**
- ការកែសម្រួលទំហំ និងចរិការបស់យោធាឲ្យស្របគ្នា ជាមួយការគម្រាមកំហែងសន្តិសុខថ្មី។
- ការធ្វើឲ្យយោធាត្រៀមខ្លួនទទួលនូវបេសកកម្មថ្មី ឧ. ប្រតិបត្តិការរក្សាសន្តិភាព។

▷ **អន្តរជាតិតូបនីយកម្ម**

កាន់តែច្រើនឡើងៗ យោធាលែងប្រតិបត្តិនៅតែក្នុងរង្វង់បរិបទជាតិទៀតហើយ តែប្រតិបត្តិការជាមួយអង្គភាពរបស់ប្រទេសផ្សេងៗ។ សហប្រតិបត្តិការអន្តរជាតិនេះមានលក្ខណៈជាបណ្ដោះអាសន្ន ដូចជា បេសកកម្មរក្សាសន្តិភាពរបស់សហប្រជាជាតិ ឬមានលក្ខណៈវែង ឬមានទម្រង់ជាស្ថាប័ន (ឧ. អង្គការណាតូ) ឬមានទម្រង់ជាទ្វេភាគី ឬពហុភាគី។
- ការដាក់យោធា (ដោយឡែក) ឲ្យស្ថិតនៅក្រោមការបញ្ជាជាអន្តរជាតិ និងមានរចនាសម្ព័ន្ធចាត់តាំងត្រឹមត្រូវ។
- បង្កើនសមត្ថភាពយោធា ក្នុងការធ្វើប្រតិបត្តិការជាមួយយោធានៃប្រទេសដទៃ ដូចជាការផ្ដល់ឧបករណ៍ ការហ្វឹកហ្វឺន ការបណ្ដុះបណ្ដាលភាសា ការផ្ដល់ព័ត៌មាន ប្រព័ន្ធបញ្ជា និងត្រួតពិនិត្យ (ប្រតិបត្តិការផ្ទៃក្នុង)។

ឧទាហរណ៍នៃអង្គភាពអន្តរជាតិជាអចិន្ត្រៃយ៍៖
- កងទ័ពទី១ របស់អាល្លឺម៉ង់-ហុល្លង់
- កងវរៈសេនាតូចបាល់ទិក (ប្រទេសលីថូនី អេស្តូនៀ ឡាត់វី)
- កងទ័ពចម្រុះប៉ូឡូញ-ដាណឺម៉ាក-អាល្លឺម៉ង់
- កងវរៈសេនាតូចវិស្វកម្មពហុជាតិរវាងប្រទេសស្លូវ៉ាគី ហុងគ្រី រ៉ូម៉ានី និងអ៊ុយក្រែន (កងវរៈសេនាតូច "TISA")។

## ការរួមចំណែកដល់សន្តិភាពអន្តរជាតិ

យោធា ចូលរួមនៅក្នុងបេសកកម្មសន្តិភាពយ៉ាងហោចណាស់ក៏មានហេតុផល២យ៉ាងដែរ។ ទី១ ដើម្បីទប់ស្កាត់ជម្លោះ និងបញ្ចៀសនូវការសាយភាយផលប៉ះពាល់របស់វា ដូចជាការធ្វើឲ្យតំបន់មិនមានស្ថិរភាព ការរំខានដល់សេដ្ឋកិច្ច និងការបង្កឲ្យមានជនភៀសខ្លួនដ៏ច្រើន ដែលមិន

អាចត្រួតត្រាបាន។ ទី២ យោធាចូលរួមចំណែកនៅក្នុងការរក្សាសន្តិសុខមនុស្សនិងការពារប្រជាជនស៊ីវិលនៅក្នុងតំបន់ជម្លោះ។ សន្តិសុខមនុស្ស ជាពិសេសការទទួលបាននូវសិទ្ធិមនុស្សបានក្លាយមកជាគោលនយោបាយដ៏មានសារៈសំខាន់របស់សហគមន៍អន្តរជាតិ ចាប់តាំងពីជម្លោះថ្មីៗបានក្លាយជាជម្លោះបែបហិង្សា និងមានផលប៉ះពាល់ទៅលើប្រជាជនស៊ីវិលមក។ ផលនៃការចូលរួមនៅក្នុងបេសកកម្មរក្សាសន្តិភាពគឺថា បេសកកម្មទាំងនេះផ្តល់នូវកាលានុវត្តន៍ភាពដល់ការហ្វឹកហ្វឺនអង្គភាពយោធា និងធ្វើឲ្យពួកគេទទួលបាននូវបទពិសោធន៍ជាក់ស្តែង។

## ជួយសង្គ្រោះពេលមានគ្រោះមហន្តរាយ

គ្រប់ប្រទេសទាំងអស់អាច ឬត្រូវបានប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះមហន្តរាយបណ្តាលមកពីមនុស្ស ដូចជា រញ្ជួយផែនដី ទឹកជំនន់ ភ្លើងឆេះ ឬធ្លាក់យន្តហោះនៅក្នុងតំបន់ទីក្រុង។ នៅក្នុងស្ថានភាពគ្រោះអាសន្នបែបនេះ យោធាត្រូវបានអំពាវនាវដោយអាជ្ញាធរស៊ីវិលឲ្យចុះជួយ និងចែកចាយនូវជំនួយសង្គ្រោះបន្ទាន់។ យោធា អនុវត្តនូវភារកិច្ចនានា ដូចជា ថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់ ផ្តល់ស្បៀង ថ្នាំពេទ្យ និងគ្រឿងបរិក្ខាដទៃផ្សេងទៀតព្រមទាំងធ្វើទំនាក់ទំនងនិងដឹកជញ្ជូន។ ផលនៃការប្រើប្រាស់យោធាសម្រាប់ប្រតិបត្តិការជួយសង្គ្រោះគ្រោះមហន្តរាយត្រូវបានសង្គមទទួលស្គាល់ក្នុងផ្លូវជាវិជ្ជមាន ហើយការគាំទ្ររបស់ប្រជាពលរដ្ឋចំពោះយោធាបានការកើនឡើងជាលំដាប់។

## ជួយដល់អាជ្ញាធរស៊ីវិលអនុវត្តច្បាប់

មុខងារផ្សេងទៀតរបស់យោធា គឺត្រូវជួយដល់អាជ្ញាធរស៊ីវិលក្នុងការអនុវត្តច្បាប់។ ក៏ប៉ុន្តែការប្រើប្រាស់យោធាបែបនេះ វាបង្កឲ្យមានភាពចម្រូងចម្រាស់ខ្លាំងណាស់។ សង្គមអាចទទួលរងការគម្រាមកំហែងដែលមានទំហំធំពេករហូតដល់អាជ្ញាធរស៊ីវិល និងនគរបាលតែឯកឯងមិនអាចធ្វើការដោះស្រាយបាន។ ដូច្នេះការជួយគាំទ្រ ដោយយោធាគឺជាការចាំបាច់ ឧ.ការគម្រាមកំហែងនេះមាន ដូចជា ការវាយប្រហារដោយភេរវករ ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ឬការជួញដូរគ្រឿងញៀនដោយខុសច្បាប់ជាដើម។ កង្វល់ និងគ្រោះថ្នាក់នៃការប្រើយោធាសម្រាប់អនុវត្តច្បាប់ដោយអាជ្ញាធរស៊ីវិលមាន៖

- ✓ វាអាចគម្រាមកំហែងដល់ការត្រួតពិនិត្យយោធាដោយប្រជាពលរដ្ឋ និងអាជ្ញាធរស៊ីវិល។
- ✓ វាចៀសមិនផុត ពីការនាំយោធាទៅប្រឡូកប្រឡាក់ជាមួយបញ្ហានយោបាយ។
- ✓ យោធា អាចស្តារច្បាប់តែក្នុងរយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ តែពួកគេមិនអាចដកឬសគល់នៃបញ្ហានយោបាយ សង្គម ឬសេដ្ឋកិច្ចនៃជម្លោះ ឬអសណ្តាប់ធ្នាប់បានឡើយ។
- ✓ កងកម្លាំងប្រដាប់អាវុធទទួលការហ្វឹកហ្វឺនសម្រាប់ប្រយុទ្ធ ដូច្នេះពួកគេមិនមែនត្រូវបាន

ហ្វឹកហ្វឺនជាពិសេស សម្រាប់អនុវត្តការងារនគរបាល ឬសម្រាប់ដោះស្រាយបញ្ហាស៊ីវិលនៅក្នុងប្រទេសឡើយ។

✓ កងកម្លាំងប្រដាប់អាវុធ និងនគរបាលអាចមានមុខងារជាលក្ខណៈប្រកួតប្រជែងនឹងគ្នា។

**ប្រអប់ទី ១៩**

**ការប្រើប្រាស់យោធានៅក្នុងការអនុវត្តច្បាប់ស៊ីវិលនៅក្នុងប្រទេស អាហ្វ្រិកខាងត្បូង**

(...) កងកម្លាំងការពារជាតិអាហ្វ្រិកខាងត្បូង (SANDF) អាចនឹងត្រូវបានដាក់តាំងពង្រាយនៅក្នុងកាលៈទេសៈលើកលែងខ្ពស់បំផុត ដូចជាការរំលោភទាំងស្រុងលើសណ្តាប់ធ្នាប់សាធារណៈហួសពីសមត្ថកិច្ចរបស់នគរបាលអាហ្វ្រិកខាងត្បូង ឬក៏រំលោភទៅលើកិច្ចការពារជាតិ (...) ការជ្រើសរើសយោធាសម្រាប់ប្រើប្រាស់នៅក្នុងប្រទេស គឺស្ថិតនៅក្រោមការត្រួតពិនិត្យដោយសភា និងបទប្បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញស្តីពី សិទ្ធិជាមូលដ្ឋាន ហើយវាត្រូវគ្រប់គ្រងដោយច្បាប់។

*ប្រភព៖ "ការការពារជាតិនៅក្នុងលទ្ធិប្រជាធិបតេយ្យ"។ សៀវភៅសស្តីពីការការពារជាតិសម្រាប់សាធារណៈរដ្ឋ អាហ្វ្រិកខាងត្បូង ខែឧសភា ឆ្នាំ១៩៩៦*

## មុខងារសង្គម

មានការទទួលស្គាល់ថា យោធាជាពិសេស យោធាដែលមានទាហានជាប់កំណែនបានរួមចំណែកដល់ការកសាងជាតិ ដូចជា យុវជនវ័យក្មេង (ភាគច្រើនជាបុរស) មកពីមជ្ឈដ្ឋានផ្សេងៗនៃសង្គម និងជនជាតិដើមភាគតិច ពួកគេធ្វើការជាមួយគ្នា។ នេះជាការពិតនៅក្នុងសង្គមដែលមានជនអន្តោប្រវេសន៍ ឬសង្គមដែលមានពហុវប្បធម៌ ដែលយោធាមានមុខងារជា "ឆ្នាំងរំលាយដែក"។ មុខងារសង្គមមួយទៀតរបស់យោធា មានដូចជាការផ្តល់ការអប់រំរៀនសូត្រដល់ប្រជាពលរដ្ឋស៊ីវិល។ ប្រជាពលរដ្ឋដែលមិនមានជំនាញ ឬ ជំនាញមានកម្រិតអាចទទួលអត្ថប្រយោជន៍ពីការចូលបម្រើកងទ័ព។ មុខងារសង្គមមួយទៀតរបស់យោធាភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺជួយ ឬគាំទ្រដល់រដ្ឋបាលស៊ីវិលនៅក្នុងតំបន់ដាច់ស្រយាល ដោយប្រើប្រាស់អតីតយុទ្ធជនជួយផ្តល់នូវការអប់រំ ជួយថែទាំសុខភាព ឬជួយទប់ស្កាត់ការខូចរិចរិលនៃបរិស្ថានជាដើម។

មុខងារសង្គមទាំងនេះ គឺជាឧទាហរណ៍នៃរបៀបដែលយោធាអាចរួមចំណែកដល់សង្គមនៅក្នុងទម្រង់ជាវិជ្ជមាន។ ទោះដូច្នេះក៏ដោយ នៅក្នុងប្រទេសខ្លះ យើងបានមើលឃើញថា យោធាបានលូកដៃប្រព្រឹត្តអំពើអវិជ្ជមាននៅក្នុងសង្គម សេដ្ឋកិច្ច និងនយោបាយ ឧ. នៅក្នុងប្រទេសខ្លះ យោធាធ្វើអន្តរាគមន៍នៅក្នុងបញ្ហានយោបាយ និងគម្រាមកំហែងដល់រដ្ឋាភិបាល។ នៅក្នុងប្រទេសខ្លះទៀត ជាអកុសល យោធាពាក់ព័ន្ធនៅក្នុងរបររកស៊ីពាណិជ្ជកម្ម ដែលផ្តល់ដល់ពួកគេនូវប្រាក់ចំណូលបន្ថែមពីថវិការបស់រដ្ឋ ដែលគេមិនអាចធ្វើការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យបាន។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ការបំពេញមុខងាររបស់យោធា

▷ សភាអាចធានាថាយោធាបំពេញមុខងារ៖

- បានល្អតាមការកំណត់ដោយច្បាប់ និងវិធាន និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធជាមួយយោធា។
- ស្របតាមទស្សនទាន និងគោលនយោបាយសន្តិសុខជាតិ។
- ឆ្លើយតបតាមតម្រូវការសន្តិសុខជាក់ស្តែងរបស់សង្គម។
- ការបំពេញមុខងារមិនមែនយោធា មិនធ្វើឲ្យប៉ះពាល់ដល់ការត្រៀមខ្លួនរបស់យោធាសម្រាប់អនុវត្តមុខងារបឋមរបស់ខ្លួន គឺត្រូវការពារអធិបតេយ្យភាពជាតិ និងរួមចំណែកដល់ការអនុវត្តនីតិរដ្ឋជាអន្តរជាតិ។

### កំណែទម្រង់ការពារជាតិ

▷ ធានាថា គណៈកម្មការមានសមត្ថកិច្ចសភាទទួលបាននូវរបាយការណ៍លំអិត អំពីកំណែទម្រង់ ដែលបានធ្វើរួមជាមួយរបាយការណ៍វិភាគពីផលប៉ះពាល់ដែលពាក់ព័ន្ធ នឹងអាចលើកបញ្ហាដែលពាក់ព័ន្ធនោះ ឧ. តាមរយៈការរៀបចំសវនការជាដើម។

### ការប្រើប្រាស់យោធានៅក្នុងការអនុវត្តច្បាប់ស៊ីវិល

ជាគោលការណ៍ យោធាមិនគួរចូលរួមអនុវត្តច្បាប់ស៊ីវិលនោះឡើយ ក៏ប៉ុន្តែនៅពេលដែលគ្មានដំណោះស្រាយសភាគួរ៖

▷ ធានាថា ការចូលរួមរបស់យោធានៅក្នុងការអនុវត្តច្បាប់ស៊ីវិល ត្រូវបានកំណត់យ៉ាងច្បាស់លាស់ត្រូវបានរិតត្បិត និងគ្រប់គ្រងដោយច្បាប់ទៅតាម៖

- កាលៈទេសៈដែលជាដំណាក់កាលចុងក្រោយបំផុត។
- ទៅតាមលក្ខណៈ និងការកំហិតនៃការចូលរួម។
- ទៅតាមរយៈពេលនៃការចូលរួម។
- ទៅតាមប្រភេទនៃអង្គភាពដែលត្រូវចូលរួមនៅក្នុងករណីនីមួយៗ។
- ទៅតាមស្ថាប័នដែលអាចទទួលយកសេចក្តីសម្រេចអនុញ្ញាតឲ្យយោធាចូលរួម និងមិនឲ្យយោធាចូលរួមបន្ត។
- ទៅតាមយុត្តាធិការមានសមត្ថកិច្ច ក្នុងករណីដែលមានការរំលោភច្បាប់ ឬរំលោភសិទ្ធិមនុស្ស ។ល។

- ធ្វើច្បាប់ដែលកំណត់ថា ការអនុម័ត ឬការអនុញ្ញាតនានាត្រូវចេញដោយស្ថាប័នដែលត្រូវបានប្រគល់សិទ្ធិអំណាច មុនចុះធ្វើការឆែកឆេរផ្ទះសម្បែង ចាប់ខ្លួន ឬមុនបើកការបាញ់ប្រហារ។
- ធានាថា មានយន្តការសភា ឬយន្តការផ្សេងទៀតដើម្បីធានាថា ការចូលរួមរបស់យោធានៅក្នុងការអនុវត្តច្បាប់ស៊ីវិល វាស្របគ្នាជាមួយច្បាប់ និងគោលការណ៍មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិ។

## ជំពូកទី ៩

# អង្គការយោធារបស់រដ្ឋដទៃទៀត

ពាក្យថា "អង្គការយោធារដ្ឋផ្សេងទៀត" (ពីពេលនេះតីសំដៅលើអក្សរកាត់ OSMOs) អាចមានអត្ថន័យខុសគ្នាទៅតាមទីកន្លែង និងប្រទេសដែលបានប្រើប្រាស់ពាក្យនេះ។ ជាទូទៅ OSMOs ខុសពីអង្គការយោធាឯកជន។ យោងតាមវិទ្យាស្ថានអន្តរជាតិ ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ សម្រាប់ការសិក្សាយុទ្ធសាស្ត្រ (IISS) ទស្សនទានរបស់ OSMOs (ពេលខ្លះសំដៅលើអង្គការដែលមានលំនាំជាកងទ័ព) រួមមាន "កងអាវុធហត្ថ" គយ និងឆ្មាំព្រំដែន ប្រសិនបើកម្លាំងទាំងនេះទទួលនូវការហ្វឹកហ្វឺនពីកលយុទ្ធយោធា មានបំពាក់ឧបករណ៍ដូចជាកងកម្លាំងយោធា និងប្រតិបត្តិការនៅក្រោមអាជ្ញាធរយោធា នៅក្នុងករណីដែលមានសង្គ្រាម។

ប្រទេសស្ទើរទាំងអស់នៅក្នុងពិភពលោក មាន OSMOs ក្រៅពីយោធា។ អង្គការទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយយោធា ហើយក្នុងករណីខ្លះ យោធាផ្ដល់នូវឧបករណ៍ ការអនុញ្ញាតឲ្យចេញចូលមូលដ្ឋានយោធា ផ្ដល់នូវការហ្វឹកហ្វឺន និងជំនួយផ្សេងៗដល់ OSMOs។

នៅក្នុងស្ថានភាពខ្លះ OSMOs អនុវត្តនូវបច្ចេកទេសយោធាដែលមិនមានលក្ខណៈសមស្របដើម្បីបង្ក្រាបសកម្មភាពស៊ីវិល និង/ឬ ទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ដោយសារការប្រើ OSMOs អាចធ្វើឲ្យមានការភ័ន្តច្រឡំរវាងកងកម្លាំងនគរបាល និងកងកម្លាំងយោធា វាសំខាន់ខ្លាំងណាស់ថា តួនាទី និងឋានៈរបស់ពួកគេត្រូវមានការកំណត់ឲ្យបានច្បាស់។ មានការគាំទ្រមិនឲ្យបញ្ចូលការចូលរួមរបស់ពួកគេនៅក្នុងប្រតិបត្តិការរក្សាសន្តិសុខផ្ទៃក្នុង។ សភាគួរអនុម័តច្បាប់ដ៏សមស្របគ្រប់គ្រងលើបញ្ហានេះ និងត្រួតពិនិត្យនូវសកម្មភាពរបស់រដ្ឋាភិបាល។ ប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីត្រូវអនុញ្ញាតឲ្យមានការត្រួតពិនិត្យដោយសភាទៅលើ OSMOs នេះមិនត្រឹមដោយសារតែច្បាប់ចែងថា រាល់កម្លាំងណាក៏ដោយដែលទទួលមូលនិធិពីរដ្ឋត្រូវតែស្ថិតនៅក្រោមការត្រួតពិនិត្យដោយសភាប៉ុណ្ណោះនោះទេ តែក៏ព្រោះថាវាមានបញ្ហាប្រឈម និងគ្រោះថ្នាក់ដែលអាចកើតមាន ដោយការប្រើប្រាស់កម្លាំងនេះយ៉ាងទូលំទូលាយ ដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវទៀតផង។

**ប្រអប់ទី ២០**

**ឧទាហរណ៍នៃអង្គភាពយោធារដ្ឋផ្សេងទៀតនៅក្នុងប្រទេសមួយចំនួន**

| ប្រទេស | ចំនួនបុគ្គលិកសកម្ម នៅក្នុងកងកម្លាំង ប្រដាប់អាវុធ សរុប | បុគ្គលិកនៅក្នុង កងកម្លាំងយោធារដ្ឋ ដទៃទៀត | ប្រភេទអង្គភាព យោធារដ្ឋ ដទៃទៀត |
| --- | --- | --- | --- |
| ហ្វាំងឡង់ | ៣១,៧០០ | ៣,៤០០ | ឆ្មាំព្រំដែន |
| សហរដ្ឋអាមេរិក | ១,៣៦៥,៨០០ | ៥៣,០០ | យាមល្បាតតាមអាកាសជាលក្ខណៈស៊ីវិល |
| សហព័ន្ធរុស្ស៊ី | ១,០០៤,១០០ | ៤២៣,០០ | ឆ្មាំព្រំដែន ទ័ពនិងកម្លាំងក្រសួងមហាផ្ទៃសម្រាប់ការពារសហព័ន្ធរុស្ស៊ី សេវាសន្តិសុខសហព័ន្ធ ទីភ្នាក់ងារទំនាក់ទំនងនិងព័ត៌មាន កងទ័ពអយស្ម័យយាន ។ល។ |
| ម៉ូរ៉ូក្កូ | ១៩៨,៥០០ | ៤២,០០០ | កងរាជអាវុធហត្ថ ទ័ពជំនួយ ។ល។ |
| បារាំង | ២៩៤,៤៣០ | ៩៤,៩៥០ | កងរាជអាវុធហត្ថ ជាពិសេសកងសន្តិសុខសាធារណៈរបស់ក្រសួងមហាផ្ទៃ នៅ `Carabinieri´ |
| អ៊ីតាលី | ២៥០,៦០០ | ២៥២,៥០០ | |
| តួគី | ៦០៩,៧០០ | ២២០,២០០ | កងរាជអាវុធហត្ថ/ ឆ្មាំជាតិ/ ឆ្មាំសមុទ្រ |
| ប៊ូគីណា ហ្វាសូ | ១០,០០០ | ៤,៤៥០ | កងអាវុធហត្ថ ក្រុមហ៊ុនសន្តិសុខ |
| ឈីលី | ៨៧,០០០ | ២៩,៥០០ | `Carabineros´ កងទ័ពការពារជនស៊ីវិល និងនគរបាលសមុទ្រ រួមមាន នគរបាល នគរបាលសមុទ្រ និងកងកម្លាំងយោធា ជំនួយក្នុងតំបន់ |
| សាធារណៈរដ្ឋកូរ៉េ | ៦៨៣,០០០ | ៣,៥០០,០០០ | |
| ឥណ្ឌូនេស៊ី | ២៩៧,០០០ | ១៩៥,០០០ | |

*ប្រភព៖ IISS តុល្យភាពយោធា ២០០០-២០០១ ទីក្រុងឡុងដ៍*

## មុខងាររបស់អង្គការយោធារដ្ឋដទៃទៀត

ជាញឹកញាប់ OSMOs បំពេញមុខងារមួយចំនួនធំដូចខាងក្រោម៖

- ✓ ត្រួតពិនិត្យព្រំដែនរួមទាំងត្រួតពិនិត្យលើការជួញដូរទំនិញ និងមនុស្សដោយខុសច្បាប់
- ✓ គ្រប់គ្រងលើកូដកម្ម
- ✓ រក្សាច្បាប់ និងសណ្តាប់ធ្នាប់ក្នុងស្ថានភាពអាសន្ន និងការពារប្រធានរដ្ឋ និងទីតាំងបំពាក់អាវុធធំៗ ដូចជា រោងចក្រនុយក្លេអ៊ែរជាដើម។

### ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

សូមអានផ្នែកពាក់ព័ន្ធ ដែលមាននៅក្នុងជំពូកមុន និងជំពូកខាងក្រោម។

# ជំពូកទី ១០

# រចនាសម្ព័ន្ធនគរបាល

## នគរបាលនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ

នគរបាលត្រូវធ្វើប្រតិបត្តិការនៅក្នុងរង្វង់នីតិរដ្ឋជាដាច់ខាត។ ពួកគេត្រូវបានគ្រប់ដណ្តប់ដោយច្បាប់តែមួយ ដោយពួកគេត្រូវអនុវត្ត និងលើកស្ទួយច្បាប់។ លើសពីនេះ នគរបាលមានតួនាទីខុសពីស្ថាប័នសំខាន់ៗផ្សេងទៀត នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា ការិយាល័យព្រះរាជអាជ្ញា តុលាការ ឬមណ្ឌលកែប្រែ។ យោងតាមទស្សនៈនៃអភិបាលកិច្ចល្អ រដ្ឋទាំងអស់ត្រូវរក្សាសន្តិសុខជូនសាធារណៈជន រួមទាំងគោរពសេរីភាព និងសិទ្ធិមនុស្សរបស់បុគ្គល។ ប្រជាពលរដ្ឋនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ មានសិទ្ធិទទួលបាននូវការប្រព្រឹត្តចំពោះខ្លួនដោយយុត្តិធម៌ មិនលម្អៀង និងមានលក្ខណៈអាចប៉ាន់ប្រមាណទុកជាមុនបាន នៅពេលនគរបាលចុះបំពេញភារកិច្ចរបស់ពួកគេ។ ការអនុវត្តវិធានការរបស់នគរបាលមកលើសាធារណៈជនអាចចាត់ទុកថាជាសូចនករ (Indication) ដ៏សំខាន់មួយដែលបញ្ជាក់ពីគុណភាពលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនោះ។

**ប្រអប់ទី ២១**

### លក្ខណៈសំខាន់ៗនៃកងកម្លាំងនគរបាលនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ

- ▷ នគរបាលត្រូវគោរពនីតិរដ្ឋ និងបំពេញភារកិច្ចស្របតាមក្រមសីលធម៌វិជ្ជាជីវៈនគរបាល។
- ▷ តាមបែបលទ្ធិប្រជាធិបតេយ្យ នគរបាលត្រូវរក្សាសន្តិសុខជូនសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងគោរពសិទ្ធិមនុស្ស។
- ▷ នគរបាលត្រូវមានគណនេយ្យភាព តម្លាភាព និងត្រូវមានយន្តការសម្រាប់ត្រួតពិនិត្យទាំងខាងក្នុង និងខាងក្រៅ។
- ▷ ការអនុវត្តភារកិច្ចរបស់នគរបាលតាមបែបប្រជាធិតេយ្យ គឺជាការអនុវត្តភារកិច្ចតាមខ្សែបណ្តោយពីក្រោមទៅលើដោយ ធ្វើការឆ្លើយតបចំពោះតម្រូវការនិងទុក្ខកង្វល់របស់ប្រជាពលរដ្ឋម្នាក់ៗ និងក្រុមសហគមន៍ ហើយនគរបាលត្រូវធ្វើឲ្យទទួលនូវភាពជឿជាក់ ការយល់ព្រម និងការគាំទ្រពីសាធារណជន។ ដូច្នេះ ទាំងអស់នេះអាចសម្រេចបានលុះត្រាតែមានតម្លាភាព និងការសន្ទនាគ្នា។ ក្នុងន័យនេះ នៅក្នុងប្រទេសជាច្រើនមានការធ្វើវិមជ្ឈការនូវអំណាចនគរបាល ដើម្បីឲ្យមានការឆ្លើយតប គ្រប់ជ្រុងជ្រោយ និងបានរហ័សស្របតាមតម្រូវការរបស់មូលដ្ឋាន។

## តម្រូវការឲ្យមានការការពារជាពិសេស

ស្ថាប័ននគរបាល គឺជាឧបករណ៍របស់អង្គនីតិប្រតិបត្តិ ហើយពួកគេមានសិទ្ធិអំណាចផ្តាច់មុខចាប់បង្ខំស្របច្បាប់ នៅក្នុងសង្គមក្នុងការបំពេញភារកិច្ចរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារពួកគេមានសមត្ថកិច្ចបែបនេះ ហើយទើបស្ថាប័នមួយនេះ ត្រូវបានគេប្រើប្រាស់ជាឧបករណ៍របស់រដ្ឋសម្រាប់ធ្វើការរំលោភបំពាន ការប្រព្រឹត្តហិង្សា និងបង្ក្រាបលើសិទ្ធិមនុស្ស និងអំពើពុករលួយ។

ដូច្នេះហើយ ទើបសេវានគរបាលនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ តម្រូវឲ្យមានការការពារពិសេស ដើម្បីធានាថាពួកគេពិតជាបម្រើ និងការពារផលប្រយោជន៍របស់សង្គម មិនមែនការពារផលប្រយោជន៍របស់អ្នកនយោបាយ អ្នកការិយាល័យធិបតេយ្យ ឬស្ថាប័ននគរបាលខ្លួនឯងនោះទេ។ នគរបាលត្រូវមានឆន្ទានុសិទ្ធិ និងបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ តែពួកគេត្រូវគោរពនូវគោលការណ៍ មិនលម្អៀងក្នុងការលើកស្ទួយច្បាប់ និងត្រូវអនុវត្តភារកិច្ចតាមវិជ្ជាជីវៈនគរបាល។ មន្ត្រីនគរបាលត្រូវយល់ដឹងនិងគោរពដោយខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈនគរបាល។ ក្រៅពីគោរពក្រមសីលធម៌ នគរបាល ត្រូវគោរពសិទ្ធិមានជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូប ក៏ដូចជាត្រូវមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រើប្រាស់កម្លាំង តែក្នុងករណីចាំបាច់ដើម្បីគាំទ្រសកម្មភាពស្របច្បាប់ និងមិនប្រើប្រាស់កម្លាំងហួសពីភាពចាំបាច់ និងហួសពីច្បាប់អនុញ្ញាតឡើយ។ ការប្រើប្រាស់កម្លាំងដោយកម្លាំងនគរបាល ជានិច្ចជាកាលត្រូវគោរពវិធានសមាមាត្រ (the rule of proportionality)។ បន្ថែមពីឋានានុក្រម ប្រកបដោយគណនេយ្យភាពខាងក្រៅ ទាំងផ្នែកនយោបាយ និងតុលាការ (សូមអានជំពូក៣) ឋានានុក្រមប្រកបដោយគណនេយ្យភាពផ្ទៃកខាងក្នុង ឬឋានានុក្រម ប្រកបដោយគណនេយ្យភាពបែបការិយាល័យធិបតេយ្យ ក៏គួរតែមានផងដែរ។ ជានិច្ចជាកាល ត្រូវមានអង្គភាពស៊ើបអង្កេតផ្ទៃក្នុង ទៅលើការប្រព្រឹត្តកំហុសរបស់នគរបាលតាមការចោទប្រកាន់ និងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ នៅក្នុងប្រព័ន្ធនគរបាលដែលមានវិជ្ជាជីវៈ។

**ប្រអប់ទី ២២**

### ការបំភ័ន្ត និងកាលៈទេសៈប្រកបដោយគ្រោះថ្នាក់

"អភិបាលកិច្ចលើកម្លាំងសន្តិសុខ មិនតាមបែបប្រជាធិបតេយ្យក៏អាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាអាទិភាពផងដែរ។ នៅក្នុងប្រទេសជាច្រើន ភាពលម្អៀងទៅរកសន្តិសុខយោធាបណ្តាលឲ្យរដ្ឋាភិបាលងាកទៅរកការកែប្រែកងកម្លាំងនគរបាល ទៅជាកងកម្លាំងយោធា (ដែលធ្វើឲ្យមានការពិបាកក្នុងការបែងចែកមួយណាជានគរបាល និងមួយណាជាយោធាពិតប្រាកដ) ឬរដ្ឋាភិបាលផ្គត់ផ្គង់មូលនិធិ មិនគ្រប់គ្រាន់ដល់កងកម្លាំងនគរបាល ដែលធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពនៃការធានាសុវត្ថិភាព និងសន្តិសុខជូនប្រជាពលរដ្ឋ។ ជាពិសេសនៅក្នុងប្រទេសមានប្រាក់ចំណូលទាប នគរបាល និងកម្លាំងសន្តិសុខផ្សេងទៀត ទទួលបានប្រាក់ខែចិញ្ចឹមជីវិត

ស្មើមិនរស់ ទទួលបានការបណ្តុះបណ្តាលតិចតួច ឬមិនទទួលបានការបណ្តុះបណ្តាលសោះ អ្នកគ្រប់គ្រងពុករលួយ និងកម្រិតនៃអវិជ្ជាខ្ពស់"។ ... "មេដឹកនាំដែលបានជាប់ឆ្នោតនៅក្នុងប្រទេសដែលលទ្ធិប្រជាធិបតេយ្យទើបដុះពន្លក ជាញឹកញាប់ពឹងផ្អែកលើកម្លាំងសន្តិសុខ ក្នុងនោះក៏មានអង្គភាពយោធាផងដែរ ដើម្បីរក្សាតំណែងរបស់ខ្លួន ពីព្រោះកងកម្លាំងទាំងនោះមានអំណាចបំផុតនៅក្នុងសង្គម។ ដូចគ្នាផងដែរ មេដឹកនាំបែបនេះអាចមិនមានគណនេយ្យភាព និងតម្លាភាពចំពោះកងទ័ព ពីព្រោះពួកគេពឹងផ្អែកលើអំណាចរបស់យោធាដើម្បីរក្សាអំណាចរបស់ខ្លួន។

*របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០០២*

## គំនិតផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន

ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យទៅលើនគរបាល ក៏អាចត្រូវបានពង្រឹងតាមរយៈយន្តការមិនផ្លូវការពីក្រោមទៅលើ ដូចជាតាមរយៈអង្គការសិទ្ធិមនុស្សដែលធ្វើការនៅក្នុងសហគមន៍មូលដ្ឋាន ដែលពួកគេអាចជួយធានាឲ្យកងកម្លាំងនគរបាលទទួលបាននូវទំនុកចិត្តពីសាធារណៈជន។ ស្ថាប័នត្រួតពិនិត្យជាលក្ខណៈស៊ីវិល ដូចជាមន្ត្រីរដ្ឋទទួលពាក្យបណ្តឹងពីសាធារណៈ ប្តឹងចំពោះនគរបាល អាចផ្តល់គណនេយ្យភាពបន្ថែមចំពោះសហគមន៍ដែលពួកគេបម្រើ។ នៅក្នុងករណីខ្លះ ការបង្កើតនូវក្រុមប្រឹក្សាសន្តិសុខខេត្ត ក្នុងនោះមានក្រុមសង្គមស៊ីវិល និងមេដឹកនាំមូលដ្ឋាន ពិតជាបានជួយកែលំអរសេវានគរបាលនៅថ្នាក់មូលដ្ឋាន។ គេត្រូវមានច្បាប់សម្រាប់ការពារអ្នកដែលផ្តល់ព័ត៌មាន និងក្រុមសង្គមស៊ីវិលដែលដើរតួនាទីជាអ្នកឃ្លាំមើលនូវអំពើធ្វើទុក្ខបុកម្នេញរបស់នគរបាលទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ និងយោធា។

**ប្រអប់ទី ២៣**

### នគរបាលនៅក្នុងប្រទេសអេរីទ្រា៖ ករណីដែលកំពុងវិវត្តន៍ទៅមុខ

ទំនាក់ទំនងរវាងស្ថាប័ននគរបាល និងបរិស្ថានជុំវិញរបស់ស្ថាប័ននេះ មានសភាពចម្រុះ។ ស្ថាប័ននគរបាលធ្វើការលើទិដ្ឋភាពធំៗ២៖ ការប្រើប្រាស់កម្លាំងដើម្បីលើកស្ទួយច្បាប់ និងផ្តល់សេវាដល់សាធារណៈជនទូទៅ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសអេរីទ្រា ភាពមិនចុះសម្រុងគ្នា (dilemma) បែបនេះត្រូវបានគេមើលឃើញច្បាស់ក្រឡែត។ ប្រទេសនេះបានតស៊ូរំដោះប្រទេសចេញពីនឹមត្រួតត្រាប្រទេសអេត្យូពី រយៈពេល៣០ឆ្នាំមកហើយ ដែលការតស៊ូបែបនេះមិនទាន់ដល់ទីបញ្ចប់នៅឡើយទេ ដោយហេតុថាមានការវាយប្រហារគ្នាឡើងវិញនៅក្នុង

ឆ្នាំ១៩៩៨ និង ១៩៩៩។ កងកម្លាំនគរបាលដែលមានបុគ្គលិកប្រហែល ៥,០០០នាក់ សុទ្ធតែជាអតីតកងទ័ពរំដោះជាតិ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០។ មូលហេតុនោះ គឺសាមញ្ញនោះទេ៖ រដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដល់អតីតយុទ្ធជន។ មន្ត្រីជាមេដឹកនាំខ្លះ មានប្រវត្តិជានគរបាលបម្រើការងារជានាយនគរបាល នៅក្នុងអតីតនគរបាលចម្រុះរបស់ប្រទេសអេរីទ្រា និងប្រទេសអេត្យូពី។

បន្ទាប់មកទៀត មានជំនួយបច្ចេកទេសផ្សេងៗដែលត្រូវបានផ្តល់ដោយរដ្ឋាភិបាលហុល្លង់នៅក្នុងផ្នែកស៊ើបអង្កេតព្រហ្មទណ្ឌ ការបង្កើតនូវសភានគរបាល ការបង្កើតនូវកម្មវិធីសិក្សា។ ដូច្នេះ វាជាក់ស្តែងណាស់គឺ មានការប្រែប្រួលនូវវប្បធម៌ខ្លះៗ យ៉ាងហោចណាស់ពី ម្ចាស់ជំនួយនិងមេដឹកនាំឆ្មើមខ្លះនៅក្នុងប្រទេស។ អ្នកដែលធ្លាប់បម្រើការងារជាយោធាក្នុងប្រទេសអេរីទ្រា មានទស្សនៈអំពីការប្រើប្រាស់កម្លាំងខុសពីការប្រើប្រាស់កម្លាំងក្នុងប្រទេសប្រជាធិបតេយ្យ ឧ.តម្រួតអង់គ្លេស។ គម្រោងផ្លាស់ប្តូរវប្បធម៌នៅក្នុងកងកម្លាំងនគរបាលអេរីទ្រា ដោយមានជំនួយពីរដ្ឋាភិបាលហុល្លង់ មានគោលបំណងធ្វើឲ្យសម្រេចជោគជ័យនូវការកសាង កម្លាំងនគរបាលប្រជាធិបតេយ្យមួយដែលរក្សាច្បាប់ និងសណ្តាប់ធ្នាប់ដោយប្រើប្រាស់កម្លាំងជាអប្បបរមា។

*ប្រភព៖ Casper W. Vroom, សាកលវិទ្យាល័យ Maastricht, The Netherlands,*
*គម្រោងផ្លាស់ប្តូរវប្បធម៌នៃកងកម្លាំងនគរបាលអេរីទ្រា ឆ្នាំ២០០២*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ក្នុងក្របខណ្ឌប្រជាធិបតេយ្យ

- ▷ សភាត្រូវមើលថាតើ នគរបាលអនុវត្តនូវភារកិច្ចរបស់ខ្លួននៅក្នុងរង្វង់នីតិរដ្ឋ ឬមួយយ៉ាងណា។
- ▷ សភាត្រូវមើលថាតើ នគរបាលអនុវត្តនូវភារកិច្ចរបស់ខ្លួនស្របតាមក្រមសីលធម៌ដែលប្រជាពលរដ្ឋរំពឹងចង់បានឬយ៉ាងណា ដូចជា ការប្រព្រឹត្តដោយយុត្តិធម៌មិនលម្អៀង និងអាចប្រមើលមើលទុកជាមុនបាន។ ក្នុងន័យនេះ សភាត្រូវមើលថាតើ រដ្ឋបានគោរពដោយខ្ជាប់ខ្ជួនតាមក្រមសីលធម៌អង្គការសហប្រជាជាតិ សម្រាប់មន្ត្រីអនុវត្តច្បាប់ (១៩៧៩) ដែរឬយ៉ាងណា៖ មើលប្រអប់ទី៦៥។

### ការបណ្តុះបណ្តាល

- ▷ ត្រូវមើលថាតើ នគរបាលបានទទួលការបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈសម្រាប់រក្សាច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈក្នុងកម្រិតជាអប្បបរមាឬយ៉ាងណា។ តើនគរបាល

បានទទួលការបណ្តុះបណ្តាលអំពីក្រមសីលធម៌ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង បញ្ហាយេនឌ័រដែរឬយ៉ាងណា។ មើលជំពូកទី៧ បន្ថែម។

មើលបន្ថែមនូវអនុសាសន៍នៅក្នុងផ្នែកទី VI, VII, VIII ស្តីពីធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានសម្ភារៈ។

## ជំពូកទី ១១

# ការរក្សាការសម្ងាត់ និងសេវាចារកម្ម

សេវាចារកម្ម (ពេលខ្លះក៏ហៅថា "សេវាសន្តិសុខ) គឺជាផ្នែកដ៏សំខាន់មួយរបស់រដ្ឋ ដែលទទួលបន្ទុកធ្វើការវិភាគឯករាជ្យ នូវព័ត៌មានពាក់ព័ន្ធជាមួយសន្តិសុខរបស់រដ្ឋ និងសង្គម ព្រមទាំងការពារផលប្រយោជន៍ធំៗរបស់រដ្ឋ និងសង្គមផងដែរ។ ទោះបីជាសេវានេះ ពឹងផ្អែកលើអង្គនីតិប្រតិបត្តិក៏ដោយ ក៏សភាមានតួនាទីដ៏សំខាន់ក្នុងការត្រួតពិនិត្យនូវសកម្មភាពរបស់ពួកគេផងដែរ។

ការគម្រាមកំហែង និងបញ្ហាប្រឈមថ្មីៗចំពោះសន្តិសុខខាងក្នុងប្រទេស ដែលបណ្តាលមកពីអំពើភេរវកម្មអន្តរជាតិ ការជួញដូរគ្រឿងញៀន ការរត់ពន្ធឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងការធ្វើចំណាកស្រុកដោយខុសច្បាប់ តម្រូវឲ្យមានការពង្រឹងនូវសមត្ថភាពខាងស៊ើបការណ៍សម្ងាត់។ ជាពិសេស បន្ទាប់ពីមានព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ មក ការទទួលបាននូវព័ត៌មានដ៏គួរឲ្យទុកចិត្ត គឺជារឿងសំខាន់។ ប៉ុន្មានខែក្រោយពីមានការវាយប្រហារ (១១ ខែកញ្ញា) រដ្ឋាភិបាលនៃប្រទេសមួយចំនួនបានផ្តល់សិទ្ធិអំណាចដល់សេវាស៊ើបការណ៍សម្ងាត់ ដូចជា ការឆែកទំនាក់ទំនងតាមអ៊ីនធឺណែត ការឆ្លើយឆ្លងតាមទូរស័ព្ទ និងទំនាក់ទំនងតាមហ្វាក់ (មើលជំពូកទី២០ ស្តីពី អំពើភេរវកម្ម)។

បច្ចេកវិទ្យាថ្មីៗ កំពុងពង្រីកសមត្ថភាពផ្នែកស៊ើបយកការណ៍ រុករក និងចាប់ជនដែលស្ថិតក្នុងការសង្ស័យ។ មានការពង្រីកសហប្រតិបត្តិការកាន់តែច្រើនឡើង ជាមួយសេវាស៊ើបការណ៍សម្ងាត់នានាទាំងក្នុង និងក្រៅប្រទេស។ ពិតណាស់វាអាស្រ័យលើសភាក្នុងការធានាថា ការកើនឡើងនូវសិទ្ធិអំណាចរបស់សេវាស៊ើបការណ៍សម្ងាត់ វាមិនផ្ទុយពីគោលការណ៍និងច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្សនោះឡើយ។

## ភារកិច្ចនៃសេវាចារកម្ម

លក្ខណៈដើមនៃសេវាចារកម្ម គឺការប្រមូលនិងការវិភាគព័ត៌មាន។ ភារកិច្ចបែបនេះតម្រូវឲ្យមានការរក្សាការសម្ងាត់ក្នុងកម្រិតខ្ពស់។ និយាយម្យ៉ាងទៀត វាអាចបង្កជាគ្រោះថ្នាក់នៅពេលដែលមានការបំពានដល់ព័ត៌មានសម្ងាត់ នៅក្នុងបរិបទនយោបាយក្នុងប្រទេស។ សេវាចារកម្មអាចក្លាយជាការគម្រាមកំហែងដល់សង្គម និងប្រព័ន្ធនយោបាយ ដែលពួកគេមានភារកិច្ចការពារ។ ដូច្នេះ វាមានការចាំបាច់ឲ្យមានការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ និងដោយសភាទៅលើសេវាចារកម្ម បន្ថែមពីលើការត្រួតពិនិត្យដោយនីតិប្រតិបត្តិ។ មានតែប្រព័ន្ធត្រួតពិនិត្យតុល្យភាព នៃអំណាច

ប៉ុណ្ណោះ ដែលអាចទប់ស្កាត់នីតិប្រតិបត្តិ ឬសភាពីការប្រើប្រាស់មិនត្រឹមត្រូវនូវសេវាចារកម្មសម្រាប់បម្រើផលប្រយោជន៍នយោបាយរបស់ខ្លួនផ្ទាល់។

នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ សេវាចារកម្មត្រូវខិតខំអនុវត្តភារកិច្ចប្រកបដោយប្រសិទ្ធភាព ត្រូវមានអព្យាក្រិតផ្នែកនយោបាយ (គ្មានបក្ខពួក) ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ ត្រូវប្រតិបត្តិនៅក្នុងរង្វង់នៃអាណត្តិស្របច្បាប់របស់ខ្លួន និងស្របតាមបទដ្ឋានច្បាប់រដ្ឋធម្មនុញ្ញ និងការអនុវត្តតាមបែបប្រជាធិបតេយ្យទាំងឡាយរបស់រដ្ឋ។

ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យទៅលើសេវាចារកម្ម គួរចាប់ផ្តើមដោយមានក្របខណ្ឌច្បាប់ច្បាស់លាស់ គឺច្បាប់ដែលបង្កើតអង្គការចារកម្មនេះ នៅក្នុងលក្ខន្តិកៈរបស់រដ្ឋដែលអនុម័តយល់ព្រមដោយសភា។ លក្ខន្តិកៈទាំងនេះ គួរបញ្ជាក់បន្ថែមទៀតនូវព្រំដែននៃសិទ្ធិអំណាច វិធីសាស្ត្រ និងមធ្យោបាយនៃការធ្វើប្រតិបត្តិការ និងគណនេយ្យភាពដែលសេវាចារកម្មនេះត្រូវមាន។

**ប្រអប់ទី ២៤**

**សភា និងមូលនិធិពិសេសដែលត្រូវបានផ្តល់ឲ្យសេវាចារកម្មៈ ឧទាហរណ៍នៃប្រទេសអាហ្សង់ទីន**

"ច្បាប់លេខ ២៥.៥២០ ស្តីពីអង្គភាពជាតិស៊ើបការណ៍សម្ងាត់ (ថ្ងៃទី២៧ ខែវិច្ឆកា ឆ្នាំ២០០១)។ មាត្រា ៣៧៖ "គណៈកម្មការជាតិទ្វិសភា (Bicameral Committee) នៃសភាជាតិមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ "ការបែងចែកថវិកា" ទៅឲ្យផ្នែកផ្សេងៗនៃអង្គភាពជាតិស៊ើបការណ៍សម្ងាត់។ ក្នុងគោលបំណងនេះ គណៈកម្មការជាតិទ្វិសភានៃសភាជាតិអាចអនុវត្តនូវវិធានការទាំងឡាយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសៈ

១. ដើម្បីចូលរួម និងធ្វើអន្តរាគមន៍នៅក្នុងកិច្ចពិភាក្សាអំពីច្បាប់ ថវិកាជាតិដែលអំណាចនីតិប្រតិបត្តិបញ្ជូនមកសភា។ ក្នុងន័យនេះ អំណាចនីតិប្រតិបត្តិបញ្ជូនរាល់ឯកសារដែលចាំបាច់ទាំងអស់ ជាពិសេស ក) ឧបសម្ព័ន្ធស្តីពីថវិកាបម្រុង ថវិកាសម្ងាត់ ថវិកាមានកម្រិត ខ) ឧបសម្ព័ន្ធដែលមានបញ្ជាក់ពី គោលបំណងកម្មវិធី និងគោលបំណងនៃការចំណាយ។

២. ដើម្បីសុំជំនួយពីអង្គការស៊ើបការសម្ងាត់ទាំងអស់ដែលបាន បញ្ចូលនៅក្នុងច្បាប់នេះ ដែលជម្រុញឲ្យមានការផ្តល់គ្រប់ទិន្នន័យទាំងអស់ ប្រវត្តិ និងរបាយការណ៍ទាក់ទងនឹងមុខងាររបស់អង្គការទាំងនោះ។ ក្នុងករណីចាំបាច់ ទិន្នន័យ និងឯកសារដែលមានចែងនៅក្នុងមាត្រា ៣៩ នៃច្បាប់នេះ ក៏ត្រូវអោយមានផងដែរ។

៣. ដើម្បីត្រួតពិនិត្យមើលថាតើបែងចែកថវិកាត្រូវបានផ្តល់ស្របតាមគោលបំណង ដែលមានចែងនៅក្នុងច្បាប់ថវិកាដែរ ឬយ៉ាងណា។

៤. ដើម្បីរៀបចំជារបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនសភាជាតិ និងប្រធានាធិបតី ក្នុងនោះមានៈ

ក) របាយការណ៍វិភាគ និងវាយតម្លៃលើការចាយវាយថវិកា ដែលបានផ្តល់ឲ្យអង្គការស៊ើបការសម្ងាត់
ខ) របាយការណ៍ពន្យល់អំពីលទ្ធផលនៃការត្រួតពិនិត្យ និងសកម្មភាពត្រួតពិនិត្យរបស់គណៈកម្មការ ទ្វិសភា រួមទាំងអនុសាសន៍ផ្សេងៗ"។

*ប្រភព៖ ច្បាប់លេខ ២៥.៥២០ ស្តីពីអង្គភាពជាតិស៊ើបការណ៍សម្ងាត់នៃប្រទេសអាហ្សង់ទីន ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០១*

រដ្ឋភាគច្រើនធ្វើការត្រួតពិនិត្យតាមដានជាផ្លូវការជាធម្មតាតាមរយៈគណៈកម្មការត្រួតពិនិត្យរបស់សភា។ វង្វង់សមត្ថកិច្ចរបស់គណៈកម្មការសភា ដែលបានបង្កើតរួចហើយ ដូចជាគណៈកម្មការការពារជាតិ ឬគណៈកម្មការកងកម្លាំងប្រដាប់អាវុធរបស់សភា ពេលខ្លះត្រូវបានពង្រីកដោយបញ្ចូលបញ្ហាទាក់ទងនឹងការស៊ើបយកការណ៍សម្ងាត់ថែមទៀត។ នៅក្នុងប្រទេសខ្លះ សភាបានបង្កើតគណៈកម្មការ ឬអនុគណៈកម្មការដែលត្រួតពិនិត្យជាពិសេសលើសេវាស៊ើបការណ៍សម្ងាត់។

គណៈកម្មការត្រួតពិនិត្យរបស់សភា ត្រូវបានធានានូវសិទ្ធនូវព័ត៌មាន មានតួនាទីក្នុងការតែងតាំងប្រធាននៃសេវាស៊ើបការណ៍សម្ងាត់ និងប្រធានត្រួតពិនិត្យថវិកា (មើលប្រអប់ទី២៤ ស្តីពីមូលនិធិពិសេស)។

ក្រៅពីគណៈកម្មការមានសមត្ថកិច្ចរបស់សភា ឬមិនមានគណៈកម្មការនេះ រដ្ឋខ្លះបានបង្កើតជាផ្លូវការនូវគណៈកម្មការត្រួតពិនិត្យលើការស៊ើបការណ៍សម្ងាត់ នៅខាងក្រៅអង្គនីតិប្រតិបត្តិ ឬឧទ្ទកាល័យ។ ជាធម្មតាស្ថាប័នត្រួតពិនិត្យរបស់ឧទ្ទកាល័យក្នុងកម្រិតនីតិប្រតិបត្តិបំពេញសកម្មភាពត្រួតមើលមុខងារផ្នែកគ្រប់គ្រង ឬរដ្ឋបាលមិនសូវមានភាពឯករាជ្យទៅលើរចនាសម្ព័ន្ធដទៃ ដូចដែលគណៈកម្មការសភាដែលមានតំណាងមកពីគណបក្សនយោបាយចម្រុះនោះទេ។

**ប្រអប់ទី ២៥**

## ការអនុវត្តខ្លះៗរបស់គណៈកម្មការសភាទាក់ទងនឹងឯកសារសម្ងាត់

- ▷ ប្រសិនបើចាំបាច់គណៈកម្មការត្រូវជួបប្រជុំបិទទ្វា។
- ▷ គណៈកម្មការរាយការណ៍ជូនសភាពេញអង្គ ដោយមានការពិភាក្សាដេញដោលជាសាធារណៈ (លើបញ្ហាមិនសម្ងាត់)។
- ▷ គណៈកម្មការមានសិទ្ធិស្នើសុំព័ត៌មានណាមួយដែលមិនបង្ហើប នូវព័ត៌មានអំពីប្រតិបត្តិការដែលកំពុងអនុវត្ត ឬស្នើសុំឈ្មោះ និងបុគ្គលិករបស់សេវាចារកម្ម។
- ▷ គណៈកម្មការអាចបញ្ចេញព័ត៌មានណាមួយបន្ទាប់ពីខ្លួនបានកំណត់ (តាមមតិភាគច្រើនដាច់ខាត ឬមតិភាគច្រើនធម្មតា) ថាព័ត៌មាននោះវាមានផលប្រយោជន៍ដល់សាធារណៈជន។

▷ គណៈកម្មការមិនដាក់កំហិតខ្លួនឯងចំពោះព័ត៌មានដែលត្រូវបានស្នើសុំនោះទេ។ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន រដ្ឋមន្ត្រីទទួលបន្ទុកលើសេវាចារកម្មត្រូវផ្តល់ព័ត៌មានដល់គណៈកម្មការនៅពេលណាដែលព័ត៌មានបែបនោះអាចជួយធ្វើឲ្យមានការយល់ដឹងពេញលេញ។

## កម្រិតសម្រាប់សេវាចារកម្មនៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ

ទម្រង់ដ៏ជាក់លាក់ នៃការត្រួតពិនិត្យលើសេវាស៊ើបការណ៍សម្ងាត់ ទទួលរងឥទ្ធិពលពីប្រពៃណីច្បាប់ ប្រព័ន្ធនយោបាយ និងកត្តាប្រវត្តិសាស្ត្ររបស់រដ្ឋ។ ឧទាហរណ៍ប្រទេសខ្លះ ទទួលរងឥទ្ធិពលពីប្រទេសអង់គ្លេស ដែលប្រពៃណីច្បាប់របស់គេគឺអនុវត្ត "ខំមិនឡូ" (common law) ដូច្នេះប្រទេសទាំងនេះ ប្រើប្រាស់តុលាការជាអ្នកត្រួតពិនិត្យទៅវិញ។ ផ្ទុយទៅវិញការត្រួតពិនិត្យដោយសភាទំនងមានការគាំទ្រច្រើនដោយប្រទេសនៅទ្វីបអឺរ៉ុប និងប្រទេសដែលទទួលរងការគាបសង្កត់ពីអំណាចនគរបាលនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប។ សហរដ្ឋអាមេរិកមានយន្តការត្រួតពិនិត្យនៅក្នុងអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងតុលាការសហព័ន្ធ។ ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យខ្លះបានបង្កើតស្ថាប័ន ឬការិយាល័យរបស់មន្ត្រីរដ្ឋ និងដោះស្រាយពាក្យបណ្តឹងដែលមានសិទ្ធិអំណាចធ្វើការស៊ើបអង្កេតនូវការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស ដោយសេវាចារកម្ម និងមានសិទ្ធិអំណាចក្នុងការជម្រាបជូនសាធារណជន អំពីលទ្ធផលនៃការស៊ើបអង្កេតនោះ (មើលជំពូក១៦ អំពីមន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹង)។

### វិសាលភាព

ជាញឹកញាប់នៃការត្រួតពិនិត្យលើសេវាស៊ើបការណ៍សម្ងាត់មានវិសាលភាពមិនទូលំទូលាយ។ នេះវាអាចពាក់ព័ន្ធជាមួយប្រភេទ នៃសកម្មភាពស៊ើបការណ៍នោះ (ការស៊ើបការណ៍ក្នុងប្រទេស/ការស៊ើបការណ៍ប្រឆាំងតបវិញ ឬការស៊ើបការណ៍ដោយបរទេស) ឬវាអាស្រ័យលើបញ្ហាដែលត្រូវស៊ើបយកព័ត៌មាននោះ (វិធីសាស្ត្រប្រតិបត្តិ សកម្មភាពលួចលាក់)។

### ការពិភាក្សាដេញដោលរបស់សភាជាសាធារណៈ និងជាសម្ងាត់

ជាទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ ការត្រួតពិនិត្យលើការឈ្លបយកការណ៍ នៅមានលក្ខណៈមិនសូវបើកចំហនិងរីកចម្រើន បើប្រៀបធៀបទៅផ្នែកផ្សេងទៀតរបស់រដ្ឋ។ ឧទាហរណ៍ការពិភាក្សាដេញដោលដោយគណៈកម្មការសភា ផ្នែកត្រួតពិនិត្យការស៊ើបការណ៍មិនបានធ្វើពេញលេញ និងបើកចំហ ហើយសមាជិកសភាដែលបានចូលរួមអាចត្រូវធ្វើសម្បថជាពិសេសថាខ្លួនគោរពគោលការណ៍នៃព័ត៌មានសម្ងាត់ទាំងឡាយដែលខ្លួនបានដឹង។ ដោយមិនគិតពីទម្រង់ផ្សេងៗ នៃការត្រួតពិនិត្យដែលបានកំណត់សង្គមប្រជាធិបតេយ្យ ខិតខំរក្សាតុល្យភាពរវាងការធានា

នូវភាពស្របច្បាប់ និងគណនេយ្យភាពរបស់អង្គការនោះ តាមរយៈការត្រួតពិនិត្យជាទៀងទាត់ ម្យ៉ាងទៀត ដើម្បីរក្សាភាពសម្ងាត់របស់ខ្លួន និងដើម្បីការពារសន្តិសុខជាតិប្រកបដោយប្រសិទ្ធភាព។

## ការបែងចែកភារកិច្ច

ការរៀបចំមធ្យោបាយ រចនាសម្ព័ន្ធសម្រាប់ត្រួតពិនិត្យលើអង្គភាពស៊ើបការណ៍សម្ងាត់ គឺដើម្បីបញ្ចៀសនូវមុខនាទីផ្តាច់មុខរបស់អង្គការមួយ ឬទីភ្នាក់ងារមួយ។ ប្រហែលដោយសារមានស្ថាប័នដាច់ដោយឡែកពីគ្នាច្រើនបែបនេះហើយ ដូចជាមានកងកម្លាំងប្រដាប់អាវុធ និងកងនគរបាល ឬកងស៊ើបការសម្ងាត់ក្នុងប្រទេស និងកងស៊ើបការណ៍សម្ងាត់ក្រៅប្រទេស ដូចនេះហើយទើបបានជាមានការរីកសាយនូវអង្គការស៊ើបការណ៍សម្ងាត់ខុសៗគ្នាផងដែរ។ ការរីកសាយបែបនេះ អាចមិនសូវមានប្រសិទ្ធភាព និងអាចជម្រុញឲ្យមានការប្រកួតប្រជែងគ្នាតាមបែបការិយាល័យធិបតេយ្យ តែជាទូទៅ គេចាត់ទុកថាវាបានបង្កឲ្យមានការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ។ ដូច្នេះ រដ្ឋភាគច្រើនមានសេវាដាច់ដោយឡែកពីគ្នាសម្រាប់ស៊ើបការណ៍ខាងក្នុង និងសម្រាប់ស៊ើបការខាងយោធា។ ការបែងចែកដាច់បែបនេះ វាល្អសម្រាប់ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ ក៏ប៉ុន្តែ វាធ្វើឲ្យការប្រមូលព័ត៌មានសម្ងាត់ និងការវិភាគមានលក្ខណៈរាយប៉ាយមិនប្រមូលផ្តុំ ដែលអាចបង្កជាបញ្ហាពិសេសក្រោយការវាយប្រហារភេរវកម្ម ទៅលើសហរដ្ឋអាមេរិក។

## ការបណ្តុះបណ្តាលបុគ្គលិកស៊ើបការណ៍សម្ងាត់

ការបណ្តុះបណ្តាល និងការកសាងអ្នកជំនាញខាងស៊ើបការណ៍ គឺជាគន្លឹះមួយនៃការត្រួតពិនិត្យ។ ជាពិសេសការបណ្តុះ វិជ្ជាជីវៈ ការបង្កើតឲ្យមានការប្តេជ្ញាចិត្តខ្ពស់ចំពោះបទដ្ឋានប្រជាធិបតេយ្យនិងគោលការណ៍សិទ្ធិមនុស្ស ក៏ដូចជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋគឺ មានសារៈសំខាន់ណាស់សម្រាប់ការបណ្តុះបណ្តាលបុគ្គលិកស៊ើបការណ៍សម្ងាត់។ ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យចង់ធ្វើការបណ្តុះបណ្តាលប្រជាពលរដ្ឋស៊ីវិលខាងផ្នែកចារកម្ម និងផ្តល់មុខងារឲ្យគេធ្វើខាងផ្នែកចារកម្ម ដោយមិនទុកឲ្យផ្នែកនេះស្ថិតនៅក្រោមយោធាឡើយ។

## ឯកសារមិនសម្ងាត់

កត្តាមួយទៀត ដែលអាចជួយសម្រួលដល់ការត្រួតពិនិត្យ និងគណនេយ្យភាព គឺថាព័ត៌មានអំពីសកម្មភាពចារកម្មអាចឲ្យសាធារណជនបានដឹងឮ និងទទួលបានក្រោយពីរយៈពេលដ៏សមស្របមួយ។ គេអាចជម្រុញការងារនេះបានតាមរយៈច្បាប់ស្តីពី សេរីភាពក្នុងការទទួលព័ត៌មាន និងតាមរយៈការបង្កើតច្បាប់ស្តីពីការបញ្ចេញឯកសារសម្ងាត់ ក្រោយពីរយៈពេលដ៏សមស្រប

ណាមួយ។ ការបង្កើតឲ្យមានតម្លាភាព និងការត្រួតពិនិត្យជាក់ស្តែងដោយសាធារណជនអាចសម្រួលការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ (មើលជំពូក ២១)។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### យន្តការត្រួតពិនិត្យរបស់សភា

- ត្រូវធានាថា សភាមានគណៈកម្មការមួយ ឬអនុគណៈកម្មការមួយ ដែលមានអាណត្តិជាក់លាក់ក្នុងការត្រួតពិនិត្យលើសេវាចារកម្មទាំងអស់ (សូមអានការប្រៀបធៀបនៅជំពូក ១៥ ស្តីពីគណៈកម្មការសភា។
- ត្រូវធានាថា អាណត្តិរបស់ស្ថាប័ននោះត្រូវបានកំណត់យ៉ាងច្បាស់ និងមានភាពតឹងរឹងតិចបំផុតតាមដែលធ្វើទៅបាន ហើយសមាជិករបស់ស្ថាប័ននោះមានសិទ្ធិទទួលបានរាល់ព័ត៌មានដ៏ចាំបាច់ទាំងអស់ និងជំនាញគ្រប់គ្រាន់។
- ត្រូវធានាថា គណៈកម្មការសភាចាត់វិធានការ និងរាយការណ៍ជាទៀងទាត់អំពីលទ្ធផលសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ខ្លួន។

### ក្របខណ្ឌប្រជាធិបតេយ្យ និងច្បាប់

- ត្រូវធានាថា ច្បាប់ស្តីពីចារកម្មគ្របដណ្តប់លើបញ្ហាដូចខាងក្រោម៖ ច្បាប់នេះត្រូវកំណត់ឲ្យបានច្បាស់នូវលក្ខណៈព្រំដែនប្រតិបត្តិការ សហប្រតិបត្តិការភារកិច្ច ភារកិច្ចរាយការណ៍ និងការត្រួតពិនិត្យសេវាចារកម្ម។ ក្រៅពីនេះ ច្បាប់ត្រូវកំណត់ពីវិធីសាស្ត្រដ៏ជាក់លាក់ដែលប្រើប្រាស់ដើម្បីទទួលព័ត៌មាន និងវិធីរក្សាកំណត់ត្រា ដែលមានព័ត៌មានលំអិតរបស់បុគ្គលរួមទាំងស្ថានភាពរបស់បុគ្គលិកចារកម្មផងដែរ។
- ឃ្លាំមើលថាតើសេវាចារកម្ម មានអព្យាក្រិតផ្នែកនយោបាយ និងប្រតិបត្តិទៅតាមក្រមសីលធម៌វិជ្ជាជីវៈ គោរពតាមការប្តេជ្ញាចិត្ត ចំពោះបទដ្ឋានប្រជាធិបតេយ្យ និងមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋដែរ ឬយ៉ាងណា។
- ត្រូវធានាថា គណៈកម្មការសភាត្រួតពិនិត្យកិច្ចការចារកម្ម ចាត់វិធានការដើម្បីធានាថាបុគ្គលិកចារកម្មទទួលនូវការបណ្តុះបណ្តាលពីគោលការណ៍ប្រជាធិបតេយ្យ និងច្បាប់ស្តីពីសិទ្ធិមនុស្ស។
- សភា ត្រូវបង្កើតច្បាប់ដែលបើកផ្លូវឲ្យស្ថាប័នរដ្ឋទាំង៣ មានតួនាទីបំពេញគ្នាទៅវិញទៅមកដូចជា៖

- អង្គការនីតិប្រតិបត្តិមានការទទួលខុសត្រូវចុងក្រោយក្នុងការអនុវត្តភារកិច្ច និងកំណត់អាទិភាពលើសេវាចារកម្ម។
- សភាបង្កើតច្បាប់ពាក់ព័ន្ធតាមដានថវិកា និងត្រួតពិនិត្យមើលការអនុវត្តតួនាទី និងមុខងារសេវាចារកម្មរបស់រដ្ឋាភិបាល។ សភាមិនគួរលូកដៃចូលទៅក្នុងប្រតិបត្តិការចារកម្មរបស់រដ្ឋាភិបាលនោះទេ។
- តុលាការចេញដីកាកោះហៅ ប្រសិនបើសេវាចារកម្មចង់បំពានលើទ្រព្យសម្បត្តិឯកជន និង/ឬ ការធ្វើទំនាក់ទំនងជាឯកជន។ តុលាការធ្វើការឃ្លាំមើលថាតើសេវាចារកម្មពិតជាបានប្រតិបត្តិក្នុងរង្វង់ច្បាប់កំណត់ ឬយ៉ាងណា។

## តម្លាភាព និងគណនេយ្យភាព

- ▷ ត្រូវធានាថា មានការពិគ្រោះយោបល់ ឬមានការជូនព័ត៌មានដល់គណៈកម្មការត្រួតពិនិត្យចារកម្មរបស់សភា អំពីគោលនយោបាយចារកម្មទូទៅ ដែលរៀបចំដោយអង្គការនីតិប្រតិបត្តិ។
- ▷ ត្រូវធានាថា គណៈកម្មការត្រួតពិនិត្យកិច្ចការចារកម្មរបស់សភា អាចធានាថាសេវាចារកម្មប្រតិបត្តិទៅតាមច្បាប់ និងមានគណនេយ្យភាព នៅពេលដែលខ្លួនរក្សានូវព័ត៌មានសម្ងាត់ និងប្រសិទ្ធភាព គឺត្រូវគោរពតាមបញ្ញត្តិ នៃច្បាប់ទាក់ទងនឹងការដាក់ខ្សែអាត់ថតយកសម្លេង។
- ▷ ត្រូវធានាថា គណៈកម្មការទទួលបានព័ត៌មានពេញលេញអំពី សកម្មភាពរបស់ទីភ្នាក់ងារចារកម្ម ហើយគណៈកម្មការមានតួនាទីតែងតាំងប្រធាននៃសេវាចារកម្មទាំងនោះ។

## បញ្ហាទាក់ទងនឹងព័ត៌មានសម្ងាត់

- ▷ ត្រូវធានាថា ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានគឺជា មធ្យោបាយដ៏សំខាន់មួយក្នុងការធានាគណនេយ្យភាព និងការត្រួតពិនិត្យទាំងដោយផ្ទាល់ និងដោយប្រយោលទៅលើសេវាចារកម្ម។
- ▷ ត្រូវបង្កើតឲ្យមានការធ្វើសវនកម្មពិសេស ក្នុងករណីមានការពាក់ព័ន្ធជាមួយ មូលនិធិសម្ងាត់ដើម្បីរក្សាតុល្យភាពរវាងព័ត៌មានសម្ងាត់ និងគណនេយ្យភាព។
- ▷ ត្រូវធានាថា លក្ខខណ្ឌវិនិច្ឆ័យ និងការពន្យាការបញ្ចេញឯកសារសម្ងាត់មានចែងនៅក្នុងច្បាប់ដើម្បីធានាដល់គោលការណ៍តម្លាភាព។ ត្រូវធ្វើការផ្សព្វផ្សាយ ជាទៀងទាត់ចំណងជើង របាយការណ៍ ដែលធានាដោយច្បាប់ ស្តីពីសិទ្ធិទទួលព័ត៌មាន ។

មើលជំពូក ២០ ស្តីពីភេរវកម្ម និងផ្នែកទី៦ ស្តីពីធនធានហិរញ្ញវត្ថុ!

# ជំពូកទី ១២

# ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន

រដ្ឋមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់កម្លាំងដោយស្របច្បាប់ និងជាអ្នកផ្តល់សេវាសន្តិសុខតែមួយគត់ដែលទទួលខុសត្រូវចំពោះការផ្តល់សន្តិសុខផ្ទៃក្នុង និងការការពារពីការគម្រាមកំហែងពីខាងក្រៅ។ ទោះដូច្នេះក៏ដោយនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះចរន្តនៃជម្លោះផ្ទៃក្នុងបានបង្កើតឲ្យមានបាតុភូតថ្មីមួយដែលគេស្គាល់ថាជាការធ្វើឯកជននូបនីយកម្មវិស័យសន្តិសុខ។ តួអង្គសន្តិសុខមិនមែនរដ្ឋខ្លះបានលេចរូបរាងឡើងហើយ វាបានបង្កការប្រឈមសម្រាប់ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យក្នុងទម្រង់ដែលធ្លាប់ធ្វើពីមុនៗមក។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មកមានការរីកសាយនូវក្រុមហ៊ុនសន្តិសុខឯកជននិងយោធាយ៉ាងច្រើន។ ជាទូទៅ គេអាចបែងចែកក្រុមហ៊ុនទាំងនេះជា៣ក្រុមធំៗ៖ ភតិការី (ក្រុមទាហ៊ានស៊ីឈ្នួលច្បាំង) ក្រុមហ៊ុនយោធាឯកជន និងក្រុមហ៊ុនសន្តិសុខឯកជន។ វាសំខាន់ខ្លាំងណាស់ថាសកម្មភាពរបស់តួអង្គទាំងនេះត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់យន្តការរដ្ឋ។

## មុខងារ និងគ្រោះថ្នាក់នៃក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន

ភាគច្រើនបំផុតមានតែរដ្ឋក្រោយជម្លោះឬបរាជ័យនោះទេ ដែលមានបំណងប្រើប្រាស់ក្រុមហ៊ុន សន្តិសុខនិងយោធាឯកជន។ រដ្ឋទាំងនេះ ធ្វើបែបនេះ ដើម្បីបំពេញនូវកង្វះខាតកម្លាំងយោធា និងកម្លាំងយោធាដែលមិនមានការហ្វឹកហ្វឺនគ្រប់គ្រាន់ដូច្នេះរដ្ឋទាំងនេះមិនមានសមត្ថភាពក្នុងការផ្តល់សន្តិសុខដល់ប្រជាពលរដ្ឋរបស់ខ្លួន និង/ឬក្រុមផ្សេងៗឬមួយពួកគេមិនចង់កាន់កាប់ផ្តាច់មុខលើការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យពិតៗ ទៅលើវិស័យសន្តិសុខរបស់ខ្លួនផ្ទាល់ ឬមួយពួកគេជួបប្រទះនូវជម្លោះខាងក្នុងរដ្ឋ។

នៅក្នុងកាលៈទេសៈបែបនោះការប្រើប្រាស់ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនហាក់ដូចជាមានផលវិជ្ជមានក្នុងរយៈពេលខ្លី ជាពិសេសទាក់ទងនឹងការពង្រឹងជំនាញវិជ្ជាជីវៈ និងសមត្ថភាពហ្វឹកហ្វឺនថ្នាក់ជាតិរួមទាំងអាចបង្កើននូវទំនុកចិត្តមកលើខ្លួនឯងផងដែរ។ ទោះដូច្នេះក្តីផលប៉ះពាល់អវិជ្ជមានមកលើដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មអាចមានកម្រិតខ្ពស់ និងស្មុគ្រស្មាញដូចមានបង្ហាញនៅក្នុងប្រអប់ទី២៦។

ស្ថាប័នសាធារណៈ និងស្ថាប័នដែលបានជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ និងជាពិសេសគឺសភានៃរដ្ឋ "ជាអ្នកជួលក្រុមហ៊ុនឯកជន" ត្រូវការនូវយន្តការគ្រប់គ្រាន់ និងមានប្រសិទ្ធភាពខ្ពស់

សម្រាប់ត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ មិនត្រឹមតែទៅលើរចនាសម្ព័ន្ធរបស់រដ្ឋខ្លួនឯងនោះទេ តែថែមទាំងត្រួតពិនិត្យលើជំនាញរបស់ក្រុមហ៊ុនយោធា/សន្តិសុខឯកជន ដែលខ្លួនបានជួលឲ្យមកបំពេញភារកិច្ចផងដែរ។

**ប្រអប់ទី ២៦**

**ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន និងគ្រោះថ្នាក់ធំៗចំពោះលទ្ធិប្រជាធិបតេយ្យ**

- តួអង្គសន្តិសុខឯកជនអាចធ្វើឲ្យផ្នែកយោធា/សន្តិសុខមានស្ថិរភាពខ្លះដែរ ក៏ប៉ុន្តែនៅក្នុងរយៈពេលវែងរដ្ឋាភិបាលខ្លះអាចមើលឃើញថាការពឹងលើកម្លាំងយោធា គឺជាវិធីសាស្ត្រដ៏សំខាន់មួយក្នុងការជួយដោះស្រាយបញ្ហា (ផ្ទៃក្នុង)។
- ការជួលជំនាញការបរទេសបង្កើតឲ្យមានបញ្ហាជាច្រើន ដូចជា ការប៉ះពាល់ទៅដល់បេសកកម្មយោធា/សន្តិសុខ និងថវិការបស់ប្រទេសនោះ។ តាមទស្សនៈប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ បញ្ហាទាំងនេះ ជានិច្ចជាកាលត្រូវតែដោះស្រាយនៅក្នុងកិច្ចពិភាក្សាដេញដោលជាសាធារណៈ និងដោយសភា។
- នៅក្នុងករណីភាគច្រើន តួអង្គឯកជនទាំងនេះ ដើរតួជាទីភ្នាក់ងារឈ្មួញកណ្តាលលក់អាវុធនៅក្រោមរូបភាពបន្លំនៅក្នុងបេសកកម្ម (ស្របច្បាប់) របស់តួអង្គដទៃ។

## ទាហ៊ានស៊ីឈ្នួលច្បាំង

ទាហ៊ានស៊ីឈ្នួលច្បាំងគឺជាបាតុភូតរាងចំណាស់បន្តិចទៅហើយ។ ជម្លោះថ្មីៗនេះបង្ហាញថា ទាហ៊ានស៊ីឈ្នួលច្បាំងនេះ នៅតែបន្តមានវត្តមាននៅក្នុងប្រទេសជាច្រើន នៅក្នុងពិភពលោកនេះ។ និយមន័យនៃទាហ៊ានស៊ីឈ្នួលច្បាំង មាននៅក្នុងមាត្រា១នៃ *អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការជ្រើសរើសការប្រើប្រាស់ ការផ្តល់ហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលទាហ៊ានស៊ីឈ្នួលច្បាំងឆ្នាំ១៩៨៩* ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសម្រេចលេខ៤៤/៣៤ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨៩។ អនុសញ្ញា បានចូលជាធរមាននៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០១ ក៏ប៉ុន្តែមកដល់ពេលនេះមានតែប្រទេសបីបួនប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ។ អនុសញ្ញានេះបានពង្រីកនិយមន័យដែលមានចែងនៅក្នុងមាត្រា៤៧ នៃ*ពិធីសារបន្ថែម១* ទៅលើ *អនុសញ្ញាក្រុងហ្សឺណែវ* ឆ្នាំ១៩៤៩ (ជាពិសេសទាក់ទងនឹងជនដែលត្រូវបានគេជួលឲ្យចូលរួមធ្វើសកម្មភាពហិង្សាដោយមានគោលបំណងផ្តួលរំលំរដ្ឋាភិបាលមួយ ឬប្រឆាំងនឹងដីកាធម្មនុញ្ញរបស់រដ្ឋមួយ ឬបំពារបំពានលើបូរណៈភាពដែនដីរបស់រដ្ឋនោះ។

"មាត្រា ១- *សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖*

*១.ទាហ៊ានស៊ីឈ្នួលច្បាំងគឺជាជនទាំងឡាយណាដែល (ក) ត្រូវបានគេជួលជាពិសេសនៅក្នុង*

*ប្រទេស ឬ ក្រៅប្រទេសដើម្បីប្រយុទ្ធនៅក្នុងជម្លោះប្រដាប់អាវុធ។ (ខ) ជនទាំងឡាយណាដែលត្រូវបានលើកទឹកចិត្តឲ្យចូលរួម នៅក្នុងសកម្មភាពប្រទុស្តរាយ ជាពិសេសដោយមានបំណងចង់បានផលប្រយោជន៍ជាឯកជន និងត្រូវបានសន្យាដោយឬក្នុងនាមនៃភាគីមួយនៃជម្លោះថាពួកគេនឹងធ្វើការប៉ះប៉ូវជាសម្ភារៈយ៉ាងច្រើនលើសលុប ឬ ផ្តល់ជាបុណ្យសក្តិមុខនាទីយោធាដូចគ្នានឹងមន្ត្រីយោធារបស់ខ្លួននៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់ភាគីក្នុងជម្លោះនោះ។ (គ) ជននោះមិនមានសញ្ជាតិនៅក្នុងប្រទេស ដែលជាភាគីនៃជម្លោះ និងក៏មិនមែនជានិវេសនជននៅលើទឹកដី ដែលគ្រប់គ្រងដោយភាគីនៃជម្លោះ។ (ឃ) ជននោះមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃភាគីនៃជម្លោះ និង (ង) មិនត្រូវបានបញ្ជូនដោយរដ្ឋដែលមិនមែនជាភាគីនៃជម្លោះឲ្យបំពេញភារកិច្ចជាផ្លូវការក្នុងនាមជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយនោះឡើយ។*

*២.ទាហ៊ានស៊ីឈ្នួលច្បាំងក៏ជាជនទាំងឡាយណាដែលក្នុងគ្រប់ស្ថានភាពទាំងអស់៖ (ក) ត្រូវបានជ្រើសរើសជាពិសេសនៅក្នុងប្រទេស ឬ ក្រៅប្រទេស សម្រាប់គោលបំណងចូលរួមនៅក្នុងសកម្មភាពហិង្សាដោយមានគោលបំណង៖(១) ផ្តួលរំលំរដ្ឋាភិបាលឬប្រឆាំងដឹកាធម្មនុញ្ញរបស់រដ្ឋមួយឬ(២) បំពារបំពានលើបូរណៈភាពដែនដីរបស់រដ្ឋមួយ។ (ខ) ជនទាំងឡាយណាដែលត្រូវបានលើកទឹកចិត្តឲ្យចូលរួមនៅក្នុងសកម្មភាពប្រទុស្តរាយ ជាពិសេសដោយមានបំណងចង់បានផលប្រយោជន៍ជាឯកជនឬត្រូវបានគេសន្យាថានឹងផ្តល់សម្ភារៈថ្នូរ (គ)ជននោះមិនមានសញ្ជាតិ នៅក្នុងប្រទេស ដែលជាភាគីនៃជម្លោះ និងក៏មិនមែនជា និវេសនជននៅលើទឹកដី ដែលគ្រប់គ្រងដោយភាគីនៃជម្លោះ។ (ឃ) មិនត្រូវបានបញ្ជូនដោយរដ្ឋមួយទៅបំពេញភារកិច្ចជាផ្លូវការនិង (ង) ជននោះមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ នៃរដ្ឋដែលនៅក្នុងដែនដីនៃរដ្ឋនោះ មានការជួលយោធាស៊ីឈ្នួលច្បាំងឲ្យធ្វើសកម្មភាព”។*

សម្រាប់គោលបំណងនៃអនុសញ្ញានេះ វាជាបទល្មើសធ្ងន់ធ្ងរប្រសិនបើបទល្មើសនេះ ត្រូវបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលបានជ្រើសរើសប្រើប្រាស់ផ្តល់ហិរញ្ញវត្ថុ ឬ ធ្វើការហ្វឹកហ្វឺនទាហ៊ានស៊ីឈ្នួលច្បាំង ឬប៉ុនប៉ងប្រព្រឹត្តអំពើបែបនោះ ឬផ្សំគំនិតនៅក្នុងអំពើបែបនោះ ឬការប៉ុនប៉ងបែបនោះ។ ទោះដូច្នេះក៏ដោយមានករណីជាច្រើនបានកើតឡើងនៅពេលដែលរដ្ឋាភិបាលជួលជំនាញការយោធាបរទេសឲ្យបំពេញភារកិច្ចពិសេស(ដូចជាធ្វើជាអ្នកបើកយន្តហោះ ឬ ចូលរួមក្នុងប្រតិបត្តិការប្រឆាំងភេរវកម្ម ។ល។)។

អ្នករាយការណ៍ពិសេសអំពីទាហ៊ានស៊ីឈ្នួលរបស់គណៈកម្មការ សិទ្ធិមនុស្សអង្គការសហប្រជាជាតិបានលើកជាអនុសាសន៍នៅក្នុងរបាយការណ៍របស់គាត់ថា “មហាសន្និបាតត្រូវអញ្ជើញរដ្ឋទាំងអស់ដែលមិនទាន់ក្លាយជាភាគីអនុសញ្ញាឲ្យផ្តល់សច្ចាប័នឬចូលជាសមាជិកនៃអនុសញ្ញា។ ទន្ទឹមនឹងនោះ អង្គការសហប្រជាជាតិក៏ត្រូវអញ្ជើញរដ្ឋជាសមាជិកនៃអនុសញ្ញានេះ ឲ្យធ្វើការពិនិត្យឡើងវិញនូវច្បាប់ជាតិរបស់ខ្លួន ដើម្បីឲ្យច្បាប់ជាតិទាំងនេះស្របជាមួយអនុសញ្ញា” (កថាខណ្ឌទី៧០)។

## ក្រុមហ៊ុនយោធាឯកជន

ក្រុមហ៊ុនយោធាឯកជនជាប្រភេទនៃ"ទាហ៊ានស៊ីឈ្នួលច្បាំង"ដ៏ទំនើប។ ដូច្នេះពួកគេបំពេញការងារដើម្បីផលចំណេញ តាមរយៈការផ្ដល់សេវាយោធា និងហ្វឹកហ្វឺន ឬចូលរួមប្រយុទ្ធផ្ទាល់ ឬមិនផ្ទាល់។ តាមទស្សនៈច្បាប់ ពួកគេមិនចូលទៅក្នុងនិយមន័យដ៏ចង្អៀតនៃកងកម្លាំងទាហ៊ានស៊ីឈ្នួលច្បាំងនោះទេ ដោយសារក្រុមនេះអាចមានក្រុមទាហ៊ានចូលនិវត្តន៍អ្នកដែលលែងសកម្មនៅក្នុងកងកម្លាំងសន្តិសុខ។ ក្រុមហ៊ុនយោធាឯកជនផ្ដល់នូវសេវាជាច្រើនចាប់ពីសេវាប្រយុទ្ធ និងប្រតិបត្តិការគាំទ្រ ឬសេវាផ្ដល់ប្រឹក្សាយោបល់ និងសេវាហ្វឹកហ្វឺន រហូតដល់សេវាទិញដូរអាវុធ ចារកម្មឬរំដោះចំណាប់ខ្មាំងជាដើម។ ដោយមិនគិតពីប្រភេទសេវាដែលពួកគេផ្ដល់ឲ្យលក្ខណៈជារួមរបស់ពួកគេគឺធ្វើប្រតិបត្តិការតាមសំណើរបស់រដ្ឋាភិបាលជាពិសេសក្នុងស្ថានភាពមានជម្លោះ ឬដំណាក់កាលនៃការកសាងប្រទេសឡើងវិញក្រោយជម្លោះ។

ឧទាហរណ៍នៃក្រុមហ៊ុនយោធាឯកជនមួយ គឺក្រុមហ៊ុន MPRI ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនអាជីពដែលចូលរួមនៅក្នុងបញ្ហាការពារជាតិតាមរយៈកិច្ចសន្យាដោយផ្ដល់នូវការគាំទ្រនិងជំនួយនៅក្នុងបញ្ហាទាក់ទងនឹងការការពារជាតិ ដូចជាជំនាញខាងអនុវត្តច្បាប់ និងការអភិវឌ្ឍភាពជាអ្នកដឹកនាំជាដើម។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងដោយអតីតមន្ត្រីយោធាជាន់ខ្ពស់នៅក្នុងឆ្នាំ១៩៨៨ ហើយក្រុមហ៊ុននេះនៅតែបន្តប្រតិបត្តិការដោយអតីតបុគ្គលិកយោធានៅឡើយ។

## ក្រុមហ៊ុនសន្តិសុខឯកជន

ក្រុមហ៊ុនសន្តិសុខឯកជនផ្ដល់សេវានានាទាក់ទងនឹងការការពារអាជីវកម្ម និង ទ្រព្យសម្បត្តិ ដូច្នេះសកម្មភាពរបស់ពួកគេគឺរួមចំណែកដល់ការទប់ស្កាត់បទល្មើស។ ដូច្នេះក្រុមហ៊ុនសន្តិសុខឯកជនកើតមាននៅគ្រប់ទីកន្លែង ក៏ប៉ុន្តែនិន្នាការថ្មីៗនេះ បង្ហាញថាការប្រើប្រាស់សេវាសន្តិសុខឯកជននេះបានកើនឡើងជាពិសេសនៅក្នុងតំបន់ដែលមានជម្លោះ ដែលម្ចាស់អាជីវកម្មចង់បាននូវកិច្ចការពារឲ្យបានច្រើនជាងរដ្ឋដែលអាចផ្ដល់ឲ្យ។ គេជឿថាក្រុមហ៊ុនបែបនេះយកចិត្តទុកដាក់ខ្លាំងទៅលើការការពារទ្រព្យសម្បត្តិ និងបុគ្គលិកច្រើនជាងយោធា។ ទោះដូច្នេះក៏ដោយជាការអនុវត្តជាក់ស្ដែង ជាញឹកញាប់ក្រុមហ៊ុនទាំងនេះមានទាំងជំនាញយោធានិងជំនាញសន្តិសុខដោយសារជំនាញទាំង២នេះជាតម្រូវការដ៏ចាំបាច់នៅក្នុងតំបន់ដែលមានជម្លោះ។ ដូច្នេះវាពិបាកនឹងញែកឲ្យដាច់ថា ក្រុមហ៊ុនណាជាក្រុមហ៊ុនយោធា និងក្រុមហ៊ុនណាជាក្រុមហ៊ុនសន្តិសុខ។ ដោយសារមានការរីកសាយនូវតួអង្គសន្តិសុខ និងសារៈសំខាន់របស់វា វាក៏កាន់តែមានសារៈសំខាន់ខ្លាំងឡើងៗសម្រាប់ស្ថាប័នប្រជាធិបតេយ្យ ជាពិសេសសភាត្រូវធានាឲ្យមានបទដ្ឋានអប្បបរមានៃការត្រួតពិនិត្យលើតួអង្គថ្មីៗទាំងនេះ នៅក្នុងវិស័យសន្តិសុខ បើមិនដូច្នោះទេគោលការណ៍ប្រជាធិបតេយ្យនឹងទទួលរងនូវការគម្រាមកំហែងជាក់ជាមិនខាន។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ផ្នែកច្បាប់

- ▷ ត្រូវស្រាវជ្រាវឲ្យឃើញថា តើរដ្ឋរបស់អ្នកជាភាគីនៃអនុសញ្ញាអន្តរជាតិប្រឆាំងការជ្រើសរើសការប្រើប្រាស់ ការផ្តល់ហិញ្ញវត្ថុ និងការហ្វឹកហ្វឺនទាហានស៊ីឈ្នួលច្បាំង និងបានអនុម័តនូវច្បាប់ពាក់ព័ន្ធដ៏ល្អៗដែរឬយ៉ាងណា។
- ▷ ត្រូវបញ្ជាក់ថា តើមានក្របខណ្ឌច្បាប់ជាធរមានសម្រាប់គ្រប់ដណ្តប់លើក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនដែរឬយ៉ាងណា។

### គោរពបទដ្ឋាន និងការដាក់ទណ្ឌកម្មអាវុធ

- ▷ នៅពេលដែលក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនធ្វើប្រតិបត្តិការនៅឯបរទេសនៅក្នុងតំបន់ជម្លោះ សូមលលើកទឹកចិត្តសភារបស់អ្នកឲ្យធ្វើការត្រួតពិនិត្យសកម្មភាពរបស់ក្រុមហ៊ុនទាំងនោះ ដែលមានមូលដ្ឋាននៅក្នុងប្រទេសរបស់អ្នក ថាតើប្រតិបត្តិការរបស់ពួកគេ វាស្របជាមួយយុទ្ធសាស្ត្រសន្តិសុខជាតិ ឬគោលនយោបាយបរទេស និងច្បាប់បទដ្ឋាន និងសេចក្តីសម្រេចអន្តរជាតិពាក់ព័ន្ធដែរឬយ៉ាងណា។
- ▷ តាមច្បាប់ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនមិនត្រូវអនុញ្ញាតឲ្យធ្វើប្រតិបត្តិការនៅក្នុងតំបន់ ឬនៅក្នុងប្រទេសដែលជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មអាវុធឡើយ។

### តម្លាភាព

- ▷ ត្រូវដឹងថា គ្មានក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនណា ត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការ នៅលើទឹកដីរបស់ជាតិដោយគ្មានការអនុញ្ញាតជាមុនពីសភាឡើយ សូម្បីកន្លែងដែលពួកគេប្រតិបត្តិនោះ ត្រូវបានស្នើសុំ ឬដោយមានការព្រមព្រៀងពីរដ្ឋាភិបាលក៏ដោយ។
- ▷ ត្រូវធានាថាថវិការបស់រដ្ឋាភិបាលសម្រាប់ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជន និងសកម្មភាពរបស់ពួកគេត្រូវស្ថិតនៅក្រោម ការត្រួតពិនិត្យរបស់សភា។

### គណនេយ្យភាព

- ▷ ត្រូវធានាថា សភាធ្វើឲ្យរដ្ឋាភិបាលមានគណនេយ្យភាព ចំពោះរាល់ទង្វើទាំងអស់របស់ក្រុមហ៊ុនសន្តិសុខ និងយោធាឯកជនចំពោះមុខច្បាប់និងការអនុវត្តជាក់ស្តែង នៅក្នុងប្រទេស និងនៅក្រៅប្រទេស។

# ផ្នែកទី IV

# សន្តិសុខជាតិនៅក្រោម ការត្រួតពិនិត្យដោយសភា៖ លក្ខខណ្ឌ និងយន្តការ

ជំពូកទី ១៣

# លក្ខខណ្ឌនៃការត្រួតពិនិត្យដោយសភាប្រកបដោយប្រសិទ្ធភាព

ការត្រួតពិនិត្យដោយសភាទៅលើវិស័យសន្តិសុខ វាអាស្រ័យលើអំណាចដែលសភាមានចំពោះរដ្ឋាភិបាល និងសេវាសន្តិសុខ។ នៅក្នុងបរិបទនេះ អំណាចមានន័យថាជាសមត្ថភាពដើម្បីមានឥទ្ធិពលទៅលើជម្រើស និងអាកប្បកិរិយារបស់រដ្ឋាភិបាលស្របតាមឆន្ទៈរួមរបស់ប្រជាពលរដ្ឋដែលបានសំដែងតាមរយៈតំណាងរាស្ត្រ។ អំណាចនេះរួមមានសមត្ថភាពត្រួតត្រាការអនុវត្តគោលនយោបាយច្បាប់ សេចក្តីសម្រេច និងថវិកាដែលសភាបានអនុម័ត។ អំណាចនេះចេញមកពីរដ្ឋធម្មនុញ្ញ និងច្បាប់ ថែមទាំងចេញមកពីវិធាននីតិវិធីរបស់សភា និងការអនុវត្តជាទម្លាប់របស់សភាផងដែរ។

លក្ខខណ្ឌដើម្បីឲ្យការត្រួតពិនិត្យដោយសភាប្រកបដោយប្រសិទ្ធភាពទៅលើវិស័យសន្តិសុខមាន៖

- ✓ អំណាចតាមរដ្ឋធម្មនុញ្ញ និងច្បាប់ត្រូវកំណត់ឲ្យបានច្បាស់។
- ✓ ការអនុវត្តជាទម្លាប់របស់សភា
- ✓ ធនធាន និងជំនាញ។
- ✓ ឆន្ទៈនយោបាយ។

## អំណាចតាមរដ្ឋធម្មនុញ្ញ និងច្បាប់

រដ្ឋធម្មនុញ្ញ (ឬច្បាប់ដែលពាក់ព័ន្ធ) ចែងនូវមូលដ្ឋានច្បាប់សំខាន់ៗបំផុតសម្រាប់ការត្រួតពិនិត្យរបស់សភា ទៅលើវិស័យសន្តិសុខ។ខណៈពេលដែលរដ្ឋធម្មនុញ្ញ មានលក្ខណៈខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតទៅតាមស្ថានភាពនយោបាយ វប្បធម៌ សេដ្ឋកិច្ច និងសង្គមភាគច្រើននៃរដ្ឋធម្មនុញ្ញចែងថា៖

- ✓ អង្គការនីតិប្រតិបត្តិ (ឧ. ប្រធានាធិបតី នាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីការពារជាតិ) ទទួលខុសត្រូវចំពោះសេវាសន្តិសុខ។
- ✓ អង្គការនីតិប្រតិបត្តិ មានការទទួលខុសត្រូវចំពោះមុខសភា។

នៅពេលដែលបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញមានយុត្តាធិការខ្ពស់បំផុត វាចាំបាច់ត្រូវចែងនូវអំណាចរបស់សភាពាក់ព័ន្ធជាមួយវិស័យសន្តិសុខនៅក្នុងរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញមិនងាយ នឹងធ្វើវិសោធនកម្មនោះទេ។ រាល់ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាទូទៅវាត្រូវការនូវមតិភាគច្រើនលើសលប់នៅក្នុងសភា។ ដូច្នេះ រដ្ឋធម្មនុញ្ញជាមធ្យោបាយដ៏សក្តិសិទ្ធមួយ ក្នុងការការពារអំណាចរបស់សភានៅក្នុងផ្នែកដ៏រសើបនេះ។ អំណាចបែបនេះ ក៏ត្រូវរំលេចនៅក្នុងច្បាប់ដ៏ជាក់លាក់ផ្សេងទៀត រួមទាំងរំលេចនៅក្នុងវិធាននីតិវិធីរបស់សភា។ ក្រៅពីនេះត្រូវរៀបចំបទដ្ឋានសង្គម និងការអនុវត្តឲ្យមានគណនេយ្យភាព និងការត្រួតពិនិត្យដោយសភា។

ប្រអប់ទី២៧ បង្ហាញពីសូចនាករទាក់ទងនឹងអំណាចរបស់សភា ដែលអាចប្រើប្រាស់ដើម្បីពិនិត្យវិស័យសន្តិសុខ។ ភាគច្រើននៃអំណាចទាំងនេះ នឹងមានពិភាក្សានៅក្នុងជំពូកបន្តបន្ទាប់។

**ប្រអប់ទី ២៧**

### លិខិតូបករណ៍ ឬឧបករណ៍ដែលអាចប្រើប្រាស់ដោយសភា សម្រាប់ធ្វើការត្រួតពិនិត្យវិស័យសន្តិសុខតាមបែបប្រជាធិបតេយ្យ

**១. អំណាចទូទៅ**

ក. ផ្តួចផ្តើមធ្វើច្បាប់
ខ. ធ្វើវិសោធនកម្មច្បាប់ ឬសរសេរច្បាប់ឡើងវិញ
គ. ចោទសួរសមាជិកនៃអង្គការនីតិប្រតិបត្តិ
ឃ. កោះហៅសមាជិកនៃអង្គការនីតិប្រតិបត្តិមកបំភ្លឺនៅក្នុងសភា
ង. កោះហៅបុគ្គលិកយោធា និងមន្ត្រីរាជការស៊ីវិលមកបំភ្លឺនៅក្នុងសភា
ច. ស្នើសុំឯកសារពីអង្គការនីតិប្រតិបត្តិ
ឆ. ធ្វើការស៊ើបអង្កេតដោយសភា
ជ. បើកសវនការ។

**២. ការត្រួតពិនិត្យថវិកា**

ក. មានសិទ្ធិពិនិត្យមើលឯកសារថវិកា។
ខ. មានសិទ្ធិពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មមូលនិធិការពារជាតិ និងសន្តិសុខ។
គ. ត្រួតពិនិត្យថវិកាតាមកម្មវិធី គម្រោង និងខ្ទង់ចំណាយ។
ឃ. មានសិទ្ធិអនុម័តយល់ព្រម/បដិសេធនូវសំណើសុំបន្ថែមថវិកាការពារជាតិនិងសន្តិសុខណាមួយ។

៣. បេសកកម្មរក្សាសន្តិភាព/ពង្រាយទ័ពនៅបរទេស៖ សិទ្ធិរបស់សភាក្នុងការអនុម័តយល់ព្រម/បដិសេធ

ក. ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត មុនទ័ពត្រូវបាន បញ្ជូនទៅបរទេស។
ខ. កំណត់អាណត្តិនៃបេសកកម្ម ធានាចំពោះតួនាទីអង្គការសហប្រជាជាតិ។
គ. សម្រេចលើថវិកាបេសកកម្ម។
ឃ. ហានិភ័យនៃបុគ្គលិកយោធា ដែលចូលរួមក្នុងបេសកកម្មរក្សាសន្តិភាព។
ង. វិធាននៃការចូលរួម។
ច. ខ្សែសង្វាក់បញ្ជា/គ្រប់គ្រង។
ឆ. រយៈពេលនៃបេសកកម្ម។
ជ. សិទ្ធិចុះសួរសុខទុក្ខកងទ័ពបំពេញបេសកកម្ម។

៤. លទ្ធកម្ម

ក. កាតព្វកិច្ចរបស់អង្គការនីតិប្រតិបត្តិ ត្រូវជូនដំណឹងពេញលេញដល់សភា អំពីសេចក្តីសម្រេចលើបញ្ហាលទ្ធកម្ម។
ខ. សិទ្ធិអនុម័តយល់ព្រម/បដិសេធកិច្ចសន្យា។
គ. ពិនិត្យឡើងវិញនូវដំណាក់កាលនីមួយៗនៃលទ្ធកម្ម៖
   I. ធ្វើការបញ្ជាក់តម្រូវសម្រាប់ឧបករណ៍ថ្មី។
   II. ធ្វើការប្រៀបធៀប និងជ្រើសរើសរោងចក្រ។
   III. វាយតម្លៃលើសំណើសុំទូទាត់ និងសំណង។

៥. គោលនយោបាយទូទៅស្តីពីការការពារជាតិ និងសន្តិសុខ៖ សិទ្ធិក្នុងការអនុម័តយល់ព្រម/បដិសេធ

ក. ទស្សនទានគោលនយោបាយសន្តិសុខ។
ខ. ទស្សនទាននៃការគ្រប់គ្រងភាពវិកវរ។
គ. រចនាសម្ព័ន្ធកងកម្លាំង។
ឃ. យុទ្ធសាស្ត្រយោធា/គោលការណ៍យោធា។

៦. បុគ្គលិកការពារជាតិ/សន្តិសុខ

ក. សិទ្ធិអនុម័តយល់ព្រម/បដិសេធផែនការបុគ្គលិក។
ខ. សិទ្ធិកំណត់អតិបរមានៃចំនួនបុគ្គលិកការពារជាតិ/សន្តិសុខ។
គ. សិទ្ធិអនុម័តយល់ព្រម/បដិសេធ ឬសិទ្ធិចូលរួមពិគ្រោះយោបល់អំពីការតែងតាំងមន្ត្រីយោធាជាន់ខ្ពស់ (ដូចជាអគ្គបញ្ជាការ)។

## ការអនុវត្តជាទម្លាប់

ច្បាប់មិនមែនគ្រប់គ្រងលើរាល់ការអនុវត្ត និងការប្រាស្រ័យទាក់ទងគ្នាទាំងអស់នោះទេ។ ដូច្នេះ វាចាំបាច់ត្រូវបង្កើត និងថែរក្សានូវទម្លាប់និងការអនុវត្តនានាដែលសភាធ្លាប់ធ្វើការត្រួតពិនិត្យកន្លងមក ដែលបានគាំទ្រដោយបទដ្ឋានសង្គម ដូចជាការគោរព និងជឿជាក់គ្នាទៅវិញទៅមក។ ឧទាហរណ៍ការជូនដំណឹង និងការចូលរួមជាមួយសភាយ៉ាងពេញលេញ និងទាន់ពេលវេលា នៅក្នុងការវិវត្តន៍ថ្មីៗទាក់ទងនឹងវិស័យសន្តិសុខគឺដើម្បីតម្លាភាព និងគណនេយ្យភាពចំពោះមុខច្បាប់ហើយក៏ជាការបង្កើតនូវកិច្ចសន្ទនារវាងប្រជាជនផងដែរ។

## ធនធាន និងជំនាញ

ជាទូទៅ សមត្ថភាពរបស់សភាក្នុងការត្រួតពិនិត្យ វិស័យសន្តិសុខតែងតែរងការប៉ះពាល់ដោយកត្តាពេលវេលានិងកម្រិតនៃជំនាញរួមទាំងព័ត៌មានដែលខ្លួនមាន។

### កត្តាពេលវេលា

វាជាការចាំបាច់ខ្លាំងណាស់សម្រាប់សភា ក្នុងការទទួលនូវព័ត៌មានទាន់ពេលវេលាអំពីចេតនា និងសេចក្តីសម្រេចរបស់រដ្ឋាភិបាលពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខ និងវិស័យសន្តិសុខ។ សភាមិនអាចត្រៀមខ្លួនបានល្អប្រសិនបើរដ្ឋាភិបាលជូនដំណឹងប្រចុចញ៉ុចក្រោយពីខ្លួនបានសម្រេចចុងក្រោយហើយនោះ។ នៅក្នុងករណីនេះ សភានឹងជួបប្រទះនូវស្ថានភាពមួយហៅថា "ត្រូវតែធ្វើដូច្នេះ "(fait accompli) ដោយគ្មានជម្រើសអ្វីក្រៅពីអនុម័តយល់ព្រម ឬបដិសេធនូវសេចក្តីសម្រេចរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។

ក្នុងពេលមានវិបត្តិជាតិ ឬគ្រោះអាសន្ន រដ្ឋាភិបាលជាធម្មតាមានសិទ្ធិចាត់វិធានការភ្លាម រួចបានជូនដំណឹងដល់សភាជាក្រោយ។ ទោះដូច្នេះក្តី រដ្ឋាភិបាលមិនអាចធ្វើសកម្មភាពប្រាស់ចាកពីវង្វង់ក្របខណ្ឌដែលសភាបានអនុម័តយល់ព្រមនោះឡើយ។

ដោយសារបញ្ហាគោលនយោបាយស្តីពីសន្តិសុខ ជាបញ្ហាសំខាន់ សភាត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីវិភាគនិងសួរដេញដោលលើបញ្ហាសំខាន់ៗ ដូចជាបញ្ហាទាក់ទងនឹងថវិកាការពារជាតិ សេចក្តីសម្រេចទិញអាវុធ ឬក៏ត្រូវពិនិត្យឡើងវិញនូវគោលនយោបាយស្តីពីការការពារជាតិជាដើម។

វិធីមួយដើម្បីបញ្ចៀសការរងសម្ពាធដោយពេលវេលា គឺត្រូវរៀបចំជាយុទ្ធសាស្ត្រដែលមានលក្ខណៈបង្កាទុកជាមុន។ ប្រអប់ទី២៨ បង្ហាញពីធាតុខ្លះនៃយុទ្ធសាស្ត្របែបនោះសម្រាប់សភាធ្វើការត្រួតពិនិត្យលើវិស័យសន្តិសុខ។

**ប្រអប់ទី ២៨**

### យុទ្ធសាស្ត្រដែលមានលក្ខណៈបង្កាទុកជាមុន សម្រាប់ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ

សភា ជាញឹកញាប់មមាញឹកជាមួយការតាមដានដំណឹងប្រចាំថ្ងៃ។ លើសពីនេះរបៀបវារៈផ្នែកនយោបាយរបស់ពួកគេមួយផ្នែកធំត្រូវបានទទួលពីរដ្ឋាភិបាល។ វិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយដើម្បីជំនះនូវសម្ពាធពេលវេលា គឺត្រូវរៀបចំទុកជាមុននូវយុទ្ធសាស្ត្រសម្រាប់ការត្រួតពិនិត្យរបស់សភា។ ទាក់ទងនឹងវិស័យសន្តិសុខយុទ្ធសាស្ត្របែបនេះ អាចមានដូចខាងក្រោម៖

**ការកំណត់របៀបវារៈ៖** សភាត្រូវព្យាយាមឥតឈប់ឈរប្រែក្លាយចេតនា និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឲ្យក្លាយជាបញ្ហានៅក្នុងរបៀបវារៈនយោបាយ។

**ការវិវត្តន៍ថ្មីបំផុត៖** សភាចាំបាច់ត្រូវទទួលដំណឹងអំពីការវិវត្តន៍ថ្មីៗបំផុតនៅថ្នាក់ជាតិ និងអន្តរជាតិទាក់ទងនឹងបញ្ហាសន្តិសុខនិងយោធា។ ការទទួលព័ត៌មាននេះមិនមែនតែតាមរយៈរដ្ឋាភិបាលតែមួយនោះទេតែសភាត្រូវឈ្នុសឈ្នលរកព័ត៌មានពីអង្គការមិនមែនរដ្ឋាភិបាលនានា ដូចជា សាកលវិទ្យាល័យ វិទ្យាស្ថានសិក្សាស្រាវជ្រាវ ។ល។

**មេរៀនដែលធ្លាប់ឆ្លងកាត់កន្លងមក៖** សភាត្រូវរៀនសូត្រពីប្រតិបត្តិការមុនៗដែលបានអនុវត្តដោយតួអង្គសន្តិសុខមុនៗតាមរយៈការសិក្សាស្រាវជ្រាវឡើងវិញឲ្យបានញឹកញាប់។

**ពិនិត្យឡើងវិញឥតឈប់ឈរ៖** សភាត្រូវតម្រូវឲ្យរដ្ឋាភិបាលយកចិត្តទុកដាក់លើចេតនាការអភិវឌ្ឍន៍ថ្មីៗបំផុត និងមេរៀនដែលបានរៀនសូត្រកន្លងមក នៅពេលដែលខ្លួនរៀបចំធ្វើបច្ចុប្បន្នភាពលើគោលនយោបាយសន្តិសុខរបស់ខ្លួន។

## ព័ត៌មាន ជំនាញ និងបុគ្គលិកសភា

ការត្រួតពិនិត្យដោយសភាប្រកបដោយប្រសិទ្ធភាពទៅលើវិស័យសន្តិសុខ តម្រូវឲ្យសភាមានជំនាញ និងធនធានគ្រប់គ្រាន់។ ទោះដូច្នេះក្តីជំនាញដែលសភាមានកម្រត្រូវគ្នាជាមួយជំនាញរបស់រដ្ឋាភិបាល និងកងកម្លាំងសន្តិសុខខ្លាំងណាស់។ ក្នុងករណីភាគច្រើន សភាមានតែក្រុមបុគ្គលិកស្រាវជ្រាវដ៏តូចមួយ ខណៈពេលដែលរដ្ឋាភិបាលអាចពឹងពាក់លើបុគ្គលិករបស់ក្រសួងការពារជាតិ និងក្រសួងដទៃទៀតដែលធ្វើការក្នុងវិស័យសន្តិសុខ។ សភាខ្លះដូចជាសភាអាហ្សង់ទីនមានការិយាល័យទំនាក់ទំនងយោធាជាអចិន្ត្រៃយ៍មួយនៅក្នុងសភា ដែលតំណាងរាស្ត្រនិងបុគ្គលិកសភាអាចធ្វើការពិគ្រោះយោបល់ និងផ្តល់នូវដំបូន្មាន ជាពិសេសទៅដល់គណៈកម្មការការពារជាតិ/សន្តិសុខ។ ម្យ៉ាងទៀត តំណាងរាស្ត្រត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតឲ្យបំពេញការងារក្នុងសភានៅក្នុងអាណត្តិដែលមានរយៈពេលមួយកំណត់ ចំណែកឯមន្ត្រីរាជការស៊ីវិល និងបុគ្គលិកយោធា ពួកគេបំពេញភារកិច្ចរហូតនៅក្នុងក្រសួងការពារជាតិ។ ទោះដូច្នោះក្តី បញ្ហាជាមូលដ្ឋាននោះគឺថាសភាពឹងផ្អែកទាំងស្រុងលើព័ត៌មានមកពីរដ្ឋាភិបាល និងយោធា ដែលជាស្ថាប័នដែលពួកគេ

មានភារកិច្ចធ្វើការត្រួតពិនិត្យ។ នេះវាបង្កើតនូវបច្ច័យមិនអំណោយផល ចំពោះសភាបើប្រៀបធៀបទៅនឹងរដ្ឋាភិបាល និងយោធា។ ស្ថានភាពនេះកាន់តែពិបាកដោយសារតែវិស័យសន្តិសុខ ជាវិស័យមិនបើកចំហព្រោះវាជាកិច្ចការរបស់យោធា ហើយវាត្រូវបានការពារដោយច្បាប់ចារកម្ម។

ប្រអប់ទី២៩ បង្ហាញនូវយោបល់ខ្លះអំពីរបៀបពង្រឹងជំនាញរបស់តំណាងរាស្ត្រ អំពីវិស័យសន្តិសុខ។

**ប្រអប់ទី ២៩**

### យន្តការ និងការអនុវត្តដើម្បីពង្រឹងឯកទេសរបស់សភាលើបញ្ហាសន្តិសុខ៖ សំណើមួយចំនួន

- ប្រសិនបើ មិនទាន់មានត្រូវបង្កើតគណៈកម្មការការពារជាតិ/សន្តិសុខសភាជាផ្នែកដាច់ដោយឡែកមួយដែលផ្នែកនេះត្រូវមានជំនាញ និងចំណេះដឹងអំពីបញ្ហាសន្តិសុខ៖ សភាអាចពិចារណាបែងចែក គណៈកម្មការនេះឲ្យទៅជាអនុគណៈកម្មការទទួលបន្ទុកបញ្ហាលទ្ធកម្ម បញ្ហាបុគ្គលិក ថវិកា និងបេសកកម្មរក្សាសន្តិសុខ។
- សម្រាប់តំណាងរាស្ត្រ សូមចូលរួមរៀនសូត្រនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ធ្វើទស្សនកិច្ចសិក្សា ចុះត្រួតពិនិត្យសេវាសន្តិសុខ (សូមអានជំពូក១១ ស្តីពីសេវាចារកម្ម និងព័ត៌មានសម្ងាត់) និងចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល។ វគ្គទាំងអស់នេះ អាចមានដូចជាកិច្ចប្រជុំរាយការណ៍សង្ខេបជូនតំណាងរាស្ត្រ ដែលត្រូវធ្វើដំណើរទៅកាន់ប្រទេសដែលកងទ័ពជាតិកំពុងបំពេញបេសកកម្មរក្សាសន្តិភាពនៅទីនោះផងដែរ។
- ធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងការអនុវត្តរវាងសភានៃប្រទេសផ្សេងៗ ឧទាហរណ៍នៅក្នុងសម័យប្រជុំសន្និបាតសភាអន្តរជាតិ។
- ត្រូវមានបុគ្គលិកសភាដែលទទួលការបណ្តុះបណ្តាលល្អ និងមានវិជ្ជាជីវៈគ្រប់គ្រាន់។
- ត្រូវធ្វើការស្រាវជ្រាវនៅបណ្ណាល័យ និងនៅមជ្ឈមណ្ឌលឯកសារ/ស្រាវជ្រាវ និងនៅលើប្រព័ន្ធទិន្នន័យអេឡិកត្រូនិក។
- ត្រូវសិក្សារៀនសូត្រពីអ្នកជំនាញមកពីអង្គការមិនមែនរដ្ឋ(ឧ.សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ) ឬពីមន្ត្រីយោធាចូលនិវត្តន៍ (សូមអានជំពូក៦ស្តីពីសង្គមស៊ីវិល)។
- ត្រូវធ្វើឲ្យសន្ធិសញ្ញាអន្តរជាតិ និងតំបន់ ពាក់ព័ន្ធជាមួយវិស័យសន្តិសុខ មានជាភាសាជាតិ ដើម្បីតំណាងរាស្ត្របានសិក្សារៀនសូត្រ រួមទាំងឯកសារពាក់ព័ន្ធជាមួយការផ្តល់សច្ចាប័ន ដែលមាននៅក្នុងស្ថាប័នពិនិត្យតាមដានការអនុវត្តសន្ធិសញ្ញាទាំងនោះប្រសិនបើមាន។
- ជារៀងរាល់ឆ្នាំ ជ្រើសរើសប្រធានបទ ២ ឬ ៣ ទាក់ទងនឹងវិស័យសន្តិសុខ ដែលនឹងត្រូវធ្វើការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយ (ឧ.ដោយអនុគណៈកម្មការ)ដើម្បីធ្វើការសិក្សារៀនសូត្រ។
- បង្កើតនូវក្រុមតំណាងរាស្ត្រដែលមានគ្រប់គណបក្ស (ទាំងសភា និងព្រឹទ្ធសភាបើចាំបាច់) ទទួលបន្ទុកការងារសន្តិសុខ/ការពារជាតិ៖ ក្រុមនេះដើរតួជា think-tank ផ្លូវការមួយលើបញ្ហាទាំងនេះ។

## ឆន្ទៈនយោបាយ

ទោះបីជាមានមូលដ្ឋានច្បាប់សម្រាប់ឲ្យសភាធ្វើការត្រួតពិនិត្យលើវិស័យសន្តិសុខ ហើយសភាមានធនធាន និងជំនាញគ្រប់គ្រាន់ក្នុងការធ្វើការការងារនេះក៏ដោយ ក៏សភាត្រូវការការចូលរួមផ្សេងទៀត ដើម្បីឲ្យការអនុវត្តការងារតាមដានត្រួតពិនិត្យរបស់ខ្លួនកាន់តែមានប្រសិទ្ធភាពខ្ពស់ នោះគឺឆន្ទៈនយោបាយរបស់តំណាងរាស្ត្រក្នុងការប្រើប្រាស់ឧបករណ៍ និងយន្តការដែលខ្លួនមានសម្រាប់ធ្វើការត្រួតពិនិត្យលើវិស័យសន្តិសុខ។ កង្វះឆន្ទៈនយោបាយក្នុងការត្រួតពិនិត្យសេវាសន្តិសុខអាចបណ្តាលមកពីកត្តាខុសគ្នា រួមទាំងកត្តាខាងក្រោម៖

- ✓ វិន័យបក្ស៖ តំណាងរាស្ត្រមកពីបក្សកាន់អំណាចចង់រក្សាអំណាចឲ្យអង្គការនីតិប្រតិបត្តិ ដូច្នេះពួកគេមានទំនោរមិនហ៊ានទិតៀនអង្គនីតិប្រតិបត្តិជាសាធារណៈ។
- ✓ កង្វះការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ៖ នៅក្នុងប្រទេសភាគច្រើន សាធារណជនជាទូទៅមិនចាប់អារម្មណ៍ចំពោះបញ្ហាសន្តិសុខ។ ដូច្នេះតំណាងរាស្ត្រជាច្រើនគិតថា ទោះបីជាពួកគេខិតខំគិតគូរលើបញ្ហាសន្តិសុខយ៉ាងណាក៏ដោយ ពេលដែលប្រជាពលរដ្ឋមិនចាប់អារម្មណ៍ ប្រជាពលរដ្ឋក៏មិនអាចបោះឆ្នោតឲ្យពួកគេឡើងវិញដែរ។
- ✓ បញ្ហាសន្តិសុខខ្លះអាចជម្រុញឲ្យតំណាងរាស្ត្រដែលជាសមាជិក នៃគណៈកម្មការចារកម្មមិនឲ្យបញ្ចេញលទ្ធផលនៃរបាយការណ៍របស់ពួកគេ។

នៅក្នុងស្ថានភាពបែបនេះ លិខិតូបករណ៍របស់សភាអាចយកមកអនុវត្តបានតាមវិធីអសកម្ម នៅពេលធ្វើការត្រួតពិនិត្យលើគោលនយោបាយ និងសកម្មភាពរបស់អង្គការនីតិប្រតិបត្តិលើកលែងតែស្ថានភាពធ្ងន់ធ្ងរ ដូចជាមានរឿងអាស្រូវ ឬ ស្ថានភាពអាសន្នដែលជម្រុញឲ្យយកលិខិតូបករណ៍នោះមកប្រើប្រាស់។ តាមពិតវាជាកាតព្វកិច្ចតាមរដ្ឋធម្មនុញ្ញ និងជាភារកិច្ចដ៏សំខាន់មួយរបស់តំណាងរាស្ត្រក្នុងការត្រួតពិនិត្យតាមដានលើចេតនា និងវិធានការរបស់អង្គការនីតិប្រតិបត្តិ។

## ជំពូកទី ១៩

# យន្តការសភាទាក់ទងនឹងវិស័យសន្តិសុខ

ប្រព័ន្ធច្បាប់ទាំងអស់ផ្តល់ដល់សភា នូវមធ្យោបាយផ្សេងៗដើម្បីទាញយកព័ត៌មាន សម្រាប់ត្រួតពិនិត្យលើគោលនយោបាយគ្រប់គ្រងលើរដ្ឋបាលផ្តល់ការការពារដល់បុគ្គល ឬ លុបបំបាត់ការរំលោភបំពាន និងភាពអយុត្តិធម៌។ ក្រៅពីនេះ តំណាងរាស្ត្រអាចទទួល អត្ថប្រយោជន៍ពីការអនុវត្តល្អៗឬតំណាងរាស្ត្រអាចអភិវឌ្ឍនូវការអនុវត្តល្អៗទាំងឡាយ និងសភាអាចអភិវឌ្ឍវិធីសាស្ត្រមិនផ្លូវការមួយចំនួនដែលបំពេញបន្ថែមទៅលើឧបករណ៍ធម្មនុញ្ញ ឬ ឧបករណ៍ច្បាប់ និងយន្តការនានា។

លទ្ធភាពផ្លូវច្បាប់ជារួមៗ យ៉ាងសម្រាប់សភាទទួលបានព័ត៌មាន ពីរដ្ឋាភិបាលមាន៖

- ✓ ការពិភាក្សាដេញដោលដោយសភា។
- ✓ ការសួរសំណួរដេញដោលដោយសភា។
- ✓ ការស៊ើបអង្កេតដោយសភា។

## ការពិភាក្សាដេញដោលដោយសភាលើបញ្ហាសន្តិសុខ

ការពិភាក្សាដេញដោលដោយសភា វាផ្តល់នូវឱកាសសំខាន់មួយ សម្រាប់ធ្វើការផ្លាស់ ប្តូរនូវគំនិត និងប្រមូលព័ត៌មានសំខាន់ៗអំពីការពិតទាំងឡាយ និងចេតនារបស់រដ្ឋាភិបាល។ ជាទូទៅការពិភាក្សាដេញដោលដោយសភាលើគោលនយោបាយសន្តិសុខ និងបញ្ហាសន្តិសុខ អាចធ្វើឡើងក្នុងទម្រង់៥ប្រភេទ៖

- ✓ បន្ទាប់ពីការធ្វើបទបង្ហាញរបស់អង្គការនីតិប្រតិបត្តិ លើការដាក់សំណើថវិកាការពារជាតិប្រចាំឆ្នាំរបស់ខ្លួន។
- ✓ តាមរយៈសេចក្តីថ្លែងការណ៍ផ្លូវការ ឬមិនផ្លូវការដោយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ ដូចជារដ្ឋមន្ត្រីការពារជាតិ ឬរដ្ឋមន្ត្រីការបរទេស។
- ✓ តាមរយៈសៀវភៅការពារជាតិ ឬឯកសារការពារជាតិសំខាន់ៗផ្សេងទៀត។
- ✓ តាមរយៈកម្មវិធីរបស់រដ្ឋាភិបាលដែលដាក់ចេញបន្ទាប់ពីការបោះឆ្នោត។
- ✓ បញ្ហាជាក់លាក់ផ្សេងទៀតដែលតម្រូវឲ្យសភាធ្វើការពិភាក្សាដេញដោល ដូចជារឿងអាស្រូវកង្វល់អំពីបញ្ហាសន្តិសុខសំខាន់ៗ ឬគ្រោះមហន្តរាយជាដើម។

**ប្រអប់ទី ៣០**

## ទិដ្ឋភាពរួមនៃក្បាលម៉ាស៊ីន និងនីតិវិធីសភាសម្រាប់ត្រួតពិនិត្យលើអង្គការនីតិប្រតិបត្តិ

▷ **ការពិភាក្សាដេញដោលទូទៅ**

"នៅក្នុងប្រទេសខ្លះ បទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញតម្រូវឲ្យអង្គការនីតិប្រតិបត្តិផ្ដល់ដល់សភានូវរបាយការណ៍ជាទៀងទាត់របស់ខ្លួន។ (...) នៅក្នុងប្រទេសភាគច្រើនបញ្ហាទាក់ទងនឹងគោលនយោបាយទូទៅ មិនមែនជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យជាទៀងទាត់ដោយស្វ័យប្រវត្តិនោះទេ។ ជាញឹកញាប់បញ្ហាទាក់ទងនឹងគោលនយោបាយទូទៅនោះអាចត្រូវបានស្នើសុំធ្វើការពិភាក្សាដេញដោល ប្រសិនជាមានសំណើពីសមាជិកម្នាក់របស់សភា (...)"។

▷ **ការសួរដេញដោល**

"(...) ការសួរដេញដោលគឺជានីតិវិធីសម្រាប់ទទួលព័ត៌មាន និងធ្វើការត្រួតពិនិត្យនៅក្នុងប្រព័ន្ធសភាដែលមានតាំងពីយូរយារណាស់មកហើយ។ ការសួរដេញដោលត្រូវបានធ្វើដោយសមាជិកសភា ចំពោះរដ្ឋមន្ត្រីឲ្យធ្វើការពន្យល់អំពីអ្វីមួយដែលក្រសួងរបស់គាត់បានធ្វើ ឬ ចំពោះមេដឹកនាំរដ្ឋាភិបាលអំពីបញ្ហាគោលនយោបាយទូទៅ។ ការសួរដេញដោលមានទិដ្ឋភាពសំខាន់២៖ ទី១ វាធ្វើឲ្យមានការជជែកជាទូទៅ និង ទី២ វាជាការដាក់ទណ្ឌកម្មនយោបាយពីព្រោះការពិភាក្សាដេញដោលនេះ នឹងនាំអោយមានការបោះឆ្នោតទៅលើសំណើដែលសំដែងពីការពេញចិត្ត ឬ មិនពេញចិត្តរបស់សភា បន្ទាប់ពីមានការពន្យល់បកស្រាយពីរដ្ឋាភិបាល។ ការសួរដេញដោលគឺជា នីតិវិធីដ៏មានប្រសិទ្ធភាពបំផុត ពីព្រោះរដ្ឋមន្ត្រីត្រូវបានអញ្ជើញដោយផ្ទាល់ឲ្យមករាយការណ៍។ វាមិនត្រឹមជាឧបករណ៍សម្រាប់ទទួលព័ត៌មានប៉ុណ្ណោះនោះទេ តែវាជាទម្រង់នៃការត្រួតពិនិត្យដោយផ្ទាល់មួយ (...)។

▷ **ការពិភាក្សាទូទៅ**

"នៅក្នុងប្រព័ន្ធអង់គ្លេសគេមិនស្គាល់អំពីនីតិវិធី នៃការសួរដេញដោល (Interpellation) នោះទេ ទោះបីជា "ការពិភាក្សាទូទៅ (Adjournment Motion)"នោះ គឺជានីតិវិធីតែមួយដូចគ្នាក៏ដោយ។ ការពិភាក្សាទូទៅ ត្រូវបានគេធ្វើភ្លាមៗមុនពេលសភាចាប់ផ្ដើម សម្រាកវាផ្ដល់នូវឱកាសសម្រាប់ការលើកនូវបញ្ហាមួយចំនួនជាមួយរដ្ឋាភិបាល តែមិនមានធ្វើការបោះឆ្នោតនោះទេ (...)"។

▷ **ការចោទសួរ**

"គោលបំណងនៃនីតិវិធីនៃការចោទសួរ (...) គឺដើម្បីឈ្វេចយកព័ត៌មានពីរដ្ឋាភិបាលដើម្បីស្នើសុំអន្តរាគមន៍ពីរដ្ឋាភិបាលតាមការចាំបាច់ដើម្បីបង្ហាញថាមានការរំលោភបំពាន និងស្វែងរកការដោះស្រាយ។ នីតិវិធីនេះ ក៏ត្រូវបានប្រើដើម្បីទទួលនូវអង្គហេតុលំអិត

ដែលជួយសមាជិកទាំងអស់ឲ្យយល់ពីបញ្ហាដ៏ស្មុគស្មាញដែលពាក់ព័ន្ធទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀតដែល បានដាក់ជូនសភាពិនិត្យ (...)។ នីតិវិធីនេះ ផ្តល់ដល់ក្រុមជំទាស់នូវមធ្យោបាយមួយ នៃការស្វែងរកចំណុចខ្សោយរបស់រដ្ឋាភិបាល ហើយផ្សព្វផ្សាយជាសាធារណៈនូវចំនុចខ្សោយទាំងអស់នេះ ធ្វើអោយគេមានប្រៀបជាងរដ្ឋាភិបាល។ (...)ប្រជាប្រិយភាពនៃនីតិវិធីនេះ អាចកើតមានដោយសារការប្រើសិទ្ធិរបស់សភាក្នុងការសួរសំណួរ ហើយសមាជិកសភាពេលនេះ ក៏ជាភ្នាក់ងារដែលមានសេរីភាពពេញលេញផងដែរ (...)”។

▷ **គណៈកម្មាធិការស៊ើបអង្កេត៖** សូមអានប្រអប់ទី ៣២។

*ប្រភពសភាដោយ Michel Ameller សហភាពអន្តរសភា ឆ្នាំ ១៩៦៦*

## សំណួរ និងការសួរដេញដោលរបស់សភាទាក់ទងនឹងបញ្ហាសន្តិសុខ

សំណួរ- ជាទម្រង់លាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់- បង្កើតបានជាមុខងារស៊ើបអង្កេត មួយរបស់សភា ហើយវាជានីតិវិធីដែលប្រើប្រាស់យ៉ាងទូលំទូលាយបំផុតដោយសភាដើម្បីត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាល។

សំណួរ អាចរួមចំណែកយ៉ាងច្រើនចំពោះការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទៅលើវិស័យសន្តិសុខ ដោយសារមុខងារដ៏សំខាន់របស់វា។ ពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខ ជាទូទៅសំណួររបស់សភា៖

- ✓ ផ្តល់ដល់សមាជិកសភានូវឱកាស ដើម្បីទទួលនូវព័ត៌មានទាន់ពេលវេលា សុក្រិត និងថ្មីៗអំពីគោលនយោបាយការពារជាតិ និងសន្តិសុខរបស់រដ្ឋាភិបាល និងអំពីបញ្ហា សន្តិសុខជាទូទៅ។
- ✓ ជួយសភាក្នុងការត្រួតពិនិត្យលើការអនុវត្តច្បាប់ ទាក់ទងនឹងវិស័យសន្តិសុខដែលបានអនុម័តដោយសភា។
- ✓ ធ្វើឲ្យសាធារណជនយកចិត្តទុកដាក់លើបញ្ហាការពារជាតិ និងសន្តិសុខ ជាពិសេសនៅពេលដែលមានសំណួរដោយផ្ទាល់មាត់ និងចម្លើយត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ និង/ឬត្រូវបានលើកយកមកពិភាក្សាដេញដោលដោយសភា ឬត្រូវបានចុះផ្សាយនៅក្នុងព្រឹត្តប័ត្រព័ត៌មានផ្លូវការរបស់ជាតិ (ច្បាស់ណាស់ព័ត៌មានបែបនេះមិនមែនមានតែសភាម្នាក់គត់ដែលទទួលនោះទេ តែមានសាធារណជនច្រើនទៀតបានទទួលផងដែរ រួមទាំងប្រព័ន្ធផ្សព្វផ្សាយអង្គការ មិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងមូល)។
- ✓ វាអាចមានឥទ្ធិពលទៅលើរបៀបវារៈរបស់រដ្ឋាភិបាលស្តីពីបញ្ហាសន្តិសុខ ឬជួយតម្រង់ទិសដល់របៀបវារៈនេះ។

✓ ផ្តល់ឱកាសឲ្យសមាជិកបក្សប្រឆាំងលើកសំណួរ អំពីបញ្ហាសន្តិសុខដែលជាកង្វល់របស់ពួកគេ ឬ ជាឱកាសឲ្យពួកគេទទួលបាននូវព័ត៌មានដ៏គួរឲ្យពេញចិត្ត ដែលខ្លួនមិនបានទទួលពីពេលមុននោះ។

សំណួររបស់សភាពាក់ព័ន្ធជាមួយវិស័យសន្តិសុខ ភាគច្រើនជាសំណួរដែលរសើបខ្លាំងណាស់។ រដ្ឋមន្ត្រីដែលទទួលបន្ទុកឆ្លើយនឹងសំណួររបស់សភា ជាញឹកញាប់រមែងបង្ហាញនូវចេតនាមិនចង់ឆ្លើយ។ ភាពអល់ឯកនេះ ជាញឹកញាប់ចេញមកពីហេតុផលថាសកម្មភាពនៃវិស័យសន្តិសុខគឺជាសកម្មភាពសម្ងាត់។ ជាទូទៅឯកសារទាក់ទងនឹងសន្តិសុខជាតិ គឺជាឯកសារសម្ងាត់ ដូច្នេះវាមិនអាចផ្សព្វផ្សាយជូនសភា និងសាធារណជនបានទេ។

**ប្រអប់ទី ៣១**

**សំណើទាក់ទងនឹងការដេញដោលប្រកបដោយប្រសិទ្ធភាព**

▷ **ការត្រៀមដំពេញលេញ៖** ការសួរសំណួរពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខមិនមែនជាការងាយស្រួល ជាពិសេសសំណួរបែបបច្ចេកទេស។ ដូច្នេះដើម្បីជួយដល់បញ្ហានេះគេត្រូវមានទំនាក់ទំនងមិនផ្លូវការជាមួយបុគ្គលិកយោធា (ឬ ត្រូវដឹងអំពីប្រវត្តិយោធា ឬ ប្រវត្តិប៉ារ៉ាយោធា)។

**ភាសាច្បាស់លាស់៖** ការបង្កើតភាពមិនច្បាស់លាស់នៅក្នុងសំណួរអាចនាំទៅរកការយល់ ខុស និងចម្លើយមិនគ្រប់គ្រាន់ពីក្រសួងសាម៉ី។

▷ **ពេលវេលា៖** ការជ្រើសរើសពេលវេលាដើម្បីសួរសំនួរគឺជា កត្តាដ៏សំខាន់មួយដែលបញ្ជាក់ពីប្រសិទ្ធភាពរបស់សំណួរ និងផលប៉ះពាល់របស់សំណួរ ដោយរួមទាំងការផ្សព្វផ្សាយជាសាធារណៈផងដែរ។

ទោះដូច្នេះក៏ដោយ អំណាចរបស់អង្គការនីតិប្រតិបត្តិក្នុងការកំណត់ឯកសារមួយ ជាឯកសារសម្ងាត់ត្រូវបានកំណត់ដោយច្បាប់។ លើសពីនេះ ដំណើរការនៃការដាក់ឯកសារ ជាឯកសារសម្ងាត់ត្រូវតែមានតម្លាភាពដើម្បីឲ្យដឹងថា អ្នកណាជាអ្នកទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្តថាឯកសារណាជាកម្មវត្ថុនៃការសម្ងាត់រយៈពេលយូរប៉ុណ្ណា សម្រាប់ឯកសារនេះ នៅជាឯកសារសម្ងាត់រួមទាំងលក្ខខណ្ឌសម្រាប់កំណត់ឯកសារមួយជាឯកសារសម្ងាត់ និងការដែលឯកសារនោះលែងជាឯកសារសម្ងាត់។

ដោយបញ្ហានេះមានការពាក់ព័ន្ធជាមួយស្ថាប័ន កត្តាខាងក្រោមទំនងរួមចំណែកដល់ការបង្កើតសំណួរប្រកបដោយប្រសិទ្ធភាពរបស់សភា៖

- ✓ តំណាងរាស្ត្រអាចដាក់នូវសំណួរបន្ថែម នៅពេលដែលពួកគេមិនពេញចិត្តជាមួយចម្លើយ ឬត្រូវការនូវការបញ្ជាក់បន្ថែមទៀត។
- ✓ តំណាងរាស្ត្រ អាចបង្កើតឲ្យមានការពិភាក្សាដេញដោលអំពី បញ្ហាដែលបានលើកនៅក្នុងម៉ោងសំណួរចម្លើយ។
- ✓ បំណងប្រាថ្នារបស់សមាជិកសភា ចង់ឆក់យកឱកាសដែលនីតិវិធីផ្តល់ឲ្យ ដើម្បីចោទជាសំណួរ។
- ✓ សាធារណជនអាចចូលរួមស្តាប់ការចោទសួររបស់តំណាងរាស្ត្រ ក្នុងម៉ោងសំណួរចម្លើយ ឬធ្វើការតាមដានវានៅតាមវិទ្យុ ឬទូរទស្សន៍។
- ✓ ការពិភាក្សាដេញដោលនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយសារតែនឹងមានការបោះពុម្ពផ្សាយនូវឯកសារសំណួរចម្លើយ ដែលសាធារណជនអាចទទួលបាននូវឯកសារទាំងនេះ។

## ការស៊ើបអង្កេតពិសេសរបស់សភាទៅលើវិស័យសន្តិសុខ

គណៈកម្មការសភា ក្រៅពីខ្លួនមានតួនាទីនៅក្នុងដំណើរការធ្វើច្បាប់ ហើយខ្លួនក៏ត្រូវចូលរួមនៅក្នុងការត្រួតពិនិត្យលើការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ។ សកម្មភាពរបស់រដ្ឋាភិបាលអាចត្រូវបានពិនិត្យ តាមរយៈមធ្យោបាយនៃការចាត់តាំងគណៈកម្មការទទួលបន្ទុកផ្នែកព័ត៌មានបណ្តោះអាសន្ន ដែលអាចមានគណៈកម្មការលើសពីមួយ និងអាចមានការបោះពុម្ពផ្សាយនូវរបាយការណ៍ព័ត៌មាន។ នៅក្នុងការស៊ើបអង្កេតពិសេសសភាត្រូវ មានអំណាចកោះហៅដូចតុលាការដែរ។

### គុណសម្បត្តិធំៗ និងលក្ខណៈនៃគណៈកម្មការស៊ើបអង្កេត

ទាក់ទងនឹងបញ្ហាសន្តិសុខ/ការពារជាតិ គណៈកម្មការចំពោះកិច្ចមួយទទួលបន្ទុកការងារស៊ើបអង្កេតមានតួនាទីសំខាន់ជាក់លាក់ ហើយគុណសម្បត្តិនៃគណៈកម្មការនេះ មានច្រើនខ្លាំងណាស់ជាពិសេស៖

- ✓ ការបង្កើតគណៈកម្មការនេះ ត្រូវបានសាធារណជនចាត់ទុកថាជាសញ្ញានយោបាយវិជ្ជមានមួយ។
- ✓ វាជាឧបករណ៍ដ៏គ្រប់ជ្រុងជ្រោយមួយ សម្រាប់ត្រួតពិនិត្យបញ្ហានយោបាយដ៏សើប ពាក់ព័ន្ធនឹងវិស័យសន្តិសុខ។
- ✓ វាអាចបង្កើតឲ្យមានការវាយតម្លៃ ដ៏ត្រឹមត្រូវមួយទៅលើគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខដ៏ជាក់លាក់និងអាចស្នើឲ្យរកមធ្យោបាយដើម្បីដោះស្រាយ ឬតម្រង់ទិសដែលអាចទទួលយកបាន ដោយសភាទាំងមូល និងរដ្ឋាភិបាល។

**ប្រអប់ទី ៣២**

## លក្ខណៈពិសេសៗនៃគណៈកម្មាធិការសភាចោទសួរ

"(...)គណៈកម្មការស៊ើបអង្កេត មានភារកិច្ចសិក្សានូវបញ្ហាជាក់លាក់ណាមួយ។ ចំពោះគោលបំណងនេះ សភាបង្គាប់ឲ្យសមាជិករបស់ខ្លួនធ្វើការប្រមូលព័ត៌មានពាក់ព័ន្ធដែលខ្លួនត្រូវការដើម្បីខ្លួនអាចធ្វើការត្រួតពិនិត្យដោយសមស្រប និងអាចធ្វើរបាយការណ៍ដាក់ជូនសភា សម្រាប់ធ្វើការពិភាក្សាដេញដោលនិងសម្រេច។ សិទ្ធក្នុងការបង្កើតសំណួរ វាជាលទ្ធផលនៃគោលការណ៍ធម្មជាតិដែលសភាត្រូវមានព័ត៌មានពេញលេញអំពីបញ្ហាទាំងឡាយ ទាក់ទងនឹងវិធានការដែលអង្គការនីតិប្រតិបត្តិបានអនុវត្ត (...)។

នៅក្នុងប្រទេសខ្លះ គណៈកម្មការស៊ើបអង្កេតមានការពិបាកនៅក្នុងការស៊ើបអង្កេតដ៏មានប្រសិទ្ធភាព។ ជាញឹកញាប់ពួកគេមិនមានអំណាចបង្គាប់បុគ្គលពាក់ព័ន្ធឲ្យចូលខ្លួនដូចតុលាការនោះទេ។ កត្តាផ្សេងទៀតអាចមានការធ្វើអន្តរាគមន៍ពីអាជ្ញាធររដ្ឋាភិបាល ដែលធ្វើឲ្យដំណើរការស៊ើបអង្កេតរបស់គណៈកម្មការមានការយឺតយ៉ាវ និងធ្វើឲ្យការស៊ើបអង្កេតមិនទទួលផល។ (...) ក៏ប៉ុន្តែវិធីសាស្ត្រដ៏ប្រសើរបំផុតនៃការធ្វើឲ្យការស៊ើបអង្កេតរបស់សភាមានប្រសិទ្ធភាព គឺត្រូវមានការធ្វើសម្បថនៅពេលមានការដាក់ភស្តុតាង។ (...)

ភស្តុតាងដែលផ្តល់ដោយមន្ត្រីរាជការស៊ីវិលដល់គណៈកម្មការស៊ើបអង្កេត អាចមានបញ្ហាពិសេស ពីព្រោះពួកគេជាកូនចៅរបស់រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងមួយ។ តើរដ្ឋាភិបាលអាចបង្គាប់ពួកគេឲ្យឆ្លើយត្រឹមកម្រិតណា ចំពោះសំណួរដែលសភាបានចោទសួរ។ (...) (នៅក្នុងប្រទេសខ្លះ) គេតម្រូវឲ្យមានការយល់ព្រមពីក្រសួងក្នុងការផ្តល់នូវភស្តុតាង។ ក៏ប៉ុន្តែភស្តុតាងនេះ អាចនឹងប្រគល់ឲ្យលើកលែងតែវាមិនបង្កមហន្តរាយដល់សន្តិសុខសាធារណៈ ឬវាមិនធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តសេវាសាធារណៈ (...)។

គួរកត់សម្គាល់ថា ទោះជានៅក្នុងប្រព័ន្ធណាក៏ដោយ ក៏គណៈកម្មការដែលបានបង្កើតដើម្បីដឹកនាំការស៊ើបអង្កេតគឺគ្មានអ្វីក្រៅពីជាអង្គភាពមួយដែលធ្វើការស៊ើបអង្កេត និងស្វែងរកការពិតនោះទេដែលតួនាទីចម្បងរបស់ អង្គភាពនេះ គឺធ្វើរបាយការណ៍ដាក់ជូន អង្គសភា ដែលជាអ្នកបានបង្កើតខ្លួននោះ។ ជាចុងក្រោយ វាអាស្រ័យលើអង្គសភាក្នុងការទាញសេចក្តីសន្និដ្ឋានពីរបាយការណ៍ស៊ើបអង្កេត និងទិន្នន័យដែលប្រមូលបានទាំងនោះ (...)"

*ប្រភព៖ សភា ដោយ Michel Ameller សហភាពអន្តរសភា ឆ្នាំ ១៩៦៦*

លក្ខណៈដ៏សំខាន់មួយទៀតរបស់គណៈកម្មការស៊ើបអង្កេត គឺសមាភាពរបស់គណៈកម្មការ។ សមាមាត្រនៃតំណាងរាស្ត្របក្សប្រឆាំង ដែលពាក់ព័ន្ធនៅក្នុងគណៈកម្មការ វាមានសារៈសំខាន់ណាស់ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការស៊ើបអង្កេត។

អំណាចនៃការស៊ើបអង្កេតមានមិនដូចគ្នាទេពីសភាមួយទៅសភាមួយទៀត និងពីគណៈកម្មការមួយទៅគណៈកម្មការមួយទៀត។ អំណាចជាស្នូលសំខាន់ៗមានដូចជា៖

- ✓ អំណាចក្នុងការជ្រើសរើសបញ្ហា និងវិសាលភាពនៃការស៊ើបអង្កេតរបស់សភា។
- ✓ អំណាចចុះត្រួតពិនិត្យនៅក្នុងមូលដ្ឋានយោធា និងបរិវេណដទៃទៀតនៃសេវាសន្តិសុខ (សូមអានជំពូក១៧)។
- ✓ អំណាចប្រមូលទិន្នន័យ និង ឯកសារសម្ងាត់ពាក់ព័ន្ធទាំងអស់ពីគណៈគ្រប់គ្រងរដ្ឋបាលគ្រប់គ្រងរដ្ឋាភិបាល ឬបុគ្គលិកទូទៅ។
- ✓ អំណាចទទួលភស្តុតាង ដោយមានធ្វើសម្បថពីគណៈគ្រប់គ្រង ពីរដ្ឋបាលគ្រប់គ្រងរដ្ឋាភិបាល ឬយោធាក៏ដូចជាពីសង្គមស៊ីវិល។
- ✓ អំណាចរៀបចំសវនការសាធារណៈ ឬសវនាការបិទទ្វា។

ការស៊ើបអង្កេតរបស់សភាកាណាដា លើការពង្រាយទាហ៊ានកាណាដា នៅក្នុងប្រទេសសូម៉ាលី គឺជាឧទាហរណ៍ដ៏ល្អមួយ (សូមអានប្រអប់ទី៣៣)។

**ប្រអប់ទី ៣៣**

### គណៈកម្មាការស៊ើបអង្កេតករណី នៃការតាំងពង្រាយកងកម្លាំងកាណាដា នៅក្នុងប្រទេសសូម៉ាលី៖ ឧទាហរណ៍របាយការណ៍របស់សភាស្តីពីផលប៉ះពាល់ជាសាធារណៈទៅលើបញ្ហាសន្តិសុខ

ក្នុងអំឡុងពេលនៃការតាំងពង្រាយកងទ័ពកាណាដា នៅក្នុងប្រទេសសូម៉ាលីក្នុងឆ្នាំ១៩៩៣ ព្រឹត្តិការណ៍ដែលបង្កការភ្ញាក់ផ្អើល ដល់ប្រជាពលរដ្ឋកាណាដាភាគច្រើន គឺការបាញ់ជនជាតិសូម៉ាលីដែលបានលបចូលទៅក្នុងបរិវេណមូលដ្ឋានយោធាកាណាដានៅក្នុងទីក្រុង Belet Huen ប្រទេសសូមាលី រួមទាំងការវាយដំរហូតដល់ស្លាប់នូវក្មេងជំទង់ម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយទាហ៊ានម្នាក់មកពីក្រុមកុម្មង់ដូលេខ២ នៃកងវរៈសេនាធំទ័ពអាកាសរបស់កាណាដា (CAR) ការប៉ុនប៉ងធ្វើអត្តឃាតដោយទាហ៊ានកាណាដាម្នាក់ និងបន្ទាប់ពីបេសកកម្មបានបញ្ចប់ មានការចោទប្រកាន់អំពីការលាក់ ឬការកាឡៃព័ត៌មានសំខាន់ៗ។ ខ្សែអាត់វីដេអូនៃសកម្មភាពធ្វើទុក្ខបុកម្នេញដ៏គួរឲ្យស្អប់ខ្ពើមរបស់សមាជិក CAR ក៏ត្រូវបានបញ្ចេញឲ្យដឹង។ គណៈកម្មការយោធាដែលស៊ើបអង្កេតព្រឹត្តិការណ៍ទាំងនោះត្រូវបានរដ្ឋាភិបាលចាត់ទុកថាមិនគ្រប់គ្រាន់ ព្រោះវាមិនបានបំពេញតាមស្តង់ដាររបស់កាណាដាទាក់ទងនឹងគណនេយ្យភាពសាធារណៈ ដូច្នេះសភាកាណាដា នៅក្រោមច្បាប់ស្តីពីការស៊ើបអង្កេត បានបង្កើតនូវការស៊ើបអង្កេតសាធារណៈដោយបើកចំហមួយ។

**វិសាលភាព និងសិទ្ធិអំណាច-** ច្បាប់ស្តីពីការស៊ើបអង្កេតផ្តល់នូវសិទ្ធិអំណាចឲ្យមានការកោះហៅសាក្សីស្តាប់ចម្លើយកសិណសាក្សីជួលមេធាវីជាអ្នកជំនាញ និងទីប្រឹក្សា និងវាយតម្លៃភស្តុតាង។

អំណាចក្នុងការបង្គាប់ឲ្យផ្តល់កសិណសាក្សី គឺជាយន្តការចម្បងដើម្បីកំណត់ថា តើបញ្ហាអ្វីខ្លះដែលបានលេចឮនៅក្នុងប្រទេសសូម៉ាលី និងនៅឯទីបញ្ជាការធំការពារជាតិ។ មានសាក្សីចំនួន ១១៦នាក់ បានផ្តល់ភស្តុតាងដល់ក្រុមស៊ើបអង្កេតនៅក្នុងសវនការសាធារណៈ ដែលបានផ្សាយតាមទូរទស្សន៍ពេញប្រទេសកាណាដា។ វិសាលភាពនៃការស៊ើបអង្កេតមិនត្រឹមតែគ្របដណ្តប់លើអ្វីដែលបានកើតឡើងនៅក្នុងប្រទេសសូម៉ាលីប៉ុណ្ណោះនោះទេ តែវាបានលាតសន្ធឹងទៅលើខ្សែសង្វាក់នៃការបញ្ជាវិន័យប្រតិបត្តិការរបស់កងកម្លាំងកាណាដា និងសកម្មភាពរួមទាំងសេចក្តីសម្រេចរបស់ក្រសួងការពារជាតិផងដែរ។ ផ្នែកទី២ នៃលក្ខខណ្ឌ ការងារពាក់ព័ន្ធ (ToR) តម្រូវឲ្យសមាជិកគណៈកម្មាធិការពិនិត្យមើលនូវបញ្ហាដ៏ជាក់លាក់ ពាក់ព័ន្ធជាមួយការតាំងពង្រាយទ័ពទាំងមុនក្នុងអំឡុងពេល និងក្រោយពេលប្រតិបត្តិការនៅក្នុងប្រទេសសូម៉ាលី។

**មិនមែនជាការជំនុំជម្រះ-** ការស៊ើបអង្កេតមិនមានគោលបំណងដូចការជំនុំជម្រះនោះទេ ទោះបីជានៅក្នុងសវនការ គេមានបញ្ចូលនូវការពិនិត្យលើការបញ្ជាពីស្ថាប័ន និងចម្លើយពាក់ព័ន្ធនឹងឧប្បទ្ទវហេតុដែលបណ្តាលឲ្យមានការចោទប្រកាន់ និងធ្វើការជំនុំជម្រះអ្នកពាក់ព័ន្ធក៏ដោយ។ ចំណុចសំខាន់នៃការស៊ើបអង្កេត គឺផ្តោតលើបញ្ហារបស់ស្ថាប័ន និងប្រព័ន្ធទាក់ទងនឹងអង្គការចាត់តាំង និងគ្រប់គ្រងរបស់កងកម្លាំងកាណាដា និងរបស់ក្រសួងការពារជាតិជាជាងលើបុគ្គលដែលបានជ្រើសរើសឲ្យបម្រើការដោយស្ថាប័នទាំងនេះ។ ទោះដូច្នេះក្តីវាចៀសមិនផុតថាការស៊ើបអង្កេតទាំងនេះ បានពិនិត្យលើសកម្មភាពរបស់បុគ្គលនៅក្នុងខ្សែសង្វាក់បញ្ជា និងក្នុងលក្ខណៈដែលពួកគេជាមេដឹកនាំ។

**លទ្ធផល-** លទ្ធផលនៃការស៊ើបអង្កេតរយៈពេល២ឆ្នាំ គឺការរៀបចំរបាយការណ៍ដ៏វែងអន្លាយមួយដែលគ្របដណ្តប់នូវបញ្ហាជាច្រើនមាន៖ រចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃកងកម្លាំងកាណាដា និងក្រសួងការពារជាតិនៅពេលចុះបំពេញបេសកកម្មនៅក្នុងប្រទេសសូម៉ាលី ការវិភាគអំពីខ្សែសង្វាក់បញ្ជានៅក្នុងយោធាកាណាដា វប្បធម៌ និងក្រមសីលធម៌របស់យោធា ទំនាក់ទំនងរវាងស៊ីវិល-យោធានៅក្នុងប្រទេសកាណាដា។ល។ របាយការណ៍បានបញ្ចប់ដោយមានអនុសាសន៍មួយចំនួនធំសម្រាប់ធ្វើការកែសម្រួលសកម្មភាព និងគោលនយោបាយរបស់រដ្ឋាភិបាល និងកងកម្លាំងយោធារបស់ប្រទេសកាណាដា។ ភាគច្រើននៃអនុសាសន៍ទាំងនេះ កំពុងត្រូវបានអនុវត្តតាម។

*ប្រភព៖ សាស្ត្រាចារ្យ បណ្ឌិត Donna Winslow ទីប្រឹក្សាបច្ចេកទេស*
*នៃក្រុមស៊ើបអង្កេតសភាកាណាដា ឆ្នាំ១៩៩៦*

**ជំពូកទី ១៥**

# គណៈកម្មការការពារជាតិ និង សន្តិសុខសភា

ដោយសារភាពស្មុគ្រស្មាញ នៃវិស័យសន្តិសុខរចនាសម្ព័ន្ធដែលបានរៀបចំដ៏ល្អរបស់គណៈកម្មការសភាគឺជាការងារសំខាន់ ប្រសិនបើសភាចង់មានឥទ្ធិពលទៅលើអង្គនីតិប្រតិបត្តិ។ ការត្រួតពិនិត្យដោយសភាទៅលើវិស័យសន្តិសុខ មានពាក់ព័ន្ធមិនត្រឹមគណៈកម្មការមួយប៉ុណ្ណោះនោះទេ តែមានពាក់ព័ន្ធជាមួយគណៈកម្មការមួយចំនួនដែលមានឈ្មោះខុសៗគ្នាទៅតាមសភានៃ ប្រទេសនីមួយៗ (ហើយពេលខ្លះមានអាណត្តិរួមបញ្ចូលគ្នា)។

ភាគច្រើនគណៈកម្មការទាំងនេះ ដែលគេអាចកោះហៅចូលរួមនៅក្នុងសម័យប្រជុំរួមមានដូចជា៖

- ✓ គណៈកម្មការការពារជាតិ (ពេលខ្លះគេហៅថាគណៈកម្មការកងកម្លាំងប្រដាប់អាវុធ ឬគណៈកម្មការការពារជាតិ និងសន្តិសុខ ឬគណៈកម្មការកិច្ចការសន្តិសុខនិងកិច្ចការប្រទេស) ដែលជាទូទៅគណៈកម្មការនេះ ធ្វើការពាក់ព័ន្ធរាល់បញ្ហាទាំងអស់ទាក់ទងនឹងវិស័យសន្តិសុខ ឧ. បេសកកម្មអង្គការចាត់តាំងបុគ្គលិក ប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់យោធា និងការជ្រើសរើសទ័ព និងលទ្ធកម្ម។
- ✓ គណៈកម្មការសម្រាប់កិច្ចការបរទេស ធ្វើការពាក់ព័ន្ធជាមួយការធ្វើសេចក្តីសម្រេចត្រូវចូលរួមនៅក្នុងបេសកកម្មរក្សាសន្តិភាព ឬទទួលវត្តមានរបស់យោធានៅក្នុងទឹកដីជាតិ បញ្ហាសន្តិសុខអន្តរជាតិ អង្គការអន្តរជាតិ/ តំបន់ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា។
- ✓ គណៈកម្មការថវិកាឬហិរញ្ញវត្ថុ ដែលជាអ្នកសម្រេចចុងក្រោយលើបញ្ហាថវិកាសម្រាប់ផ្តល់ឲ្យអង្គការវិស័យសន្តិសុខទាំងអស់ អាចមានគណៈកម្មការគណនេយ្យសាធារណៈ ជាអ្នកពិនិត្យឡើងវិញនូវរបាយការណ៍សវនកម្ម លើថវិកាជាតិទាំងមូលរួមទាំងថវិកាការពារជាតិផងដែរ។
- ✓ គណៈកម្មការ (អនុគណៈកម្មការ) កិច្ចការចារកម្ម គណៈកម្មការនេះជាញឹកញាប់បើកកិច្ចប្រជុំជាអសាធារណៈ។
- ✓ គណៈកម្មការឧស្សាហកម្ម និងពាណិជ្ជកម្ម ធ្វើការលើបញ្ហានៃការទិញដូរអាវុធ (សំណាង និងទូទាត់)។

- ✓ គណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍយោធា)។
- ✓ គណៈកម្មការមហាផ្ទៃ (ឬកិច្ចការប្រទេស) ធ្វើការជាមួយនគរបាលឆ្មាំព្រំដែន និងជាមួយអង្គការសភាដទៃទៀត។

## អំណាច និងមធ្យោបាយ

អំណាចក្នុងការប្រមូល និងទទួលភស្តុតាងពីប្រភពខាងក្រៅរបស់ គណៈកម្មការសភាមានមិនដូចគ្នាទេ។ គណៈកម្មការសភាខ្លះ ដូចជាគណៈកម្មការអចិន្ត្រៃយ៍ចំពោះកិច្ចរបស់សភាអង់គ្លេស (the British House of Commons) មិនមានសិទ្ធិប្រមូលភស្តុតាងដោយខ្លួនឯងឡើយ ខណៈពេលដែលគណៈកម្មការផ្សេងៗ ដូចជាគណៈកម្មការនៅក្នុងសភាអាមេរិកមានអំណាចស្ទើរតែគ្មានព្រំដែនក្នុងការប្រមូលភស្តុតាងពីប្រភពខាងក្រៅ (នៅក្រោមសម្បថ)។

គណៈកម្មការសភាខ្លះ មានសមត្ថភាពក្នុងការកសាង និងអនុម័តច្បាប់ ឬរៀបចំសេចក្តីព្រាងច្បាប់ថ្មី ឬ ស្នើសុំឲ្យធ្វើវិសោធនកម្មលើច្បាប់ដែលនៅជាធរមាន ខណៈពេលដែលគណៈកម្មការដទៃទៀត មានសិទ្ធិត្រឹមតែត្រួតពិនិត្យលើសកម្មភាពរបស់អង្គការនីតិប្រតិបត្តិ និងការសម្រេចលើថវិកាដោយមិនអាចបង្កើតច្បាប់។

កម្រិតមធ្យោបាយ និងជំនាញដែលគណៈកម្មាការអាចមាន គឺជាប្រការដ៏សំខាន់បំផុតព្រោះវាអាចឲ្យគណៈកម្មការបំពេញនូវភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព៖ ឧ. គណៈកម្មការត្រូវមានបុគ្គលិក សមត្ថភាព និងស្ថិរភាព សមត្ថភាពស្រាវជ្រាវ និងជំនាញពិសេស និងជំនាញទូទៅ មានអង្គភាពស្រាវជ្រាវរបស់សភា មានទិន្នន័យ និង ឯកសារគាំទ្រគ្រប់គ្រាន់ (សមត្ថភាពក្នុងការទទួល និងផលិតនូវទិន្នន័យ និងឯកសារ) សមត្ថកិច្ចក្នុងការកោះហៅ អ្នកជំនាញ សមត្ថភាពក្នុងការរៀបចំសវនការ និងសួរចម្លើយ។ (សម្រាប់ព័ត៌មានបន្ថែមទៀត សូមអានជំពូកទី១៩ ស្តីពីយន្តការ និងឧបករណ៍សភា)។

**ប្រអប់ទី ៣៤**

### មុខងារសំខាន់ៗរបស់គណៈកម្មការសភាស្តីពី បញ្ហាការពារជាតិ ឬសន្តិសុខ

#### គោលនយោបាយសន្តិសុខ

- ▷ ពិនិត្យ និងរាយការណ៍អំពី គំនិតផ្តួចផ្តើមគោលនយោបាយធំៗដែលបានប្រកាសដោយរដ្ឋមន្ត្រីការពារជាតិ។
- ▷ ពិនិត្យជាទៀតទាត់នូវការអនុវត្តគោលនយោបាយដោយរដ្ឋមន្ត្រីការពារជាតិ។
- ▷ ធ្វើការត្រួតពិនិត្យថាតើក្រសួងការពារជាតិ បានអនុវត្តតាម ច្បាប់ស្តីពីសេរីភាពនៃព័ត៌មានដែរឬយ៉ាងណា រួមទាំងគុណភាព នៃការផ្តល់ព័ត៌មានដល់សភា តើផ្តល់តាមមធ្យោបាយអ្វីខ្លះ។

- ពិនិត្យញត្តិនិងពាក្យបណ្តឹងតវ៉ាពីបុគ្គលិកយោធា និងស៊ីវិលពាក់ព័ន្ធនឹងវិស័យសន្តិសុខ។

## ច្បាប់

- ពិចារណា និងរាយការណ៍អំពីសេចក្តីព្រាងច្បាប់ដោយរដ្ឋាភិបាល និងបញ្ជូនសេចក្តីព្រាងច្បាប់ទៅសភា។
- ពិចារណាលើសន្ធិសញ្ញាអន្តរជាតិ ឬតំបន់ និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធជាមួយការទទួលខុសត្រូវ របស់ក្រសួងការពារជាតិ។
- ប្រសិនបើចាំបាច់ផ្តួចផ្តើមបង្កើតច្បាប់ថ្មីដោយស្នើសុំឲ្យរដ្ឋមន្ត្រីធ្វើការស្នើសុំច្បាប់ថ្មីឬរៀបចំសេចក្តីព្រាងច្បាប់ថ្មីដោយខ្លួនឯង។

## ការចំណាយ

- ពិនិត្យ និងរាយការណ៍អំពីការប៉ាន់ប្រមាណធំៗ និងការចំណាយប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ។
- ពិចារណាសំណើសុំបន្ថែមការចំណាយរបស់ក្រសួងការពារជាតិនិងរាយការណ៍ជូនសភា នៅពេលសភាត្រូវការ ធ្វើការពិចារណាបន្ថែមទៀត។
- ប្រសិនបើចាំបាច់ បង្គាប់ឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើសវនកម្ម។

## ការគ្រប់គ្រង និងរដ្ឋបាល

- ធ្វើការពិចារណា ហើយប្រសិនបើចាំបាច់ប្រមូលភស្តុតាង និងរៀបចំរបាយការណ៍ អំពីការតែងតាំងសំខាន់ៗ ដោយអាជ្ញាធរនីតិប្រតិបត្តិដែលពាក់ព័ន្ធ (មេបញ្ជាការយោធាដែលដឹកនាំប្រតិបត្តិការមន្ត្រីរាជការស៊ីវិលជាន់ខ្ពស់)។
- ធ្វើការពិភាក្សាជាមួយអង្គការផ្ទៃក្នុងទទួលបន្ទុកវិស័យសន្តិសុខ តាមរយៈស្ថាប័នខាងក្រៅដែលមានទំនាក់ទំនងជាមួយសភា (ឧ. ការិយាល័យទទួលពាក្យបណ្តឹង) និងទាញការយកចិត្តទុកដាក់របស់សភាចំពោះការប្រព្រឹត្តខុសឆ្គងទាំងឡាយ។

*ប្រភព៖ របាយការណ៍របស់ Hansard Society Commission ស្តីពីការត្រួតពិនិត្យដោយសភាចក្រភពអង់គ្លេស ឆ្នាំ២០០១*

ប្រអប់ទី ៣៥ គឺជាឧទាហរណ៍ស្តីពី វិធីសាស្ត្រដ៏ល្អមួយដែលអនុវត្តដោយសភា នៃប្រទេសន័រវ៉េ។

**ប្រអប់ទី ៣៥**

**សម័យប្រជុំរួមរបស់គណៈកម្មការកិច្ចការបរទេស និងគណៈកម្មការការពារជាតិនៃសភាន័រវ៉េ**

"ភារកិច្ចរបស់គណៈកម្មការចម្រុះកិច្ចការបរទេស គឺត្រូវធ្វើការពិភាក្សាលើបញ្ហាគោលនយោបាយការបរទេស ដ៏សំខាន់របស់រដ្ឋាភិបាល គោលនយោបាយពាណិជ្ជកម្ម និងបញ្ហាគោលនយោបាយសន្តិសុខជាតិ។ ក្នុងករណីពិសេស គណៈកម្មការចម្រុះនេះអាចលើកជាអនុសាសន៍ជូនសភាន័រវ៉េទៀតផង។

គណៈកម្មការចម្រុះនេះ មានសមាជិកធម្មតាមកពីគណៈកម្មការអចិន្ត្រៃយ៍កិច្ចការបរទេស ប្រធាន និងអនុប្រធានសភា (ប្រសិនបើមិនទាន់ក្លាយជាសមាជិក) រួមទាំងប្រធានគណៈកម្មការអចិន្ត្រៃយ៍ការពារជាតិដែលសមាជិកនេះ អាចមានរហូតដល់ ១១រូបដែលត្រូវបានតែងតាំងដោយគណៈកម្មការបោះឆ្នោត។ នៅពេលធ្វើការតែងតាំង គេក៏បានគិតគូរអំពីសមាមាត្រតំណាងគណបក្សនយោបាយនៅក្នុងគណៈកម្មការចម្រុះនេះផងដែរ។

យោងតាមគោលការណ៍ដូចគ្នា គណៈកម្មការបោះឆ្នោតតែងតាំងសមាជិកសភាដែលនឹងត្រូវកោះហៅក្នុងករណីដែលអវត្តមានរួមទាំង ក្នុងករណីឈប់សម្រាកផង។

គណៈកម្មការចម្រុះនេះ នឹងកោះប្រជុំនៅពេលដែលប្រធានយល់ថាជាការចាំបាច់ ឬតាមសំណើរបស់នាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីការបរទេសឬមានសំណើពីសមាជិកគណៈកម្មការចំនួន១/៣។

កិច្ចការរបស់គណៈកម្មការចម្រុះត្រូវទុកជារឿងសម្ងាត់ លើកលែងតែមានការបង្គាប់ផ្សេងពីនេះ។ ដូចគ្នាផងដែរចំពោះកិច្ចប្រជុំចម្រុះរបស់ គណៈកម្មការនេះជាមួយគណៈកម្មការដទៃទៀត ខ្លឹមសារនៃកិច្ចប្រជុំត្រូវរក្សាទុកជារឿងសម្ងាត់។ ប្រធានអាចសម្រេចថា សូម្បីតែដីកាកោះហៅ សមាជិកឲ្យចូលប្រជុំនៅក្នុងគណៈកម្មការចម្រុះនេះ ក៏ត្រូវរក្សាជាការសម្ងាត់ដែរ។

របៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការចម្រុះ ត្រូវដាក់ជូនមុនកិច្ចប្រជុំរបស់សភាន័រវ៉េ នៅពេលដែលយ៉ាងហោចណាស់មានសមាជិកចំនួន៦រូប របស់គណៈកម្មការបានស្នើសុំឲ្យធ្វើដូច្នេះ នៅក្នុងកិច្ចប្រជុំអំពីការ រៀបចំរបៀបវារៈប្រជុំ។ គណៈកម្មការត្រូវធ្វើការពិចារណា ថាតើវាមានលក្ខខណ្ឌអ្វីខ្លះសម្រាប់ឲ្យសភាយកមកធ្វើការពិចារណា ប្រសិនបើ មានគេត្រូវជូនដំណឹងដល់ប្រធានសភាអំពីបញ្ហានេះ។ សភា នឹងសម្រេចជាអសាធារណៈ ថាតើកិច្ចប្រជុំមួយត្រូវធ្វើជាសាធារណៈ ឬជាអសាធារណៈ។ សមាជិករបស់រដ្ឋាភិបាលម្នាក់អាចស្នើសុំឲ្យសភាធ្វើការពិចារណាលើបញ្ហាសំខាន់ៗតាមរយៈសំណើមួយ។ ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗត្រូវរៀបចំធ្វើជាបន្ទាន់ក្រោយពីមានសំណើ ឬក្នុងអំឡុងពេលនៃកិច្ចប្រជុំស្របតាមសំណើរបស់សភា។ សំណើទាំងឡាយអាចមិនបានដាក់ជូនសម្រាប់ការពិចារណាដោយគណៈកម្មការ"។

*ប្រភព៖ ផ្នែកទី ១៣ នៃវិធាននីតិវិធីរបស់សភាន័រវ៉េ (Storting:http://www.stortinget.no/g)*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ចំណុចសំខាន់ៗដែលគណៈកម្មការនៅក្នុងសភាត្រូវធ្វើទាក់ទងនឹងបញ្ហាការពារជាតិ

- ▷ ពិនិត្យឡើងវិញនូវអាណត្តិរបស់គណៈកម្មការ និងអនុគណៈកម្មការ ដើម្បីធានាថា៖
  - អាណត្តិនេះ ត្រូវបានកំណត់ច្បាស់លាស់ត្រឹមត្រូវ។
  - អាណត្តិនេះ អនុញ្ញាតឲ្យគណៈកម្មការអនុវត្តការងារគ្រប់បែបយ៉ាងឲ្យបានគ្រប់ជ្រុងជ្រោយ។
  - អាណត្តិនេះ វាស្របជាមួយគោលនយោបាយសន្តិសុខ និងគោលនយោបាយរបស់ក្រសួងដទៃ ដែលអាចមានផលប៉ះពាល់មកលើសន្តិសុខ ដូចជាគោលនយោបាយកិច្ចការបរទេស គោលនយោបាយស្តីពី អាកាសចរណ៍/សមុទ្រ គោលនយោបាយឧស្សាហកម្មគោលនយោបាយស្តីពីការផ្គត់ផ្គង់អគ្គិសនីជាដើម។

### គណៈកម្មការសភាដែលមានប្រសិទ្ធភាព

- ▷ ត្រូវធានាថាតាមច្បាប់ និងតាមការអនុវត្តជាក់ស្តែងគណៈកម្មការ និងអនុគណៈកម្មការដែលមានសមត្ថកិច្ចនៅក្នុងសភាត្រូវមានយន្តការដូចដែលបានរៀបរាប់នៅក្នុងប្រអប់ទី៣៤។
- ▷ ត្រូវគិតគូរបង្កើតអនុគណៈកម្មការសម្រាប់វិស័យជាក់លាក់នៃការពារជាតិដូចជាអនុគណៈកម្មការថវិកា លទ្ធកម្ម បុគ្គលិក និងបេសកកម្មរក្សាសន្តិភាពជាដើម។
- ▷ ផ្តួចផ្តើមធ្វើច្បាប់សម្រាប់គោលនយោបាយព័ត៌មានវិស័យសន្តិសុខ និង ផ្តួចផ្តើមឲ្យមានដំណើរការពិនិត្យឡើងវិញនូវការចំណាយលើការពារជាតិ។
- ▷ ធានាថា គណៈកម្មការមានធនធានគ្រប់គ្រាន់ រួមទាំងអាចទទួលមតិយោបល់ពីអ្នកជំនាញផងដែរ។
- ▷ ត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវគំរូការអនុវត្តល្អជាអន្តរជាតិ ដែលបានចងក្រងសម្រាប់ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ។

## ជំពូកទី ១៦

# មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹង

ក្នុងចំណោមតួអង្គជាស្ថាប័នឯករាជ្យ ដែលពិនិត្យតាមដានវិស័យសន្តិសុខ មន្ត្រីរដ្ឋទទួលដោះស្រាយពាក្យបណ្តឹងជាអ្នកបំពេញភារកិច្ចពិសេសជាងគេ។ មានប្រទេសខ្លះ មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងនេះ មានសមត្ថកិច្ចទូទៅ និងធ្វើការដោះស្រាយបញ្ហាទាំងអស់។ ប្រទេសខ្លះទៀតមានស្ថាប័នមួយទៀត ដែលមានតួនាទីស្រដៀងនេះដែរ ដូចជា ស្នងការ ឬគណៈកម្មការទទួលពាក្យបណ្តឹងសាធារណៈ (នៅក្នុងប្រទេសនីហ្សេរីយ៉ា)។ ទោះដូច្នេះក្តី នៅក្នុងប្រទេសដទៃទៀត មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងដែលមានជំនាញពិសេស ត្រូវបានបង្កើតឡើងដើម្បីធ្វើការដោះស្រាយបញ្ហាទាក់ទងនឹងកងកម្លាំងប្រដាប់អាវុធ។

### ប្រអប់ទី ៣៦
### មន្ត្រីរដ្ឋទទួលដោះស្រាយពាក្យបណ្តឹង

"(...) មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងធ្វើការទាក់ទងនឹងពាក្យបណ្តឹង ពីសាធារណជនពាក់ព័ន្ធនឹងសេចក្តីសម្រេច សកម្មភាព ឬ ការមិនអើពើពីរដ្ឋបាលសាធារណៈ។ មន្ត្រីរូបនេះត្រូវបានបោះឆ្នោតជ្រើសរើសដោយសភា ឬ ត្រូវបានតែងតាំងដោយប្រធានរដ្ឋ ឬ រដ្ឋាភិបាលតាមរយៈការពិគ្រោះយោបល់ ឬ ក្រោយពីមានការពិគ្រោះយោបល់ជាមួយសភា។ តួនាទីរបស់មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងគឺត្រូវការពារប្រជាពលរដ្ឋប្រឆាំងនឹងការរំលោភសិទ្ធិ ការរំលោភបំពានអំណាច កំហុស ការធ្វេសប្រហែស សេចក្តីសម្រេចមិនយុត្តិធម៌ និងការគ្រប់គ្រងមិនត្រឹមត្រូវ ដើម្បីធ្វើការកែលំអរដ្ឋបាលសាធារណៈ និងដើម្បីធ្វើឲ្យសកម្មភាពរបស់រដ្ឋាភិបាល កាន់តែមានលក្ខណៈបើកចំហ និងធ្វើឲ្យទាំងរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលកាន់តែមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹង អាចត្រូវបានគេចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេស និងគាំទ្រដោយច្បាប់ ឬត្រូវបានបង្កើតដោយច្បាប់ (...)។

ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងមានអំណាចមួយចំនួនៈ

១. ធ្វើការស៊ើបអង្កេតថាតើរដ្ឋាភិបាលបានអនុវត្តការងាររបស់ខ្លួនផ្ទុយពីច្បាប់កំណត់ ឬ ដោយអយុត្តិធម៌ដែរឬទេ។

២. ប្រសិនបើការស៊ើបអង្កេតឃើញនូវភាពមិនសមស្រប ត្រូវផ្តល់យោបល់ឲ្យធ្វើការលុបបំបាត់នូវទង្វើមិនសមស្របនោះ
៣. ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនលើករណីជាក់លាក់ណាមួយ និងដាក់ជូនរដ្ឋាភិបាល និងសាមីបណ្តឹង ហើយប្រសិនបើយោបល់ទាំងនោះ មិនត្រូវបានទទួលយកដោយរដ្ឋាភិបាល ត្រូវដាក់របាយការណ៍នោះជូនសភា។ មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងភាគច្រើនរៀបចំរបាយការណ៍ប្រចាំឆ្នាំ អំពីសមិទ្ធិផលរបស់ពួកគេ និងដាក់ជូនសភា និងសាធារណជនទូទៅ។

ជាធម្មតា មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹង មិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលចងកាតព្វកិច្ចលើរដ្ឋាភិបាលនោះឡើយ។ ផ្ទុយទៅវិញ នៅក្នុងប្រទេសខ្លះមន្ត្រីរដ្ឋមួយនេះ មានយុត្តាធិការទូទៅ លើស្ថាប័នរបស់រដ្ឋាភិបាលជាច្រើន ឧទាហរណ៍ដូចជា តុលាការ នគរបាល និងយោធា ហើយប្រទេសខ្លះទៀត ស្ថាប័នមួយ ឬច្រើនក្នុងចំណោមស្ថាប័ន ខាងលើនេះ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ការិយាល័យនេះឡើយ”។

*ប្រភព៖ ប័ណ្ណព័ត៌មាន TheInternational Ombudsman Institute Information Booklet* on
*http://www.law.ualberta.ca/centres/ioi/*

*សូមអាន៖ ការិយាល័យឧត្តមស្នងការជាន់ខ្ពស់សិទ្ធិមនុស្សសហប្រជាជាតិ*
*ឯកសារលេខ ១៩ វិទ្យាស្ថានជាតិសម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស*

## មន្ត្រីរដ្ឋទទួលដោះស្រាយពាក្យបណ្តឹងសម្រាប់ការពារជាតិ

ក្នុងនាមជាស្ថាប័នដាច់ដោយឡែកមួយ មន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការពារជាតិ មានចែងនៅក្នុងច្បាប់ និងមានឈ្មោះខុសៗគ្នា ដូចជាមន្ត្រីរដ្ឋដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការពារជាតិ (ប្រទេសហ្វាំងឡង់ ន័រវ៉េ ព័រទុយហ្កាល់ និង អាល្លឺម៉ង់) ស្នងការទទួលពាក្យបណ្តឹងទាហាននិងយោធា (អ៊ីស្រាអែល) ចំណែកមន្ត្រីរដ្ឋទទួលពាក្យបណ្តឹងនៃក្រសួងការពារជាតិ និងកងកម្លាំងប្រដាប់អាវុធកាណាដា (ប្រទេសកាណាដា) និងមន្ត្រីរដ្ឋទទួលពាក្យបណ្តឹងកងកម្លាំងការពារជាតិអូស្ត្រាលី (ប្រទេសអូស្ត្រាលី)។

**ប្រអប់ទី ៣៧**

## ទិដ្ឋភាពទូទៅនៃមន្ត្រីរដ្ឋទទួលដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងបញ្ហាការពារជាតិ នៅក្នុងប្រទេសមួយចំនួន

| *ប្រទេស* | *សមត្ថភាព* | *មុខងារ* | *រាយការណ៍ទៅអាជ្ញាធរនយោបាយ* |
|---|---|---|---|
| អូស្ត្រាលី | - **មន្ត្រីរដ្ឋទទួលពាក្យបណ្តឹងកងកម្លាំងការពារជាតិ**<br>- ចាត់តាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី | រាល់ការប្រព្រឹត្តខុសឆ្គងរបស់សមាជិកនៃកងកម្លាំងប្រដាប់អាវុធអូស្ត្រាលី | - របាយការណ៍ប្រចាំឆ្នាំដាក់ជូនទៅរដ្ឋមន្ត្រីសម្រាប់ជម្រាបជូនសភា។ |
| កាណាដា | - **មន្ត្រីរដ្ឋទទួលពាក្យបណ្តឹងការពារជាតិ**<br>- ចាត់តាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី | ដើម្បីការពារសិទ្ធិមនុស្សរបស់បុគ្គលិកនៃក្រសួងការពារជាតិ (DND) និងសមាជិកនៃកងកម្លាំងកាណាដា (CF)។ | - រាយការណ៍ទៅ DND ឬ CF អំពីករណីជាក់លាក់។ របាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពរបស់ខ្លួនដាក់ជូនរដ្ឋមន្ត្រី។<br>- ក្រុមប្រឹក្សាភិបាលអព្យាក្រឹត្យឯករាជ្យពីការគ្រប់គ្រងរបស់រដ្ឋមន្ត្រីការពារជាតិ។ |
| ន័រវ៉េ | - **មន្ត្រីរដ្ឋទទួលពាក្យបណ្តឹងការពារជាតិ**<br>- នៅក្រោមក្របខណ្ឌនៃសភាន័រវ៉េ | ថែរក្សាសុខុមាលភាពរបស់ទាហានម្នាក់ៗ។ តួនាទីស្នូលធ្វើការដោះស្រាយជម្លោះ និងរក្សាបរិយាកាសនៃការជឿទុកចិត្តគ្នា និងបើកចំហនៅក្នុងផ្នែកផ្សេងៗនៃក្រសួងការពារជាតិ។ | លើកជាអនុសាសន៍ធ្វើការវាយតម្លៃ និងធ្វើការរិះគៀន ដើម្បីឲ្យស្ថាប័នសាធារណៈពាក់ព័ន្ធអនុវត្តតាម។ |

មន្ត្រីរដ្ឋទទួលពាក្យបណ្តឹង គឺជាយន្តការបំពេញបន្ថែមមួយ សម្រាប់ត្រួតពិនិត្យលើយោធាជំនួសឲ្យប្រជាពលរដ្ឋនិង/ឬសភា។ ភារកិច្ចដ៏សំខាន់នៃការិយាល័យទទួលពាក្យបណ្តឹងទាក់ទងនឹងកិច្ចការយោធានេះ គឺត្រូវធ្វើការស៊ើបអង្កេតលើការចោទប្រកាន់នានាទាក់ទងនឹងការធ្វើសេចក្តីសម្រេចចិត្តតាមទំនើងចិត្ត ឬបទល្មើសមជ្ឈិមដែលប្រព្រឹត្តក្នុងនាមមន្ត្រីរដ្ឋទទួលបន្ទុកសេវាយោធា និងបទល្មើសមជ្ឈិមដែលប្រព្រឹត្តដោយយោធា។

មន្ត្រីរដ្ឋទទួលពាក្យបណ្តឹង ទាក់ទងនឹងកិច្ចការយោធានៅ ក្នុងប្រព័ន្ធនយោបាយមានលក្ខណៈមិនដូចគ្នានោះទេពីប្រទេសមួយទៅប្រទេសមួយទៀត។ នៅក្នុងប្រទេសខ្លះ (ប្រទេសអាល្លឺម៉ង់ និងស៊ុយអែត) សភាជាអ្នកចាត់តាំងមន្ត្រីរដ្ឋទទួលពាក្យបណ្តឹងការពារជាតិ ហើយការិយាល័យនេះត្រូវរាយការណ៍ជូនសភា។ ចំណែកប្រទេសខ្លះទៀត (ប្រទេសអ៊ីស្រាអែល និងកាណាដា) រដ្ឋមន្ត្រីការពារជាតិជាអ្នកចាត់តាំងការិយាល័យនេះ។ ការិយាល័យទទួលពាក្យបណ្តឹងខ្លះ មានការិយាល័យរបស់ខ្លួននៅក្នុងបរិវេណសភា (ដូចជា ស្នងការសភាអាល្លឺម៉ង់សម្រាប់កងប្រដាប់អាវុធ សូមអានប្រអប់ទី៣៨) ឬការិយាល័យនេះ អាចស្ថិតនៅក្រៅសភា (ប្រទេសស៊ុយអែត)។

ប្រជាពលរដ្ឋ ឬអ្នកបម្រើការងារតូចធំទាំងឡាយណា ទទួលរងនូវការធ្វើបាបពីយោធាអាចស្នើសុំឲ្យមន្ត្រីរដ្ឋរូបនេះធ្វើការស៊ើបអង្កេត។ ក្រៅពីនោះតំណាងរាស្ត្រអាចស្នើសុំការិយាល័យនេះឲ្យធ្វើការស៊ើបអង្កេតលើការរំលោភបំពាន និង ពាក្យបណ្តឹងដែលត្រូវបានចោទប្រកាន់ថែមទៀតផង។ ជាញឹកញាប់ រឿងក្តីដែលត្រូវបានស៊ើបអង្កេត ដោយការិយាល័យទទួលពាក្យបណ្តឹងមានដូចជា ករណីទាក់ទងនឹងការរួចខ្លួនពីករណីកិច្ចយោធា និងការពន្យាករណីកិច្ចយោធា ការផ្ទេរ និងការចូលបម្រើកិច្ចការយោធាឡើងវិញ របបអាហារ ការរំសាយទ័ព ការឈប់សម្រាកដោយគ្មានច្បាប់វិន័យ និងបទល្មើសដែលអាចដាក់ទោសបាន។ ប្រសិនបើ មន្ត្រីរដ្ឋរូបនេះរកឃើញ ដូចដែលពាក្យបណ្តឹងបានប្តឹងមន្ត្រីនេះ អាចលើកជាអនុសាសន៍នានា រួមទាំងតម្រូវឲ្យស្ថាប័នពាក់ព័ន្ធធ្វើការផ្លាស់ប្តូរ ឬធ្វើការពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់ពួកគេ។

## មន្ត្រីរដ្ឋទទួលពាក្យបណ្តឹង និងការសម្ងាត់

លក្ខណៈពិសេសនៃវិស័យសន្តិសុខ គឺថាព័ត៌មានខ្លះមិនអាចផ្សព្វផ្សាយដល់សាធារណជនដោយហេតុផលថាវាអាចប៉ះពាល់ដល់សន្តិសុខជាតិ។ នៅក្នុងប្រទេសជាច្រើន គេបានបង្កើតនូវប្បញ្ញត្តិជាក់លាក់នៅក្នុងច្បាប់ទាក់ទងនឹងរបៀបដែលការិយាល័យនេះ គួរប្រតិបត្តិនៅក្នុងបញ្ហាទាក់ទងនឹងសន្តិសុខជាតិ។ ជាទូទៅ ទោះបីជាវិធាននៃការរក្សាការសម្ងាត់ត្រូវបានអនុវត្តក៏ដោយ ក៏មន្ត្រីរដ្ឋទទួលពាក្យបណ្តឹង ត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតរាល់បញ្ហា ដែលខ្លួនយល់ថាជាការចាំបាច់ និងអាចចេញចូលមូលដ្ឋានយោធា និងអាចពិនិត្យរាល់ឯកសារដែលពាក់ព័ន្ធទាំងអស់។ ទោះដូច្នេះក្តី មន្ត្រីនេះមិនអាចទម្លាយលទ្ធផលនៃការស៊ើបអង្កេតជូនដល់សាធារណជនទូទៅបាននោះទេ។

**ប្រអប់ទី ៣៨**

### ស្នងការសភាអាល្លឺម៉ង់សម្រាប់កងកម្លាំងប្រដាប់អាវុធ

ដោយបង្កើតឡើងវិញនូវកងកម្លាំងប្រដាប់អាវុធ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ប្រទេសអាល្លឺម៉ង់បានផ្តល់សារៈសំខាន់ដល់ការត្រួតពិនិត្យរបស់សភា។ ដើម្បីធានាឲ្យមានការអនុវត្តនូវខ្លឹមសារដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលទាក់ទងនឹងបុគ្គលនៅក្នុងកងកម្លាំងប្រដាប់អាវុធ មាត្រា ៤៥ខ ត្រូវបានបន្ថែមទៅក្នុងច្បាប់គោលរបស់ប្រទេស។ មាត្រានេះសរសេរថា៖ "ត្រូវបង្កើតស្នងការសភា ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងដើម្បីជួយ Bundestag ក្នុងការអនុវត្តនូវការត្រួតពិនិត្យរបស់សភា"។ សេចក្តីលំអិតពាក់ព័ន្ធជាមួយការអនុវត្តនូវមាត្រានេះ មានចែងនៅក្នុង "ច្បាប់ស្តីពីស្នងការសភាសម្រាប់កងកម្លាំងប្រដាប់អាវុធ"។

ស្នងការសភាគឺជាអង្គការបំពេញបន្ថែមមួយនៅក្នុងសភា (Bundestag) ដូច្នេះស្នងការនេះ គឺជាសមាជិកមួយនៃសភា។ ស្នងការនេះអាចធ្វើការស៊ើបអង្កេតបញ្ហាជាក់លាក់តាមការបញ្ជារបស់ Bundestag ឬ គណៈកម្មការការពារជាតិរបស់សភា ឬ អាចចាត់វិធានការតាមការសម្រេចរបស់ខ្លួនផ្ទាល់នៅពេលដែលខ្លួនបានទទួលនូវពាក្យចោទប្រកាន់ផ្សេងៗ។

ស្រដៀងគ្នា ជាមួយគោលការណ៍នៃការបែងចែងអំណាចដាច់ពីគ្នាដែរ ស្នងការធ្វើការត្រួតពិនិត្យលើរដ្ឋមន្ត្រីការពារជាតិ។ ស្នងការនេះអាចទាមទារព័ត៌មាន និងអាចឆែកកំណត់ហេតុរបស់រដ្ឋមន្ត្រីការពារជាតិ និងភ្នាក់ងារ និងបុគ្គលិកក្រោមឱវាទរបស់រដ្ឋមន្ត្រី។ គាត់អាចចុះត្រួតពិនិត្យទីបញ្ជាការភ្នាក់ងារ និងអាជ្ញាធរនៃកងកម្លាំងប្រដាប់អាវុធ និងស្ថាប័នរបស់ពួកគេ នៅពេលណាក៏បានដោយមិនចាំបាច់ព្រមានជាមុន។ គាត់អាចចាប់ផ្តើមធ្វើការស៊ើបអង្កេតនៅពេលបានទទួលពាក្យបណ្តឹងពីបុគ្គលិកយោធាទោះមានឋានន្តរសក្តិប៉ុណ្ណាក្តី។ អ្នកណាក៏ដោយនៅក្នុងកងកម្លាំងប្រដាប់អាវុធ មានសិទ្ធិដាក់ជូនរឿងក្តីទៅស្នងការដោយមិនបាច់បញ្ជូនតាមច្រកផ្លូវការ និងមិនបាច់ភ័យខ្លាចថាគេដាក់វិន័យ ឬរើសអើងពីព្រោះតែញត្តិតវ៉ារបស់ខ្លួន។

*ប្រភព http://www.bundestag.de/*

## មន្ត្រីរដ្ឋទទួលពាក្យបណ្តឹង៖ យន្តការសម្រាប់ពង្រឹងការជឿទុកចិត្តចំពោះយោធា

កំណត់ហេតុរបស់មន្ត្រីរដ្ឋទទួលពាក្យបណ្តឹងយោធា ខ. ដូចករណីនៃមន្ត្រីរដ្ឋទទួលពាក្យបណ្តឹងយោធានៃប្រទេសស៊ុយអែត (ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩១៥) បង្ហាញថាស្ថាប័ននេះបានក្លាយជាយន្តការដ៏មានឥទ្ធិពលមួយ នៅក្នុងការពង្រឹងជំនឿទុកចិត្តរបស់សាធារណជននៅក្នុង

វិស័យការពារជាតិ។ ក្រៅពីនេះ ការិយាល័យនេះបានផ្តល់នូវការការពារពិសេស ចំពោះយោធាស្រីប្រុសប្រឆាំងនឹងការរំលោភបំពាននៅក្នុងយោធា។ ជាទូទៅសមិទ្ធិផលធំៗ របស់មន្ត្រីរដ្ឋទទួលពាក្យបណ្តឹងនេះ គឺជាការរួមចំណែកដល់ការបង្កើនការជឿទុកចិត្តនៅក្នុងវិស័យយោធា ដោយបង្កើតនូវតម្លាភាពកាន់តែច្រើននៅក្នុងដំណើរការរដ្ឋបាលទាំងមូល ដោយមិនធ្វើឲ្យប៉ះពាល់ដល់ឋានានុក្រមយោធា។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ស្ថាប័នទទួលពាក្យបណ្តឹង

- ▷ ប្រសិនបើស្ថាប័នបែបនេះ មិនទាន់មាននៅក្នុងប្រទេសរបស់អ្នកសូមអ្នកគិតគូរ និងចាត់វិធានការជម្រុញឲ្យមានការបង្កើតនូវស្ថាប័នមួយនេះ។
- ▷ ក្នុងន័យនេះ សូមចងចាំនូវគោលការណ៍ណែនាំ និងឯកសារយោង រួមទាំងមេរៀនដែលបានរៀនជាច្រើន ដែលអ្នកអាចរកបានទាក់ទងនឹងមន្ត្រីទទួលពាក្យបណ្តឹងអន្តរជាតិតាមអាស័យដ្ឋាន៖ http://www.ombudsmaninternational.com

### មន្ត្រីទទួលពាក្យបណ្តឹងការពារជាតិ ឬវិស័យសន្តិសុខ

- ▷ ប្រសិនបើស្ថាប័នបែបនេះ មិនទាន់មាននៅក្នុងប្រទេសរបស់អ្នក សូមអ្នកគិតគូរ និងចាត់វិធានការជម្រុញឲ្យមានការបង្កើតនូវស្ថាប័នមួយនេះ។
- ▷ ស្វែងរកព័ត៌មាន ឬ មេរៀនដែលបានរៀនសូត្រជាច្រើន ពីបទពិសោធន៍នៃប្រទេសមួយចំនួនដែលមានមន្ត្រីទទួលពាក្យបណ្តឹងការពារជាតិ។
- ▷ ប្រសិនបើប្រទេសរបស់អ្នក មានមន្ត្រីទទួលពាក្យបណ្តឹងការពារជាតិមួយរួចមកហើយ សូមអ្នកស្នើសុំធ្វើការ ពិនិត្យឡើងវិញនូវលក្ខខណ្ឌការងារ (ToR) តួនាទី នីតិវិធីទូទៅរបស់ស្ថាប័ននេះ ក្នុងនោះមាននីតិវិធីស្តីពី ការធ្វើរបាយការណ៍ដាក់ជូនសភា ផលប៉ះពាល់ធនធាន និងថវិកាដោយប្រៀបធៀបសន្តិសុខស្រដៀងគ្នា។

**ជំពូកទី ១៧**

# ការចុះត្រួតពិនិត្យទីតាំងសេវាសន្តិសុខ

## សារៈសំខាន់

ការយល់ដឹងយ៉ាងល្អិតល្អន់ អំពីវិស័យសន្តិសុខមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់តំណាងរាស្ត្រទាំងអស់។ តំណាងរាស្ត្រត្រូវមានចំណេះដឹងបែបទ្រឹស្តី តាមរយៈការចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែងសន្តិសុខ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់នូវតម្រូវការរបស់សេវាសន្តិសុខ។ ក្នុងទស្សនៈនេះ ការចុះទៅដល់ទីកន្លែងរបស់សេវាសន្តិសុខអាចចាត់ទុកថាជាវិធីមួយ នៃការរៀបចំឲ្យមានកិច្ចសន្ទនា និងកសាងនូវជំនឿទុកចិត្ត និងការយោគយល់គ្នារវាងមេដឹកនាំនយោបាយ និងមេដឹកនាំយោធា។ ការចុះទៅត្រួតពិនិត្យរបស់តំណាងរាស្ត្រ លើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រចាំថ្ងៃរបស់ទាហាន និងបង្ហាញដល់ពួកគេថា ថ្នាក់ដឹកនាំនយោបាយមានការចាប់អារម្មណ៍យ៉ាងខ្លាំង និងមានការប្តេជ្ញាចិត្តខ្ពស់ចំពោះសុខុមាលភាព និង បេសកកម្មរបស់ពួកគេ។

**ប្រអប់ទី ៣៩**

### ករណីនៃប្រទេសអាហ្សង់ទីន

អ្នកនយោបាយចុះត្រួតពិនិត្យមូលដ្ឋានយោធា និងអង្គភាពយោធា ដោយមានគោលបំណងធ្វើការផ្លាស់ប្តូរយោបល់ជាមួយបុគ្គលិកយោធា។ ការចុះត្រួតពិនិត្យនេះ មានការជូនដំណឹងដល់អាជ្ញាធរកងកម្លាំងប្រដាប់អាវុធ និងជួយកាត់បន្ថយនូវការមិនទុកចិត្តគ្នា និងភាពមិនចូលចិត្តគ្នារវាងស្ថាប័នទាំង២នេះ។ កាលណាមានការយល់ដឹងអំពីបញ្ហាយោធាកាន់តែច្បាស់ ការធ្វើទំនាក់ទំនងរវាងតំណាងរាស្ត្រ និង សមាជិកនៃកងកម្លាំងប្រដាប់អាវុធកាន់តែមានលក្ខណៈល្អប្រសើរឡើង។ ចំពោះបញ្ហាទាក់ទងនឹងវិស័យសន្តិសុខវិធាន និងពេលវេលាមានលក្ខណៈខុសគ្នា ហើយការចុះត្រួតពិនិត្យវាជួយឲ្យអ្នកនយោបាយមានការយល់ដឹងអំពីបញ្ហានេះ។

*ប្រភព៖ Pablo Carlos Martinez,"ការរៀបចំរចនាសម្ព័ន្ធឡើងវិញ នៃកងកម្លាំងប្រដាប់អាវុធ និងតួនាទីរបស់សភា៖ បទពិសោធន៍ពីប្រទេសអាហ្សង់ទីន",http://www.pdgs.org*

នៅក្នុងមណ្ឌលឃុំខ្លួន និងពន្ធនាគារ អ្នកជាប់ពន្ធនាគារគឺស្ថិតនៅក្នុងកណ្តាប់ដៃ និងស្ថិតនៅក្រោមការត្រួតត្រារបស់បុគ្គលិកសន្តិសុខទាំងស្រុង។ ស្ថានភាពពិសេសនេះ ធ្វើឲ្យអ្នកទោសទាំងនោះកាន់តែងាយរងគ្រោះ ពីការរំលោភបំពានសិទ្ធិមនុស្សគ្រប់ប្រភេទទាំងអស់។ ជាអកុសលករណីនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីនៅក្នុងពន្ធនាគារ និងមណ្ឌលឃុំឃាំងកើតមានគ្រប់ទីកន្លែង។ ដូច្នេះស្ថាប័នទាំងនោះ គួរតែជាកម្មវត្ថុនៃការត្រួតពិនិត្យតាមដានជាពិសេស។ ឧបករណ៍ដ៏មានប្រយោជន៍នៅក្នុងករណីនេះ គឺការចុះត្រួតពិនិត្យដល់ទីតាំងទាំងនេះដោយតំណាងរាស្ត្រ និងអ្នកជំនាញក្នុងគោលបំណងស្វែងរកឲ្យឃើញនូវករណី នៃការប្រព្រឹត្តមិនគប្បី និងធ្វើការទប់ស្កាត់នូវការរំលោភបំពានបន្ថែមទៀត។

ប្រអប់ទី ៤០ ពន្យល់អំពីយន្តការចុះត្រួតពិនិត្យនៅក្នុងមណ្ឌលឃុំឃាំងដែលមានចែងនៅក្នុងពិធីសារបន្ថែមនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម។

**ប្រអប់ទី ៤០**

**ពិធីសារបន្ថែម លើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មបានពង្រីកលទ្ធភាពឲ្យមានការចុះត្រួតពិនិត្យនៅក្នុងទីតាំងសេវាសន្តិសុខ**

ក្នុងខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តលើពិធីសារបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងការធ្វើទារុណកម្ម និង ការប្រព្រឹត្តដ៏ឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម។ ពិធីសារនេះចងកាតព្វកិច្ចឲ្យរដ្ឋទាំងឡាយអនុញ្ញាតឲ្យអ្នកជំនាញជាតិនិងអន្តរជាតិឯករាជ្យ ចុះធ្វើការត្រួតពិនិត្យមណ្ឌលឃុំខ្លួនរបស់ពួកគេ។ អ្នកជំនាញទាំងនោះ មានភារកិច្ចលើកជាអនុសាសន៍ ដើម្បីកាត់បន្ថយនូវហានិភ័យនៃការប្រព្រឹត្តមិនគប្បីនានា។

*សម្រាប់ព័ត៌មានបន្ថែមសូមអាន នៅលើគេហទំព័រ www.unhchr.ch*

## លក្ខខណ្ឌដើម្បីចុះធ្វើការត្រួតពិនិត្យឲ្យបានជោគជ័យ

ពិតណាស់ ការចុះត្រួតពិនិត្យនៅលើទីតាំងរបស់សេវាសន្តិសុខ ដូចជាមូលដ្ឋានទ័ព ឬមូលដ្ឋានយោធាគួរត្រូវមានការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ (ឧ.ក្រសួងការពារជាតិ)។ ការចុះត្រួតពិនិត្យដោយមិនរំពឹងទុក ឬមិនមានការសម្របសម្រួលជាមុន អាចបង្កើតជាផលវិបាកមិនល្អទៅវិញ ដោយសារគេអាចបកស្រាយថា វាខ្វះនូវការជឿទុកចិត្តពីយោធា ដោយធ្វើរំលងឋានានុក្រមនិងថាការចុះត្រួតពិនិត្យនេះរំខានដល់ការបំពេញមុខងាររបស់យោធាជាដើម។ នៅក្នុងការចុះត្រួតពិនិត្យនេះ ក៏ត្រូវមានការចូលរួមពីតំណាងនៃគណបក្សនយោបាយផ្សេងៗ និងត្រូវរៀបចំឲ្យបានល្អម៉ត់ចត់ជាមុន។

ចំណុចខ្វះខាតនៃការចុះត្រួតពិនិត្យបែបនេះ គឺថាគណៈកម្មការសភាអាចនឹងបានឃើញនូវអ្វីដែលមេបញ្ជាការនៃសេវាសន្តិសុខនោះចង់ឲ្យពួកគេមើលប៉ុណ្ណោះ។ ការចុះត្រួតពិនិត្យបែបសហការនេះ មិនឆ្លុះបញ្ចាំងនូវតថភាពពិតនៃបញ្ហានោះទេ តែវាបានផ្តល់ដល់យោធានូវឱកាស ដើម្បីកែខៃស្ថានភាពទៅតាមចិត្តពួកគេចង់បាន ជាពិសេស ក្នុងករណីនៃការត្រួតពិនិត្យលើថវិកា។ ដូចនេះ គេគួរតែមានការឯកភាពលើការចុះត្រួតពិនិត្យដែលមានលក្ខណៈ ៣ប្រភេទ៖ ការចុះត្រួតពិនិត្យដែលបានស្នើដោយយោធា ការចុះត្រួតពិនិត្យដែលស្នើដោយសភា និងប្រកាសឲ្យដឹងជាមុន និងការចុះត្រួតពិនិត្យដោយសភាតែមានការជូនដំណឹងជាបន្ទាន់ (ឧ. មួយថ្ងៃ)។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ច្បាប់ទាក់ទងនឹងការចុះត្រួតពិនិត្យនៅក្នុងទីតាំងនៃសេវាសន្តិសុខ

- ▷ ជម្រុញឲ្យមានការចុះត្រួតពិនិត្យដោយសភានៅក្នុងទីតាំងនៃសេវាសន្តិសុខ (រួមទាំងទ័ពដែលបានពង្រាយនៅឯបរទេសផង) ដែលច្បាប់តម្រូវ។
- ▷ នៅពេលដែលមិនមានច្បាប់ចែងពីគណៈប្រតិភូសភា ត្រូវចុះត្រួតពិនិត្យទីតាំងសេវាសន្តិសុខ ត្រូវសុំការបំភ្លឺថាតើតំណាងរាស្ត្រ អាចចុះធ្វើការត្រួតពិនិត្យនៅក្នុងទីតាំងនៃសេវាសន្តិសុខបានដែរឬយ៉ាងណា ហើយថាតើមានមូលដ្ឋាននីតិវិធី លក្ខខណ្ឌវិនិច្ឆ័យអ្វីខ្លះក្នុងការជ្រើសរើសតំណាងរាស្ត្រចុះត្រួតពិនិត្យ ហើយវាមានផលប៉ះពាល់អ្វីខ្លះ។
- ▷ ធានាថា មានលិខិតបទដ្ឋានគតិយុត្តដែលបញ្ជាក់៖
  - ទីតាំងនៃសេវាសន្តិសុខមួយណា ដែលអាចធ្វើការត្រួតពិនិត្យបាន។
  - មានកាលៈទេសៈ និងលក្ខខណ្ឌអ្វីខ្លះដែលអាចចុះត្រួតពិនិត្យបែបនោះបាន ឧ.ការចុះត្រួតពិនិត្យត្រូវបានគេរៀបចំគ្រប់ពេលដែលត្រូវចុះមែនឬយ៉ាងណា។
  - ការអនុវត្តជាក់ស្តែងនិងភាពញឹកញាប់នៃការចុះត្រួតពិនិត្យដោយសភានៅក្នុងអង្គភាពយោធា ឬមូលដ្ឋានយោធាជាតិ។
- ▷ ធានាថា របាយការណ៍លំអិតជាលាយលក្ខណ៍អក្សរ អំពីការចុះត្រួតពិនិត្យបែបនោះ ត្រូវបានដាក់ជូនសភា ឬគណៈកម្មការដែលពាក់ព័ន្ធនិងជាកម្មវត្ថុនៃការពិភាក្សាដេញដោល។
- ▷ ធ្វើការវាយតម្លៃ ផលប៉ះពាល់នៃការចុះត្រួតពិនិត្យដែលបានធ្វើរួចហើយទាំងនោះ។
- ▷ ពិនិត្យមើលថា តើរដ្ឋរបស់អ្នកបានផ្តល់សច្ចាប័ន លើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងពិធីសារបំពេញបន្ថែមរបស់វាដែរឬយ៉ាងណា។

### សមាជិកនៃគណៈប្រតិភូសភាដែលចុះធ្វើការត្រួតពិនិត្យ

- ធានាថា គណៈប្រតិភូសភាមិនមានបក្សពួកដែលមានតំណាងសមាមាត្រត្រឹមត្រូវរវាងបក្សដែលមានសម្លេងភាគច្រើន និងបក្សប្រឆាំងនៅក្នុងសភា។
- ពិនិត្យមើលថា តើគណៈប្រតិភូដែលចុះត្រួតពិនិត្យមានតុល្យភាពយេនឌ័រដែរឬទេ។

### ការត្រៀមចុះត្រួតពិនិត្យ

- ដើម្បីបញ្ចៀសនូវលទ្ធផលផ្ទុយ ត្រូវធានាថាការចុះត្រួតពិនិត្យរបស់សភាមានការសម្របសម្រួលជាមួយក្រសួងការពារជាតិ។

### ការរាយការណ៍ទៅសភា

- ធានាថាមានរបាយការណ៍លំអិតមួយត្រូវបានដាក់ជូនសភា/ គណៈកម្មការមានសមត្ថកិច្ចរបស់សភា ហើយរបាយការណ៍នេះអាចធ្វើការពិភាក្សាដេញដោលបាន។
- ធានាថាអាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសន្តិសុខ អាចមានសិទ្ធិទទួលរបាយការណ៍ជាមុនដើម្បីពួកគេអាចផ្តល់នូវយោបល់ផ្សេងៗ។

### ផលប៉ះពាល់ និងការផ្សព្វផ្សាយជាសាធារណៈ

- ធានាថាលទ្ធផល និងអនុសាសន៍របស់គណៈប្រតិភូសភា រួមទាំងសេចក្តីសម្រេចពាក់ព័ន្ធរបស់សភាត្រូវបានយកទៅអនុវត្តធ្វើតាម ហើយត្រូវមានការសម្រេចលើការផ្សព្វផ្សាយនូវលទ្ធផល និងអនុសាសន៍ទាំងនេះជាសាធារណៈផង។

## ផ្នែកទី V

# ការត្រួតពិនិត្យសេវាសន្តិសុខជាក់ស្តែង៖
# កាលៈទេសៈ និងប្រតិបត្តិការពិសេស

## ជំពូកទី ១៨

# ស្ថានភាពនៃករណីលើកលែង (អញ្ញត្រកម្ម)

មានកាលៈទេសៈត្រូវលើកលែង ដូចជាករណីនៃសង្គ្រាមករណីនៃជម្លោះផ្ទៃក្នុង ឬស្ថានភាពអាសន្នផ្សេងទៀតដែលរដ្ឋមួយត្រូវអនុវត្តនូវអំណាច និង នីតិវិធីពិសេសដើម្បីដោះស្រាយនូវវិបត្តិនោះ។ ការឆ្លើយតបបែបនោះ គួរត្រូវបានអនុវត្តដោយមិនឲ្យប៉ះពាល់ដល់ប្រព័ន្ធតាមបែបប្រជាធិបតេយ្យរបស់រដ្ឋាភិបាលឡើយ។

សង្គ្រាម និងស្ថានភាពអាសន្នមួយចំនួនតម្រូវឲ្យមានការឆ្លើយតប ដោយយោធា ឬអាចមានការប្រកាសច្បាប់អាជ្ញាសឹក។ នៅក្នុងករណីទាំងនេះ យោធា និងវិស័យសន្តិសុខទាំងមូលនៅតែជាកម្មវត្ថុនៃគោលការណ៍ និងការធានាជាអន្តរជាតិ ដូចជាវិធាននៃច្បាប់ មនុស្សធម៌អន្តរជាតិ ហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ។ សិទ្ធិមនុស្សក៏ត្រូវលើកស្ទួយឲ្យខ្ពស់តាមដែលអាចធ្វើបាន។ ការអនុវត្តទាំងឡាយណាដែលចាត់ទុកថាវាប្រាសចាកពីច្បាប់ និងគោលការណ៍កំណត់ គេមិនត្រូវអនុវត្តនោះទេ ដូចដែលមានបញ្ជាក់យ៉ាងច្បាស់ដោយគណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិនៅក្នុងយោបល់ទូទៅរបស់ខ្លួនលេខ ២៩ ខែសីហា ឆ្នាំ២០០១ លើមាត្រា៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

## ស្ថានភាពសង្គ្រាម

មាត្រា ២.៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ចែងថាៈ

*"នៅក្នុងទំនាក់ទំនងអន្តរជាតិ របស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ សមាជិកទាំងអស់ត្រូវចៀសវាងការគម្រាមកំហែង ឬប្រើប្រាស់កម្លាំង (...)" ។*

ការប្រើប្រាស់កម្លាំងប្រឆាំងនឹងរដ្ឋមួយទៀត គឺត្រូវបានហាមឃាត់ដាច់ខាត។ តួនាទីមួយរបស់សភាគឺត្រូវត្រួតពិនិត្យមើលថាតើអង្គនីតិប្រតិបត្តិបានគោរពតាមបម្រាមអន្តរជាតិទាំងនេះស្តីពីការប្រើប្រាស់ និងការគម្រាមកំហែងសង្គ្រាម និងមិនធ្វើហួសព្រំដែនអំណាចរបស់ពួកគេនៅក្នុងអំឡុងពេលមានជម្លោះ។ ប្រទេសអព្យាក្រិត ដូចជាប្រទេសស្វីសបានបដិសេធយ៉ាងដាច់ខាតមិនប្រើប្រាស់សង្គ្រាម ជាមធ្យោបាយនៃការដោះស្រាយជម្លោះ នៅក្នុងទំនាក់ទំនងការបរទេសរបស់ខ្លួនឡើយ។ យ៉ាងហោចណាស់ ក៏មានប្រទេសមួយគឺប្រទេសជប៉ុនដែលរដ្ឋធម្មនុញ្ញរបស់គេ (ឆ្នាំ១៩៤៦) បានហាមឃាត់យ៉ាងច្បាស់មិនឲ្យមានការរក្សាកងទ័ព។ ប្រទេសដទៃ ដូចជាប្រទេសហុងគ្រី

បានបដិសេធមិនប្រើប្រាស់សង្គ្រាម ជាមធ្យោបាយនៃការដោះស្រាយជម្លោះរវាងប្រជាជាតិ និងប្រជាជាតិឡើយ។

ក្នុងពេលសង្គ្រាម វាអាស្រ័យលើបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញសភាអាចចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តយ៉ាងហោចណាស់៣របៀបខុសៗគ្នាដែរ (ពិពណ៌នាពីកម្រិតខ្លាំងទៅខ្សោយ)៖

**(១) រដ្ឋធម្មនុញ្ញ អាចអនុញ្ញាតឲ្យសភាខ្លួនឯងធ្វើការប្រកាសអោយមានសង្គ្រាម និងសន្តិភាព។** ជាការអនុវត្តសព្វថ្ងៃលក្ខខណ្ឌនេះវាទំនងមានទម្រង់ជាសម្មតិកម្ម (hypothetical) ដោយហេតុថាសង្គ្រាមជាញឹកញាប់ចាប់ផ្តើមដោយមិនមានការព្រមាន ហើយស្ថានការណ៍ជាក់ស្តែង វាអាចជំរុញ (pre-empt) អោយសភាឈានទៅធ្វើសេចក្តីសម្រេចនេះ។

**(២) រដ្ឋធម្មនុញ្ញ អាចតម្រូវឲ្យអង្គនីតិប្រតិបត្តិទទួលយកសិទ្ធិអំណាចជាក់លាក់ពីសភាជាមុន មុនខ្លួនចាប់ផ្តើមធ្វើសង្គ្រាម ឬបង្កើតសន្តិភាព។** បទបញ្ញត្តិបែបនេះ នឹងអនុញ្ញាតឲ្យសភាធ្វើការពិភាក្សាដេញដោលលើបញ្ហាមុនការធ្វើសង្គ្រាម និងមុនការធ្វើអន្តរាគមន៍យោធាណាមួយនៅឯបរទេស។

**(៣) រដ្ឋធម្មនុញ្ញអាចតម្រូវឲ្យអង្គនីតិប្រតិបត្តិជូនដំណឹងទៅសភា។** អំពីការធ្វើសង្គ្រាមដោយមិនចាំបាច់ឲ្យអង្គការនីតិប្រតិបត្តិទទួលបាននូវការព្រមព្រៀងជាមុនពីសភាឡើយ។ រដ្ឋធម្មនុញ្ញភាគច្រើនតម្រូវឲ្យមានការជូនដំណឹងទៅសភា។

## ស្ថានភាពក្នុងគ្រាអាសន្ន

ស្ថានភាពក្នុងគ្រាអាសន្ន ឬស្ថានភាពនៃវិបត្តិជាតិ អាចកើតមានក្នុងស្ថានភាពផ្សេងៗ។ រដ្ឋធម្មនុញ្ញ និងច្បាប់ជាតិប្រមើលឃើញនូវស្ថានភាពមួយចំនួន នៅពេលមានការប្រកាសភាពអាសន្ន ក្នុងនោះមានដូចជា សកម្មភាពប្រដាប់អាវុធដែលគម្រាមកំហែងដល់សណ្តាប់ធ្នាប់រដ្ឋធម្មនុញ្ញ ឬសណ្តាប់ធ្នាប់សាធារណៈរហូតដល់គ្រោះមហន្តរាយធម្មជាតិ ជម្ងឺរាតត្បាត ឬ វិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចជាតិជាដើម។

ការប្រកាស់ដាក់ប្រទេសក្នុងស្ថានភាពអាសន្ន អាចធ្វើទៅបាននៅក្នុងករណីលើកលែង និងគួរតែអនុលោមតាមគោលការណ៍សំខាន់ៗខ្លះ ដើម្បីឲ្យគោលការណ៍ប្រជាធិបតេយ្យមិនត្រូវបានគេរំលោភ៖ សូមអានប្រអប់ទី៤១។ និយមន័យនៃកាលៈទេសៈលើកលែងវាអាស្រ័យលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនីមួយៗ។ រដ្ឋធម្មនុញ្ញ និងច្បាប់គួរទប់ស្កាត់អង្គនីតិប្រតិបត្តិមិនឲ្យប្រកាសដាក់ប្រទេសក្នុងស្ថានភាពអាសន្នដោយសារតែចេតនានយោបាយរបស់គណបក្សឡើយ។ លើសពីនេះ រដ្ឋធម្មនុញ្ញ និងច្បាប់ដែលពាក់ព័ន្ធគួរចែងថា ការធ្វើរដ្ឋប្រហារដោយយោធា គឺជាការរំលោភរដ្ឋធម្មនុញ្ញ។

**ប្រអប់ទី ៤១**

## ស្ថានភាពក្នុងគ្រាអាសន្នៈ គោលបំណង និងគោលការណ៍

"រាល់ប្រព័ន្ធច្បាប់ទាំងអស់ ចែងអំពីវិធានការពិសេសដើម្បីដោះស្រាយស្ថានភាពអាសន្ន។ ទោះដូច្នេះក្តី ការប្រព្រឹត្តខុស ឬការព្យួរសិទ្ធិណាមួយ ដែលចាំបាច់ក្នុងការដោះស្រាយវិបត្តិអាចមានលក្ខណៈជាបណ្តោះអាសន្នតែប៉ុណ្ណោះ និងអាចមានគោលបំណងត្រឹមស្តារស្ថានភាពឲ្យមករកប្រក្រតីភាព និងរក្សាការពារសិទ្ធិជាមូលដ្ឋានបំផុតតែប៉ុណ្ណោះ។ (...)

### គោលការណ៍អន្តរជាតិ

"គោលការណ៍អន្តរជាតិ ដែលបានបង្កើតឡើងទាក់ទងនឹងស្ថានភាពអាសន្ន អាចសង្ខេបដូចខាងក្រោម៖

**គោលការណ៍នីត្យានុកូលភាព (state of legality)** ដែលពាក់ព័ន្ធម្យ៉ាងជាមួយកិច្ចព្រមព្រៀងដែលមានរវាងការប្រកាសភាពអាសន្ន និងវិធានការនៃភាពអាសន្នដែលបានដាក់ចេញ និងម្យ៉ាងរវាងការប្រកាសភាពអាសន្ន និងច្បាប់ផ្ទៃក្នុងរបស់ប្រទេស។ គោលការណ៍នេះចង់ធានាបន្ថែមទៀតថាច្បាប់ផ្ទៃក្នុងត្រូវស្របជាមួយច្បាប់អន្តរជាតិ។

**គោលការណ៍នៃការប្រកាស (state of proclamation)** ដែលសំដៅលើតម្រូវការនៃការប្រកាសភាពអាសន្នជាសាធារណៈ។

**គោលការណ៍នៃការធ្វើទំនាក់ទំនង (state of communication)** ដែលសំដៅលើកាតព្វកិច្ចដែលត្រូវជូនដំណឹងដល់រដ្ឋជាភាគីដទៃទៀត ដែលជាភាគីនៃសន្ធិសញ្ញាដែលពាក់ព័ន្ធ តាមរយៈអ្នកនាំពាក្យរបស់រដ្ឋជាភាគីនោះ ក៏ដូចជាតាមរយៈអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងអំឡុងពេលនៃការដាក់ប្រទេសស្ថិតក្នុងស្ថានភាពអាសន្ន។

**គោលការណ៍បណ្តោះអាសន្ន (state of temporality)** សំដៅលើលក្ខណៈលើកលែងនៃស្ថានភាពប្រកាសអាសន្ន និងរយៈពេលកំណត់នៃស្ថានភាពអាសន្ននោះ។

**គោលការណ៍នៃការគម្រាមកំហែងជាក់ស្តែង (state of exceptional threat)** ដែលតម្រូវឲ្យមានវិបត្តិជាក់ស្តែងពិតប្រាកដថ្មី ឬ យ៉ាងហោចណាស់បង្កគ្រោះថ្នាក់ខ្លាំងណាស់ចំពោះសហគមន៍។

**គោលការណ៍សមាមាត្រ** សំដៅលើតម្រូវការឲ្យមានទម្ងន់ នៃវិបត្តិដែលមានលក្ខណៈសមាមាត្រទៅនឹងវិធានការដែល ប្រកាន់យកដើម្បីទប់ទល់ជាមួយវិបត្តិនោះ។

**គោលការណ៍នៃភាពប៉ះពាល់មិនបាន (the principle of intangibility)**
ពាក់ព័ន្ធជាមួយសិទ្ធិជាមូលដ្ឋានដ៏ជាក់លាក់ដែលមិនអាចដកហូតបាន។

"វាសំខាន់ខ្លាំងណាស់ដែលសភា ដែលជាអ្នកការពារសិទ្ធិមនុស្សមិនគួរក្លាយជាជនរងគ្រោះដំបូងគេនៃការប្រកាសភាពអាសន្ននេះនោះទេ ទាំងតាមរយៈការរំលាយសភាទាំងការព្យួរ ទាំងការកាត់បន្ថយអំណាចសភាយ៉ាងច្រើន និងអំណាចរបស់សភាក្នុងការត្រួតពិនិត្យអង្គការនីតិប្រតិបត្តិ។ វាក៏សំខាន់ផងដែរសម្រាប់សភាក្នុងការមានសមត្ថភាពដើរតួនាទីរបស់ខ្លួន ជាអ្នកប្រកាសអាសន្ន និងជាអ្នកដកប្រកាសអាសន្ន។ (...)

**លក្ខណៈផ្លូវច្បាប់នៃការប្រកាសភាពអាសន្ន**
"(...) លក្ខណៈផ្លូវច្បាប់នៃការប្រកាសភាពអាសន្នគឺថា ជាសកម្មភាពទាំងឡាយដែលបង្កើតបានជាសេចក្ដីប្រកាសការផ្ដល់សច្ចាប័ន ។ល។ និងវិធានការដែលបានដាក់ចេញនៅពេលដែលមានការព្យួរ ឬការកំហិតសិទ្ធិខ្លះ ។ល។ ត្រូវតែស្ថិតនៅក្នុងរង្វង់ក្របខណ្ឌនៃគោលការណ៍ទាំងឡាយដែលគ្រប់គ្រងដោយនីតិរដ្ឋ ដូច្នេះវាជាកម្មវត្ថុនៃការគ្រប់គ្រង។ (...)

**ការបំពេញតួនាទីរបស់សភា**
"មានការទទួលស្គាល់ថា គោលការណ៍នៃឯកភាពផ្យភាព និងតុល្យភាពនៃអំណាចផ្សេងៗ នៅក្នុងរដ្ឋមួយ (...) គឺជាផ្នែកមួយ និងកញ្ចប់មួយនៃនីតិរដ្ឋ។ ដូច្នេះហើយបានជាប្រព័ន្ធផ្លូវច្បាប់ភាគច្រើនបំផុតនៅក្នុងពិភពលោកផ្ដល់សិទ្ធិអំណាចឲ្យសភា ចូលរួមយ៉ាងសកម្មនៅក្នុងការប្រកាសដាក់ ប្រទេសក្នុងស្ថានភាពអាសន្ន ឬនៅក្នុងការផ្ដល់សច្ចាប័នរបស់ខ្លួន នៅពេលដែលអង្គនីតិប្រតិបត្តិ បានសម្រេចលើការដាក់ប្រទេសក្នុងស្ថានភាពអាសន្ន។ គោលបំណងគឺត្រូវទប់ស្កាត់អង្គនីតិប្រតិ បត្តិពីការមានសមត្ថកិច្ចដាច់មុខ ចំពោះការដាក់ចេញនូវវិធានការដែលមានស្ថានទម្ងន់។ (...)

**ឋានានុក្រមនៃបទបញ្ញត្តិផ្លូវច្បាប់ទាក់ទងនឹងការប្រកាសភាពអាសន្ន**

"តាមបទពិសោធន៍បង្ហាញថា មានការចង់ឲ្យបទបញ្ញត្តិដែលគ្រប់គ្រង លើស្ថានភាពអាសន្ន មានឋានានុក្រមក្នុងវិធានរដ្ឋធម្មនុញ្ញ។ ច្បាប់ភាគច្រើនចែងយ៉ាងច្បាស់ត្រង់ចំណុចនេះ ទោះបីជាច្បាប់ផ្សេងទៀតចែងនៅក្នុងទម្រង់ប្រយោល ដោយសរសេរថា "គ្មានអាជ្ញាធរណាអាចអនុវត្តមុខងារ

ជាអង្គការនីតិបញ្ញត្តិ ដោយហេតុផលតែប្រទេសស្ថិតនៅក្នុងស្ថានភាពអាសន្ននោះទេ”។ (...)

*សម្រង់ពីរបាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិមនុស្ស និងករណីអញ្ញត្រកម្ម លោក L. Despouy, ដាក់ជូនវេទិកា IPU ស្ដីពីសភាអ្នកការពារសិទ្ធិមនុស្ស ទីក្រុងប៊ុយតាប៉ែស្ដ ឆ្នាំ១៩៩៣*

## ករណីលើកលែង (អញ្ញត្រកម្ម) ជាក់ស្ដែង និងយូរអង្វែង

ករណីលើកលែង (អញ្ញត្រកម្ម) មានរយៈពេលវែង ដែលត្រូវបានសភាពន្យារប់ឆ្នាំ ឬ រាប់ទសវត្សរ៍ អញ្ញត្រកម្មនេះ ក៏អាចនាំទៅរកស្ថានភាពមួយដែលគោលការណ៍នៃឧត្ដមភាពស៊ីវិលលើអង្គការវិស័យសន្តិសុខជួបហានិភ័យ និងនាំទៅរកស្ថានភាពដែលអង្គការទាំងនេះអាចមាននិទណ្ឌភាព ដែលធ្វើឲ្យប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ។ ហេតុការណ៍នេះ រុញច្រានសភាចូលទៅក្នុងស្ថានភាពទន់ខ្សោយ និងងាយរងគ្រោះ។ អញ្ញត្រកម្មជាក់ស្ដែង និងគ្មានអ្វីទប់បាន ដូចដែលបានកើតឡើងនៅក្នុងប្រទេសមួយចំនួន ពិតជាបង្កការគម្រាមកំហែងដោយចំពោះការត្រួតពិនិត្យរបស់សភាទៅលើវិស័យសន្តិសុខ។

### ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

**ច្បាប់ស្ដីពីករណីលើកលែង (អញ្ញត្រកម្ម)**

- ធានាថា ប្រភេទផ្សេងៗនៃអញ្ញត្រកម្មត្រូវបានកំណត់និយមន័យ ច្បាស់លាស់នៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់។
- ករណីអញ្ញត្រកម្មគួរតែអស់សុពលភាពក្នុងរយៈពេល ៣ ឬ ៦ខែ លើកលែងតែត្រូវបានពន្យាតាមរយៈការពិភាក្សាដេញដោល និងបោះឆ្នោតគាំទ្រការពន្យាដោយសភា។
- ជម្រុញឲ្យមានការគោរពគោលការណ៍អន្តរជាតិ ស្ដីពីនិត្យានុកូលភាព ការប្រកាសភាពអាសន្ន ការធ្វើទំនាក់ទំនងភាពបណ្ដោះអាសន្ន ការគម្រាមកំហែងដែលមានការលើកលែងសមាមាត្រភាព និងច្បាប់ទាក់ទងនឹងអញ្ញត្រកម្ម។
- ធានាថា ច្បាប់មនុស្សធម៌ ការធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សដែលនៅជាធរមានត្រូវបានគោរពក្នុងអំឡុងពេល នៃអញ្ញត្រកម្ម។
- ធានាថា សមត្ថកិច្ចពាក់ព័ន្ធរបស់អង្គការនីតិប្រតិបត្តិ និងសភា ទាក់ទងនឹងការប្រកាស និងការលើកអញ្ញត្រកម្មត្រូវបានកំណត់និយមន័យយ៉ាងច្បាស់ និងពេញលេញនៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់។

**សភាក្នុងអំឡុងពេលនៃករណីលើកលែង (អញ្ញត្រកម្ម)**

- ធានាថា ការមានអញ្ញត្រកម្មពិតជាមិនបានរារាំងទាំងស្រុងនូវអំណាចរបស់សភា ក្នុងការត្រួតពិនិត្យសកម្មភាពរបស់អង្គការនីតិប្រតិបត្តិពាក់ព័ន្ធជាមួយ បញ្ហាសន្តិសុខ និងការគោរពសិទ្ធិមនុស្សដែលមិនអាចលក់ ឬបញ្ចាំបាន។

# ជំពូកទី ១៩

# ការរក្សាសន្តិសុខផ្ទៃក្នុង

សន្តិសុខផ្ទៃក្នុង (ឬសន្តិសុខសាធារណៈ) និងសណ្តាប់ធ្នាប់សាធារណៈ គឺជាប្រយោជន៍សាធារណៈដ៏សំខាន់មួយ។ វាផ្តល់ផលប្រយោជន៍ដល់សាធារណជនទូទៅនៅលើទឹកដីជាតិដោយមិនមានការរើសអើងក្នុងនោះមានទាំងជនអន្តោប្រវេសន្តនិងជនបរទេសផងដែរ។ ពាក្យសន្តិសុខផ្ទៃក្នុងនិងសណ្តាប់ធ្នាប់សាធារណៈនេះ មិនគួរត្រូវបានគេបង្វែរទៅបម្រើគោលបំណងអនិមិត្តរបស់អ្នកដឹកនាំនយោបាយ ឬកងកម្លាំង ឬបម្រើដល់ផលប្រយោជន៍វិស័យសន្តិសុខខ្លួនឯងដែលបេសកកម្មរបស់វិស័យសន្តិសុខនេះ គឺជាឧបករណ៍ដាច់មុខសម្រាប់រក្សាការពារពួកគេនោះទេ។

## សន្និទានភាព (Rationale) និងផ្នែកសំខាន់ (Feature) នៃច្បាប់បែបនោះ

គ្រប់ប្រព័ន្ធផ្លូវច្បាប់ទាំងអស់មានច្បាប់ដែលគ្របដណ្តប់លើស្ថានភាពដែលមិនតម្រូវឲ្យមានអញ្ញត្រកម្មនៃការប្រកាសភាពអាសន្ន ក៏ប៉ុន្តែវាបង្កឲ្យមានការគម្រាមកំហែងជាក់ស្តែង ឬបង្កគ្រោះថ្នាក់ចំពោះសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ។

ច្បាប់ទាំងនោះដែលមានឥទ្ធិពលខុសៗគ្នាបានប្រគល់អំណាចពិសេសដល់អង្គនីតិប្រតិបត្តិ និងមានបទបញ្ញត្តិរិតត្បិត ឬព្យួរនូវសិទ្ធិខ្លះដោយមានគោលបំណងការពារសិទ្ធិជាមូលដ្ឋានដទៃផ្សេងទៀតដែលសំខាន់ជាង និងដែលអាចត្រូវបានរំលោភបំពាន នៅក្រោមកាលៈទេសៈខ្លះដែលកាលៈទេសៈទាំងនេះ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់ដោយច្បាប់ដែលពាក់ព័ន្ធ។

សិទ្ធិដែលត្រូវបានគេនិយមរិតត្បិត ឬព្យួរបំផុតមានដូចជា សិទ្ធិទទួលបានព័ត៌មានសិទ្ធិធ្វើបាតុកម្មជាសាធារណៈ សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជ្រកកោន។ ច្បាប់អន្តរជាតិបានហាមឃាត់យ៉ាងច្បាស់ នូវការព្យួរសិទ្ធិដែលមិនអាចលក់ ឬបញ្ចាំបាន ដូចជាសិទ្ធិមានជីវិត និងសិទ្ធិមិនទទួលរងការធ្វើទារុណ ឬទទួលរងនូវការដាក់ទណ្ឌកម្មលើរាងកាយ ឬការប្រព្រឹត្តដែលមានលក្ខណៈបន្ទាបបន្ថោកឬបែបអមនុស្សធម៌។ជាធម្មតាអ្នកដែលដាក់នៅក្រោមការត្រួតពិនិត្យពិសេសមានដូចជាជនចំណាកស្រុកអ្នកសារព័ត៌មានសកម្មជននយោបាយអ្នកការពារសិទ្ធិមនុស្ស អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន ក៏ដូចជា ជនជាតិភាគតិច និងក្រុមកាន់សាសនា។

## ហានិភ័យ (Risk) ពាក់ព័ន្ធផ្សេងៗដែលមិនអាចចៀសបាន

ហានិភ័យផ្សេងៗដែលមិនអាចចៀសបានចំពោះច្បាប់ស្តីពីការថែរក្សាសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈមានដូចជា៖

- ✓ និយមន័យអំពីលក្ខណៈនៃការគម្រាមកំហែង មានលក្ខណៈមិនច្បាស់លាស់ដែលបណ្តាលឲ្យមានការបកស្រាយស្របទៅតាមសេចក្តីត្រូវការរបស់អង្គការនីតិប្រតិបត្តិ។
- ✓ ច្បាប់ដែលផ្តល់ដល់អង្គនីតិប្រតិបត្តិនូវអង្គការវិស័យសន្តិសុខមួយចំនួន ដោយមានអំណាចជាប់លាប់ និង ច្រើនហួសហេតុដោយមិនមានការត្រួតពិនិត្យ និងថ្លឹងថ្លែងសមស្រប និងដោយមិនមានការដាក់ទោសរដ្ឋបាល និងតាមផ្លូវតុលាការដ៏សមស្រប។
- ✓ ពេលខ្លះការរក្សាការពារសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគេរំលោភបំពានដើម្បីការពារផលប្រយោជន៍ជាច់មុខរបស់វិស័យមួយ ឬវិស័យជាច្រើន ការពារថ្នាក់ដឹកនាំនយោបាយ ឬវិស័យសន្តិសុខខ្លួនឯង និង ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយមួយនៃការរិតត្បិតសិទ្ធិ និងធ្វើការត្រួតត្រាលើសាធារណជនទូទៅ។
- ✓ យោធូបនីយកម្មកងកម្លាំងនគរបាលដែលជាអ្នកការពារច្បាប់ជាតិ និងសណ្តាប់ធ្នាប់ វាធ្វើឲ្យមានការបែងចែកមិនដាច់ស្រេចរវាងកងកម្លាំងនគរបាល និងយោធាដែលជាអ្នកការពារសន្តិសុខខាងក្រៅ។ នេះគឺជាគ្រោះថ្នាក់ ជាពិសេសនៅពេលដែលកងកម្លាំងទាំងនោះទទួលបានការឧបត្ថម្ភមូលនិធិតិចតួច ដូច្នេះពួកគេអាចរំលោភបំពាន អំណាចនៅក្នុងវិស័យសន្តិសុខ និងប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព (Impunity)។ គ្រោះថ្នាក់មួយទៀតនៃយោធូបនីយកម្មកងកម្លាំងនគរបាល គឺថាអ្នកដែលកាន់អំណាចអាចប្រើប្រាស់នគរបាល (និងពេលខ្លះក៏ប្រើប្រាស់ក្រុមស៊ើបការណ៍សម្ងាត់ និងកងកម្លាំងពាក់កណ្តាលយោធា) ជាឧបករណ៍មួយមិនត្រឹមការពារសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះនោះទេ តែថែមទាំងធ្វើការត្រួតត្រា និងគាបសង្កត់អ្នកប្រឆាំងថែមទៀតផង។ លើសពីនេះ ការប្រើប្រាស់ជាញឹកញាប់នូវកងកម្លាំងយោធា ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ អាចនាំទៅរកនយោបាយនូបនីយកម្មយោធា។
- ✓ ការហាមឃាត់សកម្មភាពរបស់សភា និងរបស់តុលាការ ជាពិសេសនៅពេលដែលទាំងសភា និងតុលាការ មិនមានអំណាចតវ៉ាជាមួយអាជ្ញាធរនៅក្នុងអង្គការនីតិប្រតិបត្តិ។

ដូច្នេះ វិធានការដែលប្រកាន់យកដើម្បីដោះស្រាយបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ អាចនាំទៅរកការរំលោភសិទ្ធិមនុស្សដោយសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ហើយនៅក្នុងបរិបទនិងបរិយាកាសខ្លះ សមាជិកទាំងនោះថែមទាំងបានទទួលអត្ថប្រយោជន៍ពី និទណ្ឌភាពថែមទៀតផង តាមរយៈការអនុវត្តនូវវិធានការទាំងនោះ។ សិទ្ធិដូចខាងក្រោម ជាញឹកញាប់ត្រូវបានរំលោភនៅក្នុងបរិបទទាំងនោះ៖ សិទ្ធិមានជីវិត សិទ្ធិមិនទទួលរងការធ្វើទារុណកម្ម ការប្រព្រឹត្តបែប

អមនុស្សធម៌ ឬមានលក្ខណៈបន្ទាបបន្ថោក សិទ្ធិរួចចាកផុតពីការចាប់ខ្លួនតាមទំនើងចិត្ត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយសាលាក្តីឯករាជ្យមួយ ដែលបង្កើតដោយច្បាប់សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រមូលផ្តុំ។

**ប្រអប់ទី ៤២**

***ការថែរក្សាទាំងសន្តិសុខ និងលទ្ធិប្រជាធិបតេយ្យ***

យោងតាមប្រវត្តិសាស្ត្រ និងតាមបទពិសោធន៍នៅក្នុងប្រទេសកំពុង អភិវឌ្ឍន៍ជាច្រើនបច្ចុប្បន្ននេះរដ្ឋាភិបាលផ្តាច់ការបានទប់ទល់ ឬ ផ្លាស់ប្តូរយុទ្ធសាស្ត្រឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ដោយយកលេសថា លទ្ធិប្រជាធិបតេយ្យមានវិសមិតភាពជាមួយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខបុគ្គល។ ក៏ប៉ុន្តែតាមឯកសារនានាបញ្ជាក់ថាធាតុពិត វាផ្ទុយទៅវិញនោះទេ៖ ការត្រួតពិនិត្យដោយស៊ីវិលតាមបែបប្រជាធិបតេយ្យ (democratic civil control) ទៅលើកងកម្លាំងសន្តិសុខរបស់រដ្ឋក្រៅពីមិនប្រឆាំងនឹងសន្តិសុខបុគ្គល វាថែមទាំងផ្តល់អត្ថប្រយោជន៍ដល់កងកម្លាំងសន្តិសុខទៅវិញ។ ប្រសិនបើគ្មានការត្រួតពិនិត្យតាមដានបែបនេះទេនោះ អ្នកដែលមានតួនាទីធានាសន្តិសុខបុគ្គលអាចក្លាយជាអ្នកគម្រាមកំហែងធំបំផុត។ (...)

*ប្រភព៖ របាយការណ៍អភិវឌ្ឍន៍មនុស្សរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០០២ (ទំព័រទី ៨៧)*

នៅក្នុងប្រទេសខ្លះ ច្បាប់ស្តីពីការការពារលទ្ធិប្រជាធិបតេយ្យត្រូវបានអនុម័ត។ ឧទាហរណ៍នៅក្នុងប្រទេសអាហ្សង់ទីន ច្បាប់លេខ២៣.០៧៧ ឆ្នាំ១៩៨៤ស្តីពី"ការការពារលទ្ធិប្រជាធិបតេយ្យ" បានកែសម្រួលលើក្រមព្រហ្មទណ្ឌ និងបង្កើតនូវបទល្មើសព្រហ្មទណ្ឌមួយចំនួនដែលប្រឆាំងនឹងប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ ខ. ការដាក់ទោសដល់សមាគមខុសច្បាប់ដែលមានគោលបំណងបង្កគ្រោះថ្នាក់ដល់លទ្ធិប្រជាធិបតេយ្យ និង ការគោរពរដ្ឋធម្មនុញ្ញ។

## ការឃុំខ្លួនបុគ្គល ដោយហេតុផលនៃការគម្រាមកំហែងដល់សន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ

ច្បាប់ទាំងអស់ ស្តីពីការថែរក្សាសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ ចែងអំពីការឃុំខ្លួនបុគ្គលដែលសង្ស័យពីការគម្រាមកំហែងដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនោះ។ ក្នុងន័យនេះ យ៉ាងហោចណាស់មានច្បាប់ ២ ប្រភេទ៖

- ✓ ច្បាប់ចែងអំពីការឃុំខ្លួនបុគ្គលដែលបង្កការគម្រាមកំហែងជាក់ស្តែងដល់សន្តិសុខជាតិ៖ ការឃុំខ្លួននោះជាធម្មតាត្រូវបានបង្គាប់ដោយតុលាការ តែក្នុងករណីពិសេសការឃុំខ្លួននេះអាចបង្គាប់ដោយអង្គការនីតិប្រតិបត្តិតែឯកឯងក៏បានដែរ។

- ✓ ច្បាប់ចែងពីការឃុំខ្លួនបុគ្គលណាម្នាក់ ដែលអង្គការនីតិប្រតិបត្តិយល់ឃើញថា អាចបង្កការគម្រាមកំហែងដល់សន្តិសុខជាតិ ឧ.ច្បាប់ផ្តល់សិទ្ធិអំណាចពិសេសដល់អង្គការនីតិប្រតិបត្តិផ្អែកតាមការវិនិច្ឆ័យរបស់ពួកគេដើម្បីធ្វើការគ្រប់គ្រង ឬ ទប់ស្កាត់ស្ថានការណ៍ ដែលទំនងបង្កគ្រោះថ្នាក់ដល់សន្តិសុខជាតិ។

ប្រទេសភាគច្រើនដែលបង្កើតបានជាផ្នែកមួយនៃខមិនវែលរបស់ចក្រភពអង់គ្លេស (British Commonwealth) មានទម្រង់ច្បាប់ដូចប្រភេទនៃឧទាហរណ៍ទី២នៃច្បាប់ខាងលើ។ នៅក្រោមច្បាប់នោះ អង្គការនីតិប្រតិបត្តិជាធម្មតាត្រូវបានអនុញ្ញាតឲ្យអនុវត្តនូវសិទ្ធិអំណាចធំៗមួយចំនួន ដែលព្យួរបញ្ញត្តិមួយចំនួនស្តីពី ការធានាដោយរដ្ឋធម្មនុញ្ញដោយមិនបាច់មានការយល់ព្រមជាមុន ឬ មានការចូលរួមពីអង្គការនីតិបញ្ញត្តិ ឬ អង្គតុលាការ។ មានបញ្ហាគន្លឹះមួយទាក់ទងនឹងតួនាទីរបស់អង្គការនីតិប្រតិបត្តិ ក្នុងការបង្គាប់ឲ្យមានការឃុំខ្លួនបុគ្គល ដែលអាចបង្កការគម្រាមកំហែងដល់សន្តិសុខជាតិតាមបែបរដ្ឋបាល ឬ តាមការបង្គាប់ដោយរដ្ឋមន្ត្រី។ បុគ្គលទាំងនេះ ត្រូវបានឃុំខ្លួនដោយអង្គការនីតិប្រតិបត្តិក្នុងរយៈពេលដ៏វែង ឬខ្លី ឬមួយត្រូវពន្យាពេលបន្តទៀត ឬគ្មានកាលកំណត់។ ច្បាប់ខ្លះមិនមែនច្បាប់ទាំងអស់នោះទេ មានចែងអំពីការបង្កើតនូវស្ថាប័នសើរើរឿងក្តីមួយ ដែលមានតួនាទីបង្គាប់ឲ្យអង្គការនីតិប្រតិបត្តិធ្វើការដោះលែងអ្នកជាប់ឃុំ តាមរយៈការពិគ្រោះយោបល់ ឬមិនបាច់មានការពិគ្រោះយោបល់ក៏បាន។ សមាសភាពនៃស្ថាប័ននេះ អាចមានទំនាក់ទំនងជាមួយអង្គការនីតិប្រតិបត្តិក្នុងកម្រិតផ្សេងៗ។

នៅក្នុងប្រទេសជាច្រើន ច្បាប់បែបនោះ ជាទូទៅ មានមកតាំងពីសម័យអាណានិគមនិយម ហើយកំពុងត្រូវបានគេពិភាក្សាយ៉ាងទូលំទូលាយ និងមានការជំទាស់មកដល់សព្វថ្ងៃ ដោយហេតុថា ច្បាប់នេះផ្តល់នូវសិទ្ធិអំណាចខុសគេខុសឯងដល់អង្គនីតិប្រតិបត្តិ និងអង្គការវិស័យសន្តិសុខ ជាពិសេសគឺនគរបាលហើយវាមានផលប៉ះពាល់អវិជ្ជមានមកលើសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

**ប្រអប់ទី ៤៣**

### ការភ័ន្តច្រលំដែលនាំឲ្យប៉ះពាល់ដោយមានផលវិបាកធ្ងន់ធ្ងរ

នៅពេលដែលរដ្ឋាភិបាលពឹងផ្អែកលើវិស័យសន្តិសុខ ដើម្បីរក្សាមូលដ្ឋាននៃអំណាចរបស់ខ្លួន កងកម្លាំងសន្តិសុខជាញឹកញាប់គឺជា បុព្វហេតុនៃអសន្តិសុខចំពោះប្រជាពលរដ្ឋ និងរដ្ឋជិតខាងរបស់ពួកគេ។ (...) នៅពេលដែលកងកម្លាំងរបស់ក្រសួងមហាផ្ទៃកងរាជអាវុធហត្ថ និងសេវាចារកម្ម ត្រូវបានអូសទាញឲ្យចូលរួមនៅក្នុងការតស៊ូនយោបាយការខិតខំប្រឹងប្រែងដើម្បីកែលំអការត្រួតពិនិត្យដោយស៊ីវិលតាមបែបប្រជាធិបតេយ្យ ជាញឹកញាប់ត្រូវបានគេធ្វើឲ្យចុះខ្សោយ។

*របាយការណ៍អភិវឌ្ឍន៍មនុស្សអង្គការសហប្រជាជាតិ ឆ្នាំ ២០០២ (ទំព័រទី ៨៧ និង ៩២)*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### តាក់តែងច្បាប់ដើម្បីថែរក្សាការពារសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ

- ត្រូវចងចាំថាការរក្សាការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈគឺដើម្បីប្រជាពលរដ្ឋ និងមិនមែនសម្រាប់ប្រើប្រាស់ ជាឧបករណ៍សម្រាប់ធ្វើការគាបសង្កត់លើប្រជាពលរដ្ឋនោះទេ ឬក៏សម្រាប់បម្រើឲ្យគោលបំណងរបស់គណបក្សនយោបាយនោះដែរ។ ត្រូវធានាឲ្យមានការបញ្ចៀសនូវការប្រើប្រាស់ និងការធ្វើយោធានូបនីយកម្មនគរបាលច្រើនហួសហេតុ ដើម្បីធ្វើការគាបសង្កត់លើប្រជាពលរដ្ឋ។
- ត្រូវធ្វើឲ្យអង្គការនីតិប្រតិបត្តិមានគណនេយ្យភាពចំពោះសភា និងផ្តល់អំណាចតាមផ្លូវច្បាប់ដ៏ច្បាស់លាស់ក្នុងចំនួនកំហិតមួយ។
- ត្រូវកំណត់នៅក្នុងច្បាប់ថា វិស័យសន្តិសុខនឹងទទួលរងនូវការដាក់ទោសរដ្ឋបាល និងតាមផ្លូវតុលាការបើចាំបាច់ក្នុងករណីដែលមានការប្រើប្រាស់នូវអំណាច ឬកងកម្លាំងណាមួយច្រើនហួសហេតុ។
- ធ្វើការវិភាគពីភាពអនុវត្តបាន និងភាពសមហេតុសមផលនៃច្បាប់ការពារលទ្ធិប្រជាធិបតេយ្យ។

### ការត្រួតពិនិត្យដោយសភា

- ត្រូវធានាថា សភាត្រូវធ្វើការពិភាក្សាដេញដោល ជាទៀងទាត់នូវបញ្ហាទាក់ទងនឹងសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងពិនិត្យមើលនូវភាពពាក់ព័ន្ធនៃច្បាប់ដែលនៅជាធរមាន ដែលមានការពាក់ព័ន្ធជាមួយវិស័យនេះ។
- ត្រូវធានាថា គណៈកម្មការមានសមត្ថកិច្ចរបស់សភាបានប្រើប្រាស់នូវគ្រប់មធ្យោបាយ និងធនធានទាំងអស់ដែលខ្លួនមាន ដើម្បីទទួលបាននូវព័ត៌មានដ៏សមស្រប និងធ្វើការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព តាមដែលអាចធ្វើទៅបានទាក់ទងនឹងបញ្ហាសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ។ ប្រសិនបើចាំបាច់ត្រូវពង្រឹងនូវមធ្យោបាយ និងធនធានព្រមទាំងជំនាញសម្រាប់គណៈកម្មការដែលពាក់ព័ន្ធ។
- បើអាចធ្វើបាន និងប្រសិនបើចាំបាច់ ត្រូវលើកទឹកចិត្តឲ្យមានសវនការសាធារណៈទាក់ទងនឹងបញ្ហាទាំងនេះ។
- បង្កើតឲ្យមានកិច្ចសន្ទនា ជាលក្ខណៈស្ថាប័ន ឬឯកជនជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធជាមួយបញ្ហាសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ រួមទាំងផលប៉ះពាល់នៃវិធានការដែលប្រកាន់យកដែលបានប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពជាសារវន្តរបស់ប្រជាពលរដ្ឋ។

## ជំពូកទី ២០

# អំពើភេរវកម្ម

*"អំពើភេរវកម្ម គឺជាការគម្រាមកំហែងមួយប្រឆាំងនឹងរដ្ឋ ដែលរដ្ឋចាំបាច់ត្រូវការពារប្រជាពលរដ្ឋរបស់ខ្លួន។ រដ្ឋមិនត្រឹមមានសិទ្ធិប៉ុណ្ណោះនោះទេ តែក៏មានកាតព្វកិច្ច ក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។ ក៏ប៉ុន្តែរដ្ឋក៏ត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធានាថា វិធានការប្រឆាំងភេរវកម្ម មិនត្រូវប្រែទៅជាវិធានការបិទបាំង ឬ រំលោភសិទ្ធិមនុស្សនោះទេ"។*

*"នៅក្នុងប្រទេសមួយ គ្រោះថ្នាក់តែងកើតឡើងដោយសារគេយកលេសថា ចាត់វិធានការដើម្បីរក្សាសន្តិសុខ តែធ្វើបែបនេះធ្វើឲ្យយើងលះបង់នូវសិទ្ធិសេរីភាពសំខាន់ៗ ជាលទ្ធផលវាមិនត្រឹមតែមិនពង្រឹងសន្តិសុខរបស់យើង វាថែមទាំងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរួមរបស់យើងថែមទៀត ហេតុដូច្នេះហើយវានឹងធ្វើឲ្យវិនាសនូវរដ្ឋាភិបាលប្រជាធិបតេយ្យមួយ"។*

*កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០១*

អំពើភេរវកម្មគឺជាការគម្រាមកំហែងដ៏ធំបំផុតមួយដល់សន្តិសុខ ក្នុងប្រទេសសន្តិសុខក្នុងតំបន់ និងអន្តរជាតិ។ ការឆ្លើយតបចំពោះ អំពើភេរវកម្ម មានលក្ខណៈស្មុគ្រស្មាញ ជាពិសេសនៅពេលដែល អំពើភេរវកម្មមានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។ ការឆ្លើយតបនោះ អាចមានការឆ្លើយតបចាប់ពីកងកម្លាំងនគរបាល និងតម្រួតព្រំដែនរហូតដល់ក្រុមចារកម្ម ហើយវិធានការ មានទាំងវិធានការក្នុងវិស័យហិរញ្ញវត្ថុរហូតដល់វិធានការក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ និងព័ត៌មានវិទ្យា។

ចាប់តាំងពីថ្ងៃទី១១ ខែកញ្ញាមក រដ្ឋជាច្រើនបានមើលឃើញពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការពង្រឹងឡើងវិញនូវច្បាប់របស់ខ្លួនពាក់ព័ន្ធនឹងបញ្ហាខាងលើ។ លើសពីនេះ សហប្រតិបត្តិការអន្តររដ្ឋ ក៏ត្រូវបានពង្រឹងផងដែរ ជាពិសេសពាក់ព័ន្ធជាមួយការចែករំលែកនូវព័ត៌មានចារកម្ម និងព័ត៌មានវិទ្យា។ វិធានការទាំងអស់នេះពិតណាស់ វាមិនមែនមិនប៉ះពាល់ដល់សិទ្ធិមនុស្ស និងសិទ្ធិសេរីភាព នៃជនស៊ីវិលទាល់តែសោះនោះដែរ។

ទាក់ទងនឹងសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាភេរវកម្មមានសេចក្តីសម្រេច

ចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិលេខ ១៣៧៣ (ដែលបានអនុម័តថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០១ សូមអានប្រអប់ទី៤៩) បានសង្កត់ធ្ងន់ជាពិសេសលើបញ្ហានៃការគ្រប់គ្រងលើទ្រព្យសម្បត្តិផ្នែកហិរញ្ញវត្ថុរបស់ភេរវករ។ សេចក្តីសម្រេចលេខ ១៣៧៣ ក៏ផ្តល់សារៈសំខាន់ដល់ការត្រួតពិនិត្យព្រំដែន និងការត្រួតពិនិត្យអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន និងឯកសារធ្វើដំណើរ ដើម្បីធ្វើការទប់ស្កាត់នូវចលនាខាងក្នុង និងឆ្លងដែនរបស់ភេរវករ ឬក្រុមភេរវករ។ សេចក្តីសម្រេចនេះ ក៏មានអនុសាសន៍ស្តីពីរបៀបបង្ក្រាបការជ្រើសរើសសមាជិកនៃក្រុមភេរវករ និងការផ្គត់ផ្គង់អាវុធយុទ្ធភ័ណ្ឌធម្មតាដល់ពួកភេរវករហើយ អនុសាសន៍នេះ ក៏បានលើកឡើងនូវរបៀបពង្រឹងវិធានការទប់ស្កាត់តាមរយៈសហប្រតិបត្តិការអន្តររដ្ឋផងដែរ។ អនុសាសន៍ជម្រុញឲ្យមានការបញ្ជូនអ្នកទាំងឡាយណាដែលចូលរួមនៅក្នុងការផ្តល់ហិរញ្ញវត្ថុ ធ្វើផែនការរៀបចំ ឬប្រព្រឹត្តអំពើភេរវកម្ម ឬគាំទ្រសកម្មភាពភេរវកម្មមកកាន់តុលាការ។ សេចក្តីសម្រេចក៏បានជម្រុញឲ្យមានការចែងនៅក្នុងច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ថាសកម្មភាពភេរវកម្មខាងលើនោះ គឺជាបទល្មើសព្រហ្មទណ្ឌ និងត្រូវទទួលការផ្តន្ទាទោសធ្ងន់ធ្ងរ។ សេចក្តីសម្រេចក៏បានអំពាវនាវឲ្យមានការផ្លាស់ប្តូរនូវព័ត៌មាន អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និងអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការផ្នែករដ្ឋបាល និងតុលាការ ដើម្បីទប់ស្កាត់ការប្រព្រឹត្តសកម្មភាពភេរវកម្ម។ សេចក្តីសម្រេច ក៏បានបង្កើតនូវគណៈកម្មការក្រុមប្រឹក្សាសន្តិសុខមួយផងដែរ ដែលមានរាល់សមាជិកទាំងអស់នៃក្រុមប្រឹក្សាសន្តិសុខ ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនេះ ដោយមានជំនួយពីអ្នកជំនាញដ៏សមស្រប។

**ប្រអប់ទី ៤៤**

## ការឆ្លើយតបរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចំពោះព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា

ក្រុមប្រឹក្សាសន្តិសុខ (...)

**៣.** អំពាវនាវដល់រដ្ឋទាំងអស់៖

- **ក.** រិះរកវិធីសាស្ត្រពង្រីក និងពន្លឿននូវការផ្លាស់ប្តូរព័ត៌មាន ប្រតិបត្តិការ ជាពិសេស ព័ត៌មានពាក់ព័ន្ធជាមួយសកម្មភាព ឬចលនារបស់ពួកភេរវករ ឬបណ្តាញភេរវករ ព័ត៌មានអំពីការក្លែងឯកសារធ្វើដំណើរ ចរាចរណ៍អាវុធ គ្រឿងផ្ទុះ និងអាវុធគីមី និងជីវសាស្ត្រ ការប្រើប្រាស់បច្ចេកវិទ្យាធ្វើទំនាក់ទំនងដោយក្រុមភេរវករ និងការគម្រាមកំហែងពីអាវុធមហាប្រល័យដោយក្រុមភេរវករ។
- **ខ.** ផ្លាស់ប្តូរព័ត៌មាន ដោយអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ និងធ្វើសហប្រតិបត្តិការលើផ្នែករដ្ឋបាល និងតុលាការដើម្បីទប់ស្កាត់ការប្រព្រឹត្តសកម្មភាពភេរវកម្ម។
- **គ.** ធ្វើសហប្រតិបត្តិការ ជាពិសេសតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់និងបង្ក្រាបការវាយប្រហាររបស់ភេរវករ និងចាត់វិធានការប្រឆាំងក្រុមភេរវករ។

**ឃ.** ចូលជាភាគីនៃអនុសញ្ញា និងពិធីសារអន្តរជាតិដែលពាក់ព័ន្ធឲ្យបានឆាប់តាមដែលអាចធ្វើបាន ទាក់ទងនឹងអំពើភេរវកម្ម រួមទាំងអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការផ្តល់ហិរញ្ញវត្ថុ ដល់អំពើភេរវកម្ម ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៩។

**ង.** បង្កើនសហប្រតិបត្តិការ និងអនុវត្តពេញលេញនូវអនុសញ្ញា និងពិធីសារអន្តរជាតិដែលពាក់ព័ន្ធអំពើភេរវកម្ម និងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១២៦៩ (១៩៩៩) និងលេខ ១៣៦៨ (២០០១)។

**ច.** ចាត់វិធានការសមស្របៗតាមបទប្បញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិ ក្នុងនោះមានបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស មុនផ្តល់ស្ថានភាពជាជនភៀសខ្លួន ដើម្បីធានាថាអ្នកសុំសិទ្ធិជ្រកកោន ពិតជាមិនបានរៀបចំផែនការសម្របសម្រួល ឬចូលរួមនៅក្នុងការប្រព្រឹត្តអំពើភេរវកម្ម។

**ឆ.** ដោយអនុលោមតាមច្បាប់អន្តរជាតិ ធានាថាស្ថានភាពជាជនភៀសខ្លួនមិនត្រូវបានរំលោភបំពានដោយជនល្មើស អ្នករៀបចំ ឬអ្នកសម្របសម្រួលសកម្មភាពភេរវកម្ម និងធានាមិនឲ្យមានការទទួលស្គាល់ចេតនានយោបាយ ជាហេតុផលដើម្បីបដិសេធសំណើសុំធ្វើបត្យាប័នភេរវករ ដែលទទួលរងការចោទប្រកាន់ (...)។

ប្រភព៖ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ១៣៧៣, S/RES/ ១៣៧៣, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១ http://www.un.org/Docs/scres/2001/sc2001.htm

*អនុសញ្ញាអន្តរជាតិ ស្តីពីការបង្ក្រាបការផ្តល់ហិរញ្ញវត្ថុដល់អំពើ ភេរវកម្ម* ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៩តម្រូវឲ្យរដ្ឋចុះកិច្ចសន្យាទាំងអស់ធ្វើបត្យាប័ន (Extradition) បុគ្គលដែលជាប់ចោទពីការផ្តល់មូលនិធិដល់សកម្មភាពភេរវករ និងតម្រូវឲ្យដាក់ចេញនូវវិធានការនានា ដើម្បីធ្វើការស៊ើបអង្កេតប្រតិបត្តិការហិរញ្ញវត្ថុ ដែលសង្ស័យទាំងឡាយ។ មកដល់ថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ មានប្រទេសចំនួន ១៣២ប្រទេស បានចុះហត្ថលេខាលើអនុសញ្ញានេះ ហើយមានប្រទេសចំនួន ២៦ប្រទេស ផ្សេងទៀត បានបំពេញដំណើរការផ្តល់សច្ចាប័ន (Ratification) និងក្លាយជារដ្ឋភាគីនៃអនុសញ្ញា។ អនុសញ្ញានេះ បានចូលជាធរមានក្នុងឆ្នាំ២០០២។

## ផលប៉ះពាល់នៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា

សម្រាប់តំណាងរាស្ត្រ វាសំខាន់ខ្លាំងណាស់ក្នុងការពិនិត្យនូវការដាក់ចេញនូវវិធីសាស្ត្រដែលមានតុល្យភាពប្រឆាំងនឹងការវាយប្រហារដោយពួកភេរវករ ជាវិធីសាស្ត្រមួយដែលការពារទាំងសន្តិសុខ និងសិទ្ធិមនុស្ស។ តាមទស្សនៈរបស់តំណាងរាស្ត្រ បញ្ហាទាក់ទងនឹងអំពើភេរវកម្មត្រូវ

មានច្បាប់ចែងនូវវិធីសាស្ត្រថ្មីគ្រប់ជ្រុងជ្រោយមួយ ដែលកំណត់នូវវិធានការសន្តិសុខ និងប្រឆាំងអំពើភេរវកម្ម និងថ្លឹងថ្លែងរវាងសន្តិសុខ និងសិទ្ធិសេរីភាពដែលធានានូវការគោរពដ៏ពេញលេញចំពោះច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិដែលនៅជាធរមាន។

## ការកំណត់និយមន័យអំពើភេរវកម្មតាមផ្លូវច្បាប់

រហូតមកដល់ពេលនេះ មិនមានការកំណត់និយមន័យអំពីអំពើភេរវកម្មដែលបានព្រមព្រៀងជាអន្តរជាតិនោះទេទាល់តែសហគមន៍អន្តរជាតិ ឈានដល់ការព្រមព្រៀងគ្នាលើនិយមន័យរួមតែមួយ បើមិនដូច្នោះទេនិយមន័យនៃអំពើភេរវកម្មនឹងត្រូវបានគេបន្តឲ្យនិយមន័យ ទៅតាមអ្វីដែលមិនមែនជានិយមន័យដ៏ពិតប្រាកដរបស់វា។ យោងតាមនីតិសាស្ត្រអន្តរជាតិ ការតស៊ូរំដោះជាតិ និងដណ្ដើមឯករាជ្យពីការកាន់កាប់ដោយបរទេស គឺជាសិទ្ធិស្របច្បាប់ ដូច្នេះអំពើបែបនេះ មិនបង្កើតបានជាអំពើភេរវកម្មនោះទេ។ លើសពីនេះ សហគមន៍អន្តរជាតិរួមទាំង IPU ផងដែរ បានកំណត់ហើយកំណត់ទៀតថា អំពើភេរវកម្មមិនអាចសម្អាងយោងត្រឹមតែ សាសនា សញ្ជាតិ ឬអារិយធម៌ ឬគ្រាន់តែឈ្មោះរបស់វាតែប៉ុណ្ណោះនោះទេ។ មកដល់ពេលនេះ វិធីមួយទៀតនៃការកំណត់និយមន័យនៃអំពើភេរវកម្ម គឺគេគ្រាន់តែអាចរៀបរាប់ប្រភេទនៃការវាយប្រហារ ដែលគេនិយមហៅថា អំពើភេរវកម្ម ដែលសហគមន៍អន្តរជាតិបានធ្វើការថ្កោលទោសជាប្រចាំតែប៉ុណ្ណោះគឺ៖ ការវាយប្រហារដោយឃោរឃៅមិនរើសមុខ ជាពិសេស ការវាយប្រហារមកលើជនស៊ីវិលស្លូតត្រង់ ឬទម្រង់នៃអំពើហិង្សាដោយមិនរើសមុខ ដែលប្រព្រឹត្តដោយក្រុមតូចៗនៅក្នុងប្រទេស ឬ ភ្នាក់ងារលួចលាក់ផ្សេងទៀត។

ការវាយប្រហារដោយពួកភេរវករ មានលក្ខណៈជាអំពើហិង្សាមិនរើសមុខ ប្រឆាំងនឹងជនស៊ីវិលដោយមិនគិតពីមនុស្សធម៌និងចង់លេចមុខលេចមាត់ជាខ្លាំងជាសាធារណៈ។ វិធីសាស្ត្រជារួមដែលពួកគេនិយមប្រើប្រាស់ រួមមាន ការប្លន់យន្តហោះ ការដាក់គ្រាប់បែកក្នុងរថយន្ត ការដាក់គ្រាប់បែកអត្តឃាត ការធ្វើឃាត និងការសម្លាប់រង្គាល។ យុទ្ធនាការដ៏មាននិរន្តរភាពរបស់ពួកភេរវករតម្រូវឲ្យមានការគាំទ្រហិរញ្ញវត្ថុ ការផ្គត់ផ្គង់អាវុធ និងគ្រាប់រំសេវជាប្រចាំ និងការជួយគាំទ្រពីបណ្ដាញអង្គការអន្តរជាតិ។ ជាញឹកញាប់ប្រទេសទី ៣ តែងតែផ្ដល់ដល់ពួកភេរវករនូវជំនួយ និងទីកន្លែងលាក់ខ្លួន។ ប្រអប់ទី ៥៥ ខាងក្រោមពន្យល់នូវចំណុចសំខាន់ៗខ្លះនៃវិធីសាស្ត្រដែលមានតុល្យភាពចំពោះអំពើភេរវកម្ម ដោយគូសបញ្ជាក់ទាំងតម្រូវការសម្រាប់ការពារសិទ្ធិស្របច្បាប់ក្នុងការតវ៉ា ក៏ដូចជាតម្រូវការសម្រាប់ ប្រកាន់យកវិធានការប្រឆាំងនឹងអំពើភេរវកម្ម។ ចំណុចទី៣៧ នៅក្នុងប្រអប់ពន្យល់អំពីភាពចាំបាច់នៃវិធានការប្រឆាំងអំពើភេរវកម្ម ដែលមិនត្រឹមផ្ដោតលើការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មប៉ុណ្ណោះនោះទេ តែថែមទាំងផ្ដោតលើការអភិវឌ្ឍសង្គមនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសទាំងឡាយ ដែលអាចជាជម្រកភេរវករជំនាន់ថ្មីថែមទៀតផង។

**ប្រអប់ទី ៨៥**

## ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម

**៣៥.** (...) សន្និសីទរំលឹកថា ការតស៊ូសម្រាប់ការរំដោះជាតិ និងឯករាជ្យពីការកាន់កាប់ដោយបរទេស គឺជាសិទ្ធិស្របច្បាប់ដែលមានចែងនៅក្នុងសេចក្តីសម្រេចជាអន្តរជាតិ និងថាអំពើបែបនេះមិនបង្កើតបានជា អំពើភេរវកម្មនោះឡើយ។ ទោះដូច្នេះក៏ដោយ សន្និសីទបញ្ជាក់ថាគ្មានការតស៊ូណាមួយ អាចបង្កឲ្យមានការវាយប្រហារដោយមិនរើសមុខ ជាពិសេស ទៅលើជនស៊ីវិលស្លូតត្រង់ ឬទៅលើទម្រង់ណាមួយនៃអំពើភេរវកម្មដែលមានអង្គការចាត់តាំងដោយរដ្ឋ។
**៣៧.** សន្និសីទចង់សង្កត់ធ្ងន់ចំពោះ តម្រូវការដ៏សំខាន់ឲ្យមានវិធានការសន្តិសុខ ប្រឆាំងអំពើភេរវកម្ម ដែលគាំទ្រដោយវិធានការគ្រប់ជ្រុងជ្រោយ ដែលបង្កើតឡើងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និង ពង្រឹងរដ្ឋាភិបាលដែលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ។

ប្រភព៖ ឯកសារចុងក្រោយនៃសន្និសីទលើកទី៣ របស់ IPU ស្តីពីសន្តិសុខ និងសហប្រតិបត្តិការ នៅក្នុងសមុទ្រមេឌីទែរ៉ានេ Valetta, Malta ខែវិច្ឆិកា ឆ្នាំ១៩៩៥

ច្បាប់ប្រឆាំងអំពើភេរវកម្ម ដូចជាច្បាប់របស់ប្រទេសអូទ្រីស(សេចក្តីព្រាងកថាខណ្ឌ២៧៨ខ នៃក្រមព្រហ្មទណ្ឌ) ច្បាប់របស់ប្រទេសអាល្លឺម៉ង់ ១២៩ក នៃក្រមព្រហ្មទណ្ឌ និងច្បាប់របស់ប្រទេសកាណាដា (BillC-36) មានបញ្ចូលនូវទិដ្ឋភាពដូចខាងក្រោម៖

- បញ្ជីសកម្មភាពភេរវកម្មមួយចំនួន ឧ. ជាអំពើ ឬការគម្រាមកំហែង ដែលបង្កើតបានជាបទល្មើស ដូចជា ឃាតកម្ម ការចាប់ចំណាប់ខ្មាំង ការដណ្តើមយកដោយខុសច្បាប់នូវយន្តហោះ ការដាក់គ្រាប់បែកដោយភេរវករ ឬការផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពភេរវកម្ម។ ភាគច្រើននៃបញ្ជីបទល្មើសនោះ សំដៅលើអំពើខុសច្បាប់នៅក្នុងច្បាប់ជាធរមាន (ច្បាប់ប្រឆាំងអំពើភេរវកម្ម នៃប្រទេសអាល្លឺម៉ង់ អូទ្រីស និងកាណាដា)។
- ការដឹកនាំ ឬការគាំទ្រ (ហិរញ្ញវត្ថុ) ដល់សមាគមភេរវករ ក៏ជាអំពើខុសច្បាប់ដែរ (នៅក្នុងប្រទេសអាល្លឺម៉ង់ កាណាដា និងអូទ្រីស)។
- បុព្វហេតុនៃសកម្មភាពភេរវកម្មដែលមានលក្ខណៈជានយោបាយ មនោគមន៍វិជ្ជា ឬសាសនា (ប្រទេសកាណាដា)។
- ចេតនានៃសកម្មភាពភេរវកម្ម ដែលធ្វើការបំភិតបំភ័យ ឬ គម្រាមកំហែងសាធារណជនទូទៅ ឬបង្ខិតបង្ខំសាធារណជនទូទៅ ឬ រដ្ឋាភិបាលឲ្យប្រព្រឹត្តសកម្មភាពមួយចំនួន ឬ រារាំងពីការអនុវត្តនូវសកម្មភាពមួយចំនួន (ប្រទេសកាណាដា)។
- គោលដៅផ្ទាល់របស់សកម្មភាពភេរវកម្ម ដែលបង្កឲ្យមានការស្លាប់ឬរបួសដល់ប្រជាពលរដ្ឋតាមមធ្យោបាយដ៏ឃោរឃៅដែលធ្វើឲ្យជីវិតមនុស្សមានគ្រោះថ្នាក់ ដែលបណ្តាលឲ្យខូចខាត ឬរំខានដល់សេវា ឬ ប្រព័ន្ធសាធារណៈ ឬ ឯកជនសំខាន់ (ប្រទេសកាណាដា)។

- ការមិនរាប់បញ្ចូលនូវសកម្មភាពទាំងឡាយ ដែលបានអនុវត្តក្នុងគោលបំណងបង្កើត ឬបង្កើតឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ក៏ដូចជាការការពារច្បាប់មនុស្សធម៌ (ប្រទេសអូទ្រីស)។ បទប្បញ្ញត្តិច្បាប់បែបនេះ ហាមឃាត់ការតវ៉ាស្របច្បាប់ និងចាត់ទុកការតស៊ូជាបទល្មើស។

ពាក់ព័ន្ធនឹងទិដ្ឋភាពនៃច្បាប់ប្រឆាំងអំពើភេរវកម្មទាំងនេះជាគំនិតរួមគឺថា អំពើភេរវកម្មមានទំនាក់ទំនងជាមួយអំពើហិង្សា និងការបង្កការខូចខាតដល់បុគ្គល ឬស្ថាប័ន។ ក្រៅពីនេះច្បាប់មានចែងនូវបញ្ជីសកម្មភាពមួយចំនួនដែលបង្កើតបានជាអំពើភេរវកម្ម។ មិនត្រឹមតែការប្រព្រឹត្តអំពើភេរវកម្មអាចចាត់ទុកថាជាអំពើខុសច្បាប់ប៉ុណ្ណោះនោះទេ តែថែមទាំងគ្រាន់តែចូលរួមក្រុមភេរវករមួយ (ជាសមាជិកជាអ្នកគាំទ្រ ឬ ជាអ្នកដឹកនាំ) ក៏គេចាត់ទុកថាជាសកម្មភាពភេរវកម្មដែរ។

តាមទស្សនៈនៃការត្រួតពិនិត្យដោយសភា វាសំខាន់ខ្លាំងណាស់ក្នុងការធានាឲ្យមានការបកស្រាយដ៏សមស្របនូវពាក្យអំពើភេរវកម្ម នៅក្នុងច្បាប់ប្រឆាំងអំពើភេរវកម្មថ្មី។ម្យ៉ាងទៀត និយមន័យមិនត្រូវមានលក្ខណៈចង្អៀតពេកនោះទេ ពីព្រោះវាអាចមិនរាប់បញ្ចូលនូវអំពើ ដែលប្រព្រឹត្តដោយសមាគមភេរវករ។ ម្យ៉ាងនិយមន័យភេរវកម្ម ក៏មិនត្រូវទូលាយពេករហូតដល់វាគម្រាមកំហែងដល់ការដាក់ការតវ៉ាស្របច្បាប់ និងតាមបែបប្រជាធិបតេយ្យជាអំពើល្មើសនោះដែរ។ សំណួរដំបូងនៅទីនេះគឺថា តើអំពើហិង្សាក្នុងកម្រិតណាទើបចាត់ទុកថាជាអំពើភេរវកម្ម នៅក្នុងសង្គមប្រជាធិបតេយ្យមួយ? អ្នកធ្វើច្បាប់នៃប្រទេសផ្សេងៗបានឆ្លើយនឹងសំណួរនេះខុសៗគ្នា ដោយហេតុថាសង្គមនីមួយៗបានបង្កើតនូវនិយមន័យតាមផ្លូវច្បាប់ នៃអំពើហិង្សារៀងៗខ្លួន។ នៅពេលកំពុងពិចារណានូវសំណួរនេះ គេគួរតែចងចាំនូវគោលដៅនៃអំពើហិង្សា។ ប្រសិនបើតាមផ្លូវច្បាប់អំពើហិង្សាត្រូវបានគេចាត់ទុកថាជាអំពើភេរវកម្មមែននោះ ស្ថានទម្ងន់របស់វាត្រូវតែសមាមាត្រជាមួយគោលដៅរបស់វា។

សំណួរទី២ គឺថាវិធានការប្រឆាំងអំពើភេរវកម្មគួរសមាមាត្រ ក៏ដូចជាគួរមានទំនាក់ទំនងជាមួយការគម្រាមកំហែងរបស់ភេរវករខ្លួនឯង។ គេគួរចងចាំថាគោលបំណងរបស់ច្បាប់ប្រឆាំងអំពើភេរវកម្មគឺជួយនគរបាល និងសេវាសន្តិសុខដទៃទៀត ឲ្យចាត់វិធានការដ៏មានប្រសិទ្ធភាពប្រឆាំងនឹងអ្នកដែលមានការពាក់ព័ន្ធជាមួយសកម្មភាពភេរវកម្ម។ វាមិនមានបំណង ថែមទាំងគេមិនគួរប្រើប្រាស់វាដើម្បីបំបិទសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសមាគមនោះទេ ថែមទាំងវាមិនគួរនាំទៅរកការហាមឃាត់ការប្រឆាំងឬ ការផ្លាស់ប្តូរនយោបាយដោយស្របច្បាប់នោះដែរ។

## វិធីសាស្រ្ត ៣យ៉ាងប្រឆាំងអំពើភេរវកម្ម

សេវាសន្តិសុខអាចអនុវត្តវិធានការ ៣យ៉ាង ដើម្បីការពារសង្គម និងស្ថាប័នរដ្ឋរបស់ខ្លួនប្រឆាំងនឹងការវាយប្រហារពីភេរវករៈ

- ✓ **វិធានការប្រឆាំងអំពើភេរវកម្ម៖** កាត់បន្ថយគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ជីវិតសាធារណៈ អាគារ និងហេដ្ឋារចនាសម្ព័ន្ធនានា។
- ✓ **វិធានការទប់ទល់អំពើភេរវកម្ម៖** ទប់ស្កាត់ភេរវករពីការវាយប្រហារ តាមរយៈការកំណត់អត្តសញ្ញាណ និងបញ្ឈប់ពួកគេ។
- ✓ **ការគ្រប់គ្រងវិបត្តិ៖** ការដោះស្រាយ និងការធ្វើឲ្យស្ថានការណ៍មានស្ថិរភាពឡើងវិញ (ស្ថានការណ៍គ្រោះមហន្តរាយ ស្ថានការណ៍ប្រកាសភាពអាសន្ន) ក្រោយពីការវាយប្រហារដោយពួកភេរវករ។

ការវិភាគបង្ហាញថា សកម្មភាពប្រឆាំងភេរវករភាគច្រើនមានទំនាក់ទំនងជាមួយ (១) ច្បាប់ជាតិ ការសម្របសម្រួល ការផ្តល់មូលនិធិ (២) សន្តិសុខផ្ទៃក្នុង (៣) មនុស្សចម្លែក (៤) ការធ្វើដំណើរ និងការត្រួតពិនិត្យព្រំដែន (៥) ការផ្តល់ហិរញ្ញវត្ថុ (៦) សហប្រតិបត្តិការអន្តរជាតិ និង (៧) ការគម្រាមកំហែងគ្រាប់បែកបរមាណូជីវសាស្ត្រ និងគីមីសាស្ត្រ។ បញ្ជីនៃសកម្មភាពដ៏ច្រើនទាំងនេះគួរត្រូវ បានគេពិចារណាថា ជាបញ្ជីមួយសម្រាប់រៀបចំជាវិធានការប្រឆាំងអំពើភេរវកម្ម។

<u>ច្បាប់ជាតិ ការសម្របសម្រួល និងថវិកា</u>

- អនុម័តច្បាប់ប្រឆាំងអំពើភេរវកម្មពិសេស ឬកែសម្រួលច្បាប់ដែលនៅជាធរមាន។
- ផ្តល់មូលនិធិបន្ថែមដល់កងកម្លាំងនគរបាល ឆ្មាំព្រំដែន អាកាសចរណ៍ជាតិ អាជ្ញាធរសុខាភិបាលជាតិ ប្រៃសណីយ៍ជាតិ យោធា។
- បង្កើនការចែករំលែកព័ត៌មានរវាងសេវាសន្តិសុខក្នុងប្រទេស។
- បុគ្គលិករយៈពេលវែង និងមជ្ឈមណ្ឌលសម្របសម្រួលទទួលបន្ទុកសម្រាប់ការធ្វើសុខដុមនីយកម្ម និងការសម្របសម្រួលនូវគោលនយោបាយផ្សេងៗនៃសេវាសន្តិសុខ(សេវាចារកម្ម ឆ្មាំព្រំដែន នគរបាល យោធា) នៅថ្នាក់តំបន់ និងថ្នាក់សហព័ន្ធ/ជាតិ។
- ផ្តល់សិទ្ធិដល់មន្ត្រីចារកម្ម និងមន្ត្រីអនុវត្តច្បាប់ទទួលបាននូវកំណត់ហេតុព័ត៌មានអំពីបុគ្គលទាំងឡាយនៅឯការិយាល័យគយ និងពន្ធដារ។

<u>សន្តិសុខផ្ទៃក្នុង</u>

- លួចស្តាប់ការសម្ងាត់នៃការធ្វើទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណែត ទូរស័ព្ទ ហ្វាក់ (ដោយមិនបាច់ជូនដំណឹងដល់ ស្ថាប័នពាក់ព័ន្ធ ឧ. តុលាការ)។
- តម្រូវឲ្យក្រុមហ៊ុនទូរគមនាគមន៍ ឃាត់ទុកនូវទិន្នន័យ ចរាចរណ៍របស់អតិថិជនរបស់ពួកគេ (ឧ. ទិន្នន័យក្នុងរយៈពេល១ឆ្នាំ) ដែលអាចឲ្យភ្នាក់ងារអនុវត្តច្បាប់អាចទទួលបាននូវទិន្នន័យទូរគមនាគមន៍ទាំងនេះ។

- ទទួលកំណត់ហេតុអេឡិកត្រូនិករបស់បុគ្គលម្នាក់ៗ ពីធនាគារ ក្រុមហ៊ុនអ៊ីនធឺណែត និងស្ថាប័នឥណទាន ដោយមិនជូនដំណឹងដល់បុគ្គលដែលសង្ស័យ។
- បង្កើតប្រព័ន្ធស្រាវជ្រាវតាមកុំព្យូទ័រដែលកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្សារភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានទិន្នន័យស៊ីវិលមួយចំនួន។
- អនុញ្ញាតឲ្យមន្ត្រីដែលមិនមែនជានគរបាលចូលឆែកមើលសំណុំឯកសារផ្ទាល់ខ្លួនដែលមាននៅក្នុងប្រព័ន្ធទិន្នន័យនគរបាល។
- ឃុំខ្លួនបុគ្គលសង្ស័យរយៈពេលវែង ដើម្បីសាកសួរព័ត៌មានឲ្យបានច្រើនថែមទៀត។
- បង្កើតនូវប្រព័ន្ធតាមដានថ្នាក់ជាតិ ឧ.អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន។

<u>ជនប្លែកមុខ (ជនអន្តោប្រវេសន៍ អ្នកសុំសិទ្ធិជ្រកកោន និងជនបរទេស)</u>

- ផ្តល់សិទ្ធិដល់សេវាសន្តិសុខឲ្យចូលឆែកមើលប្រព័ន្ធទិន្នន័យអំពីជនបរទេស/ជនប្លែកមុខ។
- តាមដានជនដែលជាសមាជិកនៃក្រុមជនជាតិភាគតិចខ្លះ (ក្រុមធ្លាប់ប្រកាន់ពូជសាសន៍)។
- ដកហូតសិទ្ធិមិនឲ្យទទួលបាននូវការស្នើសុំសើរើរឿងក្តីនៅតុលាការ ប្រសិនបើអ្នកសុំសិទ្ធិជ្រកកោនត្រូវបានសង្ស័យថា មានជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពភេរវកម្ម។
- បដិសេធសំណើសុំសិទ្ធិជ្រកកោនប្រសិនបើអាជ្ញាធរពាក់ព័ន្ធ (រដ្ឋមន្ត្រី) បញ្ជាក់ថាបុគ្គលស្នើសុំសិទ្ធិជ្រកកោននោះបង្កការគម្រាមកំហែងដល់សន្តិសុខជាតិ។
- រក្សាទុក (រហូតដល់១០ឆ្នាំ) នូវស្នាមក្រយៅដៃដែលខាងអន្តោកប្រវេស បានយកពីជនបរទេស និងពីអ្នកសុំសិទ្ធិជ្រកកោន។
- បង្កើនការពិនិត្យរកអត្តសញ្ញាណដោយប្រើប្រាស់នូវនីតិវិធីទាក់ទងនឹងការសុំទិដ្ឋិការ។
- បង្កើនការត្រួតពិនិត្យប្រវត្តិនយោបាយ របស់អ្នកសុំទិដ្ឋិការ និងអ្នកសុំសិទ្ធិជ្រកកោន។

<u>ការធ្វើដំណើរ និងការត្រួតពិនិត្យច្រកព្រំដែន</u>

- រិតត្បិតកន្លែងត្រួតពិនិត្យព្រំដែន។
- បំពាក់អាវុធឲ្យបុគ្គលយន្តហោះស៊ីវិល។
- បំពាក់ទ្វារការពារគ្រាប់កាំភ្លើង នៃបន្ទប់បើកបរយន្តហោះ។
- ត្រួតពិនិត្យវ៉ាលីសធ្វើដំណើរ១០០%នៅព្រលានយន្តហោះតាមម៉ាស៊ីនស្កែន។
- បន្ថែមជីវមាត្រនៅក្នុងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន/ លិខិតឆ្លងដែន។
- ធ្វើការឆែកឆេរឲ្យបានញឹកញាប់ និងពេញលេញនៅចំណុចដែលងាយរងគ្រោះ (កំពង់ផែ ផ្លូវក្រោមដី និងព្រលានយន្តហោះ)។
- សាកសួរប្រវត្តិរូបនៅចំណុចចេញចូល។

<u>ហិរញ្ញវត្ថុ</u>

- ត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុ។
- បង្កើនការត្រួតពិនិត្យធនាគារ និងស្ថាប័នឥណទានទាំងឡាយ ដើម្បីបញ្ចៀសការលាងលុយកខ្វក់ និងការកិបកេងប្រាក់ខុសច្បាប់។ បង្កកគណនីធនាគារដែលមានការពាក់ព័ន្ធជាមួយសកម្មភាពភេរវកម្ម។
- តម្រូវឲ្យធនាគារផ្តល់នូវព័ត៌មានអំពីរាល់គណនីទាំងអស់របស់ពួកគេ រួមទាំងម្ចាស់បត្ររបស់ពួកគេដល់ប្រព័ន្ធទិន្នន័យកណ្តាល (ការផ្លាស់ប្តូរព័ត៌មានគណនីធនាគារ) រួមទាំងកំណត់ជាបទល្មើស ចំពោះធនាគារណាមិនរាយការណ៍អំពីប្រតិបត្តិការ នៅពេលដែលខ្លួនបានដឹង ឬមានការសង្ស័យថាមានការធ្វើប្រតិបត្តិការបម្រើដល់សកម្មភាពភេរវកម្ម។
- បង្កើតអង្គភាពចារកម្មហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាពមួយ (នៅឯក្រសួងហិរញ្ញវត្ថុ)

<u>សហប្រតិបត្តិការអន្តរជាតិ</u>

- បង្កើនសហប្រតិបត្តិការអន្តរជាតិ ឧ. ដីកាចាប់ខ្លួនចេញដោយសហភាពអឺរ៉ុប ឬការធ្វើបត្យាប័ន (Extradition) រហ័ស។
- បញ្ចូលកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើភេរវកម្មទៅក្នុងច្បាប់ជាតិ។
- ពង្រាយទ័ពជាផ្នែកមួយនៃកងកម្លាំងជំនួយផ្នែកសន្តិសុខអន្តរជាតិ (ISAF) នៅក្នុងប្រទេសអាហ្គានីស្ថាន។
- ចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាសហប្រជាជាតិស្តីពីភេរវកម្ម។
- ចែករំលែកព័ត៌មានជាអន្តរជាតិ ជាមួយសេវាសន្តិសុខតូចៗដទៃទៀត។
- ធ្វើការដោះស្រាយបញ្ហាជាឫសគល់នៃបុព្វហេតុ នៃអំពើភេរវកម្មដោយផ្តល់នូវជំនួយអភិវឌ្ឍន៍សម្រាប់ប្រទេសដែលជាជម្រករបស់ពួកភេរវករ។

<u>ការគម្រាមកំហែងដោយគ្រាប់បែកបរមាណូ អាវុធជីវសាស្រ្ត និងគីមីសាស្រ្ត</u>

- បង្កើត ឬ ធ្វើឲ្យមជ្ឈមណ្ឌលនុយក្លេអ៊ែរ ជីវសាស្រ្ត គីមីសាស្រ្ត និងវិទ្យុសាស្រ្ត ដែលមានស្រាប់កាន់ តែមានប្រសិទ្ធភាពខ្ពស់។ ធ្វើការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់នៅក្នុងវិស័យនេះ ទាំងការផលិតវ៉ាក់សាំង/ការស្តុកទុកវ៉ាក់សាំង (វ៉ាក់សាំងជម្ងឺអុតស្វាយ)។
- បង្កើនការត្រៀមជាមុន របស់អាជ្ញាធរផ្នែកសុខាភិបាល ដោយធានាឲ្យមានការផ្គត់ផ្គង់ថ្នាំសង្គ្រោះគ្រប់គ្រាន់។
- កែលំអកិច្ចការពារទីតាំងនុយក្លេអ៊ែរ (ឧ. ការបំពាក់វ៉ាដាសម្រាប់ចាប់យន្តហោះតូច ហោះក្នុងរយៈកម្ពស់ទាបស៊ើបយកការណ៍)។

## តុល្យភាពរវាងសិទ្ធិមនុស្ស និងការរក្សាសន្តិសុខ

វិធានការទាំងនេះ ដែលមាននៅជាធរមាននៅក្នុងប្រទេសមួយចំនួនមិនមែនជាវិធានការបណ្តោះអាសន្ននោះទេ តែវានៅជាធរមានសម្រាប់រយៈពេលវែង។ ដូច្នេះ វិធានការប្រឆាំងអំពើភេរវកម្ម មិនមែនជាវិធានការប្លែកខុសប្រក្រតីនោះទេ តែវាជាវិធានការធម្មតា ដែលកើតមាននៅក្នុងជីវភាពធម្មតានៅក្នុងសង្គម។ នេះសំខាន់ខ្លាំងណាស់ ជាពិសេសនៅពេលដែលវិធានការទាំងនេះ វាមានផលប៉ះពាល់ទៅលើសិទ្ធិពលរដ្ឋដូចជា សេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិឯកជនភាពជាដើម។ ពាក់ព័ន្ធជាមួយលក្ខណៈស្ថិតស្ថេរ នៃវិធានការប្រឆាំងភេរវកម្ម ការដាក់ប្រទេសនៅក្នុងស្ថានភាពអាសន្ន ឬការប្រកាសស្ថានភាពអញ្ញត្រកម្ម វាមានលក្ខណៈមិនសមស្រប ពីព្រោះចេតនានៃវិធានការទាំងនេះ វាមានរយៈពេលយូរពេក។

ក្រៅពីនេះ វិធានការប្រឆាំងភេរវកម្មបែងចែកការងារមិនច្បាស់លាស់រវាងកងកម្លាំងអនុវត្តច្បាប់ និងកងចារកម្ម។ ភ្នាក់ងារអនុវត្តច្បាប់ ដូចជានគរបាល និងសេវាចារកម្ម មានគោលបំណងខុសគ្នា។ សេវាចារកម្មធ្វើការប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងការគម្រាមកំហែងធំៗ ខណៈពេលដែលនគរបាលមានតួនាទីរក្សាច្បាប់ និងសណ្តាប់ធ្នាប់។ ជាធម្មតា សេវាចារកម្មមិនបញ្ឈប់ ឬចាប់ខ្លួនជនសង្ស័យនោះទេ តែនគរបាលវិញមិនបំពេញ ″ការងារផ្នែកចារកម្ម″ មុនពួកគេមានភស្តុតាងគួរឲ្យជឿជាក់ថាបទល្មើសមួយនេះ ពិតជាត្រូវបានប្រព្រឹត្តមែននោះ។ តាមទស្សនៈនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ សេវាចារកម្ម មិនគួរចូលពាក់ព័ន្ធនៅក្នុងការងារ ″ស៊ើបយកការណ៍សម្ងាត់″ ពីប្រជាពលរដ្ឋខ្លួនឯងនោះទេ។ ការបែងចែកការងារបែបនេះ វាមានការពិបាកទៅៗ ដោយហេតុថា ការប្រយុទ្ធប្រឆាំងភេរវកម្មនៅក្នុងប្រទេសខ្លះ វាបណ្តាលឲ្យមានការបន្ធូរបន្ថយការរិតត្បិតទៅលើការប្រើប្រាស់ចារកម្ម (បរទេស) ដើម្បីជួយគាំទ្រដល់ការស៊ើបអង្កេតបទល្មើសនៅក្នុងប្រទេស។

បញ្ហាទី៣ គឺថាសេវាសន្តិសុខត្រូវបានអនុញ្ញាតឲ្យដាក់ប្រជាពលរដ្ឋនៅក្រោមការឃ្លាំមើលរបស់ពួកគេ ដោយមិនបាច់ជូនដំណឹងដល់ស្ថាប័នត្រួតពិនិត្យ ដូចជាតុលាការជាដើម។ នេះវាអាចបង្កើតនូវការរំលោភសិទ្ធិមនុស្សប្រកបដោយគ្រោះថ្នាក់។ វាពិបាកសម្រាប់ប្រជាពល រដ្ឋមន្ត្រីរដ្ឋទទួលពាក្យបណ្តឹង និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើឲ្យរដ្ឋាភិបាល និងភ្នាក់ងាររបស់រដ្ឋាភិបាល មានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ពីព្រោះពួកគេមិនចាំបាច់មានគេជូនដំណឹងអំពីសកម្មភាពឃ្លាំមើលទៅលើប្រជាពលរដ្ឋនោះទេ។ ទី៤ ជនអន្តោប្រវេសន៍ អ្នកសុំសិទ្ធិជ្រកកោន និងជនបរទេស ទំនងគឺជាគោលដៅនៃវិធានការប្រឆាំងអំពើភេរវកម្ម។ គ្រោះថ្នាក់អាចកើតមានឡើង ពីព្រោះវិធានការទាំងនេះ អាចបង្កើនភាពតានតឹងរវាងក្រុមជនជាតិភាគតិចផ្សេងៗនៅក្នុងសង្គម ក៏ដូចជាធ្វើឲ្យប៉ះពាល់ដល់បទដ្ឋានច្បាប់ ដែលមនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់។

ទោះបីជាវិធានការទាំងអស់នេះ អាចជាវិធានការដ៏ចាំបាច់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើភេរវកម្មប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏សភាគួរធានាថា វិធានការទាំងនេះ វាស្របជាមួយនឹងច្បាប់មនុស្សធម៌ និងគោលការណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ ម្យ៉ាងទៀត ការប្រឹងប្រែងដើម្បីរក្សាសន្តិសុខជាច់ខាតមិនត្រឹមតែមានភាពមិនប្រាកដនិយមប៉ុណ្ណោះនោះទេ តែវាអាចធ្វើឲ្យរដ្ឋមិនគោរពកាតព្វកិច្ចជាតិ និងអន្តរជាតិទៀតផង។ ចង់បានសន្តិសុខដាច់ខាត ទាល់តែមានសិទ្ធិអំណាចដាច់ខាតដែលនេះវាផ្ទុយពីទស្សនទាននៃលទ្ធិប្រជាធិបតេយ្យ។ ហេតុដូច្នេះហើយ បានជារាល់ប្រព័ន្ធច្បាប់ទាំងអស់ បង្កើតនូវការរិតត្បិតនូវអំណាចពិសេស ដែលត្រូវប្រគល់ទៅឲ្យអង្គការនីតិប្រតិបត្តិ។ ពាក់ព័ន្ធជាមួយការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មបច្ចុប្បន្នវិញ ភាពតានតឹងរវាងសិទ្ធិសេរីភាព និងការរក្សាសន្តិសុខ អាចបង្កជាការប្រឈមធ្ងន់ធ្ងរដល់សភា។ ក៏ប៉ុន្តែ វាពិតជាសំខាន់ក្នុងការធ្វើឲ្យមានតុល្យភាព រវាងសិទ្ធិសេរីភាព និងការរក្សាសន្តិសុខ ដែលវាមិនគួរជាការទទួលខុសត្រូវដាច់មុខរបស់អង្គការនីតិប្រតិបត្តិតែឯកឯងនោះទេ ហើយក្នុងនាមជាតំណាង និងអ្នកធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ សភាគួរអនុវត្តនូវការត្រួតពិនិត្យឲ្យបានជិតដល់នៅក្នុងបញ្ហានេះ។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម

- ការអនុវត្តតាមវិធីសាស្ត្រដ៏ទូលំទូលាយ ប្រឆាំងអំពើភេរវកម្ម មិនត្រឹមផ្តោតលើការការពារ និងរក្សាសន្តិសុខប៉ុណ្ណោះនោះទេ តែថែមទាំងត្រូវធ្វើការដោះស្រាយនូវបុព្វហេតុជាឫសគល់របស់វាថែមទៀតផង ដូចជា ជម្លោះផ្ទៃក្នុងជាដើម។ ចូរចងចាំថា ការដោះស្រាយជម្លោះតំបន់ តាមរយៈមធ្យោបាយសន្តិវិធី និងការលើកកម្ពស់កិច្ចសន្ទនាអន្តរវប្បធម៌ និងការយោគយល់គ្នាគឺជាវិធីសាស្ត្រដ៏សំខាន់ក្នុងការទប់ស្កាត់អំពើភេរវកម្ម។
- ជម្លោះថ្នាក់តំបន់មួយចំនួន មានឫសគល់ចេញពីជម្លោះរវាង ជនជាតិភាគច្រើន និងជនជាតិភាគតិច រួមទាំងអ្នកប្រកាន់សាសនាផងដែរ។ សេវាប្រដាប់អាវុធអាចត្រូវបានប្រើប្រាស់ ឬ ប្រើប្រាស់ខុសនៅក្នុងជម្លោះបែបនោះ។ តំណាងរាស្ត្រមកពី សហគមន៍ជនជាតិភាគតិច គួរតែជាសមាជិកនៃគណៈកម្មការការពារជាតិ ចារកម្ម និងកិច្ចការតុលាការ។ សភាគួរបង្កើតនូវគណៈកម្មការពិសេសនិងសាលាក្តីពិសេសសម្រាប់ការពារជនជាតិភាគតិច។
- ត្រូវធានាថារដ្ឋរបស់អ្នកគឺជាភាគីនៃអនុសញ្ញា និងពិធីសារអន្តរជាតិដែលពាក់ព័ន្ធនឹងអំពើភេរវកម្ម រួមទាំងអនុសញ្ញាអន្តរជាតិស្តីពី ការបង្ក្រាបការផ្តល់ហិរញ្ញវត្ថុដល់ភេរវកម្មចុះថ្ងៃទី៩ខែធ្នូ ឆ្នាំ១៩៩៩ ផងដែរ។ បើអាចធ្វើបាន ចាត់វិធានការឲ្យមានការផ្តល់សច្ចាប័ន ឬការគោរពតាមលិខិតូបករណ៍ទាំងនេះ (Instruments) និងអនុម័តនូវច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធ។

- ▷ ពិនិត្យតាមដានយ៉ាងជិតដល់នូវសកម្មភាព ដែលមានគោលបំណងដាក់ចេញនូវអនុសញ្ញាស្តីពីការបង្ក្រាប ការបង្កអំពើភេរវកម្មនុយក្លេអ៊ែរ និងអនុសញ្ញាស្តីពីការលុបបំបាត់អំពើភេរវកម្មគ្រប់ជ្រុងជ្រោយ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។
- ▷ ខិតខំដាក់ចេញនូវវិធានការច្បាប់ ដែលអនុញ្ញាតឲ្យមានការសងសំណងដល់ជនរងគ្រោះពីអំពើភេរវកម្ម ដើម្បីសាមគ្គីភាពជាតិជាផ្លូវមួយ។
- ▷ ធានាថា ច្បាប់ប្រឆាំងអំពើភេរវកម្ម រក្សានូវតុល្យភាពដ៏សមស្របមួយ រវាងការរក្សាសន្តិសុខ និងការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រវាងផលប៉ះពាល់ដែលអាចកើតមាន ច្បាប់ខាងលើជាមួយការចំណាយដែលអាចកើតមានលើការអនុវត្ត។

សូមអាននូវសំណូមពរទាំងឡាយ ដែលមាននៅក្នុងប្រអប់ក្នុងជំពូកទី ១៨ ស្តីពី បញ្ហាអញ្ញត្រកម្ម និងជំពូកទី១៩ស្តីពីការថែរក្សាសន្តិសុខផ្ទៃក្នុង និងសណ្តាប់ធ្នាប់សាធារណៈ។

# ជំពូកទី ២១

# សន្តិសុខ និងបច្ចេកវិទ្យាព័ត៌មានៈ ឧបករណ៍ថ្មី និង ការប្រឈមថ្មី

ការកើតមាននូវបច្ចេកវិទ្យាព័ត៌មានថ្មី បានជួយថែរក្សាការពារសន្តិសុខផង និង បង្កជាការគម្រាមកំហែងធ្ងន់ធ្ងរថ្មីផង។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣៧៣ (២០០១) (សូមអានប្រអប់ទី៨៤) ដែលបាននិយាយយោងនៅក្នុងជំពូកមុនបានផ្តល់នូវភស្តុតាងយ៉ាងច្បាស់ អំពីការយល់ដឹងរបស់សហគមន៍អន្តរជាតិ អំពីការអនុវត្តជាន់គ្នានេះនៃបច្ចេកវិទ្យាព័ត៌មាន ដែលមានទំនាក់ទំនងជាមួយភេរវកម្មអន្តរជាតិ និង ហានិភ័យចំពោះសន្តិសុខ និងសន្តិភាពអន្តរជាតិ។

នៅក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ អង្គការអន្តរជាតិមួយចំនួនបានខិតខំទប់ស្កាត់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្របទល្មើសនិងសកម្មភាពដែលគម្រាមកំហែងដល់សន្តិសុខអន្តរជាតិ ហើយអង្គការទាំងនេះ បានខិតខំបង្កើតគោលការណ៍ណែនាំដើម្បីទប់ស្កាត់រដ្ឋទាំងឡាយពីការប្រើប្រាស់នូវបច្ចេកវិទ្យាទាំងនេះដែលបង្កនូវការគម្រាមកំហែងដល់សិទ្ធិមនុស្ស និងសេរីភាព។

ចំណុចខាងក្រោមនេះ អាចជាទុនសម្រាប់សភាក្នុងការយកទៅធ្វើការអភិវឌ្ឍច្បាប់ ដើម្បីដោះស្រាយនូវការប្រឈមទាំងនោះ។

## ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត

និយមន័យនៃអ្វីដែលបង្កើតឧក្រិដ្ឋកម្មលើប្រព័ន្ធអ៊ីនធឺណែតកំពុងត្រូវបានរៀបចំនៅឡើយ។ ទោះដូច្នេះក្តី ពាក្យដែលគេនិយមប្រើជាទូទៅនោះ គឺជាបទល្មើសនិងការរំលោភបំពានពាក់ព័ន្ធជាមួយព័ត៌មានវិទ្យា ដូចជាការលួចមើលជាសម្ងាត់នូវព័ត៌មានទាំងឡាយនៅលើប្រព័ន្ធកុំព្យូទ័រ និងការបង្កើតមេរោគកុំព្យូទ័រជាដើម។ ទោះបីជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញមានការចាប់អារម្មណ៍យ៉ាងច្រើននៅក្នុងផ្នែកនេះក៏ដោយ ក៏បញ្ហានៃឧក្រិដ្ឋកម្មតាមកុំព្យូទ័រនេះ មិនមែនជាបញ្ហាថ្មីនោះដែរ ពីព្រោះវាមានឧបទ្ទវហេតុបែបនេះបានកើតឡើង តាំងពីថ្ងៃដំបូងដែលកុំព្យូទ័រលេចចេញជារូបរាងមកម្ល៉េះ។ ភាពខុសគ្នានោះគឺថាមានការកើនឡើងនូវការវាយប្រហារបែបនេះដោយសារតែប្រព័ន្ធអ៊ីនធឺណែតកាន់តែមានប្រជាប្រិយភាពខ្លាំងឡើង។ បច្ចុប្បន្នសាធារណជនបានទទួលយក World Wide Web ជាមធ្យោបាយនៃការធ្វើទំនាក់ទំនងនៅលើអ៊ីនធឺណែត។ ទោះដូច្នេះក្តី

ការប្រើប្រាស់កាន់តែច្រើនក៏មានភ្ជាប់មកនូវបញ្ហាក៏កាន់តែច្រើនដែរ។ ក្នុង១ថ្ងៃៗយ៉ាងហោចណាស់ក៏មានការរាយការណ៍ពីបទល្មើសតាមអ៊ីនធឺណែតកើតឡើងខ្លះដែរ។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តនូវ*អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត* ដែលបច្ចុប្បន្នកំពុងបើកផ្លូវឲ្យមានការផ្តល់សច្ចាប័ន ហើយអនុសញ្ញានេះនឹងចូលជាធរមាន នៅពេលដែលមានរដ្ឋ៥ បានផ្តល់សច្ចាប័ន ក្នុងនោះយ៉ាងហោចត្រូវមានរដ្ឋ ៣ ដែលជាសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប (ក្នុងខែឧសភា ឆ្នាំ២០០២ អនុសញ្ញាត្រូវបានចុះហត្ថលេខារួចរាល់ដោយរដ្ឋ ចំនួន២៩រដ្ឋ នៃក្រុមប្រឹក្សាអឺរ៉ុប និង រដ្ឋ៤ទៀតដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប)។ អនុសញ្ញាតម្រូវឲ្យមានគោលនយោបាយរួមមួយ សំដៅការពារសង្គមតាមរយៈការអនុម័តច្បាប់ដ៏សមស្រប និងជម្រុញលើកកម្ពស់សហប្រតិបត្តិការអន្តរជាតិ។

## សន្តិសុខនៃប្រព័ន្ធព័ត៌មាន

កំណើនដ៏គំហុក នៃការប្រើប្រាស់ប្រព័ន្ធព័ត៌មាននៅក្នុងវិស័យផ្សេងៗ ក្នុងគោលបំណងផ្សេងៗ បណ្តាលឲ្យអង្គការអន្តរជាតិនានាមានក្តីកង្វល់អំពីហានិភ័យដែលពាក់ព័ន្ធ។ កង្វល់នេះបានបណ្តាលឲ្យក្រុមប្រឹក្សានៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍ (OECD) ចេញនូវគោលការណ៍ណែនាំលំអិតមួយក្នុងខែវិច្ឆិកា ឆ្នាំ១៩៩២ ស្តីពីសន្តិសុខនៃប្រព័ន្ធព័ត៌មានដែលមាន "គោលបំណង៖

- ✓ លើកកម្ពស់ការយល់ដឹងអំពីហានិភ័យនៃប្រព័ន្ធព័ត៌មាន និង វិធីសាស្ត្រការពារហានិភ័យទាំងនោះ។
- ✓ បង្កើតនូវក្របខណ្ឌទូទៅមួយ ដើម្បីជួយអ្នកទទួលខុសត្រូវនៅក្នុងវិស័យសាធារណៈ និងឯកជនក្នុងការរៀបចំ និង អនុវត្តនូវវិធានការ និងនីតិវិធីរួមគ្នាមួយសម្រាប់រក្សាសន្តិសុខនៃប្រព័ន្ធព័ត៌មាន។
- ✓ ដើម្បីជម្រុញសហប្រតិបត្តិការរវាងវិស័យសាធារណៈ និង ឯកជននៅក្នុងការរៀបចំ និងអនុវត្តនូវវិធានការ និងនីតិ វិធីទាំងនោះ។
- ✓ បង្កើនទំនុកចិត្ត នៅក្នុងប្រព័ន្ធព័ត៌មាន និង នៅក្នុងរបៀបប្រើប្រាស់ និងផ្តល់ព័ត៌មាន (...)។
- ✓ ជម្រុញសហប្រតិបត្តិការអន្តរជាតិដើម្បីរក្សាសន្តិសុខនៅក្នុងប្រព័ន្ធព័ត៌មាន"។

នៅពេលក្រុមប្រឹក្សានៃអង្គការ OECD អនុម័តនូវគោលការណ៍ណែនាំនេះ ពួកគេបានគូសបញ្ជាក់ថា "គោលការណ៍ណែនាំនេះ មិនប៉ះពាល់ដល់សិទ្ធិជាអធិបតេយ្យភាពរបស់ប្រទេសនីមួយៗឡើយ ទាក់ទងនឹងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ហើយអ្វីដែលមានចែងនៅក្នុងគោលការណ៍នេះ ស្ថិតនៅក្រោមអំណាចនៃបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាតិ"។

## សំណុំឯកសារបុគ្គលនៅក្នុងប្រព័ន្ធកុំព្យូទ័រ

នៅក្នុងខែធ្នូ ឆ្នាំ១៩៩០ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត *គោលការណ៍ណែនាំទាក់ទងនឹងសំណុំឯកសារបុគ្គលនៅក្នុងកុំព្យូទ័រ*។ កាលពីប៉ុន្មានឆ្នាំមុននោះ ក្នុងខែកញ្ញា ឆ្នាំ១៩៨០ អង្គការ OECD បានដាក់ចេញនូវអនុសាសន៍ទាក់ទងនឹងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រង និងការការពារឯកជនភាព និងលំហូរឆ្លងដែននៃទិន្នន័យបុគ្គល នៅក្នុងឆ្នាំ១៩៨១ ក្រុមប្រឹក្សាអឺរ៉ុប បានអនុម័តនូវ *អនុសញ្ញាមួយស្តីពីការការពារបុគ្គលទាក់ទងនឹងកិច្ចដំណើរការដោយស្វ័យប្រវត្តិនូវទិន្នន័យបុគ្គល*។ សូមអានប្រអប់ទី ៤៦។

**ប្រអប់ទី ៤៦**

### អនុសញ្ញាស្តីពីការគាំពារបុគ្គលទាក់ទងនឹងកិច្ចដំណើការដោយស្វ័យប្រវត្តិនូវទិន្នន័យបុគ្គល

(ETS no. 108)

"អនុសញ្ញានេះ គឺជាលិខិតូបករណ៍អន្តរជាតិចងកាតព្វកិច្ចដំបូងគេ ដែលការពារបុគ្គលពីការរំលោភបំពានទាំងឡាយទាក់ទងនឹងការប្រមូលនិងផ្សព្វផ្សាយទិន្នន័យបុគ្គល(data processing)។ អនុសញ្ញានេះក៏មានបំណងគ្រប់គ្រងលំហូរឆ្លងដែននៃទិន្នន័យបុគ្គលផងដែរ។ ក្រៅពីការផ្តល់ការធានាទាក់ទងនឹងការប្រមូល និង ការផ្សព្វផ្សាយទិន្នន័យបុគ្គល អនុសញ្ញានេះបានកំណត់ថា ការផ្សព្វផ្សាយទិន្នន័យដែលមានលក្ខណៈ "រសើប" អំពី ជាតិសាសន៍ នយោបាយ សុខភាព សាសនា ភេទ លិខិតថ្កោលទោសជាដើម គឺជាអំពើខុសច្បាប់ ក្នុងខណៈពេលដែលមិនមានច្បាប់ដ៏សមស្របចែងអំពីបញ្ហាទាំងនេះ។ អនុសញ្ញាក៏បានចែង អំពីសិទ្ធិបុគ្គលក្នុងការដឹងអំពីព័ត៌មានដែលបានរក្សាទុកទាក់ទងនឹងរូបបុគ្គលនោះ ប្រសិនបើចាំបាច់គេមានសិទ្ធិធ្វើការកែតម្រូវនូវព័ត៌មានមិនសមស្របទាំងឡាយ។ មានការហាមឃាត់លើសិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញាលើកលែងតែការប្រើសិទ្ធិនោះធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ធំៗ (ឧ.សន្តិសុខជាតិ ការការពារជាតិ។ល។)។ អនុសញ្ញាក៏បានហាមឃាត់ផងដែរ ទៅលើលំហូរឆ្លងដែននៃទិន្នន័យបុគ្គលទៅដល់រដ្ឋនានា ដែលនៅក្នុងរដ្ឋទាំងនោះ ច្បាប់របស់ពួកគេមិនមានចែងអំពីកិច្ចការពារប្រហាក់ប្រហែលនេះ"។

*ប្រភព៖ ក្រុមប្រឹក្សាអឺរ៉ុប គេហទំព័រ http://conventions.coe.int*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ច្បាប់ស្តីពីបច្ចេកវិទ្យាព័ត៌មាន

- ធានាឲ្យមានច្បាប់គ្រប់ជ្រុងជ្រោយ ទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន ឧក្រិដ្ឋកម្មតាមអ៊ីនធឺណែត។ ដោយបច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងរហ័ស វាតម្រូវឲ្យមានការពិនិត្យច្បាប់ពាក់ព័ន្ធឡើងវិញ និងធ្វើបច្ចុប្បន្នភាពច្បាប់ទាំងនេះ។
- ធានាថារដ្ឋរបស់អ្នក គឺជាភាគីមួយនៃអនុសញ្ញាតំបន់ និងអន្តរជាតិដែលពាក់ព័ន្ធ និងបញ្ចូលបទបញ្ញត្តិផ្សេងៗនៅក្នុងអនុសញ្ញាទៅក្នុងច្បាប់ និងគោលនយោបាយជាតិ។
- ត្រូវយកចិត្តទុកដាក់ថា ច្បាប់ និងគោលនយោបាយជាតិ ពាក់ព័ន្ធជាមួយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែតត្រូវបានពិភាក្សាយ៉ាងលម្អិត និងអនុវត្តដោយយកចិត្តទុកដាក់អំពីសារៈសំខាន់នៃការរក្សាការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត។
- ប្រសិនបើអាចធ្វើបាន ចាត់វិធានការតាមរយៈការសួរដេញដោលរដ្ឋាភិបាលដោយសភា ឬស្នើសុំឲ្យមានសវនការ ឬបង្កើតច្បាប់សម្រាប់សងសំណងដល់វិធានការ ដែលបង្កផលប៉ះពាល់ទាំងឡាយ។

### មធ្យោបាយនិងធនធានរបស់សភា

- ធានាថា គណៈកម្មការសភា ឬអនុគណៈកម្មការសភាទទួលបន្ទុកតាមដានបញ្ហាវិវត្តន៍ទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន និងការអនុវត្តបច្ចេកវិទ្យាព័ត៌មាន។
- ប្រសិនបើចាំបាច់ ចាត់វិធានការបង្កើតនូវគណៈកម្មការឬអនុគណៈកម្មការ ឬធានាឲ្យមានការបញ្ចូលនូវបញ្ហានេះទៅក្នុងអាណត្តិរបស់គណៈកម្មការអចិន្ត្រៃយ៍ដែលមានស្រាប់។
- ធានាថាស្ថាប័នសភាដែលមានសមត្ថកិច្ច មានធនធាន និងជំនាញគ្រប់គ្រាន់ដើម្បីបំពេញបេសកកម្មរបស់ខ្លួន។
- ប្រសិនបើអាចបង្កើតគណៈកម្មការព័ត៌មានសភាដើម្បីតាមដាន និងជម្រុញឲ្យមានការពិភាក្សាដេញដោល និងចាត់វិធានការនៅក្នុងផ្នែកព័ត៌មាន។ គណៈកម្មការនោះមិនគួរមានបក្ខពួកនិយម និងបើអាចគណៈកម្មការនេះគួរជាទ្វិសភា។

## ជំពូកទី ២២

# បេសកកម្មរក្សាសន្តិភាពអន្តរជាតិ

នៅក្នុងបរិបទអន្តរជាតិបច្ចុប្បន្ន មានការបង្កើនកិច្ចខិតខំដោះស្រាយជម្លោះតាមមធ្យោបាយ ដែលមានចែងនៅក្នុងបទបញ្ញត្តិនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ជំពូកទី ៦ (ការដោះស្រាយជម្លោះ ដោយសន្តិវិធី) ឬ ជំពូកទី ៧ (វិធានការទាក់ទងនឹងការគម្រាមកំហែងសន្តិភាព ការរំលោភបំពានសន្តិភាព និងសកម្មភាពឈ្លានពានទាំងឡាយ)។ ផ្អែកលើបទប្បញ្ញត្តិទាំងនេះអង្គការសហប្រជាជាតិបានរៀបចំនូវទស្សនទាន និងប្រតិបត្តិការមួយចំនួន (សម្រាប់និយមន័យ សូមអានប្រអប់ទី ៤៧) រួមទាំងនីតិវិធីសម្រាប់រៀបចំ និងអនុវត្តនូវ បេសកកម្មបែបនោះ (សូមអានប្រអប់ទី ៤៨ ស្តីពីដំណើរការនៃប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិជាជំហានៗ និងប្រអប់ទី ៥០ ស្តីពីការហ្វឹកហ្វឺនអ្នករក្សាសន្តិភាពអង្គការសហប្រជាជាតិ)។ យោងតាមការវិវត្តន៍ដែលប៉ះពាល់ដល់សន្តិសុខអន្តរជាតិ គេអាចអំពាវនាវដល់រដ្ឋទាំងឡាយឲ្យចូលរួមនៅក្នុងសកម្មភាពរក្សាសន្តិភាព។

## ការរួមចំណែកដល់បេសកកម្មសន្តិភាពនៅឯបរទេស

ការរក្សាសន្តិភាព ការជម្រុញសន្តិភាព ឬប្រតិបត្តិការបង្កើតសន្តិភាព វាអាស្រ័យលើការចូលរួមពីរដ្ឋជាសមាជិកតាមរយៈអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខ។ រដ្ឋផ្តល់ទ័ពឲ្យបំពេញបេសកកម្មនៅឯបរទេស ក្នុងគោលបំណងបង្កើតឡើងវិញនូវសន្តិភាព និងសន្តិសុខ នៅក្នុងតំបន់ដែលមានអស្ថិរភាព។ វាសំខាន់ខ្លាំងណាស់ក្នុងការបញ្ជាក់ថា រាល់ការតាំងពង្រាយទ័ពទាំងឡាយវាត្រូវតែស្របជាមួយវិធាន និងគោលការណ៍អន្តរជាតិ។ សំខាន់បំផុតនោះ គឺវិធាននិងគោលការណ៍ដែលមានបញ្ជាក់នៅក្នុងជំពូកទី៥ ដែលមានចំណងជើងថាគោលនយោបាយសន្តិសុខជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ។

តាមទស្សនៈអភិបាលកិច្ចល្អ នៅក្នុងប្រព័ន្ធស្តីពីការត្រួតពិនិត្យដើម្បីតុល្យភាពនៃអំណាចរវាងសភា និងរដ្ឋាភិបាល សភាគួរមានឱកាសដើម្បីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចអំពីការបញ្ជូនកងកម្លាំងប្រដាប់អាវុធចេញទៅក្រៅប្រទេស។

**ប្រអប់ទី ៤៧**

## ការបង្កើតសន្តិភាព ការរក្សាសន្តិភាព ការជម្រុញអោយមានសន្តិភាព ការកសាងសន្តិភាព៖ និយមន័យសំខាន់ៗខ្លះរបស់អង្គការសហប្រជាជាតិ ការបង្កើតសន្តិភាព

### ការបង្កើតសន្តិភាព

ការបង្កើតសន្តិភាពសំដៅលើការប្រើប្រាស់នូវមធ្យោបាយការទូត ដើម្បីអូសទាញភាគីក្នុងជម្លោះឲ្យបញ្ឈប់ភាពប្រទូសរ៉ាយ (អរិភាព) (hostilities) និង ចាប់ផ្តើមចរចារដោះស្រាយជម្លោះដោយសន្តិវិធី។ អង្គការសហប្រជាជាតិអាចមានតួនាទីផ្តល់នូវវិធានការការពារជាបណាភាគីក្នុងជម្លោះឯកភាពគ្នាស្នើសុំឲ្យអង្គការសហប្រជាជាតិធ្វើបែបនោះ។ ដូច្នេះការបង្កើតសន្តិភាពមិនមានការប្រើប្រាស់នូវកម្លាំងប្រឆាំងភាគីណាមួយដើម្បីបង្ខំបញ្ចប់ អរិភាពនឹងគ្នានោះទេ។

### ការរក្សាសន្តិភាព

ចាប់តាំងពីឆ្នាំ១៩៤៨មក មានប្រតិបត្តិការរក្សាសន្តិភាពសហប្រជាជាតិចំនួន៥៤លើក។ ក្នុងនោះមានប្រតិបត្តិការចំនួន៤១ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ នៅក្នុងរយៈពេល១២ឆ្នាំចុងក្រោយនេះ។ បច្ចុប្បន្នមានប្រតិបត្តិការរក្សាសន្តិភាពសហប្រជាជាតិចំនួន១៥កន្លែង។

ជាដំបូង ការរក្សាសន្តិភាពគឺជាមធ្យោបាយសម្រាប់ដោះស្រាយជម្លោះនៅក្នុងរដ្ឋ ហើយវាមានការពាក់ព័ន្ធជាមួយការតាំងពង្រាយនូវបុគ្គលិកយោធាមកពីប្រទេសមួយចំនួន នៅក្រោមការបញ្ជារបស់អង្គការសហប្រជាជាតិដើម្បីជួយត្រួតពិនិត្យ និងដោះស្រាយជម្លោះប្រដាប់អាវុធ។ បច្ចុប្បន្នការរក្សាសន្តិភាព កំពុងត្រូវបានអនុវត្តច្រើនឡើងៗនៅក្នុងជម្លោះក្នុងរដ្ឋ និង សង្គ្រាមស៊ីវិល។ ភារកិច្ចរបស់អ្នករក្សាសន្តិភាពអង្គការសហប្រជាជាតិបុគ្គលិកយោធា នគរបាលស៊ីវិល និងប្រជាជនស៊ីវិលមួយចំនួនធំបានជួយឲ្យភាគីក្នុងជម្លោះមិនប្រទូស្តរាយនឹងគ្នា និងជួយឲ្យពួកគេធ្វើការជាមួយគ្នាដោយសន្តិវិធី។ នេះមានន័យថា ជួយអនុវត្តនូវកិច្ចព្រមព្រៀងសន្តិភាពត្រួតពិនិត្យបទឈប់បាញ់បង្កើតនូវតំបន់ទ្រនាប់ និងបង្កើតនូវស្ថាប័ននយោបាយដោយសហការជាមួយរដ្ឋាភិបាលអង្គការមិនមែនរដ្ឋាភិបាល និង ក្រុមប្រជាពលរដ្ឋមូលដ្ឋានដើម្បីផ្តល់នូវជំនួយសង្គ្រោះបន្ទាន់កាត់បន្ថយអតីតអ្នកប្រយុទ្ធ និង ធ្វើសមាហរណកម្ម ពួកគេចូលក្នុងសង្គមជាតិ បោសសម្អាតមីនរៀបចំការបោះឆ្នោត និង ជម្រុញការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ រដ្ឋជាសមាជិកស្ម័គ្រចិត្តផ្តល់នូវទ័ព និងឧបករណ៍ដោយអង្គការសហប្រជាជាតិមិនមានកងទ័ព ឬនគរបាលស៊ីវិលនោះទេ។ អ្នកសង្កេតការណ៍បោះឆ្នោត អ្នកពិនិត្យតាមដានសិទ្ធិមនុស្ស និងជនស៊ីវិលដទៃទៀត សហការគ្នាជាមួយបុគ្គលិកមានឯកសណ្ឋាន។ "អាវុធ" ដ៏រឹងមាំបំផុតរបស់អ្នករក្សាសន្តិភាព គឺភាពមិនលំអៀងនៅក្នុងការអនុវត្តអាណត្តិរបស់ពួកគេ។ ក៏ប៉ុន្តែការរក្សាសន្តិភាពគឺជាការងារប្រកបដោយគ្រោះថ្នាក់មួយ។ ចាប់តាំងពីឆ្នាំ១៩៤៨ មកមានអ្នករក្សាសន្តិភាពអង្គការសហប្រជាជាតិជាយោធា និង ស៊ីវិលបានស្លាប់ជាង ១៦៥០នាក់នៅក្នុងការបំពេញភារកិច្ចរបស់ពួកគេ។

## ការជម្រុញអោយមានសន្តិភាព៖ តើវិធានការជម្រុញអោយមានសន្តិភាពដូចគ្នានឹងការរក្សាសន្តិភាពដែរឬទេ?

នៅក្នុងករណីនៃវិធានការជម្រុញសន្តិភាព ក្រុមប្រឹក្សាសន្តិសុខផ្តល់នូវសិទ្ធិអំណាចដល់រដ្ឋជាសមាជិកដើម្បីចាត់វិធានការដ៏ចាំបាច់ទាំងឡាយដើម្បីធ្វើឲ្យសម្រេចនូវគោលបំណង ដែលបានកំណត់។ ការព្រមព្រៀងរបស់ភាគីមិនមែនជាការចាំបាច់នោះទេ។ វិធានការជម្រុញអោយមានសន្តិភាពត្រូវបានប្រើប្រាស់នៅក្នុងករណីមួយចំនួនតូច។ ឧ.ដូចជាសង្គ្រាមនៅក្នុងឈូងសមុទ្រ ប្រទេសសូម៉ាលី ប្រទេសរ៉្វាន់ដា ប្រទេសហៃទី បូស្នៀ និង ហឺហ្ស៊ីហ្គូវីណា អាល់បានី និងទីម័រខាងកើត។ ប្រតិបត្តិការជម្រុញសន្តិភាពទាំងនេះមិនមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិនោះទេ។ ផ្ទុយទៅវិញវាស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់ ដោយប្រទេសមួយ ឬក្រុមមួយនៃប្រទេសមួយចំនួន ដូចជា ប្រទេសអូស្ត្រាលីជួយនៅក្នុងប្រទេសទីម័រខាងកើត (១៩៩៩) អង្គការណាតូនៅក្នុងប្រទេសបូស្នៀ និងហឺហ្ស៊ីហ្គូវីណា (ពីឆ្នាំ ១៩៩៥) និងនៅក្នុងប្រទេសកូសូវ៉ូ (១៩៩៩) ដែលអង្គការណាតូជាអ្នកដឹកនាំទ័ព ហើយអង្គការសហប្រជាជាតិដឹកនាំបេសកកម្មរដ្ឋបាលបណ្តោះអាសន្ន។

បទបញ្ញត្តិនៃធម្មនុញ្ញអង្គការសហប្រជាជាតិស្តីពីការរក្សាសន្តិភាព និង សន្តិសុខអន្តរជាតិគឺជាមូលដ្ឋានគ្រឹះសម្រាប់ទាំងការរក្សាសន្តិភាពផង និងវិធានការជម្រុញអោយមានសន្តិភាពផង។

### ការកសាងសន្តិភាព

ការកសាងសន្តិភាព សំដៅលើសកម្មភាពទាំងឡាយណា ដែលមានគោលបំណងជួយប្រទេសមួយឲ្យមានសន្តិភាពលូតលាស់ឡើងក្រោយជម្លោះ។ ប្រតិបត្តិការបែបនោះ មានអាណត្តិទូលំទូលាយខ្លាំងណាស់ពីព្រោះប្រតិបត្តិការទាំងនេះមានភារកិច្ចស្តារ និងកសាងរដ្ឋឡើងវិញ។

### បេសកកម្មមនុស្សធម៌

បេសកកម្មទាំងនេះមានគោលបំណងផ្តល់នូវជំនួយមនុស្សធម៌ នៅក្នុងករណីនៃសង្គ្រាមស៊ីវិល គ្រោះទុរភិក្ស និង គ្រោះមហន្តរាយធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងរំជួយផែនដីជាដើម។ អ្នកចូលរួមនៅក្នុងប្រតិបត្តិការទាំងនេះមាន រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ រួមគ្នាធ្វើការឆ្លើយតបផ្ទួនៗគ្នា ចំពោះគ្រោះអាសន្នដែលមានលក្ខណៈស្មុគ្រស្មាញទាំងនេះដែលពេលខ្លះ ក៏មានការជួយភស្តុភាពីកងកម្លាំងយោធាក្នុងការ អនុវត្តដែលជាវិធីតែមួយគត់ក្នុងការធានានូវកម្មវិធីជួយសង្គ្រោះទាំងនេះ។

*ប្រភព៖ គេហទំព័រអង្គការសហប្រជាជាតិ៖ http://www.un.org*

មានការលើកឡើងថា វាអាស្រ័យលើរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងការចូលរួមជាមួយសភាឲ្យបានច្រើនតាមដែលអាចធ្វើបាន នៅក្នុងដំណើរការនៃការបញ្ជូនទ័ពទៅបរទេសដោយហេតុថាការពិភាក្សាដេញដោល និង បោះឆ្នោតដោយសភា វាលើកកម្ពស់នូវភាពស្របច្បាប់តាមបែបប្រជាធិបតេយ្យរបស់បេសកកម្ម និង បង្កើននូវការគាំទ្រពីប្រជាពលរដ្ឋ។

## ការចូលរួមរបស់សភានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត អំពីការបញ្ជូនទ័ពទៅបរទេស

ទោះបីជាការបញ្ជូនទ័ពទៅបរទេស កាន់តែមានសារៈសំខាន់ខ្លាំងឡើងៗយ៉ាងណាក៏ដោយ នៅក្នុងបរិបទនៃការដោះស្រាយជាមួយការគម្រាមកំហែងថ្មីៗ និង លទ្ធភាពក្នុងការដោះស្រាយនូវវិបត្តិអន្តរជាតិតួនាទីរបស់សភានៅក្នុងរដ្ឋខ្លះនៅមានកម្រិត ហើយពេលខ្លះមិនមានទាល់តែសោះទាក់ទងនឹងការអនុម័តយល់ព្រមលើការចូលរួមនៅក្នុងបេសកកម្មសន្តិភាព។ បញ្ហានេះអាច និងគួរតែធ្វើការផ្លាស់ប្តូរយ៉ាងហោចណាស់មួយផ្នែក វាបានជួយធានានូវការត្រួតពិនិត្យតាមដានតាមបែបប្រជាធិបតេយ្យនៅក្នុងបញ្ហាសន្តិសុខផងដែរ។

មានស្ថានភាព ៣ខុសៗគ្នា ដែលស្ថានភាពនីមួយៗត្រូវមានការចូលរួមដោយផ្ទាល់ពីសភាដើម្បីអភិបាលកិច្ចល្អ។

### ការអនុម័តយល់ព្រមពីសភាមុន និងក្រោយ (តួនាទីដ៏សំខាន់)

ប្រសិនជាមានតំរូវការជាមុនចាំបាច់ ត្រូវអោយសភាអនុម័តយល់ព្រមក្នុងការបញ្ជូនកងកម្លាំងប្រដាប់អាវុធទៅក្រៅប្រទេស។ មានភាពខុសគ្នាបន្តិចរវាងស្ថានភាពដែលសភាមានអំណាចធ្វើការពិភាក្សាដេញដោល និងធ្វើការបោះឆ្នោតអនុម័តលើប្រធានបទនេះ (ដូចជា សហរដ្ឋអាមេរិក) ជាមួយនឹងករណីនៅពេលដែលវាជាកាតព្វកិច្ចដែលត្រូវអនុម័តច្បាប់ពិសេស ដែលមានចែងអំពីមូលហេតុ និងអាណត្តិសម្រាប់បេសកកម្មបែបនោះ (ប្រទេសស៊ុយអែត)។ ករណីទាំង២បង្កើតបានជាភាពស្របច្បាប់នៃអន្តរាគមន៍មនុស្សធម៌ និងបេសកកម្មរក្សាសន្តិភាពតាមបែបប្រជាធិបតេយ្យ។

ពេលវេលាសំខាន់ខ្លាំងណាស់នៅក្នុងបញ្ហាការពារជាតិ ហើយនីតិវិធីរបស់សភា ជាទូទៅមិនលឿននោះទេ ដូច្នេះលក្ខខណ្ឌឲ្យមានការអនុម័តជាមុនដោយសភាជានិច្ចវាពិបាកអនុវត្តតាម។ ហេតុដូច្នេះហើយ នៅក្នុងករណីភាគច្រើន បានជាមានការចូលរួមពីសភាជាខាងក្រោយនៅក្នុងដំណើរការនៃការតាំងពង្រាយទ័ពនៅឯបរទេស។ ឧ. នៅក្នុង "សេចក្តីសម្រេចអំណាចធ្វើសង្គ្រាម" របស់សហរដ្ឋអាមេរិក សភាត្រូវតែឯកភាពយល់ព្រមជាក្រោយរាល់ការបញ្ជូនទ័ពទាំងអស់ទៅបរទេសក្នុងរយៈពេលលើសពី៩២ថ្ងៃ។ ជាពិសេសសម្រាប់ពេលខ្លះទ័ពត្រូវបានបញ្ជូនរួចទៅហើយមុនសភាអាចផ្តល់នូវការយល់ព្រមរបស់ខ្លួន។ ផ្ទុយទៅវិញ នៅក្នុងប្រទេសហ្វាំងឡង់ មាត្រា១០០នៃរដ្ឋធម្មនុញ្ញបានអំពាវនាវឲ្យមានការធ្វើសហប្រតិបត្តិការជាមុនរវាងសភា និងរដ្ឋាភិបាលទាក់ទង

នឹងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវបញ្ជូនចេញទៅបរទេសដោយចែងថា សភាត្រូវទទួលបាននូវរាល់ព័ត៌មានដ៏ចាំបាច់ទាំងអស់ជាមុន ទាក់ទងនឹងការតាំងពង្រាយកងទ័ពសម្រាប់ជម្រុញ និងលើកកម្ពស់ការ អនុវត្តច្បាប់ និងសណ្តាប់ធ្នាប់អន្តរជាតិ។ មាត្រានេះក៏មានចែងអំពីជំនួយមនុស្សធម៌នៅក្នុងករណីមានជម្លោះប្រដាប់អាវុធកើតឡើង។

## តួនាទីរបស់សភាមានកម្រិត នៅក្នុងការពិភាក្សាដេញដោលលើបញ្ហាបញ្ជូនទ័ពទៅបរទេស (តួនាទីមានកម្រិត)

រដ្ឋធម្មនុញ្ញ ឬច្បាប់កំហិត (restrict) នូវតួនាទីរបស់សភា។ សភាត្រូវបានអនុញ្ញាតឲ្យធ្វើការពិភាក្សាដេញដោលលើការបញ្ជូនទ័ពទៅបរទេស នៅក្នុងករណីជាក់ស្តែងតែមិនអាចផ្លាស់ប្តូរសេចក្តីសម្រេចចិត្តរបស់នីតិប្រតិបត្តិនោះទេ។ លើសពីនេះសភាមិនអាចបោះឆ្នោតលើប្រធានបទនេះថែមទៀតផង។ ក្នុងករណីនេះ រដ្ឋាភិបាលគ្រាន់តែជូនដំណឹងទៅសភាជាការស្រេច។ ទោះបីជាសភាមិនអាចបោះឆ្នោតលើសេចក្តីសម្រេច ដែលពាក់ព័ន្ធតែការពិភាក្សាដេញដោលបែបនេះ វាជួយលើកស្ទួយភាពស្របច្បាប់ នៃការបញ្ជូនទ័ពទៅបរទេសតាមបែបប្រជាធិបតេយ្យ។

នៅក្នុងករណីដែលអំណាចសភាមានការរិតត្បិតខ្លាំង សភាមិនអាចដឹងជាផ្លូវការអំពីនីតិវិធីនៃការបញ្ជូនទ័ពទៅបរទេសនោះទេ។ ទោះដូច្នេះក្តីការអនុវត្តជាទម្លាប់នៅក្នុងប្រទេសខ្លះ វាមានការពិភាក្សាដេញដោលគ្នារវាងសភា និងរដ្ឋាភិបាល និង ការបោះឆ្នោតអនុម័តលើការបញ្ជូនទ័ពទៅបរទេស។

## សភាមិនត្រូវបានរាប់បញ្ចូលទៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត (គ្មានតួនាទី)

ករណីនេះកើតឡើងនៅពេលដែល សភាមិនអាចគ្រាន់តែពិភាក្សាលើការបញ្ជូនទ័ពទៅបរទេសតែប៉ុណ្ណោះទេ ថែមទាំងគ្មានតម្រូវការអោយមានការអនុម័តយល់ព្រមបន្ទាប់ពីការបញ្ជូនទ័ពទៅបរទេស។ ការបញ្ជូនទ័ពទៅបរទេសត្រូវបានចាត់ទុកថាជាសេចក្តីសម្រេចគោលនយោបាយការបរទេសដ៏សំខាន់ និងសេចក្តីសម្រេច ដែលជាកម្មសិទ្ធិផ្តាច់មុខរបស់អង្គនីតិប្រតិបត្តិ។ នេះគឺថាសភា មិនចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដែលនេះវាធ្វើឲ្យសភាមិនអាចធ្វើការត្រួតពិនិត្យបេសកកម្មរក្សាសន្តិភាពរបស់រដ្ឋាភិបាលបាន។

## មធ្យោបាយដទៃទៀតដែលសភាអាចប្រើបាន

សូម្បីសភា មិនត្រូវបានគេបញ្ចូលទៅក្នុងដំណើរការនៃការធ្វើ សេចក្តីសម្រេចចិត្តយ៉ាងណាក៏ដោយ ឬគ្រាន់តែអាចមានតួនាទីខ្លះក៏ដោយ ក៏សភាអាចដាក់សម្ពាធដោយប្រយោលលើរដ្ឋាភិបាលយ៉ាងហោចណាស់តាមវិធី ៤យ៉ាង៖

- ✓ សភាអាចបង្ខំអង្គការនីតិប្រតិបត្តិឲ្យធ្វើការពន្យល់ អំពីការទទួលខុសត្រូវរបស់ពួកគេនៅចំពោះមុខសភា សម្រាប់ការសម្រេចចិត្តបញ្ជូនទ័ពទៅបរទេស។ ទោះដូច្នោះក្តី ប្រសិនបើសភាមិនត្រូវបានជម្រាបពេញលេញ អំពីកិច្ចព្រមព្រៀងអន្តរជាតិរបស់រដ្ឋាភិបាលទេនោះ សភាមិនអាចតវ៉ាប្រកបដោយប្រសិទ្ធភាពលើសេចក្តីសម្រេចរបស់រដ្ឋាភិបាលនោះឡើយ។
- ✓ សភាអាចតវ៉ាជាមួយអង្គនីតិប្រតិបត្តិនៅពេលមានការស្នើសុំកែសម្រួលថវិកា។ ក្នុងករណីដែលមានបេសកកម្ម រក្សាសន្តិភាពដែលមិនបានគ្រោងទុក ឬរំពឹងទុក សភាត្រូវបានស្នើសុំឲ្យធ្វើការអនុម័តយល់ព្រមលើមូលនិធិបន្ថែម ដែលមិនបានបញ្ចូលនៅក្នុងថវិកា ដែលបានសម្រេចហើយ។ ដូច្នេះសភាមានលទ្ធភាពបញ្ចេញមតិតាមរយៈ អំណាចកាបូបដាក់ប្រាក់ (ឧ. ប្រទេសបារាំង)។
- ✓ ការចូលរួមរបស់សភាមិនមែនសំខាន់ត្រឹមក្នុងអំឡុងពេលពិភាក្សាដេញដោលនិងបោះឆ្នោតបញ្ជូនទ័ពទៅបរទេសនោះទេ។ ក្នុងអំឡុងនៃបេសកកម្មរក្សាសន្តិភាពតំណាងរាស្ត្រអាចចោទសំណួរ ឬប្រើប្រាស់ម៉ោងសួរឆ្លើយដើម្បីចោទសួររដ្ឋាភិបាលក៏បានដែរ ទាក់ទងនឹងបេសកកម្មនេះ។ ក្រៅពីនេះ តំណាងរាស្ត្រអាចចុះត្រួតពិនិត្យទ័ពនៅឯបរទេសថែមទៀតផង (សូមអានជំពូកទី ១៧)។
- ✓ យោងតាមទស្សនៈ គណនេយ្យភាពក្រោយបេសកកម្មក្រោយពីបេសកកម្មរក្សាសន្តិភាពត្រូវបានបញ្ចប់សភាអាចធ្វើការចោទសួរ ឬសុំឲ្យរដ្ឋាភិបាលធ្វើការវាយតម្លៃអំពីបេសកកម្មរក្សាសន្តិភាពរបស់ខ្លួន។

**ប្រអប់ទី ៤៨**

### ដំណើរការតាំងពង្រាយទ័ព រក្សាសន្តិភាពអង្គការសហប្រជាជាតិជាជំហានៗ

អង្គការសហប្រជាជាតិមិនមានកងទ័ពនោះទេ។ ប្រតិបត្តិការរក្សាសន្តិភាពនីមួយៗ ត្រូវបានគេរៀបចំឡើងដើម្បីបំពេញតាមលក្ខខណ្ឌនៃស្ថានភាពថ្មីនីមួយៗ និង ទៅតាមការអំពាវនាវពីក្រុមប្រឹក្សាសន្តិសុខ។ សមាសភាពរបស់វាកើតឡើង "ពីបាតដៃទទេ"។

សមាជិកទាំង ១៥រូប របស់ក្រុមប្រឹក្សាសន្តិសុខផ្តល់សិទ្ធិអំណាចឲ្យមានការតាំងពង្រាយប្រតិបត្តិការរក្សាសន្តិភាព និង ជាអ្នកកំណត់នូវអាណត្តិរបស់បេសកកម្មនេះ។ សេចក្តីសម្រេចបែបនេះតម្រូវឲ្យមានសម្លេងឆ្នោតយ៉ាងតិចបំផុត៩សម្លេងគាំទ្រ ហើយត្រូវមិនមានការបោះឆ្នោតអវិជ្ជមានពីសមាជិកអចិន្ត្រៃយ៍ទាំង៥របស់ក្រុមប្រឹក្សា (មានប្រទេសចិន បារាំង សហព័ន្ធរុស្ស៊ី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក)។ អគ្គលេខាធិការចេញអនុសាសន៍ពីរបៀបដែលប្រតិបត្តិការត្រូវអនុវត្តដូចម្តេចខ្លះ និងរបៀបធ្វើរបាយការណ៍អំពីវឌ្ឍនភាពរបស់ប្រតិបត្តិការនោះ។ ផ្នែកប្រតិបត្តិការរក្សាសន្តិភាព (DPKO) ទទួលខុសត្រូវចំពោះការដឹកនាំផ្នែកប្រតិបត្តិការគ្រប់គ្រង និងការជួយ

គាំទ្រផ្នែកភស្តុភាប្រចាំថ្ងៃ សម្រាប់ប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ នៅទូទាំងពិភពលោក។

អគ្គលេខាធិការជ្រើសរើសមេបញ្ជាការទ័ព និងស្នើសុំឲ្យរដ្ឋជាសមាជិករួមវិភាគទានទ័ពនគរបាលស៊ីវិល ឬ បុគ្គលិកដទៃទៀត។ រដ្ឋជាសមាជិក ឬ ក្រុមហ៊ុនឯកជនក៏ចូលរួមផ្តល់នូវគ្រឿងបរិក្ខាឧបករណ៍ ការដឹកជញ្ជូន និង ការគាំទ្រភស្តុភាផ្សេងៗផងដែរ។ បុគ្គលិកគាំទ្រស៊ីវិល ក្នុងនោះមានបុគ្គលិកដែលត្រូវបានតែងតាំងពីក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ក៏ត្រូវបានសុំខ្ចីដោយរដ្ឋជាសមាជិក រួមទាំងបុគ្គលដែលបានជ្រើសរើសជាអន្តរជាតិ ឬ ក្នុងស្រុកដើម្បីបំពេញបេសកកម្មជាក់លាក់ផងដែរ។

ពេលវេលាដែលតម្រូវឲ្យមានការតាំងពង្រាយបេសកកម្មមានមិនដូចគ្នា ហើយវាអាស្រ័យសំខាន់លើឆន្ទៈរបស់រដ្ឋជាសមាជិកក្នុងការរួមចំណែកទ័ពដល់ប្រតិបត្តិការនោះ។ ពេលវេលាសម្រាប់ផ្តល់ធនធាន ហិរញ្ញវត្ថុ និងសមត្ថភាពជាយុទ្ធសាស្ត្រក៏អាចប៉ះពាល់ដល់ប្រតិបត្តិការនេះផងដែរ។ ឧទាហរណ៍ក្នុងឆ្នាំ១៩៧៣ បុគ្គលិករបស់កងជំនួយសង្គ្រោះបន្ទាន់របស់អង្គការសហប្រជាជាតិទី២ (UNEF II) ត្រូវបានតាំងពង្រាយនៅក្នុងមជ្ឈិមបូព៌ាក្នុងរយៈពេល២៤ម៉ោង។ ទោះដូច្នេះក្តីសម្រាប់បេសកកម្មខ្លះដែលមានអាណត្តិស្មុគស្មាញ ឬមានការលំបាកខាងភស្តុភា ឬ អ្នករក្សាសន្តិភាពជួបប្រទះនូវហានិភ័យខ្ពស់ វាអាចចំណាយពេលរាប់ខែដើម្បីប្រមូលផ្តុំ និងតាំងពង្រាយបុគ្គលិកដ៏ចាំបាច់ទាំងនោះ។

*ប្រភព៖ គេហទំព័រអង្គការសហប្រជាជាតិ៖ http://www.un.org*

**ប្រអប់ទី ៤៩**

**វិធានទាក់ទងការចូលរួមនៅក្នុងបេសកកម្មរក្សាសន្តិភាព**

នៅពេលដែលសភា ផ្តល់សិទ្ធិអំណាចឲ្យបញ្ជូនទ័ពទៅបរទេស សភាក៏អាចកំណត់កម្រិតនៃកងកម្លាំង ដែលត្រូវអនុញ្ញាតឲ្យប្រើប្រាស់នៅក្រោមកាលៈទេសៈអ្វីខ្លះ មានន័យថាសភាកំណត់នូវវិធាននៃការចូលរួម។

យើងយល់ថាតាមរយៈវិធាននៃការចូលរួម (ROE) មានការដាក់កម្រិតដល់អ្នករក្សាសន្តិភាពឲ្យបញ្ចៀសនូវប្រតិបត្តិការដែលបណ្តាលឲ្យបាត់បង់ជីវិត។ បញ្ហានេះ ត្រូវសម្រេចជាលក្ខណៈបុគ្គល និង ព្យាយាមកាត់បន្ថយឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយអនុញ្ញាតឲ្យអ្នករក្សាសន្តិភាពធ្វើការការពារខ្លួនគេ។ គោលការណ៍គ្រឹះ នៃការការពារខ្លួនត្រូវតែមានសុពលភាព។

ROE គឺជាកត្តាគាំទ្របុគ្គលិករក្សាសន្តិភាព ក៏ដូចជាប្រតិបត្តិការ ឬការកំណត់យុទ្ធសាស្ត្ររបស់ពួកគេ។ យុទ្ធសាស្ត្រទាំងនេះ ត្រូវតែមានការរៀបចំយ៉ាងប្រុងប្រយ័ត្នដើម្បីឲ្យវាអនុលោមតាមប្រតិបត្តិការ និងគោលនយោបាយ ក៏ដូចជា លិខិតបទដ្ឋានគតិយុត្តជាអន្តរជាតិ ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិជាដើម។

ROE ត្រូវមានចែងនូវលក្ខខណ្ឌវិនិច្ឆ័យ ដែលគួសបញ្ជាក់យ៉ាងច្បាស់នូវការប្រើប្រាស់ទ័ពច្រើនឡើងៗ ដើម្បីធ្វើឲ្យមានតុល្យភាពដ៏ចាំបាច់រវាងការបញ្ឈប់ការបង្កើន ឬការដោះស្រាយការប្រឈមមុខដាក់គ្នា។ ការកំណត់ ROE ទាក់ទងនឹងការបង្កើនការឆ្លើយតប វាជួយឲ្យមានការតាំងពង្រាយទ័ពដ៏ចាំបាច់ ដើម្បីបំពេញតាមកម្រិតផ្សេងៗនៃអំពើហិង្សា ទន្ទឹមនោះវាជួយកាត់បន្ថយនូវគ្រោះថ្នាក់ផ្សេងៗ។ ក្នុងន័យនេះ ROE អាចចែងនូវការប្រើប្រាស់ទ័ពក្នុងកម្រិតដូចខាងក្រោម (ចាប់ពីតិចបំផុតទៅច្រើនបំផុត)៖

- សម្រាប់តែការការពារខ្លួនទ័ពតែប៉ុណ្ណោះ។
- ការការពារខ្លួនទ័ព រួមទាំងការការពារជីវិតរបស់ជនស៊ីវិល។
- ការពារខ្លួនទ័ព ជីវិតរបស់ជនស៊ីវិល និង ការពារនូវទីតាំងសំខាន់ៗ (ឧ. មន្ទីរពេទ្យ ស្ពាន ។ល។)
- ការប្រើប្រាស់នូវវិធានការដ៏ចាំបាច់ទាំងអស់ ដើម្បីធានាឲ្យមានការធ្វើឲ្យសម្រេចនូវគោលបំណងរបស់ប្រតិបត្តិការ។

ទន្ទឹមនោះ ROE គួរបញ្ចូលនូវប្រភេទនៃអាវុធ ដែលអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងប្រតិបត្តិការរក្សាសន្តិភាពមួយៗ។ លក្ខខណ្ឌអាចចាប់ ពីគ្មានអាវុធទាល់តែសោះ រហូតដល់ការប្រើប្រាស់នូវអាវុធធន់ធ្ងន់រួមទាំងនាវា យន្តហោះ និងបច្ចេកវិទ្យាមីស៊ីល។

## ការបណ្តុះបណ្តាលទាហានសម្រាប់រក្សាសន្តិភាព

ការចូលរួមនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព គឺជាភារកិច្ចដ៏ធ្ងន់ធ្ងរសម្រាប់កងកម្លាំងយោធា ហើយវាទាមទារនូវការហ្វឹកហ្វឺនបំប៉នបន្ថែម និងការណែនាំថែមពីលើការត្រៀមរៀបចំទ័ពឲ្យស្របតាមស្តង់ដារ។

ការហ្វឹកហ្វឺនបំប៉ននេះជាការចាំបាច់ ដូចជា ជំនាញពិសេសខាងដោះមីនសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយជនស៊ីវិលរួមទាំងជំនាញសមាធិជាក់ស្តែង (ក៏ដូចជា ចំណេះដឹងខាងផ្នែកភាសាអ្នកស្រុក) ចំណេះដឹងអំពីប្រពៃណី និងទំនៀមទម្លាប់របស់អ្នកស្រុកការយល់ដឹងយ៉ាងច្បាស់អំពីច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្ស និងជាពិសេសត្រូវមានចំណេះដឹងជ្រៅជ្រះ អំពីវិធាននៃការចូលរួមនៅក្នុងបេសកកម្មនីមួយៗ។ ទាក់ទងនឹងចំណុចចុងក្រោយនេះ វាសំខាន់ខ្លាំងណាស់ក្នុង

ការគួសបញ្ជាក់ថា នៅក្នុងបេសកកម្មរក្សាសន្តិភាព ជាធម្មតាការប្រើប្រាស់កម្លាំងទ័ពត្រូវបានរិតត្បិត ហើយក្នុងករណីខ្លះ កម្លាំងយោធាមិនកាន់អាវុធទាល់តែសោះ។

តម្រូវការនូវការហ្វឹកហ្វឺនពិសេសក៏ចាំបាច់ផងដែរ នៅក្នុងដំណាក់កាលរៀបចំផែនការដែលកងកម្លាំងប្រដាប់អាវុធពាក់ព័ន្ធនៅក្នុងបេសកកម្មរក្សាសន្តិភាព ជាញឹកញាប់ត្រូវបានពង្រាយឆ្ងាយពីប្រទេស នៅក្នុងទីកន្លែងដ៏លំបាកដែលមិនបានគិតដល់។ នៅក្នុងកាលៈទេសៈបែបនេះ ការដឹកជញ្ជូន និងការផ្គត់ទ័ពពិតជាការប្រឈមដ៏លំបាក ហើយក្នុងកាលៈទេសៈខ្លះពួកគេមានសម្ភារៈឧបករណ៍ត្រូវយកតាមខ្លួនជាច្រើនថែមទៀត។

ជាចុងក្រោយការហ្វឹកហ្វឺន និងត្រៀមខ្លួនបន្ថែមក៏ជាការចាំបាច់ផងដែរ នៅដំណាក់កាលបញ្ហា និងផ្គត់ផ្គង់ភស្តុភា។ នៅពេលដែលទ័ពនៃប្រទេសជាច្រើនធ្វើប្រតិបត្តិការនៅក្នុងតំបន់តែមួយនៅក្រោមការត្រួតពិនិត្យរួមខ្សែចង្វាក់ នៃការបញ្ជាជាប្រពៃណីពីក្រសួងការពារជាតិត្រូវផ្លាស់ប្តូរ។ ការសម្របសម្រួលរវាងកងកម្លាំងប្រដាប់អាវុធនៃប្រជាជាតិផ្សេងៗនិងអង្គការផ្សេងៗ ដូចជា គណៈកម្មការកាកបាតក្រហមអន្តរជាតិ រិតតែមានសារៈសំខាន់ខ្លាំងឡើង។

នៅក្នុងករណីដែលបេសកកម្មរក្សាសន្តិភាព ដឹកនាំដោយអង្គការសហប្រជាជាតិការបញ្ជាទ័ពមានការលំបាក មិនត្រឹមតែដោយសារសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សារក្សាសន្តិសុខប៉ុណ្ណោះនោះទេ តែដោយសារវិធាននៃការចូលរួម វិធានប្រតិបត្តិរបស់អង្គការសហប្រជាជាតិ និងក្រមសីលធម៌អង្គការសហប្រជាជាតិ រួមទាំងលក្ខខណ្ឌរដ្ឋបាលទាំងឡាយ ទាក់ទងនឹងកងកម្លាំងពហុជាតិរបស់អង្គការសហប្រជាជាតិទៀតផង។

**ប្រអប់ទី ៥០**

## ការហ្វឹកហ្វឺនរបស់អង្គការសហប្រជាជាតិចំពោះអ្នករក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

អង្គភាពហ្វឹកហ្វឺនមួយ ដែលបានបង្កើតនៅក្នុងផ្នែកប្រតិបត្តិការរក្សាសន្តិភាពរបស់លេខាធិការដ្ឋាន ជាអ្នកផ្តល់ការណែនាំ អ្នកជំនាញ និងព័ត៌មានផ្សេងៗដល់រដ្ឋជាសមាជិកអំពីការហ្វឹកហ្វឺនអ្នករក្សាសន្តិភាព។ អង្គភាពនេះឮជាអ្នករៀបចំនូវកម្មវិធី និងឯកសារបណ្តុះបណ្តាលដែលមានគោលបំណងពង្រីកចំណេះដឹង និង នីតិវិធីប្រតិបត្តិតាមស្តង់ដារដែលទទួលបានពីបទពិសោធន៍ប្រតិបត្តិការរក្សាសន្តិភាពដែលមានរយៈពេលរាប់ឆ្នាំ។ អង្គភាព ហ្វឹកហ្វឺនសហការជាមួយសាលាយោធា និងស្ថាប័នបណ្តុះបណ្តាល ថ្នាក់ជាតិ និងតំបន់នៅក្នុងប្រទេសជាច្រើន និងជាមួយបេសកកម្មរក្សាសន្តិភាព។ ក្រុមជំនួយបណ្តុះបណ្តាលសហប្រជាជាតិនិងវគ្គ" គ្រូបណ្តុះបណ្តាលបន្ត" ត្រូវបានបង្កើតឡើងដើម្បីជួយរដ្ឋជាសមាជិក នៅក្នុងការរៀបចំ និងអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលស្តីពីការរក្សាសន្តិភាព។ ក្រមសីលធម៌ និងសៀវភៅណែនាំ និងមេរៀនដទៃទៀតត្រូវបានរៀបចំឡើងជាលក្ខណៈស្តង់ដារដើម្បី ផ្តល់ការហ្វឹកហ្វឺនដល់អ្នករក្សាសន្តិភាពទាំងឡាយ។

*ប្រភព៖ គេហទំព័រអង្គការសហប្រជាជាតិ៖ http://www.un.org*

## លក្ខខណ្ឌវិនិច្ឆ័យសម្រាប់បញ្ជូនទ័ពចូលរួមក្នុងបេសកកម្មមនុស្សធម៌នៅឯបរទេស

សភា និងរដ្ឋាភិបាលអាចរៀបចំជាលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ បញ្ជូនទ័ពទៅបរទេស។ ការប្រើប្រាស់នូវលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ វាបង្កើននូវតម្លាភាពនៃដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត ដែលជាលទ្ធផលវាអាចបង្កើននូវការគាំទ្រពីសាធារណៈ ចំពោះប្រតិបត្តិការរក្សាសន្តិភាព។ មានលក្ខខណ្ឌវិនិច្ឆ័យ ២សំខាន់ (សូមអានប្រអប់ខាងក្រោម)។ លក្ខខណ្ឌវិនិច្ឆ័យទី១ ពាក់ព័ន្ធ ជាមួយបរិបទនយោបាយ និងប្រភេទប្រតិបត្តិការ។ លក្ខខណ្ឌវិនិច្ឆ័យទី២ ពាក់ព័ន្ធជាមួយបេសកកម្ម អាណត្តិ ការបញ្ជា រយៈពេល និងប្រភេទនៃទ័ពដែលត្រូវបញ្ជូន។

### ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

#### លក្ខខណ្ឌទូទៅពាក់ព័ន្ធជាមួយបរិបទ និងប្រភេទនៃបេសកកម្មរក្សាសន្តិភាព

▷ សភា ឬគណៈកម្មការមានសមត្ថកិច្ចរបស់សភាត្រូវសិក្សា ឬពិនិត្យមើលៈ

- ការប្តេជ្ញាចិត្តជាអន្តរជាតិរបស់រដ្ឋ។
- ភាពសមស្របនៃការបញ្ជូន/ទទួលទ័ពចូលរួមនៅក្នុងបេសកកម្មសន្តិភាព។
- មូលហេតុ ឬប្រវត្តិទាក់ទងនឹងអន្តរាគមន៍ពិសេសណាមួយ (ឧ. ការរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសមានវិបត្តិនោះ)។
- បង្កើតនូវលក្ខខណ្ឌការងារ (ToR) សម្រាប់បេសកកម្មសន្តិភាពថ្នាក់តំបន់ ឬសាកលលោក។
- វិធានជាមូលដ្ឋាននៃការចូលរួមរបស់ទាហាននៅក្នុងបេសកកម្មសន្តិភាពតំបន់ ឬសាកលលោក។
- ការប្រើប្រាស់ដ៏សមស្របនូវកម្លាំងយោធា។
- ការបង្កើតសេចក្តីសម្រេចចិត្តផ្នែកនយោបាយដ៏មានប្រសិទ្ធភាព។
- ការកម្រិតនូវសិទ្ធិអំណាចរបស់រដ្ឋ។
- ការគាំទ្ររបស់សាធារណជន ឬមិនគាំទ្រចំពោះការចូលរួមនៅក្នុងបេសកកម្មសន្តិភាព។
- នីតិវិធីវាយតម្លៃ និងគោលការណ៍ផ្សេងៗពាក់ព័ន្ធជាមួយការពិនិត្យតាមដានបន្ត។
- ភាពចាំបាច់របស់សភាក្នុងការទទួលនូវព័ត៌មានពេញលេញនៅពេលបញ្ចប់បេសកកម្ម ដើម្បីសិក្សាឡើងវិញអំពីបេសកកម្មសន្តិភាពទាំងមូល។

#### លក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ពាក់ព័ន្ធជាមួយបេសកកម្មសន្តិភាព

▷ សភា និងគណៈកម្មការមានសមត្ថកិច្ចរបស់សភាត្រូវពិនិត្យមើលនូវបញ្ហាដូចខាងក្រោមៈ

- និយមន័យវិសាលភាព និងអាណត្តិរបស់បេសកកម្មសន្តិភាព។
- ប្រភេទនៃអង្គភាពយោធាដែលត្រូវចូលរួម។
- លទ្ធភាពរបស់យោធានៅក្នុងបេសកកម្ម។
- តម្រូវការនិងលទ្ធភាព(Suitability and availability) នៃអង្គភាពនិងសម្ភារៈយោធា។
- រយៈពេលរំពឹងទុកនៃប្រតិបត្តិការ និងលក្ខខណ្ឌវិនិច្ឆ័យដែលត្រូវបំពេញទាក់ទងនឹងការពន្យាបេសកកម្មប្រសិនបើចាំបាច់។
- បញ្ហាថវិកា
- ប្រតិកម្មរបស់សាធារណជនចំពោះបេសកកម្ម។

### ប្រើប្រាស់នីតិវិធីរបស់សភា ពាក់ព័ន្ធនឹងបេសកកម្មសន្តិភាព

▷ ប្រសិនបើចាំបាច់ សភាអាចៈ
- រៀបចំសវនការសាធារណៈអំពីបេសកកម្មសន្តិភាព។
- សាកសួរបន្ថែមអំពីការអនុវត្តបេសកកម្មសន្តិភាព។
- ស្នើសុំឲ្យមានការនាំខ្លួនបុគ្គលិកដែលពាក់ព័ន្ធនៅក្នុងបេសកកម្មសន្តិភាពដែលសង្ស័យថារំលោភសិទ្ធិមនុស្សឲ្យឡើងមកបកស្រាយ។

▷ កុំរុញរាក្នុងការប្រើប្រាស់នីតិវិធីចោទសួរ និងសវនការសភាពាក់ព័ន្ធជាមួយបេសកកម្មសន្តិភាពដែលកំពុងអនុវត្ត។

# ផ្នែកទី VI

# ធនធានហិរញ្ញវត្ថុ៖
# ការធ្វើឲ្យសម្រេចបាននូវការត្រួតពិនិត្យថវិកា
# ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខប្រកបដោយប្រសិទ្ធភាព

# ជំពូកទី ២៣

# សន្តិសុខ និងអំណាចឃ្លាំងប្រាក់

## សភា និង ដំណើរការការចាត់ចែងថវិកាពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ

គ្រប់ទីកន្លែងនៅក្នុងពិភពលោក តាមច្បាប់សភាមានតួនាទីគន្លឹះមួយនៅក្នុងការអនុម័ត និងត្រួតពិនិត្យការផ្តល់ថវិកាពាក់ព័ន្ធជាមួយវិស័យសន្តិសុខ ទោះបីជាតួនាទីនេះ មានមិនដូចគ្នាពីប្រទេសមួយទៅប្រទេសមួយ ដោយសារតែបញ្ហានយោបាយ ឬលទ្ធភាពបំពេញតួនាទីរបស់សភាខុសៗគ្នាក៏ដោយ។ ជាញឹកញាប់និងជាក់ស្តែង សភាមិនមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្ត ហើយវិធានការរបស់ពួកគេត្រូវបានរាំងដោយការសម្ងាត់ និងការមិនបង្ហើបឲ្យដឹងពីការចាត់ចែងបែកចែកថវិកាទៅលើវិស័យសន្តិសុខ និងការចំណាយមួយចំនួនដែលពាក់ព័ន្ធ។ វប្បធម៌ដែលបានបង្កើតឡើងយ៉ាងយូរអង្វែងនៃអំណាចដ៏ឧត្តុង្គឧត្តមរបស់អង្គការនីតិប្រតិបត្តិ នៅក្នុងវិស័យសន្តិសុខ ជាញឹកញាប់បានរាំងវិធានការរបស់សភា ដែលធ្វើឲ្យរាល់គំនិតផ្តួចផ្តើមទាំងអស់នៃការរៀបចំរដ្ឋនៃថវិកាការពារជាតិ ធ្លាក់ចូលក្នុងដៃរបស់នីតិប្រតិបត្តិ និង កងកម្លាំងប្រដាប់អាវុធ។

ទោះដូច្នេះក្តី តំណាងរាស្ត្រមិនគួរមើលស្រាលលើអំណាចចេញសេចក្តីសម្រេចលើថវិកាជាតិនោះទេ ដោយសារវាជាឧបករណ៍មួយសម្រាប់ត្រួតពិនិត្យ និង ធ្វើកំណែទម្រង់វិស័យសន្តិសុខទៅតាមតម្រូវការរបស់សង្គមជាតិ។ "អំណាចឃ្លាំងដាក់ប្រាក់" (power of the purse) អាច និងត្រូវតែប្រើប្រាស់ ដើម្បីធានាឲ្យការប្រើប្រាស់ការចាត់ចែងបែងចែកថវិកា ប្រកបដោយគណនេយ្យភាពចំពោះសាធារណជន។

**ប្រអប់ទី ៥១**

**ថវិកា៖ ឧបករណ៍សំខាន់សម្រាប់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ**

▷ "ថវិកាជាតិមិនត្រឹមតែជាឧបករណ៍បច្ចេកទេសមួយ ដែលមានរួមបញ្ចូលប្រាក់ចំណូល និងចំណាយប៉ុណ្ណោះនោះទេ។ វាជាសេចក្តីថ្លែងការណ៍គោលនយោបាយដ៏សំខាន់មួយដែលនីតិប្រតិបត្តិធ្វើឡើងក្នុងមួយឆ្នាំៗ។ វាឆ្លុះបញ្ចាំងនូវខ្លឹមសារជាមូលដ្ឋានដែលមានចែងនៅក្នុងគោលនយោបាយជាតិ។ វាគូសបញ្ជាក់អំពីទស្សនៈរបស់រដ្ឋាភិបាល អំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ។ វាជាសេចក្តីប្រកាសមួយរបស់រដ្ឋាភិបាល អំពីគោលបំណងទាក់ទងនឹងបញ្ហាសារពើពន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ហើយវាឆ្លុះបញ្ចាំងអំពីអាទិភាពសង្គម និង សេដ្ឋកិច្ចរបស់រដ្ឋាភិបាល។ (...) ថវិកាក៏ជាឧបករណ៍មួយសម្រាប់វាស់វែងនូវ

ចេតនានាពេលអនាគត និងការអនុវត្តការងាររបស់រដ្ឋាភិបាលក្នុងពេលអតីតកាលផងដែរ។

▷ "ថវិកា គឺជាឯកសារដ៏សំខាន់មួយក្នុងការធានានូវ តម្លាភាព គណនេយ្យភាព ភាពគ្រប់ជ្រុងជ្រោយ និងអភិបាលកិច្ចល្អ។ តាមរយៈការពន្យល់លំអិត អំពីចំណាយដែលបានស្នើ វាអាចឲ្យសភា និងសាធារណជនទូទៅ "ដឹងថាតើប្រាក់វាទៅកន្លែងណាខ្លះ" ធ្វើដូចនេះវាបង្កើននូវតម្លាភាព។ លើសពីនេះ ថវិកាតម្រូវឲ្យមានការអនុម័តយល់ព្រមពីសភាមុនរដ្ឋាភិបាលអាចចំណាយប្រាក់ ឬបង្កើនប្រាក់ចំណូល តាមរយៈនេះវាធ្វើឲ្យរដ្ឋមន្ត្រីមានគណនេយ្យភាពចំពោះសភា និងគណៈកម្មការរបស់សភា។

▷ "តម្លាភាព និងគណនេយ្យភាព ត្រូវតែជាលក្ខខណ្ឌដែលកំណត់ដោយរដ្ឋធម្មនុញ្ញ ជាពិសេសពាក់ព័ន្ធជាមួយដំណើរការនៃថវិកាជាតិ។ រួមជាមួយតម្លាភាព នៅក្នុងដំណើរការថវិកាទាំងមូល គណនេយ្យភាពគឺជាចំណុចក្រអៅបេះដូងនៃលទ្ធិប្រជាធិបតេយ្យ"។

*សម្រង់ចេញពីរបាយការណ៍ទូទៅនៃសិក្ខាសាលា IPU ស្តីពីសភា និងដំណើរការការចាត់ចែងថវិកា រួមទាំងដកស្រង់ចេញពីសៀវភៅស្តីពីទស្សនៈយេនឌ័រ Nairobi ខែឧសភា ឆ្នាំ២០០០*

តាមពិត សភាអាចយកចិត្តទុកដាក់លើបញ្ហាសន្តិសុខ និងវិស័យសន្តិសុខនៅក្នុងដំណាក់កាលសំខាន់ៗ៤ នៃវគ្គគោលនៃការកំណត់ថវិកា៖

**ដំណាក់កាលរៀបចំថវិកា៖** ដំណាក់កាលនេះ ជាដំណាក់កាលដែលអង្គការនីតិប្រតិបត្តិស្នើសុំធ្វើការបែងចែកថវិកាសម្រាប់គោលបំណងមួយចំនួន ក៏ប៉ុន្តែសភា និងសមាជិកសភា អាចរួមវិភាគទានដល់ដំណើរការនេះតាមរយៈយន្តការផ្លូវការ និងមិនផ្លូវការមួយចំនួន។

**ដំណាក់កាលអនុម័តថវិកា៖** នៅក្នុងដំណាក់កាលនេះ សភាអាចធ្វើការសិក្សា និងកំណត់នូវការចាប់អារម្មណ៍របស់សាធារណជន និងភាពសមស្របនៃវិភាជន៍ថវិកា ហើយក្នុងករណីខ្លះ សភាអាចផ្តល់នូវយោបល់ជាក់លាក់ខ្លះ ទាក់ទងនឹងថវិកាសន្តិសុខនេះ។

**ដំណាក់កាលអនុវត្តថវិកា ឬចំណាយ៖** នៅក្នុងដំណាក់កាលនេះ សភាពិនិត្យឡើងវិញ និងធ្វើការតាមដានការចំណាយរបស់រដ្ឋាភិបាលដើម្បីពង្រឹងតម្លាភាព និងគណនេយ្យភាព។ សូមអាននូវផ្នែកពាក់ព័ន្ធខាងក្រោម។ ក្នុងករណីមានការស្នើសុំថវិកាបន្ថែម សភាធ្វើការតាមដាន និងត្រួតពិនិត្យនូវសំណើនេះ ដើម្បីទប់ស្កាត់នូវការចំណាយហៀរហួរ។

**ដំណាក់កាលធ្វើសវនកម្ម ឬសើរើរ៖** នៅក្នុងដំណាក់កាលនេះ សភាធ្វើការត្រួតពិនិត្យ ថាតើមានការប្រើប្រាស់ថវិកាដែលបានចាត់ចែងបែងចែកឲ្យត្រឹមត្រូវដែរឬយ៉ាងណា។ លើសពីនេះ សភាវាយតម្លៃជាទៀងទាត់នូវដំណើរការថវិកា និងសវនកម្មទាំងមូលដើម្បីធានានូវគណនេយ្យភាព ប្រសិទ្ធភាព និងសុក្រិតភាព។

## ការចំណាយលើវិស័យការពារជាតិ

**ប្រអប់ទី ៥២**

**ហេតុអ្វីសភាគួរចូលរួមយ៉ាងសកម្មនៅក្នុងបញ្ហាថវិកា?**

- ▷ គណបក្សប្រឆាំងអាចប្រើប្រាស់ការពិភាក្សាដេញដោលលើបញ្ហាថវិកា ដើម្បីដាក់នូវសំណើផ្សេងៗ។
- ▷ សម្លេងភាគច្រើននៅក្នុងការបោះឆ្នោតសម្រេចលើថវិកា បង្ហាញនូវទំនុកចិត្តរបស់តំណាងរាស្ត្រភាគច្រើននៅក្នុងវិធានការរបស់អង្គការនីតិប្រតិបត្តិ។
- ▷ ការត្រួតពិនិត្យថវិកា គឺជាវិធីមួយដ៏មានសារៈសំខាន់បំផុត ក្នុងការមានឥទ្ធិពលទៅលើគោលនយោបាយរបស់រដ្ឋាភិបាល។
- ▷ នៅក្រោមច្បាប់ស្តីពី ការកែសម្រួលថវិកា ច្បាប់នេះអនុញ្ញាតឲ្យនីតិប្រតិបត្តិធ្វើការទូទាត់ដោយបញ្ចប់វដ្តនៃកញ្ចប់ថវិកា។

*សម្រង់ពីរបាយការណ៍ទូទៅនៃសិក្ខាសាលាស្តីពី "សភា និងដំណើរការការចាត់ចែងថវិកា រួមទាំងពីសៀវភៅទស្សនៈយេនឌ័រ", Bamako, Mali, ខែវិច្ឆិកា ឆ្នាំ២០០១*

ប្រអប់ខាងក្រោម ពន្យល់អំពីទិដ្ឋភាពទូទៅនៃការចំណាយលើវិស័យការពារជាតិ នៅក្នុងប្រទេសផ្សេងៗនៅក្នុងពិភពលោក។ ការធ្លាក់ចុះនៅក្នុងការចំណាយខាងការពារជាតិ បានកើតឡើងនៅក្រោយយុគសម័យនៃសង្គ្រាមត្រជាក់ ដែលបង្ហាញថាប្រទេសជាច្រើនកំពុងចំណេញប្រាក់ពីរបស់ដែលហៅថា "ចំណែកសន្តិភាព"។ ទោះដូច្នោះក្តី ប្រទេសដទៃទៀតនៅក្នុងទ្វីបអាស៊ី និងអាហ្វ្រិក បានបង្កើននូវការចំណាយរបស់ខ្លួននៅក្នុងវិស័យការពារជាតិ នៅក្នុងរយៈពេលនេះ។

**ប្រអប់ទី ៥៣**

**ការចំណាយលើការពារជាតិ គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក (GDP) របស់ពិភពលោក និងប្រទេសមួយចំនួន**

| | ១៩៨៥ | ២០០០ | ២០០១ |
|---|---|---|---|
| **អង្គការណាតូ** | **៤.០** | **២.២** | **២.២** |
| សហរដ្ឋអាមេរិក | ៦.៥ | ៣.០ | ៣.២ |
| អង់គ្លេស | ៥.២ | ២.៤ | ២.៥ |
| បារាំង | ៤.០ | ២.៦ | ២.៦ |
| អាល្លឺម៉ង់ | ៣.២ | ១.៦ | ១.៥ |
| **ប្រទេសនៅអឺរ៉ុបមិនមែនជាសមាជិកអង្គការណាតូ** | **៤.៣** | **២.៨** | **២.៣** |
| សហភាពសូវៀត/រុស្ស៊ី | ១៦.១ | ៥.០ | ៤.៣ |
| **មជ្ឈិមបូព៌ា និង អាហ្វ្រិកខាងជើង** | **១១.៩** | **៦.៧** | **៧.២** |
| **អាស៊ីកណ្តាល និង អាស៊ីខាងត្បូង** | **៤.៣** | **៥.២** | **៣.៨** |
| **អាស៊ីបូព៌ា និងអូស្ត្រាលី** | **៦.៤** | **៣.៥** | **៣.៣** |
| ជប៉ុន | ១.០ | ១.០ | ១.០ |
| **ការ៉ាប៊ីន និង អាមេរិកឡាទីន** | **៣.២** | **១.៧** | **១.៧** |
| **អនុសមុទ្រខ្សាច់នៅអាហ្វ្រិក** | **៣.១** | **៣.៨** | **៣.៤** |
| អេរីទ្រា | មិនដឹង | ៣០.០ | ២០.៩ |
| **សរុបជាសាកល** | **៦.៧** | **៣.៦** | **៣.៥** |

*ប្រភព៖ តុល្យភាពយោធា ២០០២-២០០៣, IISS, ទីក្រុងឡុងដ៍*

## ការរៀបចំថវិកាពាក់ព័ន្ធនឹងសន្តិសុខប្រកបដោយប្រសិទ្ធភាព

គណនេយ្យភាព និងតម្លាភាព គឺជាលក្ខខណ្ឌពិសេសសម្រាប់ឲ្យមានការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព។ គណនេយ្យភាពកើតមានឡើង តាមរយៈការធ្វើថវិកាដែលមានតម្លាភាព។ តម្លាភាព និង គណនេយ្យភាព អាចកើតចេញមកពីគោលការណ៍នៃការធ្វើថវិកា ប្រកបដោយប្រសិទ្ធភាព៖

**ការផ្តល់សិទ្ធិអំណាចជាមុន** – សភាត្រូវផ្តល់សិទ្ធិអំណាចដល់អង្គការនីតិប្រតិបត្តិ ដើម្បីអនុវត្តការចំណាយ។

**កត្តាឯកភាព** – រាល់ការចំណាយ និង ចំណូល ត្រូវបញ្ចូលនៅក្នុងឯកសារថវិកាតែមួយសម្រាប់ដាក់ជូនសភា។

**កត្តារយៈពេល** – អង្គការនីតិប្រតិបត្តិត្រូវគោរពក្របខណ្ឌពេលវេលាក្នុងការដាក់ឯកសារថវិកាជូនសភាជារៀងរាល់ឆ្នាំ។ ត្រូវមានការបញ្ជាក់ក្របខណ្ឌពេលវេលាដែលនឹងត្រូវចំណាយថវិកាដែលបានចាត់ចែងបែងចែកទៅឲ្យ។

**កត្តាច្បាស់លាស់** – ត្រូវមានបញ្ជាក់ឲ្យបានច្បាស់អំពីចំនួន និងសេចក្តីពណ៌នាទូទៅ នៃរាល់ខ្ទង់ថវិកាចំណាយរបស់រដ្ឋាភិបាល។ ដូច្នេះ ការពន្យល់អំពីខ្ទង់ថវិកានីមួយៗត្រូវតែច្បាស់លាស់ រួមទាំងមូលនិធិដែលពាក់ព័ន្ធនឹងថវិកាមិនត្រូវច្រើនពេកនោះទេ។

**កត្តានីត្យានុកូលភាព (legality)** –រាល់ការចំណាយនិងសកម្មភាពទាំងអស់ត្រូវស្របតាមច្បាប់កំណត់។

**រចនាសម្ព័ន្ធងាយយល់** – នីតិប្រតិបត្តិត្រូវដាក់ជូនសភានូវផែនការនៃការចំណាយប៉ាន់ស្មានដែលមានលក្ខណៈងាយគ្រប់គ្រង និង ងាយយល់សម្រាប់សាធារណជនទូទៅ។

**កត្តានៃភាពគ្រប់ជ្រុងជ្រោយ** – ថវិការដ្ឋពាក់ព័ន្ធនឹងទិដ្ឋភាពផ្សេងៗនៃវិស័យសន្តិសុខ ត្រូវតែមានលក្ខណៈពេញលេញនិងគ្រប់ជ្រុងជ្រោយ។ គ្មានការចំណាយណាមួយដែលមិនមានគណនេយ្យភាព រួមទាំងថវិកាសម្រាប់សេវាសន្តិសុខទាំងអស់ ក្នុងនោះមានយោធាអង្គការយោធារបស់រដ្ឋផ្សេងទៀត នគរបាល និងសេវាចារកម្ម ក៏ដូចជាក្រុមហ៊ុនយោធាឯកជនដែលបានជួលដោយនីតិប្រតិបត្តិ។

**ការផ្សព្វផ្សាយជាសាធារណៈ** – ប្រជាពលរដ្ឋគ្រប់រូប (បុគ្គល ឬជាអង្គការ) ត្រូវមានឱកាសដើម្បីសំដែងនូវចំណាប់អារម្មណ៍របស់ពួកគេអំពីថវិកា។ នេះវាទាមទារឲ្យរាល់ឯកសារថវិកាទាំងអស់ត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធដែលមានលក្ខណៈងាយយល់ ងាយអាន គ្រប់ទីកន្លែងនៅក្នុងប្រទេស (ឧ. តាមរយៈការផ្ញើឯកសារនេះទៅតម្កល់នៅបណ្ណាល័យក្នុងមូលដ្ឋាន)។

**ភាពស៊ីសង្វាក់គ្នា** – ត្រូវមានទំនាក់ទំនងដ៏ច្បាស់លាស់ រវាងគោលនយោបាយផែនការសំណើសុំថវិកា និងលទ្ធផលនៃការអនុវត្ត។

**មធ្យោបាយ និងលទ្ធផល** – ត្រូវមានការពន្យល់អំពីគោលបំណងនៃថវិកាដើម្បីឲ្យមានការយល់ដឹងដ៏ច្បាស់លាស់ទាក់ទងនឹង ក) ធនធានដែលត្រូវផ្តល់ឲ្យ ខ) ការបំពេញភារកិច្ច ឬសមត្ថភាពដើម្បីបានទទួលជោគជ័យ និង គ) លទ្ធផលដែលអាចវាស់វែងបាន។ ផែនការថវិកាគួរមានលក្ខណៈបត់បែនដែលអាចធ្វើការកែសម្រួលបាននៅក្នុងចំណុចណាមួយនៃចំណុច ៣ ខាងលើ។

តាមពិតគោលការណ៍ទាំងនេះ អាចជាលក្ខខណ្ឌវិនិច្ឆ័យបែបគុណភាព សម្រាប់ការរៀបចំថវិកាដ៏សមស្របបែបទំនើប។ នៅពេលដែលតំណាងរាស្ត្រខ្វះនូវព័ត៌មានដ៏សមស្រប អំពីវិស័យសន្តិសុខ ពួកគេមិនអាចសំដែងនូវកង្វល់ទាក់ទងនឹងវដ្តថវិកាការពារជាតិបាននោះទេ។

# លក្ខខណ្ឌនៃការរៀបចំថវិកាសន្តិសុខដ៏សមស្រប

មានធាតុជាច្រើនទាក់ទងនឹងការរៀបចំថវិកាដ៏សមស្រប ដែលលើកកម្ពស់ការត្រួតពិនិត្យរបស់សភាទៅលើថវិកាវិស័យសន្តិសុខ។ ក្នុងចំណោមនោះក្នុងក្របខណ្ឌផ្លូវច្បាប់ និងធម្មនុញ្ញដ៏ច្បាស់លាស់ ធាតុទាំងនោះមានការចំណាយដើម្បីបានលទ្ធផលជាក់ស្តែង បែបបទនៃថវិកាពេលវេលា និងការធ្វើទំនាក់ទំនងជាមួយសង្គមស៊ីវិល សុទ្ធតែជាបញ្ហាសំខាន់។

## ក្របខណ្ឌច្បាប់ និងរដ្ឋធម្មនុញ្ញដ៏ច្បាស់លាស់

សិទ្ធិរបស់តំណាងរាស្ត្រក្នុងការត្រួតពិនិត្យវិស័យសន្តិសុខ ត្រូវតែមានចែងឲ្យច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ដទៃទៀត។ លើសពីនេះ សភាត្រូវបង្កើតច្បាប់ស្តីពី ការទទួលព័ត៌មានពីរដ្ឋាភិបាល ហើយអំណាចគាស់កកាយព័ត៌មានពីរដ្ឋាភិបាល ត្រូវអនុវត្តស្របតាមច្បាប់ទាំងនោះ។ ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខ តាមរយៈការធ្វើថវិកាត្រូវតែធ្វើវាឲ្យក្លាយជាទម្លាប់នយោបាយរបស់សភា។ នេះវាតម្រូវឲ្យមានការខិតខំប្រឹងប្រែងសម្បើមណាស់។

## ការចំណាយដើម្បីបានលទ្ធផលជាក់ស្តែង

ដំណើរការនៃការរៀបចំថវិកាគួរអនុវត្តតាមវិធានជាមូលដ្ឋាន ២ នៃការចំណាយដើម្បីបានលទ្ធផលជាក់ស្តែង៖

- ✓ ប្រសិទ្ធភាព៖ ធ្វើឲ្យសម្រេចនូវគោលដៅរបស់គោលនយោបាយ ("អនុវត្តចំចំណុចដែលចង់បាន")។
- ✓ ប្រសិទ្ធិផល៖ ធ្វើឲ្យសម្រេចនូវគោលដៅរបស់គោលនយោបាយ ដោយប្រើប្រាស់នូវធនធានតិចតួចបំផុត ("អនុវត្តចំចំណុចដែលចង់បាន ដោយភាពសន្សំសំចៃខ្ពស់")។

**ប្រអប់ទី ៥៤**

**ប្រព័ន្ធរៀបចំផែនការ កម្មវិធី និងថវិកា (PPBS)**

"(...) ប្រព័ន្ធរៀបចំផែនការ កម្មវិធី និងថវិកា (PPBS) ជាដំបូងត្រូវបានប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក (ដើមទសវត្សរ៍ទី៦០) សម្រាប់ការរៀបចំថវិកាការពារជាតិ (ហើយបច្ចុប្បន្នប្រព័ន្ធនេះត្រូវបានប្រើប្រាស់នៅក្នុងប្រទេសជាច្រើន (...)។ វត្ថុគោលនៃប្រព័ន្ធ PPBS រួមមានដំណាក់កាលធ្វើផែនការដំបូង ដែលនៅក្នុងដំណាក់កាលនេះ គេចាប់ផ្តើមវិភាគលើបរិស្ថានសន្តិសុខ ក៏ដូចជាផលប្រយោជន៍ជាតិនិងការគម្រាមកំហែងដើម្បីកំណត់នូវភារកិច្ច សមភាព និងរចនាសម្ព័ន្ធរបស់

កងកម្លាំងប្រដាប់អាវុធ។ ដោយធ្វើការពិចារណាលើភាពចាំបាច់នេះ ទើបមានការរៀបចំជាកម្មវិធីឡើង។ កម្មវិធី គឺជាទម្រង់មួយនៃផែនការការងារដែលកំណត់នូវគោលបំណងជាក់លាក់ដែលត្រូវធ្វើឲ្យសម្រេច។ វាមានទំនាក់ទំនងសំខាន់ខ្លាំងណាស់ នៅក្នុងវគ្គគោលនៃប្រព័ន្ធនេះ ដោយសារវាភ្ជាប់ទំនាក់ទំនងនៃគោលបំណងដែលបានកំណត់ជាមួយនឹងធនធានហរិញ្ញវត្ថុ។ តាមវិធីនេះ ប្រព័ន្ធ PPBS វាភ្ជាប់គ្នាជាមួយការចាត់ចែងបែងចែកធនធាន ទៅតាមតម្រូវការដែលបានកំណត់ និងផែនការ និងកម្មវិធីស្របតាមថវិកាដែលបានព្យាករណ៍។ ដូច្នេះ វាសំខាន់ខ្លាំងណាស់ថាត្រូវមានការរៀបចំកម្មវិធី ដោយផ្អែកទៅលើអាទិភាពដែលត្រូវបំពេញតាមតម្រូវការបន្ទាន់បំផុតរបស់កងកម្លាំងប្រដាប់អាវុធ។ ការវាយតម្លៃពីហានិភ័យទាក់ទងនឹងផលវិបាកដែលមិនបានសម្រេចតាមគោលបំណងដែលបានកំណត់ អាចត្រូវបានប្រើប្រាស់សម្រាប់កំណត់អាទិភាព។ នៅចុងបញ្ចប់នៃវគ្គគោលនៃប្រព័ន្ធ PPBS គឺជំណាក់កាលវាស់វែង លើការអនុវត្តដែលនៅក្នុងដំណាក់កាលនេះ ក្រសួងនិងសង្គមទាំងមូលអាចកំណត់បាន ថាតើនៅចុងឆ្នាំមានគោលបំណងចំនួនប៉ុន្មានត្រូវបានធ្វើឲ្យសម្រេច។ នៅពេលនោះ ទើបគេអាចធ្វើការបែងចែកធនធានប្រកបដោយប្រសិទ្ធភាពបាន...”។

*ប្រភព៖ តម្លាភាពថវិកាការពារជាតិនៅលើអ៊ីនធឺណែត ដោយ Kate Starkey និង Andri van Meny ព័ត៌មាន & សន្តិសុខ, លេខ ៥, ២០០០។ C4 នៅក្នុង Defence of Reengineering (ការធ្វើវិស្វកម្មការពារជាតិឡើងវិញ)*

ដើម្បីធ្វើការវាយតម្លៃ ថាតើថវិកាការពារជាតិពិតជាត្រូវបានចំណាយស្របតាមគោលបំណងទៅតាមទ្រឹស្តីទំនើបនៃថវិកា ការចំណាយគួរតែមានទំនាក់ទំនងជាមួយកម្មវិធី និងគោលបំណង (សូមអានប្រអប់ទី ៥៤) ឧ. ការចំណាយគួរមានការពាក់ព័ន្ធជាមួយគោលដៅ និងគោលបំណងនៃគោលនយោបាយ (ឧ. បេសកកម្មរក្សាសន្តិភាពធ្វើការអប់រំ)។ រាល់ការចំណាយទាំងអស់ គួរបញ្ចូលទៅតាមខ្ទង់នៃកញ្ចប់សកម្មភាព។ លើសពីនេះ សភាត្រូវមានសមត្ថភាពធ្វើការវាយតម្លៃលើការចំណាយទាំងនោះ តើវាស្របជាមួយគោលបំណងឬយ៉ាងណាដោយមានជំនួយពីសវនករ (សូមអានជំពូកបន្ទាប់)។ នេះមានន័យថា រដ្ឋាភិបាលដាក់ជូនសភានូវធាតុចេញ (output budget) នៃថវិកា និងលទ្ធផលរបស់វាមិនមែនធាតុចូល (input budget) នៃថវិកាដែលស្នើសុំនោះទេ។ ប្រព័ន្ធរៀបចំថវិកាដែលមានលក្ខណៈជាប្រព័ន្ធដូចជា PPBS អាចប្រើប្រាស់បានលុះត្រាតែសេវាសន្តិសុខរៀបចំផែនការរបស់ពួកគេមានតម្លាភាពស្របតាមលក្ខខណ្ឌនៃការរក្សាការសម្ងាត់។

## បែបបទថវិកា

ដើម្បីដឹងថា រដ្ឋាភិបាលពិតជាអនុវត្តតាមវិធាននៃក្របខណ្ឌច្បាប់ និងអនុវត្តតាមថវិកាដែលសភាបានអនុម័តយល់ព្រមមែននោះ ការមានបែបបទថវិកា គឺជាមូលដ្ឋានដ៏សំខាន់ដែលសភាគួរពិចារណាដូចតទៅ៖

- ✓ ទំនាក់ទំនងរវាងថវិកាការពារជាតិ(ការគណនាការចំណាយ) និងការរៀបចំតម្លៃ។
- ✓ ការប្រើប្រាស់បទដ្ឋានសម្រាប់ពិនិត្យតាមដាន និងកំណត់ការដាក់កំហិតលើការចាយមិនអស់ និងការចាយលើស។
- ✓ ក្នុងករណីចាយថវិកាការពារជាតិមិនអស់ ឬ លើស ផ្តល់ដំណឹងដល់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងគណៈរដ្ឋមន្ត្រី (Cabinet)។
- ✓ វិធានសម្រាប់សងថវិកាដែលចាយលើស៖ ការសងលើថវិកាដែលបានចាយលើសចេញពីថវិកាការពារជាតិ ឬ ការសងលើថវិកាដែលបានចាយលើសចេញពីថវិការដ្ឋាភិបាល។

## ក្របខណ្ឌពេលវេលា និងរយៈពេល

ដើម្បីសម្រេចបាននូវការរៀបចំថវិកាដ៏សមស្របប្រកបដោយប្រសិទ្ធភាព នៅក្នុងវិស័យសន្តិសុខ វាជាការចាំបាច់ត្រូវទុកពេលគ្រប់គ្រាន់សម្រាប់ពិនិត្យមើលសំណើថវិកាការពារជាតិមុនមានការបោះឆ្នោត។ រយៈពេលដ៏សមស្របគួរយ៉ាងហោចណាស់ក៏មានរយៈពេល ៤៥ថ្ងៃ រហូតដល់ ៣ខែ ដែលអាចឲ្យសភាធ្វើការពិនិត្យឡើងវិញ នូវភាពស្មុគ្រស្មាញនៃសំណើថវិកាការពារជាតិឲ្យបានគ្រប់ជ្រុងជ្រោយ។

ការផ្តល់នូវព័ត៌មានដ៏សុក្រិតគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា អំពីគោលនយោបាយថវិកាការពារជាតិក៏សំខាន់ផងដែរ សម្រាប់ហេតុផលដូចខាងក្រោម៖

- ✓ ព័ត៌មាននេះ គឺជាបុរេនិច្ឆ័យមួយសម្រាប់ការពិភាក្សាជាសាធារណៈ។
- ✓ វាជួយក្នុងការកំណត់នូវចំណុចខ្វះខាត និងតម្រូវការសម្រាប់ធ្វើការកែសម្រួល និងបំពេញបន្ថែមពីការចំណាយផ្នែកសន្តិសុខ និងការចំណាយរបស់រដ្ឋាភិបាលផ្សេងទៀត។
- ✓ ការគ្រប់គ្រងថវិកាវិស័យសន្តិសុខប្រកបដោយតម្លាភាព លើកកម្ពស់នូវគណនេយ្យភាពចំពោះសាធារណជន និងសភា និងបង្កើននូវទំនុកចិត្តសាធារណជនចំពោះរដ្ឋាភិបាល។

## ការធ្វើទំនាក់ទំនងជាមួយសង្គមស៊ីវិល

សភាអាចសុំជំនួយពីអ្នកជំនាញខាងធ្វើផែនការហិរញ្ញវត្ថុ និងថវិកាពីអង្គការសង្គមស៊ីវិលឲ្យជួយដល់ពួកគេក្នុងដំណើរការពិនិត្យឡើងវិញនិងតាមដានហិរញ្ញវត្ថុ។ នេះវាសំខាន់ខ្លាំងណាស់ ជាពិសេស នៅក្នុងការរៀបចំនូវថវិកាពាក់ព័ន្ធជាមួយវិស័យសន្តិសុខ ដែលជានិច្ចជាកាល វាមានលក្ខណស្មុគ្រស្មាញ និងពិបាកយល់។ តម្លាភាពនៃដំណើរការរៀបចំថវិកាគួរតែផ្អែកលើច្បាប់ស្តីពីសេរីភាពនៃការទទួលព័ត៌មាន និងនីតិវិធីដទៃទៀត។

## ការបណ្តុះបណ្តាល និងជំនាញ

ជាចុងក្រោយ សភាភាគច្រើនត្រូវការលើកកម្ពស់សមត្ថភាព ទាំងសមាជិកសភា ទាំងបុគ្គលិកសភា តាមរយៈការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ ជាពិសេសសម្រាប់បុគ្គលិកជំនាញ។ ក្នុងន័យនេះ ដើម្បីលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការងាររបស់សភាប្រកបដោយប្រសិទ្ធភាព សភា IPU កំពុងរៀបចំនូវសិក្ខាសាលាថ្នាក់តំបន់ និងថ្នាក់អនុតំបន់សម្រាប់ទាំងតំណាងរាស្ត្រ និងបុគ្គលិករបស់សភា (សូមអាន www.ipu.org) ព្រមទាំងរៀបចំនូវសៀវភៅបណ្តុះបណ្តាលជាច្រើនទៀត ដូចសៀវភៅនេះដែរ។

**ប្រអប់ទី ៥៥**

**សមាសភាគជាមូលដ្ឋាននៃថវិកាការពារជាតិ៖ ថវិកាការពារជាតិ នៃប្រទេសអេស្ប៉ាញ ឆ្នាំ ២០០២**

**ទំនិញ និងសេវាកម្ម**

- ស្បៀងអាហារ
- ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ
- ប្រេងឥន្ធនៈ
- សេវា៖ ភ្លើង ទឹក ទូរស័ព្ទ ។ល។
- សម្លៀកបំពាក់
- ប្រាក់ឧត្ថម្ភ
- ការដឹកជញ្ជូន
- ការបណ្តុះបណ្តាល
- ការថែទាំវេជ្ជសាស្ត្រ
- ការចំណាយលើប្រតិបត្តិការផ្សេងទៀត។

**ការចំណាយហិរញ្ញវត្ថុផ្សេងទៀតនិន្នាការនៃផ្ទេរនានា**

- អង្គការអន្តរជាតិ
- អង្គភាពស្វយ័ត
- ការផ្ទេរផ្សេងទៀត។

**ការវិនិយោគជាក់ស្តែង**

- ការធ្វើទំនើបកម្មនៃកងកម្លាំងប្រដាប់អាវុធ

- ការជួសជុលអាវុធ និងសម្ភារៈ
- ការស្រាវជ្រាវ និងអភិវឌ្ឍន៍
- ការវិនិយោគផ្សេងទៀត។

**ការផ្ទេរមូលធន**

**ទ្រព្យហិរញ្ញវត្ថុ**

ប្រភព៖ ថវិកាការពារជាតិនៃប្រទេសអេស្ប៉ាញឆ្នាំ២០០២ ក្រសួងការពារជាតិ នៃប្រទេសអេស្ប៉ាញ

## តម្លាភាព និងគណនេយ្យភាពនៅក្នុងការរៀបចំថវិកា វិស័យសន្តិសុខ

### តម្លាភាព និង ការសម្ងាត់

តម្លាភាពនៃការធ្វើសេចក្តីសម្រេចចិត្តមានសារៈសំខាន់ណាស់ ដើម្បីធានាថា លទ្ធផលនៃការធ្វើសេចក្តីសម្រេចចិត្ត វាស្របគ្នាជាមួយការចង់បានរបស់សាធារណជន និង គោលបំណងនៃគោលនយោបាយ។ តម្លាភាពនៅក្នុងការរៀបចំថវិកាការពារជាតិជួយឲ្យសភាបំពេញតួនាទីត្រួតពិនិត្យរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ វាបង្កើនទំនុកចិត្តរបស់សង្គមនៅក្នុងវិស័យសន្តិសុខ។ កង្វះនូវតម្លាភាពនៅក្នុងការរៀបចំថវិកាការពារជាតិ ជាញឹកញាប់វាមានទំនាក់ទំនងជាមួយការរៀបចំថវិកាបែបហួសសម័យ ឬក៏ការកំណត់នូវគោលបំណងសន្តិសុខមិនបានត្រឹមត្រូវ។ វាក៏មានទំនាក់ទំនងជាមួយការខ្វះជំនាញជាពហុវិស័យនៅក្នុងអង្គការសវនកម្មជាតិ រួមទាំងបទបញ្ញត្តិដ៏ទន់ខ្សោយរបស់រដ្ឋធម្មនុញ្ញទាក់ទងនឹងការផ្តល់ព័ត៌មាន ដើម្បីធ្វើឲ្យមានការត្រួតពិនិត្យជាសាធារណៈលើសេចក្តីសម្រេចនានា រួមទាំងការិយាល័យធិបតេយ្យ ដែលតម្រូវឲ្យមានការលាក់ការណ៍សម្ងាត់ដែលវារត់បញ្ច្រាសពីគណនេយ្យភាព។ អាជ្ញាធរសវនកម្ម និងតំណាងរាស្ត្រត្រូវកំណត់និងធ្វើការដោះស្រាយនូវភាពកម្សោយនានា ដែលមានលក្ខណៈជាប្រព័ន្ធដ៏ធំធេងនេះឲ្យបាន (សូមអានជំពូកបន្ទាប់)។

**ប្រអប់ទី ៥៦**

**ឧបសគ្គសំខាន់ៗ ចំពោះតម្លាភាពនៃការបង្កើតកញ្ចប់ថវិកាវិស័យសន្តិសុខ**

"កង្វះតម្លាភាព និងគណនេយ្យភាព វាជាបញ្ហានៅក្នុងការធ្វើថវិកាដែលមានបុគ្គលិកពីរបីនាក់នៅក្នុងផ្នែកអង្គការនីតិប្រតិបត្តិ ជាអ្នកធ្វើសេចក្តីសម្រេចលើគោលនយោបាយ និងធនធាននៅក្នុងវិស័យសន្តិសុខ។ មន្ត្រីសំខាន់ៗនៅក្នុងក្រសួងហិរញ្ញវត្ថុ និងផ្នែកខ្លះនៃអង្គការនីតិប្រតិបត្តិជាញឹកញាប់ត្រូវបានផាត់ចេញពីការធ្វើសេចក្តីសម្រេចចិត្ត ឬសេចក្តីសម្រេចចិត្តរបស់ពួកគេមិនត្រូវបានគេទទួលយក។ ស្ថាប័នសភា ដែលអាចមានអំណាចត្រួតពិនិត្យដែលតម្រូវដោយរដ្ឋធម្មនុញ្ញជាតិ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ និង សង្គមស៊ីវិលត្រូវបានគេទុកមួយជុំនៅកន្លែងងងឹតឈឹង"។ ...

"រាល់ការចំណាយទាំងអស់ទៅលើកម្លាំងសន្តិសុខផ្សេងៗ ទាំងបុគ្គលិក ប្រតិបត្តិការ និងឧបករណ៍ គួរតែបញ្ចូលទៅក្នុងថវិកា។ ថវិកាទាំងនោះ គួរតែបង្ហាញពីរបៀបផ្តល់ហិរញ្ញវត្ថុដល់ការចំណាយនីមួយៗ"។ ក៏ប៉ុន្តែ ថវិកាសន្តិសុខភាគច្រើនមិនបានតម្រូវតាមលក្ខខណ្ឌណាមួយនោះទេ។ ការចាត់ចែងបែងចែកថវិកាតាមផ្នែក ស្ថិតនៅក្នុងភាពលំបាកនិងស្រពិចស្រពិល ដែលគិតបញ្ចូលទាំងថវិកាមកពីក្រសួងផ្សេងៗ។

នៅក្នុងប្រទេសដែលអនុវត្តសកម្មភាពដ៏ច្រើនដោយគ្មានថវិកា រដ្ឋាភិបាលខ្លួនឯងតែងតែខ្វះនូវព័ត៌មានសុក្រិត។ ហេតុដូច្នេះហើយ បានជាម៉ែត្រសម្រាប់វាស់គណនេយ្យភាពដោយធ្វើការប្រៀបធៀបផែនការ និងការប្រតិបត្តិមិនអាចប្រើប្រាស់បាន។ មន្ត្រីនៅក្នុងក្រសួងការពារជាតិនិងផ្នែកដទៃទៀតនៃផ្នែកអង្គការនីតិប្រតិបត្តិ ត្រូវការនូវចំណេះដឹងផ្នែកបច្ចេកទេសជាក់លាក់ទាក់ទងនឹងការការពារជាតិ ដើម្បីខ្លួនអាចធ្វើសេចក្តីសម្រេចដ៏សមស្របទៅលើគោលនយោបាយការពារជាតិ ថវិកា និងលទ្ធកម្ម។ ការដោះស្រាយបញ្ហាមិនមានថវិកាជាញឹកញាប់ គឺមានលក្ខណៈនយោបាយខ្ពស់ដែលតម្រូវឲ្យមានការផ្លាស់ប្តូរជាមូលដ្ឋានរយៈពេលវែងនៅក្នុងទំនាក់ទំនងរវាងស៊ីវិល និងយោធា។

*ប្រភព៖ របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០២ (ទំព័រ ៨៩ ដល់៩១)*

## ការចំណាយទាក់ទងនឹងការពារជាតិនិងសន្តិសុខដែលអាច និងមិនអាចត្រួតពិនិត្យបាន

ប្រសិនបើដើម្បីត្រួតពិនិត្យវិស័យសន្តិសុខ និងអាចធ្វើការវាយតម្លៃ ថាតើប្រាក់គួរត្រូវចំណាយលើសេវាសន្តិសុខ ឬ ក្នុងផ្នែកណាមួយរបស់រដ្ឋាភិបាលសភាចាំបាច់ត្រូវមានសិទ្ធិទទួលបាននូវឯកសារថវិកាដែលពាក់ព័ន្ធដើម្បីធានានូវសុចរិតភាពហិរញ្ញវត្ថុ។ ការផ្តល់ដល់សភាត្រឹមតែចំនួនសរុប វារំលោភលើគោលការណ៍ស្តីពី ភាពជាក់លាក់ដែលជាគោលការណ៍មួយនៃការរៀបចំថវិកាឲ្យបានសមស្រប (សូមអានសេចក្តីពន្យល់ខាងលើ)។ នៅពេលដែល ព័ត៌មានមិនត្រូវបានផ្តល់ជាក់លាក់ទេនោះ សភាមិនអាចបំពេញនូវភារកិច្ចតាមរដ្ឋធម្មនុញ្ញក្នុងការត្រួតពិនិត្យថវិកាការពារជាតិបាននោះទេ។

សភា ត្រូវមានសិទ្ធិទទួលបាននូវឯកសារថវិកាការពារជាតិទាំងអស់។ នៅក្នុងប្រទេសខ្លះ (ឧ. ប្រទេសដាណឹម៉ាក និងប្រទេសលុយហ្សំប៊ួរ) គេបានផ្តល់ព័ត៌មានដល់សភាទាក់ទងនឹងខ្ទង់ថវិកាដែលត្រូវចំណាយដែលជាឯកសារថវិកាលំអិតបំផុត។ នៅក្នុងប្រទេសដទៃ (ដូចជា ប្រទេសបារាំង ក្រិច និងប៉ូឡូញ) គណៈកម្មការការពារជាតិសភា គឺជាស្ថាប័នតែមួយគត់ដែលជាអ្នកផ្តល់ព័ត៌មានអំពីខ្ទង់ថវិកាការពារជាតិ។ តាមទស្សនៈអភិបាលកិច្ចល្អគួរមានការធានាថា គណៈកម្មាធិការ ឬ មួយសភាត្រូវមានសិទ្ធិទទួលបាននូវឯកសារថវិកាទាំងអស់ (ប្រសិនបើចាំបាច់ដំណើរការនេះគួរធ្វើជាសាធារណៈ)។ នីតិវិធីដូចគ្នានេះ គួរអនុវត្តចំពោះសេវាសន្តិសុខដទៃទៀត ដូចជាសេវាចារកម្មជាដើម។

ការធ្វើចំណាត់ថ្នាក់ថវិកាសេវាសន្តិសុខត្រូវអនុលោមតាមច្បាប់ និងជាពិសេសច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន (សូមអានប្រអប់ទី ៥៧)។

ខណៈពេលដែលសភាធ្វើការពិភាក្សា និងបោះឆ្នោតលើថវិកាសន្តិសុខ សេរីភាពរបស់សភាទាក់ទងនឹងការកែសម្រួលថវិកា ត្រូវបានកំហិតដោយឯកសារចំណាយជាប់កាតព្វកិច្ចមួយចំនួន (ឧ. កិច្ចសន្យាលទ្ធកម្មដែលបានចុះហត្ថលេខានៅឆ្នាំមុនៗ) និងគោលនយោបាយនានា (ឧ. គោលនយោបាយស្តីពី ប្រាក់សោធននិវត្តន៍ និងគោលនយោបាយថែទាំសុខភាពសម្រាប់យោធិន)។ ការចំណាយទាំងនេះ អាចធ្វើការកែសម្រួលតែក្នុងរយៈពេលវែងប៉ុណ្ណោះ។

**ប្រអប់ទី ៥៧**

### ចំណាត់ថ្នាក់ ពាកម្រិត នៅក្នុងថវិកាសន្តិសុខ

តំណាងរាស្ត្រចាំបាច់ត្រូវធានាឲ្យមានតុល្យភាពរវាងការសម្ងាត់ នៃព័ត៌មាននៅក្នុងកាលៈទេសៈពិសេសនិងការវិភាជន៍ចាត់ចែងបែងចែកការពារជាតិជាមួយគណនេយ្យភាព។ វិធីមួយអាចថាត្រូវមានការបំបែកនូវខ្ទង់ថវិកាលំអិតតូចៗទៅតាមការងារនៃផ្នែកសន្តិសុខដូចខាងក្រោម៖

- ▷ ថវិកាការពារជាតិទូទៅដាក់ជូនសភាពិនិត្យ។
- ▷ ការចំណាយមូលធនសម្រាប់ការងារខាងចារកម្ម និងចំណាយសម្រាប់ប្រតិបត្តិការ ដែលអាចអនុគណៈកម្មការថវិកាការពារជាតិ និងការចំណាយយោធាធ្វើការត្រួតពិនិត្យ។
- ▷ ការចំណាយ ដែលពាក់ព័ន្ធជាមួយការងារចារកម្មយោធា ដែលអាចត្រួតពិនិត្យដោយសមាជិកនៃគណៈកម្មការត្រួតពិនិត្យរបស់សភា។ គណៈកម្មការនេះ ត្រូវមានសិទ្ធិចូលឆែកមើលឯកសារទៅតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ស្តីពីការសម្ងាត់ជាតិ។

*ប្រភព៖ Ravinder Pal Singh, ដំណើរការធ្វើសេចក្តីសម្រេចទាក់ទងនឹងការងារលទ្ធកម្មអាវុធ, លេខ ១, OUP, Oxford, ១៩៩៨*

## តម្លាភាពប្រឆាំងនឹងការកិបកេងមូលនិធិសាធារណៈ និងអំពើពុករលួយ

សភា ដើរតួនាទីដ៏សំខាន់ក្នុងការធានាថា រដ្ឋាភិបាលមិនកិបកេងមូលនិធិសាធារណៈ។ មានការបង្ហាញថា ការបំពានបែបនេះអាចកើតឡើងជាពិសេសទាក់ទងនឹងថវិកាដែលបានចាត់ចែងបែងចែកទៅឲ្យវិស័យសន្តិសុខ ដោយសារតែលក្ខណៈពិសេសរបស់វា ដូចជាបញ្ហាស្មុគ្រស្មាញទាក់ទងនឹងបច្ចេកទេស រួមទាំងលក្ខខណ្ឌដែលមានចែងនៅក្នុងយុទ្ធសាស្ត្រសន្តិសុខជាតិ។

តម្លាភាព និងគណនេយ្យភាពនៅក្នុងការរៀបចំថវិកាការពារជាតិ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ឲ្យសភា ធ្វើការត្រួតពិនិត្យវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាព។ តម្លាភាព គឺជាបុរេលក្ខខណ្ឌចំពោះគណនេយ្យភាពដែលជាមូលដ្ឋានគ្រឹះ នៃអភិបាលកិច្ចល្អ។ ដូច្នេះទស្សនទានទាំង ២ គឺជាគន្លឹះនៅក្នុងវគ្គគោលនៃថវិកាទាំងមូល។

*"ដោយសារកង្វះនូវគណនេយ្យភាព និងតម្លាភាព ទូទៅនៅក្នុងការរៀបចំថវិកាការពារជាតិ វាអាច [...] ធ្វើឲ្យមានកង្វល់អំពីទំហំ សមត្ថភាព និងចេតនារបស់កងកម្លាំងប្រដាប់អាវុធរបស់ប្រទេសមួយការមានតម្លាភាពកាន់តែច្រើន វាធ្វើឲ្យមានការទាញការចាប់អារម្មណ៍ ចំពោះការចំណាយលើយោធា និងកាត់បន្ថយភាពមិនច្បាស់លាស់ និងការយល់ខុស ដែលនាំទៅរកជម្លោះ"។*

Paul George, "ការចំណាយការពារជាតិក្នុងទសវត្សរ៍ ឆ្នាំ១៩៩០៖ បញ្ហាគោលនយោបាយស្តីពីថវិកា និងសារពើពន្ធសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍" ឆ្នាំ២០០២។

មានការទទួលស្គាល់ជាទូទៅថា ការចំណាយលើយោធាដ៏ច្រើនលើសលុប វាអាចបង្វែរធនធានដ៏មានតម្លៃសម្រាប់ប្រើប្រាស់លើការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍសង្គម។ តំណាងរបស់ប្រជាពលរដ្ឋ ត្រូវទទួលបាននូវព័ត៌មានអំពីមូលហេតុ និងវិធីសាស្ត្រដែលនីតិប្រតិបត្តិមានផែនការរៀបចំសន្តិសុខសម្រាប់សង្គមជាតិ ដោយសារថវិកាទាំងនេះ ចេញមកពីការរួមវិភាគទានពីការបង់ពន្ធរបស់ប្រជាពលរដ្ឋ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការប្រើប្រាស់ថវិកាមិនត្រឹមត្រូវ បង្កឲ្យមានការខាតបង់ច្រើនណាស់។ ខណៈពេលដែលរដ្ឋាភិបាលកំពុងប្រកាន់ខ្ជាប់នូវអភិបាលកិច្ចល្អខ្លួនក៏មានកាតព្វកិច្ចត្រូវអនុញ្ញាតឲ្យសាធារណជន ចូលរួមនៅក្នុងការពិភាក្សាទាក់ទងនឹងវិស័យសន្តិសុខផងដែរ។ សភាត្រូវធានាថា ថវិកាការពារជាតិមានតុល្យភាពរវាងការអភិវឌ្ឍន៍និងតម្រូវការផ្នែកសន្តិសុខ។ វាមានបញ្ហាជាច្រើនដែលអាចរារាំងនូវការត្រួតពិនិត្យថវិកាវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាពដោយសភាដូចមានពន្យល់នៅក្នុងប្រអប់ខាងក្រោម។

**ប្រអប់ទី ៥៨**

### បញ្ហាចម្បងៗរារាំងការត្រួតពិនិត្យថវិកាវិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាព

- ▷ **ការអវត្តមានក្របខណ្ឌរដ្ឋធម្មនុញ្ញ** - វាមានការលំបាកដែលអាចកើតឡើងដោយសារការអវត្តមាននូវក្របខណ្ឌរដ្ឋធម្មនុញ្ញដ៏ច្បាស់លាស់ ដែលផ្តល់សិទ្ធិអំណាចដល់តំណាងរាស្ត្រដើម្បីត្រួតពិនិត្យសកម្មភាពរបស់វិស័យសន្តិសុខ។
- ▷ **កង្វះព័ត៌មាន** - បន្ទាប់ពីបញ្ហាខ្វះក្របខណ្ឌរដ្ឋធម្មនុញ្ញមក ពុំមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលបង្កឲ្យមានការបញ្ចេញនូវព័ត៌មានរសើបនានា។ ដូច្នេះភាពមិនល្អឥតខ្ចោះ និងភាពស្រពិចស្រពិលនៅក្នុងក្របខណ្ឌច្បាប់អាចរារាំងនូវការខិតខំរបស់សភាក្នុងការពិនិត្យតាមដានលើសកម្មភាពវិស័យសន្តិសុខនេះ។ ផលវិបាកគឺថាសាធារណជន និងសភា ត្រូវបានគេដកហូតគណនេយ្យភាពរបស់ពួកគេ ដែលត្រូវបានធានាដោយប្រព័ន្ធលទ្ធិប្រជាធិបតេយ្យដ៏ល្អមួយ។

- ▷ **សកម្មភាព និងប្រភពប្រាក់ចំណូលនៃវិស័យសន្តិសុខ ដែលមានលក្ខណៈមិនច្បាស់លាស់** - លក្ខណៈជាក់ស្តែង និងអត្ថប្រយោជន៍ នៃប្រភពប្រាក់ចំណូលនៃវិស័យសន្តិសុខមិនច្បាស់លាស់សម្រាប់សកម្មភាពពិសេស (ជាពិសេសសកម្មភាពពាណិជ្ជកម្ម ដូចជា ប្រាក់ចំណេញរបស់ក្រុមហ៊ុន យោធា ឬប្រាក់ចំណេញពីការផ្តល់សេវាកម្មទាំងឡាយ) ជានិច្ចសភាមិនបានដឹង ឬសូម្បីមន្ត្រីយោធាខ្លួនឯងហ្នឹងក៏មិនដឹងផង។ សកម្មភាពទាំងនេះ ត្រូវតែមានគណនេយ្យភាពចំពោះសភា ដូចគ្នានឹងការផ្តល់ហិរញ្ញវត្ថុដល់វិស័យសន្តិសុខដែរ។
- ▷ **ការលាក់បាំងការចំណាយការពារជាតិ** - ការចំណាយវិស័យការពារជាតិលើប្រាក់សោធននិវត្តន៍ ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន ជាដើម ជាញឹកញាប់ត្រូវបានផ្ទេរចូលទៅក្នុងថវិការបស់ក្រសួង/វិស័យផ្សេងទៀត ដូចជាសុខុមាលភាព លំនៅដ្ឋាន ផ្លូវរថភ្លើង ជាដើម។ ការធ្វើបែបនេះ វាធ្វើឲ្យបាត់រូបរាងជាថវិកាការពារជាតិ ហើយវាធ្វើអោយសាធារណជន និងសភា មិនអាចធ្វើការវាយតម្លៃទៅលើការចំណាយការពារជាតិដ៏ពិតប្រាកដបាន។
- ▷ **ប្រព័ន្ធផ្សព្វផ្សាយទន់ខ្សោយ-** ប្រទេសជាច្រើនមានប្រព័ន្ធផ្សព្វផ្សាយទន់ខ្សោយ (ក្នុងន័យថាខ្វះជំនាញ និងធនធាន) ដែលមិនអាចធ្វើការតាមដាននូវការងាររបស់វិស័យសន្តិសុខ និងសភាបាន។ បញ្ហានេះ វាធ្វើឲ្យសាធារណជនទូទៅមិនអាចទទួលបាននូវព័ត៌មានថ្មីៗ និងត្រូវបានធ្វើបច្ចុប្បន្នភាពអំពីសកម្មភាពរបស់តំណាងរាស្ត្ររបស់ខ្លួន និងភាគីនៅក្នុងវិស័យសន្តិសុខ។
- ▷ **មានពេលវេលាតិចពេកសម្រាប់ធ្វើការត្រួតពិនិត្យដ៏សមស្រប** - ដូចដែលបានលើកឡើងខាងដើម ការមានពេលវេលាតិចពេកសម្រាប់ធ្វើការត្រួតពិនិត្យលើថវិកាការពារជាតិ វាអាចធ្វើឲ្យការត្រួតពិនិត្យដោយសភាមិនមានប្រសិទ្ធភាព។
- ▷ **ខ្វះហេដ្ឋារចនាសម្ព័ន្ធ ជំនាញ និងបុគ្គលិក-** សភាភាគច្រើនខ្វះ ហេដ្ឋារចនាសម្ព័ន្ធ ជំនាញ និងបុគ្គលិកដើម្បីអនុវត្តនូវរាល់តម្រូវការទាំងអស់ដែលចាំបាច់ ដើម្បីធានាថា នីតិប្រតិបត្តិមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋដែលខ្លួនបម្រើ។

## ការត្រួតពិនិត្យថវិកានៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ

រលកលទ្ធិប្រជាធិបតេយ្យ ដែលបានបក់បោកចូលទៅក្នុងទ្វីបអឺរ៉ុប ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ បានបង្ហាញថាការអនុវត្ត ការត្រួតពិនិត្យដោយសភា ពិតជាមានការពាក់ព័ន្ធជាពិសេសជាមួយប្រទេសកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដមែន។ ប្រអប់ទី ៥៩ ពន្យល់យ៉ាងលំអិតអំពីការអនុវត្តថវិកានៅក្នុងរដ្ឋអឺរ៉ុបភាគអាគ្នេយ៍ ដែលបានបញ្ចូលប្រព័ន្ធនយោបាយរបស់ពួកគេទៅក្នុងក្របខណ្ឌនៃការរៀបចំថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព។

**ប្រអប់ទី ៥៩**

**ការអនុវត្តថវិកាការពារជាតិនៅក្នុងរដ្ឋមួយចំនួននៅក្នុងអឺរ៉ុបភាគអាគ្នេយ៍ (គិតត្រឹមឆ្នាំ២០០១)**

**ប្រទេសអាល់បានី៖** ការិយាល័យគ្រប់គ្រងថវិកាត្រូវបានបង្កើតឡើងនៅក្នុងខែតុលា ឆ្នាំ ២០០០។ ឯកសារគោលនយោបាយការពារជាតិត្រូវ បានបោះពុម្ពផ្សាយដោយគូសបញ្ជាក់ពីលក្ខខណ្ឌការពារជាតិរហូតដល់ឆ្នាំ២០០៨។ក្រសួងការពារជាតិជាអ្នកទទួលខុសត្រូវចំពោះ ដំណើរការនៃការរៀបចំថវិកាជាតិ។

**ប្រទេសប៊ុលហ្គារី៖** ថវិកាការពារជាតិត្រូវបានពិភាក្សាដោយសភាជាតិ (សភាប៊ុលហ្គារី) អស់រយៈពេល១០ឆ្នាំ។ មានការរំពឹងជាទូទៅថាសភា នឹង កែលំអសមត្ថភាពត្រួតពិនិត្យរបស់ខ្លួនដើម្បីឲ្យការងារត្រួតពិនិត្យលើវិស័យសន្តិសុខនេះមានលក្ខណៈពេញលេញ។

**ប្រទេសក្រូអាត៖** ថវិកាត្រូវបានរដ្ឋាភិបាលជាអ្នកស្នើ បន្ទាប់មកទើបដាក់ជូនសភា និងត្រូវបានបោះពុម្ពផ្សាយនៅក្នុង "ព្រឹត្តបត្រព័ត៌មានផ្លូវការ"។ ដំណើរការធ្វើថវិកាចាប់ពី ខែកក្កដា ដល់ខែវិច្ឆិកា រួចដាក់ទៅក្រសួងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ។ សភាសម្រេចត្រឹមតែលើចំនួនសរុបនៃថវិកាការពារជាតិប៉ុណ្ណោះ តែមិនមានសិទ្ធិអំណាចសម្រេចលើរចនាសម្ព័ន្ធថវិកាឡើយ។

**សាធារណៈរដ្ឋម៉ាសេដូនី៖** ក្រសួងការពារជាតិជាអ្នករៀបចំសំណើថវិកា បន្ទាប់មកដាក់ទៅក្រសួងហិរញ្ញវត្ថុ។ នៅដំណាក់កាលនេះ មានការពិភាក្សាគ្នាជាមួយក្រសួងដទៃដើម្បីផ្ទៀងផ្ទាត់ជាមួយលទ្ធភាពរបស់ប្រទេស។ បន្ទាប់មកថវិកាត្រូវបានដាក់ទៅរដ្ឋាភិបាល។ បន្ទាប់ពីមានការពិនិត្យរួចរាល់ហើយថវិកាក៏បានបញ្ជូនទៅសភា។ រដ្ឋមន្ត្រីការពារជាតិដាក់សំណើថវិកាជូនគណៈកម្មការគោលនយោបាយផ្ទៃក្នុង និងការពារជាតិ។ បន្ទាប់ពីមានការបោះឆ្នោត ថវិកាត្រូវបានពង្រាងបញ្ចូលជាក្រិតដោយប្រធាន។ ថវិកាជាតិគឺ ២.១២% នៃ GDP។

**ប្រទេសរ៉ូម៉ានី៖** ប្រព័ន្ធធ្វើផែនការកម្មវិធីថវិកា និង វាយតម្លៃ (PPBES) ត្រូវបានអនុវត្តចាប់តាំងពីខែមករា ឆ្នាំ២០០០ ដោយក្រសួងការពារជាតិ។ គោលបំណងរបស់ប្រព័ន្ធនេះ គឺត្រូវពង្រឹងតម្លាភាពចំពោះរាល់សកម្មភាពទាំងអស់របស់វិស័យសន្តិសុខ។ មានគណៈកម្មការមួយចំនួននៅក្នុងសភាដែលមានការពាក់ព័ន្ធនៅក្នុងដំណើរការនៃការធ្វើថវិកានេះ៖ ការពារជាតិសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ថវិកាហិរញ្ញវត្ថុ និងធនាគារ។ នាយកដ្ឋាននៅខាងក្នុងក្រសួងការពារជាតិមានឈ្មោះថានាយកដ្ឋានទំនាក់ទំនងជាមួយសភាច្បាប់សុខដុមនីយកម្ម និងទំនាក់ទំនងសាធារណៈ។ ឯកសារផែនការ-ការពារជាតិសំខាន់ត្រូវបានផ្សព្វផ្សាយនៅលើអ៊ីនធឺណែត។

# ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

## វិស័យសន្តិសុខនៅក្នុងវគ្គថវិកា

▷ សភាត្រូវយកចិត្តទុកដាក់ចំពោះវិស័យសន្តិសុខ នៅក្នុងដំណាក់កាលសំខាន់ៗ ៤ នៃវដ្តថវិកា៖ ដំណាក់កាលរៀបចំថវិកា ដំណាក់កាលអនុម័តថវិកា ដំណាក់កាលអនុវត្តថវិកា និងដំណាក់កាលធ្វើសវនកម្មលើការចំណាយថវិកា។

▷ ត្រូវធានាឲ្យមានការត្រួតពិនិត្យ ដោយស្ថាប័នសវនកម្ម ដែលបង្កើតដោយច្បាប់។

▷ សភា និងស្ថាប័នត្រួតពិនិត្យដទៃទៀត គួរធ្វើសវនកម្មលើទំនាក់ទំនងនៃតម្រូវការថវិកា និងលទ្ធផលរបស់វា (ការធ្វើសវនកម្មលើលទ្ធផលសកម្មភាព)។

## ចំណាត់ការសភាប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យមានតម្លាភាពនៅក្នុងការធ្វើថវិកាវិស័យសន្តិសុខ

▷ តម្រូវថា ត្រូវរៀបចំថវិកាទៅតាមគោលការណ៍ដែលបានពន្យល់ នៅក្នុងជំពូកនេះស្តីពីការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព។

▷ ព្យាយាមសុំជំនួយពីអ្នកជំនាញឯករាជ្យដែលអាចជួយសភា ឬខ្លួនអ្នកផ្ទាល់ក្នុងការវាយតម្លៃលើសំណើសុំថវិកាសន្តិសុខ ថាតើវាសមស្របនិងពាក់ព័ន្ធដែរឬទេ ហើយការដាក់សំណើនេះ ត្រូវធ្វើក្នុងទម្រង់មួយប្រកបដោយតម្លាភាព។

▷ ធានាថា សេវាសន្តិសុខកំពុងប្រើប្រាស់នូវវិធីសាស្ត្រទំនើប ក្នុងការធ្វើផែនការហិរញ្ញវត្ថុ និងថវិកាដែលអាចឲ្យសភា ធ្វើការវាយតម្លៃទៅលើការចំណាយលើការពារជាតិបានដោយស្របច្បាប់ និងមានការយល់ពីទំនាក់ទំនងរវាងគោលបំណងថវិកាដែលបានផ្តល់ឲ្យ និងលទ្ធផលទទួលបាន។

▷ តាមដានស្ថានភាពនៅក្នុងសភារបស់អ្នកដោយប្រើប្រាស់នូវចំណុចពន្យល់នៅក្នុងប្រអប់ទី៥៨ និងផ្តួចផ្តើមគំនិតដើម្បីកែលំអចំណុចខ្សោយរបស់អ្នក ទៅតាមបរិបទនយោបាយរបស់ប្រទេសអ្នក។

*IPU and DCAF – Parliamentary oversight of the security sector, 2003*

ជំពូកទី ២៤

# ការធ្វើសវនកម្ម (audit) លើការចំណាយថវិកាជាតិទាក់ទងនឹងវិស័យសន្តិសុខ

## សភា និងការិយាល័យសវនកម្មជាតិ

ការទទួលខុសត្រូវរបស់សភាចំពោះថវិកាជាតិ មិនមែនចប់ត្រឹមសភាធ្វើការអនុម័តលើថវិកានោះទេ។ សភាត្រូវបំពេញតួនាទីជាអ្នកត្រួតពិនិត្យ និង ធ្វើសវនកម្មដោយចងចាំថាការធ្វើសវនកម្មបញ្ជីគណនេយ្យដ៏ពេញលេញទៅលើសេវាសន្តិសុខជាផ្នែកមួយ នៃដំណើរការតាមលទ្ធិប្រជាធិបតេយ្យ ហើយចងចាំថាដំណើរការសវនកម្មត្រូវគ្របដណ្តប់ទាំងការធ្វើសវនកម្មលើតួលេខ និងការធ្វើសវនកម្មទាំងលទ្ធផលអនុវត្ត។ បញ្ជីចំណូលចំណាយ និងរបាយការណ៍ប្រចាំឆ្នាំរបស់សេវាសន្តិសុខ គឺជាប្រភពដ៏សំខាន់មួយសម្រាប់សភាធ្វើការវាយតម្លៃថា តើមានប្រាក់ប៉ុន្មានត្រូវបានចំណាយនៅក្នុងឆ្នាំថវិកាឆ្នាំមុន។

ក្នុងមុខនាទី ជាអ្នកត្រួតពិនិត្យសភា ត្រូវទទួលជំនួយពីស្ថាប័នឯករាជ្យដែលជាការិយាល័យសវនកម្មជាតិមួយ (ពេលខ្លះគេហៅថាការិយាល័យអគ្គសវនកម្មជាតិ ការិយាល័យថវិកា ឬការិយាល័យគណនេយ្យ) ដែលគួរតែត្រូវបានបង្កើតឡើងដោយច្បាប់រដ្ឋធម្មនុញ្ញជាស្ថាប័នឯករាជ្យមួយរបស់ផ្នែកនៃ នីតិប្រតិបត្តិ នីតិបញ្ញត្តិ និង តុលាការ។ តាមពិតសភាគួរធានាថាអគ្គសវនករ៖

- ✓ ត្រូវបានតែងតាំងដោយសភា និង មានអាណត្តិការងារដ៏ច្បាស់លាស់។
- ✓ មានមធ្យោបាយតាមផ្លូវច្បាប់និងធនធានដើម្បីបំពេញបេសកកម្មរបស់ពួកគេដោយឯករាជ្យ។
- ✓ មានសិទ្ធិអំណាចឯករាជ្យក្នុងការរាយការណ៍ទៅសភា និងគណៈកម្មការថវិការបស់ខ្លួននៅពេលណាក៏បាន អំពីបញ្ហាណាមួយទាក់ទងនឹងការចំណាយ។

សភាត្រូវត្រួតពិនិត្យមើល ថាតើមានការដាក់ទោសតាមផ្លូវតុលាការ ដែលមានចែងដោយច្បាប់ដែរឬទេ ចំពោះករណីនៃអំពើពុករលួយ និងការចាត់ចែងមិនត្រឹមត្រូវនូវធនធានរបស់រដ្ឋដោយមន្ត្រី និង ស្ថាប័ននយោបាយ។ សភាគួរត្រួតពិនិត្យផងដែរ ថាតើមានការប៉ះប៉ូវសងវិញដែរឬទេ ក្នុងករណីមានការចោទប្រកាន់ខុស។

**ប្រអប់ទី ៦០**

## អគ្គសវនករ

"ទោះបីជាអគ្គសវនករស្ថិតនៅក្រោម អង្គការនីតិប្រតិបត្តិ នីតិបញ្ញត្តិ ឬ តុលាការ ក៏ដោយ ក៏វាចាំបាច់ណាស់សម្រាប់ការិយាល័យសវនកម្មត្រូវតែឯករាជ្យ និងស្វ័យយ័តពិតប្រាកដ។ ការិយាល័យមួយនេះ ត្រូវមានធនធានគ្រប់គ្រាន់ ដើម្បីបំពេញបេសកកម្មរបស់ខ្លួនឲ្យបានជោគជ័យ។ មុខងាររបស់ការិយាល័យនេះមាន ៣៖

### ធ្វើការត្រួតពិនិត្យហិរញ្ញវត្ថុ

ការិយាល័យសវនកម្ម ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ពីសុក្រិតភាព ភាពជឿជាក់ និងភាពពេញលេញនៃហរិញ្ញវត្ថុរបស់អង្គភាពទាំងអស់ របស់អង្គការនីតិប្រតិបត្តិ និងនាយកដ្ឋានសាធារណៈ។ ការិយាល័យនេះ ត្រូវពិនិត្យផ្ទៀងផ្ទាត់ថារាល់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ ត្រូវបានអនុវត្តស្របតាមលិខិតបទដ្ឋានស្តីពីមូលនិធិសាធារណៈ។ នៅក្នុងបរិបទនៃការបំពេញមុខងារត្រួតពិនិត្យ ការិយាល័យសវនកម្ម ត្រូវបំពេញបេសកកម្មជាគណនេយ្យករ និងមន្ត្រីដែលអនុញ្ញាតឲ្យមានការទូទាត់ប្រាក់។ ពួកគេត្រូវមានគណនេយ្យភាពចំពោះសាច់ប្រាក់ ពួកគេបានចាត់ចែង លើកលែងតែក្នុងករណីដែលមិនមែនជាការទទួលខុសត្រូវរបស់ពួកគេ។ ក្នុងករណីមានការចាយវាយមិនត្រឹមត្រូវ ឬមានអំពើពុករលួយ ការិយាល័យសវនកម្មមានកាតព្វកិច្ចក្នុងការរាយការណ៍អំពីលទ្ធផលរបស់ពួកគេទៅកាន់តុលាការ។

### ការត្រួតពិនិត្យតាមដានផ្លូវច្បាប់

ការិយាល័យសវនកម្ម ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ថារាល់ការចំណាយ និងចំណូលសាធារណៈទាំងអស់ត្រូវតែបានធ្វើស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថវិកា។

### ការធានានូវការប្រើប្រាស់ដ៏សមស្របនូវមូលនិធិសាធារណៈ

ការិយាល័យសវនកម្មទំនើបដែលបំពេញមុខនាទី ជាអ្នកអភិបាលកិច្ចល្អត្រូវធានាឲ្យមានការប្រើប្រាស់ដ៏សមស្របនូវមូលនិធិសាធារណៈ ដោយផ្អែកលើមូលដ្ឋាននៃលក្ខខណ្ឌវិនិច្ឆ័យ ៣ខាងក្រោម៖

I. *ការប្រើប្រាស់ធនធានឲ្យចំគោលដៅ៖* ត្រូវធានាថា ធនធានត្រូវបានប្រើប្រាស់ដើម្បីជាផលប្រយោជន៍ជាអតិបរមាទាំងគុណភាព និងបរិមាណ។
II. *ប្រសិទ្ធភាព៖* ចាត់វិធានការដើម្បីធ្វើឲ្យសម្រេចគោលបំណងដែលបានកំណត់។
III. *ប្រសិទ្ធិផល៖* ចាត់វិធានការដើម្បីឲ្យមានការប្រើប្រាស់ធនធាន ដើម្បីសម្រេចបាននូវលទ្ធផលជាអតិបរមា។

ការត្រួតពិនិត្យទាំងមុន និងក្រោយ ត្រូវធ្វើតាមគំនិតផ្តួចផ្តើមរបស់ការិយាល័យសវនកម្ម ឬតាមសំណើរបស់សភា”។

*សម្រង់ពីរបាយការណ៍ទូទៅនៃសិក្ខាសាលា IPU ស្តីពីសភា និងដំណើរការថវិកាដោយមានបញ្ចូលទស្សនវិស័យយេនឌ័រ (Bamako, Mali, ខែវិច្ឆិកា ឆ្នាំ២០០១)*

## ការធ្វើសវនកម្មថវិកាលើវិស័យសន្តិសុខក្នុងការអនុវត្តជាក់ស្តែង

ការធ្វើសវនកម្មថវិកាវិស័យសន្តិសុខពិតជាដំណើរការដ៏ស្មុគ្រស្មាញមួយសម្រាប់សភាមែន ដោយសារតែវាមានការពាក់ព័ន្ធជាមួយការវិភាគទៅលើរបាយការណ៍សវនកម្ម ដែលមានបញ្ហាខ្លះមានទំនាក់ទំនងផ្ទាល់ និង បញ្ហាខ្លះមានទំនាក់ទំនងដោយប្រយោល ជាមួយវិស័យសន្តិសុខ ឧ. បញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម ការធ្វើទំនាក់ទំនង ឬការផ្ទេរប្រាក់។ ការប្រឈមដ៏ធំគឺការយល់ដឹងមិនច្បាស់អំពីទំនាក់ទំនងនៃសកម្មភាពដែលមិនមានទំនាក់ទំនងនឹងគ្នា។

ជាក់ស្តែង ក្រសួងសាម៉ីផ្នែកសន្តិសុខ ការពារជាតិ មហាផ្ទៃ ពាណិជ្ជកម្ម ឧស្សាហកម្ម គមនាគមន៍ និងហិរញ្ញវត្ថុ ជាទម្លាប់ត្រូវដាក់ជូនសភាជាទៀងទាត់នូវរបាយការណ៍ដ៏ពេញលេញស្តីពី របៀបដែលពួកគេចំណាយថវិកាដែលបានវិភាជន៍ទៅឲ្យ។ នីតិវិធីដែលសភាប្រើប្រាស់អាចមាន៖ ការពិនិត្យរបាយការណ៍ប្រចាំឆ្នាំដែលផ្ញើមកពីក្រសួងនីមួយៗ ការពិនិត្យមើលឡើងវិញអំពីការចាត់ចែងបែងចែកថវិកានីមួយៗដោយគណៈកម្មការសភា ការធ្វើសវនកម្មបញ្ជីគណនេយ្យប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ការពិភាក្សាដេញដោលជាមួយក្រសួងនីមួយៗនៅក្នុងសភាជាដើម។

ដូច្នេះ ដំណើរការធ្វើសវនកម្មអាចជួយសភាក្នុងការវាយតម្លៃថា តើវដ្តថវិកាត្រូវបានគោរពតាមគោលការណ៍នីត្យានុកូលភាព ប្រសិទ្ធិផលនៃការចំណាយ និងប្រសិទ្ធភាពក្នុងការធ្វើឲ្យសម្រេចជោគជ័យតាមគោលបំណងដែលបានកំណត់ឬយ៉ាងណា។

**ប្រអប់ទី ៦១**

### តួនាទីនៃការិយាល័យសវនកម្មជាតិ របស់ចក្រភពអង់គ្លេសក្នុងការត្រួតពិនិត្យដោយសភា លើវិស័យសន្តិសុខ

ដោយត្រូវបានបង្កើតឡើងជាស្ថាប័នឯករាជ្យមួយក្នុងឆ្នាំ១៩៨៣ និងដឹកនាំដោយមន្ត្រីជម្រះបញ្ជីម្នាក់ និងអគ្គសវនករម្នាក់ (C&AG) ការិយាល័យសវនកម្មជាតិរបស់ចក្រភពអង់គ្លេស (NAO) ត្រូវរាយការណ៍ជូនសភាអំពីការចំណាយប្រាក់របស់រដ្ឋាភិបាលកណ្តាល។ NAO **ធ្វើសវនកម្មហិរញ្ញវត្ថុ** និងរាយការណ៍អំពី **លទ្ធផលដែលកើតពីការប្រើប្រាស់ថវិកានោះ**។

▷ **ធ្វើសវនកម្មហិរញ្ញវត្ថុ**

យោងតាមច្បាប់ C&AG និង NAO ទទួលខុសត្រូវចំពោះការធ្វើសវនកម្មលើគណនេយ្យរបស់នាយកដ្ឋាន និងភ្នាក់ងារទាំងអស់របស់រដ្ឋាភិបាល និងរាយការណ៍លទ្ធផលជូនសភា។ ជាមួយសវនករផ្សេងទៀត C&AG ត្រូវផ្តល់នូវគំនិតរបស់ខ្លួនអំពីគណនីយទាំងនោះ ថាតើពិតជាមិនមានការរាយការណ៍ខុសពីការពិតនោះទេ។ C&AG ក៏ត្រូវបញ្ជាក់ថារាល់ប្រតិបត្តិការនៅក្នុងគណនេយ្យ សុទ្ធតែបានទទួលការអនុញ្ញាតដ៏សមស្របពីសភារួចហើយ។ ប្រសិនបើ NAO បានរកឃើញនូវកំហុសណាមួយ C&AG នឹងបញ្ចេញនូវមតិយោបល់របស់ខ្លួន។ ក្នុងករណីដែលមិនមានកំហុស ឬភាពមិនប្រក្រតីនៅក្នុងគណនេយ្យទេនោះ C&AG អាចរៀបចំរបាយការណ៍ដាក់ជូនសភា អំពីបញ្ហាសំខាន់ៗផ្សេងទៀត។ របាយការណ៍បែបនោះ អាចត្រូវបានពិចារណាដោយគណៈកម្មការគណនេយ្យសាធារណៈរបស់សភាជាន់ទាប។

▷ **សវនកម្មលើលទ្ធផលសម្រេចបាន**

ជារៀងរាល់ឆ្នាំមានរបាយការណ៍ប្រហែល៥០របាយការណ៍ ត្រូវបានដាក់ជូនសភាដោយមន្ត្រីជម្រះបញ្ជី និងអគ្គសវនករអំពីលទ្ធផលសម្រេចបានដោយនាយកដ្ឋាន និងភ្នាក់ងាររដ្ឋាភិបាលបន្ទាប់ពីបានទទួលធនធានពីការិយាល័យសវនកម្ម។ ការិយាល័យសវនកម្មជាតិពិនិត្យ និងរាយការណ៍អំពីការសន្សំសំចៃប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការចំណាយសាធារណៈ។ ខណៈពេលដែលរបាយការណ៍អាចបង្ហាញនូវការអនុវត្តមិនបានល្អ ឬការអនុវត្តល្អ របាយការណ៍ក៏ផ្តល់នូវអនុសាសន៍ដើម្បីជួយធ្វើឲ្យសម្រេចបាននូវលទ្ធផលខ្ពស់ផងដែរ។ NAO ជឿថា តាមរយៈការអនុវត្តតាមអនុសាសន៍ទាំងអស់ដែលខ្លួនបានលើកឡើងក្នុងរយៈពេល ៣ឆ្នាំ រដ្ឋាភិបាលបានសន្សំប្រាក់បានចំនួន ១.៤៣ពាន់លានផោន។ របាយការណ៍អំពី សមិទ្ធិផលការពារជាតិបានគ្របដណ្តប់លើការចំណាយផ្សេងៗ ដូចជាឧទ្ធម្ភាគចក្រដឹកកសុភារ ការធ្វើអត្តសញ្ញាណកម្មក្រុមប្រយុទ្ធ ឃ្លាំងស្តុក និងជួសជុល និងកែលម្អឧបករណ៍ប្រើប្រាស់នៅលើដី និងការកសាងអាគារធំៗ របស់ក្រសួងការពារជាតិឡើងវិញ។ NAO ក៏រាយការណ៍អំពីវឌ្ឍនភាពនៃគម្រោងធំៗទាំង៣០ ផងដែរ។

▷ **ទំនាក់ទំនងជាមួយសភា និងវគ្គនៃគណនេយ្យភាព**

ទំនាក់ទំនងជាមួយសភា ជាពិសេសជាមួយគណៈកម្មការ គណនេយ្យសាធារណៈមានសារៈសំខាន់ខ្លាំងណាស់ចំពោះការងាររបស់ការិយាល័យសវនកម្ម។ យោងតាមលក្ខន្តិកៈ C&AG គឺជាមន្ត្រីរបស់សភាជាន់ទាប ហើយការងារដ៏ចម្បងរបស់មន្ត្រីរូបនេះ គឺធ្វើជាតំណាងសភា។ តាមវិធីនេះវគ្គនៃគណនេយ្យភាពអាចប្រតិបត្តិបាន។ នៅពេលដែលថវិកាសាធារណៈត្រូវបានចំណាយដោយរដ្ឋាភិបាលកណ្តាល C&AG មានសេរីភាពក្នុង

ការរាយការណ៍ជូនសភា អំពីភាពប្រក្រតីភាពសមស្របនិងសមិទ្ធិផលដែលទទួលបានពីការចំណាយថវិកានេះ។ គណៈកម្មការគណេយ្យសាធារណៈ អាចទទួលនូវភស្តុតាងដែលមាននៅក្នុងរបាយការណ៍នេះ ពីមន្ត្រីជាន់ខ្ពស់បំផុតនៅក្នុងស្ថាប័នសាធារណៈនោះ និងអាចលើកឡើងនូវអនុសាសន៍នានា ដែលរដ្ឋាភិបាលត្រូវធ្វើការឆ្លើយតប។ ក្រៅពីនេះ NAO ត្រូវឆ្លើយនូវសំណួរជាង ៥០០សំណួរ ពីសមាជិកសភាអំពីបញ្ហាដែលប៉ះពាល់ដល់ការចំណាយសាធារណៈ។

*ប្រភព៖ Tom McDonald, មន្ត្រីសវនករជាន់ខ្ពស់ ការិយាល័យសវនកម្មជាតិចក្រភពអង់គ្លេស ឆ្នាំ២០០២*

## ធាតុសំខាន់ៗរបស់ការិយាល័យសវនកម្ម

ការិយាល័យសវនកម្ម គឺជាឧបករណ៍ដ៏សំខាន់បំផុតមួយសម្រាប់សភា ក្នុងការត្រួតពិនិត្យ។ ការិយាល័យនេះ ត្រូវមានលក្ខណៈសម្បត្តិសំខាន់ៗដូចខាងក្រោម ដើម្បីខ្លួនអាចបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់៖

- ✓ អាជ្ញាធរសវនកម្មជាតិ រាយការណ៍ទៅគណៈកម្មការគណនេយ្យសភា ដែលជាគណៈកម្មការមួយខុសពីគណៈកម្មការថវិកា។
- ✓ ការិយាល័យនេះ គួរមានសិទ្ធិចូលឆែកមើលឯកសារសម្ងាត់នានា តែមិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឯកសារទាំងនោះទេ។
- ✓ ការិយាល័យនេះ ត្រូវមានសមត្ថភាពជាពហុវិស័យជាមួយជំនាញខាងវិស័យសន្តិសុខ ការគ្រប់គ្រងវិស័យការពារជាតិ បច្ចេកទេស ហិរញ្ញវត្ថុ និងច្បាប់។

**ប្រអប់ទី ៦២**

### សភារបស់ប្រទេសចចចា និងការត្រួតពិនិត្យថវិកា

នៅចុងឆ្នាំ២០០១ តំណាងរាស្ត្រនៃប្រទេសចចចាបានពន្យាការពិភាក្សាដេញដោលរបស់សភាអំពីច្បាប់ស្តីពីថវិកាឆ្នាំ២០០២ រយៈពេល១ខែ ពីព្រោះមានការខ្វែងយោបល់គ្នាអំពីតួលេខជាមូលដ្ឋាន និងកង្វះពេលវេលាសម្រាប់ធ្វើការពិភាក្សា ពីព្រោះរដ្ឋាភិបាលបានផ្ញើសេចក្តីព្រាងថវិកាមកយឺតពេក។ ទន្ទឹមនោះ ដោយមានជំនួយពីអ្នកជំនាញអាមេរិក ក្រសួងការពារជាតិបានរៀបចំកម្មវិធីថវិកាការពារជាតិមួយ ដែលមិនធ្លាប់មានពីមុនមក។ តំណាងរាស្ត្រមានឱកាសពិនិត្យមើលធាតុនៃរចនាសម្ព័ន្ធជាមូលដ្ឋាននៃកងកម្លាំងប្រដាប់អាវុធ និង ផ្តល់នូវមតិយោបល់អំពីការចំណាយលើការពារជាតិ។ ក្រៅពីនេះ សេចក្តីព្រាងថវិកាដែលបានរៀបចំតាមស្តង់ដារអង្គការណាតូ បានបែងចែកការចំណាយជាពផ្នែក៖ បុគ្គលិកជួសជុលឧបករណ៍សម្ភារៈ និង វិនិយោគ។

យោងតាមទស្សនៈនៃការគ្រប់គ្រងដោយសភា បញ្ហាសំខាន់ គឺថាសភាបានអនុម័តយល់ព្រមលើ

ថវិកានៅចុងខែមករា ឆ្នាំ២០០២ និងថា ក) ប្រធានាធិបតី រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីការពារជាតិ មានទស្សនៈខុសគ្នាលើការចំណាយដ៏ច្រើនលើវិស័យការពារជាតិ ខ) មានការកែប្រែភ្លាមៗនៅក្នុងតួលេខថវិកាដែលមិនបានពន្យល់ដល់តំណាងរាស្ត្រ គ) តំណាងរាស្ត្រមិនត្រូវបានគេជម្រាបជូនអំពី កាលវិភាគនៃការកាត់បន្ថយបុគ្គលិកនៅក្នុងក្រសួងការពារជាតិ និងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុមកលើវិធានការកាត់បន្ថយបុគ្គលិកនេះ។ ទន្ទឹមនោះ សំណើសុំថវិការបស់ភ្នាក់ងាររដ្ឋាភិបាលដែលមិនទាន់បានបញ្ចូលទៅក្នុងច្បាប់ថវិកា ត្រូវបានរួចផុតពីការត្រួតពិនិត្យរបស់សភា។

នៅចុងក្រោយ កម្មវិធីថវិកាការពារជាតិបានទទួលរងនូវការប៉ះពាល់យ៉ាងខ្លាំង ពីព្រោះសភាបានអនុម័តយល់ព្រមត្រឹមតែ៣៨លានដែល (38 million GEL) (លុយនៃប្រទេសចចចា) សម្រាប់ការចំណាយការពារជាតិ ខណៈដែលកម្មវិធីថវិកានោះត្រូវការសរុបរហូតដល់ ៧១លានដែល។ នៅក្នុងបរិបទនេះ ប្រធានាធិបតី និងក្រុមប្រឹក្សាសន្តិសុខជាតិ នឹងសម្រេចពីរបៀបត្រូវចាត់ចែងបែងចែកមូលនិធិថវិកាទៅឲ្យស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល។ សភាអាច ឆ្លៀតយកឱកាសដ៏មានតម្លៃនេះ ដើម្បីអនុវត្តនូវការត្រួតពិនិត្យបែបប្រជាធិបតេយ្យតាមរយៈនីតិវិធីសភា ដើម្បីពិភាក្សាដេញដោល និងអនុម័តយល់ព្រមលើថវិកាដែលបានស្នើ។

*ប្រភព៖ David Darchiashvili ប្រធានផ្នែកស្រាវជ្រាវសភា នៃសភាប្រទេសចចចា ឆ្នាំ២០០២*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ការធ្វើសវនកម្មដោយឯករាជ្យ និង មានប្រសិទ្ធភាព

- ▷ ជម្រុញឲ្យមានការបញ្ចូលនូវការបង្កើតនូវស្ថាប័នសវនកម្មកំពូលមួយទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ដែលមានចែងអំពី៖
  - លក្ខណៈនិងវិសាលភាពនៃទំនាក់ទំនងរវាងស្ថាប័នសវនកម្មជាតិនិងសភា។
  - ឯករាជ្យភាពរបស់ស្ថាប័នសវនកម្មជាតិ និងសមាជិក ព្រមទាំងមន្ត្រីរបស់ស្ថាប័ននេះ ក៏ដូចជា ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័ន។
  - ចែងពីការពិនិត្យតាមដាននូវការឆ្លើយតប និងវិធានការរបស់រដ្ឋាភិបាលបន្ទាប់ពីមានការធ្វើរបាយការណ៍ ដោយការិយាល័យសវនកម្ម និង គណៈកម្មការគណនេយ្យសាធារណៈរបស់សភា។
- ▷ ពិនិត្យថា តើគោលការណ៍ដែលមានចែងនៅក្នុងសេចក្តីប្រកាសលីម៉ា ស្តីពីគោលការណ៍ណែនាំអំពីច្បាប់សវនកម្ម (the Lima Declaration of Guidelines on Auditing Precepts) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ជាតិ និងការអនុវត្តរបស់អ្នកដែរឬទេ។
  សេចក្តីប្រកាសនេះ អាចរកបាននៅលើគេហទំព័ររបស់អង្គការអន្តរជាតិរបស់វិទ្យាស្ថានសវនកម្មកំពូលគឺ www.intosai.org ។

### សវនកម្មតាមនីត្យានុកូលភាព ប្រក្រតីភាពសវនកម្ម និង សកម្មភាពសវនកម្ម

- ពិនិត្យមើលថា តើស្ថាប័នសវនកម្មជាតិបានយកចិត្តទុកដាក់លើទិដ្ឋភាពទាំង ៣ នេះដែរឬទេ ទាក់ទងនឹងបញ្ហាសន្តិសុខ។
- ពិនិត្យមើលថា ទោះបីជាមានការធ្វើសវនកម្មក្រោយការចំណាយលើវិស័យសន្តិសុខក៏ដោយ ក៏សភាបានរៀនសូត្រ និងដកបទពិសោធន៍ដ៏ចាំបាច់ ព្រមទាំងធ្វើការពិចារណានូវបញ្ហាពាក់ព័ន្ធនានា នៅពេលដែលកំពុងពិភាក្សាលើថវិកាវិស័យសន្តិសុខនៅពេលក្រោយ។
- របាយការណ៍សវនកម្មភាគច្រើនមានការធ្វើសវនកម្មលើហិរញ្ញវត្ថុបន្តិចបន្តួច។ អាជ្ញាធរសវនកម្មស្របច្បាប់ គួរតែអាចធ្វើសវនកម្មលើគម្រោងដ៏ជាក់លាក់ជាលំអិត ឬប្រើប្រាស់ទីប្រឹក្សាដើម្បីធ្វើការវាយតម្លៃឯករាជ្យ ប្រសិនបើអាជ្ញាធរសវនកម្មនេះ ខ្វះខាតនូវជំនាញរបស់ខ្លួន។
- អាជ្ញាធរសវនកម្មស្របច្បាប់ ក៏គួរធ្វើសវនកម្មលើការបំពេញមុខងាររបស់អង្គភាពហិរញ្ញវត្ថុនៃសេវាសន្តិសុខផងដែរ។

## ផ្នែកទី VII

# ធនធានមនុស្សនៅក្នុងវិស័យសន្តិសុខ៖ ការធានាឲ្យមានវិជ្ជាជីវៈ និង ការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ

ជំពូកទី ២៥

# ការលើកកម្ពស់តម្លៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងវិស័យសន្តិសុខ

ការរៀនសូត្រអំពីលទ្ធិប្រជាធិបតេយ្យ និងឥរិយាបថរបស់កងកម្លាំងប្រដាប់អាវុធ ចាំបាច់ត្រូវតែលើកកម្ពស់ដើម្បីឲ្យពួកគេអាចធ្វើសមាហរណកម្មចូលទៅក្នុងសង្គម និងមិនបង្កការគម្រាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ។ នៅក្នុងផ្នែកផ្សេងៗនៃពិភពលោកបទពិសោធន៍បានបង្ហាញថា យោធាមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវ និងតាមបែបប្រជាធិបតេយ្យ ឬមិនបានបញ្ចូលពេញលេញទៅក្នុងស្រទាប់សង្គម ហើយបញ្ហានេះ វាអាចបង្កជាការគម្រាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ៖

- ✓ ពួកគេអាចប្រើប្រាស់ឥទ្ធិពលរំលោភលើរដ្ឋធម្មនុញ្ញ ឬអាចធ្វើរដ្ឋប្រហារយោធា។
- ✓ ពួកគេអាចធ្វើសកម្មភាពយោធាតាមទំនើងចិត្ត ឬអាចធ្វើការជួញដូរផ្សេងៗ។
- ✓ ពួកគេអាចស្រូបយកធនធានច្រើនជ្រុលហួសហេតុ ដែលចាំបាច់សម្រាប់ប្រើប្រាស់នៅក្នុងវិស័យដទៃទៀតនៅក្នុងសង្គម។
- ✓ ពួកគេអាចប្រើប្រាស់មិនត្រឹមត្រូវនូវមូលនិធិដែលបានចាត់ចែងបែងចែកឲ្យ។
- ✓ ពួកគេអាចរំលោភសិទ្ធិមនុស្ស (ឧ. លួច ប្លន់ ធ្វើអំពើខុសច្បាប់ផ្សេងៗដោយហិង្សា ឬចាប់រំលោភកូនគេជាដើម)។

## យន្តការសម្រាប់បណ្តុះបណ្តាលបុគ្គលិកអោយប្រកាន់យកឆន្ទៈប្រជាធិបតេយ្យ នៅក្នុងវិស័យសន្តិសុខ

ការលើកកម្ពស់ឥរិយាបថប្រជាធិបតេយ្យរបស់កងកម្លាំងប្រដាប់អាវុធមានន័យថា ជាការបង្កើតនូវយន្តការនៅក្នុងអង្គការយោធាដែលរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹង និងការគោរពលទ្ធិប្រជាធិបតេយ្យ គោរពស្ថាប័ននិងគោលការណ៍សិទ្ធិមនុស្ស។ យន្តការផ្ទៃក្នុងទាំងនេះ វាចាំបាច់ខ្លាំងណាស់ដើម្បីបំពេញបន្ថែមដល់ការត្រួតពិនិត្យរបស់សភា រដ្ឋាភិបាល និងសាធារណជនទៅលើកងកម្លាំងប្រដាប់អាវុធ។ លក្ខណៈសម្បត្តិខាងក្រោមអាចជួយក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យដល់កងកម្លាំងប្រដាប់អាវុធ។

## ការមានស្វាមីភក្តិចំពោះរដ្ឋធម្មនុញ្ញ និងស្ថាប័នរដ្ឋ

អភិបាលកិច្ចល្អ រួមមានការបណ្តុះសីលធម៌ ការគោរពនីតិរដ្ឋ និងរដ្ឋធម្មនុញ្ញ និងស្ថាប័នជាតិនៅក្នុងវិស័យសន្តិសុខ។ ទាហាន និង អ្នកការពារសង្គមប្រជាធិបតេយ្យដទៃទៀត ត្រូវស្បថថាខ្លួន ត្រូវមានស្វាមីភក្តិចំពោះរដ្ឋធម្មនុញ្ញ និង ស្ថាប័នរដ្ឋមិនមែនមានស្វាមីភក្តិចំពោះមេដឹកនាំនយោបាយនោះទេ។ ការស្បថ "មិនចំពោះមុខ" អំពីការមានស្វាមីភក្តិនេះ គឺជានិមិត្តរូបតំណាងឲ្យពាក្យថា សេវាសន្តិសុខមិនត្រឹមមានភាពស្មោះត្រង់ចំពោះរដ្ឋាភិបាលបច្ចុប្បន្ននេះប៉ុណ្ណោះនោះទេ តែត្រូវគោរពរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលបានអនុម័តដោយតំណាងស្របច្បាប់របស់ប្រជាពលរដ្ឋ។ ការត្រួតពិនិត្យដោយប្រជាពលរដ្ឋលើវិស័យសន្តិសុខ គួរមានដូចជា ការដឹងអំពីសម្បថជាក់លាក់របស់យោធា និងតើត្រូវធ្វើដូចម្តេច ដើម្បីឲ្យយោធាអនុវត្តតាមសម្បថរបស់ខ្លួន។

## បទបញ្ញាផ្ទៃក្នុងដែលបានកំណត់យ៉ាងល្អនៃវិស័យសន្តិសុខ

វាសំខាន់ខ្លាំងណាស់ ក្នុងការបញ្ចូលក្របខណ្ឌច្បាប់ ទាក់ទងនឹងការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យទៅក្នុងបទបញ្ញាផ្ទៃក្នុងនៃវិស័យសន្តិសុខ ដូចជា៖

- ✓ ការដាក់កំហិតសិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់មន្ត្រីយោធា។
- ✓ ការអនុម័ត ឬពិនិត្យឡើងវិញនូវច្បាប់ជ្រើសរើសកងទ័ពច្បាប់ស្តីពីការចូលបម្រើកងទ័ពក្រមព្រហ្មទណ្ឌយោធា ដោយបញ្ចូលក្របខណ្ឌច្បាប់ ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ។
- ✓ ការគោរពបទបញ្ញាគឺជាកាតព្វកិច្ចរបស់បុគ្គលិកយោធា។

នៅក្នុងរដ្ឋភាគច្រើននៅពេលដែលរដ្ឋធម្មនុញ្ញធានាសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋគ្រប់រូប ច្បាប់នៅក្រោមរដ្ឋធម្មនុញ្ញមួយចំនួន អាចរឹតត្បិតសិទ្ធិរបស់យោធាក្នុងករណីដែលពួកគេត្រូវបានប្រគល់ភារកិច្ចដ៏ជាក់លាក់មួយចំនួន។ ដូច្នេះជាគោលការណ៍ យោធាមានសិទ្ធិដូចជាប្រជាពលរដ្ឋដទៃ ពីព្រោះយោធាក៏ជាប្រជាពលរដ្ឋដែរខុសគ្នាត្រង់ពួកគេមានឯកសណ្ឋាន។

ទោះដូច្នេះក្តី យោធាទទួលរងនូវការរឹតត្បិតនូវសេរីភាពនៃការបញ្ចេញមតិ សិទ្ធិចូលពិនិត្យមើលឯកសារសម្ងាត់ សេរីភាពត្រាច់ចរ (freedom of movement) ពីព្រោះវាពាក់ព័ន្ធជាមួយការត្រៀមខ្លួនរួចរាល់របស់យោធា/វិស័យសន្តិសុខ និងសិទ្ធិត្រូវបានគេបោះឆ្នោតនៅក្នុងតំណែងនយោបាយ។ មិនមែនរាល់ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យទាំងអស់ សុទ្ធតែរឹតត្បិតសិទ្ធិពលរដ្ឋរបស់យោធានោះទេ។ ឧទាហរណ៍ នៅក្នុងប្រទេសទាំងឡាយនៅតំបន់ស្កង់ឌីណាវ ដូចជាប្រទេសអាល្លឺម៉ង់ និងប្រទេសហុល្លង់ យោធាមានសិទ្ធិបង្កើត និងចូលរួមនៅក្នុងសហជីព។ នៅក្នុងរដ្ឋដទៃ យោធាមានសិទ្ធិបង្កើតនិងចូលរួមនៅក្នុងសមាគមតែប៉ុណ្ណោះ។ ទោះដូច្នេះក៏ដោយ ក្នុងគ្រប់ករណីរាល់ការរឹតត្បិតទាំងឡាយត្រូវតែចែងឲ្យច្បាស់នៅក្នុងច្បាប់ និងបញ្ជាក់ឲ្យច្បាស់ថា មន្ត្រីយោធានៅក្នុងសន្តិសុខជាតិ ឋានៈ តួនាទីកម្រិតត្រឹមណាដែលច្បាប់តម្រូវឲ្យមានការរឹតត្បិត។

## សមាគម និងសហជីពយោធា

នៅក្នុងរដ្ឋជាច្រើន មានការហាមឃាត់មិនឲ្យយោធាបង្កើត ឬ ចូលរួមនៅក្នុងសហជីពដើម្បីការពារផលប្រយោជន៍របស់អ្នកចូល បម្រើយោធាដោយស្ម័គ្រចិត្តនិង/ឬអ្នកដែលត្រូវបានកេណ្ឌឲ្យចូលបម្រើទ័ព។ ការប្រឆាំងជាធម្មតាចំពោះការចូលរួមសហជីពពីបុគ្គលិក យោធាគឺថា ពួកគេអាចធ្វើឲ្យប៉ះពាល់ដល់វិន័យ និងសណ្ដាប់ធ្នាប់យោធានៅក្នុងកងកម្លាំងប្រដាប់អាវុធ។ ទោះដូច្នេះក៏ដោយនៅក្នុងរដ្ឋផ្សេងទៀតដែលអនុវត្តស្របតាមមាត្រា ១១ នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ECHR) អនុញ្ញាតឲ្យបុគ្គលិកយោធាបង្កើត និងចូលរួមសមាគម ឬសហជីព។ ប្រទេសទាំងនោះមានដូចជាប្រទេសអូទ្រីស បែលហ្សិក សាធារណៈរដ្ឋឆែក ដាណឺម៉ាក ហ្វាំងឡង់ អាល្លឺម៉ង់ ហុងគ្រី អៀរឡង់ដ៍ ឡុចហ្សំប៊ួរ ហុល្លង់ ន័រវ៉េ ព័រទុយហ្គាល់ រុស្ស៊ី សាធារណៈរដ្ឋស្លូវ៉ាគី ស្លូវ៉ានៀ ស៊ុយអែត និង ស្វីស។ នៅក្នុងរដ្ឋទាំងនេះបុគ្គលិកយោធាដែលមានសមាគមឬសហជីពមានសិទ្ធិខុសៗគ្នាអាស្រ័យលើប្រភេទសមាគមដែលពួកគេចូលរួមនោះ។ ពួកគេទាំងអស់មានសិទ្ធិពិគ្រោះយោបល់ ជាមួយរដ្ឋមន្ត្រីការពារជាតិហើយអ្នកខ្លះមានសិទ្ធិចរចាលក្ខខណ្ឌការងាររបស់ពួកគេថែមទៀតផង។ នៅក្នុងករណីនីមួយៗ ពួកគេបានលើកកម្ពស់នូវលក្ខខណ្ឌអំពីសុខភាព និងសុវត្ថិភាពរបស់យោធា ហើយពួកគេជួយគាំទ្រដល់សមាជិកម្នាក់ៗរបស់ពួកគេ ឧ. ក្នុងករណីមានជម្លោះទាក់ទងនឹងផ្នែកច្បាប់ រវាងបុគ្គលិកយោធា និង ថ្នាក់ដឹកនាំរបស់ពួកគេ។ អឺរ៉ុបមានអង្គការមេចំនួន២ សម្រាប់បុគ្គលិកយោធា។ នៅក្នុងទីក្រុងប្រ៊ុយសែល EUROMIL គឺជាអង្គការបុគ្គលិកយោធាអឺរ៉ុបតែមួយគត់ដោយមិនគិតពីឋានៈ។ អង្គការមេទី២នៅក្នុងអឺរ៉ុប គឺក្រុមប្រឹក្សាអឺរ៉ុបនៃអង្គការជ្រើសរើសទ័ព (ECCO) នៅក្នុងទីក្រុងស្តុកខុម។

**ប្រអប់ទី ៦៣**

### អនុសាសន៍របស់ក្រុមប្រឹក្សាអឺរ៉ុប ស្ដីពី សិទ្ធិចងក្រងសមាគមសម្រាប់បុគ្គលិកអាជីពនៃកងកម្លាំងប្រដាប់អាវុធ

១. សភារំលឹក (...) ដើម្បីផ្ដល់ដល់សមាជិកអាជីពនៃកងកម្លាំងប្រដាប់អាវុធនៅក្រោមកាលៈទេសៈធម្មតានូវសិទ្ធិចងក្រងសមាគមតែមិនមានសិទ្ធិធ្វើកូដកម្មនោះទេ(...)។

៤. នៅក្នុងរយៈពេលជាច្រើនឆ្នាំនេះកងទ័ព នៃរដ្ឋជាសមាជិកខ្លះបានផ្លាស់ប្ដូរពីប្រព័ន្ធកេណ្ឌទ័ពមកជាប្រព័ន្ធទ័ពអាជីពសុទ្ធសាធ។ ជាផលវិបាក បុគ្គលិកយោធាបានក្លាយជាបុគ្គលិក "អចិន្ត្រៃយ៍" ដែលស្ថាប័នរបស់ពួកគេ គឺជាក្រសួងការពារជាតិ ដូច្នេះពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការមានសិទ្ធិ ដែលបានប្រគល់ឲ្យនៅក្នុងអនុសញ្ញាអឺរ៉ុប ស្ដីពីសិទ្ធិមនុស្ស និង ធម្មនុញ្ញអឺរ៉ុប ស្ដីពីបញ្ហាសង្គមកិច្ច។

៥. នៅពេលដែលកងទ័ពមិនបំពេញភារកិច្ចទ័ពសមាជិក នៃកងកម្លាំងប្រដាប់អាវុធ ដូចជា

"ប្រជាពលរដ្ឋក្នុងឯកសណ្ឋាន" ដែរគួរមានសិទ្ធិពេញលេញក្នុងការបង្កើតចូលរួមយ៉ាងសកម្ម នៅក្នុងសមាគមណាមួយ ដែលបានបង្កើតដើម្បីការពារនូវផលប្រយោជន៍ជាអាជីពរបស់ពួកគេនៅក្នុងក្របខណ្ឌនៃស្ថាប័នប្រជាធិបតេយ្យខណៈពេលពួកគេនៅជាទ័ព។

៦. កងបុគ្គលិកយោធា គួរមានសិទ្ធិអនុវត្តនូវសិទ្ធិដូចគ្នា រួមទាំងសិទ្ធិចូលរួមជាមួយគណបក្សនយោបាយដែលស្របច្បាប់។

៧. ដូច្នេះ សភាស្នើឲ្យគណៈកម្មការនៃរដ្ឋមន្ត្រីអំពាវនាវដល់រដ្ឋាភិបាល នៃរដ្ឋជាសមាជិក៖

I. អនុញ្ញាតឲ្យសមាជិកនៃកងកម្លាំងប្រដាប់អាវុធនិងបុគ្គលិកយោធាអាចបង្កើតជាសមាគម ដែលមានសិទ្ធិធ្វើការចរចាអំពីបញ្ហាដែលពាក់ព័ន្ធជាមួយប្រាក់ខែ និងលក្ខខណ្ឌការងារ។

II. ដកចេញនូវការរិតត្បិតលើសិទ្ធិ ដែលមិនចាំបាច់នាពេលបច្ចុប្បន្នក្នុងការបង្កើតសមាគម សម្រាប់សមាជិកនៃកងកម្លាំងប្រដាប់អាវុធ។

III. អនុញ្ញាតឲ្យសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងបុគ្គលិកយោធាក្លាយជាសមាជិកនៃគណបក្សនយោបាយដែលស្របច្បាប់។

IV. ដើម្បីបញ្ចូលនូវសិទ្ធិទាំងនេះទៅក្នុងលិខិតបទដ្ឋានយោធា និង ក្រមយោធារបស់រដ្ឋជាសមាជិក។

V. ពិនិត្យមើលពីលទ្ធភាពនៃការបង្កើតអោយមានមន្ត្រីរដ្ឋទទួលពាក្យបណ្តឹង ដែលបុគ្គលិកយោធាអាចដាក់ពាក្យបណ្តឹងបានក្នុងករណីមានវិវាទការងារ ឬវិវាទផ្សេងទៀត ទាក់ទងនឹងសេវាយោធា។

៨. សភា ក៏អំពាវនាវដល់គណៈកម្មការរដ្ឋមន្ត្រី ដើម្បីពិនិត្យមើលលទ្ធភាពនៃការកែសម្រួលធម្មនុញ្ញអឺរ៉ុបស្តីពីវិស័យសង្គមកិច្ចដោយធ្វើវិសោធនកម្មលើមាត្រា ៥ ដែលចែងថា "ដោយមានគោលបំណងដើម្បីធានា ឬលើកកម្ពស់សេរីភាពរបស់កម្មករនិយោជិត និងនិយោជកក្នុងការបង្កើតនូវអង្គការមូលដ្ឋាន អង្គការជាតិ ឬអង្គការអន្តរជាតិ សម្រាប់ការពារផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងដើម្បីចូលរួមនៅក្នុងអង្គការទាំងនោះភាគីត្រូវធានាថា ច្បាប់ជាតិមិនត្រូវ ឬត្រូវបានគេយកទៅធ្វើឲ្យប៉ះពាល់ដល់សេរីភាពនេះនោះទេ។ ការធានាដែលមាននៅក្នុងមាត្រានេះ ត្រូវយកទៅអនុវត្តចំពោះនគរបាល និងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ហើយការធានានេះ ត្រូវតែកំណត់នៅក្នុងលិខិតបទដ្ឋាន និងច្បាប់ជាតិ"។

អនុសាសន៍លេខ ១៥៧២ (២០០២) ក្រុមប្រឹក្សាសភាអឺរ៉ុប ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០២

## ការលើកកម្ពស់ការបណ្ដុះបណ្ដាលអំពីតម្លៃ និងបទដ្ឋានសំខាន់ៗ

ការបណ្ដុះបណ្ដាលដល់យោធាគួរផ្ដោតលើការកសាងយោធាដែលមានវិជ្ជាជីវៈ ដែលមានការប្ដេជ្ញាចិត្តខ្ពស់ និងត្រៀមខ្លួនដើម្បីបំពេញភារកិច្ចរបស់ពួកគេ។ ការបណ្ដុះបណ្ដាលគួរមានលក្ខណៈអព្យាក្រិតខាងនយោបាយ និងមិនគួរបញ្ចូលមនោគមន៍វិជ្ជានយោបាយ និងការឃោសនានយោបាយនោះឡើយ។ ការបណ្ដុះបណ្ដាលនេះគួរមានវគ្គស្ដីពីលទ្ធិប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញ ច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្ស។ ការផ្ដល់វគ្គបណ្ដុះបណ្ដាលដល់វិស័យសន្តិសុខ អំពីច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់សិទ្ធិមនុស្សមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជម្រុញលទ្ធិប្រជាធិបតេយ្យនៅក្នុងវិស័យនោះ។ ដើម្បីមានការយល់ដឹងអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិសមាជិកសភាអាចសិក្សាពីសៀវភៅមានចំណងជើងថា សៀវភៅណែនាំសម្រាប់សភាស្ដីពី "ការគោរពច្បាប់មនុស្សធម៌អន្តរជាតិ" ដែលបានចេញផ្សាយក្នុងឆ្នាំ ១៩៩៩ ដោយសហភាពអន្តរសភា និងគណៈកម្មការកាកបាទក្រហមអន្តរជាតិ (Handbook N°1)។ ទាំងគណៈកម្មការកាកបាទក្រហមអន្តរជាតិ (ICRC) ទាំងការិយាល័យឧត្តមស្នងការជាន់ខ្ពស់សម្រាប់សិទ្ធិមនុស្សអង្គការសហប្រជាជាតិ (UNHCHR) បានផ្ដល់នូវជំនួយបច្ចេកទេសដល់រដ្ឋ ដែលមានបំណងពង្រឹងសមត្ថភាពរបស់ពួកគេទាក់ទងនឹងការគោរពច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## អព្យាក្រិតភាពនយោបាយ និងការចូលរួមមិនសកម្ម

សេវាសន្តិសុខ ត្រូវតែមានអព្យាក្រិតភាពនយោបាយ។ នេះមានន័យថា គណបក្សនយោបាយមិនអនុញ្ញាតឲ្យធ្វើយុទ្ធនាការនៅក្នុងបន្ទាយយោធាឡើយ។ នៅក្នុងប្រទេសខ្លះ យោធាសកម្មត្រូវបានអនុញ្ញាតឲ្យក្លាយជាសមាជិកនៃគណបក្សនយោបាយ ចំណែកនៅក្នុងប្រទេសផ្សេងទៀត ជាពិសេសរដ្ឋដែលបានប្ដូរពីរបបកុំម្មុយនីស្ត បុគ្គលិកយោធាមិនអនុញ្ញាតឲ្យចូលរួមនៅក្នុងបក្សនោះទេ។ ឧទាហរណ៍ នៅក្នុងប្រទេសប៉ូឡូញ បុគ្គលិកនៃក្រសួងមហាផ្ទៃ ដូចជា សេវាចារកម្ម ឬនគរបាល ត្រូវបានហាមឃាត់មិនឲ្យចូលជាសមាជិកនៃគណបក្សនយោបាយឡើយ។ នៅក្នុងប្រទេសភាគច្រើន យោធាមិនអាចជាសមាជិកនៃសភាជាតិឡើយ។ ទោះដូច្នេះក្ដី នៅក្នុងប្រទេសខ្លះ ឧ. ប្រទេសហុល្លង់ និងប្រទេស អាល្លឺម៉ង់ យោធាសកម្មអាចជាសមាជិកនៃសភាមូលដ្ឋាន ឬសភាតំបន់បាន។

## សេវាសន្តិសុខគឺជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម

ជាគោលការណ៍ រាល់តួនាទី និង ឋានៈនៅក្នុងសេវាសន្តិសុខត្រូវតែបើកចំហដល់ប្រជាពលរដ្ឋទាំងអស់ ដោយមិនគិតពីយេនឌ័រ បក្សនយោបាយ វណ្ណៈ ពូជសាសន៍ ឬសាសនាឡើយ។ អ្នកដែលឆ្នើមជាងគេទោះស្រី ឬ ប្រុសត្រូវស្ថិតនៅក្នុងលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ធ្វើការជ្រើសរើស។ រដ្ឋភាគច្រើនយល់ឃើញថាបុគ្គលិកសេវាសន្តិសុខ ជាពិសេស នគរបាល និងកងកម្លាំងប្រដាប់

អាវុធ ត្រូវតែជាកញ្ចក់ឆ្លុះបញ្ចាំងសង្គមទាំងមូល។ រដ្ឋទាំងនេះបានដាក់ចេញនូវគោលនយោបាយដ៏ជាក់លាក់ ដើម្បីលើកទឹកចិត្តក្រុមទាំងឡាយនៅក្នុងសង្គម ដែលមិនមានតំណាងនៅក្នុងសេវាសន្តិសុខឲ្យដាក់ពាក្យចូលបម្រើការងារនៅទីនោះ។

## ច្បាប់ដាក់ទោសដល់ការមិនគោរពច្បាប់ និងបំពានបទបញ្ជា

លក្ខណៈ វិសាលភាពប្រតិបត្តិការ ភារកិច្ច ការរាយការណ៍ ការទទួលខុសត្រូវ និង ការត្រួតពិនិត្យលើសេវាសន្តិសុខទាំងអស់ត្រូវតែគ្រប់គ្រងដោយច្បាប់។ សេវាសន្តិសុខមិនមានអំណាចលើកលែងតែមានការចង្អុលបង្ហាញដោយច្បាប់។ ពាក់ព័ន្ធជាមួយយោធាច្បាប់ជាក់លាក់ ដូចជាច្បាប់ស្តីពីបុគ្គលិកយោធា ឬ ក្រមព្រហ្មទណ្ឌយោធាគួរបញ្ជាក់ឲ្យច្បាស់អំពីកម្រិតនៃបទបញ្ជា ដែលយោធាត្រូវគោរពតាម។ នៅក្នុងប្រទេសភាគច្រើន ច្បាប់ទាំងនេះចងកាតព្វកិច្ចឲ្យមេបញ្ជាការនីមួយៗត្រូវគោរពនីតិរដ្ឋនៅពេលណាក៏ដោយ ដែលមានការចេញបទបញ្ជាដែលធ្វើដូច្នេះ វាដូចជារិតត្បិតនូវសិទ្ធិអំណាចរបស់មេបញ្ជាការខ្លះដែរ។ ច្បាប់ចែងថា បុគ្គលិកយោធាមានភារកិច្ចមិនអនុវត្តនូវបទបញ្ជា (បទល្មើស) ខុសច្បាប់។ គ្មានបុគ្គលិកយោធាណាម្នាក់អាចយកលេសថាខ្លួនធ្វើបែបនេះ ទៅតាមបញ្ជារបស់មេបញ្ជាការរបស់ខ្លួន ដែលជាអ្នកបញ្ជាឲ្យខ្លួនប្រព្រឹត្តល្មើសបែបនេះ។ លើសពីនេះ បុគ្គលិកយោធាមិនមានកាតព្វកិច្ចអនុវត្តបទបញ្ជាប្រសិនបើវាមិនមែនជាភារកិច្ចរបស់ខ្លួន ឬ អំពើនោះវារំលោភសេចក្តីថ្លៃថ្នូររបស់មនុស្ស។ នេះមានន័យថា បុគ្គលិកខ្លួនឯងជានិច្ចត្រូវមានគណនេយ្យភាពផ្ទាល់ខ្លួនចំពោះសកម្មភាពរបស់ខ្លួន ទោះបីជាពួកគេត្រូវបានបញ្ជាដោយមេរបស់ខ្លួនក៏ដោយ។

ថ្នាក់ដឹកនាំយោធាកំពូលត្រូវបានលើកទឹកចិត្តឲ្យធ្វើជាគំរូគេ និង ត្រូវឲ្យសាធារណជនបានដឹងថា សកម្មភាពដែលផ្ទុយពីលទ្ធិប្រជាធិបតេយ្យប្រឆាំង ឬផ្ទុយពីរដ្ឋធម្មនុញ្ញឬបទបញ្ជាអសីលធម៌របស់យោធាមិនត្រូវបានអនុញ្ញាតឡើយ។ នេះវាសំខាន់ខ្លាំងណាស់សម្រាប់កងកម្លាំងប្រដាប់អាវុធនៃអតីតយោធាផ្តាច់ការ។ ឧ. ក្រោយពីមានការវិលត្រឡប់មកវិញនូវលទ្ធិប្រជាធិប តេយ្យនៅក្នុងប្រទេស អាហ្សង់ទីន ឧត្តមសេនីយ៍កំពូលៗរបស់យោធាអាហ្សង់ទីនបានប្រកាសថា *"ឈប់ប្រព្រឹត្តអំពើមិនគប្បីតទៅទៀត។ អ្នកណាក៏ដោយដែលចេញបទបញ្ជាអសីលធម៌ ហើយអ្នកណាក៏ដោយដែលធ្វើតាមបទបញ្ជាអសីលធម៌ គឺជាការរំលោភច្បាប់"*។ តាមរយៈការថ្លែងបែបនេះ ថ្នាក់ដឹកនាំកំពូល បានបញ្ជាក់ច្បាស់ថារាល់បុគ្គលិកយោធាគ្រប់រូបនឹងត្រូវមានគណនេយ្យភាពផ្ទាល់ខ្លួនម្នាក់ៗចំពោះបទល្មើស និងបទមជ្ឈិម ហើយពួកគេមិនត្រូវយកលេសថា ពួកគេគោរពតាមបទបញ្ជា (ខុសច្បាប់)ពីថ្នាក់លើរបស់ពួកគេឡើយ។

បញ្ហាដែលពាក់ព័ន្ធមួយជាមួយការទប់ស្កាត់ និង ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពគឺត្រូវធានាថា ការប្រព្រឹត្តខុសវិជ្ជាជីវៈ និងការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ និងសិទ្ធិមនុស្សនឹងត្រូវផ្តន្ទាទោសដោយស្ថាប័នតុលាការ ឬស្ថាប័នរដ្ឋបាលមានសមត្ថកិច្ច។

## ការបង្កើតនូវលក្ខខណ្ឌវិនិច្ឆ័យសម្រាប់តែងតាំងបុគ្គលិកសន្តិសុខ

ឋានៈ និង តួនាទីកំពូលរបស់សេវាសន្តិសុខ ដូចជាអគ្គមេបញ្ជាការ ឬ ប្រធានសេវាចារកម្ម ត្រូវតែងតាំងដោយខុទ្ទកាល័យឬរដ្ឋមន្ត្រីការពារជាតិ។ នៅក្នុងរដ្ឋខ្លះ ការតែងតាំងទាំងនេះត្រូវដាក់ស្ថិតនៅក្រោមការពិភាក្សាដេញដោលដោយសភា និង/ឬ មានការអនុម័តយល់ព្រមពីសភា។ ទោះបីជា មន្ត្រីកំពូលត្រូវបានតែងតាំងដោយថ្នាក់ដឹកនាំនយោបាយស៊ីវិលក៏ដោយលក្ខខណ្ឌវិនិច្ឆ័យវិជ្ជាជីវៈ គឺមានសារៈសំខាន់បំផុតនៅក្នុងដំណើរការជ្រើសរើស។

## មន្ត្រីស៊ីវិលនៅក្នុងគណៈគ្រប់គ្រងកំពូលនៅក្នុងវិស័យសន្តិសុខ

ជាចុងក្រោយ តាមទស្សនៈអភិបាលកិច្ចល្អ សេវាសន្តិសុខ ដូចជាកងកម្លាំងប្រដាប់អាវុធគួរមានមន្ត្រីស៊ីវិលនៅក្នុងគណៈគ្រប់គ្រងកំពូល។ មូលហេតុចម្បងគឺថា រដ្ឋមន្ត្រីពាក់ព័ន្ធត្រូវទទួលយោបល់មិនត្រឹមពីឧត្តមសេនីយ៍យោធាប៉ុណ្ណោះនោះទេ តែថែមទាំងត្រូវទទួលយោបល់ពីមន្ត្រីស៊ីវិលផងដែរ ដើម្បីធានាឲ្យដំណើរការនៃការធ្វើសេចក្តីសម្រេចមានតុល្យភាព។

## ក្រមសីលធម៌វិជ្ជាជីវៈ

ក្រមសីលធម៌ការងារវិជ្ជាជីវៈ ត្រូវបានបង្កើតឡើងចេញពីការអនុវត្ត ចេញពីច្បាប់ និងគោលនយោបាយ។ បុគ្គលិកយោធាត្រូវរួមសហការគ្នាដោយសុទ្ធចិត្តជាមួយស្ថាប័នរដ្ឋ និងគោរពរដ្ឋធម្មនុញ្ញ ហ៊ានលះបង់បម្រើសេវាសាធារណៈបំពេញភារកិច្ចរបស់ខ្លួនដោយប្រសិទ្ធភាព និងប្រសិទ្ធិផល និងមិនបំពានអំណាច ឬ ប្រើប្រាស់ថវិកាសាធារណៈមិនត្រឹមត្រូវនោះទេ។ វាសំខាន់ខ្លាំងណាស់ថា ក្រមសីលធម៌វិជ្ជាជីវៈត្រូវមានលក្ខណៈអនុវត្តតាមដោយសុទ្ធចិត្ត ដោយមិនត្រូវមានត្រឹមតែលក្ខណៈជាការចាប់បង្ខំឲ្យអនុវត្តតាមតែមួយមុខគត់នោះទេ។ ការអនុវត្តតាមដោយសុទ្ធចិត្ត មានន័យថា បុគ្គលិកយោធាមានបុរេនិច្ឆ័យវិជ្ជមានចំពោះរដ្ឋធម្មនុញ្ញ និងស្ថាប័នជាតិ ពីព្រោះពួកគេបានយល់ដឹងអំពីគុណប្រយោជន៍នៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងសង្គមជាតិរបស់ពួកគេ។

នៅក្នុងប្រទេសភាគច្រើន បានដាក់ចេញនូវក្រមសីលធម៌ដែលគ្រប់គ្រងលើអាកប្បកិរិយារបស់បុគ្គលិកយោធា។ ឧទាហរណ៍ ក្រមសីលធម៌វិជ្ជាជីវៈរបស់អាល្លឺម៉ង់សម្រាប់កងកម្លាំងប្រដាប់អាវុធមានពន្យល់នៅក្នុងប្រអប់ទី ៦៤។

**ប្រអប់ទី ៦៤**

## ការអប់រំភាពជាអ្នកដឹកនាំ និងពលរដ្ឋវិជ្ជាដល់កងកម្លាំងប្រដាប់អាវុធអាល្លឺម៉ង់៖ គោលការណ៍ "Innere Führung"

"(...) ក្នុងអំឡុងពេលពិភាក្សាដេញដោលលើការបង្កើត Bundeswehr (កងកម្លាំងប្រដាប់អាវុធរួបរួមមួយរបស់អាល្លឺម៉ង់) ក្រោយពីសង្គ្រាមលោកលើកទី២ទស្សនទាននៃពាក្យ Innere Führung (ការដឹកនាំប្រកបដោយសីលធម៌ និងការអប់រំពលរដ្ឋវិជ្ជា) ត្រូវបានគេចាត់ទុកថាជាវិធីសាស្ត្រមួយនៅក្នុងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ តាមរយៈការចាកចេញប្រកបដោយមនសិការពីប្រពៃណីបុរាណ។ (...) មានការឯកភាពជាទូទៅថា គោលការណ៍ Innere Führung ផ្តល់នូវការណែនាំជាមូលដ្ឋានសម្រាប់អង្គការផ្ទៃក្នុងនៃ Bundeswehr អំពីការធ្វើសមាហរណកម្មរបស់ខ្លួនចូលទៅក្នុងរដ្ឋ និង សង្គម។

(...) Innere Führung ជួយកាត់បន្ថយនូវស្ថានភាពតឹងតែង ឬជម្លោះដែលកើតឡើងរវាងសិទ្ធិបុគ្គល និងសេរីភាពរបស់បុគ្គលិកយោធាក្នុងនាមជាប្រជាពលរដ្ឋជាមួយ នឹងតម្រូវការឲ្យមានការបំពេញភារកិច្ចយោធា។ អ្នកដឹកនាំជាមន្ត្រីជាន់ខ្ពស់ត្រូវមានការគោរពយ៉ាងជ្រាលជ្រៅចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាមូលដ្ឋានគ្រឹះ នៃរដ្ឋធម្មនុញ្ញរបស់យើង (...)។

ម្យ៉ាងទៀតគោលបំណង គឺដើម្បីធ្វើសមាហរណកម្ម Bundeswehr ចូលទៅក្នុងរដ្ឋ និងសង្គមឲ្យក្លាយជាស្ថាប័នមួយ ហើយគ្រប់បុគ្គលិកយោធាទាំងអស់ឲ្យក្លាយជាប្រជាពលរដ្ឋ (...)។ គោលបំណង គឺត្រូវបំបាត់នូវការព្រួយបារម្ភទាំងឡាយដែល Bundeswehr អាចក្លាយជា "រដ្ឋក្នុងរដ្ឋ" ដែលជាគ្រោះថ្នាក់មួយនៅក្នុងគ្រប់កងកម្លាំងប្រដាប់អាវុធទាំងអស់ (...)។

គោលបំណងរបស់ Innere Führung គឺ៖

- ធ្វើឲ្យបុគ្គលិកយោធាមានការយល់ដឹងយ៉ាងច្បាស់ អំពីមូលដ្ឋានគ្រឹះតាមផ្លូវនយោបាយ និងច្បាប់របស់ Bundeswehr ក៏ដូចជាគោលបំណង និងអត្ថន័យនៃបេសកកម្មយោធារបស់ពួកគេផងដែរ។
- ដើម្បីជម្រុញការធ្វើសមាហរណកម្មរបស់ Bundeswehr និងបុគ្គលិកយោធារបស់ពួកគេទៅក្នុងរដ្ឋនិងសង្គម និងដើម្បីបង្កើតឲ្យមានការយល់ដឹងពីសាធារណជនកាន់តែច្រើនអំពីបេសកកម្មរបស់ពួកគេ។
- ដើម្បីលើកកម្ពស់ឆន្ទៈរបស់បុគ្គលិកយោធា ក្នុងការអនុវត្តនូវភារកិច្ចរបស់ពួកគេប្រកបដោយមនសិកា និងដើម្បីរក្សានូវវិន័យ និងសាមគ្គីភាពនៅក្នុងកងកម្លាំងប្រដាប់អាវុធ។
- ដើម្បីធានាថា រចនាសម្ព័ន្ធផ្ទៃក្នុងរបស់កងកម្លាំងប្រដាប់អាវុធ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងស្របតាមច្បាប់ និងរដ្ឋធម្មនុញ្ញ

និងដើម្បីសម្រួលដល់ការអនុវត្តនូវបេសកកម្មរបស់កងកម្លាំងប្រដាប់អាវុធ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ខ្លឹមសារ និងគោលបំណងជាក់ស្តែងរបស់ Innere Führung នៅក្នុងជីវិតយោធាប្រចាំថ្ងៃមានចែងនៅក្នុងច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានគតិយុត្តរបស់យោធា។ (...)”។

*ប្រភព៖ គេហទំព័ររបស់សភាសហព័ន្ធអាល្លឺម៉ង់ www.bundestag.de*

នៅថ្នាក់អន្តរជាតិ រហូតមកដល់ពេលនេះមានក្រមសីលធម៌ចំនួន២ ដែលត្រូវបានរៀបចំដែលមានចែងក្របខណ្ឌ សម្រាប់ក្រមសីធម៌វិជ្ជាជីវៈរបស់បុគ្គលិកយោធា នៅក្នុងសង្គមកាន់លទ្ធិប្រជាធិបតេយ្យ។ ទី១ ក្នុងឆ្នាំ១៩៧៩ មហាសន្និបាតបានអនុម័តលើក្រមអន្តរជាតិសម្រាប់មន្ត្រីអនុវត្តច្បាប់៖ សូមអានប្រអប់ទី៦៥។ ក្រមនេះចែងពីលក្ខណៈទូទៅមួយ និងត្រូវបានអនុវត្តមិនត្រឹមចំពោះបុគ្គលិកយោធាឯកសណ្ឋានប៉ុណ្ណោះនោះទេ តែថែមទាំងសម្រាប់មន្ត្រីសាធារណៈទាំងអស់ដែលធ្វើការនៅក្នុងទីភ្នាក់ងារអនុវត្តច្បាប់ទៀតផង។

**ប្រអប់ទី ៦៥**

## ក្រមប្រតិបត្តិសម្រាប់មន្ត្រីអនុវត្តច្បាប់

***ត្រូវបានអនុម័តដោយសេចក្តីសម្រេចមហាសន្និបាត ៣៤/១៦៩ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩***

មាត្រា ១- គ្រប់ពេលវេលា មន្ត្រីអនុវត្តច្បាប់ ត្រូវបំពេញភារកិច្ចដែលច្បាប់បានប្រគល់ដល់ពួកគេដោយបម្រើសហគមន៍ និងការពារជនគ្រប់រូបពីអំពើខុសច្បាប់ ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈ របស់ខ្លួន។

មាត្រា ២- នៅក្នុងការអនុវត្តភារកិច្ចរបស់ពួកគេ មន្ត្រីអនុវត្តច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូរមនុស្ស និងរក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប។

មាត្រា ៣- មន្ត្រីអនុវត្តច្បាប់អាចប្រើប្រាស់កម្លាំងតែក្នុងករណីចាំបាច់បំផុត និង តម្រូវឲ្យមានការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

មាត្រា ៤- បញ្ហាទាក់ទងនឹងការសម្ងាត់នៅក្នុងវិជ្ជាជីវៈមន្ត្រីអនុវត្តច្បាប់ត្រូវរក្សាការសម្ងាត់លើកលែងតែការអនុវត្តភារកិច្ច ឬតម្រូវឲ្យមានការស្វែងរកយុត្តិធម៌។

មាត្រា ៥- គ្មានមន្ត្រីអនុវត្តច្បាប់ណាម្នាក់អាចធ្វើទារុណកម្ម ញុះញង់ឲ្យមានការធ្វើទារុណកម្ម ឬ អត់ឱនឲ្យអំពើធ្វើទារុណកម្ម ឬ ប្រព្រឹត្តអំពីឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬ ដាក់ទណ្ឌកម្ម ឬ ថែមទាំងមន្ត្រីអនុវត្តច្បាប់មិនអាចយកលេសថាអនុវត្តតាមបទបញ្ជាថ្នាក់លើ ឬ យកលេសថា ជាកាលៈទេសៈលើកលែង ដូចជាប្រទេសមានសង្គ្រាម ឬការគម្រាមកំហែងពីសង្គ្រាម ឬមានការគម្រាមកំហែងដល់សន្តិសុខជាតិ អស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នសាធារណៈផ្សេងទៀត ដើម្បីបានជាមូលហេតុដើម្បីធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ឬបន្ទាបបន្ថោក ឬដាក់ទណ្ឌកម្មនោះឡើយ។

មាត្រា ៦- មន្ត្រីអនុវត្តច្បាប់ត្រូវធានានូវការការពារដ៏ពេញលេញចំពោះសុខភាពរបស់បុគ្គលនៅក្នុងមណ្ឌលឃុំឃាំង និងជាពិសេសត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឲ្យមានការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រចំពោះបុគ្គលទាំងនោះក្នុងករណីចាំបាច់។

មាត្រា ៧- មន្ត្រីអនុវត្តច្បាប់មិនត្រូវប្រព្រឹត្តអំពើពុករលួយណាមួយ។ ពួកគេត្រូវប្រឆាំង និងប្រយុទ្ធប្រឆាំងជាដាច់ខាត នូវអំពើទាំងអស់បែបនោះ។

មាត្រា ៨- មន្ត្រីអនុវត្តច្បាប់ត្រូវគោរពច្បាប់ និងក្រមជាធរមាន។ ពួកគេក៏ត្រូវទប់ស្កាត់តាមសមត្ថភាពរបស់ពួកគេ និងប្រឆាំងដាច់ខាតចំពោះការរំលោភច្បាប់។ មន្ត្រីអនុវត្តច្បាប់ដែលមានហេតុផលគួរឲ្យជឿបានថា មានការរំលោភច្បាប់ពិតប្រាកដមែន ឬជិតមានការរំលោភច្បាប់កើតឡើង ត្រូវរាយការណ៍អំពីបញ្ហាទាំងនេះ ទៅអាជ្ញាធរថ្នាក់លើ ហើយបើចាំបាច់ត្រូវរាយការណ៍ទៅអាជ្ញាធរដ៏សមស្របដទៃទៀត ឬស្ថាប័នដទៃទៀត ដែលមានសិទ្ធិអំណាចក្នុងការសើរើ ឬផ្តល់សំណង។

កំណត់សម្គាល់៖ មាត្រានីមួយៗនៃក្រមប្រតិបត្តិនេះមានបញ្ចូលនូវបទអត្ថាធិប្បាយដែលមិនត្រូវបានសរសេរនៅក្នុងផ្នែកនេះឡើងវិញនោះទេ។ ដើម្បីអានឯកសារទាំងមូលសូមចូលទៅ៖ www.un.org

ក្រមប្រតិបត្តិទី២ គឺក្រមសីលធម៌ OSCE ស្តីពីទិដ្ឋភាពនយោបាយនិងយោធានៃវិស័យសន្តិសុខ (សូមអានប្រអប់ទី៦៦)។ ក្រមនេះត្រូវអនុវត្តចំពោះបុគ្គលិកយោធានៃអង្គការវិស័យសន្តិសុខទាំងអស់ ហើយវាបានផ្តល់នូវការណែនាំសម្រាប់បុគ្គលិកកងកម្លាំងប្រដាប់អាវុធ។ ក្រមចែងថា បុគ្គលិកយោធាត្រូវគោរពគោលការណ៍នៃនីត្យានុកូលភាព លទ្ធិប្រជាធិបតេយ្យ អព្យាក្រិតភាព គោរពសិទ្ធិមនុស្ស និងអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ។ ក្រមបានចង្អុលបង្ហាញថា បុគ្គលិកយោធាអាចចាប់ឲ្យទទួលខុសត្រូវជាបុគ្គល ចំពោះការរំលោភច្បាប់មនុស្សធម៌។ ទោះដូច្នេះក្តីច្បាប់បានលើកពីបញ្ហាជាច្រើនដែលស្ថិតនៅក្រោមយុត្តាធិការរបស់ប្រទេសសាមី។ ដូច្នេះក្រមនេះ គឺជាក្រមឈានមុខមួយដ៏សំខាន់ពាក់ព័ន្ធជាមួយ អំណាចរបស់រដ្ឋែលត្រូវបានការពារយ៉ាងប្រុងប្រយ័ត្នមកដល់ពេលនេះ។ ចាប់តាំងពីបញ្ហារដ្ឋ OSCE បានចុះហត្ថលេខាលើក្រមនេះក្នុងឆ្នាំ ១៩៩៤មក បណ្តារដ្ឋ

ពួកគេ។ នេះវាមានទំនាក់ទំនងជាមួយចំណុចសំខាន់ៗ នៅក្នុងក្រមដែលចែងថា ការកសាងកងកម្លាំងប្រដាប់អាវុធប្រកបដោយវិជ្ជាជីវៈ ត្រូវស្របទៅតាមការត្រួតពិនិត្យលើកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ។

**ប្រអប់ទី ៦៦**

### ក្រមប្រតិបត្តិរបស់ OSCE ស្តីពីទិដ្ឋភាពនយោបាយ-យោធាទាក់ទងនឹងវិស័យសន្តិសុខ៖ ទិដ្ឋភាពសំខាន់ៗ

- ទស្សនទានដ៏ទូលំទូលាយនៃកងកម្លាំងផ្ទៃក្នុង មានដូចជា សេវាចារកម្ម កងកម្លាំងពាក់កណ្តាលយោធា និងនគរបាល។ បញ្ញត្តិទាំងនេះ បញ្ជាក់ពីភារកិច្ចរបស់រដ្ឋក្នុងការរក្សាកងកម្លាំងទាំងនោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ តាមរយៈអាជ្ញាធរដែលមានសិទ្ធិស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ (កថាខណ្ឌទី ២០ និង២១)។
- ការផ្តល់ការអនុម័តយល់ព្រមពីសភាចំពោះថវិកាការពារជាតិ និងការលើកទឹកចិត្តឲ្យមានការកាត់បន្ថយការចំណាយលើយោធា។ តម្លាភាពនិងសិទ្ធិទទួលបានព័ត៌មានរបស់សាធារណជន នូវព័ត៌មានដែលពាក់ព័ន្ធជាមួយនឹងកងកម្លាំងប្រដាប់អាវុធ (កថាខណ្ឌទី២២)។
- អព្យាក្រឹតភាពនយោបាយរបស់កងកម្លាំងប្រដាប់អាវុធ (កថាខណ្ឌទី ២៣)។
- បុគ្គលិកកងកម្លាំងប្រដាប់អាវុធ អាចចាប់ឲ្យទទួលខុសត្រូវជាលក្ខណៈបុគ្គល ចំពោះការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ (កថាខណ្ឌទី ៣១)។
- ទោះជាក្នុងពេលមានសន្តិភាព និងទោះជាក្នុងពេលមានសង្គ្រាម កងកម្លាំងប្រដាប់អាវុធត្រូវបានបញ្ជាធ្វើការបណ្តុះបណ្តាល និងបំពាក់ឧបករណ៍ដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់អន្តរជាតិ (កថាខណ្ឌទី៣៥)។
- ការប្រើប្រាស់កម្លាំង ដើម្បីបំពេញបេសកកម្មសន្តិសុខផ្ទៃក្នុង ត្រូវតែសមស្របជាមួយតម្រូវការ។ កងកម្លាំងប្រដាប់អាវុធត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ដល់ជនស៊ីវិល ឬទ្រព្យសម្បត្តិរបស់ពួកគេ (កថាខណ្ឌទី៣៦)។
- កងកម្លាំងប្រដាប់អាវុធ មិនត្រូវបានគេប្រើប្រាស់ដើម្បីរិតត្បិត ការអនុវត្តសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋដោយសន្តិវិធី និងស្របច្បាប់បានឡើយ ឬដើម្បីដកហូតអត្តសញ្ញាណជាតិ សាសនា វប្បធម៌ ភាសា ឬជាតិពន្ធុពីប្រជាពលរដ្ឋបានឡើយ (កថាខណ្ឌទី ៣៧)។

*ប្រភព៖ ក្រមប្រតិបត្តិរបស់ OSCE ផ្នែកទី VII និង VIII។ សូមអាន៖ គេហទំព័ររបស់ OSCE៖ www.osce.org និងគេហទំព័រក្រមប្រតិបត្តិរបស់ OSCE៖ http://www.osce.org/docs/english/1990-1999/summits/buda94e.htm#Anchor_COD_65130*

## យុត្តាធិការយោធា (Military Jurisdiction)

លក្ខខណ្ឌសម្រាប់ដាក់ពិន័យយោធា ផ្អែកលើលក្ខខណ្ឌជាច្រើន ដែលចេញមកពីលក្ខណៈពិសេសនៃបេសកកម្មយោធា។ ឧទាហរណ៍ យោធា និងស៊ីវិលមានទស្សនៈវិស័យខុសៗគ្នាអំពីការប្រព្រឹត្តល្មើសរបស់យោធា។

បុគ្គលិកស៊ីវិលម្នាក់ មិនទទួលរងនូវការចោទប្រកាន់ព្រហ្មទណ្ឌ ចំពោះការដើរចេញពីការងារដែលបានចាត់តាំងឲ្យធ្វើ ឬខកខានមិនបានបំពេញនូវការងារនោះអោយបានល្អ។ ប្រធានស្ថាប័នអាចគ្រាន់តែបណ្តេញចេញនូវបុគ្គលិកនោះ ចំពោះការបំពេញការងារមិនបានល្អ របស់បុគ្គលិកនោះ និងអាចបដិសេធមិនផ្តល់នូវការគាំទ្រគាត់នៅពេលគាត់ទៅដាក់ពាក្យនៅកន្លែងធ្វើការផ្សេង ក៏ប៉ុន្តែប្រធានស្ថាប័ននោះ មិនបានប្តឹងគាត់ទៅតុលាការព្រហ្មទណ្ឌនោះទេ។ ចំណែកបុគ្គលិកយោធាវិញ ត្រូវទទួលរងនូវការចោទប្រកាន់ព្រហ្មទណ្ឌចំពោះការចាកចេញពីតំណែងរបស់គាត់ ឬមិនបានបំពេញនូវភារកិច្ចដែលបានចាត់តាំង ដោយអនុលោមតាមបទដ្ឋាន និងលក្ខខណ្ឌមួយចំនួន។ ការប្រព្រឹត្តបែបនោះមិនត្រឹមតែត្រូវបានចោទប្រកាន់ថាបាន បោះបង់ចោលភារកិច្ចប៉ុណ្ណោះនោះទេ តែត្រូវបានចោទប្រកាន់ថា បានធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាពនិងសុខុមាលភាពរបស់បុគ្គលិកយោធាដទៃទៀតផងដែរ។ មានឧទាហរណ៍ផ្សេងទៀតនៃបទល្មើសយោធា ដែលមិនបានទទួលស្គាល់នៅក្នុងសង្គមស៊ីវិល ក្នុងនោះមានការបង្កើតបញ្ជីឈ្មោះទាហានក្លែងបន្លំ ការរត់ចោលជួរ ការឈប់ដោយគ្មានច្បាប់ ការមិនគោរពចំពោះថ្នាក់លើ ការចចេសមិនព្រមស្តាប់បង្គាប់ ការជួយដល់ខ្មាំង និងការដេកពេលយាមជាដើម។

បញ្ហានេះបង្កជាកង្វល់ដ៏ធំមួយ ថាតើបទល្មើសអ្វីខ្លះ គួរស្ថិតនៅក្រោមយុត្តាធិការយោធា ហើយបទល្មើសដូចម្តេចខ្លះគួរស្ថិតនៅក្រោមយុត្តាធិការស៊ីវិល។ ជាគោលការណ៍ គេគួរប្រើតុលាការយោធាក្នុងរបៀបកំហិតមួយ ហើយគេគួរប្រើប្រាស់យុត្តាធិការរបស់តុលាការស៊ីវិលឲ្យបានច្រើនតាមដែលអាចធ្វើបាន។ យុត្តាធិការយោធាគួរត្រូវបានរិតត្បិតត្រឹមបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងពេលកំពុងអនុវត្តមុខងារយោធា ហើយក្រមសីលធម៌យោធាគួរមានភាពត្រូវគ្នាតិចបំផុតជាមួយច្បាប់ព្រហ្មទណ្ឌស៊ីវិល។

វាសំខាន់ខ្លាំងណាស់ក្នុងការគូសបញ្ជាក់ថា នៅក្នុងប្រទេសភាគច្រើន នៅក្នុងកងកម្លាំងប្រដាប់អាវុធតុលាការយោធាមិនត្រឹមតែជាផ្នែកមួយនៃសាលាក្តីតុលាការ តែក៏ជាសាលាក្តីរដ្ឋបាលដែលជាផ្នែកមួយនៃអង្គនីតិប្រតិបត្តិ។ នេះមានន័យថាចៅក្រមយោធាជាញឹកញាប់ មិនត្រូវបានតែងតាំងតាមរយៈបទបញ្ញត្តិតាមរដ្ឋធម្មនុញ្ញ និងលក្ខខណ្ឌ នៃការតែងតាំងចៅក្រមនោះទេ។ ទោះដូច្នោះក្តី គេត្រូវចងចាំថា នៅក្នុងគ្រប់ករណីទាំងអស់ តុលាការយោធាគួរត្រូវបានពិនិត្យតាមដានដោយផ្នែកតុលាការ។ នៅក្នុងប្រទេសភាគច្រើនគេធ្វើដូច្នេះ តាមរយៈការបង្កើតនូវសាលាឧទ្ធរណ៍ស៊ីវិលនៅពេលមានការប្តឹងទាស់ចំពោះយុត្តាធិការយោធា។

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

ត្រូវពិនិត្យមើលថា៖

១. បុគ្គលិកយោធាបានធ្វើសម្បថថា ខ្លួនមានស្វាមីភក្តិចំពោះរដ្ឋធម្មនុញ្ញ នីតិរដ្ឋ និង ស្ថាប័នរដ្ឋ ប៉ុន្តែមិនមែនមានស្វាមីភក្តិចំពោះបុគ្គលនោះទេ។

២. នៅក្នុងការបណ្តុះបណ្តាលយោធា ត្រូវតែមានការបណ្តុះបណ្តាលអំពីតម្លៃ នៃលទ្ធិប្រជាធិបតេយ្យ និងច្បាប់ស្តីពីសិទ្ធិពលរដ្ឋ និងច្បាប់ស្តីពីមនុស្សធម៌។

៣. មន្ត្រីយោធាមិនត្រូវអនុញ្ញាតឲ្យក្លាយជាសមាជិកសភាឡើយ។

៤. ការជ្រើសរើសទាហានថ្មី និងមន្ត្រីថ្មីត្រូវផ្អែកលើវិជ្ជាជីវៈ។

៥. ត្រូវដាក់ឲ្យស្របច្បាប់នូវភារកិច្ចរបស់យោធាក្នុងការមិនគោរពអនុវត្តតាមបទបញ្ជាខុសច្បាប់ (បទល្មើស) និងធ្វើទុក្ខបុកម្នេញ។

៦. ក្រមសីលធម៌របស់យោធាត្រូវមានលក្ខណៈជាការអនុវត្តដោយស្ម័គ្រចិត្តដែលត្រូវគាំទ្រដោយក្រមប្រតិបត្តិដ៏សមស្រប។

៧. ត្រូវមានការរិតត្បិតសមភាពរបស់យុត្តាធិការយោធាតាមដែលអាចធ្វើបាន ហើយសេចក្តីសម្រេចរបស់តុលាការយោធា ជានិច្ចអាចប្តឹងទាស់នៅក្នុងតុលាការព្រហ្មទណ្ឌស៊ីវិល។

៨. សេវាសន្តិសុខនីមួយៗរបស់រដ្ឋ ត្រូវចាប់ឲ្យទទួលខុសត្រូវទាំងចំពោះមុខច្បាប់ និងទាំងចំពោះការអនុវត្ត (សូមអានជំពូកមុនអំពី គណនេយ្យភាពរបស់យោធានីមួយៗ) ហើយត្រូវមានច្បាប់ចែងអំពីការមានយន្តការគណនេយ្យភាពផ្ទៃក្នុង សម្រាប់សេវាសន្តិសុខដែលអនុញ្ញាតឲ្យមានការពិនិត្យឡើងវិញផ្ទៃក្នុងនៃការប្រព្រឹត្តខុសឆ្គង និងពាក្យបណ្តឹងសាធារណៈព្រមទាំងការដាក់ទោសចំពោះអ្នកទទួលខុសត្រូវផងដែរ។ ត្រូវពិនិត្យមើលថា យន្តការបែបនោះបានអនុវត្តនូវភារកិច្ចរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។ ត្រូវពិនិត្យមើលថា សភាតម្រូវឲ្យមានការស៊ើបអង្កេតដោយឯករាជ្យហើយជនសង្ស័យត្រូវបាននាំទៅជំនុំជម្រះ។

### សិទ្ធិជាពលរដ្ឋរបស់បុគ្គលិកយោធា

- ▷ រិតត្បិតដោយច្បាប់ ចំពោះសិទ្ធិពលរដ្ឋរបស់បុគ្គលិកយោធា ដើម្បីធានាភាពត្រៀមខ្លួនរួចរាល់ និងអព្យាក្រិតភាពរបស់សេវាសន្តិសុខ។
- ▷ ទោះដូច្នេះក្តីត្រូវចងចាំថា ការកាត់បន្ថយនូវសិទ្ធិជាពលរដ្ឋណាមួយត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយលក្ខណៈ និងភារកិច្ចដ៏ជាក់លាក់របស់សេវាសន្តិសុខ ឧ. ការកាន់កាប់ផ្តាច់មុខលើកងកម្លាំងសន្តិសុខនៅក្នុងសង្គម។
- ▷ ការអនុវត្តលើការរិតត្បិតលើសិទ្ធិជាពលរដ្ឋ ត្រូវបើកផ្លូវឲ្យមានការដោះស្រាយនូវបណ្តឹងសារទុក្ខ។

**ការស្តាប់បង្គាប់ (obedience)**

- ច្បាប់ត្រូវចែងថាបុគ្គលិកយោធា រួមទាំងអ្នកដែលបានកេណ្ឌមានភារកិច្ចមិនគោរពធ្វើតាមបទបញ្ជាខុសច្បាប់ និង អសីលធម៌ និង បទបញ្ជាដែលផ្ទុយពីច្បាប់សិទ្ធិមនុស្ស អន្តរជាតិ។
- ត្រូវពិនិត្យមើលថា វាមានប្រព័ន្ធដាក់វិន័យទៅលើបុគ្គលិក យោធាណាដែលអនុវត្តផ្ទុយពីខាងលើនៅក្នុងសេវាសន្តិសុខ។

**ការបំពាន និងអំពើពុករលួយ**

- ត្រូវចាត់វិធានការភ្លាម ប្រសិនបើមានរឿងអាស្រូវ ឬអំពើពុករលួយ និងអំពើហិង្សាកើតឡើងនៅក្នុងកងកម្លាំងសន្តិសុខ។
- ធានាថា មានការស៊ើបអង្កេតស៊ីជម្រៅនិងសមស្រប ហើយបើចាំបាច់មានការសម្រេចដាក់ទោសដោយមិនបង្អង់ពីស្ថាប័នមានសមត្ថកិច្ច។
- បង្កើតច្បាប់ ដែលហាមឃាត់យោធា និង បុគ្គលិកសេវាសន្តិសុខ ផ្សេងទៀតមិនឲ្យធ្វើការងារទី២ ឬ ចូលរួមនៅក្នុងការងារពាណិជ្ជកម្មឯកជន ឬក្រុម/អង្គការ។

## ជំពូក ២៦

# ការគ្រប់គ្រងបុគ្គលិកនៅក្នុងវិស័យសន្តិសុខ

ការងារយោធាគឺជា ការងារមួយដែលតម្រូវឲ្យមានការឆ្លងកាត់នូវការលំបាកធំៗខ្លះ ដូចជាការលំបាកផ្នែករាងកាយ ការផ្លាស់ទីកន្លែងជាទៀងទាត់ ការចាកឆ្ងាយពីគ្រួសារជាដើម។ សភាត្រូវដឹងថា យោធា "មិនមែនគ្រាន់តែជាការងារមួយផ្សេងទៀត" នោះទេ។ ការគ្រប់គ្រងបុគ្គលិកដ៏សមស្រប រួមទាំងការជ្រើសរើសការសម្រិតសម្រាំងការបែងចែកបុគ្គលិក ប្រាក់ឈ្នួល ការបណ្តុះបណ្តាល និងប្រព័ន្ធលើកទឹកចិត្ត សុទ្ធតែសំខាន់ដល់ការរៀបចំនូវវិស័យសន្តិសុខមួយ ប្រកបដោយវិជ្ជាជីវៈ ដោយគោរពតាមគោលការណ៍ប្រជាធិបតេយ្យ និងគោរពនីតិរដ្ឋ និងឧត្តមភាពស៊ីវិល។

សភាត្រូវត្រួតមើលការបង្កើត និងថែរក្សាសេវាសន្តិសុខប្រកបដោយវិជ្ជាជីវៈ។ ពួកគេគួរធានាថា ត្រូវមានការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងបុគ្គលិក ដែលនាំទៅរកកម្លាំងការងារមួយដែលមានវិជ្ជាជីវៈ និងគោរពប្រជាធិបតេយ្យ។ សភាគួរធ្វើការឃ្លាំមើលបន្ថែមថាតើរដ្ឋបានប្រព្រឹត្តដោយយុត្តិធម៌ដែរឬយ៉ាងណា ចំពោះបុគ្គលិកយោធាពាក់ព័ន្ធជាមួយប្រាក់ខែលក្ខខណ្ឌការងារប្រាក់ឧបត្ថម្ភប្រាក់សោធននិវត្តន៍ជាដើម។

**ប្រអប់ទី ៦៧**

### ការគ្រប់គ្រងបុគ្គលិកៈ មន្ត្រីបង្គោលសម្រាប់តំណាងរាស្ត្រ

សភាគួរត្រូវបានគេជូនដំណឹងអំពីចំណុចនានា នៃសំណើរបស់រដ្ឋាភិបាលពាក់ព័ន្ធជាមួយការគ្រប់គ្រងបុគ្គលិកនៅក្នុងសេវាសន្តិសុខ។

### បញ្ហាគោលនយោបាយទូទៅ

- ▷ តើសភា ត្រូវបានស្នើសុំឲ្យធ្វើការអនុម័តយល់ព្រមលើគោលនយោបាយគ្រប់គ្រងបុគ្គលិកសម្រាប់សេវាសន្តិសុខនៅក្នុងសំណើសុំថវិកាប្រចាំឆ្នាំ ឬនៅក្នុងឯកសារដោយឡែកដែរឬទេ?
- ▷ តើគោលនយោបាយគ្រប់គ្រងបុគ្គលិក និងគោលនយោបាយ រចនាសម្ព័ន្ធកងកម្លាំងមានលក្ខណៈជាក់ស្តែង និងសមស្របជាមួយថវិកា និងសេដ្ឋកិច្ចជាតិដែរឬទេ?

## ចំណុចខ្លាំង និងលក្ខខណ្ឌទូទៅ

- ▷ តើសភា មានបានកំណត់នូវចំនួនអតិបរមានៃបុគ្គលិកយោធា ដូចជាកងកម្លាំងប្រដាប់អាវុធ នគរបាល ឬសេវាចារកម្មដែរឬទេ?
- ▷ តើសភាមានបានសម្រេចលើការចំណាយជាអតិបរមាសម្រាប់បុណ្យសក្តិនីមួយៗដែរឬទេ?
- ▷ តើនយោបាយគ្រប់គ្រងបុគ្គលិកទាំងអស់ត្រូវបានបើកចំហរអោយសាធារណជនដែរឬទេ?
- ▷ តើសភា បានទទួលនូវព័ត៌មានពាក់ព័ន្ធទាំងអស់ជាមួយចំនួននៃបុណ្យសក្តិ ប្រាក់ខែ មុខងារ តំណែងទំនេរ ។ល។ ដែរឬទេ?
- ▷ តើគោលនយោបាយកំណែទម្រង់វិស័យសន្តិសុខ កំពុងធ្វើការដោះស្រាយនូវផលវិបាកសង្គម ពាក់ព័ន្ធជាមួយការបញ្ឈប់បុគ្គលិកយោធាដែរឬទេ?

## ការជ្រើសរើស និង ការចម្រាញ់

- ▷ តើការជ្រើសរើស ត្រូវបានបើកដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងនោះក៏មានស្ត្រីមែនដែរឬទេ? តើច្បាប់មានចែងបែបនេះដែរ ឬទេ?
- ▷ តើមានប្រព័ន្ធជ្រើសរើសបុគ្គលិកដោយចំហសម្រាប់សេវាសន្តិសុខដែរឬទេ ដែលខុសពីប្រព័ន្ធជ្រើសរើសដោយបិទបាំង ដែលមានតែបុគ្គលខ្លះនៃសង្គមអាចដាក់ពាក្យបាន?
- ▷ តើលក្ខខណ្ឌវិនិច្ឆ័យវិជ្ជាជីវៈត្រូវបានប្រើប្រាស់ដែរឬទេ ដើម្បីធ្វើការជ្រើសរើសបេក្ខជន?
- ▷ តើមានសល់តំណែងទំនេរច្រើនដែរឬទេនៅក្នុងសេវាសន្តិសុខ?
- ▷ តើមានអត្រាបោះបង់ខ្ពស់ដែរឬទេបន្ទាប់ពីមានការជ្រើសរើសបឋម?

## បញ្ហាទាក់ទងនឹងបុគ្គលិក

- ▷ តើគោលការណ៍ឈានមុខដែលថា បុគ្គលិកយោធានឹងត្រូវជ្រើសរើស និងតម្លើងឋានន្តរសក្តិដោយផ្អែកលើស្នាដៃ និងគុណសម្បត្តិត្រូវបានគោរពធ្វើតាមឬទេ?
- ▷ តើមានប្រព័ន្ធវាយតម្លៃវិជ្ជាជីវៈជាប្រចាំដែរឬទេ?
- ▷ តើប្រព័ន្ធនេះមានតម្លាភាព សត្យានុម័ត និងយុត្តិធម៌ដែរឬទេ?
- ▷ តើសេវាសន្តិសុខផ្តល់នូវការទាក់ទាញ និងលើកទឹកចិត្តដែរឬទេ?
- ▷ តើបុគ្គលិកយោធាត្រូវបានហាមឃាត់មិនឲ្យមានមុខរបរថ្មីមួយទៀតដែលមានប្រាក់ខែដែរឬទេ?
- ▷ តើមេបញ្ជាការដឹកនាំមានបទពិសោធន៍នៅក្នុងសមរភូមិ និងធ្លាប់បម្រើការងារនៅក្នុងបេសកកម្មរក្សាសន្តិភាពឯបរទេសដែរឬទេ?
- ▷ តើសភា ឬ គណៈកម្មការសភាដែលពាក់ព័ន្ធត្រូវបានពិគ្រោះយោបល់ ដោយរដ្ឋមន្ត្រី

ការពារជាតិ (ឬរដ្ឋមន្ត្រីពាក់ព័ន្ធដទៃទៀត) ក្នុងករណីមានការតែងតាំងឋានៈខ្ពស់ដូចជា អគ្គមេបញ្ជាការដែរឬទេ?

### ប្រាក់បៀវត្សរ៍

- តើប្រាក់ខែរបស់បុគ្គលិកយោធាខ្ពស់គ្រប់គ្រាន់ បើប្រៀបធៀបជាមួយអ្នកមានវិជ្ជាជីវៈផ្សេងទៀត ដែលអាចឲ្យសេវាសន្តិសុខប្រកួតប្រជែងជាមួយក្រុមហ៊ុនឯកជន នៅលើទីផ្សារការងារបានដែរឬទេ?
- តើប្រាក់ខែបានបើកទាន់ពេលវេលាដែរឬទេ?
- តើបុគ្គលិកយោធាទទួលបាននូវរង្វាន់លើកទឹកចិត្តដែរឬទេទៅតាមស្នាដៃ និងគុណសម្បត្តិរបស់ពួកគេ?
- តើស្នាដៃពិតប្រាកដរបស់បុគ្គលិកយោធា មានឥទ្ធិពលទៅលើប្រាក់បៀវត្សរ៍របស់ពួកគេដែរឬទេ?
- តើប្រព័ន្ធប្រាក់បៀវត្សរ៍មានតម្លាភាពសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធនេះ និងសម្រាប់សាធារណជនទូទៅដែរឬទេ?
- តើមានបញ្ហាអ្វីខ្លះទាក់ទងនឹងការចូលនិវត្តន៍ និងប្រព័ន្ធប្រាក់ សោធននិវត្តន៍?
- ទាក់ទងនឹងប្រាក់ខែ និងអត្ថប្រយោជន៍របស់បុគ្គលិកយោធា តើមានការពេញចិត្តពេញថ្លើម ជាមួយកម្មវិធីចូលនិវត្តន៍ដែរឬទេ? តើបុគ្គលិកយោធាបានទទួលអ្វីខ្លះ និងពួកគេខាតអ្វីខ្លះ នៅពេលពួកគេចូលនិវត្តន៍?

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ភារកិច្ច និង ទំហំនៃកងកម្លាំងសន្តិសុខ

- ត្រូវពិនិត្យមើលថាភារកិច្ចដែលបានប្រគល់ទៅឲ្យកងកម្លាំងប្រដាប់អាវុធ ក៏ដូចជាទំហំនៃកងកម្លាំងប្រដាប់អាវុធវាសមស្របគ្នាជាមួយធនធានសេដ្ឋកិច្ចរបស់ជាតិ។

### ប្រាក់បៀវត្សរ៍របស់កងកម្លាំងសន្តិសុខ

- ត្រូវពិនិត្យមើលថា ប្រាក់ខែរបស់បុគ្គលិកយោធាមាននិរន្តរភាពផ្នែកសេដ្ឋកិច្ច និងមានលក្ខណៈប្រកួតប្រជែងនៅក្នុងទីផ្សារការងារ និងសមរម្យសម្រាប់ចិញ្ចឹមជីវិត។
- ត្រូវតាមដានមើលថា ប្រាក់ខែត្រូវបានបើកជាទៀងទាត់។

- ត្រូវចាំថាប្រាក់ខែមិនគ្រប់គ្រាន់អាចប៉ះពាល់ដល់ការផ្តល់សេវាសន្តិសុខនិងមិនលើកទឹកចិត្តដល់យុទ្ធជនវ័យក្មេងដែលមានសក្តានុពល។
- ត្រូវចងចាំថាប្រាក់ខែមិនគ្រប់គ្រាន់ និង/ឬការបង់ប្រាក់ខែមិនទៀងទាត់អាចនាំសេវាសន្តិសុខទៅរកសកម្មភាពពុករលួយ ឬកេងប្រវ័ញ្ចនិងអំពើហិង្សា។
- អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងបុព្វសិទ្ធិរបស់បុគ្គលិកយោធា រួមទាំងថ្នាក់ដឹកនាំរបស់ពួកគេមិនត្រូវបង្កើតបានជាការលើកទឹកចិត្ត ដល់សេវាសន្តិសុខឲ្យខិតខំរក្សា នូវឥទ្ធិពលនយោបាយរបស់ពួកគេនោះឡើយ។ អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនិង បុព្វសិទ្ធិ ត្រូវមានតុល្យភាពជាមួយបុគ្គលិករបស់រដ្ឋាភិបាល ដទៃទៀតផងដែរ។ បុព្វសិទ្ធិប្រគល់ទៅឲ្យបុគ្គលិកយោធាសមស្របជាមួយលក្ខខណ្ឌនិងការបំពេញភារកិច្ចនៅតំបន់គ្រោះថ្នាក់។
- ត្រូវពិនិត្យមើលថាតើ មានរបបចូលនិវត្តន៍ដ៏គួរឲ្យពេញចិត្តដែរ ឬទេ?

# ជំពូកទី ២៧

# កំណែនទ័ព និង ការបដិសេធប្រកបដោយសម្បជញ្ញៈ

រដ្ឋធម្មនុញ្ញរបស់រដ្ឋស្ទើរទាំងអស់ មានបញ្ចូលនូវបញ្ញត្តិមួយដែលចែងថា ការការពាររដ្ឋគឺជាភារកិច្ច និងជាការទទួលខុសត្រូវប្រកបដោយសីលធម៌ចំពោះប្រជាពលរដ្ឋគ្រប់រូប។ នៅក្នុងរដ្ឋខ្លះភារកិច្ចបែបនេះ គឺចងកាតព្វកិច្ចដោយច្បាប់តាមរយៈសេវាយោធាដោយមានគោលបំណងថា ប្រជាពលរដ្ឋគ្រប់រូបត្រូវត្រៀមចូលបម្រើកងកម្លាំងប្រដាប់អាវុធ នៅពេលដែលរដ្ឋាភិបាលត្រូវការពួកគេចាំបាច់។ ប្រជាពលរដ្ឋជាប់កាតព្វកិច្ចចូលបម្រើយោធា (ភាគច្រើនជាបុរស)។ បញ្ញត្តិនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងមាននៅក្នុងច្បាប់ដែលបញ្ជាក់ថា៖

- ✓ អ្នកណាខ្លះ ដែលត្រូវចូលបម្រើយោធា។
- ✓ រយៈពេលបម្រើយោធា។
- ✓ ការពន្យា/ការលើកលែងការចូលបម្រើយោធា។
- ✓ នីតិវិធីនៃការជ្រើសរើស។
- ✓ ទោសចំពោះការគេចវេស។
- ✓ អាយុអប្បបរមា និងអតិបរមា។

ក្រៅពីនេះ ប្រទេសភាគច្រើនបានបញ្ចូលទៅក្នុងច្បាប់នូវសិទ្ធិបដិសេធមិនកាន់អាវុធ គឺការបដិសេធប្រកបដោយសម្បជញ្ញៈ និងការជ្រើសរើសទៅបម្រើសេវាផ្សេង។

## អត្ថប្រយោជន៍ និងភាពពេញចិត្តពេញថ្លើមចំពោះការចូលបម្រើយោធា

ប្រទេសភាគច្រើនបន្តជ្រើសរើសកងទ័ព។ មូលហេតុដ៏សំខាន់មួយ គឺថាប្រទេសទាំងនោះបានចាត់ទុកការជ្រើសរើសយោធានេះ គឺជាធាតុដ៏មានតម្លៃមួយនៃលទ្ធិប្រជាធិបតេយ្យ និងវប្បធម៌ជាតិ។ ក៏ប៉ុន្តែមកដល់ពេលនេះ ការជ្រើសរើសទ័ពកំពុងរងការតវ៉ានៅក្នុងប្រទេសលើពិភពលោក។ សំណួរសម្រាប់ពិភាក្សាដេញដោល គឺអំពីសារៈប្រយោជន៍ និងការពេញចិត្តពេញថ្លើមក្នុងការចូលបម្រើទ័ពនៅក្នុងកងទ័ពដ៏ទំនើប ដោយសារជម្លោះប្រដាប់អាវុធមានលក្ខណៈថ្មីៗ។ ប្រទេសមួយចំនួនបានលុបចោល ឬមានបំណងលុបចោលនូវការកេណ្ឌទ័ពក្នុងពេលអនាគតដ៏ខ្លី។ សូម្បីប្រទេស

បារាំងដែលជាប្រទេសមួយដែលបាន "បង្កើត" ឲ្យមានការកេណ្ឌទ័ពនៅក្នុងសម័យទំនើបនេះ ប្រទេសនេះបានលុបចោលការកេណ្ឌទ័ពនេះនៅក្នុងឆ្នាំ២០០១។ ខ្លះបានទស្សន៍ទាយពីការបញ្ចប់ទៅនៃកងទ័ពមហាជន តែវានឹងត្រូវជំនួសដោយកងកម្លាំងស្ម័គ្រចិត្តទាំងអស់ដែលមានទម្រង់តូច ប្រើបច្ចេកទេសខ្ពស់ និងអាចចល័តបាន។

**ប្រអប់ទី ៦៨**

**សេវាយោធាជុំវិញពិភពលោក**

ការទទួលខុសត្រូវចំពោះការចូលបម្រើកងទ័ព៖ នៅក្នុងប្រទេសភាគច្រើន អាយុចាប់ផ្តើមចូលបម្រើយោធាគឺ ១៨ឆ្នាំ តែនៅក្នុងប្រទេសខ្លះអាយុចូលបម្រើយោធាគឺ ១៦, ១៧, ១៩ ឬ ២០ឆ្នាំ។ សព្វថ្ងៃប្រទេសមួយចំនួនទទួលស្ត្រីធ្វើជាកងទ័ពកំណែនផងដែរ។

រយៈពេលនៃការចូលបម្រើកងទ័ព៖ ជាធម្មតាមានរយៈពេល ៦ខែរហូត ដល់ ៣ឆ្នាំ។

ការបដិសេធប្រកបដោយសម្បជញ្ញៈនិងសេវាជំនួស៖ ប្រទេសជិតពាក់ កណ្តាលពិភពលោកទទួលយកការបដិសេធប្រកបដោយសម្បជញ្ញៈ និងមានសេវាជំនួស។ ក្នុងករណីភាគច្រើនមានការដាក់ទោសជាប់ពន្ធនាគារចំពោះការបដិសេធមិនចូលបម្រើទ័ព។

*ប្រភព៖ របាយការណ៍របស់អគ្គលេខាធិការដែលបានរៀបចំអនុលោមតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការលេខ ១៩៩៥/៨៣ UNCHR ១៩៩៧។ E/CN.4/1997/99*

## ទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃកំណែនទ័ព

នៅពេលយើងធ្វើវិភាគអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃការកេណ្ឌទ័ព តំណាងរាស្ត្រអាចគិតដូចខាងក្រោម៖

### ហេតុអ្វីត្រូវរក្សាកំណែនទ័ព?

មតិគាំទ្រចំពោះកំណែនទ័ពមានដូចខាងក្រោម៖

✓ កំណែនទ័ព ជាញឹកញាប់មានការពាក់ព័ន្ធជាមួយគំនិតនៃលទ្ធិប្រជាធិបតេយ្យ ពីព្រោះវាជាកាតព្វកិច្ចផ្លូវច្បាប់មួយ និងការទទួលខុសត្រូវប្រកបដោយសីលធម៌សម្រាប់ប្រជាពលរដ្ឋម្នាក់ៗ (ភាគច្រើនគឺជាបុរស) និងដោយសារគេចង់អនុវត្តដោយស្មើភាពចំពោះអ្នកពាក់ព័ន្ធទាំងអស់៖ អ្នកដែលមានកាតព្វកិច្ចចូលបម្រើទ័ពដោយមិនគិតពី វណ្ណៈ សាសនា ឬ

ពូជសាសន៍ឡើយ។ នៅក្នុងប្រទេសខ្លះ កាតព្វកិច្ចនេះមិនគិតពីភេទនោះទេ ព្រោះការចូលបម្រើទ័ពនេះ វាសំខាន់សម្រាប់ទាំងបុរស និងស្ត្រីស្មើៗគ្នា។

- ✓ ទាហានដែលបានជ្រើសរើសហើយ ក៏ជាប្រជាពលរដ្ឋក្នុងឯកសណ្ឋាន ហើយវត្តមានរបស់ពួកគេជួយទប់ស្កាត់កងកម្លាំងប្រដាប់អាវុធពីការក្លាយជារដ្ឋមួយនៅក្នុងរដ្ឋ។ ដូច្នេះការកេណ្ឌទ័ពអាចចាត់ទុកថា វាបានផ្សារភ្ជាប់តាមលទ្ធិប្រជាធិបតេយ្យរវាងសង្គម និងកងកម្លាំងប្រដាប់អាវុធ។
- ✓ និយាយជាទូទៅ ការកេណ្ឌទ័ពត្រូវចំណាយទាបជាងកងទ័ពស្ម័គ្រចិត្តដោយសារតែប្រាក់ខែរបស់ទាហានដែលបានជ្រើសរើស ទាបជាងប្រាក់ខែទាហានស្ម័គ្រចិត្តឆ្ងាយណាស់។
- ✓ កំណែនទ័ពនេះ វាធ្វើឲ្យមានការប្រមូលផ្តុំប្រជាពលរដ្ឋមកពីគ្រប់ស្រទាប់ និងគ្រប់ទីកន្លែងនៃសង្គម។ ដូច្នេះទាហានដែលត្រូវបានកេណ្ឌមានប្រវត្តិរៀនសូត្រ និងប្រវត្តិបទពិសោធន៍ការងារចម្រុះដោយអ្នកខ្លះជា គណនេយ្យករ ឬវិស្វករ រហូតដល់ ជាងឈើ ឬកសិករ។ អ្នកដែលជាប់កំណែនទាំងនេះ អាចប្រើនូវគុណវុឌ្ឍន៍រៀនសូត្រ និងបទពិសោធន៍ការងារទាំងនេះបានយ៉ាងល្អ រួមទាំងនៅក្នុងអំឡុងពេលបេសកកម្មរក្សាសន្តិភាពទៀតផង ហើយពួកគេអាចរួមចំណែកដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័នរបស់ប្រទេសក្រោយជម្លោះបានថែមទៀតផង។

## ហេតុអ្វីត្រូវបញ្ចប់កំណែនទ័ព?

ការសិក្សារបស់យើង អំពីការកេណ្ឌកងទ័ព នៅជុំវិញពិភពលោកបានបង្ហាញនូវហេតុផលចម្បងៗដូចខាងក្រោម ដែលនាំទៅរកការបញ្ចប់នូវកងទ័ពមហាជន និងប្រព័ន្ធកេណ្ឌទ័ពនេះ៖

- ✓ នៅក្នុងរយៈពេល២៥ឆ្នាំនេះ ជាពិសេសបន្ទាប់ពីបញ្ចប់ទៅនៃសង្គ្រាមត្រជាក់កងកម្លាំងប្រដាប់អាវុធរបស់ប្រទេស ជាច្រើនបានរួមតូចទៅៗ នេះវានាំទៅរកនូវសមាមាត្រដ៏តូចនៃការកេណ្ឌទ័ពដែលចាំបាច់ដើម្បីបម្រើនៅក្នុងកងទ័ព (ពេលខ្លះមូលហេតុអាចបណ្តាលមកពីសាធារណជនមិនពេញចិត្ត ចំពោះភាពអយុត្តិធម៌រីកសាយ នៅក្នុងដំណើរការនៃការកេណ្ឌទ័ពនេះ)។ ជាពិសេស ប្រទេសនៅក្នុងតំបន់អឺរ៉ុប-អាត្លង់ទិកបានកាត់បន្ថយនូវកងទ័ពរបស់ខ្លួន។ ប្រទេសនៅក្នុងទ្វីបអាហ្វ្រិកនិងទ្វីបអាស៊ីទំនងជាបានប្រើប្រាស់នូវអត្ថប្រយោជន៍នៃសន្តិភាពដែលប្រទេសរបស់ខ្លួនមានបានធ្វើការកាត់បន្ថយនូវចំនួនកងទ័ពបន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់ទៅ។
- ✓ កងកម្លាំងប្រដាប់អាវុធ កាន់តែមានវិជ្ជាជីវៈខ្លាំងឡើងៗ និងមានការពឹងផ្អែកលើបច្ចេកវិទ្យាទំនើបៗ។ ជាញឹកញាប់ ចាំបាច់ត្រូវមានបណ្តុះបណ្តាលរយៈពេលវែង មុនទាហានអាចប្រើប្រាស់នូវប្រព័ន្ធអាវុធដ៏ទំនើប និងស្មុគ្រស្មាញ។ ទាហានដែលបានកេណ្ឌជាទូទៅមិន

បម្រើកងទ័ពយូរនោះទេ ដូច្នេះពួកគេអាចមិនសូវចេះប្រើនូវអាវុធយុទ្ធភ័ណ្ឌដ៏ទំនើបទាំងនេះ ដូច្នេះហើយ បានជាកងទ័ពមានទំនោរទៅរកការជឿជាក់លើទាហានស្ម័គ្រចិត្តអាជីពច្រើនឡើងៗ។

- ✓ បេសកកម្មរក្សាសន្តិភាពតម្រូវយោធាមិនត្រឹមមានជំនាញយោធាជាមូលដ្ឋានប៉ុណ្ណោះនោះទេ តែតម្រូវឲ្យពួកគេក៏ចេះជំនាញចរចា និងជំនាញដទៃផ្សេងទៀតដែរ។ អ្នកជាប់កំណែនភាគច្រើនបម្រើកងទ័ពរយៈពេលខ្លីពេក មិនអាចទទួលបាននូវជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ ដែលអាចចូលរួមនៅក្នុងប្រតិបត្តិការគាំទ្រសន្តិភាព ដែលមានលក្ខណៈស្មុគ្រស្មាញ នៅក្នុងប្រទេសក្រោយជម្លោះបាននោះទេ។
- ✓ នៅក្នុងប្រទេសខ្លះ រដ្ឋធម្មនុញ្ញហាមឃាត់មិនឲ្យប្រើប្រាស់ទាហានកំណែន ដើម្បីការពារទឹកដីរបស់ប្រទេស និងមិនអនុញ្ញាតឲ្យតាំងពង្រាយទាហានកំណែននៅឯបរទេសនោះទេ។

**ប្រអប់ទី ៦៩**

## ការធ្វើទុកបុកម្នេញលើទាហានកំណែន

នៅក្នុងការបម្រើយោធា ឋានានុក្រមមិនផ្លូវការតែងកើតមាន រវាងទាហានកំណែនវ័យក្មេង និងទាហានកំណែនវ័យចំណាស់។ ឋានានុក្រមមិនផ្លូវការបែបនេះ វាសំខាន់ខ្លាំងណាស់ ពីព្រោះទាហានកំណែនវ័យចំណាស់បង្រៀនទាហានកំណែនវ័យក្មេងអំពីវិធាន និងទម្លាប់របស់កងទ័ព។ វាបង្កើតបានជាស្រទាប់សង្គមមួយរបស់យោធា។ ទោះដូច្នេះក៏ដោយ នៅក្នុងករណីជាច្រើនទាហានកំណែនវ័យចំណាស់បានបំពានដល់ឋានានុក្រមមិនផ្លូវការនេះ ដើម្បីអត្ថប្រយោជន៍ឯកជនរបស់ខ្លួន ដោយបង្ខំទាហានវ័យក្មេងធ្វើការជំនួសពួកគេ និងធ្វើបាបពួកគេ។ ប្រសិនបើមិនបានគ្រប់គ្រងដោយមន្ត្រីយោធាបានល្អទេនោះ ឋានានុក្រមមិនផ្លូវការនេះ អាចទៅហួសពីការគ្រប់គ្រងដែលបណ្តាលឲ្យកើតមានស្ថានភាព ដែលទាហានកំណែនវ័យក្មេងធ្វើការតបតជាមួយនឹងការធ្វើបាបអំពើហិង្សាលើរាងកាយ និងការបំភិតបំភ័យ។ យោងតាមអង្គការកំណែនទ័ពនៃក្រុមប្រឹក្សាអឺរ៉ុប (ECCO) ការធ្វើបាប គឺជាបញ្ហាដ៏ធំមួយសម្រាប់ទាហានកំណែនវ័យក្មេង ដោយពេលខ្លះ វាធ្វើឲ្យមានរបួសស្នាម ឬ ពិការរហូត និងអាចបណ្តាលឲ្យស្លាប់ ឬការធ្វើអត្តឃាត។ ដើម្បីធ្វើការការពារទាហានកំណែននិងដើម្បីកេរ្តិ៍ឈ្មោះរបស់កងទ័ព ការធ្វើបាបបែបនេះ ត្រូវតែធ្វើការទប់ស្កាត់តាមរយៈការគ្រប់គ្រងដ៏តឹងរឹងពីមន្ត្រីយោធា។ លើសពីនេះ ស្ថាប័នត្រួតពិនិត្យខាងក្នុង និងខាងក្រៅត្រូវដាក់ទោសក្នុងករណីធ្ងន់ធ្ងរកើតឡើងនិងត្រូវស្តារនីតិរដ្ឋនៅក្នុងកងទ័ពឡើងវិញ។

*ប្រភព៖ Ilona Kiss សិទ្ធិជាប់កំណែននៅក្នុងពេលមានសន្តិភាពឆ្នាំ ២០០១ នៅក្នុង www.dcaf.ch និង ECCO (សូមអានសៀវភៅខ្មៅស្តីពី សិទ្ធិរបស់អ្នកជាប់កំណែន នៅក្នុងអឺរ៉ុបកណ្តាល និងខាងកើត ឆ្នាំ១៩៩៦ http://www.xs4all.nl/~ecco/)*

## ការបដិសេធប្រកបដោយសម្បជញ្ញៈ (conscientious objection “CO”) និងសេវាជំនួស

ប្រជាពលរដ្ឋខ្លះចង់គេចវេសពីកាតព្វកិច្ចរបស់ពួកគេក្នុងការការពារមាតុភូមិ ដោយផ្អែកលើក្រមសីលធម៌ផ្សេងៗ ដូចជាខ្លួនកាន់សាសនា (“មិនត្រូវសម្លាប់ជីវិតមនុស្សសត្វ” ឬជំនឿស៊ីបផ្ទាល់ខ្លួន (ត្រូវប្រកាន់ធម៌អហិង្សា)។ ជាផលវិបាកអ្នកទាំងនេះត្រូវទទួលរងនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរ រួមមានទណ្ឌកម្មលើរាងកាយចំពោះការមិនគោរពតាមបទបញ្ជារបស់រដ្ឋ។

នៅក្នុងពាក់កណ្តាលសតវត្សរ៍ចុងក្រោយ គំនិតទាក់ទងនឹងសិទ្ធិបដិសេធមិនចូលរួមនៅក្នុងកងកម្លាំងប្រដាប់អាវុធ និងកាន់អាវុធបានលេចឡើង និងត្រូវបានគេទទួលយកយ៉ាងទូលំទូលាយ។ នៅក្នុងរដ្ឋខ្លះ គេបានចែងចំណុចនេះនៅក្នុងច្បាប់ថែមទៀតផង។ និន្នាការនេះ វាកើតឡើងទន្ទឹមគ្នានឹងការបញ្ចប់នូវការចូលបម្រើកងទ័ពដោយជាប់កាតព្វកិច្ច នៅក្នុងរដ្ឋខ្លះ (អង់គ្លេស អាល្លឺម៉ង់ អៀកឡង់ដ៍ ហ្វាំងឡង់ បែលហ្សិក លុចហ្សំបួរ បារាំង អេស្ប៉ាញ អ៊ីតាលី និងព័រទុយហ្គាល)។

គេឲ្យនិយមន័យដល់អ្នកបដិសេធប្រកបដោយសម្បជញ្ញៈថាជា អ្នកដែលប្រឆាំងការកាន់អាវុធ ឬ អ្នកបដិសេធមិនចូលរួមនៅក្នុងការហ្វឹកហ្វឺន និងសេវាយោធាណាមួយ។ ទោះបីជាអ្នកបដិសេធទាំងអស់ប្រកាន់ជំហររបស់ខ្លួនដោយផ្អែកលើមនសិការក៏ដោយ ក៏ពួកគេមានហេតុផលសាសនា ទស្សនៈវិជ្ជា ឬ នយោបាយផ្សេងៗគ្នាសម្រាប់ជំនឿរបស់ពួកគេផងដែរ។

## សេចក្តីសម្រេចរបស់សភា

ដោយសារតែការបដិសេធប្រកបដោយសម្បជញ្ញៈកាន់តែត្រូវបានគេគាំទ្រច្រើនឡើង សភានៃរដ្ឋខ្លះ បានសម្រេចបង្កើតច្បាប់នៅក្រោមកាលៈទេសៈដែលប្រជាពលរដ្ឋត្រូវបានរដ្ឋប្រកាសឲ្យចូលបម្រើទ័ព ពួកគេអាចគេចវេសពីកាតួកិច្ចនេះបាន។ ដូចជានៅក្នុងសហរដ្ឋអាមេរិកនិងរដ្ឋនៅអឺរ៉ុបខាងលិចទាំងអស់ដោយប្រទេសក្រិចជាប្រទេសចុងក្រោយដែលទទួលយក CO នេះនៅក្នុងឆ្នាំ ១៩៩៧។

នៅក្នុងរដ្ឋដែល CO មិនត្រូវបានគេទទួលស្គាល់ ពួកគេទទួលរងនូវការចោទប្រកាន់ដោយយកលេសថា ពួកគេរត់ចោលជួរ ឬក្បត់ជាតិដែលជាបទល្មើស២ ដែលមានជាប់ទោសធ្ងន់ធ្ងរ។ នៅក្នុងរដ្ឋផ្សេងទៀត មានការដាក់ទោសព្រហ្មទណ្ឌពិសេស (“ការមិនគោរពប្រតិបត្តិតាមដោយមិនរាងចាល”) ហើយទោសនេះ ត្រូវបានចែងនៅក្នុងច្បាប់យោធា។

## ការទទួលស្គាល់ថាជា CO៖ អ្នកណាជាអ្នកសម្រេច និងផ្អែកលើហេតុផលអ្វីខ្លះ?

នីតិវិធីក្នុងការកំណត់ថាជា CO មានដូចជា ការពន្យល់ហេតុផលពីជំនឿសាសនារបស់ពួកគេ តើជំនឿនេះវាមានឥទ្ធិពលអ្វីខ្លះ មកលើជីវិតរបស់ពួកគេ ហើយតើជំនឿនេះវាប្រឆាំងជាមួយការ

ចូលបម្រើកងទ័ពដូចម្ដេចខ្លះ។ សេចក្ដីសម្រេច ថាតើត្រូវទទួលឋានៈជា CO ឬ ក៏មិនទទួលនោះ វាអាស្រ័យទៅលើគណៈកម្មាធិការចំណុះឲ្យក្រសួងការងារ (ប្រទេសស្វីស ប្រទេសប៊ុលហ្គារី) ក្រសួងមហាផ្ទៃ (ប្រទេសស្លូវ៉ានី) ឬ ក្រសួងយុត្តិធម៌ (ប្រទេសក្រូអាត)។

## CO ក្នុងនាមជាសិទ្ធិមនុស្សមួយ

នៅក្នុងខែមេសា ឆ្នាំ២០០០ បន្ទាប់ពីមានគោលការណ៍ចែងនៅក្នុងសេចក្ដីសម្រេចលេខ ១៩៩៨/៧៧ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានដាក់ចេញដោយមិនមានការបោះឆ្នោតនូវសេចក្ដីសម្រេចលេខ ២០០០/៣៤ ដោយទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការបដិសេធមិនចូលបម្រើកងទ័ពដោយហេតុផលសម្បជញ្ញៈ ថាជាការអនុវត្តសិទ្ធិសេរីភាពដោយស្របច្បាប់នៃការបញ្ចេញមតិ មនសិការ និងសាសនា ដូចដែលមានចែងនៅក្នុងសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ក្នុងឆ្នាំ ១៩៩៣ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានទទួលស្គាល់ថា CO គឺជាសិទ្ធិមួយដែលកើតចេញមកពីមាត្រា ១៨ នៃកតិកាសញ្ញាអន្តរជាតិស្ដីពី"ការប្រើប្រាស់ទ័ពស្ម័គ្រស្លាប់អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃមនសិការ និងសិទ្ធិមានជំនឿលើសាសនា ឬ សិទ្ធិមានជំនឿ"។ គណៈកម្មការអង្គការសហប្រជាជាតិបាន បញ្ជាក់បន្ថែមទៀតថា "នៅពេលដែលសិទ្ធិនេះត្រូវបានគេទទួលស្គាល់ដោយច្បាប់ ឬដោយទម្លាប់ ពេលនោះវាមិនមានអ្វីខុសគ្នារវាងអ្នកបដិសេធប្រកបដោយសម្បជញ្ញៈដោយឈរលើមូលដ្ឋានថា ការចូលបម្រើកងទ័ពជាការប្រឆាំងនឹងជំនឿរបស់ពួកគេដូច្នេះវានឹងគ្មានការរើសអើងប្រឆាំងនឹងអ្នកបដិសេធប្រកបដោយសម្បជញ្ញៈនោះទេ ដោយហេតុដែលពួកគេមិនបានបម្រើកងទ័ពនោះឡើយ"។

**ប្រអប់ទី ៧០**

**សេចក្ដីសម្រេចរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ ១៩៩៨/៧៧៖ ការបដិសេធប្រកបដោយសម្បជញ្ញៈមិនចូលបម្រើកងទ័ព**

គណៈកម្មាធិការ (...) *ចងចាំថា* មានការទទួលស្គាល់នៅក្នុងសេចក្ដីប្រកាសជាសាកលស្ដីពី សិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដី ពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថាមនុស្សគ្រប់រូបមានសិទ្ធិមានជីវិត សេរីភាព និងសន្តិសុខ ក៏ដូចជាមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ មនសិកា និងសាសនា និងសិទ្ធិមិនត្រូវបានគេរើសអើង (...)

*ទទួលស្គាល់ថា* ការបដិសេធប្រកបដោយសម្បជញ្ញៈ មិនចូលបម្រើកងទ័ពដកស្រង់ចេញពីគោលការណ៍ និងហេតុផលនៃមនសិការ ជំនឿដ៏ស៊ុប មានដូចជា ជំនឿលើសាសនា សីលធម៌មនុស្សធម៌ (...)។

១. *មានការចាប់អារម្មណ៍ចំពោះ* សិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការបដិសេធប្រកបដោយសម្បជញ្ញៈមិនចូលបម្រើកងទ័ពថាជាការអនុវត្ត សិទ្ធិសេរីភាពបញ្ចេញមតិ មនសិកា និងសាសនាស្របច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា ១៨ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។

២. *សូមស្វាគមន៍* ចំពោះរដ្ឋខ្លះដែលបានទទួលយកនូវការបដិសេធប្រកបដោយសម្បជញ្ញៈនេះថាជាការបដិសេធស្របច្បាប់ដោយមិនមានការសួរដេញដោល។

៣. *អំពាវនាវដល់រដ្ឋទាំងឡាយ* ដែលមិនទាន់មានប្រព័ន្ធបែបនោះឲ្យបង្កើតនូវស្ថាប័នធ្វើសេចក្តីសម្រេចចិត្តដោយឯករាជ្យ និងមិនលំអៀងក្នុងការអនុញ្ញាតឲ្យមានការបដិសេធប្រកបដោយសម្បជញ្ញៈក្នុងករណីជាក់លាក់ ដោយមិនមានការរើសអើងរវាងអ្នកបដិសេធប្រកបដោយសម្បជញ្ញៈដោយហេតុផលពួកគេមានជំនឿផ្សេងៗ។

៤. *រំលឹកដល់រដ្ឋទាំងឡាយ* ដែលមានប្រព័ន្ធកាតព្វកិច្ចចូលបម្រើកងទ័ពដែលមិនទាន់មានបទបញ្ញត្តិទាក់ទង នឹងការបដិសេធប្រកបដោយសម្បជញ្ញៈត្រូវផ្តល់ដល់អ្នកបដិសេធនូវទម្រង់ផ្សេងៗនៃសេវាជំនួស ដែលសមស្របជាមួយហេតុផល ដែលពួកគេបដិសេធ ដូចជាអ្នកមិនប្រយុទ្ធ ឬ ជាអ្នកជួយសង្គ្រោះដល់ជនស៊ីវិលដើម្បីផលប្រយោជន៍សាធារណៈ និងមិនមែនដើម្បីជាការដាក់ទោសនោះទេ។

៥. *សង្កត់ធ្ងន់ថា* រដ្ឋទាំងឡាយត្រូវប្រកាន់យកនូវវិធានការដ៏ចាំបាច់នានា ដើម្បីកុំដាក់ទោសពន្ធនាគារដល់អ្នកបដិសេធប្រកបដោយសម្បជញ្ញៈ ឬ ដាក់ទណ្ឌកម្មដដែលៗ ចំពោះការខកខានមិនបានចូលបម្រើកងទ័ព និងរំលឹកថា គ្មានបុគ្គលណាម្នាក់ត្រូវទទួលខុសត្រូវ ឬទទួលទោសម្តងទៀតចំពោះបទល្មើសដែលខ្លួនបានកាត់ទោសស្ថាពររួចហើយ ឬត្រូវបានលើកលែងទោសរួចហើយស្របតាមច្បាប់និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗឡើយ (...)។

សេចក្តីសម្រេចលេខ ១៩៩៨/៧៧ UNCHR

## សេវាជំនួស

រដ្ឋភាគច្រើន ដែលទទួលស្គាល់ឋានៈរបស់ CO បានផ្តល់នូវសេវាជំនួសឲ្យសេវាយោធាដែលមានចែងនៅក្នុងច្បាប់។ សេវាជំនួសនេះ អាចមានគំរូ ២ធំៗៈ

- ✓ ចូលបម្រើកងទ័ពដោយមិនកាន់អាវុធ។
- ✓ ចូលបម្រើស្ថាប័នខាងសុខុមាលភាពសង្គម ដូចជាមន្ទីរពេទ្យថែទាំមនុស្សចាស់ជរា អង្គការជនពិការ។ល។ ពេលខ្លះចូលបម្រើការងារជាមួយ NGOs ឬ អង្គការអន្តររដ្ឋាភិបាល។

ជាធម្មតា សេវាជំនួសមានរយៈពេលវែងជាងសេវាយោធា។ ឧទាហរណ៍ នៅក្នុងប្រទេសបារាំងវាមានរយៈពេល២០ខែហើយសេវាយោធាមានរយៈពេល១០ខែ។ នៅក្នុងប្រទេសអូទ្រីសវាមានរយៈពេល ១២ខែ ហើយសេវាយោធាមានត្រឹមតែ៧ខែ។ នៅក្នុងប្រទេសប៊ុលហ្គារីមានរយៈពេល ២៤ខែ ហើយសេវាយោធាមានរយៈ ពេលចន្លោះ ៦ ទៅ ៩ខែប៉ុណ្ណោះ។

**ប្រអប់ទី ៧១**

## សេវាជំនួស៖ ករណីប្រទេសស្វីស

ប្រទេសស្វីសគឺជា ប្រទេសមួយក្នុងចំណោមប្រទេសបីបួននៅក្នុងអឺរ៉ុបខាងលិច ដែលនៅប្រើប្រាស់កំណែនទ័ព។ កំណែនទ័ពត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ៥៩.១) ច្បាប់ស្តីពីអង្គការយោធាឆ្នាំ ១៩៩៥ និងច្បាប់ស្តីពីសេវាយោធាឆ្នាំ ១៩៩៥។ កំណែនទ័ពត្រូវបានអនុវត្តចំពោះបុរសទាំងអស់អាយុចន្លោះពី ២០ ដល់ ៤២ឆ្នាំ និងរហូតដល់ ៥៥ឆ្នាំសម្រាប់អ្នកមានឋានន្តរសក្តិខ្ពស់។

សេវាយោធាមានដំបូងមានរយៈពេល ៤ខែ និង ៣សប្តាហ៍រៀងរាល់ ២ឆ្នាំ រួមទាំងលំហាត់បាញ់កាំភ្លើងពេញមួយឆ្នាំទៀត។

ច្បាប់ស្តីពីសេវាជំនួសឆ្នាំ១៩៩៦ ទទួលស្គាល់សិទ្ធិបដិសេធប្រកបដោយសម្បជញ្ញៈដោយហេតុផលសីលធម៌និងសាសនា។ក្រសួងឧស្សាហកម្ម និងការងារទទួលពាក្យសុំដែលត្រូវបានសម្រេចដោយគណៈកម្មាធិការ ដែលមានសមាជិក ៣រូប ដែលបានជ្រើសរើសចេញពីសមាជិកចំនួន១២០រូប ដែលបានជ្រើសរើសចេញពីការផ្សាយតាមសារព័ត៌មាន។ ប្រហែលជា ៥% នៃអ្នកដែលមានអាយុជាប់កំណែនត្រូវ បានចុះបញ្ជីថាជា COs។ ចំពោះអ្នកដែលសិទ្ធិរបស់ពួកគេត្រូវចាត់ទុកថាជា COs មិនត្រូវបានទទួលស្គាល់នោះទេ តែនៅទទូចចង់ក្លាយជាCOs អាចប្រឈមមុខនឹងការជាប់ទោសពន្ធនាគាររយៈពេល ៤ ទៅ ៥ ខែ។

COs ត្រូវបំពេញសេវាពលរដ្ឋជំនួសឲ្យសេវាយោធា។ សេវានេះមានរយៈពេល ៤៥០ថ្ងៃនៅក្នុងស្ថាប័នសាធារណៈនិងឯកជនដែលបម្រើឲ្យផលប្រយោជន៍សាធារណៈ ដូចជាមន្ទីរពេទ្យ មណ្ឌលយុវជន មណ្ឌលស្រាវជ្រាវនៅឯសាកលវិទ្យាល័យ នាយកដ្ឋានព្រៃឈើ ។ល។

*ប្រភព៖ ការិយាល័យអឺរ៉ុបសម្រាប់ការបដិសេធប្រកបដោយសម្បជញ្ញៈ(EBCO)*

# ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

## កំណែនទ័ព ឬគ្មានកំណែនទ័ព?

- ▷ ត្រូវថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នទាំងគុណសម្បត្តិ និងគុណវិបត្តិស្របតាមបរិបទនៃប្រទេសរបស់អ្នក។
- ▷ ក្នុងន័យនេះ ត្រូវចងចាំនូវធាតុសំខាន់ៗទាំងឡាយដែលមាននៅក្នុងជំពូកនេះ និងត្រូវពិនិត្យមើលថា តើធាតុណាខ្លះដែលវាពាក់ព័ន្ធជាមួយបរិបទនៃប្រទេសរបស់អ្នក។

## អ្នកជាប់កំណែនទទួលរងនូវការបំពាន ឬការប្រព្រឹត្តបែបបន្ទាបបន្ថោក

- ▷ ត្រូវចាត់វិធានការជាបន្ទាន់ប្រសិនបើមានអ្នកជាប់កំណែនណាម្នាក់ត្រូវបានរាយការណ៍ថាបានទទួលរងនូវការបំពានការរុកគួន ឬអំពើហិង្សា។
- ▷ ត្រូវពិនិត្យមើលថាតើមានការស៊ើបអង្កេតស៊ីជម្រៅដែលឬទេហើយប្រសិនបើចាំបាច់ត្រូវមានការដាក់ទោសដោយស្ថាប័នមានសមត្ថកិច្ច និងត្រូវអនុវត្តដោយមិនបង្អង់យូរ។
- ▷ ប្រសិនបើមិនទាន់មានការិយាល័យបណ្តឹងការពារជាតិនៅក្នុងប្រទេសរបស់អ្នក សូមពិចារណាស្នើសុំឲ្យមានការបង្កើតការិយាល័យបណ្តឹងនោះ ហើយត្រូវប្រគល់សិទ្ធិអំណាចដល់ការិយាល័យនោះ ដើម្បីធ្វើការដោះស្រាយនូវការប្រព្រឹត្តបំពាន ឬការបន្ទាបបន្ថោកទៅលើអ្នកជាប់កំណែន។

## ឋានៈជា COs

- ▷ ធ្វើការបញ្ជាក់ឋានៈផ្លូវច្បាប់របស់ COs នៅក្នុងប្រទេសរបស់អ្នក ហើយប្រសិនបើអាចសូមពិចារណាចាត់វិធានការកំណត់និយមន័យវា នៅក្នុងច្បាប់ឬកែលំអច្បាប់ដែលមានស្រាប់។
- ▷ នៅក្នុងបរិបទនេះ ធានាថាអ្នកបានទទួលនូវព័ត៌មានថ្មីៗបំផុតទាក់ទងនឹងវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហា និង ស្ថានភាពផ្លូវច្បាប់ និងជាក់ស្តែងនៅក្នុងរដ្ឋផ្សេងទៀត។

## សេវាជំនួស

- ▷ ត្រូវផ្ទៀងផ្ទាត់មើលថាតើសេវាជំនួសមានបញ្ចូល នៅក្នុងច្បាប់នៅក្នុងប្រទេសរបស់អ្នកឬទេ ហើយប្រសិនបើអាចសូមពិចារណាបញ្ចូលនិយមន័យរបស់វានៅក្នុងច្បាប់ឬធ្វើការកែលំអច្បាប់ដែលមានស្រាប់។
- ▷ នៅក្នុងបរិបទនោះ អ្នកត្រូវធានាថាអ្នកបានទទួលនូវព័ត៌មានថ្មីបំផុតអំពីវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហា និងស្ថានភាពផ្លូវច្បាប់ និងជាក់ស្តែងនៅក្នុងរដ្ឋផ្សេងទៀត។

## ផ្នែកទី VIII

# ធនធានសម្ភារៈ៖
# ការធ្វើឲ្យសម្រេចដោយជោគជ័យនូវការត្រួតពិនិត្យ
# ប្រកបដោយប្រសិទ្ធភាពលើការផ្ទេរអាវុធ
# និងលទ្ធកម្មអាវុធ

## ជំពូកទី ២៨

# លទ្ធកម្មអាវុធ និងសម្ភារៈយោធា

គោលនយោបាយលទ្ធកម្មត្រូវចេញពីផែនការ និងគោលនយោបាយ "ជាន់ខ្ពស់" ដូចជាយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខយោធា ជាដើម។ រាល់តម្រូវការសម្រាប់អាវុធ ឬសម្ភារៈយោធា គួរតែត្រូវបានត្រួតពិនិត្យដោយគិតពិចារណានូវផលប៉ះពាល់ និងសារៈសំខាន់របស់វា ចំពោះគោលនយោបាយសន្តិសុខជាតិ។

ទស្សនាទានជាតិស្តីពី វិស័យសន្តិសុខជួយធ្វើឲ្យសម្រេចបាននូវស្ថិរភាពនៅក្នុងដំណើរការគ្រប់គ្រងកិច្ចការការពារជាតិនិងបង្កើននូវភាពអាចប្រមើលមើលនៅក្នុងការរៀបចំគោលនយោបាយការពារជាតិរយៈពេលវែង។ វាសំខាន់ណាស់ក្នុងការរក្សានូវគោលបំណង នៃគោលនយោបាយការពារជាតិឲ្យសមស្របជាមួយធនធាន ដែលបានផ្តល់ឲ្យសម្រាប់វិស័យការពារជាតិ និងរក្សានូវតុល្យភាពរវាងវិស័យការពារជាតិ និងសង្គម។

## តម្លាភាពនៅក្នុងលទ្ធកម្មអាវុធ

នៅក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យដ៏រឹងមាំសកម្មភាពធ្វើថវិកា ជាទូទៅ និងលទ្ធកម្មអាវុធជាពិសេស ត្រូវតែមានតម្លាភាពនិងគណនេយ្យភាពចំពោះសាធារណជន។ តាមទស្សនៈនៃគណនេយ្យភាពសាធារណៈ វាត្រូវមានទំនាក់ទំនងសមហេតុផលរវាងគោលនយោបាយផែនការថវិកាជាមួយនឹងលទ្ធកម្មអាវុធ។ នៅគ្រប់ទីកន្លែង បញ្ហានេះគេមិនធ្វើទាំងប្រថុយប្រថាននោះទេ។ ជាអកុសលនៅក្នុង ប្រទេសភាគច្រើន សភាមានអំណាចកំណត់នៅក្នុងបញ្ហាលទ្ធកម្មអាវុធ។

នៅពេលផ្តល់មូលនិធិ ឬផ្តល់នូវសិទ្ធិអំណាចដល់ប្រតិបត្តិការលទ្ធកម្ម វាសំខាន់ណាស់សម្រាប់សភាធ្វើការត្រួតពិនិត្យមើល អំពីនីត្យានុកូលភាពនៃប្រតិបត្តិការបែបនោះ ជាពិសេសត្រូវចងចាំនូវលិខិតូបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិ ដែលរឹតត្បិតនូវការផលិត ការជួញដូរ ឬការប្រើប្រាស់នូវប្រភេទនៃអាវុធខ្លះ ដូចជា សន្ធិសញ្ញា មិនរីកសាយអាវុធនុយក្លេអ៊ែរ (១៩៦៨) អនុសញ្ញាក្រុងអូតាវ៉ាស្តីពីការហាមឃាត់ការប្រើប្រាស់ការស្តុកទុកការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងបំផ្លាញមនុស្ស (១៩៩៧) សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ល។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលសភាបានជួបការលំបាកនៅក្នុងការដោះស្រាយនូវភាពស្មុគស្មាញពាក់ព័ន្ធជាមួយការគណនាតម្លៃលើសម្ភារៈការពារជាតិធំៗ។ បញ្ហានេះ វាធ្វើឲ្យ

ប្រទេសកំពុងអភិវឌ្ឍនិងប្រទេសងើបពីជម្លោះងាយរងគ្រោះពីអ្នកផ្គត់ផ្គង់អាវុធខាងក្រៅនិងខាងក្នុង ដែលធ្វើការលក់ដូរផលិតផលរបស់ពួកគេក្នុងតម្លៃដ៏ថោក និងមានកង្វល់បន្តិចបន្តួចអំពីលក្ខខណ្ឌនៃការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យ។

ចំពោះមូលហេតុទាំងនេះ សភាមានចំណាប់អារម្មណ៍ នៅក្នុងការបង្កើតគណៈកម្មការពិសេស ឬអនុគណៈកម្មការទទួលបន្ទុកបញ្ហាលទ្ធកម្មអាវុធ។ ដោយធ្វើបែបនេះ ពួកគេអាចលើកកម្ពស់តម្លាភាពនៅក្នុងដំណើរការលទ្ធកម្មអាវុធ និងបង្ខំនីតិប្រតិបត្តិឲ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

សភាមានបញ្ហា ដោយសាររដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការបញ្ចេញនូវតួលេខពាក់ព័ន្ធនឹងការមានអាវុធធំៗធម្មតា និងតម្រូវការនៃការទិញអាវុធធំៗធម្មតាទាំងនេះ (យន្តហោះចម្បាំង រថក្រោះ កាំភ្លើងធំ ប្រព័ន្ធរ៉ាដា មីស៊ីល និង នាវាចម្បាំង ជាដើម) ហើយមួយផ្នែកទៀត រដ្ឋាភិបាលមិនមានឆន្ទៈក្នុងការផ្សព្វផ្សាយជាសាធារណៈនូវប្រភេទអាវុធធន់តូច និងធន់ស្រាលដែលខ្លួនមាន និងត្រូវផ្ទេរ (កាំភ្លើងគ្រាប់ calibre តូចជាង ១០០ ម.ម)។

នៅក្នុងដំណើរការទិញអាវុធ ជាគោលការណ៍រដ្ឋាភិបាលត្រូវសហការជាមួយសភាដើម្បីធានាថា ផែនការទិញអាវុធដែលហួសពីមហិច្ឆតាវាមិនដាក់បន្ទុកលើហិរញ្ញវត្ថុរបស់ប្រទេសក្នុងរយៈពេលវែង។ កម្មវិធីទិញអាវុធគឺចាត់ទុកដូចជាការទិញដូរទ្រព្យសម្បត្តិសាធារណៈដទៃទៀតដែរ។ ដូច្នេះ មិនត្រឹមតែយោធាមានអាទិភាពប៉ុណ្ណោះនោះទេ វិស័យផ្សេងទៀតក៏មានអាទិភាពនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តផងដែរ។ សភាត្រូវវាយតម្លៃពីផលប៉ះពាល់ និងបន្ទុកហិរញ្ញវត្ថុនៃការទិញអាវុធទៅលើសង្គមជាតិ។

**ប្រអប់ទី ៧២**

## ហេតុអ្វីសភាគួរយកចិត្តទុកដាក់ចំពោះការធ្វើលទ្ធកម្មអាវុធ?

- ▷ ដោយសារមានការពាក់ព័ន្ធជាមួយមូលនិធិសាធារណៈ។
- ▷ ការសម្រេចអំពីប្រព័ន្ធអាវុធ វាមិនត្រឹមតែជាបញ្ហាទាក់ទងនឹងជំនាញបច្ចេកទេស និងសន្តិសុខប៉ុណ្ណោះនោះទេ តែវាក៏ទាក់ទងនឹងការធ្វើសេចក្ដីសម្រេចលើថវិកា ដែលត្រូវចំណាយទៅលើ "កាំភ្លើង ឬប៊ឺរ" (gun or butter) ហើយប្រសិនបើវាត្រូវចំណាយលើ "កាំភ្លើង" តើជា "កាំភ្លើងប្រភេទអ្វី" តើវាតម្លៃប៉ុន្មាន ហើយហេតុអ្វីចាំបាច់ទិញកាំភ្លើងប្រភេទនេះជាដើម។
- ▷ ការទិញអាវុធ មិនត្រូវបង្កជាបន្ទុកដល់ហិរញ្ញវត្ថុរបស់ប្រទេសឡើយទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង (រួមទាំងការ ចំណាយទូទៅពេញមួយវដ្តរបស់វាផង)។
- ▷ ការត្រួតពិនិត្យដោយសភា ត្រូវធ្វើការថ្លឹងថ្លែងនូវតម្លៃនៃការចំណាយលើអាវុធធៀបនឹងតម្រូវការក្នុងវិស័យសង្គមកិច្ច។

- ▷ ដំណើរការលទ្ធកម្មអាវុធត្រូវមានតម្លាភាព មានគណនេយ្យភាពចំពោះសភា ចៀសវាងអំពើពុករលួយធ្វើឲ្យខាតបង់ និងរំលោភបំពានមូលនិធិសាធារណៈ។
- ▷ ការត្រួតពិនិត្យដោយសភា និងសាធារណជនអាចនាំទៅរកការកាត់បន្ថយនូវគ្រោះថ្នាក់នៃការទិញអាវុធតាមផ្លូវមិនត្រង់នៅក្នុងតំបន់។

## តើកាលៈទេសៈពិសេសត្រូវរក្សាជាការម្ងាត់ ឬទេ?

គោលការណ៍នៃអភិបាលកិច្ចល្អ ជាពិសេសតម្លាភាពត្រូវតែជួយតម្រង់ទិសដល់ការរៀបចំគោលនយោបាយសាធារណៈក្នុងគ្រប់ទិដ្ឋភាពទាំងអស់ រួមទាំងទិដ្ឋភាពទាក់ទងនឹងការលក់ ឬទិញអាវុធផងដែរ។ ដូច្នេះវាជាការចាំបាច់ក្នុងការពិនិត្យមើលថាតើកាលៈទេសៈពិសេសអ្វីខ្លះ ដែលអាចធ្វើឲ្យការធ្វើសេចក្តីសម្រេចចិត្តផ្នែកការពារជាតិក្លាយជាករណីលើកលែង ហើយវាចាំបាច់ត្រូវតែរក្សាជាការសម្ងាត់នោះ។

គោលការណ៍ណែនាំអំពីការលក់ និងទិញអាវុធ ត្រូវផ្អែកលើគោលការណ៍នៃតម្លាភាព និងគណនេយ្យភាពសាធារណៈ។ មូលហេតុនៃភាពសម្ងាត់ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលតម្រូវដោយប្រទេសជាអ្នកផ្គត់ផ្គង់ ឬ ជាអ្នកទទួលត្រូវថែងឲ្យបានច្បាស់លាស់។ ប្រសិនបើមូលហេតុបែបនោះនាំទៅរកលទ្ធភាពនៃអំពើពុករលួយនៅក្នុងកិច្ចព្រមព្រៀង ទិញ - លក់ អាវុធហានិភ័យបែបនេះត្រូវតែកំណត់ឡើងដោយភាគីទាំង២ហើយត្រូវកំណត់ផងដែរ នូវវិធានការដើម្បីបញ្ចៀសនូវហានិភ័យទាំងនោះ។

**ប្រអប់ទី ៧៣**

### គោលនយោបាយដ៏ខ្សោយ ឬមិនច្បាស់លាស់នៃលទ្ធកម្មអាវុធ ឬដំណើរការនៃការធ្វើលទ្ធកម្មអាវុធមានលក្ខណៈសម្ងាត់ខ្ពស់អាចនាំទៅរក...

- ▷ ការពិនិត្យទៅលើមូលហេតុនៃការទិញប្រព័ន្ធអាវុធមិនបានគ្រប់ជ្រុងជ្រោយ។
- ▷ ការមិនមានប្រសិទ្ធភាពនៅក្នុងសេចក្តីសម្រេចរបស់រដ្ឋាភិបាល ដោយវាអាចមានផលវិបាកមិនល្អចំពោះសន្តិសុខជាតិ និងតំបន់។
- ▷ ការសង្ស័យពីប្រទេសជិតខាង។
- ▷ អំពើពុករលួយនៅក្នុងលទ្ធកម្មអាវុធ និងសេចក្តីសម្រេចលើលទ្ធកម្មទាក់ទងនឹងសម្ភារៈយោធាគ្រប់ប្រភេទ។
- ▷ មានការប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ទំនុកចិត្តសាធារណជន ចំពោះកងកម្លាំងប្រដាប់អាវុធដែលអាចនាំទៅរកការបាត់បង់នូវកេរ្តិ៍ឈ្មោះ និងមានភាពចម្រូងចម្រាសដែលមិនចាំបាច់។

## ការធ្វើសេចក្តីសម្រេចគ្រប់គ្រងជ្រោយលើបញ្ហាលទ្ធកម្ម

នៅក្នុងករណីនៃការទិញប្រព័ន្ធអាវុធនៅក្នុងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត គេត្រូវកំណត់ និងបញ្ចូលនូវវិធីសាស្ត្រ និងទិដ្ឋភាពដូចខាងក្រោម៖

- ✓ បែបនៃការវាយតម្លៃការគម្រាមកំហែង។
- ✓ ទស្សនទានរយៈពេលវែងនៃការកសាងសមត្ថភាពការពារជាតិ។
- ✓ ការកំណត់នូវតម្រូវការសម្ភារៈថ្មីៗ។
- ✓ ការចាត់ចែងបែងចែកថវិកាសម្រាប់លទ្ធកម្មអាវុធ។
- ✓ ការធានានូវគុណភាពបច្ចេកទេស និងដំណើរការសវនកម្មទៅលើសមិទ្ធិផលក្រោយពីលទ្ធកម្មអាវុធ។
- ✓ ការចំណាយទាំងមូលទៅលើវគ្គនៃលទ្ធកម្មអាវុធ (life cycle cost) រួមទាំងការថែទាំ និងការធ្វើកែលំអ ឬធ្វើបច្ចុប្បន្នភាពអាវុធ។ល។
- ✓ វាយតម្លៃលើសំណង និងការទូទាត់ផ្សេងៗ។

បង្កើតនូវដំណើរការពិនិត្យ និងសើរើរបស់សភានៅក្នុងគ្រប់ដំណាក់កាលទាំងអស់នេះ វានឹងកាត់បន្ថយនូវឱកាសនៃការខាតបង់ ការកេងបន្លំ ឬការបំពាននៅក្នុងប្រព័ន្ធនៃការធ្វើសេចក្តីសម្រេចរបស់អង្គការនីតិប្រតិបត្តិ។ ដើម្បីអនុវត្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពសភាត្រូវតម្រូវឲ្យរដ្ឋាភិបាលជូនដំណឹងដល់ពួកគេ អំពីគ្រប់ដំណាក់កាលនៃលទ្ធកម្មអាវុធទាំងអស់។ លើសពីនេះសភាត្រូវមានសិទ្ធិសម្រេច លើកិច្ចសន្យាលទ្ធកម្មទាំងអស់។ សភារបស់ប្រទេសហ្វាំងឡង់ជាឧទាហរណ៍មួយនៃអង្គនីតិប្បញ្ញត្តិមួយ ដែលពិនិត្យតាមដានរាល់ដំណាក់កាលទាំងអស់នៃសេចក្តីសម្រេចលើបញ្ហាលទ្ធកម្មអាវុធ (សូមអានប្រអប់ទី ៧៤)។

**ប្រអប់ទី ៧៤**

### គោលនយោបាយប្រទេសហ្វាំងឡង់ ស្តីពីការធ្វើលទ្ធកម្មការពារជាតិ៖ ផ្នែកត្រួតពិនិត្យដោយសភា

ប្រទេសហ្វាំងឡង់មានប្រពៃណីរឹងមាំយូរអង្វែង និងការអនុវត្តដ៏តឹងរឹងនៃការត្រួតពិនិត្យដោយសភាទៅលើលទ្ធកម្មការពារជាតិ។ ជាគោលការណ៍រាល់សេចក្តីសម្រេចលទ្ធកម្មទាំងអស់ដែលមានតម្លៃលើសពី២៥លានអឺរ៉ូ (ប្រហែល ២៥លានដុល្លា) ត្រូវឆ្លងកាត់សភា។ ដំណើការនេះគេហៅថានីតិវិធីទិញ។ រដ្ឋាភិបាល(ជាក់ស្តែងគឺរដ្ឋមន្ត្រីការពារជាតិ) បញ្ជូនលិខិតមួយដែលបានជ្រើសរើសចេញពីប្រភេទទាំង ៤ (ក ខ គ និងឃ) អាស្រ័យលើដំណាក់កាលនៃការទិញ។ ដោយមិនបាច់ពន្យល់លំអិតដំណាក់កាលខុសៗគ្នានេះ វាចាប់ផ្តើមពីតម្រូវការនៃប្រព័ន្ធអាវុធថ្មីមួយ (ឬ

ទិញអាវុធថ្មីយកមកផ្លាស់ប្តូរអាវុធកំពុងប្រើ)រហូតដល់សំណើធំសុំទិញប្រព័ន្ធអាវុធ X ពីអ្នកផលិត Y ជាដើម។

សភា ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់ដំណាក់កាលទាំងអស់នៃការទិញ។ ដូច្នេះ នៅពេលដែលរដ្ឋាភិបាលបង្ហាញថាខ្លួន ចង់ផ្លាស់ប្តូរអាវុធ ឬទិញអាវុធ (ឬលើកឡើងអំពីការចង់បានប្រព័ន្ធអាវុធនេះ ឬ អាវុធនោះ) សភាអាចជំទាស់ ឬ កែសម្រួលនូវសំណើនោះ។ សេចក្តីសម្រេចចុងក្រោយ (ការផ្តល់"ភ្លើងខៀវ") ក៏អាចត្រូវបានជំទាស់ ឬ កែសម្រួលផងដែរ ទោះបីជាក់ស្តែងការណ៍នេះជាញឹកញាប់កម្រកើតឡើងណាស់។ ភាគច្រើនចេតនារបស់រដ្ឋាភិបាលនៅក្នុងដំណើរការទាំងមូលត្រូវទទួលរងនូវឥទ្ធិពលពីអក្សរ ៤តួ (ក ខ គ និង ឃ) ដែលត្រូវបានពិភាក្សានៅក្នុងសភា។

ចំពោះគម្រោងធំៗដែលលើសពី ១០០ លានអឺរ៉ូ នីតិវិធីពិសេសត្រូវបានបង្កើតឡើង ("គម្រោងធំ") ដែលពាក់ព័ន្ធការរាយការណ៍កាន់តែលំអិត និងញឹកញាប់ទៅកាន់សភា។ ឧទាហរណ៍ជាក់ស្តែងមួយនៃរឿងនេះគឺ ចេតនារបស់រដ្ឋាភិបាលហូឡង់ក្នុងការចូលរួមនៅក្នុងដំណាក់កាល រៀបចំសំណើទិញយន្តហោះវាយប្រហាររួមដែលជាយន្តហោះបន្តវេនពីយន្តហោះ F-16 របស់អាមេរិក។ ក៏ប៉ុន្តែវាមានគម្រោងធំៗផ្សេងទៀត ឧ. កងពលតូចចល័តទ័ពអាកាសរបស់ប្រទេសហូឡង់។

ជាទូទៅ វាហាក់ដូចជាថានៅក្នុងប្រទេសហូឡង់ស្ថានការណ៍បច្ចុប្បន្នរបស់ប្រទេសត្រូវបានវិនិច្ឆ័យថាវាគួរឲ្យពេញចិត្ត។ វាមានការពិភាក្សាអំពីបន្ទុកហិរញ្ញវត្ថុ និងការត្រួតពិនិត្យដោយសភាទៅលើដំណើរការដែលពេលខ្លះវាមានលក្ខណៈបច្ចេកទេសខ្លាំង។ នៅក្នុងក្របខណ្ឌនេះ ស្ថាប័នការពារជាតិឯករាជ្យបានចោទជាសំណួរទាក់ទងនឹងបញ្ហាគុណភាព និងឯករាជ្យភាពនៃព័ត៌មានរបស់រដ្ឋាភិបាល និងការចង់បាននូវ "ភស្តុតាងដើម្បីយកមកជំទាស់" ដោយស្ថាប័ននេះ។ ចុងក្រោយក៏មានការពិភាក្សាអំពីតួនាទីរបស់ឧស្សាហកម្ម និងអ្នកបញ្ចុះបញ្ចូល និងការឆ្លងកាត់សមាជិកគណៈកម្មការការពារជាតិ។ ទោះដូច្នេះក៏ដោយ ដោយមិននិយាយអំពីបញ្ហារឿងអាស្រូវ វាមិនមានហេតុការណ៍អាក្រក់ធំៗកើតឡើងនោះទេ ទាក់ទងនឹងបញ្ហានេះ។

*ប្រភព៖ Jan Hoekema អតីតសមាជិកសភា ប្រទេសហូឡង់ ឆ្នាំ២០០២*

## ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

### ការត្រួតពិនិត្យលទ្ធកម្មអាវុធ

- ▷ ការត្រួតពិនិត្យលទ្ធកម្មអាវុធរបស់សភាត្រូវតែបញ្ចូលទៅក្នុងច្បាប់។
- ▷ ត្រូវពិនិត្យមើលថាតើការត្រួតពិនិត្យដោយសភាទៅលើវិស័យសន្តិសុខបានគ្រប់ជ្រុងជ្រោយ ឬទេ ហើយវាបានគ្របដណ្តប់រាល់ទិដ្ឋភាពទាំងអស់នៃលទ្ធកម្មដែរឬទេ

ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ៖
- តម្រូវការផ្នែកសន្តិសុខ។
- ផលវិបាកផ្នែកនយោបាយនៅក្នុងតំបន់ ដូចជា ការរត់ប្រណាំងសព្វាវុធនៅក្នុងតំបន់។
- បន្ទុកថវិកា (រយៈពេលខ្លី និងរយៈពេលវែង) និង
- ឥទ្ធិពលទៅលើឧស្សាហកម្មជាតិ នៅក្នុងវិស័យឯកជន និងសាធារណៈ។

## តម្លាភាព និង គណនេយ្យភាពនៅក្នុងលទ្ធកម្មសព្វាវុធ

▷ ត្រូវធ្វើឲ្យប្រាកដថា សភាមានយោបល់នៅក្នុងដំណើរការនៃលទ្ធកម្មសព្វាវុធ និងសម្ភារៈយោធា។

▷ តម្រូវឲ្យមានវត្តមានសភា ឬគណៈកម្មការមានសមត្ថកិច្ចរបស់សភា ក្នុងករណីចាំបាច់ ដោយមានរបាយការណ៍លំអិតថ្មីៗ ទាក់ទងនឹងការមានសព្វាវុធធំៗធម្មតា និងមានគុណភាពផ្នែកបច្ចេកទេស (យន្តហោះចម្បាំង រថក្រោះ កាំភ្លើងធំ ប្រព័ន្ធរ៉ាដា មីស៊ីល និងនាវាចម្បាំង) និងប្រភេទកាំភ្លើងធន់តូច និងស្រាល (កាំភ្លើងគ្រាប់តូចជាង ១០០ ម.ម) រួមទាំងមូលហេតុនៃការទិញសព្វាវុធថ្មីៗទាំងនេះ។

▷ ត្រូវធានាថា សភាទទួលបាននូវឯកសារពន្យល់អំពីផែនការកសាងសមត្ថភាពការពារជាតិរយៈពេលវែង។

▷ ត្រូវធានាថា បញ្ហាទាក់ទងនឹងការសម្ងាត់នៅក្នុងកិច្ចព្រមព្រៀងលទ្ធកម្ម ត្រូវបានដោះស្រាយដោយសភា ឬដោយគណៈកម្មការមានសមត្ថកិច្ចរបស់សភា តាមរយៈដំណើរការស្របច្បាប់ដែលធានានូវគណនេយ្យភាពទន្ទឹមនឹងការរក្សានូវការសម្ងាត់យោធា។

## ការវិភាគផលប៉ះពាល់នៃលទ្ធកម្ម

▷ ធ្វើវិភាគភាពស៊ីសង្វាក់គ្នានៃផែនការលទ្ធកម្មជាមួយគោលនយោបាយវិស័យសន្តិសុខ។

▷ ត្រូវធានាថា សភាបានសិក្សានិងវាយតម្លៃបន្ទុកហិរញ្ញវត្ថុនៃលទ្ធកម្មសព្វាវុធដោយប្រៀបធៀបជាមួយតម្រូវការសាធារណៈ និងអាទិភាពសង្គមផ្សេងទៀត ដើម្បីទប់ស្កាត់នូវអតុល្យភាព ដែលធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍ និងស្ថិរភាពនៃសេដ្ឋកិច្ចសង្គមរបស់ប្រទេស។

▷ ប្រើប្រាស់នូវនីតិវិធីសភា ដើម្បីទប់ស្កាត់នូវសេចក្តីសម្រេចលទ្ធកម្មសព្វាវុធដែលហួសមហិច្ឆតា។ សភា ត្រូវធានានូវភាពសមហេតុសមផលនៅក្នុងផែនការដែលមិនបណ្តាលឲ្យមានបន្ទុកយោធាដល់ប្រទេសជាតិក្នុងរយៈពេលវែង។

### សវនកម្មលើលទ្ធកម្មសព្វាវុធ

- ត្រូវពិនិត្យ ពីភាពសមស្របរវាងគោលនយោបាយ និងផែនការការពារជាតិ ថវិកាការពារជាតិ ជាមួយការចំណាយជាក់ស្តែងទៅលើសម្ភារៈយោធា និងគ្រឿងសព្វាវុធ។
- ធ្វើសវនកម្ម អំពីលទ្ធផលក្រោយពីលទ្ធកម្មប្រព័ន្ធសព្វាវុធ ក្រោយពីកិច្ចសន្យាត្រូវបានអនុវត្ត (យ៉ាងហោចណាស់ក៏ធ្វើសវនកម្មដំណាក់កាលទាំងពចំណុចនៅក្នុងវដ្តនៃលទ្ធកម្មសព្វាវុធដែរ)។

### គណៈកម្មការលទ្ធកម្មសភា

- ប្រសិនបើមិនទាន់មានគណៈកម្មការ ឬអនុគណៈកម្មការលទ្ធកម្មសភាទេ សូមបង្កើតគណៈកម្មការ ឬអនុគណៈកម្មការនេះ ដោយលើកឡើងអំពីសារៈសំខាន់នៃទំនាក់ទំនងរវាងការធ្វើផែនការគោលនយោបាយ ផែនការហិរញ្ញវត្ថុ និងសវនកម្ម ឧស្សាហកម្មការស្រាវជ្រាវ និងការអភិវឌ្ឍន៍ការពារជាតិ។
- ក្នុងន័យនេះ ស្នើសុំ និងសិក្សាព័ត៌មានអំពីលក្ខខណ្ឌការងារ (ToR) នីតិវិធី និងលទ្ធផលរបស់ស្ថាប័នស្រដៀងគ្នានៅក្នុងសភាផ្សេង។
- ធ្វើការធានាថា ស្ថាប័នសភារបស់អ្នកទទួលបាននូវយោបល់ និងប្រើប្រាស់យោបល់ពីអ្នកជំនាញនានា។

## ជំពូកទី ២៩

# ការជួញដូរ និងការផ្ទេរអាវុធ

សភា មានតួនាទីដ៏សំខាន់នៅក្នុងការត្រួតពិនិត្យទាំងការជួញដូរ និងផ្ទេរសព្វាវុធ។ វិធាន និងនីតិវិធីដែលគ្រប់គ្រងលើលទ្ធកម្មសព្វាវុធត្រូវតែស្របគ្នាជាមួយវិធាន និងនីតិវិធីដែលមានចែង នៅក្នុងច្បាប់ជាតិ ស្តីពីលទ្ធកម្មសព្វាវុធ ច្បាប់ថវិកាជាតិ និងច្បាប់ហិរញ្ញវត្ថុ ឬកិច្ចសន្យា និងច្បាប់ស្តីពីការដោះស្រាយវិវាទ។ទិដ្ឋភាពនានានៃគោលនយោបាយ ស្តីពីការជួញដូរ និងផ្ទេរសព្វាវុធ និងក្របខណ្ឌច្បាប់របស់វា គួរតែផ្អែកលើគោលការណ៍តម្លាភាព និងគណនេយ្យភាព។

**ប្រអប់ទី ៧៥**

**ការផ្ទេរសព្វាវុធ៖ និយមន័យ**

ការផ្ទេរអាវុធ ជាទូទៅត្រូវបានគេយល់ថា វាគ្របដណ្តប់លើរាល់ សកម្មភាពទាំងអស់ដែលរដ្ឋ និងតួអង្គមិនមែនរដ្ឋបានចូលរួមនៅក្នុង សកម្មភាព ទាំងនោះដើម្បីទទួល ឬលក់សព្វាវុធ។ ការផ្ទេរសព្វាវុធរួមមាន ការលក់ ឬធ្វើអាជីវកម្ម ទិញ ឬធ្វើលទ្ធកម្ម រួមទាំងការបរិច្ចាគសព្វាវុធ។

## គោលនយោបាយជាតិស្តីពីការជួញដូរ និងផ្ទេរសព្វាវុធ

រដ្ឋាភិបាលគួរដាក់ចេញនូវគោលនយោបាយ និងច្បាប់ ស្តីពីការលក់សព្វាវុធដែលត្រូវដាក់ជូនសភាដើម្បីអនុម័តយល់ព្រម។ គោលនយោបាយនេះ គួរតែកំណត់នូវគោលការណ៍ណែនាំសម្រាប់ការលក់សព្វាវុធធម្មតា និងត្រូវបញ្ចូលនូវចំណុចដូចខាងក្រោម៖

- ✓ ការនាំចូល និងនាំចេញ នូវសព្វាវុធធម្មតាត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយគណៈកម្មការសភាដែលពាក់ព័ន្ធ។
- ✓ លិខិតបទដ្ឋានគតិយុត្ត ស្តីពីការជួញដូរសព្វាវុធត្រូវស្របជាមួយគោលការណ៍ទាំងឡាយនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ច្បាប់អន្តរជាតិ ឬការហាមឃាត់សព្វាវុធរបស់អង្គការសហប្រជាជាតិ និងត្រូវគិតដល់បញ្ហាសេដ្ឋកិច្ច នយោបាយ សីលធម៌ និងសន្តិសុខរបស់ប្រទេសដែលទិញសព្វាវុធ។
- ✓ គោលការណ៍តម្លាភាពនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីធានានូវសុចរិតភាពនិងគណនេយ្យភាពវិជ្ជាជីវៈ។

- ✓ យន្តការទប់ស្កាត់ការលក់ដោយមិនមានសីលធម៌គួរបញ្ចូលទៅក្នុងច្បាប់ដោយផ្អែកលើអនុសាសន៍អង្គការសហប្រជាជាតិ និងអនុសាសន៍ពាក់ព័ន្ធដទៃទៀតនិងផ្អែកលើការអនុវត្តល្អៗនៅក្នុងប្រទេសនានា។ អ្នកផ្គត់ផ្គង់និងអ្នកទទួលគួរបង្កើតនូវក្រមសុចរិតមួយ។
- ✓ សភាត្រូវមានការយល់ដឹងអំពីលក្ខណៈ និងប្រភេទ នៃសព្វាវុធដែលបានលក់ថាវាពិតជាដើម្បីបម្រើសេចក្តីត្រូវការខាងការពារជាតិពិតប្រាកដមែន ដូចដែលសភានៃប្រទេសទទួលបានអនុម័តយល់ព្រម។
- ✓ សភានៃប្រទេសផ្គត់ផ្គង់សព្វាវុធត្រូវមានការយល់ដឹងពីប្រទេសទទួលថា តើប្រទេសនេះមានការគោរពសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋាន និងមានប្រព័ន្ធគណនេយ្យភាពប្រកបដោយប្រសិទ្ធភាពចំពោះសេចក្តីសម្រេចចិត្តពាក់ព័ន្ធជាមួយលទ្ធកម្មសព្វាវុធ។
- ✓ សភាត្រូវមានការយល់ដឹងថា ការលក់សព្វាវុធនេះមិនមែនដើម្បីបំផ្លាញសន្តិភាពបង្កើនភាពតានតឹងតំបន់ ឬជម្លោះប្រដាប់អាវុធ ឬបង្កើតការលក់សព្វាវុធតាមផ្លូវងងឹតនៅក្នុងតំបន់នោះទេ ឬបង្កអស្ថិរភាពនៅក្នុងតំបន់តាមរយៈការលក់ប្រព័ន្ធសព្វាវុធដែលធ្វើឲ្យពិភពលោកមិនមានស្ថិរភាព ឬការលក់អាវុធធុនតូច និងស្រាលនោះទេ។ សភាត្រូវមានការយល់ដឹងថាតើគណៈកម្មការការពារជាតិសភាបានចាប់ផ្តើមពិភាក្សា អំពីការគម្រាមកំហែងដល់ស្ថិរភាពតំបន់ឬទេ ឬយល់ដឹងអំពីការទិញអាវុធដ៏ច្រើនលើសលុបនិងមានករណីអំពើពុករលួយដែលបើកឲ្យមានការពិភាក្សាដេញដោលនៅថ្នាក់តំបន់ដែរឬទេ។
- ✓ គួរបង្កើតយន្តការ ដើម្បីទប់ស្កាត់ការលក់សព្វាវុធដល់ប្រទេសខ្លះដែលបាននាំចេញសព្វាវុធបន្ត ឬបង្វែរគោលបំណងផ្ទុយពីលក្ខខណ្ឌដែលមានបញ្ជាក់នៅក្នុងលិខិតនាំចូល។

សភាត្រូវបង្កើតនូវនីតិវិធីសវនកម្មឯករាជ្យមួយ ដោយមានអំណាចតាមផ្លូវច្បាប់ដើម្បីធានាថាដំណើរការលក់សព្វាវុធថ្នាក់ជាតិ វាស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានដោយឯករាជ្យ។ នេះគឺ ត្រូវធ្វើដោយអនុលោមតាមគោលការណ៍ណែនាំដែលកំណត់ដោយសភា។ ប្រអប់ទី៧៦ មានឧទាហរណ៍អំពីកិច្ចព្រមព្រៀងអន្តរជាតិ និងក្រមប្រតិបត្តិពាក់ព័ន្ធជាមួយគោលនយោបាយជាតិស្តីពីជួញដូរសព្វាវុធ។

**ប្រអប់ទី ៧៦**

## កិច្ចព្រមព្រៀងតំបន់ស្តីពីការផ្ទេរសព្វាវុធ

▷ **ក្រមប្រតិបត្តិអឺរ៉ុប**

ក្រុមប្រឹក្សាសហភាពអឺរ៉ុប បានចេញនូវសេចក្តីសម្រេចមួយ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៩៨។ សេចក្តីសម្រេចនេះមានគោលបំណងទប់ស្កាត់នូវលំហូសព្វាវុធចេញពីប្រទេស

ក្នុងសហភាពអឺរ៉ុបទៅកាន់តំបន់អស្ថិរភាពនៅក្នុងពិភពលោក ដែលមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ រដ្ឋជាសមាជិកសហភាពអឺរ៉ុប បានចេញនូវសេចក្ដីសម្រេចចិត្តបន្ទាប់ពីទទួលនូវការគាបសង្កត់ពីអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ស្នើសុំឲ្យដាក់ចេញនូវគោលនយោបាយជួញដូរសព្វាវុធប្រកបដោយការទទួលខុសត្រូវ។ ក្រមនេះមានបញ្ចូលនូវបញ្ជីឈ្មោះទិសដៅដែលរសើបមួយចំនួន និងផ្ដល់នូវប្រព័ន្ធមួយសម្រាប់ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យនូវការផ្ដល់និងការប្រើប្រាស់សព្វាវុធ ក៏ដូចជាប្រព័ន្ធចែករំលែកព័ត៌មានទៅវិញទៅមកនិងការពិគ្រោះយោបល់គ្នាស្ដីពីការអនុញ្ញាត និងបដិសេធអាជ្ញាប័ណ្ណនាំចេញ។ ក្រមប្រតិបត្តិអឺរ៉ុបមិនបានចងកាតព្វកិច្ចលើរដ្ឋជាភាគីនោះទេ ហើយក៏មិនមានយន្តការដើម្បីតម្រូវឲ្យរដ្ឋទាំងនោះឲ្យមានការទទួលខុសត្រូវ ចំពោះការខកខានមិនបានគោរពតាមក្រមនោះដែរ។

ដូច្នេះវាអាស្រ័យលើរដ្ឋដែលមានច្បាប់ ស្ដីពីការនាំចេញសព្វាវុធធ្វើការរឹតត្បិតការនាំចេញទៅឲ្យជនល្មើស ដែលរំលោភសិទ្ធិមនុស្ស ហើយបន្ទាប់មកដាក់ការគាបសង្កត់នៅក្នុងយន្តការពិគ្រោះយោបល់ទ្វេភាគី។

ក្រមនេះ មានលក្ខខណ្ឌវិនិច្ឆ័យ៨ចំណុច ដែលរដ្ឋជាសមាជិកត្រូវយកចិត្តទុកដាក់ពាក់ព័ន្ធជាមួយការនាំចេញសព្វាវុធៈ

១) "គោរពការប្ដេជ្ញាចិត្តជាអន្តរជាតិរបស់រដ្ឋជាសមាជិកសហភាពអឺរ៉ុបទាំងអស់ ជាពិសេសការដាក់ទណ្ឌកម្ម ដែលបានចេញក្រិតដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ(...)។

២) គោរពសិទ្ធិមនុស្សនៅក្នុងប្រទេសដែលជាគោលដៅចុងក្រោយ (...)។

៣) ស្ថានភាពផ្ទៃក្នុងនៅក្នុងប្រទេស ដែលជាគោលដៅចុងក្រោយ ដែលកើតមាននូវភាពតានតឹង ឬជម្លោះប្រដាប់អាវុធ (...)។

៤) រដ្ឋជាសមាជិកនឹងមិនចេញនូវអាជ្ញាប័ណ្ណនាំចេញ ប្រសិនបើមានហានិភ័យជាក់ស្ដែងដែលប្រទេសទទួល និងប្រើប្រាស់នូវសព្វាវុធនាំចេញដ៏ច្រើនលើសលុបនេះ ដើម្បីប្រឆាំងនឹងប្រទេសមួយទៀត ឬដើម្បីប្រើប្រាស់កម្លាំងដើម្បីទាមទារទឹកដីមកវិញ (...)។

៥) សន្តិសុខជាតិរបស់រដ្ឋជាសមាជិក និងរបស់ដែនដីដែលទំនាក់ទំនងការបរទេសរបស់ប្រទេសនោះ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រដ្ឋជាសមាជិក ឬជាសម្ព័ន្ធមិត្ត (...)។

៦) អាកប្បកិរិយារបស់ប្រទេសអ្នកទិញទាក់ទងនឹងសហគមន៍ អន្តរជាតិ ដូចជាឥរិយាបថគាំទ្រដល់ពួកភេរវករ ចរិកលក្ខណៈនៃសម្ព័ន្ធភាពរបស់ប្រទេសនោះ និងការគោរពច្បាប់អន្តរជាតិរបស់ប្រទេសនោះ (...)។

៧) មានហានិភ័យថា សម្ភារៈសព្វាវុធនឹងត្រូវបង្វែរទៅទិសដៅផ្សេង នៅក្នុងប្រទេសអ្នកទិញ ឬត្រូវបានដឹកជញ្ជូនបន្តទៅកន្លែងផ្សេងដែលមានលក្ខខណ្ឌមិនល្អ (...)។

៨) ភាពសមស្របនៃសមត្ថភាពផ្នែកបច្ចេកទេស និងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសទទួល (...)″

*ប្រភព៖ http://europa.eu.int*

### ▷ អង្គការរដ្ឋអាមេរិក និងការផ្ទេរសព្វាវុធ

តម្លាភាព នៅក្នុងការជួញដូរសព្វាវុធតំបន់សម្រាប់អាមេរិកត្រូវបានកែលំអនៅពេលដែលសមាជិកទាំង១៩ នៃអង្គការរដ្ឋអាមេរិក(OAS)បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្តីពីការផ្ទេរអាវុធធម្មតា។ អនុសញ្ញាអន្តរអាមេរិកស្តីពីតម្លាភាពនៅក្នុងការទិញសព្វាវុធធម្មតាដែលត្រូវបានអនុម័តយល់ព្រមនៅក្នុងមហាសន្និបាតនៅក្នុងទីក្រុងកាតិម៉ាឡា តម្រូវឲ្យប្រទេសហត្ថលេខីទាំងអស់បញ្ចេញព័ត៌មានអំពីការនាំចេញ និងនាំចូលគ្រឿងសព្វាវុធធំៗប្រចាំឆ្នាំ។

យោងតាមមាត្រា៣ ៉រដ្ឋជាភាគីត្រូវរាយការណ៍ជាប្រចាំឆ្នាំ ដល់ឃ្លាំងស្តុក (depositary) អំពីការនាំចេញ និងនាំចូលនូវអាវុធធម្មតារបស់ខ្លួន នៅក្នុងឆ្នាំប្រតិទិនខាងមុខដោយផ្តល់នូវព័ត៌មានអំពីរដ្ឋនាំចេញពាក់ព័ន្ធជាមួយការនាំចូល និងបរិមាណ និងប្រភេទនៃសព្វាវុធដែលបាននាំចូលរួមទាំង ព័ត៌មានអំពីប្រទេសនាំចូលពាក់ព័ន្ធជាមួយការនាំចេញ និងបរិមាណ និងប្រភេទនៃសព្វាវុធដែលបាននាំចេញ។ រដ្ឋភាគីអាចផ្តល់នូវព័ត៌មានបន្ថែមដែលខ្លួនគិតថាវាមានការពាក់ព័ន្ធ ដូចជាការកំណត់អាវុធនិងម៉ូដែលរបស់អាវុធ (...)។ ក្រៅពីនេះ រដ្ឋត្រូវជូនដំណឹងដល់គ្នាទៅវិញទៅមកអំពីការនាំចូលការផលិតសព្វាវុធនៅក្នុងប្រទេស និងព័ត៌មានទាក់ទងនឹងការមិនមានការនាំចូល ឬការផលិតសព្វាវុធក្នុងប្រទេស (មាត្រា ៦)។

*ប្រភព៖http://www.oas.org,2002*

## ការគោរពការដាក់ទណ្ឌកម្មសព្វាវុធជាអន្តរជាតិ

ទណ្ឌកម្ម គឺជាឧបករណ៍របស់សហគមន៍អន្តរជាតិមួយសម្រាប់បញ្ជូនសញ្ញាមិនយល់ស្របចំពោះអាកប្បកិរិយារបស់រដ្ឋមួយក្នុងករណីរដ្ឋនោះកំពុងរំលោភច្បាប់អន្តរជាតិ និងគម្រាមកំហែងសន្តិភាព និងសន្តិសុខអន្តរជាតិ។ មូលដ្ឋានផ្លូវច្បាប់នេះមានចែងនៅក្នុងមាត្រា៤១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលអាចឲ្យក្រុមប្រឹក្សាសន្តិសុខធ្វើការអំពាវនាវដល់រដ្ឋជាសមាជិកកុំឲ្យប្រើអាវុធដើម្បីស្តារសន្តិភាពនិងសន្តិសុខអន្តរជាតិ។ ចាប់ពីឆ្នាំ១៩៤៥ រហូតដល់ឆ្នាំ១៩៩០ ក្រុមប្រឹក្សា

សន្តិសុខអង្គការសហប្រជាជាតិបានដាក់ទណ្ឌកម្មតែលើប្រទេស២ប៉ុណ្ណោះ។ ចាប់តាំងពីឆ្នាំ១៩៩០ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានដាក់ទណ្ឌកម្មសរុបចំនួន១២ដង។

ក្នុងន័យនេះ ការស្នើសុំលិខិតទិញអាវុធ ដែលមានបញ្ជាក់ទិសដៅ ចុងក្រោយដែលសព្វាវុធត្រូវបញ្ជូនទៅដល់នោះ អាចជាឧបករណ៍ដ៏សំខាន់មួយសម្រាប់សភាធ្វើការពិនិត្យទូទៅលើនីតិវិធីសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ការផ្ទេរអាវុធ។ ទោះដូច្នេះក៏ដោយ វាមានការបំពានយ៉ាងច្រើនដោយសារមានការក្លែងបន្លំនូវលិខិតទិញអាវុធនេះ។

## ការចុះបញ្ជីសព្វាវុធធម្មតារបស់អង្គការសហប្រជាជាតិ

នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩១ មហាសន្និបាតបានចេញនូវសេចក្តីសម្រេចលេខ ៤៦/៣៦L មានចំណងជើងថា "តម្លាភាពចំពោះគ្រឿងសព្វាវុធ" ដែលស្នើសុំឲ្យអគ្គលេខាធិការបង្កើតនិងរក្សាទុកនូវបញ្ជីគ្រឿងសព្វាវុធធម្មតាដែលមានលក្ខណៈជាសាកល និងមិនរើសអើងនៅឯសេនាធិការដ្ឋានអង្គការសហប្រជាជាតិនៅក្នុងទីក្រុងញូយ៉កដើម្បីបញ្ចូលទិន្នន័យ ស្តីពីការផ្ទេរអាវុធជាអន្តរជាតិ រួមទាំងព័ត៌មានដែលបានផ្តល់ដោយរដ្ឋជាសមាជិកអំពី បន្ទាយយោធាលទ្ធកម្មអាវុធការផលិតអាវុធក្នុងប្រទេសនិងគោលនយោបាយពាក់ព័ន្ធដទៃទៀត។

បញ្ជីមានចុះអាវុធធំៗចំនួន៧ប្រភេទ ដែលបានឯកភាពក្នុងនោះមាន រថក្រោះ យាន្តមានបំពាក់អាវុធ (armoured vehicles) ប្រព័ន្ធកាំភ្លើងធ្លោង យន្តហោះប្រយុទ្ធ ឧទ្ធម្ភាគចក្រប្រយុទ្ធ នាវាចម្បាំង និងមីស៊ីល។ បញ្ជីនេះបានចូលជាធរមានពីឆ្នាំ១៩៩២។ អគ្គលេខាធិការបានដាក់របាយការណ៍ជាទៀងទាត់ជូនមហាសន្និបាត ដែលមានទិន្នន័យ និងព័ត៌មានដែលបានផ្តល់ដោយរដ្ឋចំនួន ១១០ រដ្ឋអំពីការនាំចូល និងនាំចេញនូវគ្រឿងសព្វាវុធដែលមាននៅក្នុងបញ្ជីនោះ។ របាយការណ៍នេះ ក៏មានបញ្ចូលនូវព័ត៌មានដែលផ្តល់ដោយរដ្ឋាភិបាលអំពីការទិញអាវុធពីប្រទេសផលិតអាវុធនិងពីបន្ទាយយោធាផងដែរ។ សូមអាន http://disarmament.un.org/cab/register.html។

## តម្រូវការនូវ "ការដាក់ទណ្ឌកម្មដ៏វៃឆ្លាត"

អគ្គលេខាធិការបានហៅការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ចដ៏គ្រប់ជ្រុងជ្រោយថាជា "ឧបករណ៍មិនវៃឆ្លាត" មួយ។ វិធានការនេះ ជានិច្ចជាកាលមិនមានប្រសិទ្ធភាពហើយជាញឹកញាប់វាធ្វើឲ្យប៉ះពាល់ដល់ប្រទេសជិតខាង ក៏ដូចជាប្រជាពលរដ្ឋសាមញ្ញនៃប្រទេស ដែលជាគោលដៅនៃទណ្ឌកម្ម។ ដូច្នេះ អ្នកខ្លះជឿថាការដាក់ទណ្ឌកម្ម ដែលមានលក្ខណៈកាន់តែវៃឆ្លាតនិងផ្តោតចំបញ្ហាជាងមុនគឺជាការចាំបាច់បំផុត។ ការដាក់ទណ្ឌកម្មសព្វាវុធ គឺជាប្រភេទមួយនៃការដាក់ទណ្ឌកម្មដ៏វៃឆ្លាត បន្ទាប់ពីការដាក់ទណ្ឌកម្មលើហិរញ្ញវត្ថុ និងការធ្វើ ដំណើរ។ ការដាក់ទណ្ឌកម្មដ៏វៃឆ្លាត តម្រង់គោលដៅទៅរករបប និងអ្នកដឹកនាំប្រទេសដោយមិនធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ សាមញ្ញ និងកងកម្លាំងប្រឆាំងនៅក្នុងប្រទេស។ ទោះដូច្នេះក្តីការដាក់ទណ្ឌកម្មដ៏វៃឆ្លាតបានបង្ហាញថាវាមានការ

លំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តនិងមិនទទួលបានជោគជ័យទាំងស្រុងនោះទេ។ វិធានការនេះត្រូវកែសម្រួល និងកែលំអឡើងវិញ (សូមអានប្រអប់ទី ៧៧)។

**ប្រអប់ទី ៧៧**

**ការធ្វើឲ្យការដាក់ទណ្ឌកម្មអាវុធកាន់តែមានភាពវៃឆ្លាត៖ តើសភាអាចធ្វើអ្វីបានខ្លះ?**

សភានៅក្នុងប្រទេសនាំអាវុធចេញ ត្រូវធានាឲ្យមានការបង្កើតនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ត្រូវមានច្បាប់ និងគោលការណ៍ណែនាំរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្តដែលកំណត់ការរំលោភលើការដាក់ទណ្ឌកម្មអាវុធរបស់អង្គការសហប្រជាជាតិ គឺជាបទល្មើសព្រហ្មទណ្ឌមួយ។
- ត្រូវមានការសម្របសម្រួលខាងក្នុងរដ្ឋាភិបាល ដែលត្រូវចាត់តាំងអង្គភាពនាំមុខមួយសម្រាប់អនុវត្តការដាក់ទណ្ឌកម្ម។
- ត្រូវចែករំលែកព័ត៌មាន និងព័ត៌មានចារកម្មជាមួយក្រសួងរបស់រដ្ឋាភិបាល និងរវាងរដ្ឋាភិបាល និងរដ្ឋាភិបាលដើម្បីកំណត់នូវការដឹកជញ្ជូនទិសដៅផ្លូវឆ្លងកាត់ដែលសង្ស័យ ឬឈ្មួញកណ្តាល។
- ត្រួតពិនិត្យបញ្ជីដែលកំណត់នូវមុខទំនិញដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្ម។
- ត្រូវមានសិទ្ធិអំណាចដកហូតទំនិញដឹកជញ្ជូន ដែលបំពានលើការដាក់ទណ្ឌកម្មជាជាងបង្វិលទំនិញត្រឡប់ទៅប្រទេសប្រភពដើម។
- ត្រូវមានបទបញ្ញត្តិក្នុងការបង្កក ឬដកហូតទ្រព្យសម្បត្តិពីផលនៃបទល្មើស ឬពីការលក់ដូរអាវុធដោយខុសច្បាប់។
- ធ្វើការស៊ើបអង្កេត និងផ្ទៀងផ្ទាត់នូវការដឹកជញ្ជូនអាវុធ ដែលអាចបង្វែរខុសទិសដៅ។

ប្រភព៖ គេហទំព័ររបស់ BICC www.bicc.de, ឆ្នាំ២០០២

## កេរមរតកក្រោយសង្គ្រាមត្រជាក់៖ គ្រឿងសព្វាវុធដែលផលិតលើស និងការផ្ទេរ

សង្គ្រាមត្រជាក់ បាននាំទៅរកការកាត់បន្ថយទំហំនៃកងទ័ពនៅជុំវិញពិភពលោក។ នេះមានន័យថា មានគ្រឿងសព្វាវុធរាប់លាន ត្រូវបាននៅសល់លែងប្រើការ។ កង្វះនូវការគ្រប់គ្រងដ៏ស៊ីសង្វាក់នូវអាវុធដែលនៅសល់ទាំងនេះនៅក្នុងពិភពលោក បណ្តាលឲ្យមានការផ្ទេរអាវុធរាប់លានពីរដ្ឋាភិបាលមួយ ទៅរដ្ឋាភិបាលមួយ និងពីរដ្ឋាភិបាលទៅក្រុមមិនទាន់មានរដ្ឋ ដែលនេះវាធ្វើឲ្យការផ្ទេរអាវុធបែបនេះ គេចផុតពីការត្រួតពិនិត្យជាសាធារណៈ។ វាច្បាស់ណាស់ថាភាគច្រើននៃអាវុធទាំងនេះត្រូវបានបង្វែរខុសទិសដៅឲ្យទៅជាការលួចអាវុធ ឬលួចដោយផ្ទាល់ចេញពីឃ្លាំងសព្វាវុធដែលមិនមានការយាមកាមតឹងរ៉ឹង។

ប្រហែល ២/៥ នៃសព្វាវុធធំៗធម្មតាទាំងអស់ដែលបានធ្វើការជួញដូរនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ចេញមកពីស្តុកដែលនៅសល់។ មូលហេតុនៃការនៅសល់អាវុធដ៏ច្រើនសន្ធឹកសន្ធាប់នេះ រួមទាំង បាតុភូតនៃការជួញដូរអាវុធជាអន្តរជាតិនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ គឺជាឃ្លាំងសព្វាវុធដ៏ធំរបស់អតីតប្លុកសូវៀត ដែលបានរួចផុតពីការគ្រប់គ្រងរបស់អាជ្ញាធរមជ្ឈិម។ ដោយសារប្រទេសមានបញ្ហាសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ និងដោយសារនៅមានសេសសល់អាវុធដ៏ច្រើនសន្ធឹកសន្ធាប់ ឃ្លាំងសព្វាវុធដែលលើសបានក្លាយជាប្រភពនៃសាច់ប្រាក់ដែលត្រូវការចាំបាច់ ដើម្បីបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុជាបន្ទាន់។ ម្យ៉ាងទៀត វាជាការពិតដែលថាការលក់ដូរភាគច្រើនត្រូវបានរៀបចំដោយបណ្តាញឧក្រិដ្ឋជន ដែលអាចមាន ឬមិនមានទំនាក់ទំនងជាមួយអ្នកដឹកនាំនយោបាយដែលកំពុងកាន់អំណាច។ ទោះដូច្នេះក្តីអតីតប្លុកសូវៀតមិនមែនជាអ្នកប្រែក្លាយឃ្លាំងអាវុធឲ្យទៅជាការលក់ដូរតែឯងនោះទេ។ មានប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ជាច្រើនបានធ្វើបែបនេះផងដែរ។

**ប្រអប់ទី ៧៨**

**ការជួញដូរអាវុធដែលនៅសល់៖ ផលអវិជ្ជមាននៃការដកហូតអាវុធ**

"ទោះបីជាមានការធ្លាក់ចុះនូវការជួញដូរអាវុធថ្មីៗក៏ដោយ ក៏ស្ថិតិបង្ហាញថាមានការជួញដូរយ៉ាងច្រើននូវអាវុធចាស់ៗដែលសេសសល់។ កត្តារួមផ្សំរវាងកត្តារុញច្រាន និងកត្តាអូសទាញមានឥទ្ធិពលទៅលើការជួញដូរអាវុធនៅសេសសល់នេះ។ សន្ធិសញ្ញាស្តីពីការដកហូតអាវុធការឈប់បាញ់ និងការកាត់បន្ថយនូវការតាំងពង្រាយបានបង្កើតនូវបញ្ជីសារពើភ័ណ្ឌដែលមានអាវុធធំៗសរុបចំនួន ១៦៥,០០០ អាវុធ។ នៅក្នុងពិភពលោកទាំងមូលដែលក្នុងនោះ មានអាវុធជាង ១៨,០០០អាវុធ ត្រូវបាននាំចេញ ឬបានផ្តល់ឲ្យចន្លោះ ឆ្នាំ១៩៩០ និង ១៩៩៥។ ជាលើកដំបូងហើយក្នុងឆ្នាំ១៩៩៤ ដែលការជួញដូរអាវុធលើសមានចំនួនច្រើនជាងការជួញដូរអាវុធថ្មី។ មានការជួញដូរអាវុធលើសដោយតម្លៃទាប ឬការផ្តល់អាវុធដោយគិតថ្លៃតាមរយៈកម្មវិធីជំនួយ។ ការជួញដូរបែបនេះវាមានផលមិនល្អចំពោះ កម្មវិធីដកហូតសព្វាវុធនៅក្នុងតំបន់ជម្លោះ និងបង្កឲ្យមានការរត់ប្រណាំងសព្វាវុធនៅក្នុងតំបន់។

*ប្រភព៖ Herbert Wulf ឆ្នាំ១៩៩៨ មជ្ឈមណ្ឌលអន្តរជាតិទីក្រុងបោន*
*សម្រាប់ការទប់ស្កាត់ការបម្លែងអាវុធធុនតូច www.bicc.de*

វាច្បាស់ណាស់ថា ប្រទេសដែលទិញអាវុធគឺជា ប្រទេសមិនសូវរីកចម្រើនដូច្នេះជាទូទៅប្រទេសនេះមានរចនាសម្ព័ន្ធសភា សម្រាប់ធ្វើការពិនិត្យតាមដាននៅទន់ខ្សោយនៅឡើយ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ មានប្រទេសយ៉ាងហោចណាស់ចំនួន៩០ប្រទេស បាននាំចូលអាវុធធំៗដែលលើស។ វាសំខាន់ណាស់ ដែលត្រូវធ្វើការត្រួតពិនិត្យឲ្យកាន់តែតឹងរ៉ឹងចំពោះអាវុធធុនតូចហើយច្បាប់គួរចងកាតព្វកិច្ចចំពោះរដ្ឋាភិបាល និងយោធាឲ្យរាយការណ៍ប្រចាំឆ្នាំដល់សភាអំពីការ

បាត់បង់ ឬចោរកម្មអាវុធធុនតូច និងគ្រាប់រំសេវ។ គេត្រូវប្រកាន់យកនូវវិធានការចំពោះការបំលែងរោងចក្រអាវុធធុនតូចឲ្យទៅជារោងចក្រផលិតទំនិញមិនមែនយោធា។

នៅក្នុងរយៈពេល៥ឆ្នាំចន្លោះឆ្នាំ១៩៩៧-២០០១ មានការធ្លាក់ចុះជាសាកលនូវការជួញដូរអាវុធ។ មានការកាត់បន្ថយដោយសហរដ្ឋអាមេរិក ដែលជាអ្នកផ្គត់ផ្គង់ដ៏ធំបំផុត ក្នុងចន្លោះឆ្នាំ ១៩៩៧-២០០១ ក្នុងចំនួន ៦៥% ចាប់តាំងពីឆ្នាំ១៩៩៨។ ប្រទេសរុស្ស៊ីគឺជា ប្រទេសផ្គត់ផ្គង់ធំបំផុតទី២នៅក្នុងរយៈពេលនេះ។ មានការកើនឡើងចំនួន ២៤%ពីឆ្នាំ ២០០០ ដល់ ២០០១ ដែលធ្វើឲ្យប្រទេសរុស្ស៊ីក្លាយជាប្រទេសផ្គត់ផ្គង់ធំបំផុតក្នុងឆ្នាំ ២០០១ (ប្រភព SIPRI Yearbook ២០០២)។

ប្រទេសចិនជាប្រទេសទទួលអាវុធធំបំផុតក្នុងឆ្នាំ ២០០១ បន្ទាប់ពីមានការកើនឡើង ៤៤% ពីឆ្នាំ ២០០០។ ការនាំចូលដោយប្រទេសឥណ្ឌា មានការកើនឡើង ៥០% ដែលធ្វើឲ្យប្រទេសនេះក្លាយជាប្រទេសទទួលអាវុធធំបំផុតទី ៣ក្នុងឆ្នាំ ២០០១។

ប្រទេសទទួលអាវុធធំៗផ្សេងទៀតនៅក្នុងឆ្នាំ១៩៩៧-២០០១ មានប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត តៃវ៉ាន់ និងប្រទេសទួគី (SIPRI Yearbook ២០០២)។

**ប្រអប់ទី ៧៩**

## តួលេខប៉ាន់ស្មានអំពីការជួញដូរអាវុធធុនតូច

"ខណៈពេលដែលទំហំនៃការផលិតអាវុធធុនតូចកំពុងថយចុះតិចជាងការផលិត ក្នុងអំឡុងសង្គ្រាមត្រជាក់មានអាវុធរាប់លានដើមកំពុងត្រូវបានផលិតជារៀងរាល់ឆ្នាំនៅឡើយ (...)។ ផ្អែកតាមការប៉ាន់ស្មាន (...) តម្លៃនៃការផលិតអាវុធក្នុងសាកលលោករួមទាំងគ្រាប់រំសេវផងសម្រាប់ឆ្នាំ២០០០ ត្រូវបានប៉ាន់ប្រមាណថាមានតម្លៃយ៉ាងហោចណាស់៤ពាន់លានដុល្លាអាមេរិក។ ចំពោះបរិមាណវិញគេប៉ាន់ស្មានថាមានអាវុធធុនតូចថ្មីៗប្រហែល ៤.៣លានដើម ត្រូវបានផលិតក្នុងឆ្នាំ២០០០ (...) គឺធ្លាក់ចុះ ៣០% (បើប្រៀបធៀបជាមួយចំនួនប្រចាំឆ្នាំជា មធ្យមក្នុងអំឡុងសង្គ្រាមត្រជាក់)"។ "នៅពេលដែលតម្រូវការអាវុធធុនតូចថ្មីៗអាចមានការធ្លាក់ចុះ (...) ការផ្គត់ផ្គង់នៅក្នុងទីផ្សារទំនងជាមានការរីកសាយ" (...)។ ចំនួនក្រុមហ៊ុនបានកើនឡើងជាង៣ដងក្នុងរយៈពេលតិចជាងពីរទសវត្សរ៍នេះ ចាប់ពី១៩៦ក្រុមហ៊ុនក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដល់ ៦០០ក្រុមហ៊ុន មកដល់បច្ចុប្បន្ន"។ (...)វត្តមាននៃការកើនឡើងនូវក្រុមហ៊ុនថ្មីៗ និងប្រទេសដែលផលិតអាវុធធុនតូច និងអ្នកដែលមានបំណងលក់វាទៅឲ្យមនុស្សគ្រប់គ្នាគ្រប់ទីកន្លែង និងក្នុងតម្លៃណាក៏បាន នេះមានន័យថាបច្ចុប្បន្ននេះវាកាន់តែងាយស្រួលឡើងៗសម្រាប់រដ្ឋាភិបាលផ្តាច់ការ តួអង្គមិនមែនរដ្ឋ ពួកភេរវករ និងឧក្រិដ្ឋជន ក្នុងការទទួលបាននូវអាវុធដែលកាន់តែថ្មី ទំនើប និងមហាប្រល័យជាងពេលមុនៗទាំងអស់។ ដូច្នេះវាជាបញ្ហា សន្តិសុខអន្តរជាតិបន្ទាន់មួយដែលតម្រូវឲ្យមានការត្រួតពិនិត្យរបស់រដ្ឋាភិបាលទៅលើការផលិតអាវុធធុនតូច។

ប្រភព៖ អង្កេតអាវុធធុនតូចឆ្នាំ ២០០១ Oxford University Press

**ប្រអប់ទី ៨០**

## កម្មវិធីអង្គការសហប្រជាជាតិប្រឆាំង នឹងការជួញដូរអាវុធធុនតូច និងធុនស្រាលខុសច្បាប់ ៖ មន្ត្រីបង្គោលសម្រាប់តំណាងរាស្ត្រ

"ដើម្បីទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងលុបបំបាត់នូវការជួញដូរខុសច្បាប់នូវអាវុធធុនតូច និងធុនស្រាល (SALW) រដ្ឋដែលបានចូលរួមនៅក្នុងសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការជួញដូរខុសច្បាប់នូវអាវុធធុនតូច និងធុនស្រាលនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់របស់វា ( ខែកក្កដា ឆ្នាំ២០០១ ទីក្រុងញូយ៉ក)បានដាក់ចេញនូវការប្តេជ្ញាចិត្តនយោបាយជាច្រើននៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ក្នុងនោះមាន៖

### នៅថ្នាក់ជាតិ

- ▷ ក្នុងករណីមិនទាន់មានបង្កើតច្បាប់លិខិតបទដ្ឋានគតិយុត្តនីតិវិធីរដ្ឋបាលឲ្យបានគ្រប់គ្រាន់ ដើម្បីធ្វើការត្រួតពិនិត្យលើការផលិត SALW នៅក្នុងតំបន់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងត្រួតពិនិត្យការនាំចេញ ការឆ្លងកាត់ ឬការផ្ទេរនូវអាវុធប្រភេទនោះ។
- ▷ កំណត់ក្រុមនិងបុគ្គលដែលចូលរួមនៅក្នុងការផលិតដោយខុសច្បាប់ ជួញដូរ ស្តុកទុក ផ្ទេរ កាន់កាប់ក៏ដូចជាផ្តល់ហិរញ្ញវត្ថុដើម្បីទិញ SALW ខុសច្បាប់ និងចាត់វិធានការនៅក្រោមច្បាប់ជាតិប្រឆាំងនឹងក្រុម និងបុគ្គលទាំងនោះ។
- ▷ ធានាថា រោងចក្រដែលបានទទួលអាជ្ញាប័ណ្ណបិទស្លាកសម្គាល់លើ SALW នីមួយៗ នៅក្នុងដំណើរការផលិតកម្មរបស់ខ្លួន។
- ▷ ធានាថាកំណត់ហេតុគ្រប់ជ្រុងជ្រោយនិងសុក្រិតត្រូវបានរក្សាទុករយៈពេលវែងតាមដែលអាចធ្វើបាន អំពីការផលិត ការស្តុកទុក ការផ្ទេរ SALW នៅក្រោមយុត្តាធិការរបស់ខ្លួន។
- ▷ ធានានូវការទទួលខុសត្រូវចំពោះរាល់ SALW ទាំងអស់ដែលកាន់កាប់និងចេញដោយរដ្ឋ និងវិធានការប្រកបដោយប្រសិទ្ធភាពដើម្បីស៊ើបរកអាវុធបែបនោះ។
- ▷ បង្កើត និងអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីរដ្ឋបាល ដើម្បីធានានូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទៅលើការនាំចេញ និងការឆ្លងកាត់នូវ SALW រួមទាំងការប្រើប្រាស់នូវលិខិតយថាភូតសម្រាប់ទិញអាវុធយកទៅប្រើផងដែរ។
- ▷ ខិតខំប្រឹងប្រែងដោយមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋក្នុងការនាំចេញ SALW ដែលពួកគេបាននាំចូលលើកមុន ដើម្បីជូនដំណឹងដល់រដ្ឋ ដែលជាប្រភពដើមនាំចេញអាវុធដោយអនុលោមតាមកិច្ចព្រមព្រៀងទ្វេភាគីមុនផ្ទេរនូវអាវុធទាំងនោះឡើងវិញ។
- ▷ រៀបចំច្បាប់ជាតិ ឬ នីតិវិធីរដ្ឋបាលឲ្យបានគ្រប់គ្រាន់ដើម្បីគ្រប់គ្រងសកម្មភាពរបស់អ្នកដែលចូលរួមនៅក្នុងការងារជាឈ្មួញកណ្តាលលក់ SALW។

- ចាត់វិធានការដ៏សមស្រប ប្រឆាំងនឹងសកម្មភាពដែលរំលោភវិធានការរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីទណ្ឌកម្មសព្វាវុធ។
- ធានាថា SALW ដែលបានចាប់ដកហូត ឬប្រមូលបានត្រូវបានបំផ្លាញចោលទាំងអស់។
- ធានាថា កងកម្លាំងប្រដាប់អាវុធ នគរបាល និងស្ថាប័នផ្សេងទៀត ដែលមានសិទ្ធិអំណាចកាន់កាប់ SALW បង្កើតនូវបទដ្ឋាន និងនីតិវិធីលំអិត និងគ្រប់ជ្រុងជ្រោយពាក់ព័ន្ធជាមួយការគ្រប់គ្រង និងការរក្សាសន្តិសុខឃ្លាំងស្តុកអាវុធទាំងនោះ។
- រៀបចំ និងអនុវត្តតាមដែលអាចធ្វើបាននូវកម្មវិធីដកហូតអាវុធ កាត់រំសាយកងទ័ព និងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាព។
- ធ្វើការដោះស្រាយនូវតម្រូវការជាពិសេសរបស់កុមារដែលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ (...)"។

*ប្រភព៖ ផ្នែកកិច្ចការដកអាវុធអង្គការសហប្រជាជាតិ*
*គេហទំព័រ៖ http://www.un.org/Depts/dda, ឆ្នាំ២០០២*

ដោយរងផលប៉ះពាល់ ពីការរីកចម្រើនក្រោយសង្គ្រាមត្រជាក់ បញ្ហានៃតម្លាភាពនិងគណនេយ្យភាព នៃនីតិវិធីត្រួតពិនិត្យលើការនាំចេញអាវុធ បានក្លាយជាចំណុចដែលត្រូវធ្វើការពិភាក្សាដេញដោលក្តៅគគុកនៅក្នុងប្រទេសជាច្រើនអំពី ថាតើសភាអាច និងគួរធ្វើអ្វីខ្លះ។

ប្រអប់ទី៨១ បង្ហាញនូវឧទាហរណ៍នៃវិធានការដែលរដ្ឋជាសមាជិក នៃសហភាពអឺរ៉ុបបានប្រកាន់យក។ ការយល់ដឹងកាន់តែច្រើនឡើងអំពីសារៈសំខាន់នៃតម្លាភាព និងគណនេយ្យភាពបាននាំទៅរកការកែលំអជាដុំកំភួន នៅក្នុងការត្រួតពិនិត្យរបស់សភាទៅលើការនាំចេញអាវុធនៅក្នុងរដ្ឋទាំងនោះ ក៏ប៉ុន្តែវានៅឆ្ងាយពីភាពល្អឥតខ្ចោះនៅឡើយនៅក្នុងប្រទេសជាច្រើន។

**ប្រអប់ទី ៨១**

**តួនាទីរបស់សភានៅក្នុងការត្រួតពិនិត្យការនាំចេញអាវុធ៖ តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេសសហភាពអឺរ៉ុប**

ប្រទេសអូទ្រីស៖ មិនមានបទបញ្ញត្តិនៅក្រោមច្បាប់ប្រទេសអូទ្រីស ទាក់ទងនឹងការទម្លាយព័ត៌មានដល់តំណាងរាស្ត្រនោះទេ។

ប្រទេសបែលហ្ស៊ិក៖ មានច្បាប់មួយ ដែលបានអនុម័តក្នុងឆ្នាំ១៩៩១ បានចងកាតព្វកិច្ចឲ្យរដ្ឋាភិបាលរាយការណ៍ទៅសភាអំពីការផ្ទេរអាវុធជារៀងរាល់ឆ្នាំ។ ច្បាប់មិនបានចែងអំពីការត្រួតពិនិត្យទៅលើអ្នកដែលបានទទួលអាជ្ញាប័ណ្ណ ដើម្បីនាំចេញអាវុធ ហើយនាំចេញទៅឲ្យអ្នកណា

ឬប្រទេសមួយណានោះទេ។ នេះគឺជាកត្តាគន្លឹះ ដោយសារតែការនាំចេញមិនត្រូវបំពានលើក្រមប្រតិបត្តិរបស់សហភាពអឺរ៉ុបឡើយ។

**ប្រទេសដាណឺម៉ាក ៖** មិនមានបទបញ្ញត្តិចែងអំពីការពិភាក្សាដេញដោល ដោយសភាអំពីការនាំចេញអាវុធ ឬក៏មានលិខិតូបករណ៍ស្របច្បាប់សម្រាប់ការត្រួតពិនិត្យលើបញ្ហានេះ តាមបែបប្រជាធិបតេយ្យនោះទេ។ ទោះដូច្នេះក៏ដោយ បន្ទាប់ពីមានសម្ពាធជាសាធារណៈខ្លាំងឡើងៗ រដ្ឋមន្ត្រីយុត្តិធម៌កំពុងព្យាយាមបញ្ចេញនូវរបាយការណ៍បឋម អំពីការនាំចេញអាវុធ ដែលនឹងបញ្ចូលការត្រួតពិនិត្យការនាំចេញ តម្លៃនៃការនាំចេញ និងប្រទេសជាគោលដៅនៃការនាំចេញ។

**ប្រទេសហ្វាំងឡង់ ៖** មកដល់ពេលនេះ ក្រសួងការជាតិបានចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំចំនួន២ អំពីការនាំចេញឧបករណ៍សម្ភារៈការពារជាតិ អនុលោមតាមក្រមប្រតិបត្តិរបស់សហភាពអឺរ៉ុប។ របាយការណ៍មានលក្ខណៈគ្រប់ជ្រុងជ្រោយដូច្នេះវាពង្រឹងតម្លាភាព។ ទោះដូច្នេះក៏ដោយក៏នៅមានកង្វះការពិភាក្សាដេញដោលដោយសភា ជាទៀងទាត់អំពីការផ្ទេរអាវុធនេះផងដែរ។

**ប្រទេសបារាំង ៖** សភាបារាំងបានទាមទារយ៉ាងខ្លាំងក្លាឲ្យរដ្ឋាភិបាលបញ្ជាក់ និងផ្តល់នូវរបាយការណ៍ប្រចាំឆ្នាំលំអិត ដូចជា ព័ត៌មានអំពី អាវុធធុនតូច នគរបាល ឧបករណ៍សន្តិសុខ និងកិច្ចសហប្រតិបត្តិការយោធាទាំងអស់។ លើសពីនេះ វាគួរតែមានការពិភាក្សាដេញដោលច្រើនថែមទៀត អំពីរបាយការណ៍នៅក្នុងសភា។

**ប្រទេសអាល្លឺម៉ង់ ៖** របាយការណ៍ដំបូងអំពីការនាំចេញអាវុធត្រូវបានចេញផ្សាយក្នុងឆ្នាំ២០០០។ គេរំពឹងថា គណៈកម្មការសភាដែលពាក់ព័ន្ធ នឹងធ្វើការសិក្សាអំពីរបាយការណ៍បន្ទាប់៖ របាយការណ៍អំពី ការពាជាតិ កិច្ចការបរទេស ពាណិជ្ជកម្ម និងអាចមានសិទ្ធិមនុស្ស។ តួនាទីរបស់សភាត្រូវបានរឹតត្បិតចំពោះការត្រួតពិនិត្យទៅលើអ្វីដែល រដ្ឋាភិបាលបាននាំចេញក្នុងអតីតកាល។

**ប្រទេសក្រិក ៖** មិនមានយន្តការរាយការណ៍ ដែលផ្តល់ដល់សភា និង សាធារណជនអំពីព័ត៌មានពាក់ព័ន្ធជាមួយការអនុញ្ញាតិឲ្យនាំចេញនូវអាវុធនោះទេ។ មានព័ត៌មានផ្លូវការតែមួយគត់ដែលបានផ្តល់ដោយផ្នែកចុះបញ្ជីអាវុធរបស់អង្គការសហប្រជាជាតិ។

**ប្រទេសអៀឡង់ ៖** មានបទបញ្ញត្តិនៅក្រោមច្បាប់នៃប្រទេសអៀឡង់ ដែលចងកាតព្វកិច្ចលើរដ្ឋាភិបាលឲ្យចេញផ្សាយនូវរបាយការណ៍អំពី ការនាំចេញទាក់ទងនឹងអាវុធ។ ទោះដូច្នេះក៏ដោយអនុលោមតាមក្រមប្រតិបត្តិរបស់សហភាពអឺរ៉ុប ក្រសួងការបរទេសរហូតមកដល់ឆ្នាំ២០០២ បានចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំចំនួន២។ កំពុងមានការអនុវត្តនូវទម្លាប់មួយនៅក្នុងសភាដើម្បីឲ្យតំណាងរាស្ត្រដាក់សំណួរទៅរដ្ឋមន្ត្រីពាក់ព័ន្ធអំពីអាជ្ញាប័ណ្ណនាំចេញ។

**ប្រទេសអ៊ីតាលី ៖** រដ្ឋាភិបាលត្រូវរាយការណ៍ទៅសភាអំពីការអនុញ្ញាត និងការដឹកជញ្ជូនពាក់ព័ន្ធជាមួយការនាំចេញ នាំចូល និងការឆ្លងកាត់នូវសម្ភារៈការពារជាតិ។ ចំណុចទាំងនេះមានចែងនៅក្នុងច្បាប់ឆ្នាំ១៩៩០ ដែលតម្រូវឲ្យមានរបាយការណ៍លំអិតផង។ ទោះដូច្នេះក្តី ក៏សភាមិនមានតួនាទីជាផ្លូវការនៅក្នុងការត្រួតពិនិត្យលើការនាំចេញនោះដែរ។

**ប្រទេសលុចហ្សំប៊ួរ ៖** មិនមានឧស្សាហកម្មអាវុធលេចធ្លោ និងក៏មិនមាននូវប្រព័ន្ធគណនេយ្យភាពផងដែរ។

**ប្រទេសហូឡង់ ៖** មានរបាយការណ៍គ្រប់ជ្រុងជ្រោយដំបូង ១ អំពីការនាំចេញអាវុធ ត្រូវបានចេញផ្សាយក្នុងខែតុលា ឆ្នាំ១៩៩៨។ មានការជូនដំណឹងក្រៅផ្លូវការ មុនសភាធ្វើការត្រួតពិនិត្យទៅលើប្រព័ន្ធនាំចេញអាវុធរបស់ប្រទេសហូឡង់៖ ផ្នែកចារកម្មរបស់រដ្ឋាភិបាលបានជម្រាបគណៈកម្មការការពារជាតិសភា អំពីរាល់ការលក់អាវុធដែលលើសទាំងអស់។

**ប្រទេសព័រទុយហ្កាល់៖** មុនមានរបាយការណ៍ដែលបានចេញផ្សាយក្នុងឆ្នាំ១៩៩៨ មិនមានបទបញ្ញត្តិសម្រាប់ឲ្យសភាធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេចចេញអាជ្ញាប័ណ្ណនាំអាវុធចេញនោះទេ ហើយក៏មិនមានបទបញ្ញតិសម្រាប់សភាធ្វើការពិភាក្សានោះដែរ។ តំណាងរាស្ត្រអាចសួរសំណួរអំពីការចេញអាជ្ញាប័ណ្ណនាំចេញអាវុធក្នុងអតីតកាលបាន។

**ប្រទេសអេស្ប៉ាញ៖** មានរបាយការណ៍មួយចេញផ្សាយចាប់តាំងពីឆ្នាំ១៩៩៨មក។ មិនមានការត្រួតពិនិត្យលើការនាំចេញអាវុធជាមុននោះទេ។ មានតែគណៈកម្មការព័ត៌មានចារកម្មផ្លូវការរបស់សភាប៉ុណ្ណោះដែលបានចូលរួម។ ការពិភាក្សាដេញដោលដោយសភាកំពុងកើនឡើង។

**ប្រទេសស៊ុយអែត ៖** របាយការណ៍ដំបូងបានចេញផ្សាយក្នុងឆ្នាំ១៩៨៥ គឺនៅក្នុងឆ្នាំដែលសភាបានបង្កើតនូវក្រុមប្រឹក្សាផ្តល់យោបល់អំពីការនាំចេញឧបករណ៍យោធា ហើយនេះគឺជាគំរូមួយសម្រាប់ប្រទេសនៅអឺរ៉ុបផ្សេងទៀត។ សភាធ្វើការពិភាក្សាលើរបាយការណ៍ជារៀងរាល់ឆ្នាំ។

**ចក្រភពអង់គ្លេស ៖** ប្រព័ន្ធរាយការណ៍របស់អង់គ្លេសមានតម្លាភាពបំផុត។ ចាប់តាំងពីមានរបាយការណ៍លើកទី១ ចេញផ្សាយក្នុងឆ្នាំ១៩៩៩មក គណៈកម្មការចម្រុះមួយ ត្រូវបានបង្កើតដោយរដ្ឋមន្ត្រីការពារជាតិ រដ្ឋមន្ត្រីការបរទេស រដ្ឋមន្ត្រីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ។ គណៈកម្មការចម្រុះនេះ រាយការណ៍ជូនសភាជាន់ទាប និងមានសិទ្ធិអំណាចត្រួតពិនិត្យការនាំចេញ។

*ប្រភព៖ www.saferworld.co.uk, ឆ្នាំ២០០២*

## ជំនាញរបស់សភា

ដូចបានលើកខាងដើម ជំនាញរបស់សភាគឺជាកត្តាដ៏សំខាន់ដើម្បីធានាថា សភាអាចធ្វើការតាមដានគ្រប់ជ្រុងជ្រោយទៅលើដំណើរការនៃការជួញដូរនិងការផ្ទេរអាវុធ។ កង្វះនូវជំនាញវិជ្ជាជីវៈអាចជាមូលហេតុធំៗជាច្រើន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធជាមួយព័ត៌មានសម្ងាត់។ ការបណ្តុះបណ្តាលសមាជិកសភា ជាពិសេសអ្នកដែលជាសមាជិកនៃគណៈកម្មការមានសមត្ថកិច្ចសភា គឺជាការចាំបាច់ខ្លាំងណាស់។ ដូចគ្នានេះផងដែរ គេត្រូវផ្តល់នូវការបណ្តុះបណ្តាលដល់បុគ្គលិកសភានូវជំនាញនានា ដូចជាជំនាញខាងការជួញដូរអាវុធ លទ្ធកម្មអាវុធ ជំនាញផ្នែកស្រាវជ្រាវ ការគ្រប់គ្រងឯកសារ ការគណនាតម្លៃនិងការត្រួតពិនិត្យបញ្ជីសារពើភ័ណ្ឌទាំងអស់នេះវាជួយបង្កើតនូវក្រុបខណ្ឌមួយនៃអ្នកជំនាញ ដែលមានសមត្ថភាពក្នុងការឆ្លើយតបចំពោះសំណួរទាំងឡាយរបស់គណៈកម្មការការពារជាតិសភា។ លើសពីនេះ ការបង្កើតនូវធនាគារទិន្នន័យព័ត៌មានអំពីទិដ្ឋភាពផ្សេងៗនៃការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធជាមួយវិស័យសន្តិសុខ នឹងអាចជួយដល់គណៈកម្មការការពារជាតិសភា ក្នុងការស្នើសុំនូវព័ត៌មានពីអង្គការនីតិប្រតិបត្តិ និងពីយោធាដើម្បីខ្លួនធ្វើការពិនិត្យ និងពិនិត្យមើលនូវសេចក្តីសម្រេចចិត្តនានា។

### ក្នុងនាមជាតំណាងរាស្ត្រអ្នកអាចធ្វើអ្វីបានខ្លះ

#### ការត្រួតពិនិត្យការជួញដូរអាវុធ

- ជម្រុញឲ្យមានការបញ្ចូលការត្រួតពិនិត្យលើការជួញដូរអាវុធ ជាអន្តរជាតិនៅក្នុងរបៀបវារៈសភា។
- ជម្រុញឲ្យមានការអនុវត្តអនុសាសន៍ ដែលមាននៅក្នុងប្រអប់ទី៨០ ដែលមានចំណងជើងថា "កម្មវិធីអង្គការសហប្រជាជាតិ ប្រឆាំងនឹងការជួញដូរខុសច្បាប់អាវុធធុនតូច និងធុនស្រាលខុសច្បាប់៖ មន្ត្រីបង្គោលសម្រាប់សមាជិកសភា"។
- លើកទឹកចិត្តរដ្ឋរបស់អ្នកឲ្យអនុវត្តជាទៀងទាត់តាម៖
  - លក្ខខណ្ឌទាក់ទងនឹងការរាយការណ៍ អំពីអាវុធដែលមាននៅក្នុងបញ្ជីអាវុធរបស់អង្គការសហប្រជាជាតិ។
  - លិខិតូបករណ៍អង្គការសហប្រជាជាតិទាក់ទងនឹងការរាយការណ៍អំពីការចំណាយយោធា។
  - សន្ធិសញ្ញាតំបន់ដែលពាក់ព័ន្ធជាមួយអាវុធ។

## គោលនយោបាយជាតិស្តីពីការជួញដូរអាវុធ

▷ ធានាឲ្យមានការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិ ស្តីពីការលក់អាវុធ និងត្រូវដឹងថា តើគោលនយោបាយនេះបានដាក់ជូនសភាសុំការអនុម័តយល់ព្រមដែរឬយ៉ាងណា។

▷ ត្រូវធានាថា មានយន្តការមួយដើម្បីចងកាតព្វកិច្ចលើរដ្ឋាភិបាលឲ្យដាក់របាយការណ៍ជូនសភាពាក់ព័ន្ធជាមួយការជួញដូរអាវុធ។

## ការដាក់ទណ្ឌកម្មអាវុធ

▷ ធានាថា បញ្ហាទាក់ទងនឹងការដាក់ទណ្ឌកម្មអាវុធ ត្រូវបានលើកយកមកពិភាក្សានៅក្នុងសភា ទាក់ទងនឹងភាពសមស្របនៃការដាក់ទណ្ឌកម្ម ប្រភេទនៃទណ្ឌកម្ម និងផលប៉ះពាល់នៃទណ្ឌកម្មទាំងនោះ។

▷ ជម្រុញឲ្យមានការពិភាក្សាអំពី "ការដាក់ទណ្ឌកម្មតាមលក្ខណៈវៃឆ្លាត" នៅក្នុងសភា ជាពិសេសចំណុចដែលមាននៅក្នុងប្រអប់ទី ៧៧។

▷ ជម្រុញឲ្យរដ្ឋាភិបាលរបស់អ្នក គោរពតាមការដាក់ទណ្ឌកម្មអាវុធ និងធានាឲ្យមានការផ្តល់យុត្តិធម៌ និងការដាក់ទោសក្នុងករណីមានការរំលោភលើការដាក់ទណ្ឌកម្មអាវុធ។

## អាវុធដែលលើស

▷ ជម្រុញឲ្យសភា ឬគណៈកម្មការមានសមត្ថកិច្ចរបស់សភា រួមទាំងគណៈកម្មការពន្ធគយឲ្យយកចិត្តទុកដាក់ចំពោះអាវុធលើស និងចាត់វិធានការដើម្បីទប់ស្កាត់ និងត្រួតពិនិត្យ៖
- រាល់ការផ្ទេរអាវុធលើសពីឬឆ្លងកាត់ប្រទេសរបស់អ្នក។
- រាល់លទ្ធកម្មអាវុធលើសទាំងអស់។

▷ ជម្រុញរដ្ឋរបស់អ្នកឲ្យរួមវិភាគទានដល់បញ្ជីសារពើភ័ណ្ឌ ស្តីពីអាវុធដែលលើស និងឲ្យមានការបំផ្លាញចោលនូវអាវុធទាំងនោះ។

▷ ជម្រុញរដ្ឋរបស់អ្នកឲ្យចាត់វិធានការបន្ថែមទៀត ដើម្បីកំណត់នូវក្រុមហ៊ុនដែលពាក់ព័ន្ធនៅក្នុងការផ្ទេរនូវអាវុធដែលលើស និងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ពួកគេ។

## អាវុធធុនតូច

▷ ធានាថាសភា ឬគណៈកម្មការដែលពាក់ព័ន្ធរបស់សភា ទទួលបាននូវព័ត៌មានលំអិតក្នុងឆ្នាំនីមួយៗ ស្តីពីការផលិតក្នុងស្រុកនិងការលក់អាវុធធុនតូច។ ទាមទារឲ្យមានការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ ដោយមានបញ្ចូលនូវព័ត៌មានលំអិត អំពីសកម្មភាពរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធទាំងនោះ។

▷ ត្រូវដឹងថា ការលក់អាវុធធុនតូចដែលផលិតនៅក្នុងស្រុក ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតឹងរ៉ឹងដូចបានបញ្ជាក់នៅក្នុងជំពូកនេះ។

# តើ IPU ជាអ្វី?

ដោយត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ១៨៨៩ IPU គឺជាអង្គការសភាអន្តរជាតិរបស់រដ្ឋមាន អធិបតេយ្យភាព។ ឋានៈជាអ្នកសង្កេតការថ្មីរបស់ IPU នៅក្នុងអង្គការសហប្រជាជាតិ បានធ្វើឲ្យ IPU អាចនាំសភាចូលទៅក្នុងឆាកអន្តរជាតិ និងធ្វើឲ្យសម្លេងរបស់អ្នកជាប់ឆ្នោត ដែលជាតំណាង របស់ប្រជាពលរដ្ឋ ត្រូវបានគេស្តាប់ឮនៅក្នុងវេទិកា កិច្ចពិភាក្សាជាអន្តរជាតិ។

មកដល់ខែមករា ឆ្នាំ២០០៣ មានសភាចំនួន ១៤៤សភា បានចូលជាសមាជិក IPU។ ក្នុងនាម ជាជនបង្គោលសម្រាប់ការពិភាក្សា និងចំណាត់ការដោយសភា IPU ប្រមូលផ្តុំសភាដើម្បីៈ

- ▷ ធ្វើការពិចារណាអំពីសំណួរទាំងឡាយដែលជាកង្វល់និងជាការចាប់អារម្មណ៍របស់អន្តរជាតិ។
- ▷ រួមចំណែកដល់ការការពារ និងលើកកម្ពស់សិទ្ធមនុស្សរបស់តំណាងរាស្ត្រ។
- ▷ ជួយពង្រឹងស្ថាប័នតំណាងប្រជាពលរដ្ឋនៅជុំវិញពិភពលោក។

បញ្ហាសន្តិភាព និងសន្តិសុខ ជានិច្ចជាកាលត្រូវបានលើកយកមកពិភាក្សាកម្រិតខ្ពស់ នៅក្នុង របៀបវារៈរបស់ IPU។ ភាគច្រើនសមាជិករបស់ IPU បានចាត់វិធានការទាក់ទងនឹងបញ្ហាសន្តិសុខ នានា ដូចជា ការដកហូតអាវុធ ការដាក់ទណ្ឌកម្មអាវុធជាអន្តរជាតិ តុលាការ ព្រហ្មទណ្ឌអន្តរជាតិ និងអំពើភេរវកម្ម។ នៅក្នុងឆ្នាំ១៩៩៤ IPU បានបង្កើតនូវគណៈកម្មការពិសេសមួយដើម្បីលើក កម្ពស់ការគោរពច្បាប់មនុស្សធម៌អន្តរជាតិ។ ដោយសហការណ៍ជាមួយ គណៈកម្មការកាកបាទ ក្រហមអន្តរជាតិ គណៈកម្មការនេះ បានចេញផ្សាយនូវសៀវភៅមួយក្នុងឆ្នាំ១៩៩៩ សម្រាប់តំណាង រាស្ត្រស្តីពី ការគោរពច្បាប់មនុស្សធម៌អន្តរជាតិ។

IPU ក៏ចង់ជួយបន្ធូរនូវភាពតានតឹង តាមរយៈការចរចានយោបាយ។ IPU រៀបចំកិច្ចប្រជុំ ដើម្បីផ្តល់ឱកាសឲ្យមានកិច្ចសន្ទនាដើម្បីបន្ធូរភាពតានតឹង និងបង្កើតនូវទំនុកចិត្ត។ IPU ក៏មាន គណៈកម្មការសភាមួយ ដើម្បីជួយពន្លឿនការដោះស្រាយវិបត្តិនៅមជ្ឈិមបូព៌ា និងមានក្រុមសម្រប សម្រួលមួយក្រុម ដើម្បីជម្រុញនូវកិច្ចសន្ទនា រវាងតំណាងរបស់គណបក្សនយោបាយបច្ចុប្បន្ននៅ ក្នុងផ្នែកទាំងពីរនៃ Cyprus។ IPU ក៏មានយន្តការពិសេសមួយផងដែរ សម្រាប់លើកកម្ពស់វិស័យ សន្តិសុខ និងសហប្រតិបត្តិការក្នុងវិស័យសន្តិសុខនៅក្នុងតំបន់មេឌីទែរ៉ាណេ។

**IPU Headquarters**
Inter-Parliamentary Union
Chemin du Pommier 5
Case Postale 330
CH-1218 Grand Saconnex, Geneva
Switzerland
Tel: 41 22 919 41 50
Fax: 41 22 919 41 60
e-mail: postbox@mail.ipu.org
Website: www.ipu.org

**Office of the Permanent Observer of the IPU to the UN**
Inter-Parliamentary Union
220 East 42nd Street
Suite 3102
New York, N.Y. 10017
USA
Tel. (212) 557 58 80
Fax (212) 557 39 54
e-mail: ny-office@mail.ipu.org

# មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធ តាមបែបប្រជាធិបតេយ្យ (DCAF)

ទោះបីជាមានវឌ្ឍនៈភាពក្នុងរយៈពេលមួយទសវត្សរ៍នេះក៏ដោយ ក៏ការកែទម្រង់ និងការគ្រប់គ្រងទំនាក់ទំនងរវាងស៊ីវិល-យោធាតាមបែបប្រជាធិបតេយ្យ នៅតែជាការប្រឈមដ៏ធំចំពោះរដ្ឋភាគីច្រើនដដែល។ នេះជាការពិត ជាពិសេសចំពោះប្រទេសដែលស្ថិតនៅក្នុងអន្តរកាលឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ប្រទេសដែលត្រូវបានខ្ទេចខ្ទាំដោយសង្គ្រាម និងប្រទេសក្រោយជម្លោះបានបញ្ចប់។ កងកម្លាំងប្រដាប់អាវុធ និងកងកម្លាំងពាក់កណ្តាលយោធា ក៏ដូចជា នគរបាល ឆ្មាំព្រំដែន និងរចនាសម្ព័ន្ធ ពាក់ព័ន្ធនឹងវិស័យសន្តិសុខដទៃទៀត នៅតែជាតួអង្គដ៏សំខាន់នៅក្នុងប្រទេសភាគច្រើន។ ជាញឹកញាប់ពួកគេដើរតួជា "រដ្ឋក្នុងរដ្ឋ" ដោយដាក់បន្ទុកទៅលើធនធានដ៏ខ្សត់ខ្សោយ រាំងស្ទះដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម និងបង្កើននូវជម្លោះផ្ទៃក្នុង ឬជម្លោះជាអន្តរជាតិ។ ដូច្នេះ មានការទទួលស្គាល់ដ៏ទូលំទូលាយថា ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដែលមានប្រជាពលរដ្ឋចូលរួមទៅលើរចនាសម្ព័ន្ធកងកម្លាំងប្រដាប់អាវុធ គឺជាឧបករណ៍ដ៏សំខាន់មួយក្នុងការទប់ស្កាត់នូវជម្លោះ លើកកម្ពស់សន្តិភាព និងលទ្ធិប្រជាធិបតេយ្យ និងធានានូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព។

ការពង្រឹងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដែលមានពលរដ្ឋចូលរួមទៅលើរចនាសម្ព័ន្ធកងកម្លាំងប្រដាប់អាវុធ បានក្លាយជាបញ្ហាគោលនយោបាយដ៏សំខាន់មួយ នៅលើរបៀបវារៈរបស់សហគមន៍អន្តរជាតិ។ នៅខែតុលា ឆ្នាំ២០០០ ដើម្បីរួមចំណែកជាក់ស្តែងដល់និន្នាការទូទៅ និងដែលមានលក្ខណៈវិជ្ជមាននេះ រដ្ឋាភិបាលនៃប្រទេសស្វីសបានបង្កើតនូវមជ្ឈមណ្ឌលសម្រាប់គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (DCAF) តាមគំនិតផ្តួចផ្តើមរួមមួយរបស់ក្រសួងសហព័ន្ធទទួលបន្ទុកការពារជាតិការពារប្រជាពលរដ្ឋ ស៊ីវិល និងកីឡា និងក្រសួងការបរទេសសហព័ន្ធ។

## បេសកកម្ម

មជ្ឈមណ្ឌលលើកទឹកចិត្ត និងគាំទ្ររដ្ឋ និងស្ថាប័នមិនមែនរដ្ឋនៅក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេ ក្នុងការពង្រឹងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដែលមានប្រជាពលរដ្ឋចូលរួមទៅលើកងកម្លាំងប្រដាប់អាវុធ និងកងសន្តិសុខ និងលើកកម្ពស់សហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យនេះដោយជាបឋមផ្តោតលើតំបន់អឺរ៉ុប-អាត្លង់ទិកជាមុនសិន។

ដើម្បីអនុវត្តនូវគោលបំណងទាំងនេះ មជ្ឈមណ្ឌលៈ

- **ត្រូវប្រមូលព័ត៌មានធ្វើការសិក្សាស្រាវជ្រាវនិងធ្វើសកម្មភាពជាបណ្តាញ** ដើម្បីកំណត់នូវបញ្ហាបង្កើតនូវមេរៀនដែលបានរៀនសូត្រ និង ចងក្រងនូវការអនុវត្តល្អៗនៅក្នុងវិស័យនៃការគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ និង ទំនាក់ទំនងរវាងប្រជាពលរដ្ឋ- យោធា។
- **ផ្តល់នូវជំនាញនិងការគាំទ្ររបស់ខ្លួន** ចំពោះភាគីដែលមានការចាប់អារម្មណ៍ទាំងអស់ជាពិសេស រដ្ឋាភិបាល សភា អាជ្ញាធរយោធា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានសិក្សាស្រាវជ្រាវជាដើម។

DCAF សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកជំនាញ។ នៅក្នុងការងារប្រតិបត្តិ និងវិភាគរបស់ខ្លួន DCA ពឹងផ្អែកលើការជួយគាំទ្រពីរដ្ឋាភិបាលចំនួន៤២ប្រទេស ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សាមូលនិធិរបស់ខ្លួន និងពឹងផ្អែកលើក្រុមប្រឹក្សាភិបាលអន្តរជាតិដែលមានអ្នកជំនាញល្បីៗជាង៥០រូប និងពឹងផ្អែកលើវិទ្យាស្ថាន Think Tank និងក្រុមការងាររបស់ខ្លួន។ មជ្ឈមណ្ឌលបានបង្កើតភាពជាដៃគូ ឬបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវមួយចំនួន និងជាមួយអង្គការអន្តរជាតិខ្លះ រួមទាំងជាមួយអន្តរសភាផ្សេងទៀតផងដែរ។

## កម្មវិធីការងារ

ដើម្បីអាចសិក្សាលើប្រធានបទដ៏ជាក់លាក់ ទាក់ទងនឹងការគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ DCAF បានបង្កើត ឬកំពុងតែបង្កើតនូវក្រុមការងារចំនួន១២ក្រុម ដែលធ្វើការសិក្សាលើបញ្ហាដូចជា៖ កំណែទម្រង់វិស័យសន្តិសុខការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ ការកសាងតម្លាភាពនៅក្នុងការធ្វើថវិកា និងលទ្ធកម្មការពារជាតិ និងមានការជួយពីអ្នកជំនាញខាងកិច្ចការស៊ីវិលផ្នែកគោលនយោបាយសន្តិសុខជាតិ ការត្រួតពិនិត្យលើកងកម្លាំងនគរបាល និងកងកម្លាំងសន្តិសុខមិនមែនយោធា ទំនាក់ទំនងរវាងស៊ីវិល-យោធា នៅក្នុងស្ថានភាពក្រោយជម្លោះ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ភាពជោគជ័យ ឬបរាជ័យនៅក្នុងការគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ ទំនាក់ទំនងរវាងស៊ីវិល-យោធា នៅក្នុងបរិបទនៃប្រទេសនៅអាហ្វ្រិក ការធ្វើផែនការ ការគ្រប់គ្រង និងការសម្របសម្រួលក្រុមការងារដោយវិទ្យាស្ថាន Think Tank របស់មជ្ឈមណ្ឌល។

ក្រសួងសហព័ន្ធនៃប្រទេសស្វីសទទួលបន្ទុកកិច្ចការពារជាតិ ការពារពលរដ្ឋ និង កីឡា ជាអ្នកផ្តល់ថវិកាដល់ DCAF ដែលមានចំនួន៨លានហ្វ្រង់ប្រាក់ស្វីសក្នុងឆ្នាំ២០០២។ អ្នករួមវិភាគទានដ៏ធំមួយទៀត គឺក្រសួងសហព័ន្ធការបរទេសនៃប្រទេសស្វីស ហើយក៏មានរដ្ឋជាសមាជិកខ្លះនៃមូលនិធិ DCAF បានគាំទ្រ DCAF ដោយផ្តល់បុគ្គលិកបន្ថែម ឬរួមចំណែកនៅក្នុងសកម្មភាពជាក់លាក់ខ្លះរបស់មជ្ឈមណ្ឌល។

## អាស័យដ្ឋានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ (DCAF)៖ Rue de Chantepoulet 11, P.O.Box 1360, CH-1211 Geneva 1, Switzerland
Tel: +41 (22) 741-7700; Fax: +41 (22) 741-7705; Email: info@dcaf.ch; Website: www.dcaf.ch.

អាល់បានី អាមេរិក អូទ្រីស អាហ្សែបៃហ្សង់ បែលឡារុស បូសនី ហឺហ្សីកូវីណា កូដឌីវ័រ ក្រូអាត សាធារណៈ[1]រដ្ឋឆែក ដាណឺម៉ាក អេស្តូនៀ ហ្វាំងឡង់ បារាំង ចចចា អាល្លឺម៉ង់ ក្រិក ហុងគ្រី អៀរឡង់ អ៊ីតាលី ឡាតវី លីថូនៀ ម៉ូលដូវ៉ា ហុល្លង់ នីហ្សេរីយ៉ា ន័រវេ៉ ប៉ូឡូញ ព័រទុយហ្គាល់ រ៉ូម៉ានី សហព័ន្ធរុស្ស៊ី ស៊ឺប និងម៉ុងតេណេហ្គ្រ សាធារណៈរដ្ឋស្លូវ៉ាគី ស្លូវ៉ានី អាហ្វ្រិក ខាងត្បូង អេស្ប៉ាញ ស៊ុយអែត ស្វីស អតីតសាធារណៈរដ្ឋយូហ្គោស្លាវីនៃម៉ាសេដូនី អ៊ុយក្រែន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និង Canton of Geneva។

# Thematic Index


Accountability (see also *oversight)*

Internal accountability

Political accountability

African Union

Agreements (international)

Aliens

Alternative service: see *conscientious objectors*

Armament

Armed Forces: see *military*

Arms trade/transfer

Arms embargo: see *sanctions*

Association of South East Asian Nations

Auditing

Audit office

Best practices

Border control

Budget

Budgeting systems (PPBS)

Catastrophes/Crises

Civic education

Civil-Military Relations

Civil rights

Civil society

Code of conduct

For politico-military aspects of security (OSCE)

For law enforcement officials (UN)

For arms transfer (EU)

Collective security

Committee

Community policing

Confidentiality: see *secrecy*

Conflict

Conscientious objectors/objection

Commonwealth of Independent States

Cooperation

Corruption

Council of Europe

Courts

Customary Law

Cyber-crime

Decision-making

Defence

Defence budget

Defence reform

Democracy

Democratic values

Democratic control: see *oversight*

Democratisation (of military)

Deployment abroad

Detention Centres

Disarmament

Disaster relief

Disobedience

Eavesdropping

Emergency: see *exceptional circumstances*

European Union

Exceptional circumstances

Executive: see *government*

Expenditure (military)

Expertise

Freedom of information legislation

Gender: see *women*

Government

Governance

democratic governance

effective governance

good governance

Conscription

Constitution/constitutional framework

Human rights

Human security

Humanitarian law

Humanitarian missions

Information warfare: see *Cyber-crime*

Innere Führung (leadership)

Intelligence services (see also *secrecy)*

Inter-Parliamentary Union

International Organisations (*see also under the organisation's name)*

International peace missions: see *peace missions*

International regulations

International law

Internal security

Internationalisation (of the military)

Internet

Judiciary

Law enforcement

Legitimacy

Media

Military

Military Unions: see *representative associations*

Monitor/monitoring

Nation

Non-Governmental Organisation

North Atlantic Treaty Organisation

Ombudsman

Opposition

Organisation of African Unity (*see also African Union)*

Organisation for Security and Cooperation in Europe

Other state militarised organisations

Oversight

Grassroots initiatives

Harassment (of conscripts)

Hearings

Parliamentary Assembly of the Council of Europe

Paramilitary units: *see other state militarised organisations*

Parliamentary

Debate

Hearings

Inquiry

Questions

Powers

Resources

Staff

Parliamentary Committees

Defence committee

Intelligence committee

Security committee

Peace-building

Peace-enforcement

Peacekeeping: see *peace missions*

Peacemaking

Peace missions

Pensions

Police

Principles

Prisons: see *detention centres*

Private security actors

Procurement

Reform

- Defence reform
- Police reform
- Security sector reform

Retirement: see *pensions*

Representative associations

Rules of engagement

Democratic oversight
Parliamentary oversight
Parliamentary Assemblies
NATO – Parliamentary Assembly
September 11
Servicemen / -women
Small arms
Society: see *civil society*
State of emergency/siege: see *exceptional circumstances*
Terrorism (see also *internal security)*
Definition of terrorism
Policy
Measures
Legislation
Torture
Transparency
Treaties: see *agreements*
Troops: see *military*
United Nations
Value-for-money
Women
War
Western European Union
World Wide Web, see Internet
World Bank
Salaries (of servicemen)
Sanctions
Secrecy (see also *intelligence services)*
Security
Security Council
Security policy

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានផ្នែកណាមួយនៃសៀវភៅគោលនេះអាចត្រូវបានផលិត រក្សាទុក នៅក្នុងប្រព័ន្ធដែលអាចបើកមើលបាន ឬត្រូវបានបញ្ជូនទោះក្នុងទម្រង់អ្វីក៏ដោយ ឬទោះជាតាមមធ្យោបាយអ្វីមួយក៏ដោយ ដូចជាមធ្យោបាយអេឡិកត្រូនិក មេកានិក ថតចម្លង ថតទុកដោយមិនមានការអនុញ្ញាតជាមុនពី សហភាពអន្តរសភា ឬពី មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ។

សៀវភៅគោលនេះ ត្រូវបានផ្សព្វផ្សាយដោយអនុលោមតាមលក្ខខណ្ឌថា សៀវភៅនេះមិនត្រូវបានជួញដូរ ឲ្យខ្ចី លក់ ជួល ឬធ្វើការផ្សព្វផ្សាយដោយមិនមានការយល់ព្រមជាមុនពីម្ចាស់សៀវភៅ នៅក្នុងទម្រង់កិបជាសៀវភៅ ឬមានក្របដែលខុសពីទម្រង់សៀវភៅដែលបានបោះពុម្ព៕

---

ISBN (IPU)

ISBN (DCAF)

**ការត្រួតពិនិត្យដោយសភាលើវិស័យសន្តិសុខៈ គោលការណ៍ យន្តការ និង ការអនុវត្ត**

**បោះពុម្ពផ្សាយដោយៈ**
**សហភាពអន្តរសភា**
**មជ្ឈមណ្ឌលហ្សឺណែវសម្រាប់ការត្រួតពិនិត្យ**
**កងកម្លាំងប្រដាប់អាវុធតាមបែបប្រជាធិបតេយ្យ**

**អ្នកកែសម្រួល**
Philipp Fluri, **ប្រទេសស្វីស**
Anders B. Johnsson, **ប្រទេសហូល្លង់**

**អ្នកដឹកនាំនិពន្ធ**
Hans Born,
**ម្ចាស់បោះពុម្ពផ្សាយធំ**
**មជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងស៊ីវិល-យោធា**

**បោះពុម្ពដោយ**
**ហ្សឺណែវ ២០០៣**

មជ្ឈមណ្ឌលហ្សឺណែវ
សម្រាប់ការត្រួតពិនិត្យកងកម្លាំងប្រដាប់អាវុធ
តាមបែបប្រជាធិបតេយ្យ

សហភាពអន្តរសភា